# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ខុទ្ទកនិកាយ ចូឡនិទ្ទេស
# បឋមភាគ
# ៦៧



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ ក្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

## KHUDDAKANIKĀYA

## CŪḶANIDDESA

## PAṬHAMABHĀGA

## 67

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី**
**សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមវ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# សេចក្តីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

*ឧទាហរណ៍*

-ពាក្យខ្មែរៈ **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សន្លឹកប្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

សុត្តន្តបិដក

ខុទ្ទកនិកាយ ចូឡនិទ្ទេស

បឋមភាគ

៦៧

ព. ស. ២៥០៤

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស ចូឡនិទ្ទេសោ

# បឋមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បារាយនវគ្គោ

## វត្ថុគាថា

[១] កោសលានំ បុរា រម្មា អគមា ទក្ខិណាបថំ
អាកិញ្ចញ្ញំ បត្ថយានោ ព្រាហ្មណោ មន្តចារគូ ។
[២] សោ អស្សកស្ស វិសយេ មុឡកស្ស[១] សមាសនេ
វសី គោធាវរីកូលេ ឧញ្ឆេន ច ផលេន ច ។
[៣] តស្សេវ ឧបនិស្សាយ គាមោ ច វិបុលោ អហុ
តតោ ជាតេន អាយេន មហាយញ្ញំ អកប្បយិ ។
[៤] មហាយញ្ញំ យជិត្វាន បុន ចាវិសិ អស្សមំ
តស្មឹ បដិបវិដ្ឋម្ហិ អញ្ញោ អាគញ្ឆិ ព្រាហ្មណោ ។

---

១ ម. មឡកស្ស ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ចូឡនិទ្ទេស

# បឋមភាគ

---

*សូមនមស្ការ ចំពោះព្រះអរហន្ត សម្មាសម្ពុទ្ធព្រះអង្គនោះ ។*

## បារាយនវគ្គ

## វត្ថុគាថា

[១] *ពាវរីព្រាហ្មណ៍ អ្នកដល់ត្រើយនៃមន្ត ប្រាថ្នាសេចក្ដីមិនមានកង្វល់ ចេញចាកបុរីជាទីរីករាយ នៃពួកអ្នកដែនកោសល ទៅកាន់ទក្ខិណាបថជនបទ ។*

[២] *គាត់អាស្រ័យនៅ ទៀបច្រាំងស្ទឹងគោធាវរី ក្នុងទីព្រំដែនអស្សកៈ និងមុឡកៈ* (ចិញ្ចឹមជីវិត) *ដោយការស្វែងរកមើមនិងផលាផល ។*

[៣] *ស្រុកអាស្រ័យជិតស្ទឹងគោធាវរីនោះ ជាស្រុកសម្បូរ ព្រាហ្មណ៍ក៏បានបរិច្ចាគមហាយ័ញ្ញ ដោយសួយ ដែលកើតអំពីស្រុកនោះ ។*

[៤] *លុះពាវរីព្រាហ្មណ៍ បរិច្ចាគមហាយ័ញ្ញរួចហើយ ក៏ចូលមកកាន់អាស្រមវិញ កាលគាត់ត្រឡប់ចូលមកហើយ ព្រាហ្មណ៍ដទៃ បានមកដល់ដែរ ។*

២

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ចូឡនិទ្ទេសោ

[៥] ឧគ្ឃដ្ដចាទោ តសិតោ បង្កទន្តោ រជស្សិរោ
សោ ច នំ ឧបសង្កម្ម សតានិ បញ្ច យាចតិ ។

[៦] តមេនំ ពាវរី ទិស្វា អាសនេន និមន្តយិ
សុខញ្ច កុសលំ បុច្ឆិ ឥទំ វចនមព្រវិ ។

[៧] យំ ខោ មមំ ទេយ្យធម្មំ សព្វំ វិសជ្ជិតំ មយា
អនុជានាហិ មេ ព្រហ្មេ នត្ថិ បញ្ច សតានិ មេ ។

[៨] សចេ មេ យាចមានស្ស ភវំ នានុប្បទស្សតិ
សត្តមេ ទិវសេ តុយ្ហំ មុទ្ធា ផលតុ សត្តធា ។

[៩] អភិសង្ខរិត្វា កុហកោ ភេរវំ សោ អកិត្តយិ
តស្ស តំ វចនំ សុត្វា ពាវរី ទុក្ខិតោ អហុ ។

[១០] ឧស្សុស្សតិ អនាហារោ សោកសល្លសមប្បិតោ
អថោបិ ឯវំ ចិត្តស្ស ឈានេ ន[១] រមតី មនោ ។

---

១ ឱ. ម. ឈានេ ។

[៥] ព្រាហ្មណ៍នោះ មានជើងរឡើង សស្ងក់សស្ងើត មានធ្មេញព័ណ៌ភក់ ក្បាលប្រឡាក់ធូលី ចូលមករកពាវរីព្រាហ្មណ៍នោះ ហើយសូមទ្រព្យ ចំនួន ៥០០ ។

[៦] ពាវរីព្រាហ្មណ៍ លុះឃើញព្រាហ្មណ៍យាចកនោះហើយ ក៏អញ្ជើញដោយអាសនៈ ហើយសាកសួរសេចក្ដីសប្បាយស្រួល ទើបពោលនូវពាក្យនេះថា

[៧] ទេយ្យធម៌ណា ដែលខ្ញុំគប្បីឲ្យ ទេយ្យធម៌ទាំងអស់នោះ ខ្ញុំបរិច្ចាគអស់រលីងហើយ ម្នាលព្រាហ្មណ៍ អ្នកចូរអនុញ្ញាត ដល់ខ្ញុំផងចុះ ខ្ញុំមិនមានទ្រព្យ ៥០០ ទេ ។

[៨] (ព្រាហ្មណ៍យាចកពោលថា) អ្នកដ៏ចម្រើន កាលបើខ្ញុំសូម ប្រសិនបើ អ្នកដ៏ចម្រើន មិនឲ្យ សូមឲ្យក្បាលអ្នក បែកជា ៧ ភាគ ក្នុងថ្ងៃជាគម្រប់ ៧ ។

[៩] ព្រាហ្មណ៍ អ្នកកុហកនោះ បានក្លែងក្លាយ ពោលពាក្យគួរខ្លាច ពាវរីព្រាហ្មណ៍ បានឮពាក្យនៃព្រាហ្មណ៍នោះហើយ ក៏កើតទុក្ខ ។

[១០] គាត់អត់អាហារ ដោតដោយសរ គឺសោកក្រៀមក្រំ មួយទៀត កាលព្រាហ្មណ៍មានចិត្តយ៉ាងនេះហើយ ចិត្តក៏មិនរីករាយ ក្នុងការលះបង់[១] ។

---

១ បានដល់ចិត្តដែលមិនរីករាយ ក្នុងការចម្រើនឈាន ។ អដ្ឋកថា ។

៣

វត្ថុគាថា

[១១] ឧត្រស្តំ ឧក្ខិត្តំ ទិស្វា ទេវតា អត្ថកាមិនី
ពារី ឧបសង្កម្ម ឥទំ វចនមព្រវិ ។

[១២] ន សោ មុទ្ធំ បជានាតិ កុហកោ សោ ជដន្តិកោ
មុទ្ធនិ មុទ្ធាធិបាតេ វា ញាណំ តស្ស ន វិជ្ជតិ ។

[១៣] បហោតិ(១) ចរហិ ជានាតិ តម្មេ អក្ខាហិ បុច្ឆិតា
មុទ្ធំ មុទ្ធាធិបាតញ្ច តំ សុណោម វចោ តវ ។

[១៤] អហម្បេតំ ន ជានាមិ ញាណម្មេត្ថ ន វិជ្ជតិ
មុទ្ធំ មុទ្ធាធិបាតោ ច(២) ជិនានំ ហេតទស្សនំ(៣) ។

[១៥] អថ កោ ចរហិ ជានាតិ អស្មឹ បថវិមណ្ឌលេ
មុទ្ធំ មុទ្ធាធិបាតញ្ច តម្មេ អក្ខាហិ ទេវតេ ។

[១៦] បុរា កបិលវត្ថុម្ហា និក្ខន្តោ លោកនាយកោ
អបច្ចោ ឱក្កាករាជស្ស សក្យបុត្តោ បភង្ករោ ។

---

១ ឱ. ភោតិ ។ ម. ភោតិ ។ ២ ម. មុទ្ធាធិបាតេ ។ ៣ ម. ជិនានញ្ចេត្ថ ទស្សនំ ។

## វត្ថុគាថា

[១១] ទេវតា អ្នកប្រាថ្នាប្រយោជន៍ បានឃើញពាវរីព្រាហ្មណ៍ កំពុងមានសេចក្ដីតក់ស្លុត កើតទុក្ខ ទើបចូលទៅរក ពាវរីព្រាហ្មណ៍ ហើយពោលពាក្យនេះថា

[១២] (ព្រាហ្មណ៍នោះ) មិនដឹងប្រាកដនូវអំបែងក្បាល ព្រាហ្មណ៍នោះជាអ្នកកុហក ប្រាថ្នាទ្រព្យ ញាណសម្រាប់ដឹងនូវក្បាល ឬធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ របស់គាត់នោះ មិនមានទេ ។

[១៣] (ពាវរីព្រាហ្មណ៍សួរថា) នរណា អាចដឹងនូវក្បាល ដឹងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ខ្ញុំសួរហើយ អ្នកចូរប្រាប់ដំណើរនោះដល់ខ្ញុំ ខ្ញុំនឹងស្ដាប់ពាក្យរបស់អ្នកនោះ ។

[១៤] (ទេវតាតបថា) ខ្ញុំក៏មិនដឹងដំណើរនោះដែរ ការដឹងក្នុងដំណើរនុ៎ះរបស់ខ្ញុំមិនមានទេ លុះតែព្រះជិនៈ ទើបទ្រង់ជ្រាបនូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ។

[១៥] (ពាវរីព្រាហ្មណ៍សួរថា) លើប្រឹថពីមណ្ឌលនេះ តើនរណា ទើបដឹងនូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ម្នាលទេវតា អ្នកចូរប្រាប់បុគ្គលអ្នកដឹងនោះ ដល់ខ្ញុំ ។

[១៦] (ទេវតាតបថា) ព្រះលោកនាយក ជាពូជពង្សរបស់ព្រះបាទឱក្កាកៈ ជាសក្យបុត្រ ជាអ្នកធ្វើនូវពន្លឺ ព្រះអង្គស្ដេចចេញចាកកបិលវត្ថុបុរី (ទ្រង់ព្រះផ្នួស) ។

[១៧] សោ ហិ ព្រាហ្មណ សម្ពុទ្ធោ សព្វធម្មាន បារគូ
សព្វាភិញ្ញាពលប្បត្តោ សព្វធម្មេសុ ចក្ខុមា
សព្វធម្មក្ខយំ បត្តោ វិមុត្តោ ឧបធិក្ខយេ ។

[១៨] ពុទ្ធោ សោ ភគវា លោកេ ធម្មំ ទេសេតិ ចក្ខុមា
តំ ត្វំ គន្ត្វាន បុច្ឆស្សុ សោ តេ តំ ព្យាការិស្សតិ ។

[១៩] សម្ពុទ្ធោតិ វចោ សុត្វា ឧទគ្គោ ពាវរី អហុ
សោកស្ស តនុកោ អាសិ បីតិញ្ច វិបុលំ លភិ ។

[២០] សោ ពាវរី អត្តមនោ ឧទគ្គោ
តំ ទេវតំ បុច្ឆតិ វេទជាតោ
កតមម្ហិ គាមេ និគមម្ហិ វា បន
កតមម្ហិ វា ជនបទេ លោកនាថោ
យត្ថ គន្ត្វា នមស្សេមុ[១]
សម្ពុទ្ធំ ទិបទុត្តមំ ។

[២១] សាវត្ថិយំ កោសលមន្ទិរេ ជិនោ
បហូតបញ្ញោ វរភូរិមេធសោ
សោ សក្យបុត្តោ វិធុរោ អនាសវោ
មុទ្ធាធិបាតស្ស វិទូ នរាសភោ ។

---

១ ម. បស្សេមុ ។

[១៧] ម្នាលព្រាហ្មណ៍ ព្រះលោកនាយកនោះ ជាអ្នកត្រាស់ដឹង ដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ដល់ហើយនូវអភិញ្ញានិងពលៈសព្វគ្រប់ ប្រកបដោយសមន្តចក្ខុ ក្នុងធម៌ទាំងពួង ទ្រង់ដល់នូវធម៌ទាំងពួងជាទីអស់កិលេស ទ្រង់ផុតវិសេសហើយ និមិត្តធម៌ជាទីក្ស័យនៃឧបធិ ។

[១៨] ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាព្រះពុទ្ធ ក្នុងលោក មានបញ្ញាចក្ខុ តែងសម្ដែងធម៌ អ្នកចូរទៅក្រាបទូលសួរព្រះសម្ពុទ្ធអង្គនោះចុះ ទ្រង់នឹងព្យាករនូវធម៌នោះ ដល់អ្នក ។

[១៩] ពាវរីព្រាហ្មណ៍ ឮពាក្យថា សម្ពុទ្ធ ដូច្នេះហើយ ក៏មានចិត្តអណ្ដែតឡើង មានសោកស្រាល ទាំងបានបីតិដ៏ខ្លាំងក្លា ។

[២០] ពាវរីព្រាហ្មណ៍នោះ មានចិត្តត្រេកអរ មានចិត្តអណ្ដែតឡើង មានចិត្តរីករាយ សួរទេវតានោះថា ព្រះលោកនាថ ទ្រង់គង់នៅ ក្នុងស្រុកណា និគមណា ឬក្នុងជនបទណា យើងនឹងទៅនមស្ការព្រះសម្ពុទ្ធដ៏ឧត្តមជាងសត្វជើងពីរនោះក្នុងទីណា ។

[២១] (ទេវតាតបថា) ព្រះជិនៈ ទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថក្នុងកោសលមន្ទីរ ជិតក្រុងសាវត្ថី ទ្រង់មានបញ្ញាច្រើន មានបញ្ញា ដូចផែនដីដ៏ប្រសើរ ព្រះអង្គជាសក្យបុត្រ ទ្រង់មិនមានធុរៈ មិនមានអាសវៈ ជាឧត្តមបុរស ប្រសើរជាងជនជ្រាបច្បាស់នូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ។

៨

## វត្ថុគាថា

[២២] តតោ អាមន្តយី សិស្សេ ព្រាហ្មណោ មន្តបារគេ
ឯថ មាណវា អក្ខិស្សំ សុណោថ វចនំ មម ។

[២៣] យស្សេសោ ទុល្លភោ លោកេ បាតុភាវោ អភិណ្ហសោ
ស្វាជ្ជ លោកម្ហិ ឧប្បន្នោ សម្ពុទ្ធោ ឥតិ វិស្សុតោ
ខិប្បំ គន្ត្វាន សាវត្ថឹ បស្សវ្ហោ ទិបទុត្តមំ ។

[២៤] កថំ ចរហិ ជានេមុ ទិស្វា ពុទ្ធោតិ ព្រាហ្មណ
អជានតំ នោ បព្រូហិ យថា ជានេមុ តំ មយំ ។

[២៥] អាគតានិ ហិ មន្តេសុ មហាបុរិសលក្ខណា
ទ្វត្តឹសា ច ព្យាខ្យាតា[១] សមត្តា អនុបុព្វសោ ។

[២៦] យស្សេតេ ហោន្តិ គត្តេសុ មហាបុរិសលក្ខណា
ទុវេ វ[២] តស្ស គតិយោ តតិយា ហិ ន វិជ្ជតិ ។

---

១ ឱ. ម. ព្យាក្ខាតា ។ ២ ឱ. ម. ទ្វេយេវ ។

វត្ថុគាថា

[២២] លំដាប់នោះ ពាវរីព្រាហ្មណ៍ ហៅពួកព្រាហ្មណ៍ជាសិស្ស អ្នកដល់នូវត្រើយនៃមន្ត ថា ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយចូរមក យើងនឹងប្រាប់ អ្នកទាំងឡាយ ចូរស្តាប់ពាក្យរបស់យើង ។

[២៣]ការកើតប្រាកដរឿយៗ ក្នុងលោក នៃព្រះសម្ពុទ្ធអង្គណា ដែលរកកម្របាន ថ្ងៃនេះ ព្រះសម្ពុទ្ធជាម្ចាស់អង្គនោះ ទ្រង់កើតហើយក្នុងលោក គេដឹងឮល្បីល្បាញប្រាកដថា ព្រះអង្គត្រាស់ដឹងឯង អ្នកទាំងឡាយ ចូរប្រញាប់ទៅកាន់ក្រុងសាវត្ថី គាល់ព្រះអង្គទ្រង់ឧត្តមជាងសត្វជើងពីរនោះ ។

[២៤] (ព្រាហ្មណ៍ជាសិស្សច្បងសួរថា) បពិត្រព្រាហ្មណ៍ ធ្វើម្តេចយើងទាំងឡាយ ឃើញហើយ ទើបស្គាល់ថាជាព្រះពុទ្ធ សូមលោកប្រាប់ឧបាយ ជាហេតុឲ្យយើងស្គាល់ នូវព្រះសម្ពុទ្ធនោះ ដល់យើងទាំងឡាយ ដែលមិនធ្លាប់ស្គាល់ ។

[២៥] (ពាវរីព្រាហ្មណ៍តបថា) មហាបុរិសលក្ខណៈទាំងឡាយ ៣២ ប្រការ មានមកក្នុងមន្តទាំងឡាយ (ដែលពួកព្រាហ្មណាចារ្យ) ព្យាករគ្រប់គ្រាន់ហើយ តាមលំដាប់ ។

[២៦] មហាបុរិសលក្ខណៈទាំងនុ៎ះ រមែងមានក្នុងកាយរបស់មហាបុរសណា មហាបុរសនោះ មានគតិទៀងតែ ២ មិនមានគតិទៅជាគម្រប់បីទេ ។

[២៧] សចេ អគារំ អាវសតិ វិជេយ្យ បឋវឹ ឥមំ
អទណ្ឌេន អសត្ថេន ធម្មេនមនុសាសតិ ។
[២៨] សចេ ច សោ បព្វជតិ អគារា អនគារិយំ ។
វិវដច្ឆទោ សម្ពុទ្ធោ អរហា ភវតិ អនុត្តរោ ។
[២៩] ជាតឹ គោត្តញ្ច លក្ខណំ មន្តេ សិស្សេ បុនាបរេ
មុទ្ធំ មុទ្ធាធិបាតញ្ច មនសាយេវ បុច្ឆថ ។
[៣០] អនាវរណទស្សាវី យទិ ពុទ្ធោ ភវិស្សតិ
មនសា បុច្ឆិតេ បញ្ហេ វាចាយ វិសជ្ជេស្សតិ ។
[៣១] ពាវរិស្ស វចោ សុត្វា សិស្សា សោឡស ព្រាហ្មណា
អជិតោ តិស្សមេត្តេយ្យោ បុណ្ណកោ អថ មេត្តគូ
ធោតកោ ឧបសីវោ ច នន្ទោ ច អថ ហេមកោ
តោទេយ្យកប្បា ឧភយោ ជតុកណ្ណី ច បណ្ឌិតោ
ភទ្រាវុធោ ឧទយោ ច ចោសាលោចាបិ ព្រាហ្មណោ
មោឃរាជា ច មេធាវី បិង្គិយោ ច មហាឥសិ ។

[២៧] បើមហាបុរសនោះ នៅគ្រប់គ្រងផ្ទះ គប្បីឈ្នះប្រឹថពីមណ្ឌលនេះ ដោយមិនមានប្រើអាជ្ញា សស្ត្រាវុធ ទាំងគ្រប់គ្រងតាមច្បាប់ ។

[២៨] ប្រសិនបើ មហាបុរសនោះ (ចេញ) ចាកផ្ទះហើយ បួសក្នុងភេទនៃបុគ្គលមិនមានផ្ទះ នឹងបានជាព្រះពុទ្ធ មានដំបូលគឺកិលេសបើកហើយ ជាអរហន្ត ឥតមានបុគ្គលដទៃប្រសើរដូច ។

[២៩] អ្នកទាំងឡាយ ចូរសួរនូវជាតិ គោត្ត លក្ខណៈ មន្ត និងសិស្សទាំងឡាយដទៃទៀតផង នូវក្បាល និងជម់ធ្វើក្បាលឲ្យធ្លាក់ចុះផង ដោយចិត្តតែម្យ៉ាង ។

[៣០] ប្រសិនបើ ព្រះអង្គជាព្រះពុទ្ធ មានកិរិយាឃើញ ឥតមានអ្វីទើសទាល់ កាលបើអ្នកទាំងឡាយ សួរប្រស្នា ដោយចិត្តហើយ ទ្រង់នឹងវិសជ្ជនា ដោយវាចា ។

[៣១] លុះស្តាប់ពាក្យពាវរីព្រាហ្មណ៍ហើយ ព្រាហ្មណ៍ជាសិស្ស ១៦ នាក់គឺ អជិតៈ ១ តិស្សមេត្តេយ្យៈ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ តោទេយ្យៈ ១ កប្បៈ ១ ជតុកណ្ណីបណ្ឌិត ១ ភទ្រាវុធ ១ ឧទយៈ ១ បោសាលព្រាហ្មណ៍ ១ មោឃរាជមេធាវី ១ បិង្គិយមហាឫសី ១ ។

## ៧

### វត្ថុគាថា

[៣២] បច្ចេកគណិនោ សព្វេ  សព្វលោកស្ស វិស្សុតា
ឈាយី ឈានរតា ធីរា  បុព្វាសនវាសិតា ។

[៣៣] ពាវរី អភិវាទេត្វា  កត្វា ច នំ បទក្ខិណំ
ជដាជិនធរា សព្វេ  បក្កាមុំ ឧត្តរាមុខា ។

[៣៤] មុឡ្ហកស្ស បតិដ្ឋានំ  បុរិមំ(១) មាហិស្សតី តទា
ឧជ្ជេនិញ្ចាបិ គោនទ្ធំ  វេទិសំ វនសវ្ហយំ
កោសម្ពិញ្ចាបិ សាកេតំ  សាវត្ថិញ្ច បុរុត្តមំ
សេតព្យំ កបិលវត្ថុំ  កុសិនារញ្ច មន្ទិរំ
បាវញ្ច ភោគនគរំ  វេសាលឹ មាគធំ បុរំ
បាសាណកំ ចេតិយញ្ច  រមណីយំ មនោរមំ ។

[៣៥] តសិតោ វុទកំ សីតំ  មហាលាភំវ វាណិជោ
ឆាយំ ឃម្មាភិតត្តោវ  តុរិតា បព្វតមារុហុំ

[៣៦] ភគវា ច តម្ហិ សមយេ  ភិក្ខុសង្ឃបុរក្ខតោ
ភិក្ខូនំ ធម្មំ ទេសេតិ  សីហោវ នទតី វនេ ។

---

១ បុរន្តិ បាឋោ ទិស្សតិ អដ្ឋកថាយំ ។

វត្ថុគាថា

[៣២] អ្នកទាំងអស់គ្នា ជាគណាចារ្យមួយៗ ល្បីទួទៅពេញលោកថា ជាអ្នកមានឈាន ត្រេកអរក្នុងឈាន ជាអ្នកប្រាជ្ញ សឹងមានវាសនាអប់រំមកហើយ ក្នុងបុព្វជាតិ ។

[៣៣] (ព្រាហ្មណ៍ទាំងនោះ) ក៏ក្រាបអភិវាទ ធ្វើប្រទក្សិណា នូវពាវរីព្រាហ្មណ៍នោះ ទាំងអស់គ្នា ជាអ្នកមានជដា ទ្រទ្រង់អជិនចម្មាភរណៈ មានមុខឆ្ពោះទៅកាន់ឧត្តរទិស ដើរចេញទៅ ។

[៣៤]ក្នុងកាលនោះ តាបសទាំងនោះ ទៅកាន់ក្រុងឈ្មោះ មហិស្សតី ជាទីប្រតិស្ឋាននៃដែនមុឡ្ហកៈ ១ ក្រុងឧជ្ជេនី ១ ក្រុងគោនទ្ធៈ ១ ព្រៃវេទិសៈ ១ ក្រុងកោសម្ពី ១ ក្រុងសាកេត ១ ក្រុងសាវត្ថីដ៏ឧត្តម ១ ក្រុងសេតព្យៈ ១ ក្រុងកបិលវត្ថុ ១ ក្រុងកុសិនារា ១ ក្រុងបាវា ១ ភោគនគរ ១ ក្រុងវេសាលី ១ ក្រុងក្នុងដែនមគធៈ ១ និងបាសាណកចេតិយស្ថាន ជាទីត្រេកអរ រីករាយចិត្ត ១ ។

[៣៥] (ពួកព្រាហ្មណ៍ទាំងនោះ) នាំគ្នាឡើងកាន់ភ្នំ ប្រញាប់ប្រញាល់ ដូចជាបុគ្គលស្រេក បានទឹកត្រជាក់ ដូចជាពាណិជ បានលាភធំ ឬ ដូចជាបុគ្គលដែលត្រូវក្តៅ បានម្លប់ ។

[៣៦] សម័យនោះ ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម កំពុងសម្តែងធម៌ដល់ពួកភិក្ខុ ដូចសីហៈកំពុងបន្លឺ ក្នុងព្រៃ ។

[៣៧] អជិតោ អទ្ទស សម្ពុទ្ធំ វីតរំសីវ ភាណុមំ
ចន្ទំ យថា បណ្ណរសេ បារិបូរឹ ឧបាគតំ ។

[៣៨] អថស្ស គត្តេ ទិស្វាន បរិបូរញ្ច ព្យញ្ជនំ
ឯកមន្តំ ឋិតោ ហដ្ឋោ មនោបញ្ហេ អបុច្ឆថ

[៣៩] អាទិស្ស ជម្មនំ ព្រូហិ គោត្តំ ព្រូហិ សលក្ខណំ
មន្តេសុ បារមឹ ព្រូហិ កតិ វាចេតិ ព្រាហ្មណោ ។

[៤០] វីសំ វស្សសតំ អាយុ សោ ច គោត្តេន ពាវរី
តិណាស្ស លក្ខណាគត្តេ តិណ្ណំ វេទាន បារគូ

[៤១] លក្ខណេ ឥតិហាសេ ច សនិឃណ្ឌុ សកេដុភេ
បញ្ចសតានិ វាចេតិ សធម្មេ បារមឹ គតោ ។

[៤២] លក្ខណានំ បវិចយំ ពាវរិស្ស នរុត្តម
តណ្ហាច្ឆិទ[១] បកាសេហិ មា នោ កង្ខាយិតំ អហុ ។

---

១ ម. តណ្ហាច្ឆិទំ ។

[៣៧] អជិតមាណព បានឃើញព្រះសម្ពុទ្ធ ហាក់ដូចព្រះអាទិត្យកំពុងផ្សាយចេញនូវរស្មី ពុំនោះសោត ដូចព្រះចន្ទពេញវង់ រះឡើងក្នុងថ្ងៃពេញបូណ៌មី ។

[៣៨] លុះអជិតមាណព ឃើញព្រះកាយ របស់ព្រះសម្ពុទ្ធ ដ៏បរិបូណ៌ដោយព្យញ្ជនៈ ក៏មានចិត្តរីករាយ ឋិតនៅក្នុងទីសមគួរ ហើយសួរបញ្ហា ដោយចិត្តនឹកថា

[៣៩] សូមព្រះអង្គ ទ្រង់សម្តែងអាង នូវចំណាស់ សម្តែងនូវគោត្ត ព្រមទាំងលក្ខណៈ សម្តែងនូវសេចក្តីសម្រេច ក្នុងមន្តទាំងឡាយ តើព្រាហ្មណ៍ (ជាអាចារ្យរបស់ខ្ញុំព្រះអង្គ) បង្រៀនសិស្សប៉ុន្មាន ។

[៤០] (ព្រះមានព្រះភាគត្រាស់ថា) ព្រាហ្មណ៍ ជាអាចារ្យរបស់អ្នកនោះ ឈ្មោះពាវរី ដោយគោត្ត មានអាយុ ១២០ វស្សា កាយរបស់គាត់មានលក្ខណៈ ៣ យ៉ាង អ្នកដល់នូវត្រើយនៃវេទទាំងបី ។

[៤១] គាត់បង្រៀនលក្ខណៈ និងឥតិហាសសាស្ត្រ ព្រមទាំងនិឃណ្ឌុ-សាស្ត្រ និងកេដុភសាស្ត្រ ដល់សិស្ស ៥០០ នាក់ ដល់នូវការសម្រេច ក្នុងធម៌របស់ខ្លួន ។

[៤២] (អជិតមាណពទូលសួរថា) បពិត្រព្រះអង្គឧត្តមជាងជន ជាអ្នកផ្តាច់បង់នូវតណ្ហា សូមព្រះអង្គ ជ្រើសរើសលក្ខណៈទាំងឡាយរបស់ពាវរីព្រាហ្មណ៍ហើយប្រកាស កុំឲ្យយើងខ្ញុំសង្ស័យឡើយ ។

៩

## វត្ថុគាថា

[៤៣] មុខំ និជ្ឈាយ ឆាទេតិ ឧណ្ណាស្ស ភមុកន្តរេ
កោសោហិតំ វត្ថុគុយ្ហំ ឯវំ ជានាហិ មាណវ ។

[៤៤] បុច្ឆំ ហិ កញ្ចិ អសុណន្តោ សុត្វា បញ្ហេ វិយាកតេ
វិចិន្តេតិ ជនោ សព្វោ វេទជាតោ កតញ្ជលិ

[៤៥] កោ នុ ទេវោ ព្រហ្មា វា ឥន្ទោ វាបិ សុជម្បតិ
មនសា បុច្ឆិតេ បញ្ហេ កមេតំ បដិភាសតិ ។

[៤៦] មុទ្ធំ មុទ្ធាធិបាតញ្ច ពាវរី បរិបុច្ឆតិ
តំ ព្យាករោហិ ភគវា កង្ខំ វិនយ នោ ឥសេ ។

[៤៧] អវិជ្ជា មុទ្ធាតិ ជានាហិ វិជ្ជា មុទ្ធាធិបាតិនី
សទ្ធាសតិសមាធីហិ ឆន្ទវីរិយេន សំយុតា ។

[៤៨] តតោ វេទេន មហតា សន្ថម្ភិត្វាន មាណវោ
ឯកំសំ អជិនំ កត្វា បាទេសុ សិរសា បតិ

## វត្ថុគាថា

[៤៣](ព្រះមានព្រះភាគត្រាស់ថា) ពាវរីព្រាហ្មណ៍បិទបាំងមុខ ដោយជិវ្ហាបាន មានឧណ្ណាលោម ត្រង់ចន្លោះចិញ្ចើម មានវត្ថុគុយ្ហៈនៅក្នុងស្រោម ម្នាលមាណព អ្នកចូរដឹងយ៉ាងនេះចុះ ។

[៤៤] ពួកជនទាំងពួង មិនឮនូវការសួរនីមួយសោះ លុះឮបញ្ហាដែលព្រះមានព្រះភាគព្យាករហើយ ក៏កើតសេចក្ដីរីករាយ ប្រណម្យអញ្ជលី គិតផ្សេង ៗ ថា

[៤៥] នរណាហ្ន៎ ជាទេវតា ឬជាព្រហ្ម ឬជាព្រះឥន្ទ្រឈ្មោះសុជម្បតិ កាលបើគេសួរប្រស្នាដោយចិត្ត ម្ដេចក៏ទ្រង់ឆ្លើយតបប្រស្នានោះបាន ។

[៤៦] (អជិតមាណព ទូលសួរដោយចិត្តតទៅទៀតថា) បពិត្រព្រះមានព្រះភាគ ពាវរីព្រាហ្មណ៍សួរនូវក្បាល និងធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ សូមព្រះអង្គព្យាករប្រស្នានោះ បពិត្រព្រះអង្គជាឥសី សូមព្រះអង្គកម្ចាត់បង់នូវកង្ខារបស់យើងទាំងឡាយ ។

[៤៧](ព្រះមានព្រះភាគត្រាស់ថា) អ្នកចូរដឹងថា អវិជ្ជា ជាក្បាល វិជ្ជាដែលប្រកបដោយ សទ្ធា សតិ សមាធិ ឆន្ទៈ វីរិយៈ ជាធម៌ធ្វើក្បាលឲ្យធ្លាក់ចុះ ។

[៤៨] លំដាប់នោះ (អជិតមាណព) មានបីតិ មានកម្លាំងក្លាខ្លាំងកើតហើយ ទើបធ្វើអជិនចម្មាករណៈ ឆៀងស្មាម្ខាង ក្រាបទៀបព្រះបាទដោយសិរសា ទូលថា

[៤៩] ពាវរី ព្រាហ្មណោ ភោតោ សហ សិស្សេហិ មារិស

ឧទគ្គចិត្តោ សុមនោ ចាទេ វន្ទតិ ចក្ខុម ។

[៥០] សុខិតោ ពាវរី ហោតុ សហ សិស្សេហិ ព្រាហ្មណោ

ត្វញ្ចាបិ សុខិតោ ហោហិ ចិរំ ជីវាហិ មាណវ ។

[៥១] ពាវរិស្ស ច តុយ្ហំ វា សព្វេសំ សព្វសំសយំ

កតាវកាសា បុច្ឆវ្ហោ យង្កិញ្ចិ មនសិច្ឆថ ។

[៥២] សម្ពុទ្ធេន កតោកាសោ និសីទិត្វាន បញ្ជលិ

អជិតោ បឋមំ បញ្ហំ តត្ថ បុច្ឆិ តថាគតំ ។

វត្ថុគាថា និដ្ឋិតា ។

[៤៩] បពិត្រព្រះអង្គទ្រង់និរទុក្ខមានចក្ខុ ពាវរីព្រាហ្មណ៍ ព្រមទាំងពួកសិស្ស មានចិត្តរីករាយសោមនស្ស ថ្វាយបង្គំព្រះបាទ នៃព្រះអង្គដ៏ចម្រើន ។

[៥០] (ព្រះមានព្រះភាគ ត្រាស់តបថា) ពាវរីព្រាហ្មណ៍ ព្រមទាំងពួកសិស្ស ចូរបានសុខ ម្នាលមាណព ទាំងអ្នកក៏ចូរបានសុខ ចូរមានជន្មាយុយឺនយូរ ។

[៥១] អ្នកទាំងឡាយ តថាគតបើកឱកាសឲ្យហើយ ប្រាថ្នាក្នុងចិត្ត (ដើម្បីសួរ) នូវប្រស្នាណាមួយ ចូរសួរមកចុះ ដើម្បីកម្ចាត់បង់សេចក្តីសង្ស័យគ្រប់ប្រការ របស់ពាវរីព្រាហ្មណ៍ផង របស់អ្នកផង ទាំងអស់គ្នា ។

[៥២] អជិតមាណព ដែលព្រះសម្ពុទ្ធទ្រង់បើកឱកាសឲ្យហើយ ក៏អង្គុយប្រណម្យអញ្ជលី សួរប្រស្នាជាបឋម ចំពោះព្រះតថាគត ក្នុងបាសាណកចេតិយនោះ ។

ចប់ វត្ថុគាថា ។

# អជិតមាណវកប្បញ្ហានិទ្ទេសោ

[៨៣] កេនស្សុ និវុតោ លោកោ (ឥច្ចាយស្មា អជិតោ)
កេនស្សុ នប្បកាសតិ
កិស្សាភិលេបនំ ព្រូហិ[១]
កឹសុ តស្ស មហព្ភយំ ។

[៨៤] កេនស្សុ[២] និវុតោ លោកោតិ និរយ-លោកោ តិរច្ឆានលោកោ បិត្តិវិសយលោកោ មនុស្សលោកោ ទេវលោកោ ខន្ធលោកោ ធាតុ-លោកោ អាយតនលោកោ អយំ លោកោ បរោ លោកោ ព្រហ្មលោកោ សទេវលោកោ អយំ វុច្ចតិ លោកោ ។ អយំ លោកោ កេន អាវុតោ និវុតោ ឱផុដោ បិហិតោ បដិច្ឆន្នោ បដិកុជ្ជិតោតិ កេនស្សុ និវុតោ លោកោ ។

[៨៥] ឥច្ចាយស្មា អជិតោតិ ឥច្ចាតិ បទសន្ធិ បទសំ-សគ្គោ បទចារិបូរិ អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ គរុ-វចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។

១ ឱ. ម. ព្រូសិ ។ ២ ឱ. ម. ឥមេ បាឋា កេនស្សុ និវុតោត្យាទិកា នត្ថិ ។

# អជិតមាណវកបញ្ហានិទ្ទេស

[៨៣] (អជិតមាណព មានអាយុ សួរដូច្នេះថា)

លោក ត្រូវអ្វី បិទបាំង

លោក មិនភ្លឺស្វាង ព្រោះហេតុអ្វី

សូមព្រះអង្គត្រាស់ប្រាប់នូវធម៌អ្វី ថាជាគ្រឿងលាប

លោកនោះ អ្វីជាភ័យធំ របស់លោកនោះ ។

[៨៤] ពាក្យថា លោក ត្រូវអ្វីបិទបាំង សេចក្តីថា និរយលោក តិរច្ឆានលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកខាងមុខ ព្រហ្មលោក ព្រមទាំងទេវលោក នេះហៅថា លោក ។ លោកនេះ ត្រូវអ្វីបិទបាំង បិទទាំងខាងក្រោម បិទទាំងខាងលើ បិទភ្ជិត គ្រប ហេតុនោះ (លោកសួរថា) លោក ត្រូវអ្វីបិទបាំង ។

[៨៥] ពាក្យថា ដូច្នេះ នៃពាក្យថា អជិតៈ មានអាយុ សួរ ដូច្នេះ គឺជាពាក្យតបទ ជាពាក្យភ្ជាប់បទ ជាពាក្យបំពេញបទ ជាទីប្រជុំនៃអក្ខរៈ ជាសេចក្តីពីរោះដោយព្យញ្ជនៈ ពាក្យថា ដូច្នេះ នុ៎ះ ជាលំដាប់នៃបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នុ៎ះ ជាពាក្យពោលដោយគោរព កោតក្រែង ។

អជិតោតិ តស្ស ព្រាហ្មណស្ស នាមំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោតិ ឥច្ចាយស្មា អជិតោ ។

[៤៦] កេនស្សុ នប្បកាសតីតិ កេន លោកោ នប្បកាសតិ ន ភាសតិ ន តបតិ ន វិរោចតិ ន សញ្ញាយតិ ន បញ្ញាយតីតិ កេនស្សុ នប្បកាសតិ ។

[៤៧] កិស្សាភិលេបនំ ព្រូសីតិ កឹ អស្ស លោកស្ស អភិលេបនំ លគ្គនំ ពន្ធនំ ឧបក្កិលេសោ កេន លោកោ លិត្តោ បលិត្តោ កិលិដ្ឋោ សង្កិលិដ្ឋោ មក្ខិតោ សំសដ្ឋោ លគ្គោ លគ្គិតោ បលិពុទ្ធោ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ កិស្សាភិលេបនំ ព្រូហិ ។

[៤៨] កឹសុ តស្ស មហព្ភយន្តិ កឹ តស្ស លោកស្ស មហព្ភយំ បីឡនំ ឃដ្ដនំ ឧបទ្ទវោ ឧបសគ្គោតិ កឹសុ តស្ស មហព្ភយំ ។ តេនាហ សោ ព្រាហ្មណោ

ពាក្យថា អជិត: គឺជានាម ជាសង្ខា ជាឈ្មោះ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមធេយ្យ ជាភាសា ជាព្យញ្ជនៈ ជាពាក្យហៅ របស់ព្រាហ្មណ៍នោះ ហេតុនោះ មានពាក្យថា អជិតមាណពមានអាយុ សួរ ដូច្នេះ ។

[៥៦] ពាក្យថា លោកមិនភ្លឺស្វាងព្រោះហេតុអ្វី គឺលោកមិនភ្លឺស្វាង មិនមានរស្មី មិនមានពន្លឺ មិនរុងរឿង មិនយល់ច្បាស់ មិនប្រាកដ ព្រោះហេតុអ្វី ហេតុនោះ លោកសួរថា លោកមិនភ្លឺស្វាងព្រោះហេតុអ្វី ។

[៥៧] ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ នូវធម៌អ្វីជាគ្រឿងលាបលោកនោះ គឺអ្វីជាគ្រឿងលាប ជាគ្រឿងចំពាក់ ជាគ្រឿងចង ជាឧបក្កិ-លេស របស់លោកនោះ លោក ត្រូវអ្វីលាប ស្រឡាប ធ្វើឲ្យសៅហ្មង ឲ្យសៅហ្មងព្រម ឲ្យប្រឡាក់ ឲ្យប្រឡាំព្រម ឲ្យជាប់ ឲ្យចំពាក់ ឲ្យជាប់ស្អិត សូមព្រះអង្គត្រាស់ប្រាប់ សម្តែងបញ្ញត្ត តាំងទុក បើក ចែក រំលែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ សូមព្រះអង្គត្រាស់ប្រាប់នូវអ្វី ជាគ្រឿងលាបលោកនោះ ។

[៥៨] ពាក្យថា អ្វីជាភ័យធំ របស់លោកនោះ គឺអ្វីជាភ័យធំ ជាគ្រឿងបៀតបៀន ជាគ្រឿងគាប ជាឧបទ្រព ជាឧបស័គ្គ របស់លោកនោះ ហេតុនោះ លោកសួរថា អ្វីជាភ័យធំ របស់លោកនោះ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលហើយថា

១៣

អជិតមាណវកប្បញ្ហានិទ្ទេសោ

កេនស្សុ និវុតោ លោកោ (ឥច្ចាយស្មា អជិតោ)

កេនស្សុ នប្បកាសតិ

កិស្សាភិលេបនំ ព្រូហិ

កឹសុ តស្ស មហព្ភយន្តិ ។

[៥៩] អវិជ្ជាយ និវុតោ លោកោ (អជិតាតិ ភគវា)

វេវិច្ឆា (បមាទា) នប្បកាសតិ

ជប្បាភិលេបនំ ព្រូមិ

ទុក្ខមស្ស មហព្ភយំ ។

[៦០] អវិជ្ជាយ និវុតោ លោកោតិ អវិជ្ជាតិ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញា-ណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ

លោក ត្រូវអ្វី បិទបាំង

លោក មិនភ្លឺស្វាង ព្រោះហេតុអ្វី

សូមព្រះអង្គត្រាស់ប្រាប់នូវធម៌អ្វី ជាគ្រឿងលាប

លោកនោះ អ្វីជាភ័យធំ របស់លោកនោះ ។

[៥៩] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអជិតៈ)

លោកត្រូវអវិជ្ជាបិទបាំង លោក មិនភ្លឺស្វាង

ព្រោះសេចក្តីប្រាថ្នាផ្សេងៗ (និងសេចក្តីប្រ-

ហែស) តថាគពោលនូវសេចក្តីប្រាថ្នា ថាជា

គ្រឿងលាប ទុក្ខជាភ័យធំ របស់លោកនោះ ។

[៦០] អធិប្បាយពាក្យថា លោក ត្រូវអវិជ្ជាបិទបាំង ត្រង់ពាក្យថាអវិជ្ជា បានន័យថា សេចក្តីមិនដឹងក្នុងទុក្ខ សេចក្តីមិនដឹងក្នុងតណ្ហា ជាហេតុឲ្យកើតទុក្ខ សេចក្តីមិនដឹងក្នុងកិរិយារលត់ទុក្ខ សេចក្តីមិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ សេចក្តីមិនដឹងក្នុងទីបំផុតខាងដើម សេចក្តីមិនដឹងក្នុងទីបំផុតខាងចុង សេចក្តីមិនដឹងក្នុងទីបំផុតខាងដើម និងទីបំផុតខាងចុង សេចក្តីមិនដឹងក្នុងធម៌ដែលកើតឡើងហើយ អាស្រ័យធម៌នេះជាបច្ច័យ

យំ ឯវរូបំ អញ្ញាណំ អទស្សនំ អនភិសមយោ អននុពោធោ អសម្ពោធោ អប្បដិវេធោ អសង្គាហនា អបរិយោគាហនា អសមបេក្ខនា អប្បច្ចវេក្ខនា អប្បច្ចក្ខកម្មំ ទុម្មេជ្ឈំ ពាល្យំ អសម្បជញ្ញំ បមោហោ សម្មោហោ អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាជាលំ មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជា ។ លោកោតិ និរយលោកោ តិរច្ឆានលោកោ បិត្តិវិសយលោកោ មនុស្សលោកោ ទេវលោកោ ខន្ធលោកោ ធាតុលោកោ អាយតនលោកោ អយំ លោកោ បរោ លោកោ ព្រហ្មលោកោ សទេវលោកោ អយំ វុច្ចតិ លោកោ ។ ឥមាយ អវិជ្ជាយ អាវុតោ និវុតោ ឱផុដោ បិហិតោ បដិច្ឆន្នោ បដិកុជ្ជិតោតិ អវិជ្ជាយ និវុតោ លោកោ ។

[៦១] អជិតាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ អបិច ភគ្គរាគោតិ ភគវា ។ ភគ្គទោសោតិ ភគវា ។

កិរិយាមិនដឹង ការមិនឃើញ ការមិនត្រាស់ដឹង ការមិនត្រាស់ដឹងតាម ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនចុះចិត្ត ការមិនចុះចិត្តស៊ប់ ការមិនមានការរំពៃ ការមិនមានការពិចារណា ការមិនមានការយល់ច្បាស់ ការយល់បានដោយក្រ ភាពជាពាល ភាពមិនមានសម្បជញ្ញៈ សេចក្ដីវង្វេងទូទៅ សេចក្ដីវង្វេងព្រម ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា ការស្ទាក់ដំណើរគឺអវិជ្ជា បណ្ដាញគឺអវិជ្ជា មោហៈ អកុសលមូល ណា មានសភាពយ៉ាងនេះ នេះហៅថា អវិជ្ជា ។ ពាក្យថា លោក គឺនិរយលោក តិរច្ឆានលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកខាងមុខ ព្រហ្មលោក ព្រមទាំងទេវលោក នេះហៅថា លោក ។ លោក ត្រូវអវិជ្ជានេះ បិទបាំង បិទ បិទខាងក្រោម បិទខាងលើ បិទភ្ជិត គ្រប ហេតុនោះ (ទ្រង់ត្រាស់ថា) លោកត្រូវអវិជ្ជាបិទបាំង ។

[៦១] ពាក្យថា អជិតៈ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅ នូវព្រាហ្មណ៍នោះចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។ មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់រាគៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់ទោសៈ ។

១៨

## អជិតមាណវកប្បញ្ហានិទ្ទេសោ

ភគ្គមោហោតិ ភគវា ។ ភគ្គមានោតិ ភគវា ។ ភគ្គទិដ្ឋីតិ ភគវា ។ ភគ្គកណ្ដកោតិ ភគវា ។ ភគ្គកិលេសោតិ ភគវា ។ ភជិ វិភជិ បដិវិភជិ ធម្មរតនន្តិ ភគវា ។ ភវានំ អន្តករោតិ ភគវា ។ ភាវិតកាយោតិ ភគវា ។ ភាវិតសីលោតិ ភាវិតចិត្តោតិ ភាវិតប្បញ្ញោតិ ភគវា ។ ភជិ វា ភគវា អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានីតិ ភគវា ។ ភាគី វា ភគវា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ភគវា ។ ភាគី វា ភគវា អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស អធិសីលស្ស អធិចិត្តស្ស អធិប្បញ្ញាយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ ឈានានំ ចតុន្នំ អប្បមញ្ញានំ ចតុន្នំ អរូបសមាបត្តីនន្តិ ភគវា ។

ព្រះនាមថាព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់មោហៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់មានះ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់ទិដ្ឋិ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់បន្ទាគឺកាម ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់បំបាក់បង់កិលេស ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់ចែកបែងរំលែកនូវធម្មរតនៈ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់ធ្វើនូវទីបំផុតភព ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់មានកាយចម្រើន ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះទ្រង់មានសីលចម្រើន ព្រោះទ្រង់មានចិត្តចម្រើន ព្រោះទ្រង់មានបញ្ញាចម្រើន ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់គប់រកសេនាសនៈដ៏ស្ងាត់ ដែលតាំងនៅក្នុងព្រៃតូចព្រៃធំ មិនមានសូរសព្ទ មិនមានគឹកកង ជាទីប្រាសចាកខ្យល់ដែលកើតអំពីសរីរៈនៃមនុស្ស គួរជាទីកំបាំងនៃមនុស្ស គួរដល់កិរិយាសម្ងំនៅ ។ មួយទៀត ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យទ្រង់មានភាគនៃចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារគឺថ្នាំកែរោគ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត និងអធិប្បញ្ញា ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យមានភាគនៃឈាន៤ អប្បមញ្ញា៤ និងអរូបសមាបត្តិ៤ ។

ភាគី វា ភគវា អដ្ឋន្នំ វិមោក្ខានំ អដ្ឋន្នំ អភិភាយតនានំ នវន្នំ អនុបុព្វវិហារសមាបត្តីនន្តិ ភគវា ។ ភាគី វា ភគវា ទសន្នំ សញ្ញាភាវនានំ ទសន្នំ កសិណសមាបត្តីនំ អានាបានស្សតិសមាធិស្ស អសុភសមាបត្តិយាតិ ភគវា ។ ភាគី វា ភគវា ចតុន្នំ សតិប្បដ្ឋានានំ ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្សាតិ ភគវា ។ ភាគី វា ភគវា ទសន្នំ តថាគតពលានំ ចតុន្នំ វេសារជ្ជានំ ចតុន្នំ បដិសម្ភិទានំ ឆន្នំ អភិញ្ញានំ ឆន្នំ ពុទ្ធធម្មានន្តិ ភគវា ។ ភគវាតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ អជិតាតិ ភគវា ។

ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃវិមោក្ខ ៨ អភិភាយតនៈ ៨ និងអនុបុព្វវិហារសមាបត្តិ ៩ ។ ព្រះនាមថាព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃសញ្ញាភាវនា ១០ កសិណសមាបត្តិ ១០ អានាបានស្សតិសមាធិ និងអសុភសមាបត្តិ ។ ព្រះនាមថា មានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ព្រះនាមថា ព្រះមានព្រះភាគ ព្រោះព្រះមានបុណ្យ ទ្រង់មានភាគនៃតថាគតពល ១០ វេសារជ្ជៈ ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ និងពុទ្ធធម៌ ៦ ។ ពាក្យថា ព្រះមានព្រះភាគនេះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនមិត្តនិងអាមាត្យថ្វាយ មិនមែនញាតិសាលោហិតថ្វាយ មិនមែនសមណៈនិងព្រាហ្មណ៍ថ្វាយ មិនមែនទេវតាទាំងឡាយថ្វាយទេ ពាក្យថា ព្រះមានព្រះភាគនុ៎ះ កើតក្នុងទីបំផុតវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានភាគ ។ បញ្ញត្តិថា ព្រះមានព្រះភាគនេះ (កើតហើយ) ដោយកិរិយាធ្វើឲ្យជាក់ច្បាស់ ព្រមទាំងការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ ទើបមានពាក្យថា ព្រះមានព្រះភាគត្រាស់ថា ម្នាលអជិតៈ ។

## អជិតមាណវកបញ្ញានិទ្ទេសោ

[៦២] វេវិច្ឆា (បមាទា) នប្បកាសតីតិ វេវិច្ឆំ វុច្ចតិ បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ កុលមច្ឆរិយំ លាភមច្ឆរិយំ វណ្ណមច្ឆរិយំ ធម្មមច្ឆរិយំ ។ យំ ឯវរូបំ មច្ឆរិយំ មច្ឆរាយនា មច្ឆរាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា អគ្គហិតត្តំ ចិត្តស្ស ឥទំ វុច្ចតិ មច្ឆរិយំ ។ អបិច ខន្ធមច្ឆរិយំបិ មច្ឆរិយំ ធាតុមច្ឆរិយំបិ មច្ឆរិយំ អាយតនមច្ឆរិយំបិ មច្ឆរិយំ គាហោ វុច្ចតិ មច្ឆរិយំ ។ បមាទោ វត្តព្វោ កាយទុច្ចរិតេ វា វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ វា កាមគុណេសុ ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ វា កុសលានំ វា ធម្មានំ ភាវនាយ អសក្កច្ចកិរិយតា អសាតច្ចកិរិយតា អនដ្ឋិតតា ឱលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ បមាទោ យោ ឯវរូបោ បមាទោ បមជ្ជនា បមជ្ជិតត្តំ អយំ វុច្ចតិ បមាទោ ។

អជិតមាណវកប្បញ្ហានិទ្ទេស

[៦២] ពាក្យថា លោក មិនភ្ជាប់ស្អាងព្រោះសេចក្ដីប្រាថ្នាផ្សេងៗ(និងសេចក្ដីប្រហែស) អធិប្បាយថា សេចក្ដីកំណាញ់ ៥ គឺ កំណាញ់អាវាស កំណាញ់ត្រកូល កំណាញ់លាភ កំណាញ់វណ្ណៈ កំណាញ់ធម៌ ហៅថា សេចក្ដីប្រាថ្នាផ្សេងៗ ។ សេចក្ដីកំណាញ់ អាការនៃសេចក្ដីកំណាញ់ ភាពនៃសេចក្ដីកំណាញ់ សេចក្ដីកំណាញ់ផ្សេងៗ សេចក្ដីកំណាញ់រឹង ភាពនៃសេចក្ដីកំណាញ់ក្ដៅ ភាពនៃចិត្តហួងហែងមាំ ណា មានសភាពយ៉ាងនេះ នេះហៅថា សេចក្ដីកំណាញ់ ។ មួយទៀត សេចក្ដីកំណាញ់ខន្ធ ហៅថា កំណាញ់ សេចក្ដីកំណាញ់ធាតុ ហៅថា កំណាញ់ សេចក្ដីកំណាញ់អាយតនៈ ហៅថា កំណាញ់ សេចក្ដីកាន់ (ក្ដាប់ទុក) ហៅថា កំណាញ់ ។ សេចក្ដីប្រហែស ខ្ញុំគប្បីពោលដូចតទៅនេះ ការបណ្ដោតបណ្ដោយចិត្ត ការឲ្យកម្លាំងដល់ការបណ្ដោតបណ្ដោយចិត្ត ទៅក្នុងកាយទុច្ចរិតក្ដី ក្នុងវចីទុច្ចរិតក្ដី ក្នុងមនោទុច្ចរិតក្ដី ក្នុងកាមគុណប្រាំក្ដី ឬភាពនៃការធ្វើមិនគោរព ភាពនៃកិរិយាមិនធ្វើព្យាយាមរឿយៗ ភាពនៃចិត្តមិនតាំងនៅមាំ ភាពនៃចិត្តប្រព្រឹត្តរួញរា ភាពនៃសេចក្ដីប្រាថ្នាដាក់ចុះ ភាពនៃធុរៈដាក់ចុះ ការមិនសេព ការមិនចម្រើន អំពើមិនសន្សំរឿយៗ ការមិនតាំងចិត្ត ការមិនប្រកបព្យាយាមរឿយៗ សេចក្ដីប្រហែសក្នុងការចម្រើននូវកុសលធម៌ទាំងឡាយ សេចក្ដីប្រហែស អាការនៃសេចក្ដីប្រហែស ភាពនៃសេចក្ដីប្រហែសណាមានសភាពយ៉ាងនេះ នេះហៅថាសេចក្ដីប្រហែស ។

វេវិច្ឆា (បមាទា) នប្បកាសតីតិ ឥមិនា មច្ឆរិយេន ឥមិនា បមាទេន លោកោ នប្បកាសតិ ន ភាសតិ ន តបតិ ន វិរោចតិ ន សញ្ញាយតិ ន បញ្ញាយតីតិ វេវិច្ឆា (បមាទា) នប្បកាសតិ ។

[៦៣] ជប្បាភិលេបនំ ព្រូមីតិ ជប្បា វុច្ចតិ តណ្ហា យោ រាគោ សារាគោ អនុនយោ អនុរោធោ នន្ទិ នន្ទិរាគោ ចិត្តស្ស សារាគោ ឥច្ឆា មុច្ឆា អជ្ឈោសានំ គេធោ បលិគេធោ សង្គោ បង្កោ ឯជា មាយា ជនិកា សញ្ជននី សិព្វិនី ជាលិនី សរិតា វិសត្តិកា សោត្តំ វិសតា អាយូហនី ទុតិយា បណិធិ ភវនេត្តិ វនំ វនថោ សន្ថវោ សិនេហោ អបេក្ខា បដិពន្ធា អាសា អាសីសនា អាសីសិតត្តំ រូបាសា សទ្ទាសា គន្ធាសា រសាសា ផោដ្ឋព្វាសា លាភាសា ធនាសា បុត្តាសា ជីវិតាសា ជប្បា បជប្បា អភិជប្បា ជប្បនា ជប្បិតត្តំ

ពាក្យថា លោក មិនភ្ញីស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេង ៗ (និងសេចក្តីប្រហែស) បានសេចក្តីថា លោក មិនភ្ញឺស្វាង មិនមានរស្មី មិនមានពន្លឺ មិនរុងរឿង មិនយល់ច្បាស់ មិនប្រាកដ ព្រោះសេចក្តីកំណាញ់នេះ ព្រោះសេចក្តីប្រហែសនេះ ហេតុនោះ(ទ្រង់ត្រាស់ថា) លោក មិនភ្ញឺស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេង ៗ (និងសេចក្តីប្រហែស) ។

[៦៣] ពាក្យថា តថាគត ពោលនូវសេចក្តីប្រាថ្នាថាជាគ្រឿងលាប អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់តម្រេក តម្រេកខ្លាំង សេចក្តីត្រេកអរ សេចក្តីត្រេកអរខ្លាំង សេចក្តីត្រេកត្រអាល សេចក្តីត្រេកត្រអាលខ្លាំង គឺតម្រេក ចិត្តត្រេកខ្លាំង សេចក្តីប្រាថ្នា សេចក្តីជ្រប់ចុះ កិរិយាលង់ចុះ បំណង់ បំណង់ខ្លាំង ការជាប់កក់ញាប់ញ័រ ការលោភពុត ធម្មជាតញ៉ាំងសត្វឲ្យកើត គ្រឿងញ៉ាំងទុក្ខឲ្យកើត គ្រឿងចាក់ស្រេះបណ្តាញ គ្រឿងហូរទៅ ធម្មជាតដូចពិស ខ្សែតណ្ហា គ្រឿងផ្សព្វផ្សាយ គ្រឿងញ៉ាំងអាយុឲ្យវិនាស សម្ងាញ់ ប្រណិធាន គ្រឿងនាំសត្វទៅកាន់ភព ព្រៃតូច ព្រៃធំ សន្ថវៈ ស្នេហា អាល័យ សេចក្តីជាប់ចំពាក់ បំណង សេចក្តីប៉ុនប៉ង ភាពនៃសេចក្តីប៉ុនប៉ង បំណងរូប បំណងសំឡេង បំណងក្លិន បំណងរស បំណងផ្សព្វ បំណងលាភ បំណងទ្រព្យ បំណងបុត្រ បំណងជីវិត ការជាប់ចិត្ត ការជាប់ចិត្តខ្លាំង ការជាប់ចិត្តក្រៃលែង អាការជាប់ចិត្ត ភាពនៃការជាប់ចិត្ត

១៩

## អជិតមាណវកបញ្ហានិទ្ទេសោ

លោលុប្បា លោលុប្បាយនា លោលុប្បាយិតត្តំ បុច្ឆ-ញ្ជិកតា សាធុកម្យតា អធម្មរាគោ វិសមលោភោ និកន្តិ និកាមនា បត្ថនា បិហនា សម្បត្ថនា កាម-តណ្ហា ភវតណ្ហា វិភវតណ្ហា រូបតណ្ហា អរូបតណ្ហា និរោធតណ្ហា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រស-តណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ឱឃោ យោគោ គន្ថោ ឧបាទានំ អាវរណំ នីវរណំ ឆទនំ ពន្ធនំ ឧបក្កិលេសោ អនុសយោ បរិយុដ្ឋានំ លតា វេវិច្ឆំ ទុក្ខមូលំ ទុក្ខនិទានំ ទុក្ខប្បភវោ មារបាសោ មារពលិសំ មារវិសយោ មារគោចរោ មារពន្ធនំ តណ្ហានទី តណ្ហាជាលំ តណ្ហាគទ្ទុលំ តណ្ហាសមុទ្ទោ អភិជ្ឈា លោភោ អកុសលមូលំ អយំ វុច្ចតិ ជប្បា ។ លោកស្ស លេបនំ លគ្គនំ ពន្ធនំ ឧបក្កិលេសោ ឥមាយ ជប្បាយ លោកោ លិត្តោ បលិត្តោ គិលិដ្ឋោ សង្កិលិដ្ឋោ មក្ខិតោ សំសដ្ឋោ លគ្គោ លគ្គិតោ បលិពុទ្ធោ ។ ព្រូហិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានី-ករោមិ បកាសេមីតិ ជប្បាភិលេបនំ ព្រូមិ ។

សេចក្តីលោភលន់ អាការលោភលន់ ភាពនៃសេចក្តីលោភលន់ សេចក្តីប្រាថ្នាអន្ទះអន្ទែង សេចក្តីប្រាថ្នា ក្នុងអារម្មណ៍ស្រួល តម្រេកខុសធម៌ លោភខុសទំនង អាល័យ អាការអាល័យ ការប្រាថ្នា សេចក្តីស្រឡាញ់ ការប្រាថ្នាខ្លាំង ចំណង់កាម ចំណង់ភព ចំណង់វិភព ចំណង់រូប ចំណង់អរូប ចំណង់និរោធ ចំណង់រូប ចំណង់សំឡេង ចំណង់ក្លិន ចំណង់រស ចំណង់ផ្សព្វ ចំណង់ធម្មារម្មណ៍ អន្ទង់ គ្រឿងប្រកប គ្រឿងសាំញុាំ គ្រកង់ប្រកាន់ គ្រឿងពាំង គ្រឿងហាម គ្រឿងប្រក់ គ្រឿងចង គ្រឿងចូលទៅឲ្យសៅហ្មង គ្រឿងដេកត្រាំ គ្រឿងស្ទាក់ដំណើរ វល្លិ៍ សេចក្តីប្រាថ្នាផ្សេង ៗ ឫសនៃទុក្ខ ហេតុនៃទុក្ខ កំណើតទុក្ខ អន្ទាក់មារ សន្ទូចមារ វិស័យមារ គោចរមារ ចំណងមារ ស្ទឹងគឺតណ្ហា បណ្តាញគឺតណ្ហា ទន្លីងគឺតណ្ហា សមុទ្ទគឺតណ្ហា សេចក្តីសម្លឹងលោភ អកុសលមូល ណា នេះហៅថា សេចក្តីប្រាថ្នា ។ គ្រឿងលាប គ្រឿងជាប់ គ្រឿងចង គ្រឿងចូលទៅឲ្យសៅហ្មង របស់លោក លោកលាប លាបស្រឡាប សៅហ្មង សៅហ្មងព្រម ប្រឡាក់ ប្រឡាំព្រម ជាប់ ចំពាក់ ជាប់ស្អិតហើយ ដោយសេចក្តីប្រាថ្នានេះ ។ តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក រំលែក ធ្វើឱ្យងាយប្រកាស ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោល នូវសេចក្តីប្រាថ្នាថាជាគ្រឿងលាប ។

[៦៤] ទុក្ខមស្ស មហព្ភយន្តិ ទុក្ខន្តិ ជាតិទុក្ខំ ជរាទុក្ខំ ព្យាធិទុក្ខំ មរណទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខំ នេរយិកំ ទុក្ខំ តិរច្ឆានយោនិកំ ទុក្ខំ បិត្តិវិសយិកំ ទុក្ខំ មានុសិកំ ទុក្ខំ គព្ភោក្កន្តិមូលកំ ទុក្ខំ គព្ភេដ្ឋិតិមូលកំ ទុក្ខំ គព្ភវុដ្ឋានមូលកំ ទុក្ខំ ជាតស្សុបនិពន្ធកំ ទុក្ខំ ជាតស្ស បរាធេយ្យកំ ទុក្ខំ អត្តុបក្កមំ ទុក្ខំ បរុបក្កមំ ទុក្ខំ ទុក្ខទុក្ខំ សង្ខារទុក្ខំ វិបរិណាមទុក្ខំ ចក្ខុរោគោ សោតរោគោ ឃានរោគោ ជិវ្ហារោគោ កាយរោគោ សីសរោគោ កណ្ណរោគោ មុខរោគោ ទន្តរោគោ កាសោ សាសោ បិនាសោ ឌហោ ជរោ កុច្ឆិរោគោ មុច្ឆា បក្ខន្ទិកា សុលា វិសូចិកា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ ទទ្ទុ កណ្ឌុ កច្ឆុ រខសា វិតច្ឆិកា លោហិតំ បិត្តំ មធុមេហោ អំសា បិឡកា ភគន្ទលា

[៦៤] អធិប្បាយពាក្យថា ទុក្ខជាភ័យធំរបស់លោកនោះ ត្រង់ពាក្យថា ទុក្ខ គឺទុក្ខព្រោះកំណើត ទុក្ខព្រោះសេចក្តីចាស់ ទុក្ខព្រោះជំងឺ ទុក្ខព្រោះសេចក្តីស្លាប់ ទុក្ខព្រោះសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំ ទុក្ខក្នុងកំណើតនរក ទុក្ខក្នុងកំណើតតិរច្ឆាន ទុក្ខក្នុងកំណើតបេតវិស័យ ទុក្ខក្នុងកំណើតមនុស្ស ទុក្ខមានការចុះកាន់គភ៌ជាមូល ទុក្ខមានការឋិតនៅក្នុងគភ៌ជាមូល ទុក្ខមានកិរិយាចេញចាកគភ៌ជាមូល ទុក្ខជាបំណាំងរបស់[១]សត្វ ដែលកើតហើយ ទុក្ខទាក់ទងដោយបុគ្គលដទៃនៃសត្វ ដែលកើតហើយ ទុក្ខកើត ព្រោះព្យាយាមរបស់ខ្លួន ទុក្ខកើត ព្រោះព្យាយាមរបស់បុគ្គលដទៃ ទុក្ខគឺទុក្ខវេទនា (ប្រព្រឹត្តទៅក្នុងកាយនិងចិត្ត) ទុក្ខព្រោះសង្ខារ ទុក្ខព្រោះការផ្លាស់ប្តូរ រោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគស្លឹកត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត ឫសដូងច្រមុះ ក្តៅក្រហាយ ស្គាំងស្គម រោគផ្ទៃ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុះរាក ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគក្នុងទីខ្វារដោយក្រចក កមរលាយ ប្រមាត់ក្រហម ទឹកនោមផ្អែម ឫសដូងដុះ រលកកែវ ឫសដូងបាត

១ បានដល់សេចក្តីទុក្ខដោយការថែទាំ គឺ ងូតទឹក លាបប្រេង ទំពាស៊ី ហុត ផឹក ជាដើម ។ អដ្ឋកថា ។

## អជិតមាណវកប្យញ្ហានិទ្ទេសោ

បិត្តសមុដ្ឋានា អាពាធា សេម្ហសមុដ្ឋានា អាពាធា វាតសមុដ្ឋានា អាពាធា សន្និបាតិកា អាពាធា ឧតុបរិណាមជា អាពាធា វិសមបរិហារជា អាពាធា ឱបក្កមិកា អាពាធា កម្មវិបាកជា អាពាធា សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ ឌំសមកសវាតាតបសិរឹសបសម្ផស្សទុក្ខំ មាតុមរណំ ទុក្ខំ បិតុមរណំ ទុក្ខំ ភាតុមរណំ ទុក្ខំ ភគិនីមរណំ ទុក្ខំ បុត្តមរណំ ទុក្ខំ ធីតុមរណំ ទុក្ខំ ញាតិព្យសនំ ទុក្ខំ ភោគព្យសនំ ទុក្ខំ រោគព្យសនំ ទុក្ខំ សីលព្យសនំ ទុក្ខំ ទិដ្ឋិព្យសនំ ទុក្ខំ យេសំ ធម្មានំ អាទិតោ សមុទាគមនំ បញ្ញាយតិ អត្ថង្គមតោ និរោធោ បញ្ញាយតិ កម្មសន្និស្សិតោ វិបាកោ វិបាកសន្និស្សិតំ កម្មំ នាមសន្និស្សិតំ រូបំ រូបសន្និស្សិតំ នាមំ ជាតិយា អនុគតំ ជរាយ អនុសដំ ព្យាធិនា អភិភូតំ មរណេន អព្ភាហតំ ទុក្ខេ បតិដ្ឋិតំ អតាណំ អលេណំ អសរណំ អសរណីភូតំ ឥទំ វុច្ចតិ ទុក្ខំ ។ អស្ស លោកស្ស ទុក្ខំ មហាព្ភយំ បីឡនំ ឃដ្ដនំ ឧបទ្ទវោ ឧបសគ្គោតិ ទុក្ខមស្ស មហាព្ភយំ ។ តេនាហ ភគវា

អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីការប្រជុំ (ខ្យល់ប្រមាត់ស្លេស្ម) អាពាធកើតអំពីការផ្លាស់ប្តូររដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីព្យាយាម (មានការសម្លាប់និងចងជាដើម) អាពាធកើតអំពីផលកម្ម ត្រជាក់ ក្តៅ សេចក្តីឃ្លាន សេចក្តីស្រេក ឧច្ចារៈ បស្សាវៈ ទុក្ខកើតអំពីសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់ ការស្លាប់មាតាជាទុក្ខ ការស្លាប់បិតាជាទុក្ខ ការស្លាប់បងប្អូនប្រុសជាទុក្ខ ការស្លាប់បងប្អូនស្រីជាទុក្ខ ការស្លាប់កូនប្រុស ជាទុក្ខ ការស្លាប់កូនស្រីជាទុក្ខ ការព្រាត់ប្រាសញាតិជាទុក្ខ ការវិនាសភោគៈជាទុក្ខ វិនាសគឺរោគជាទុក្ខ វិនាសសីលជាទុក្ខ វិនាសទិដ្ឋិជាទុក្ខ ការកើតឡើងនៃធម៌ទាំងឡាយណា រមែងប្រាកដក្នុងខាងដើម ការរលត់ទៅ (នៃធម៌ទាំងឡាយនោះ) រមែងប្រាកដដោយការវិនាស វិបាកអាស្រ័យកម្ម កម្មអាស្រ័យវិបាក រូបអាស្រ័យនាម នាមអាស្រ័យរូប ត្រូវជាតិទៅតាមហើយ ត្រូវជរាផ្តេកផ្តិតហើយ ត្រូវព្យាធិគ្របសង្កត់ហើយ ត្រូវមរណៈកម្ចាត់ហើយ តាំងនៅស៊ប់ក្នុងសេចក្តីទុក្ខ ឥតមានទីពឹង ឥតមានទីជ្រក ឥតមានទីរឭក ឥតមានទីសង្ឃឹម នេះហៅថា ទុក្ខ ។ ទុក្ខជាភ័យធំ ជាគ្រឿងបៀតបៀន ជាគ្រឿងគាប ជាគ្រឿងឧបទ្រព ជាឧបស័គ្គ របស់លោកនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ទុក្ខជាភ័យធំរបស់លោកនោះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ហើយថា

អវិជ្ជាយ និវុតោ លោកោ (អជិតាតិ ភគវា)
វេវិច្ឆា (បមាទា) នប្បកាសតិ
ជប្បាភិលេបនំ ព្រូមិ
ទុក្ខមស្ស មហព្ភយន្តិ ។

[៦៥] សវន្តិ សព្វធិ សោតា (ឥច្ចាយស្មា អជិតោ)
សោតានំ កិន្និវារណំ
សោតានំ សំវរំ ព្រូហិ
កេន សោតា បិធិយ្យរេ ។

[៦៦] សវន្តិ សព្វធិ សោតាតិ សោតាតិ តណ្ហាសោតោ ទិដ្ឋិសោតោ កិលេសសោតោ ទុច្ចរិតសោតោ អវិជ្ជាសោតោ ។ សព្វធីតិ សព្វេសុ អាយតនេសុ ។ សវន្តីតិ សវន្តិ អាសវន្តិ សន្ទន្តិ បវត្តន្តិ ចក្ខុតោ រូបេ សវន្តិ អាសវន្តិ សន្ទន្តិ បវត្តន្តិ សោតតោ សទ្ទេ សវន្តិ ឃានតោ គន្ធេ សវន្តិ ជិវ្ហាតោ រសេ សវន្តិ កាយតោ ផោដ្ឋព្វេ សវន្តិ មនតោ ធម្មេ សវន្តិ អាសវន្តិ សន្ទន្តិ បវត្តន្តិ ចក្ខុតោ រូបតណ្ហា សវន្តិ អាសវន្តិ សន្ទន្តិ បវត្តន្តិ សោតតោ

(ព្រះមានព្រះភាគត្រាស់ថា) ម្នាលអជិតៈ លោក ត្រូវអវិជ្ជាបិទបាំង លោក មិនភ្លឺស្វាង ព្រោះសេចក្ដីប្រាថ្នាផ្សេង ៗ (និងសេចក្ដីប្រហែស) តថាគត ពោលនូវសេចក្ដីប្រាថ្នាថា ជាគ្រឿងលាប ទុក្ខជាភ័យធំ របស់លោកនោះ ។

[៦៥] (អជិតមាណពមានអាយុ ក្រាបបង្គំទូលសួរដូច្នេះថា) ខ្សែទាំងឡាយ រមែងហូរទៅ ក្នុងទីទាំងពួង អ្វីជាគ្រឿងរារាំងនូវខ្សែទាំងឡាយ សូមព្រះអង្គ ទ្រង់សម្ដែងធម៌ជាគ្រឿងបិទខ្សែទាំងឡាយ បុគ្គលបិទខ្សែទាំងឡាយ ដោយអ្វី ។

[៦៦] អធិប្បាយពាក្យថា ខ្សែទាំងឡាយ រមែងហូរទៅក្នុងទីទាំងពួង ត្រង់ពាក្យថា ខ្សែទាំងឡាយ បានដល់ខ្សែគឺតណ្ហា ខ្សែគឺទិដ្ឋិ ខ្សែគឺកិលេស ខ្សែគឺទុច្ចរិត ខ្សែគឺអវិជ្ជា ។ ពាក្យថា ក្នុងទីទាំងពួង គឺក្នុងអាយតនៈទាំងពួង ។ ពាក្យថា ហូរទៅ សេចក្ដីថា ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ គឺហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ អំពីភ្នែកទៅកាន់រូប ហូរអំពីត្រចៀកទៅកាន់សំឡេង ហូរអំពីច្រមុះទៅកាន់ក្លិន ហូរអំពីអណ្ដាតទៅកាន់រស ហូរអំពីកាយទៅកាន់ផ្សព្វ ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ អំពីចិត្តទៅកាន់ធម្មារម្មណ៍ រូបតណ្ហា ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ អំពីភ្នែក

អជិតមាណវកបញ្ញានិទ្ទេសោ

សទ្ទតណ្ហា សវន្តិ អាសវន្តិ សន្ទន្តិ បវត្តន្តិ ឃានតោ គន្ធតណ្ហា សវន្តិ ជិវ្ហាតោ រសតណ្ហា សវន្តិ កាយតោ ផោដ្ឋព្វតណ្ហា សវន្តិ មនតោ ធម្មតណ្ហា សវន្តិ អាសវន្តិ សន្ទន្តិ បវត្តន្តីតិ សវន្តិ សព្វធិ សោតា ។

[៦៧] ឥច្ចាយស្មា អជិតោតិ ឥច្ចាតិ បទសន្ធិ បទសំសគ្គោ បទបារិបូរិ អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។ អជិតោតិ តស្ស ព្រាហ្មណស្ស នាមំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោតិ ឥច្ចាយស្មា អជិតោ ។

[៦៨] សោតានំ កិន្និវារណន្តិ សោតានំ កឹ អាវរណំ នីវរណំ សំវរណំ រក្ខនំ គោបនន្តិ សោតានំ កិន្និវារណំ ។

សទ្ទតណ្ហា ហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ អំពីត្រចៀក គន្ធតណ្ហា ហូរទៅអំពីច្រមុះ រសតណ្ហា ហូរទៅអំពីអណ្តាត ផោដ្ឋព្វ-តណ្ហា ហូរទៅអំពីកាយ ធម្មតណ្ហាហូរទៅ ហូរសំយុង ហូរមិនដាច់ ប្រព្រឹត្តទៅ អំពីចិត្ត ហេតុនោះ លោកសួរថា ខ្សែទាំងឡាយ រមែង ហូរទៅ ក្នុងទីទាំងពួង ។

[៦៧] ពាក្យថា ដូច្នេះនៃបទថា អជិតៈមានអាយុ (ទូលសួរ) ដូច្នេះ គឺជាការតបទ ជាការជាប់ដោយបទ ជាការបំពេញបទ ជាការប្រជុំនៃអក្ខរៈ ជាសេចក្តីពីរោះ ដោយព្យញ្ជនៈ ពាក្យថា ដូច្នេះ នេះ ជាលំដាប់នៃបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុនេះ ជាពាក្យពោល ដោយគោរពកោតក្រែង ។ ពាក្យថា អជិតៈ គឺជានាម ជាសង្ខា ជាឈ្មោះ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមធេយ្យ ជាភាសា ជាព្យញ្ជនៈ ជាពាក្យហៅ របស់ព្រាហ្មណ៍នោះ ហេតុនោះ មានពាក្យថា អជិតៈមានអាយុ (ទូលសួរ) ដូច្នេះ ។

[៦៨] ពាក្យថា អ្វីជាគ្រឿងរាំងនូវខ្សែទាំងឡាយ គឺអ្វីជាគ្រឿងឃាត់ខាំង ជាគ្រឿងរាំង ជាគ្រឿងបិទ ជាគ្រឿងរក្សា ជាគ្រឿងគ្រប់គ្រង នូវខ្សែទាំងឡាយ ហេតុនោះ លោកសួរថា អ្វីជាគ្រឿងរាំង នូវខ្សែទាំងឡាយ ។

[៦៩] សោតានំ សំវរំ ព្រូហីតិ សោតានំ អា-
វរណំ នីវរណំ សំវរណំ រក្ខនំ គោបនំ ព្រូហិ
អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ
វិភជាហិ ឧត្តានីករោហិ បកាសេហីតិ សោតានំ
សំវរំ ព្រូហិ ។

[៧០] កេន សោតា បិធិយ្យរេតិ កេន សោតា
បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ
នប្បវត្តន្តីតិ កេន សោតា បិធិយ្យរេ ។ តេនាហ
សោ ព្រាហ្មណោ

សវន្តិ សព្វធិ សោតា (ឥច្ចាយស្មា អជិតោ)
សោតានំ កិន្និវារណំ
សោតានំ សំវរំ ព្រូហិ
កេន សោតា បិធិយ្យរេតិ ។

[៧១] យានិ សោតានិ លោកស្មឹ (អជិតាតិ ភគវា)
សតិ តេសំ និវារណំ
សោតានំ សំវរំ ព្រូមិ
បញ្ញាយេតេ បិធិយ្យរេ ។

[៦៩] ពាក្យថា សូមព្រះអង្គ ទ្រង់សម្តែងធម៌ជាគ្រឿងបិទខ្សែទាំងឡាយ គឺសូមព្រះអង្គ ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស នូវធម៌ជាគ្រឿងឃាត់ខាំង គ្រឿងរារាំង គ្រឿងបិទ គ្រឿងរក្សា គ្រឿងគ្រប់គ្រង ខ្សែទាំងឡាយ ហេតុនោះ លោកសួរថា សូមព្រះអង្គ ទ្រង់សម្តែងធម៌ជាគ្រឿងបិទខ្សែទាំងឡាយ ។

[៧០] ពាក្យថា បុគ្គលបិទខ្សែទាំងឡាយ ដោយអ្វី គឺខ្សែទាំងឡាយ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយៗ មិនប្រព្រឹត្តទៅ ដោយអ្វី ហេតុនោះ លោកសួរថា បុគ្គលបិទខ្សែទាំងឡាយ ដោយអ្វី ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

ខ្សែទាំងឡាយ រមែងហូរទៅ ក្នុងទីទាំងពួង អ្វីជា
គ្រឿងរារាំង នូវខ្សែទាំងឡាយ សូមព្រះអង្គទ្រង់សម្តែង
ធម៌ ជាគ្រឿងបិទខ្សែទាំងឡាយ បុគ្គលបិទខ្សែទាំងឡាយ
ដោយអ្វី ។

[៧១] (ព្រះមានព្រះភាគត្រាស់ថា ម្នាលអជិតៈ) ខ្សែទាំងឡាយ
ណា ក្នុងលោក សតិ ជាគ្រឿងបិទខ្សែទាំងនោះ តថាគត
ពោលនូវការបិទខ្សែទាំងឡាយ ខ្សែទាំងនុ៎ះ បុគ្គលបិទ
បាន ដោយបញ្ញា ។

២៤

## អជិតមាណវកប្បញ្ហានិទ្ទេសោ

[៧២] យានិ សោតានិ លោកស្មិន្តិ យានិ ឯតានិ សោតានិ មយា កិត្តិតានិ អាចិក្ខិតានិ ទេសិតានិ បញ្ញបិតានិ បដ្ឋបិតានិ វិវរិតានិ វិភជិតានិ ឧត្តានីកតានិ បកាសិតានិ សេយ្យថីទំ តណ្ហាសោតោ ទិដ្ឋិសោតោ កិលេសសោតោ ទុច្ចរិតសោតោ អវិជ្ជាសោតោ ។ លោកស្មិន្តិ អបាយលោកេ មនុស្សលោកេ ទេវលោកេ ខន្ធលោកេ ធាតុលោកេ អាយតនលោកេតិ យានិ សោតានិ លោកស្មឹ ។ អជិតាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។

[៧៣] សតិ តេសំ និវារណន្តិ សតីតិ យា សតិ អនុស្សតិ បដិស្សតិ សតិ សរណតា ធារណតា អបិលាបនតា អសម្មុស្សនតា សតិ សតិន្ទ្រិយំ សតិសម្ពោជ្ឈង្គោ ឯកាយនមគ្គោ អយំ វុច្ចតិ សតិ ។ និវារណន្តិ អាវរណំ នីវរណំ សំវរណំ រក្ខនំ គោបនន្តិ សតិ តេសំ និវារណំ ។

អជិតមាណវកប្បញ្ហានិទ្ទេស

[៧២] ពាក្យថា ខ្សែទាំងឡាយណា ក្នុងលោក សេចក្ដីថា ខ្សែទាំងឡាយណា ដែលតថាគត ពោល ប្រាប់ សម្ដែង បញ្ញត្ត តាំងទុក ញែក បែក ធ្វើឲ្យរាក់ ប្រកាសហើយថា ខ្សែគឺតណ្ហា ខ្សែគឺទិដ្ឋិ ខ្សែគឺកិលេស ខ្សែគឺទុច្ចរិត ខ្សែគឺអវិជ្ជា ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ខ្សែទាំង-ឡាយណា ក្នុងលោក ។ ពាក្យថា អជិតៈ គឺ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រាហ្មណ៍នោះចំឈ្មោះ ។

[៧៣] ពាក្យថា សតិជាគ្រឿងបិទទាំងនោះ ត្រង់ពាក្យថា សតិ បានដល់សេចក្ដីរឭក សេចក្ដីរឭករឿយ ៗ សេចក្ដីរឭកចំពោះ សេចក្ដីរឭក អាការនៃសេចក្ដីរឭក សេចក្ដីចាំ សេចក្ដីជ្រួតជ្រាប សេចក្ដីមិនវង្វេង សេចក្ដីរឭក ឥន្ទ្រិយគឺសតិ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹងគឺសតិ ផ្លូវជាទីទៅនៃបុគ្គលតែមួយ នេះហៅថា សតិ ។ ពាក្យថា ជាគ្រឿងបិទ គឺជាគ្រឿងរារាំង ជាគ្រឿងបិទ ជាគ្រឿងឃាត់ខាំង ជាគ្រឿងរក្សា ជាគ្រឿងគ្រប់គ្រង ហេតុនោះ ទ្រង់ត្រាស់ថា សតិ ជាគ្រឿងបិទខ្សែទាំងនោះ ។

[៧៤] សោតានំ សំវរំ ព្រូមីតិ សោតានំ អាវរណំ នីវរណំ សំវរណំ រក្ខនំ គោបនំ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ សោតានំ សំវរំ ព្រូមិ ។

[៧៥] បញ្ញាយេតេ បិធិយ្យរេតិ បញ្ញាតិ យា បញ្ញា បជានានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ បញ្ញាយេតេ បិធិយ្យរេតិ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។ សព្វេ សង្ខារា អនិច្ចាតិ ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។ សព្វេ សង្ខារា ទុក្ខាតិ ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។ សព្វេ ធម្មា អនត្តាតិ ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។

[៧៨] ពាក្យថា តថាគតពោល នូវការបិទខ្សែទាំងឡាយ គឺ តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក ញែក ចែក ធ្វើឲ្យរាក់ ប្រកាសនូវការរារាំង ឃាត់ខាំង បិទរក្សា គ្រប់គ្រងនូវខ្សែទាំងឡាយ ហេតុនោះ ទ្រង់ត្រាស់ថា តថាគតពោល នូវការបិទខ្សែទាំងឡាយ ។

[៧៩] អធិប្បាយពាក្យថា ខ្សែទាំងនុ៎ះ បុគ្គលបិទបាន ដោយបញ្ញា ត្រង់ពាក្យថា បញ្ញា បានដល់ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ សេចក្តីយល់ត្រូវ ។ ពាក្យថា ខ្សែទាំងនុ៎ះ បុគ្គលបិទបាន ដោយបញ្ញា គឺខ្សែទាំងនោះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយ ៗ មិនប្រព្រឹត្តទៅ ដោយបញ្ញា ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយ ៗ មិនប្រព្រឹត្តទៅ ដោយបញ្ញា របស់បុគ្គលអ្នកដឹង អ្នកឃើញថា សង្ខារទាំងពួងមិនទៀង ។ ខ្សែទាំងនុ៎ះបុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយ ៗ មិនប្រព្រឹត្តទៅ ដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា សង្ខារទាំងពួងជាទុក្ខ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយ ៗ មិនប្រព្រឹត្តទៅ ដោយបញ្ញា របស់បុគ្គលអ្នកដឹង អ្នកឃើញថា ធម៌ទាំងពួងជាអនត្តា ។

អជិតមាណវកប្បញ្ហានិទ្ទេសោ

អវិជ្ជាបច្ចយា សង្ខារាតិ ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។ សង្ខារប្បច្ចយា វិញ្ញាណន្តិ វិញ្ញាណប្បច្ចយា នាមរូបន្តិ នាមរូបប្បច្ចយា សឡាយតនន្តិ សឡាយតនប្បច្ចយា ផស្សោតិ ផស្សប្បច្ចយា វេទនាតិ វេទនាបច្ចយា តណ្ហាតិ តណ្ហាបច្ចយា ឧបាទានន្តិ ឧបាទានប្បច្ចយា ភវោតិ ភវប្បច្ចយា ជាតីតិ ជាតិប្បច្ចយា ជរាមរណន្តិ ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។ អវិជ្ជានិរោធា សង្ខារនិរោធោតិ សង្ខារនិរោធា វិញ្ញាណនិរោធោតិ វិញ្ញាណនិរោធា នាមរូបនិរោធោតិ នាមរូបនិរោធា សឡាយតននិរោធោតិ សឡាយតននិរោធា ផស្សនិរោធោតិ ផស្សនិរោធា វេទនានិរោធោតិ

ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររៀយៗ មិនប្រព្រឹត្តទៅ ដោយបញ្ញា របស់បុគ្គលអ្នកដឹង អ្នកឃើញថា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររៀយៗ មិនប្រព្រឹត្តទៅ ដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា វិញ្ញាណ (កើតមាន) ព្រោះសង្ខារជាបច្ច័យ ថានាមនិងរូប (កើតមាន) ព្រោះវិញ្ញាណជាបច្ច័យ ថាអាយតនៈប្រាំមួយ (កើតមាន) ព្រោះនាមនិងរូបជាបច្ច័យ ថាផស្សៈ (កើតមាន) ព្រោះអាយតនៈប្រាំមួយជាបច្ច័យ ថាវេទនា (កើតមាន) ព្រោះផស្សៈជាបច្ច័យ ថាតណ្ហា (កើតមាន) ព្រោះវេទនាជាបច្ច័យ ថាឧបាទាន (កើតមាន) ព្រោះតណ្ហាជាបច្ច័យ ថាភព (កើតមាន) ព្រោះឧបាទានជាបច្ច័យ ថាជាតិ (កើតមាន) ព្រោះភពជាបច្ច័យ, ថាជរានិងមរណៈ(កើតមាន) ព្រោះជាតិជាបច្ច័យ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររៀយៗ មិនប្រព្រឹត្តទៅ ដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា សេចក្តីរលត់សង្ខារ ព្រោះការរលត់អវិជ្ជា ថាសេចក្តីរលត់វិញ្ញាណ ព្រោះការរលត់សង្ខារ ថាសេចក្តីរលត់នាមនិងរូប ព្រោះការរលត់វិញ្ញាណ ថាសេចក្តីរលត់ អាយតនៈប្រាំមួយ ព្រោះការរលត់នាមនិងរូប ថាសេចក្តីរលត់ផស្សៈ ព្រោះការរលត់អាយតនៈប្រាំមួយ ថាសេចក្តីរលត់វេទនា ព្រោះការរលត់ផស្សៈ

វេទនានិរោធា តណ្ហានិរោធោតិ តណ្ហានិរោធា ឧបាទាននិរោធោតិ ឧបាទាននិរោធា ភវនិរោធោតិ ភវនិរោធា ជាតិនិរោធោតិ ជាតិនិរោធា ជរាមរណនិរោធោតិ ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។ ឥទំ ទុក្ខន្តិ អយំ ទុក្ខសមុទយោតិ អយំ ទុក្ខនិរោធោតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។ ឥមេ អាសវាតិ អយំ អាសវសមុទយោតិ អយំ អាសវនិរោធោតិ អយំ អាសវនិរោធគាមិនី បដិបទាតិ ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។ ឥមេ ធម្មា អភិញ្ញេយ្យាតិ ឥមេ ធម្មា បរិញ្ញេយ្យាតិ ឥមេ ធម្មា បហាតព្វាតិ ឥមេ ធម្មា ភាវេតព្វាតិ ឥមេ ធម្មា សច្ឆិកាតព្វាតិ ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។

ថាសេចក្តីរលត់តណ្ហា ព្រោះការរលត់វេទនា ថា សេចក្តីរលត់ឧបាទាន ព្រោះការរលត់តណ្ហា ថាសេចក្តីរលត់ភព ព្រោះការរលត់ឧបាទាន ថា សេចក្តីរលត់ជាតិ ព្រោះការរលត់ភព ថា សេចក្តីរលត់ជរានិងមរណៈ ព្រោះការរលត់ជាតិ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយ ៗ មិនប្រព្រឹត្តទៅ ដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា នេះទុក្ខ ថានេះហេតុឲ្យកើតទុក្ខ ថា នេះសេចក្តីរលត់ទុក្ខ ថានេះបដិបទាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយ ៗ មិនប្រព្រឹត្តទៅ ដោយបញ្ញា របស់បុគ្គលអ្នកដឹង អ្នកឃើញថា នេះពួកអាសវៈ ថានេះហេតុឲ្យកើតអាសវៈ ថា នេះសេចក្តីរលត់អាសវៈ ថានេះបដិបទាដំណើរទៅកាន់ទីរលត់អាសវៈ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយ ៗ មិនប្រព្រឹត្តទៅ ដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញថា ធម៌ទាំងនេះ គប្បីត្រាស់ដឹង ថាធម៌ទាំងនេះ គប្បីកំណត់ដឹង ថាធម៌ទាំងនេះ គប្បីលះ ថាធម៌ទាំងឡាយនេះ គប្បីចម្រើន ថាធម៌ទាំងឡាយនេះ គប្បីធ្វើឲ្យជាក់ច្បាស់ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូររឿយ ៗ មិនប្រព្រឹត្តទៅដោយបញ្ញា របស់បុគ្គលអ្នកដឹង អ្នកឃើញសេចក្តីកើតឡើង វិនាសទៅ អានិសង្ស ទោស និងកិរិយារលាស់ចេញ នូវផស្សាយតនៈទាំងប្រាំមួយ ។

២៩

## អជិតមាណវកបញ្ហានិទ្ទេសោ

ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តិ ។ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច ជានតោ បស្សតោ ចតុន្នំ មហាភូតានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច ជានតោ បស្សតោ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ជានតោ បស្សតោ បញ្ញាយ ឯតេ សោតា បិធិយ្យន្តិ បច្ឆិជ្ជន្តិ ន សវន្តិ ន អាសវន្តិ ន សន្ទន្តិ នប្បវត្តន្តីតិ បញ្ញាយ ឯតេ សោតា បិធិយ្យរេ ។ តេនាហ ភគវា

យានិ សោតានិ លោកស្មឹ (អជិតាតិ ភគវា)
សតិ តេសំ និវារណំ
សោតានំ សំវរំ ព្រូមិ
បញ្ញាយេតេ បិធិយ្យរេតិ ។

អជិតមាណវកប្បញ្ហានិទ្ទេស

ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិនហូរទៅ មិនហូរសំយុង មិនហូរ ហៀរៗ មិនប្រព្រឹត្តទៅដោយបញ្ញារបស់បុគ្គលអ្នកដឹង អ្នកឃើញ សេចក្តីកើតឡើង វិនាសទៅ អានិសង្ស ទោស និងកិរិយារលាស់ចេញ នូវផស្សាយតនៈទាំងប្រាំមួយ ។ ខ្សែទាំងនុ៎ះ បុគ្គលបិទ ដាច់សូន្យ មិន ហូរទៅ មិនហូរសំយុង មិនហូរហៀរៗ មិនប្រព្រឹត្តទៅ ដោយបញ្ញា របស់បុគ្គលអ្នកដឹង អ្នកឃើញ សេចក្តីកើតឡើង វិនាសទៅ អានិសង្ស ទោស និងកិរិយារលាស់ចេញ នូវឧបាទានក្ខន្ធ ៥ អ្នកដឹង អ្នកឃើញ នូវការកើតឡើង វិនាសទៅ អានិសង្ស ទោស និងកិរិយារលាស់ចេញនូវ មហាភូតទាំង ៤ អ្នកដឹង អ្នកឃើញថា ធម៌ណាមួយមានសភាពកើតឡើង ហើយ ធម៌ទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា (ហេតុនោះ ទ្រង់ត្រាស់ថា) ខ្សែទាំងនុ៎ះ បុគ្គលបិទបាន ដោយបញ្ញា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលអជិតៈ ខ្សែទាំងឡាយណា ក្នុងលោក សតិជាគ្រឿង
បិទ ខ្សែទាំងនោះ តថាគតពោល នូវការបិទខ្សែទាំងឡាយ
ខ្សែទាំងនុ៎ះ បុគ្គល បិទបានដោយបញ្ញា ។

[៧៦] បញ្ញា ចេវ សតិ ចាបិ (ឥច្ចាយស្មា អជិតោ)
នាមរូបញ្ច មារិស
ឯតម្មេ បុដ្ឋោ បព្រូហិ
កត្ថេតំ ឧបរុជ្ឈតិ ។

[៧៧] បញ្ញា ចេវ សតិ ចាបីតិ បញ្ញាតិ យា បញ្ញា បជានជា វិចយោ បវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិ-ណាយិកា វិបស្សនា សម្បជញ្ញំ បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញាបាសាទោ បញ្ញាអាលោកោ បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ សតីតិ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតីតិ បញ្ញា ចេវ សតិ ចាបិ ឥច្ចាយស្មា អជិតោ ។

[៧៦] (អជិតៈមានអាយុក្រាបបង្គំទូលថា) បពិត្រព្រះអង្គនិរទុក្ខ បញ្ញា ១ សតិ ១ នាមនិងរូប ១ ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់សម្តែងប្រាប់ នូវសេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គ តើធម៌នុ៎ះរលត់ទៅក្នុងទីណា ។

[៧៧] ពាក្យថា បញ្ញា ១ សតិ ១ ត្រង់ពាក្យថា បញ្ញា បានខាងប្រាជ្ញា ការដឹងច្បាស់ ការពិចារណា ការពិចារណាឃើញ ការកំណត់ ការកំណត់ដឹង ការកំណត់ដឹងសព្វ ភាពនៃការឈ្លាសវៃ ភាពនៃការវាងវៃ ភាពនៃបញ្ញាដ៏ពេញលេញ សេចក្តីយល់ច្បាស់ ការគិត ការរំពឹង ប្រាជ្ញាក្រាស់ ប្រាជ្ញាសម្រាប់ទម្លាយបង់នូវកិលេស ប្រាជ្ញាសម្រាប់ដឹកនាំ ប្រាជ្ញាសម្រាប់ឃើញច្បាស់ សេចក្តីដឹងច្បាស់ សភាពនៃការទម្លុះបញ្ញា ឥន្ទ្រិយគឺបញ្ញា កម្លាំងគឺបញ្ញា សស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា រស្មីគឺបញ្ញា ការរុងរឿងគឺបញ្ញា កែវគឺបញ្ញា សេចក្តីមិនវង្វេង ការពិចារណាធម៌ សេចក្តីយល់ត្រូវ ។ ពាក្យថា សតិ បានដល់សេចក្តីរឭក សេចក្តីរឭករឿយៗ ។ បេ ។ សេចក្តីរឭកត្រូវ ហេតុនោះ (មានពាក្យថា) អជិតមាណពដ៏មានអាយុពោលថា បញ្ញា ១ សតិ ១ ។

៣១

អជិតមាណវកប្បញ្ហានិទ្ទេសោ

[៧៨] នាមរូបញ្ច មារិសាតិ នាមន្តិ ចត្តារោ អរូបិនោ ខន្ធា ។ រូបន្តិ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ មារិសាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ មារិសាតិ នាមរូបញ្ច មារិស ។

[៧៩] ឯតម្មេ បុដ្ឋោ បព្រូហីតិ ឯតម្មេតិ យំ បុច្ឆាមិ យំ យាចាមិ យំ អជ្ឈេសាមិ យំ បសាទេមិ ។ បុដ្ឋោតិ បុច្ឆិតោ យាចិតោ អជ្ឈេសិតោ បសាទិតោ ។ បព្រូហីតិ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ ឯតម្មេ បុដ្ឋោ បព្រូហិ ។

[៨០] កត្ថេតំ ឧបរុជ្ឈតីតិ កត្ថេតំ និរុជ្ឈតិ វូបសមតិ អត្ថំ គច្ឆតិ បដិប្បស្សម្ភតីតិ កត្ថេតំ ឧបរុជ្ឈតិ ។ តេនាហ សោ ព្រាហ្មណោ

អជិតមាណវកបញ្ហានិទ្ទេស

[៧៨] ពាក្យថា បពិត្រព្រះអង្គជានិរទុក្ខ នាមនិងរូប ១ ត្រង់ពាក្យថា នាម បានដល់អរូបក្ខន្ធ ៤ ។ ពាក្យថា រូប គឺមហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូបទាំង ៤ ។ ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គជានិរទុក្ខ ជាពាក្យពោលដោយគោរព កោតក្រែង ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គនិរទុក្ខ នាមនិងរូប ១ ។

[៧៩] ពាក្យថា ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់សម្តែងប្រាប់ នូវសេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា នូវសេចក្តីនុ៎ះដល់ខ្ញុំព្រះអង្គ គឺខ្ញុំព្រះអង្គសួរសេចក្តីណា សូមសេចក្តីណា អារាធនាសេចក្តីណា ជ្រះថ្លាសេចក្តីណា ។ ពាក្យថា ខ្ញុំព្រះអង្គសួរហើយ គឺខ្ញុំព្រះអង្គសួរ សូមអារាធនា ជ្រះថ្លាហើយ ។ ពាក្យថា សូមទ្រង់សម្តែងប្រាប់ គឺសូមទ្រង់ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក ញែក ចែក ធ្វើឲ្យង៉ាយ ប្រកាស ហេតុនោះ (លោកសួរថា) ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់សម្តែងប្រាប់នូវសេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គ ។

[៨០] ពាក្យថា តើធម៌នុ៎ះ រលត់ទៅក្នុងទីណា គឺធម៌នុ៎ះ រលត់ទៅ រម្ងាប់ទៅ ដល់នូវសេចក្តីវិនាស ស្ងប់រម្ងាប់ទៅក្នុងទីណា ហេតុនោះ (លោកសួរថា) ធម៌នុ៎ះរលត់ទៅក្នុងណា ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា:

បញ្ញា ចេវ សតិ ចាបិ (ឥច្ចាយស្មា អជិតោ)
នាមរូបញ្ច មារិស
ឯតម្មេ បុដ្ឋោ បព្រូហិ
កត្ថេតំ ឧបរុជ្ឈតីតិ ។

[៨១] យមេតំ បញ្ហំ អបុច្ឆិ អជិត តំ វទាមិ តេ យត្ថ នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតិ វិញ្ញាណស្ស និរោធេន ឯត្ថេតំ ឧបរុជ្ឈតិ ។

[៨២] យមេតំ បញ្ហំ អបុច្ឆីតិ យមេតន្តិ បញ្ញញ្ច សតិញ្ច នាមរូបញ្ច ។ អបុច្ឆីតិ អាបុច្ឆសិ អាយាចសិ អជ្ឈេសសិ បសាទេសីតិ យមេតំ បញ្ហំ អបុច្ឆិ ។

[៨៣] អជិត តំ វទាមិ តេតិ អជិតាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ តន្តិ បញ្ញញ្ច សតិញ្ច នាមរូបញ្ច ។ វទាមីតិ តំ វទាមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ អជិត តំ វទាមិ តេ ។

បពិត្រព្រះអង្គជានិរទុក្ខ បញ្ញា ១ សតិ ១ នាមនិងរូប ១ ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់សម្តែងប្រាប់នូវសេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គ តើធម៌នុ៎ះ រលត់ទៅក្នុងទីណា ។

[៨១] (ព្រះមានព្រះភាគត្រាស់ថា) ម្នាលអជិតៈ អ្នកបានសួរហើយនូវប្រស្នាណា តថាគតនឹងពោលនូវប្រស្នានោះដល់អ្នក នាមនិងរូប រលត់មិនមានសេសសល់ក្នុងទីណា នាមនិងរូបនុ៎ះរលត់ក្នុងទីនុ៎ះ ព្រោះកិរិយារលត់វិញ្ញាណ ។

[៨២] ពាក្យថា អ្នកបានសួរហើយ នូវប្រស្នាណា ត្រង់ពាក្យថា នូវប្រស្នាណា គឺ នូវបញ្ញា សតិនិងនាមរូប ។ ពាក្យថា បានសួរហើយ គឺសួរ សូម អារាធនា ជ្រះថ្លាហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកបានសួរហើយ នូវប្រស្នាណា ។

[៨៣] ពាក្យថា អជិតៈ នៃបទថា ម្នាលអជិតៈ តថាគតនឹងពោលប្រស្នានោះដល់អ្នក គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះចំណោះ ។ ពាក្យថា នូវប្រស្នានោះ គឺនូវបញ្ញាផង សតិផង នាមនិងរូបផង ។ ពាក្យថា នឹងពោល គឺ នឹងពោល ប្រាប់ សម្តែង បញ្ញត្តតាំងទុក ញែក ចែក ធ្វើឲ្យងាយ ប្រកាស នូវប្រស្នានោះ ហេតុនោះ(ទ្រង់ត្រាស់ថា) ម្នាលអជិតៈ តថាគត នឹងពោលនូវប្រស្នានោះដល់អ្នក ។

៣៣

## អជិតមាណវកប្បញ្ហានិទ្ទេសោ

[៨៤] យត្ថ នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតីតិ នាមន្តិ ចត្តារោ អរូបិនោ ខន្ធា ។ រូបន្តិ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ អសេសន្តិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ អសេសន្តិ ។ ឧបរុជ្ឈតីតិ និរុជ្ឈតិ វូបសមតិ អត្ថំ គច្ឆតិ បដិប្បស្សម្ភតីតិ យត្ថ នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតិ ។

[៨៥] វិញ្ញាណស្ស និរោធេន ឯត្ថេតំ ឧបរុជ្ឈតីតិ សោតាបត្តិមគ្គញាណេន អភិសង្ខារវិញ្ញាណស្ស និរោធេន សត្ត ភវេ ឋបេត្វា អនមតគ្គេ សំសារេ យេ ឧប្បជ្ជេយ្យុំ នាមញ្ច រូបញ្ច ឯត្ថេតេ និរុជ្ឈន្តិ វូបសមន្តិ អត្ថំ គច្ឆន្តិ បដិប្បស្សម្ភន្តិ ។ សកទាគាមិមគ្គញាណេន អភិសង្ខារវិញ្ញាណស្ស និរោធេន ទ្វេ ភវេ ឋបេត្វា បញ្ចសុ ភវេសុ យេ ឧប្បជ្ជេយ្យុំ នាមញ្ច រូបញ្ច ឯត្ថេតេ និរុជ្ឈន្តិ វូបសមន្តិ អត្ថំ គច្ឆន្តិ បដិប្បស្សម្ភន្តិ ។

អជិតមាណវកបញ្ហានិទ្ទេស

[៨៤] ពាក្យថា នាមនិងរូប រលត់ មិនមានសេសសល់ ក្នុងទីណា ត្រង់ពាក្យថា នាម បានដល់ អរូបក្ខន្ធ ៤ ។ ពាក្យថា រូប គឺ មហាភូតរូប ៤ និងរូបអាស្រ័យមហាភូតរូប ៤ ។ ពាក្យថា មិនមានសេសសល់ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនមានសេសសល់ រកសេសសល់គ្មាន ពាក្យថា មិនមានសេសសល់ នេះជាពាក្យរួមយក ។ ពាក្យថា រលត់ គឺរលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ហេតុនោះ (ទ្រង់ត្រាស់ថា) នាមនិងរូប រលត់ មិនមានសេសសល់ ក្នុងទីណា ។

[៨៥] ពាក្យថា នាមនិងរូបនុ៎ះ រលត់ ក្នុងទីនុ៎ះ ព្រោះកិរិយារលត់វិញ្ញាណ អធិប្បាយថា ធម៌ទាំងឡាយណា គឺនាមនិងរូប គប្បីកើតក្នុងសង្សារ មានទីបំផុតខាងដើម ដែលគេមិនអាចដឹងបាន វៀរលែងតែកំណើតប្រាំពីរចេញ ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងសោតាបត្តិមគ្គនុ៎ះ ព្រោះកិរិយារលត់ អភិសង្ខារវិញ្ញាណ[១] ដោយសោតាបត្តិមគ្គញ្ញាណ ។ ធម៌ទាំងឡាយណា គឺនាមនឹងរូប គប្បីកើតក្នុងកំណើតប្រាំ វៀរលែងតែកំណើតពីរ ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងសកទាគាមិមគ្គនុ៎ះ ព្រោះកិរិយា រលត់ អភិសង្ខារវិញ្ញាណ ដោយសកទាគាមិមគ្គញ្ញាណ ។

---

១ បានដល់ចិត្តដ៏សម្បយុត្ត ដោយកុសលាកុសលចេតនា ។ អដ្ឋកថា ។

អនាគាមិមគ្គញ្ញាណេន អភិសង្ខារវិញ្ញាណស្ស និរោធេន ឯកំ ភវំ ឋបេត្វា កាមធាតុយា វា រូបធាតុយា វា អរូបធាតុយា វា យេ ឧប្បជ្ជេយ្យុំ នាមញ្ច រូបញ្ច ឯត្ថេតេ និរុជ្ឈន្តិ វូបសមន្តិ អត្ថំ គច្ឆន្តិ បដិប្បស្សម្ភន្តិ ។ អរហត្តមគ្គញ្ញាណេន អភិសង្ខារវិញ្ញាណស្ស និរោធេន យេ ឧប្បជ្ជេយ្យុំ នាមញ្ច រូបញ្ច ឯត្ថេតេ និរុជ្ឈន្តិ វូបសមន្តិ អត្ថំ គច្ឆន្តិ បដិប្បស្សម្ភន្តិ ។ អរហតោ អនុបាទិសេសាយ បរិនិព្វានធាតុយា បរិនិព្វាយន្តស្ស បុរិមវិញ្ញាណស្ស និរោធេន បញ្ញា ច សតិ ច នាមញ្ច រូបញ្ច ឯត្ថេតេ និរុជ្ឈន្តិ វូបសមន្តិ អត្ថំ គច្ឆន្តិ បដិប្បស្សម្ភន្តីតិ វិញ្ញាណស្ស និរោធេន ឯត្ថេតំ ឧបរុជ្ឈតិ ។ តេនាហ ភគវា

យមេតំ បញ្ហំ អបុច្ឆិ អជិត តំ វទាមិ តេ
យត្ថ នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតិ
វិញ្ញាណស្ស និរោធេន ឯត្ថេតំ ឧបរុជ្ឈតីតិ ។

ធម៌ទាំងឡាយណា គឺនាមនិងរូប គប្បីកើតក្នុងកាមធាតុក្តី រូបធាតុក្តី អរូបធាតុក្តី វៀរលែងតែកំណើតមួយ ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងអនាគាមិមគ្គនុ៎ះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណ ដោយអនាគាមិមគ្គញ្ញាណ ។ ធម៌ទាំងឡាយណា គឺនាមនិងរូប គប្បីកើត ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងអរហត្តមគ្គនុ៎ះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណ ដោយអរហត្តមគ្គញ្ញាណ ។ ព្រះអរហន្ត កាលបរិនិព្វាន ដោយអនុបាទិសេសបរិនិព្វានធាតុ បញ្ញាផង សតិផង នាមនិងរូបផង ធម៌ទាំងនុ៎ះ តែងរលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងអរហត្តមគ្គនុ៎ះ ព្រោះកិរិយារលត់វិញ្ញាណមុន ហេតុនោះ (ទ្រង់ត្រាស់ថា) នាមនិងរូបនុ៎ះ រលត់ក្នុងទីនុ៎ះ ព្រោះកិរិយារលត់វិញ្ញាណ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ម្នាលអជិតៈ អ្នកបានសួរហើយ នូវប្រស្នាណា តថាគតនឹងពោលនូវប្រស្នានោះដល់អ្នក នាមនិងរូប រលត់មិនមានសេសសល់ ក្នុងទីណា នាមនិងរូបនុ៎ះ រលត់ក្នុងទីនុ៎ះ ព្រោះកិរិយារលត់វិញ្ញាណ ។

អជិតមាណវកប្បញ្ហានិទ្ទេសោ

[៨៦] យេ ច សង្ខាតធម្មា សេ យេ ច សេក្ខា បុថូ ឥធ តេសំ មេ និបកោ ឥរិយំ បុដ្ឋោ បព្រូហិ មារិស ។

[៨៧] យេ ច សង្ខាតធម្មា សេតិ សង្ខាតធម្មា វុច្ចន្តិ អរហន្តោ ខីណាសវា ។ កឹការណា សង្ខាតធម្មា វុច្ចន្តិ អរហន្តោ ខីណាសវា ។ តេ សង្ខាតធម្មា ញាតធម្មា តុលិតធម្មា តិរិតធម្មា វិភូតធម្មា វិភាវិតធម្មា សព្វេ សង្ខារា អនិច្ចាតិ សង្ខាតធម្មា ញាតធម្មា តុលិតធម្មា តិរិតធម្មា វិភូតធម្មា វិភាតធម្មា សព្វេ សង្ខារា ទុក្ខាតិ សង្ខាតធម្មា ។ បេ ។ សព្វេ ធម្មា អនត្តាតិ សង្ខាតធម្មា ។ បេ ។ អវិជ្ជាបច្ចយា សង្ខារាតិ សង្ខាតធម្មា ។ បេ ។

អជិតមាណវកប្បញ្ហានិទ្ទេស

[៨៦] (អជិតៈសួរថា) បុគ្គលទាំងឡាយណា មានធម៌ពិចារណាឃើញហើយ និងបុគ្គលទាំងឡាយណា ជាសេក្ខៈ មានប្រមាណច្រើន ក្នុងទីនេះ បពិត្រព្រះអង្គនិរទុក្ខ ព្រះអង្គជាបុគ្គលមានបញ្ញាចាស់ក្លា ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់ត្រាស់ ប្រាប់នូវសេចក្តីប្រព្រឹត្ត របស់បុគ្គលទាំងឡាយនោះ ដល់ខ្ញុំព្រះអង្គ ។

[៨៧] ពាក្យថា បុគ្គលទាំងឡាយណា មានធម៌ពិចារណាឃើញហើយ អធិប្បាយថា អរហន្តខីណាស្រពទាំងឡាយ លោកហៅថា អ្នកមានធម៌ពិចារណាឃើញហើយ ។ ព្រោះហេតុអ្វី អរហន្តខីណាស្រពទាំងឡាយ លោកហៅថា អ្នកមានធម៌ពិចារណាឃើញហើយ ។ អរហន្តខីណាស្រពទាំងនោះ មានធម៌ពិចារណាឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ពិនិត្យហើយ មានធម៌ប្រាកដហើយ មានធម៌ចម្រើនច្បាស់ហើយ គឺមានធម៌ពិចារណាឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ពិនិត្យហើយ មានធម៌ប្រាកដហើយ មានធម៌ចម្រើនច្បាស់ហើយថា សង្ខារទាំងពួង មិនទៀង មានធម៌ពិចារណាឃើញហើយ ។ បេ ។ ថា សង្ខារទាំងពួង ជាទុក្ខ មានធម៌ពិចារណាឃើញហើយ ។ បេ ។ ថា ធម៌ទាំងពួង ជាអនត្តា មានធម៌ពិចារណាឃើញហើយ ។ បេ ។

យត្ថិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ សង្ខាតធម្មា ញាតធម្មា តុលិតធម្មា តីរិតធម្មា វិភូតធម្មា វិភាវិតធម្មា អថវា តេសំ ខន្ធា សង្ខាតា ធាតុយោ សង្ខាតា អាយតនានិ សង្ខាតានិ គតិយោ សង្ខាតា ឧបបត្តិយោ សង្ខាតា បដិសន្ធិយោ សង្ខាតា ភវា សង្ខាតា សំសារា សង្ខាតា វដ្ដា សង្ខាតា ។ អថវា តេ ខន្ធបរិយន្តេ ឋិតា ធាតុបរិយន្តេ ឋិតា អាយតនបរិយន្តេ ឋិតា គតិបរិយន្តេ ឋិតា ឧបបត្តិបរិយន្តេ ឋិតា បដិសន្ធិបរិយន្តេ ឋិតា ភវបរិយន្តេ ឋិតា សំសារបរិយន្តេ ឋិតា វដ្ដបរិយន្តេ ឋិតា អន្តិមភវេ ឋិតា អន្តិមសមុស្សយេ ឋិតា អន្តិមទេហធរា អរហន្តោ ។

តេសំ ចាយំ បច្ឆិមកោ ចរិមោយំ សមុស្សយោ
ជាតិមរណសំសារោ នត្ថិ នេសំ បុនព្ភវោតិ ។

ថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ មានធម៌ពិចារណាឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ពិនិត្យហើយ មានធម៌ប្រាកដហើយ មានធម៌ចម្រើនច្បាស់ហើយថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ មួយទៀតថា ព្រះអរហន្តទាំងនោះ មានខន្ធពិចារណាឃើញហើយ មានធាតុពិចារណាឃើញហើយ មានអាយតនៈពិចារណាឃើញហើយ មានគតិពិចារណាឃើញហើយ មានឧបបត្តិពិចារណាឃើញហើយ មានបដិសន្ធិពិចារណាឃើញហើយ មានភពពិចារណាឃើញហើយ មានសង្សារពិចារណាឃើញហើយ មានវដ្តៈពិចារណាឃើញហើយ ។ មួយទៀតថា ព្រះអរហន្តខីណាស្រពទាំងឡាយនោះ តាំងនៅក្នុងទីបំផុតខន្ធ តាំងនៅក្នុងទីបំផុតធាតុ តាំងនៅក្នុងទីបំផុតអាយតនៈ តាំងនៅក្នុងទីបំផុតគតិ តាំងនៅក្នុងទីបំផុតឧបបត្តិ តាំងនៅក្នុងទីបំផុតបដិសន្ធិ តាំងនៅក្នុងទីបំផុតភព តាំងនៅក្នុងទីបំផុតសង្សារ តាំងនៅក្នុងទីបំផុតវដ្តៈ តាំងនៅក្នុងភពជាទីបំផុត តាំងនៅក្នុងសរីរៈជាទីបំផុត មានកិរិយាទ្រទ្រង់នូវរាងកាយជាទីបំផុត ។

នេះ រាងកាយ ជាទីបំផុត នេះរាងកាយខាងក្រោយរបស់
ព្រះអរហន្តទាំងនោះ ការអន្ទោលទៅកាន់ជាតិនិងមរណៈ
និងការកើតក្នុងភពថ្មី របស់ព្រះអរហន្តទាំងនោះមិនមានទេ ។

តំការណា សង្ខាតធម្មា វុច្ចន្តិ អរហន្តោ ខីណាសវាតិ យេ ច សង្ខាតធម្មា សេ ។

[៨៨] យេ ច សេក្ខា បុថូ ឥធាតិ សេក្ខាតិ កឹការណា វុច្ចន្តិ សេក្ខា ។ សិក្ខន្តីតិ សេក្ខា ។ កឹ សិក្ខន្តិ ។ អធិសីលម្បិ សិក្ខន្តិ អធិចិត្តម្បិ សិក្ខន្តិ អធិប្បញ្ញម្បិ សិក្ខន្តិ ។

កតមា ច អធិសីលសិក្ខា ។ ឥធ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោ-ចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ខុទ្ទកោបិ សី-លក្ខន្ធោ មហន្តោបិ សីលក្ខន្ធោ សីលំ បតិដ្ឋា អាវរណំ សំយមោ សំវរោ មុខំ បមុខំ កុសលានំ ធម្មានំ សមាបត្តិយា អយំ អធិសីលសិក្ខា ។

កតមា ច អធិចិត្តសិក្ខា ។ ឥធ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ អធិចិត្តសិក្ខា ។

ហេតុនោះ ព្រះអរហន្តខីណាស្រពទាំងឡាយ លោកហៅថា អ្នកមានធម៌ពិចារណាឃើញហើយ ហេតុនោះ លោកសួរថា បុគ្គលទាំងឡាយណា មានធម៌ពិចារណាឃើញហើយ ។

[៨៨] អធិប្បាយពាក្យថា បុគ្គលទាំងឡាយណា ជាសេក្ខៈមានប្រមាណច្រើនក្នុងទីនេះ បុច្ឆាត្រង់ពាក្យថា សេក្ខបុគ្គលទាំងឡាយដែលលោកហៅថា សេក្ខៈ ព្រោះហេតុអ្វី ។ ឈ្មោះថា សេក្ខៈព្រោះនៅសិក្សា ។ នៅសិក្សាអ្វី ។ នៅសិក្សាអធិសីលខ្លះ សិក្សាអធិចិត្តខ្លះ សិក្សាអធិប្បញ្ញាខ្លះ ។

អធិសីលសិក្ខា តើដូចម្ដេច ។ ភិក្ខុ ក្នុងធម្មវិន័យនេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរសីល បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យ ក្នុងទោសបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ សីលក្ខន្ធតូចក្ដី សីលក្ខន្ធធំក្ដី សីលជាទីពឹង ជាគ្រឿងរារាំង ជាការសង្រួម ជាការបិទ ជាប្រធាន ជាប្រមុខនៃការបាននូវកុសលធម៌ទាំងឡាយ នេះជា អធិសីលសិក្ខា ។

អធិចិត្តសិក្ខា តើដូចម្ដេច ។ ភិក្ខុ ក្នុងធម្មវិន័យនេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលបឋមជ្ឈានប្រកបដោយវិតក្កៈ វិចារៈ និងបីតិ សុខៈ ដែលកើតអំពីវិវេក ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន នេះជា អធិចិត្តសិក្ខា ។

៣៨



កតមា ច អធិប្បញ្ញាសិក្ខា ។ ឥធ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ អយំ ទុក្ខនិរោធោតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ អយំ អាសវសមុទយោតិ អយំ អាសវនិរោធោតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ អយំ អធិប្បញ្ញាសិក្ខា ។

ឥមា តិស្សោ សិក្ខា អាវជ្ជេន្តា សិក្ខន្តិ ជានន្តា សិក្ខន្តិ ចិត្តំ អធិដ្ឋហន្តា សិក្ខន្តិ សទ្ធាយ អធិមុច្ចន្តា សិក្ខន្តិ វីរិយំ បគ្គណ្ហន្តា សិក្ខន្តិ សតឹ ឧបដ្ឋបេន្តា សិក្ខន្តិ ចិត្តំ សម្មាទហន្តា សិក្ខន្តិ បញ្ញាយ បជានន្តា សិក្ខន្តិ អភិញ្ញេយ្យំ អភិជានន្តា សិក្ខន្តិ បរិញ្ញេយ្យំ បរិជានន្តា សិក្ខន្តិ បហាតព្វំ បជហន្តា សិក្ខន្តិ ភាវេតព្វំ ភាវេន្តា សិក្ខន្តិ សច្ឆិកាតព្វំ សច្ឆិករោន្តា សិក្ខន្តិ ចរន្តិ អាចរន្តិ សមាចរន្តិ សមាទាយ វត្តន្តិ តំការណា វុច្ចន្តិ សេក្ខា ។

អធិប្បញ្ញាសិក្ខា តើដូចម្តេច ។ ភិក្ខុ ក្នុងធម្មវិន័យនេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ទៅក្នុងសេចក្តីចម្រើននិងសេចក្តីវិនាស ជាប្រាជ្ញាដ៏ប្រសើរ ចាក់ធ្លុះដល់នូវសេចក្តីអស់ទុក្ខដោយប្រពៃ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុឲ្យកើតទុក្ខ នេះសេចក្តីរលត់ទុក្ខ នេះបដិបទាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះអាសវៈ នេះហេតុឲ្យកើតអាសវៈ នេះសេចក្តីរលត់អាសវៈ នេះបដិបទាដំណើរទៅកាន់ទីរលត់អាសវៈ នេះជា អធិប្បញ្ញាសិក្ខា ។

សេក្ខបុគ្គលទាំងឡាយ ពិចារណាសិក្សាសិក្ខាទាំង ៣ នេះ ដឹងសិក្សា តាំងចិត្តសិក្សា ចុះចិត្តស៊ប់ដោយសទ្ធាសិក្សា ផ្គងព្យាយាមសិក្សា តាំងសតិសិក្សា តាំងចិត្ត ដោយប្រពៃសិក្សា ដឹងច្បាស់ ដោយបញ្ញាសិក្សា ដឹងប្រាកដនូវធម៌ ដែលគួរដឹងប្រាកដសិក្សា កំណត់ដឹងធម៌ដែលគួរកំណត់ដឹងសិក្សា លះបង់ធម៌ដែលគួរលះបង់សិក្សា ចម្រើនធម៌ដែលគួរចម្រើនសិក្សា ធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា ប្រព្រឹត្ត ប្រព្រឹត្តដោយគោរព ប្រព្រឹត្តដោយប្រពៃសមាទាន ប្រព្រឹត្ត ហេតុនោះ ទើបលោកហៅថា សេក្ខៈ ។

៣៩

អជិតមាណវកប្បញ្ហានិទ្ទេសោ

បុថូតិ ពហុកា ឯតេ សេក្ខា សោតាបន្នា ច បដិបន្នា ច សកទាគាមិនោ ច បដិបន្នា ច អនាគាមិនោ ច បដិបន្នា ច អរហត្តា ច បដិបន្នា ច ។ ឥធាតិ ឥមិស្សា ទិដ្ឋិយា ឥមិស្សា ខន្តិយា ឥមិស្សា រុចិយា ឥមស្មឹ អាទាយេ ឥមស្មឹ វិនយេ ឥមស្មឹ ធម្មេ ឥមស្មឹ ធម្មវិនយេ ឥមស្មឹ បាវចនេ ឥមស្មឹ ព្រហ្មចរិយេ ឥមស្មឹ សត្ថុសាសនេ ឥមស្មឹ អត្តភាវេ ឥមស្មឹ មនុស្សលោកេតិ យេ ច សេក្ខា បុថូ ឥធ ។

[៨៩] តេសំ មេ និបកោ ឥរិយំ បុដ្ឋោ បព្រូហិ មារិសាតិ ត្វំបិ និបកោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី តេសំ សង្ខាតធម្មានញ្ច សេក្ខានញ្ច ឥរិយំ ចរិយំ វុត្តឹ អាចារំ គោចរំ វិហារំ បដិបទំ ។

ពាក្យថា មានប្រមាណច្រើន សេក្ខបុគ្គលទាំងឡាយនុ៎ះ មានប្រមាណច្រើន គឺសោតាបន្នបុគ្គល ១ បុគ្គលប្រតិបត្តិ (ដើម្បីសោតៈ ១) សកទាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិ (ដើម្បីសកទាគាមិ ១) អនាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិ (ដើម្បីអនាគាមិ ១) អរហន្ត ១ បុគ្គលប្រតិបត្តិ (ដើម្បីព្រះអរហត្ត ១) ។ ពាក្យថា ក្នុងទីនេះ គឺក្នុងទិដ្ឋិនេះ ក្នុងការគួរនេះ ក្នុងសេចក្តីគាប់ចិត្តនេះ ក្នុងសេចក្តីប្រកាន់នេះ ក្នុងវិន័យនេះ ក្នុងធម៌នេះ ក្នុងធម្មវិន័យនេះ ក្នុងសាសនានេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសត្ថុសាសនានេះ ក្នុងអត្តភាពនេះ ក្នុងមនុស្សលោកនេះ ហេតុនោះ(លោកសួរថា) បុគ្គលទាំងឡាយណា ជាសេក្ខៈ មានប្រមាណច្រើន ក្នុងទីនេះ ។

[៨៩] ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ ព្រះអង្គជាបុគ្គលមានបញ្ញាចាស់ក្លា ខ្ញុំព្រះអង្គសួរហើយ សូមព្រះអង្គត្រាស់សម្តែង សេចក្តីប្រព្រឹត្តរបស់បុគ្គលទាំងឡាយនោះ ដល់ខ្ញុំព្រះអង្គ សេចក្តីថា ព្រះអង្គជាបុគ្គលមានបញ្ញាចាស់ក្លា ជាបណ្ឌិតមានបញ្ញា មានបញ្ញាជាគ្រឿងត្រាស់ដឹង មានញាណ មានបញ្ញា ជាគ្រឿងជ្រាបច្បាស់ មានបញ្ញាជាគ្រឿងទម្លាយកិលេស (សូមទ្រង់ត្រាស់ប្រាប់) នូវសេចក្តីប្រព្រឹត្ត ចរិយា ការប្រព្រឹត្ត មារយាទ គោចរ ឥរិយាបថ បដិបទានៃអរហន្តនិងសេក្ខបុគ្គលទាំងឡាយនោះ ដល់ខ្ញុំព្រះអង្គ ។

បុដ្ឋោតិ បុដ្ឋោ បុច្ឆិតោ យាចិតោ អជ្ឈេ-សិតោ បសាទិតោ ។ បព្រូហីតិ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហិ ។ មារិសាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ មារិសាតិ តេសំ មេ និបកោ ឥរិយំ បុដ្ឋោ បព្រូ-ហិ មារិស ។ តេនាហ សោ ព្រាហ្មណោ

យេ ច សង្ខាតធម្មា សេ យេ ច សេក្ខា បុថូ ឥធ
តេសំ មេ និបកោ ឥរិយំ បុដ្ឋោ បព្រូហិ មារិសាតិ ។

[៩០] កាមេសុ នាភិគិជ្ឈេយ្យ មនសានាវិលោ សិយា
កុសលោ សព្វធម្មានំ សតោ ភិក្ខុ បរិព្វជេ ។

សួរហើយ គឺសួរ ដណ្ដឹង សូមអារាធនា ជ្រះថ្លាហើយ ។ ពាក្យថា សូមទ្រង់ ត្រាស់ប្រាប់ គឺសូមទ្រង់ពោល ត្រាស់បញ្ចេញ សម្ដែង បញ្ញត្ត តាំងទុក វែកញែក បែក ធ្វើឲ្យរាយ ប្រកាស ។ ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះជាពាក្យ ជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះជាពាក្យពោល ដោយគោរព កោតក្រែង ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គនិរទុក្ខ ព្រះអង្គជា បុគ្គលមានបញ្ញាចាស់ក្លា ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់ត្រាស់ប្រាប់ សេចក្ដីប្រព្រឹត្ត នៃបុគ្គលទាំងឡាយនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុ នោះ ព្រាហ្មណ៍នោះ ពោលថា

បុគ្គលទាំងឡាយ មានធម៌ពិចារណាឃើញហើយ និង
បុគ្គលទាំងឡាយណា ជាសេក្ខៈ មានប្រមាណច្រើន
ក្នុងទីនេះ បពិត្រព្រះអង្គនិរទុក្ខ ព្រះអង្គជាបុគ្គលមានបញ្ញា
ចាស់ក្លា ខ្ញុំព្រះអង្គសួរហើយ សូមទ្រង់ត្រាស់ប្រាប់សេចក្ដី
ប្រព្រឹត្ត នៃបុគ្គលទាំងឡាយនោះ ដល់ខ្ញុំព្រះអង្គ ។

[៩០] (ព្រះមានព្រះភាគត្រាស់ថា) បុគ្គលមិនគប្បីប្រាថ្នាក្នុងកាម
ទាំងឡាយ មិនគប្បីធ្វើចិត្តឲ្យល្អក់ ជាបុគ្គលឈ្លាសវៃ ក្នុង
ធម៌ទាំងពួង គប្បីប្រព្រឹត្ត មានសតិ ជាភិក្ខុ ។

## អជិតមាណវកប្បញ្ហានិទ្ទេសោ

[៩១] កាមេសុ នាភិគិជ្ឈេយ្យាតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។

កតមេ វត្ថុកាមា ។ មនាបិកា រូបា មនាបិកា សទ្ទា មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា អត្ថរណា បាវុរណា ទាសីទាសា អជេឡកា កុក្កុដសូករា ហត្ថិគវាស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញំ សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច យង្កិញ្ចិ រជនីយវត្ថុ វត្ថុកាមា ។ អបិច អតីតា កាមា អនាគតា កាមា បច្ចុប្បន្នា កាមា អជ្ឈត្តា កាមា ពហិទ្ធា កាមា អជ្ឈត្តពហិទ្ធា កាមា ហីនា កាមា មជ្ឈិមា កាមា បណីតា កាមា អាបាយិកា កាមា មានុសិកា កាមា ទិព្វា កាមា បច្ចុបដ្ឋិតា កាមា និម្មិតា កាមា បរនិម្មិតា កាមា បរិគ្គហិតា កាមា អបរិគ្គហិតា កាមា មមាយិតា កាមា អមមាយិតា កាមា សព្វេបិ កាមាវចរា ធម្មា សព្វេបិ រូបាវចរា ធម្មា សព្វេបិ អរូបាវចរា ធម្មា តណ្ហាវត្ថុកា តណ្ហារម្មណា កាមនីយដ្ឋេន រជនីយដ្ឋេន មទនីយដ្ឋេន កាមា ឥមេ វុច្ចន្តិ វត្ថុកាមា ។

[៩១] អធិប្បាយពាក្យថា បុគ្គល មិនគប្បីប្រាថ្នា ក្នុងកាមទាំង-ឡាយ ត្រង់ពាក្យថា កាម បើតាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។

វត្ថុកាម តើដូចម្តេច ។ រូបជាទីគាប់ចិត្ត សំឡេងជាទីគាប់ចិត្ត ក្លិនជាទីគាប់ចិត្ត រសជាទីគាប់ចិត្ត ផ្សព្វជាទីគាប់ចិត្ត កម្រាល គ្រឿងស្លៀកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោសេះឈ្មោល-ញី ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជ-ធានី ដែន ជនបទ សេនានិករ ឃ្លាំង វត្ថុជាទីតាំងនៃសេចក្តីត្រេកអរណាមួយ ឈ្មោះថា វត្ថុកាម ។ មួយទៀត កាមជាអតីត កាមជាអនាគត កាមជាបច្ចុប្បន្ន កាមខាងក្នុង កាមខាងក្រៅ កាមទាំងខាងក្នុងទាំងខាងក្រៅ កាមថោកទាប កាមយ៉ាងកណ្តាល កាមខ្ពង់ខ្ពស់ កាមប្រព្រឹត្តទៅក្នុងអបាយ កាមជារបស់មនុស្ស កាមជាទិព្វ កាមដែលតាំងឡើងឯង កាមដែលនិម្មិត កាមដែលបុគ្គលដទៃនិម្មិត កាមដែលហួងហែង កាមដែលមិនហួងហែង កាមដែលរាប់អាន កាមដែលមិនរាប់អាន ធម៌ជាកាមាវចរទាំងអស់ក្តី ធម៌ជារូបាវចរទាំងអស់ក្តី ធម៌ជាអរូបាវចរទាំងអស់ក្តី ជាវត្ថុនៃតណ្ហា ជាអារម្មណ៍នៃតណ្ហា ឈ្មោះថាកាម ដោយសេចក្តីថា គប្បីប្រាថ្នា ដោយសេចក្តីថា គប្បីត្រេកអរ ដោយសេចក្តីថា គប្បីស្រវឹង ទាំងនេះ លោកហៅថា វត្ថុកាម ។

កតមេ កិលេសកាមា ។ ឆន្ទោ កាមោ រាគោ កាមោ ឆន្ទរាគោ កាមោ សង្កប្បោ កាមោ រាគោ កាមោ សង្កប្បរាគោ កាមោ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទិ កាមតណ្ហា កាមសិនេហោ កាមបិបាសា កាមបរិឡាហោ កាមគេធោ កាមមុច្ឆា កាមជ្ឈោសានំ កាមោឃោ កាមយោគោ កាមុបាទានំ កាមច្ឆន្ទនីវរណំ ។

អទ្ទសំ កាម តេ មូលំ សង្កប្បា កាម ជាយសិ
ន តំ សង្កប្បយិស្សាមិ ឯវំ កាម ន ហេហិសីតិ ។

ឥមេ វុច្ចន្តិ កិលេសកាមា ។ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ កាមេសុ ជាភិគិជ្ឈេយ្យាតិ កិលេសកាមេសុ វត្ថុកាមេសុ ជាភិគិជ្ឈេយ្យ ន បលិពុជ្ជេយ្យ អគិទ្ធោ[១] អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ វីតគេធោ[២] ចត្តគេធោ វន្តគេធោ មុត្តគេធោ បហីនគេធោ បដិនិស្សដ្ឋគេធោ វីតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ

១ ម. អគិទ្ធោ អស្ស ។ ២ ម. វិគតគេធោ វិគតគេធោ ។

កិលេសកាម តើដូចម្តេច ។ ចំណង់ឈ្មោះថា កាម តម្រេកឈ្មោះថា កាម ចំណង់និងតម្រេក ឈ្មោះថា កាម តម្រិះឈ្មោះថា កាម តម្រេកឈ្មោះថា កាម តម្រិះនិងតម្រេក ឈ្មោះថា កាម បានដល់ចំណង់ គឺកាមក្នុងកាមទាំងឡាយ តម្រេកគឺកាម សេចក្តីរីករាយគឺកាម តណ្ហាគឺកាម សេចក្តីស្នេហាគឺកាម សេចក្តីស្រេកឃ្លានគឺកាម សេចក្តីអន្ទះអន្ទែង គឺកាម សេចក្តីប្រាថ្នាគឺកាម សេចក្តីជ្រប់គឺកាម កិរិយាលង់ចុះគឺ កាម អន្ទង់គឺកាម គ្រឿងប្រកបគឺកាម សេចក្តីប្រកាន់គឺកាម នីវរណៈគឺកាមច្ឆន្ទៈ ។

ម្នាលកាម តថាគតឃើញ ទីតាំងរបស់អ្នកហើយ ម្នាល
កាម អ្នកកើតអំពីសេចក្តីត្រិះរិះ តថាគត នឹងលែងត្រិះរិះ
រកអ្នក ម្នាលកាម អ្នកនឹងមិនមានដោយប្រការយ៉ាងនេះ ។

ពួកនេះ លោកហៅថា កិលេសកាម ។ តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានខាង តម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា បុគ្គលមិនគប្បីប្រាថ្នា ក្នុងកាមទាំងឡាយ បានសេចក្តីថា បុគ្គលមិនគប្បីប្រាថ្នា មិនគប្បីជាប់នៅ ក្នុងកិលេសកាម និងវត្ថុកាមទាំងឡាយ គឺជាអ្នកមិនប្រាថ្នា មិនលង់ចុះ មិនជ្រប់ មិនជប់ ប្រាសចាកប្រាថ្នា ចោលប្រាថ្នា ខ្ជាក់ប្រាថ្នា លែងប្រាថ្នា លះប្រាថ្នា លះចោលប្រាថ្នា ប្រាសចាករាគៈ ចោលរាគៈ ខ្ជាក់រាគៈ លែងរាគៈ លះរាគៈ រលាស់ចោលរាគៈ ចេញចាកតណ្ហា

អជិតមាណវកប្បញ្ហានិទ្ទេសោ

និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរេយ្យាតិ កាមេសុ នាភិគិជ្ឈេយ្យ ។

[៩២] មនសានាវិលោ សិយាតិ មនោតិ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ[១] មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ[២] មនោវិញ្ញាណធាតុ ។ កាយទុច្ចរិតេន ចិត្តំ អាវិលំ ហោតិ លុឡិតំ ឯរិតំ ឃដ្ដិតំ ចលិតំ ភន្តំ អវូបសន្តំ វចីទុច្ចរិតេន មនោទុច្ចរិតេន រាគេន ទោសេន មោហេន កោធេន ឧបនាហេន មក្ខេន បឡាសេន ឥស្សាយ មច្ឆរិយេន មាយាយ សាឋេយ្យេន ថម្ភេន សារម្ភេន មានេន អតិមានេន មទេន បមាទេន សព្វកិលេសេហិ សព្វទុច្ចរិតេហិ សព្វទរថេហិ សព្វបរិឡាហេហិ សព្វសន្តាបេហិ សព្វាកុសលាភិសង្ខារេហិ ចិត្តំ អាវិលំ ហោតិ លុឡិតំ ឯរិតំ ឃដ្ដិតំ ចលិតំ ភន្តំ អវូបសន្តំ ។

១ ម. បណ្ឌរំ មនោ ។ ២ ម. ឯត្ថន្តរេ តជ្ជំ ។

មានសភាពរលត់ មានត្រជាក់កើតហើយ មានកិរិយាបានចំពោះនូវសុខ គប្បីនៅដោយខ្លួនដ៏ប្រសើរ ហេតុនោះទ្រង់ត្រាស់ថា បុគ្គលមិនគប្បីប្រាថ្នា ក្នុងកាមទាំងឡាយ ។

[៩២] អធិប្បាយពាក្យថា មិនគប្បីធ្វើចិត្តឲ្យល្អក់ ត្រង់ពាក្យថា ចិត្ត បានដល់ធម្មជាតសម្រាប់ត្រិះរិះ សម្រាប់ដឹង សម្រាប់ប្រាថ្នា ហទ័យ ភវង្គចិត្ត មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ។ ចិត្ត ជាធម្មជាតល្អក់ រឹកររ ញាប់ញ័រ ចង្អៀតចង្អល់ ឃ្លេងឃ្លោង ភ្ញាក់ផ្អើល មិនស្ងប់ ដោយកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រាគៈ ទោសៈ មោហៈ ក្រោធ ការចងក្រោធទុក ការលុបលាងគុណ ការវាយឫកស្មើ សេចក្តីឈ្នានីស សេចក្តីកំណាញ់ ការលាក់ពុត ការអួតអាង ការចចេស ការប្រណាំងវាសនា មានះ ការមើលងាយ សេចក្តីស្រវឹង និងសេចក្តីប្រហែស ចិត្តនោះ ជាធម្មជាតល្អក់ រឹកររ ញាប់ញ័រ ចង្អៀតចង្អល់ ឃ្លេងឃ្លោង ភ្ញាក់ផ្អើល មិនស្ងប់ ដោយកិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួង ។

មនសានាវិលោ សិយាតិ ចិត្តេន អនាវិលោ សិយា អលុឡិតោ អនេរិតោ អឃដ្ដិតោ អចលិតោ អភន្តោ វូបសន្តោ អាវិលករេ កិលេសេ ជហេយ្យ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យ អាវិល-ករេហិ កិលេសេហិ ច អារតោ វិរតោ[៣] បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វូបសន្តោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរេយ្យាតិ មនសានា-វិលោ សិយា ។

[៩៣] កុសលោ សព្វធម្មានន្តិ សព្វេ សង្ខារា អនិច្ចាតិ កុសលោ សព្វធម្មានំ សព្វេ សង្ខារា ទុក្ខាតិ កុសលោ សព្វធម្មានំ សព្វេ ធម្មា អ-នត្តាតិ កុសលោ សព្វធម្មានំ អវិជ្ជាបច្ចយា សង្ខា-រាតិ កុសលោ សព្វធម្មានំ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ កុសលោ សព្វធម្មានំ ឯវម្បិ កុសលោ សព្វធម្មានំ ។

---

៣ ម. អស្ស វិរតោ ។

ពាក្យថា មិនគប្បីធ្វើចិត្តឲ្យល្អក់ បានន័យថា មិនគប្បីមានចិត្តល្អក់ មិនរឹករវ មិនញាប់ញ័រ មិនចង្អៀតចង្អល់ មិនឃ្វេងឃ្វាង មិនភ្ញាក់ផ្អើល ស្ងប់ គប្បីលះបង់ លះបង់ផ្តាច់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពនូវកិលេសទាំងឡាយជាគ្រឿងធ្វើឲ្យល្អក់ មួយទៀត ជាបុគ្គលធ្លាយ វៀរ វៀរស្រឡះ ចេញផុត ស្ងប់ រួចស្រឡះ ប្រកបប្រាស ចាកកិលេសទាំងឡាយជាគ្រឿងធ្វើឲ្យល្អក់ គប្បីទៅដោយចិត្តប្រាសចាកសេចក្តីសល់រំលល់ (ហេតុនោះទ្រង់ត្រាស់ថា) មិនគប្បីធ្វើចិត្តឲ្យល្អក់ ។

[៩៣] ពាក្យថា ឈ្វាសវៃក្នុងធម៌ទាំងពួង អធិប្បាយថា ឈ្វាសវៃក្នុងធម៌ទាំងពួងថា សង្ខារទាំងពួងមិនទៀង ឈ្វាសវៃក្នុងធម៌ទាំងពួងថា សង្ខារទាំងពួងជាទុក្ខ ឈ្វាសវៃក្នុងធម៌ទាំងពួងថា ធម៌ទាំងពួងជាអនត្តា ឈ្វាសវៃក្នុងធម៌ទាំងពួងថា សង្ខារទាំងឡាយ (មាន) ព្រោះអវិជ្ជាជាបច្ច័យ ។ បេ ។ ឈ្វាសវៃក្នុងធម៌ទាំងពួងថា ធម្មជាតណាមួយ មានសភាពកើតឡើង ធម្មជាតទាំងអស់នោះ មានសភាពរលត់ទៅជាធម្មតា បុគ្គលឈ្វាសវៃក្នុងធម៌ទាំងពួង យ៉ាងនេះឯង ។

៤៨

អជិតមាណវកប្បញ្ហានិទ្ទេសោ

អថវា អនិច្ចតោ កុសលោ សព្វធម្មានំ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ ឦតិតោ ឧបទ្ទវតោ អសាតតោ ភយតោ ឧបសគ្គតោ ចលតោ បភង្គុតោ អទ្ធុវតោ អតាណតោ អលេណតោ អសរណតោ អសរណីភូតតោ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ អាទីនវតោ វិបរិណាមធម្មតោ អសារកតោ អឃមូលតោ វធកតោ វិភវតោ សាសវតោ សង្ខតតោ មារាមិសតោ ជាតិធម្មតោ ជរាធម្មតោ ព្យាធិធម្មតោ មរណធម្មតោ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មតោ សង្កិលេសធម្មតោ សមុទយតោ អត្ថង្គមតោ អនស្សាទតោ[១] អាទីនវតោ អនិស្សរណតោ កុសលោ សព្វធម្មានំ ឯវម្បិ កុសលោ សព្វធម្មានំ ។ អថវា ខន្ធកុសលោ ធាតុកុសលោ អាយតនកុសលោ បដិច្ចសមុប្បាទកុសលោ សតិបដ្ឋានកុសលោ សម្មប្បធានកុសលោ ឥទ្ធិបាទកុសលោ ឥន្ទ្រិយកុសលោ ពលកុសលោ ពោជ្ឈង្គកុសលោ មគ្គកុសលោ ផលកុសលោ និព្វានកុសលោ ឯវម្បិ កុសលោ សព្វធម្មានំ ។

---

១ ម. អស្សាទតោ ។

មួយទៀតឈ្លាសវៃក្នុងធម៌ទាំងពួង ថាមិនទៀង ថាជាទុក្ខ ជារោគ ជាបូស ជាសរ ជាអន្តរាយ ជាជំងឺ ជារបស់ដទៃ ជារបស់វិនាស ជាចង្រៃ ជាឧបទ្រព ជារបស់មិនគួរប្រាថ្នា ជាភ័យ ជាឧបសគ្គ ជារបស់ញាប់ញ័រ ជារបស់ពុករលួយ ជារបស់មិនឋិតថេរ ជារបស់ពឹងមិនបាន ជារបស់ពួនមិនបាន ជារបស់មិនមែនជាទីរឭក ជារបស់សង្ឃឹមមិនបាន ជារបស់ឥតអំពើ ជារបស់ទទេ ជារបស់សូន្យ ជារបស់មិនមែនខ្លួន ជាទោស ជារបស់តែងប្រែប្រួល ជារបស់ឥតខ្លឹម ជាទីតាំងនៃទុក្ខ ជាអ្នកសម្លាប់ ជារបស់ប្រាសចាកសេចក្ដីចម្រើន ជារបស់ប្រកបដោយអាសវៈ ជារបស់ដែលបច្ច័យតាក់តែង ជានុយរបស់មារ ជារបស់មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានមរណៈជាធម្មតា មានសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្ដីតានតឹងជាធម្មតា មានគ្រឿងសៅហ្មងជាធម្មតា មានការកើត មានការវិនាស មានសភាពមិនគួរជ្រះថ្លាជាទោស មានការរើចេញមិនបាន បុគ្គលឈ្លាសវៃក្នុងធម៌ទាំងពួង យ៉ាងនេះឯង ។ មួយទៀត ឈ្លាសវៃក្នុងខន្ធ ឈ្លាសវៃក្នុងធាតុ ឈ្លាសវៃក្នុងអាយតនៈ ឈ្លាសវៃក្នុងបដិច្ចសមុប្បាទ ឈ្លាសវៃក្នុងសតិប្បដ្ឋាន ឈ្លាសវៃ ក្នុងសម្មប្បធាន ឈ្លាសវៃក្នុងឥទ្ធិបាទ ឈ្លាសវៃក្នុងឥន្ទ្រិយ ឈ្លាសវៃក្នុងពលៈ ឈ្លាសវៃក្នុងពោជ្ឈង្គ ឈ្លាសវៃក្នុងមគ្គ ឈ្លាសវៃក្នុងផល ឈ្លាសវៃក្នុងនិព្វាន បុគ្គលជាអ្នកឈ្លាសវៃក្នុងធម៌ទាំងពួងយ៉ាងនេះឯង ។

អថវា សព្វធម្មា វុច្ចន្តិ ទ្វាទសាយតនានិ ចក្ខុ ចេវ រូបា ច សោតញ្ច សទ្ទា ច ឃានញ្ច គន្ធា ច ជិវ្ហា ច រសា ច កាយោ ច ផោដ្ឋព្វា ច មនោ ច ធម្មា ច ។ យតោ ច អជ្ឈត្តិកពាហិរេសុ អាយតនេសុ រាគោ[១] បហី- នោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភា- វង្គតោ អាយតឹ អនុប្បាទធម្មោ ឯត្តាវតាបិ កុសលោ សព្វធម្មានន្តិ កុសលោ សព្វធម្មានំ ។

[៩៤] សតោ ភិក្ខុ បរិព្វជេតិ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិ- បដ្ឋានំ ភាវេន្តោ សតោ វេទនាសុ វេទនានុបស្ស- នាសតិបដ្ឋានំ ភាវេន្តោ សតោ ចិត្តេ ចិត្តានុបស្ស- នាសតិបដ្ឋានំ ភាវេន្តោ សតោ ធម្មេសុ ធម្មានុ- បស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ ។ អប- រេហិបិ ចតូហិ ការណេហិ សតោ អសតិបរិវជ្ជ- នាយ សតោ សតិករណីយានំ ធម្មានំ កតត្តា សតោ សតិបដិបក្ខានំ ធម្មានំ ហតត្តា សតោ សតិនិមិត្តានំ ធម្មានំ អប្បមុដ្ឋត្តា សតោ ។

---

១ ម. ឆន្ទរាគោ ។

មួយទៀត អាយតនៈ ១២ គឺភ្នែកនិងរូប ត្រចៀកនិងសំឡេង ច្រមុះនិងក្លិន អណ្តាតនិងរស កាយនិងផ្សព្វ ចិត្តនិងធម៌ ហៅថា ធម៌ទាំងពួង ។ តម្រេកក្នុងអាយតនៈ ជាខាងក្នុងខាងក្រៅទាំងឡាយ ជាកិលេសដែលបុគ្គលនោះលះបង់ មានឫសផ្តាច់ចោលហើយ ធ្វើមិនឲ្យមានទីតាំងដូចជាដើមត្នោត មិនឲ្យមានបែបភាព មិនឲ្យមានសភាពកើតឡើងតទៅដោយហេតុណា បុគ្គលនោះឈ្មោះថា ឈ្វាសវៃក្នុងធម៌ទាំងពួងដោយហេតុប៉ុណ្ណេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ឈ្វាសវៃក្នុងធម៌ទាំងពួង ។

[៩២] អធិប្បាយពាក្យថា គប្បីប្រព្រឹត្ត មានសតិជាភិក្ខុ ត្រង់ពាក្យថា មានសតិ គឺឈ្មោះថា មានសតិ ដោយហេតុ ៤ គឺ ចម្រើនកាយានុបស្សនាសតិប្បដ្ឋាន ក្នុងកាយ ឈ្មោះថា មានសតិ ចម្រើនវេទនានុបស្សនាសតិប្បដ្ឋាន ក្នុងវេទនាទាំងឡាយ ឈ្មោះថា មានសតិ ចម្រើន ចិត្តានុបស្សនាសតិប្បដ្ឋាន ក្នុងចិត្ត ឈ្មោះថា មានសតិ ចម្រើន ធម្មានុបស្សនាសតិប្បដ្ឋាន ក្នុងធម៌ទាំងឡាយ ឈ្មោះថា មានសតិ ។ មានសតិដោយហេតុ ៤ ដទៃទៀតគឺ ឈ្មោះថា មានសតិ ព្រោះវៀរចាកការមិនមានសតិ មានសតិ ព្រោះបានធ្វើធម៌ ដែលគប្បីធ្វើដោយសតិ មានសតិ ព្រោះកម្ចាត់ចោលធម៌ ដែលជាសត្រូវដល់សតិ មានសតិ ព្រោះមិនភ្លេចធម៌ ជានិមិត្តរបស់សតិ ។

៤៧

## អជិតមាណវកប្បញ្ហានិទ្ទេសោ

អបរេហិបិ ចតូហិ ការណេហិ សតោ សតិយា សមន្នាគតត្តា សតោ សតិយា វសិតត្តា សតោ សតិយា ចាគុញ្ញតាយ[១] សតោ សតិយា អបច្ចោរោហណតាយ សតោ ។ អបរេហិបិ ចតូហិ ការណេហិ សតោ សតត្តា សតោ សន្តត្តា សតោ សមិតត្តា សតោ សន្តធម្មសមន្នាគតត្តា សតោ ។ ពុទ្ធានុស្សតិយា សតោ ធម្មានុស្សតិយា សតោ សង្ឃានុស្សតិយា សតោ សីលានុស្សតិយា សតោ ចាគានុស្សតិយា សតោ ទេវតានុស្សតិយា សតោ អានាបានស្សតិយា សតោ មរណានុស្សតិយា សតោ កាយគតាសតិយា សតោ ឧបសមានុស្សតិយា សតោ ។ យា សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ ឯកាយនមគ្គោ អយំ វុច្ចតិ សតិ ។ ឥមាយ ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ សោ វុច្ចតិ សតោ ។

១ ម. បាគុញ្ញេន ។

មានសតិដោយហេតុ ៤ ដទៃទៀតគឺ ឈ្មោះថា មានសតិ ព្រោះជាអ្នកបរិបូណ៌ដោយសតិ មានសតិ ព្រោះប្តឹកដោយសតិ មានសតិ ព្រោះស្ទាត់ជំនាញដោយសតិ មានសតិ ព្រោះមិនរំាកចោលសតិ ។ មានសតិដោយហេតុ ៤ ដទៃទៀតគឺ ឈ្មោះថា មានសតិ ព្រោះជាអ្នកមានសតិ មានសតិ ព្រោះជាអ្នកស្ងប់ មានសតិ ព្រោះជាអ្នករម្ងាប់ មានសតិ ព្រោះបរិបូណ៌ ដោយសប្បុរិសធម៌ ។ ឈ្មោះថា មានសតិ ព្រោះការរឭករឿយ ៗ នូវព្រះពុទ្ធ មានសតិ ព្រោះការរឭករឿយ ៗ នូវព្រះធម៌ មានសតិ ព្រោះការរឭករឿយ ៗ នូវព្រះសង្ឃ មានសតិ ព្រោះការរឭករឿយ ៗ នូវសីល មានសតិ ព្រោះការរឭករឿយ ៗ នូវចាគៈ មានសតិ ព្រោះការរឭករឿយ ៗ នូវធម៌ដែលធ្វើឲ្យជាទេវតា មានសតិ ព្រោះការរឭករឿយ ៗ នូវខ្យល់ដង្ហើមចេញចូល មានសតិ ព្រោះការរឭករឿយ ៗ នូវសេចក្តីស្ងប់ មានសតិ ដោយការរឭក ប្រព្រឹត្តទៅក្នុងកាយ មានសតិ ព្រោះការរឭករឿយ ៗ នូវព្រះនិព្វាន ។ ការរឭក ។ បេ ។ ការរឭកត្រូវ ការរឭកជាអង្គនៃធម៌ ជាគ្រឿងត្រាស់ដឹង ជាផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯងណា នេះលោកហៅថា សតិ ។ ភិក្ខុប្រកប ប្រកបព្រម ចូលទៅ ចូលទៅជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រមហើយ ដោយសតិនោះ ភិក្ខុនោះ លោកហៅថា មានសតិ ។

ភិក្ខូតិ សត្តន្នំ ធម្មានំ ភិន្នត្តា ភិក្ខុ សក្កាយទិដ្ឋិ ភិន្នា ហោតិ វិចិកិច្ឆា ភិន្នា ហោតិ សីលព្វតបរាមាសោ ភិន្នោ ហោតិ រាគោ ភិន្នោ ហោតិ ទោសោ ភិន្នោ ហោតិ មោហោ ភិន្នោ ហោតិ មានោ ភិន្នោ ហោតិ ភិន្នស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ។

បជ្ជេន កតេន[១] អត្តនា (សភិយាតិ ភគវា)
បរិនិព្វានគតោ វិតិណ្ណកង្ខោ
វិភវញ្ច ភវញ្ច វិប្បហាយ
វុសិតវា ខីណាបុនព្ភវោ[២] ស ភិក្ខូតិ ។

សតោ ភិក្ខុ បរិព្វជេតិ សតោ ភិក្ខុ បរិព្វជេ សតោ គច្ឆេយ្យ សតោ តិដ្ឋេយ្យ សតោ និសីទេយ្យ សតោ សេយ្យំ កប្បេយ្យ សតោ អភិក្កមេយ្យ សតោ បដិក្កមេយ្យ សតោ អាលោកេយ្យ សតោ វិលោកេយ្យ សតោ សម្មិញ្ជេយ្យ សតោ បសារេយ្យ សតោ សង្ឃាដិបត្តចីវរំ ធារេយ្យ សតោ ចរេយ្យ សតោ វិហរេយ្យ វត្តេយ្យ ឥរិយេយ្យ បាលេយ្យ យបេយ្យ យាបេយ្យាតិ សតោ ភិក្ខុ បរិព្វជេ ។ តេនាហ ភគវា

១ ម. បជោតកតេន ។ ២ ម. ខីណជាតិបុនព្ភវោ ។

ពាក្យថាភិក្ខុ គឺថាភិក្ខុ ព្រោះជាអ្នកទម្លាយធម៌ប្រាំពីរគឺ ទម្លាយសក្កាយទិដ្ឋិ ទម្លាយវិចិកិច្ឆា ទម្លាយសីលព្វតបរាមាស ទម្លាយរាគៈ ទម្លាយទោសៈ ទម្លាយមោហៈ ទម្លាយមានៈ ទម្លាយអកុសលធម៌លាមកទាំងឡាយ ប្រកបដោយគ្រឿងសៅហ្មងព្រម ដែលឲ្យបដិសន្ធិក្នុងភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល ជាបច្ច័យនៃជាតិ ជរា មរណៈ ក្នុងអនាគត ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលសភិយៈ បុគ្គលដល់នូវបរិ-
និព្វាន ដោយមគ្គដែលខ្លួនចម្រើនហើយ មានសេចក្តីសង្ស័យ
ឆ្លងហើយ លះបង់នូវសេចក្តីវិនាសនិងសេចក្តីចម្រើន មានមគ្គ
អប់រំហើយ មានភពថ្មីអស់ហើយ បុគ្គលនោះហៅថា ភិក្ខុ ។

ពាក្យថា គប្បីប្រព្រឹត្តមានសតិជាភិក្ខុ បានន័យថា គប្បីប្រព្រឹត្តមានស្មារតីជាភិក្ខុ គឺគប្បីមានសតិដើរទៅ មានសតិឈរ មានសតិអង្គុយ មានសតិសម្រេចនូវសេយ្យាសន៍ មានសតិឈានទៅ មានសតិឈានថយ មានសតិក្រឡេកមើល មានសតិក្រឡេកមើលផ្សេងៗ មានសតិបត់ចូល (នូវអវយវៈ) មានសតិលា (នូវអវយវៈ) មានសតិទ្រទ្រង់សង្ឃាដី បាត្រ និងចីវរ មានសតិត្រាច់ទៅ គប្បីមានសតិសម្រាន្តនៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះទ្រង់ត្រាស់ថា គប្បីប្រព្រឹត្តមានសតិជាភិក្ខុ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

៤៩

## អជិតមាណវកប្បញ្ហានិទ្ទេសោ

កាមេសុ នាភិគិជ្ឈេយ្យ មនសានាវិលោ សិយា កុសលោ សព្វធម្មានំ សតោ ភិក្ខុ បរិព្វជេតិ ។

[៩៨] សហ គាថាបរិយោសានា តេន ព្រាហ្មណេន សទ្ធឹ ឯកច្ឆន្ទា ឯកប្បយោគា ឯកាធិប្បាយា ឯកវាសនវាសិតា តេសំ អនេកបាណសហស្សានំ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ តស្ស ច ព្រាហ្មណស្ស អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិ ។ សហ អរហត្តប្បត្តា អជិនជដាវាកចីរទណ្ឌកមណ្ឌលុកេសា ច មស្សុ ច អន្តរហិតា ។ ភណ្ឌកាសាយវត្ថវសនោ សង្ឃាដិបត្តចីវរធរោ ភិក្ខុ អន្វត្តប្បដិបត្តិយា បញ្ជលិកោ ភគវន្តំ នមស្សមានោ និសិន្នោ ហោតិ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

អជិតមាណវកប្បញ្ហានិទ្ទេសោ បឋមោ ។

អជិតមាណវកបញ្ហានិទ្ទេស

*បុគ្គលមិនគប្បីប្រាថ្នា ក្នុងកាមទាំងឡាយ មិនគប្បីធ្វើចិត្តឲ្យល្អក់ ជាបុគ្គលឈ្លាសវៃក្នុងធម៌ទាំងពួង គប្បីប្រព្រឹត្ត មានសតិ ជាភិក្ខុ ។*

*[៩៥] ព្រាហ្មណ៍ទាំងឡាយ មានអធ្យាស្រ័យតែមួយ មានបយោគតែមួយ*(១) *មានសេចក្ដីប៉ុនប៉ងតែមួយ មានធម៌ជាគ្រឿងអប់រំតែមួយ អប់រំហើយ (ក្នុងពុទ្ធសាសនាជាអតីត) ជាមួយគ្នា មួយអន្លើដោយព្រាហ្មណ៍ (ឈ្មោះអជិតៈ) នោះ ធម្មចក្ខុ គឺសោតាបត្តិមគ្គ មានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ កើតឡើងដល់ពាន់នៃសត្វដ៏ច្រើនទាំងនោះថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ឯ(អជិតៈ) ព្រាហ្មណ៍នោះ មានចិត្តផុតស្រឡះហើយ ចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដំណាលគ្នាដោយការចប់គាថា ។ (លំដាប់នោះ) ស្បែកខ្លាជដា សំពត់សំបកឈើ ឈើច្រត់ កុណ្ឌីទឹក និងសក់ពុកមាត់ពុកចង្កា ក៏បាត់ទៅជាមួយនឹងពេលដែលដល់ នូវភាពនៃខ្លួនជាព្រះអរហន្ត ។ (អជិតព្រាហ្មណ៍) ជាឯហិភិក្ខុ ស្លៀកដណ្ដប់នូវភណ្ឌគឺសំពត់កាសាយៈ ទ្រទ្រង់នូវសង្ឃាដី បាត្រ និងចីវរ អង្គុយប្រណម្យអញ្ជលី នមស្ការព្រះមានព្រះភាគ ដោយប្រតិបត្តិសមគួរដល់ប្រយោជន៍ (ហើយប្រកាសថា) បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្ដារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។*

ចប់អជិតមាណវកបញ្ហានិទ្ទេស ទី ១

---

១ បយោគមាន ៣ យ៉ាងគឺ កាយប្បយោគ ១ វចីបយោគ ១ មនោបយោគ ១ ។

# តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេសោ

[៩៦] កោធ សន្តុសិតោ លោកេ (ឥច្ចាយស្មា តិស្សមេត្តេយ្យោ)

កស្ស នោ សន្តិ ឥញ្ជិតា
កោ ឧភន្តមភិញ្ញាយ
មជ្ឈេ មន្តា ន លិម្បតិ
កំ ព្រូសិ មហាបុរិសោតិ
កោ ឥធ សិព្វិនិមច្ចគាតិ(១) ។

[៩៧] កោធ សន្តុសិតោ លោកេតិ សន្តុដ្ឋោ អត្តមនោ បរិបុណ្ណសង្កប្បោតិ កោធ សន្តុសិតោ លោកេ ។ ឥច្ចាយស្មា តិស្សមេត្តេយ្យោតិ ឥច្ចាតិ បទសន្ធិ បទសំសគ្គោ បទចារិបូរិ អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វកមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។ តិស្សាតិ តស្ស ព្រាហ្មណស្ស នាមំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោ ។

១ ម. សិព្វិនិមជ្ឈគាតិ ។

# តិស្សមេត្តេយ្យមាណវកបញ្ហានិទ្ទេស

[៩៦] (តិស្សមេត្តេយ្យ មានអាយុ ទូលសួរ ដូច្នេះថា)

បុគ្គលណា ក្នុងលោកនេះ ជាអ្នកត្រេកអរពេញលេញ
បុគ្គលណា មិនមានសេចក្តីញាប់ញ័រ បុគ្គលណាដឹងច្បាស់
នូវទីបំផុតទាំងពីរនិងកណ្តាល ដោយប្រាជ្ញាហើយព្រះអង្គ
ទ្រង់ហៅបុគ្គលណាថា មហាបុរស បុគ្គលណា បានកន្លង
នូវតណ្ហា ជាគ្រឿងចាក់ស្រេះ ក្នុងលោកនេះ ។

[៩៧] ពាក្យថា បុគ្គលណា ក្នុងលោកនេះ ជាអ្នកត្រេកអរពេញលេញ គឺជាអ្នកត្រេកអរពេញហើយ មានចិត្តរីករាយ មានសេចក្តីត្រិះរិះពេញលេញ ហេតុនោះ (លោកសួរថា) បុគ្គលណា ក្នុងលោកនេះ ជាអ្នកត្រេកអរ ពេញលេញ ។ ពាក្យថា ដូច្នេះ ក្នុងបទថា តិស្សមេត្តេយ្យមានអាយុ (ទូលសួរ) ដូច្នេះ គឺជាបទភ្ជាប់ ជាពាក្យភ្ជាប់បទ បំពេញបទ ប្រជុំអក្ខរៈ សម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះនុ៎ះ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នុ៎ះ ជាពាក្យពោល ដោយគោរពកោតក្រែង ។ ពាក្យថា តិស្សៈ គឺជាឈ្មោះ ជាពាក្យសម្រាប់ហៅសម្រាប់សម្គាល់ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមបញ្ញត្តិ ជាសម្តី ជាគ្រឿងបញ្ជាក់ ជាគ្រឿងប្រកាស នៃព្រាហ្មណ៍នោះ ។

មេត្តេយ្យាតិ តស្ស ព្រាហ្មណស្ស គោត្តំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោតិ ឥច្ចាយស្មា តិស្ស-មេត្តេយ្យោ ។

[៩៨] កស្ស នោ សន្តិ ឥញ្ជិតាតិ តណ្ហិញ្ជិតំ ទិដ្ឋិញ្ជិតំ មានិញ្ជិតំ កិលេសិញ្ជិតំ កម្មិញ្ជិតំ កស្សិ-មេ ឥញ្ជិតា នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នូបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិ-កា ញាណគ្គិនា ទឌ្ឍាតិ កស្ស នោ សន្តិ ឥញ្ជិតា ។

[៩៩] កោ ឧភន្តមភិញ្ញាយាតិ កោ ឧភោ អន្តេ អភិញ្ញាយ ជានិត្វា តុលយិត្វា តិរយិត្វា វិភា-វយិត្វា វិភូតំ កត្វាតិ កោ ឧភន្តមភិញ្ញាយ ។

[១០០] មជ្ឈេ មន្តា ន លិម្បតីតិ[១] អលិត្តោ អនូបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ មជ្ឈេ មន្តា ន លិម្បតិ ។

១ ម.ឯត្ថន្តរេ មជ្ឈេ មន្តាយ ន លិម្បតីតិ ទិស្សតិ ។

តិស្សមេត្តេយ្យមាណវកបញ្ហានិទ្ទេស

ពាក្យថា មេត្តេយ្យ គឺជាគោត្រ ជាពាក្យសម្រាប់ហៅ ជាពាក្យសម្រាប់សម្គាល់ ជាបញ្ញត្តិ ជាវោហារ នៃព្រាហ្មណ៍នោះ ហេតុនោះ (លោកពោលថា) តិស្សមេត្តេយ្យ មានអាយុ (ទូលសួរ) ដូច្នេះ ។

[៩៨] ពាក្យថា បុគ្គលណា មិនមានសេចក្តីញាប់ញ័រ សេចក្តីថា ការញាប់ញ័រ ដោយតណ្ហា ញាប់ញ័រដោយទិដ្ឋិ ញាប់ញ័រដោយមានះ ញាប់ញ័រដោយកិលេស ញាប់ញ័រដោយកម្ម សេចក្តីញាប់ញ័រទាំងនេះ របស់បុគ្គលណា គ្មាន មិនមាន មិនមានព្រម មិនបាន គឺបុគ្គលណា លះបង់ ផ្តាច់បង់ ចូលទៅរម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (លោកសួរថា) បុគ្គលណា មិនមានសេចក្តីញាប់ញ័រ ។

[៩៩] ពាក្យថា បុគ្គលណា ដឹងច្បាស់នូវទីបំផុតទាំងពីរ គឺបុគ្គលណា ដឹងច្បាស់ ដឹង ថ្លឹង ពិចារណា សម្តែងធ្វើឲ្យជាក់ច្បាស់ នូវទីបំផុតទាំងពីរ ហេតុនោះ (លោកសួរថា) បុគ្គលណា ដឹងច្បាស់នូវទីបំផុតទាំងពីរ ។

[១០០] ពាក្យថា និងកណ្តាល ដោយប្រាជ្ញា ហើយមិនជាប់ គឺមិនជាប់ មិនចូលទៅជិតជាប់ ចេញ រលាស់ចេញ រួចស្រឡះ ប្រាសចេញ នៅដោយចិត្ត ដែលប្រាសចាកទំនប់គឺកិលេស ហេតុនោះ (លោកសួរថា) និងកណ្តាលដោយប្រាជ្ញា ហើយមិនជាប់ ។

[១០១] កំ ព្រូសិ មហាបុរិសោតិ មហាបុរិសោ អគ្គបុរិសោ សេដ្ឋបុរិសោ វិសេដ្ឋបុរិសោ ធាមោក្ខបុរិ-សោ ឧត្តមបុរិសោ បវរបុរិសោតិ កំ ព្រូសិ កំ កថេសិ កំ មញ្ញសិ កំ ភណសិ កំ បស្សសិ កំ វោហារេសីតិ កំ ព្រូសិ មហាបុរិសោតិ ។

[១០២] កោ ឥធ សិព្វនិមច្ចគាតិ កោ សិព្វនឹ តណ្ហំ អច្ចគា ឧបច្ចគា អតិក្កន្តោ សមតិក្កន្តោ វី-តិវត្តោតិ កោ ឥធ សិព្វនិមច្ចគា ។ តេនាហ សោ ព្រាហ្មណោ

កោធ សន្តុសិតោ លោកេ (ឥច្චាយស្មា តិស្សមេត្តេយ្យោ)

កស្ស នោ សន្តិ ឥញ្ជិតា

កោ ឧភន្តមភិញ្ញាយ

មជ្ឈេ មន្តា ន លិម្បតិ

កំ ព្រូសិ មហាបុរិសោតិ

កោ ឥធ សិព្វនិមច្ចគាតិ ។

[១០០] ពាក្យថា ព្រះអង្គទ្រង់ហៅបុគ្គលណាថា មហាបុរស គឺព្រះអង្គទ្រង់ហៅបុគ្គលណា ទ្រង់សម្តែងបុគ្គលណា ទ្រង់សម្គាល់បុគ្គលណា ទ្រង់ត្រាស់បុគ្គលណា ទ្រង់ឃើញបុគ្គលណា ទ្រង់ប្រកាសបុគ្គលណាថា មហាបុរស បុរសលើស បុរសប្រសើរ បុរសវិសេសផុត បុរសចម្បង បុរសឧត្តម បុរសថ្លៃថ្លា ហេតុនោះ (លោកសួរថា) ព្រះអង្គទ្រង់ហៅបុគ្គលណាថា មហាបុរស ។

[១០២] ពាក្យថា បុគ្គលណាបានកន្ទង់នូវតណ្ហា ជាគ្រឿងចាក់ស្រេះក្នុងលោកនេះ គឺបុគ្គលណា បានកន្ទង់ កន្ទង់បង់ ឈានកន្ទង់ កន្ទង់ព្រម ប្រព្រឹត្តកន្ទង់ នូវតណ្ហាជាគ្រឿងចាក់ស្រេះ ហេតុនោះ (លោកសួរថា) បុគ្គលណា បានកន្ទង់នូវតណ្ហាជាគ្រឿងចាក់ស្រេះ ក្នុងលោកនេះ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលហើយថា

(តិស្សមេត្តេយ្យ មានអាយុ ទូលសួរ ដូច្នេះថា)

បុគ្គលណា ក្នុងលោកនេះ ជាអ្នកត្រេកអរពេញលេញ
បុគ្គលណា មិនមានសេចក្តីញាប់ញ័រ បុគ្គលណា ដឹងច្បាស់
នូវទីបំផុតទាំងពីរ និងកណ្តាល ដោយប្រាជ្ញា ហើយមិនជាប់
ព្រះអង្គទ្រង់ហៅបុគ្គលណាថា មហាបុរស បុគ្គលណា
បានកន្ទង់នូវតណ្ហាជាគ្រឿងចាក់ស្រេះ ក្នុងលោកនេះ ។

៤៣

តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេសោ

[១០៣] កាមេសុ ព្រហ្មចរិយវា (មេត្តេយ្យាតិ ភគវា)
វីតតណ្ហោ សទា សតោ
សង្ខាយ និព្វុតោ ភិក្ខុ
តស្ស នោ សន្តិ ឥញ្ជិតា
សោ ឧភន្តមភិញ្ញាយ
មជ្ឈេ មន្តា ន លិម្បតិ
តំ ព្រូមិ មហាបុរិសោតិ
សោ ឥធ សិព្វិនិមច្ចគាតិ ។

[១០៤] កាមេសុ ព្រហ្មចរិយវាតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ ព្រហ្មចរិយវាតិ ព្រហ្មចរិយំ វុច្ចតិ អសទ្ធម្មសមាបត្តិយា អារតិ វិរតិ បដិវិរតិ វេរមណី អកិរិយា អករណំ អនជ្ឈាបត្តិ វេលាអនតិក្កមោ ។ អបិច និប្បរិយាយេន ព្រហ្មចរិយំ វុច្ចតិ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។

## តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេស

[១០៣] (ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមេត្តេយ្យ) ភិក្ខុណា មានព្រហ្មចរិយៈ សង្រួមក្នុងកាមទាំងឡាយ ប្រាសចាកតណ្ហា មានស្មារតីសព្វកាល ដឹងហើយ រលត់ហើយ ឯសេចក្តីញាប់ញ័រ របស់ភិក្ខុនោះ មិនមានទេ ភិក្ខុនោះ ដឹងច្បាស់ទីបំផុតទាំងពីរ និងកណ្តាល ដោយការដឹង ហើយមិនជាប់ តថាគតហៅភិក្ខុនោះថា មហាបុរស ភិក្ខុនោះ បានកន្លងនូវតណ្ហាជាគ្រឿងចាក់ស្រេះ ក្នុងលោកនេះ ។

[១០៤] អធិប្បាយពាក្យថា មានព្រហ្មចរិយៈ ក្នុងកាមទាំងឡាយ ត្រង់ពាក្យថា កាមទាំងឡាយ បើតាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះ ហៅថាវត្ថុកាម ។ បេ ។ នេះ ហៅថា កិលេសកាម ។ ពាក្យថា មានព្រហ្មចរិយៈ សេចក្តីថាការវៀរ ការចៀសវាង ការវៀរស្រឡះ ការបណ្តេញបង់នូវពៀរ កិរិយាមិនធ្វើ ការមិនធ្វើ ការមិនត្រូវ ការមិនប្រព្រឹត្តកន្លងនូវដែន ចាកការដល់ព្រម នៃអសទ្ធម្ម លោកហៅថា ព្រហ្មចរិយៈ ។ មួយទៀត ដោយនិប្បរិយាយ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺប្រាជ្ញាយល់ត្រូវ សេចក្តីត្រិះរិះត្រូវ វាចាត្រូវ ការងារត្រូវ ការចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ សេចក្តីរឭកត្រូវ ការតាំងចិត្តនឹងត្រូវ លោកហៅថា ព្រហ្មចរិយៈ ។

យោ ឥមិនា អរិយេន អដ្ឋង្គិកេន មគ្គេន ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ សោ វុច្ចតិ ព្រហ្មចរិយវា ។ យថា ច ធនេន ធនវាតិ វុច្ចតិ ភោគេន ភោគវាតិ វុច្ចតិ យសេន យសវាតិ វុច្ចតិ សិប្បេន សិប្បវាតិ វុច្ចតិ សីលេន សីលវាតិ វុច្ចតិ វីរិយេន វីរិយវាតិ វុច្ចតិ បញ្ញាយ បញ្ញវាតិ វុច្ចតិ វិជ្ជាយ វិជ្ជវាតិ វុច្ចតិ ឯវមេវ យោ ឥមិនា អរិយេន អដ្ឋង្គិកេន មគ្គេន ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ សោ វុច្ចតិ ព្រហ្មចរិយវាតិ កាមេសុ ព្រហ្មចរិយវា ។ មេត្តេយ្យាតិ ភគវា តំ ព្រាហ្មណំ គោត្តេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ មេត្តេយ្យាតិ ភគវា ។

បុគ្គលណាប្រកប ប្រកបព្រម ចូលមកជិត ចូលមកជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រម ដោយមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ បុគ្គលនោះ លោកហៅថា អ្នកមានព្រហ្មចរិយៈ ។ ឧបមាដូចជា បុគ្គលដែលលោកហៅថា អ្នកមានទ្រព្យ ព្រោះទ្រព្យ ហៅថា អ្នកមានភោគៈ ព្រោះភោគៈ ហៅថាអ្នកមានយស ព្រោះយស ហៅថាអ្នកមានសិល្បៈ ព្រោះសិល្បៈ ហៅថាអ្នកមានសីល ព្រោះសីល ហៅថាអ្នកមានព្យាយាម ព្រោះព្យាយាម ហៅថាអ្នកមានប្រាជ្ញា ព្រោះប្រាជ្ញា ហៅថាអ្នកមានវិជ្ជា ព្រោះវិជ្ជា យ៉ាងណាមិញ បុគ្គលណាប្រកប ប្រកបព្រម ចូលមកជិត ចូលមកជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រម ដោយមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះ បុគ្គលនោះលោកហៅថា អ្នកមានព្រហ្មចរិយៈ យ៉ាងនោះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមានព្រហ្មចរិយៈក្នុងកាមទាំងឡាយ ។ ពាក្យថា ម្នាលមេត្តេយ្យ គឺព្រះមានព្រះភាគ ទ្រង់ហៅព្រាហ្មណ៍នោះ ដោយគោត្រ ពាក្យថា ព្រះមានព្រះភាគ នេះគឺជាពាក្យសម្រាប់ហៅដោយគោរព ។ បេ ។ ការបញ្ញត្តថា មានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យ ។

### តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេសោ

[១០៤] វីតតណ្ហោ សទា សតោតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ យស្សេសា តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ វីតតណ្ហោ ចត្តតណ្ហោ វន្តតណ្ហោ មុត្តតណ្ហោ បហីនតណ្ហោ បដិនិស្សដ្ឋតណ្ហោ វីតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ។ សទាតិ សទា សព្វទា សព្វកាលំ និច្ចកាលំ ធុវកាលំ សតតំ សមិតំ អព្វោកិណ្ណំ បោខានុបោខំ អវីចិ សមង្គិសហិតំ ផុសិតំ[១] បុរេភត្តំ បច្ឆាភត្តំ បុរិមយាមំ មជ្ឈិមយាមំ បច្ឆិមយាមំ កាឡេ ជុណ្ហេ វស្សេ ហេមន្តេ គិម្ហេ បុរិមេ វយោខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេ ។

---

១ ម. ឧទកុម្មិកជាតំ អវីចិ សន្តាសហិតំ បស្សតិ ។

តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេស

[១០៥] អធិប្បាយពាក្យថា ប្រាសចាកតណ្ហា មានស្មារតីសព្វកាល ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហានេះ បុគ្គលណា បានលះបង់ ផ្តាច់បង់ រម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះលោកហៅថា អ្នកប្រាសចាកតណ្ហា អ្នកលះបង់តណ្ហា មានតណ្ហាខ្ជាក់ចោល មានតណ្ហាលែងហើយ អ្នកលះតណ្ហា អ្នករលាស់ចោលតណ្ហា អ្នកប្រាសចាករាគៈ អ្នកលះរាគៈ អ្នកខ្ជាក់រាគៈ អ្នកលែងរាគៈ អ្នកលះបង់រាគៈ អ្នករលាស់ចោលរាគៈ មិនមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់កើតហើយ អ្នកសោយសុខ មានខ្លួនដ៏ប្រសើរ ។ ពាក្យថា សព្វកាល គឺក្នុងកាលទាំងពួង ក្នុងកាលទាំងអស់ អស់កាលទាំងស្រុង អស់កាលជានិច្ច អស់កាលដ៏ទៀងរឿយៗ ប្រព្រឹត្តទៅព្រម ប្រទ្បូកប្រទ្បំ មិនឃ្លាត គ្មានចន្លោះ ប្រកបដោយសេចក្តីព្រមព្រៀង ពាល់ត្រូវ កាលមុននៃភត្ត កាលជាខាងក្រោយនៃភត្ត យាមខាងដើម យាមកណ្តាល យាមខាងក្រោយ រនោច ខ្នើត រដូវភ្លៀង រដូវរងា រដូវក្តៅ ខន្ធអស់ទៅ ក្នុងខាងដើម ខន្ធអស់ទៅ ក្នុងកណ្តាល ខន្ធអស់ទៅ ក្នុងខាងក្រោយ ។

សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវិតត្តា(១) សតោ វេទនាសុ វេទនានុបស្សនាសតិប្បដ្ឋានំ ភាវិតត្តា សតោ ចិត្តេ ចិត្តានុបស្សនាសតិប្បដ្ឋានំ ភាវិតត្តា សតោ ធម្មេសុ ធម្មានុបស្សនាសតិប្បដ្ឋានំ ភាវិតត្តា សតោ ។ បេ ។ សោ វុច្ចតិ សតោតិ វីតតណ្ហោ សទា សតោ ។

[១០៦] សង្ខាយ និព្ពុតោ ភិក្ខូតិ សង្ខាតិ(២) ញាណំ យា បញ្ញា បជានានា វិចយោ ។ បេ ។ អមោហោ ធម្ម-វិចយោ សម្មាទិដ្ឋិ ។ សង្ខាយាតិ សង្ខាយ ជានិត្វា តុល-យិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ សង្ខាយ ជានិត្វា តុលយិត្វា តីរយិត្វា វិភា-វយិត្វា វិភូតំ កត្វា សព្វេ សង្ខារា ទុក្ខាតិ សព្វេ ធម្មា អនត្តាតិ អវិជ្ជាបច្ចយា សង្ខារាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ សង្ខាយ ជា-និត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។

---

១ ម. ភាវេន្តោ ។ ២ ម. សង្ខា វុច្ចតិ ។

ពាក្យថា មានស្មារតី គឺឈ្មោះថា អ្នកមានស្មារតីដោយហេតុ ៤ គឺ មានស្មារតី ព្រោះបានចម្រើនសតិប្បដ្ឋាន គឺការពិចារណារឿយៗ នូវកាយ ក្នុងកាយ ១ មានស្មារតី ព្រោះបានចម្រើនសតិប្បដ្ឋាន គឺការពិចារណារឿយៗ នូវវេទនា ក្នុងវេទនាទាំងឡាយ ១ មានស្មារតីព្រោះបានចម្រើនសតិប្បដ្ឋាន គឺការពិចារណារឿយៗ នូវចិត្ត ក្នុងចិត្ត ១ មានស្មារតី ព្រោះបានចម្រើនសតិប្បដ្ឋាន គឺការពិចារណារឿយៗនូវធម៌ ក្នុងធម៌ ១ ។ បេ ។ បុគ្គលនោះលោកហៅថា អ្នកមានស្មារតី ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រាសចាកតណ្ហា មានស្មារតី សព្វកាល ។

[១០៦] ពាក្យថា ដឹងហើយ រលត់ហើយ ជាភិក្ខុ អធិប្បាយថា ញាណឈ្មោះថា ការដឹង បានដល់បញ្ញា ការដឹងច្បាស់ ការពិចារណា ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវ ។ ពាក្យថា ដឹងហើយ គឺបានដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យជាក់ច្បាស់ គឺថាដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យជាក់ច្បាស់ថា សង្ខារទាំងពួងមិនទៀង បានដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យជាក់ច្បាស់ថា សង្ខារទាំងពួងជាទុក្ខ ថា ធម៌ទាំងពួង ជាអនត្តា ថា សង្ខារ (កើត) ព្រោះអវិជ្ជាជាបច្ច័យ ។ បេ ។ ថាធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅជាធម្មតា ។

៤៧

## តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេសោ

អថវា អនិច្ចតោ សង្ខាយ ជានិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ ។ បេ ។ អនិស្សរណតោ សង្ខាយ ជានិត្វា តុល-យិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ និព្វុតោតិ រាគ-ស្ស និព្វាបិតត្តា និព្វុតោ ទោសស្ស និព្វាបិតត្តា និ-ព្វុតោ មោហស្ស និព្វាបិតត្តា និព្វុតោ កោធស្ស ឧប-នាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស សព្វកិលេសានំ សព្វទុច្ចរិតានំ សព្វទរថានំ សព្វបរិឡាហានំ សព្វ-សន្តានំ សព្វាកុសលាភិសង្ខារានំ និព្វាបិតត្តា និព្វុ-តោ ។ ភិក្ខូតិ សត្តន្នំ ធម្មានំ ភិន្នត្តា ភិក្ខុ ។ បេ ។ វុសិតវា ខីណាបុនព្ភវោ ស ភិក្ខូតិ សង្ខាយ និព្វុតោ ភិក្ខុ ។

[១០៧] តស្ស នោ សន្តិ ឥញ្ជិតាតិ តស្សាតិ អរហតោ ខីណាសវស្ស ឥញ្ជិតា តណ្ហិញ្ជិតំ ទិដ្ឋិញ្ជិតំ មានិញ្ជិតំ កិលេសិញ្ជិតំ កម្មិញ្ជិតំ ។

មួយទៀត បានដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យជាក់ច្បាស់ថា មិនទៀង បានដឹង យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យជាក់ច្បាស់ ថា ជាទុក្ខ ជារោគ ជាបូស ជាសរ ។ បេ ។ ថាមិនមែនជាគ្រឿងរលាស់ ខ្លួនចេញចាកទុក្ខ ។ ពាក្យថា រលត់ហើយ គឺរលត់ហើយព្រោះលោក ញុំាងរាគៈឲ្យរលត់ រលត់ហើយ ព្រោះញុំាងទោសៈឲ្យរលត់ រលត់ហើយ ព្រោះញុំាងមោហៈឲ្យរលត់ រលត់ហើយ ព្រោះញុំាងក្រោធ ការចងក្រោធ ទុក សេចក្តីលុបគុណ ការវាយឫកស្មើ សេចក្តីច្រណែន សេចក្តីកំណាញ់ ការបិទបាំងទោសរបស់ខ្លួន សេចក្តីអួតអាង សេចក្តីរឹងត្អឹង ការ ប្រណាំងប្រជែង មានះ សេចក្តីមើលងាយ សេចក្តីស្រវឹង សេចក្តីធ្វេស កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តី រោលរាលទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អភិសង្ខារជាអកុសល ទាំងពួងឲ្យរលត់ ។ ពាក្យថា ភិក្ខុ គឺឈ្មោះថា ភិក្ខុ ព្រោះទម្លាយបង់ធម៌ ប្រាំពីរ ។ បេ ។ មានមគ្គអប់រំ មានភពថ្មីអស់ បុគ្គលនោះលោកហៅ ថាភិក្ខុ ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងហើយ រលត់ហើយ ជាភិក្ខុ ។

[១០៧] អធិប្បាយពាក្យថា សេចក្តីញាប់ញ័រ របស់ភិក្ខុនោះ មិនមាន ត្រង់ពាក្យថា របស់ភិក្ខុនោះបានដល់ការញាប់ញ័រទាំងឡាយ គឺការញាប់ ញ័រដោយតណ្ហា ញាប់ញ័រដោយទិដ្ឋិ ញាប់ញ័រដោយមានះ ញាប់ញ័រ ដោយកិលេស ញាប់ញ័រដោយកម្ម របស់ព្រះអរហន្តខីណាស្រព ។

តស្សិមេ ឥញ្ជិតា នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នូបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ តស្ស នោ សន្តិ ឥញ្ជិតា[១] ។

[១០៨] សោ ឧភន្តមភិញ្ញាយ មជ្ឈេ មន្តា ន លិម្ប-តីតិ អន្តោតិ ផស្សោ ឯកោ អន្តោ ផស្សសមុទយោ ទុតិយោ អន្តោ ផស្សនិរោធោ មជ្ឈេ អតីតំ ឯកោ អន្តោ អនាគតំ ទុតិយោ អន្តោ បច្ចុប្បន្នំ មជ្ឈេ សុខា វេទនា ឯកោ អន្តោ ទុក្ខា វេទនា ទុតិយោ អន្តោ អទុក្ខមសុខា វេទនា មជ្ឈេ នាមំ ឯកោ អន្តោ រូបំ ទុតិយោ អន្តោ វិញ្ញាណំ មជ្ឈេ ឆ អជ្ឈត្តិកានិ អា-យតនានិ ឯកោ អន្តោ ឆ ពាហិរានិ អាយតនានិ ទុតិយោ អន្តោ វិញ្ញាណំ មជ្ឈេ សក្កាយោ ឯកោ អន្តោ សក្កាយសមុទយោ ទុតិយោ អន្តោ សក្កាយ-និរោធោ មជ្ឈេ ។ មន្តា វុច្ចតិ បញ្ញា យា បញ្ញា បជា-នានា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ លេ-បាតិ ទ្វេ លេបា តណ្ហាលេបោ ច ទិដ្ឋិលេបោ ច ។

១ ម. ឥតោ បរំ តេនាហ ភគវា កាមេសុ ព្រហ្មចរិយវា មេត្តេយ្យាតិ ភគវា វីតតណ្ហា សទា សតោ សង្ខាយ និព្វុតោ ភិក្ខុ តស្ស នោ សន្តិ ឥច្ឆិតាតិ ។ សោ ឧភន្តមភិញ្ញាយ មជ្ឈេ មន្តា ន លិម្បតិ តំ ព្រូមិ មហាបុរិសោតិ សោ ឥធ សិព្វនិមជ្ឈតា ។

សេចក្តីញាប់ញ័រទាំងនេះ របស់ព្រះខីណាស្រពនោះ គ្មាន មិនមាន មិនមានព្រម មិនបាន (គឺលោក) បានលះបង់ ផ្តាច់បង់ រម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីញាប់ញ័ររបស់ភិក្ខុនោះ មិនមាន ។

[១០៨] អធិប្បាយពាក្យថា ភិក្ខុនោះ ដឹងច្បាស់នូវទីបំផុតទាំងពីរ និងកណ្តាលដោយការដឹង ហើយមិនជាប់ ត្រង់ពាក្យថា ទីបំផុត គឺ ផស្សៈជាទីបំផុតមួយ ការកើតឡើងនៃផស្សៈ ជាទីបំផុតទីពីរ ការរលត់នៃផស្សៈ ទុកជាកណ្តាល អតីតជាទីបំផុតមួយ អនាគតជាទីបំផុតទីពីរ បច្ចុប្បន្នទុកជាកណ្តាល សុខវេទនាជាទីបំផុតមួយ ទុក្ខវេទនាជាទីបំផុតទីពីរ អទុក្ខមសុខវេទនា ទុកជាកណ្តាល នាមជាទីបំផុតមួយ រូបជាទីបំផុតទីពីរ វិញ្ញាណទុកជាកណ្តាល អាយតនៈ ខាងក្នុង ៦ ជាទីបំ-ផុតមួយ អាយតនៈ ខាងក្រៅ ៦ ជាទីបំផុតទីពីរ វិញ្ញាណទុកជាកណ្តាល សក្កាយៈ ជាទីបំផុតមួយ ការកើតឡើងនៃសក្កាយៈ ជាទីបំផុតទីពីរ ការរលត់នៃសក្កាយៈ ទុកជាកណ្តាល ។ បញ្ញា លោកហៅថា ការដឹង គឺ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវ ។ ពាក្យថា ការជាប់ បានដល់ការជាប់ជំពាក់ពីរគឺ ការជាប់ជំពាក់ ដោយតណ្ហា ១ ការជាប់ជំពាក់ ដោយទិដ្ឋិ ១ ។

៤៩

## តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេសោ

កតមោ តណ្ហាលេបោ ។ យាវតា តណ្ហាសង្ខាតេន សីមកតំ មរិយាទិកតំ ឱធិកតំ បរិយន្តិកតំ បរិគ្គហិតំ មមាយិតំ ឥទំ មមំ ឯតំ មមំ ឯត្តកំ មមំ ឯត្តាវតា មមំ មម រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា អត្ថរណា ចាបុរណា[១] ទាសីទាសា អជេឡកា កុក្កុដសូករា ហត្ថិគវាស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញំ សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច កេវលម្បិ មហាបថវឹ តណ្ហាវសេន មមាយតិ យាវតា អដ្ឋសតតណ្ហាវិបរីតំ[២] អយំ តណ្ហាលេបោ ។ កតមោ ទិដ្ឋិលេបោ ។ វីសតិវត្ថុកា សក្កាយទិដ្ឋិ ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ វិបរីតគ្គាហោ វិបល្លាសគ្គាហោ មិច្ឆាគាហោ អយាថាវកស្មឹ យាថាវកន្តិ គាហោ

១ ម. បាវុរណា ។ ២ ម. អដ្ឋសតតណ្ហាវិចរិតំ ។

តិស្សមេត្តេយ្យមាណវកបញ្ហានិទ្ទេស

ការជាប់ចំពាក់ដោយតណ្ហា តើដូចម្តេច ។ សេចក្តីហួងហែង សេចក្តីប្រកាន់ដែលធ្វើឲ្យជាដែន ធ្វើឲ្យជាទំនប់ ធ្វើឲ្យជាចំណែក ធ្វើឲ្យជាទីបំផុត ដោយចំណែកនៃតណ្ហាជាកំណត់ថា នេះរបស់អញ នុ៎ះរបស់អញ វត្ថុមានប្រមាណប៉ុណ្ណេះ របស់អញ ធម្មជាតមានប្រមាណប៉ុណ្ណេះ របស់អញ រូប សំឡេង ក្លិន រស ផ្សព្វ កម្រាល សំពត់ដណ្តប់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល-ញី ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ ឃ្លាំង ជង្រុក របស់អញ មួយវិញទៀត បុគ្គលប្រកាន់មហាប្រឹថពីទាំងមូល ដោយអំណាចនៃតណ្ហា តណ្ហាវិបរីត យ៉ាងពិស្តារ ១០៨ ជាកំណត់ នេះឈ្មោះថា ការជាប់ចំពាក់ដោយតណ្ហា ។ ការជាប់ចំពាក់ដោយទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកាទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃស្បាតគឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ សេចក្តីញាប់ញ័រគឺទិដ្ឋិ សញ្ញោជនៈ គឺទិដ្ឋិ ការប្រកាន់ ការប្រកាន់ចំពោះ ការផ្តេកផ្តិត ការស្ទាបអង្អែល ផ្លូវខុស ផ្លូវអាក្រក់ ភាពនៃសេចក្តីខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ដោយការស្វែងខុស សេចក្តីប្រកាន់វិបរីត សេចក្តីប្រកាន់វិបល្លាស សេចក្តីប្រកាន់ខុស សេចក្តីប្រកាន់ថា ជារបស់ពិត ក្នុងរបស់ដែលមិនពិត

យាវតា ទ្វាសដ្ឋី ទិដ្ឋិគតានិ អយំ ទិដ្ឋិលេចោ ។ សោ ឧភន្តមភិញ្ញាយ មជ្ឈេ មន្តា ន លិម្បតីតិ សោ ឧភោ ច អន្តេ មជ្ឈញ្ច មន្តាយ អភិញ្ញាយ ជានិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា ន លិម្បតិ[១] នូបលិម្បតិ អលិត្តោ[២] អនូបលិត្តោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិសំយុត្តោ វិមរិយា-ទិកតេន ចេតសា វិហរតីតិ សោ ឧភន្តមភិញ្ញាយ មជ្ឈេ មន្តា ន លិម្បតិ ។

[១០៩] តំ ព្រូមិ មហាបុរិសោតិ អគ្គបុរិសោ សេដ្ឋបុរិសោ វិសេដ្ឋបុរិសោ បាមោក្ខបុរិសោ ឧត្តម-បុរិសោ បវរបុរិសោតិ តំ ព្រូមិ តំ កថេមិ តំ មញ្ញាមិ តំ ភណាមិ តំ បស្សាមិ[៣] តំ វោហារេមិ ។ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច មហាបុរិសោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ មហាបុរិសោ ហោតីតិ ។

---

១ ម. ឯត្ថន្តរេ ន ច បលិម្បតីតិ ទិស្សតិ ។ ២ ម. ឯត្ថន្តរេ អសំលិត្តោ ។ ៣ ម. ទីបេមិ ។

ទិដ្ឋិ ៦២ ទាំងប៉ុន្មាន ឯណា មានសភាពយ៉ាងនេះ នេះឈ្មោះថា ការជាប់ចំពាក់ដោយទិដ្ឋិ ។ ពាក្យថា ភិក្ខុនោះដឹងច្បាស់ទីបំផុតទាំងពីរនិងកណ្តាល ដោយការដឹង ហើយមិនជាប់ បានន័យថា ភិក្ខុនោះដឹងច្បាស់ យល់ ពិចារណា ត្រិះរិះ សម្តែង ធ្វើឲ្យប្រាកដ ទីបំផុតទាំងពីរនិងកណ្តាល ដោយការដឹងហើយ មិនចូលទៅជិតជាប់ គឺជាអ្នកមិនជាប់ចំពាក់ មិនចូលទៅជិតជាប់ ចេញ រលាស់ ចេញផុតស្រឡះ មិនប្រកបព្រម នៅដោយចិត្តដែលធ្វើកិលេសដូចជាទំនប់ទៅប្រាសហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះដឹងច្បាស់ទីបំផុតទាំងពីរនិងកណ្តាល ដោយការដឹងហើយ ។

[១០៩] ពាក្យថា តថាគតហៅបុគ្គលនោះថា មហាបុរស អធិប្បាយថា តថាគតហៅបុគ្គលនោះ ប្រាប់បុគ្គលនោះ សម្គាល់បុគ្គលនោះ ពោលបុគ្គលនោះ ឃើញបុគ្គលនោះ ហៅបុគ្គលនោះថា មហាបុរស បុរសដ៏លើស បុរសដ៏ប្រសើរ បុរសវិសេសបំផុត បុរសជាប្រធាន បុរសឧត្តម បុរសថ្លៃថ្លា ។ ឧទាហរណ៍ដូចព្រះសារីបុត្តមានអាយុ ទូលសួរពាក្យនេះ នឹងព្រះមានបុណ្យថា សូមទ្រង់ព្រះមេត្តាប្រោស បុគ្គលដែលគេហៅថា មហាបុរស សូមទ្រង់ព្រះមេត្តាប្រោស បុគ្គលដែលជាមហាបុរស តើដោយហេតុប៉ុន្មាន ។

៦១

## តិស្សមេត្តេយ្យមាណវកបញ្ហានិទ្ទេសោ

វិមុត្តចិត្តា ខ្វាហំ សារីបុត្ត មហាបុរិសោតិ វទាមិ អវិមុត្តចិត្តា នោ មហាបុរិសោតិ វទាមិ កថញ្ច សារីបុត្ត វិមុត្តចិត្តា ហោតិ ឥធ សារីបុត្ត ភិក្ខុ អជ្ឈត្តំ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-ទោមនស្សំ តស្ស កាយេ កាយានុបស្សិនោ វិហរតោ ចិត្តំ វិរជ្ជតិ វិមុច្ចតិ អនុបាទាយ អាសវេហិ វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-ទោមនស្សំ តស្ស ធម្មេសុ ធម្មានុបស្សិនោ វិហរតោ ចិត្តំ វិរជ្ជតិ វិមុច្ចតិ អនុបាទាយ អាសវេហិ ឯវំ ខោ សារីបុត្ត ភិក្ខុ វិមុត្តចិត្តោ វិមុត្តចិត្តា ខ្វាហំ សារីបុត្ត មហាបុរិសោតិ វទាមិ អវិមុត្តចិត្តា នោ មហាបុរិសោតិ វទាមីតិ តំ ព្រូមិ មហាបុរិសោតិ ។

## តិស្សមេត្តេយ្យមាណវកបញ្ហានិទ្ទេស

ម្នាលសារីបុត្ត តថាគតហៅថា មហាបុរស ព្រោះបុគ្គលនោះមានចិត្តរួចស្រឡះហើយ មិនហៅថា មហាបុរស ព្រោះបុគ្គលនោះមានចិត្តគ្រាន់តែជឿទេ ម្នាលសារីបុត្ត បុគ្គលមានចិត្តរួចស្រឡះហើយដោយប្រការដូចម្តេច ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ដឹងច្បាស់ មានស្មារតី បន្ទោបង់អភិជ្ឈានិងទោមនស្សក្នុងលោក ភិក្ខុនោះកាលពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ចិត្តក៏ប្រាសចាកតម្រេក រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ជាអ្នកពិចារណាឃើញរឿយៗ (នូវវេទនា) ក្នុងវេទនាទាំងឡាយ ពិចារណាឃើញរឿយៗ (នូវចិត្ត) ក្នុងចិត្ត ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាអ្នកមានព្យាយាម ដុតកម្តៅកិលេស ដឹងច្បាស់ មានស្មារតី បន្ទោបង់អភិជ្ឈានិងទោមនស្សក្នុងលោក ភិក្ខុនោះ កាលពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ចិត្តក៏ប្រាសចាកតម្រេក រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ម្នាលសារីបុត្ត ភិក្ខុមានចិត្តរួចស្រឡះហើយ យ៉ាងនេះឯង ម្នាលសារីបុត្ត តថាគតហៅថា មហាបុរស ព្រោះភិក្ខុនោះមានចិត្តផុតស្រឡះហើយ មិនហៅថា មហាបុរស ព្រោះភិក្ខុនោះមានចិត្តគ្រាន់តែជឿទេ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតហៅបុគ្គលនោះថា មហាបុរស ។

[១១០] សោ ឥធ សិព្វនិមច្ចគាតិ សិព្វនី វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសា សិព្វនី តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ សិព្វនី តណ្ហំ អច្ចគា ឧបច្ចគា អតិក្កន្តោ សមតិក្កន្តោ វីតិវត្តោតិ សោ ឥធ សិព្វនិមច្ចគា ។ តេនាហ ភគវា

កាមេសុ[១] ព្រហ្មចរិយវា (មេត្តេយ្យាតិ ភគវា)
វីតតណ្ហោ សទា សតោ
សង្ខាយ និព្វុតោ ភិក្ខុ
តស្ស នោ សន្តិ ឥញ្ជិតា
សោ ឧភន្តមភិញ្ញាយ
មជ្ឈេ មន្តា ន លិម្បតិ
តំ ព្រូមិ មហាបុរិសោតិ
សោ ឥធ សិព្វនិមច្ចគាតិ ។

១ ម. ឥធ កាមេសុត្យាទិ នត្ថិ ។

[១១០] ពាក្យថា ភិក្ខុនោះបានកន្លងតណ្ហាជាគ្រឿងចាក់ស្រេះក្នុងលោកនេះ សេចក្តីថា តណ្ហា លោកហៅថា ធម្មជាតិជាគ្រឿងចាក់ស្រេះ បានខាងសេចក្តីត្រេកអរ សេចក្តីត្រេកអរខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាជាគ្រឿងចាក់ស្រេះនេះ ដែលបុគ្គលណា លះបង់ ផ្តាច់បង់ រម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះបានកន្លង ចូលទៅកន្លង ឈានកន្លង ឈានកន្លងព្រម ប្រព្រឹត្តកន្លង នូវតណ្ហាជាគ្រឿងចាក់ស្រេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនោះបានកន្លងតណ្ហាជាគ្រឿងចាក់ស្រេះ ក្នុងលោកនេះ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តេយ្យ)

(ភិក្ខុណា) មានព្រហ្មចរិយៈ (សង្រួម) ក្នុងកាមទាំងឡាយ
ប្រាសចាកតណ្ហា មានស្មារតី សព្វកាល ដឹងហើយ
រលត់ហើយ សេចក្តីញាប់ញ័ររបស់ភិក្ខុនោះ មិនមានទេ
ភិក្ខុនោះដឹងច្បាស់ទីបំផុតទាំងពីរនិងកណ្តាល ដោយការដឹង
ហើយមិនជាប់ តថាគតហៅភិក្ខុនោះថា មហាបុរស ភិក្ខុនោះ
បានកន្លងតណ្ហាជាគ្រឿងចាក់ស្រេះ ក្នុងលោកនេះ ។

## ៦៣

### តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេសោ

[១១១] សហ គាថាបរិយោសានា[១] តេន ព្រាហ្មណេន សទ្ធឹ ឯកច្ឆន្ទា ឯកប្បយោគា ឯកាធិប្បាយា ឯកវាសនវាសិតា តេសំ អនេកបាណសហស្សានំ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ តស្ស ច ព្រាហ្មណស្ស អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិ ។ សហ អរហត្តប្បត្តា អជិនជដាវាកចីរតិទណ្ឌកមណ្ឌលុកេសា ច មស្សុ ច អន្តរហិតា ។ ភណ្ឌុកាសាយវត្ថវសនោ សង្ឃាដិបត្តចីវរធរោ អន្វត្ថប្បដិបត្តិយា បញ្ជលិកោ ភគវន្តំ នមស្សមានោ និសិន្នោ ហោតិ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេសោ ទុតិយោ ។

---

១ ម. ឯត្ថន្តរេ យេ ទិស្សតិ ។

តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេស

[១១១] ព្រាហ្មណ៍មាណពទាំងឡាយ មានអធ្យាស្រ័យតែមួយ មានប្រយោគតែមួយ មានសេចក្តីប៉ុនប៉ងតែមួយ មានធម៌ជាគ្រឿងអប់រំតែមួយ បានអប់រំហើយ (ក្នុងពុទ្ធសាសនាជាអតីត) ជាមួយគ្នា មួយអន្លើដោយព្រាហ្មណ៍ (ឈ្មោះតិស្សមេត្តេយ្យ) នោះ ធម្មចក្ខុ (សោតាបត្តិ-មគ្គ) មានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ កើតឡើងដល់ពាន់នៃសត្វដ៏ច្រើនទាំងនោះថា ធម្មជាតណាមួយ មានកិរិយា-កើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ឯ (តិស្សមេត្តេយ្យព្រាហ្មណ៍នោះ) មានចិត្តផុតស្រឡះហើយចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់ ដំណាលគ្នានឹងការចប់គាថា ។ (លំដាប់នោះ) ស្បែកខ្លា ជដា សំពត់សម្បកឈើ ឈើច្រត់ កុណ្ឌិទឹក និងសក់ ពុកមាត់ ពុកចង្កា ក៏បាត់ទៅ ជាមួយនឹងពេលដែលដល់នូវភាពនៃខ្លួនជាព្រះអរហន្ត ។ (តិស្សមេត្តេយ្យព្រាហ្មណ៍បានជាឯហិភិក្ខុ) ស្លៀកដណ្តប់នូវគណ្ឋៈ គឺសំពត់កាសាយៈ ទ្រទ្រង់នូវសង្ឃាដី បាត្រ និងចីវរ អង្គុយប្រណម្យអញ្ជលីនមស្ការព្រះមានព្រះភាគ ដោយប្រតិបត្តិសមគួរដល់ប្រយោជន៍ (ហើយប្រកាសថា) បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេស ទី ២ ។

# បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

[១១២] អនេជំ មូលទស្សាវឹ (ឥច្ចាយស្មា បុណ្ណកោ)
អត្ថិ បញ្ហេន អាគមំ
កឹ និស្សិតា ឥសយោ មនុជា
ខត្តិយា ព្រាហ្មណា ទេវតានំ
យញ្ញមកប្បឹសុ[១] បុថូ ឥធ លោកេ
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។

[១១៣] អនេជំ មូលទស្សាវិន្តិ ឯជា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ សា ឯជា តណ្ហា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អនេជោ ។ ឯជាយ បហីនត្តា អនេជោ ។

១ ម. យញ្ញមកប្បយឹសុ ។

# បុណ្ណកមាណវកប្បញ្ហានិទ្ទេស

[១១២] (បុណ្ណកៈមានអាយុ ក្រាបទូលសួរថា) យើងខ្ញុំមកដោយត្រូវការសួរប្រស្នា ចំពោះព្រះអង្គ ជាបុគ្គលមិនមានការញាប់ញ័រ ទ្រង់ឃើញនូវមូល ចុះពួកមនុស្ស គឺឥសី ក្សត្រ និងព្រាហ្មណ៍ ច្រើននាក់ ក្នុងលោកនេះ អាស្រ័យអ្វី ទើបបានសម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[១១៣] ពាក្យថា ជាបុគ្គលមិនមានការញាប់ញ័រ ទ្រង់ឃើញនូវមូល អធិប្បាយថា តណ្ហាលោកហៅថាការញាប់ញ័រ បានដល់សេចក្តីត្រេកអរ សេចក្តីត្រេកអរខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ការញាប់ញ័រ គឺតណ្ហានោះ ព្រះពុទ្ធមានព្រះភាគ លះបង់ហើយ មានឫសផ្តាច់ផ្តិលហើយ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើឲ្យដល់នូវការមិនមានបែបភាព មិនឲ្យមានការកើតឡើងតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានការញាប់ញ័រ ។ ព្រះពុទ្ធឈ្មោះថា មិនញាប់ញ័រ ព្រោះព្រះអង្គលះនូវការញាប់ញ័រ ។

៦៤

## បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

ភគវា លាភេបិ ន ឥញ្ជតិ អលាភេបិ ន ឥញ្ជតិ យសេបិ ន ឥញ្ជតិ អយសេបិ ន ឥញ្ជតិ បសំសាយបិ ន ឥញ្ជតិ និន្ទាយបិ ន ឥញ្ជតិ សុខេបិ ន ឥញ្ជតិ ទុក្ខេបិ ន ឥញ្ជតិ ន ចលតិ ន វេធតិ នប្បវេធតីតិ អនេជំ ។ មូលទស្សាវិន្តិ ភគវា មូលទស្សាវី ហេតុទស្សាវី និទានទស្សាវី សម្ភវទស្សាវី សមុដ្ឋានទស្សាវី អាហារទស្សាវី អារម្មណទស្សាវី បច្ចយទស្សាវី សមុទយទស្សាវី ។ តីណិ អកុសលមូលានិ លោភោ អកុសលមូលំ ទោសោ អកុសលមូលំ មោហោ អកុសលមូលំ ។ វុត្តញ្ហេតំ ភគវតា តីណិមានិ ភិក្ខវេ និទានានិ កម្មានំ សមុទយាយ លោភោ និទានំ កម្មានំ សមុទយាយ ទោសោ និទានំ កម្មានំ សមុទយាយ មោហោ និទានំ កម្មានំ សមុទយាយ ន ភិក្ខវេ លោភជេន កម្មេន ទោសជេន កម្មេន មោហជេន កម្មេន ទេវា បញ្ញាយន្តិ មនុស្សា បញ្ញាយន្តិ យា វា បនញ្ញាបិ កាចិ សុគតិយោ

ទុកជាក្នុងលាភ ព្រះមានព្រះភាគក៏មិនញាប់ញ័រ ទុកជាក្នុងអលាភក៏មិនញាប់ញ័រ ទុកជាក្នុងយសក៏មិនញាប់ញ័រ ទុកជាក្នុងអយសក៏មិនញាប់ញ័រ ទុកជាក្នុងសេចក្ដីសរសើរក៏មិនញាប់ញ័រ ទុកជាក្នុងសេចក្ដីតិះដៀលក៏មិនញាប់ញ័រ ទុកជាក្នុងសុខក៏មិនញាប់ញ័រ ទុកជាក្នុងទុក្ខក៏មិនញាប់ញ័រ មិនកម្រើក មិនរំភើប មិនរន្ធត់ ហេតុនោះ(លោកសួរថា) ជាបុគ្គលមិនមានការញាប់ញ័រ ។ ពាក្យថា ឃើញមូល គឺព្រះមានព្រះភាគ ទ្រង់ឃើញឫស-គល់ ឃើញហេតុ ឃើញនិទាន ឃើញសម្ភវៈ ឃើញសមុដ្ឋាន ឃើញអាហារ ឃើញអារម្មណ៍ ឃើញបច្ច័យ ឃើញសមុទ័យ ។ អកុសលមូល ៣ គឺ លោភៈ ជាអកុសលមូល ទោសៈ ជាអកុសលមូល មោហៈជាអកុសលមូល ។ សមដូចព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៣ នេះ ជាហេតុឲ្យកើតកម្មទាំងឡាយ គឺលោភៈ ជាហេតុឲ្យកើតកម្ម ទោសៈជាហេតុឲ្យកើតកម្ម មោហៈជាហេតុឲ្យកើតកម្ម ម្នាលភិក្ខុទាំងឡាយ មិនមែនដោយកម្មកើតអំពីលោភៈ ដោយកម្មកើតអំពីទោសៈ ដោយកម្មកើតអំពីមោហៈទេ ដែល(ធ្វើឲ្យ) ពួកទេវតាប្រាកដ ពួកមនុស្សប្រាកដ ឬក៏ពួកសុគតិណានីមួយសូម្បីដទៃ (ប្រាកដ)

អថខោ ភិក្ខវេ លោភជេន កម្មេន ទោសជេន កម្មេន មោហជេន កម្មេន និរយោ បញ្ញាយតិ តិរច្ឆានយោនិ បញ្ញាយតិ បិត្តិវិសយោ បញ្ញាយតិ យា វា បនញ្ញាបិ កាចិ ទុគ្គតិយោ និរយេ តិរច្ឆាន-យោនិយំ បិត្តិវិសយេ អត្តភាវាភិនិព្វត្តិយា ឥមានិ តីណិ អកុសលមូលានីតិ ភគវា ជានាតិ បស្សតិ ។ ឯវម្បិ ភគវា មូលទស្សាវី ។ បេ ។ សមុទយទស្សាវី ។ តីណិ កុសលមូលានិ អលោភោ កុសលមូលំ អទោ-សោ កុសលមូលំ អមោហោ កុសលមូលំ ។ វុត្តញ្ហេតំ ភគវតា តីណិមានិ ។ បេ ។ ន ភិក្ខវេ អលោភជេន កម្មេន អទោសជេន កម្មេន អមោហជេន កម្មេន និរយោ បញ្ញាយតិ តិរច្ឆានយោនិ បញ្ញាយតិ បិត្តិវិស-យោ បញ្ញាយតិ យា វា បនញ្ញាបិ កាចិ ទុគ្គតិយោ អថខោ ភិក្ខវេ អលោភជេន កម្មេន អទោសជេន កម្មេន អមោហជេន កម្មេន ទេវា បញ្ញាយន្តិ មនុស្សា បញ្ញាយន្តិ យា វា បនញ្ញាបិ កាចិ សុគតិ-យោ ទេវេ ច មនុស្សេ ច អត្តភាវាភិនិព្វត្តិយា ឥមានិ តីណិ កុសលមូលានីតិ ភគវា ជានាតិ បស្សតិ ។

ម្នាលភិក្ខុទាំងឡាយ តាមពិត ដោយកម្មកើតអំពីលោភៈ ដោយកម្មកើតអំពីទោសៈ ដោយកម្មកើតអំពីមោហៈ នរកទើបប្រាកដ កំណើតតិរច្ឆានប្រាកដ វិស័យនៃប្រេតប្រាកដ ឬក៏ពួកទុគ្គតិឯណានីមួយសូម្បីដទៃ ដើម្បីញុំាងអត្តភាពឲ្យកើតក្នុងនរក ក្នុងកំណើតតិរច្ឆាន ក្នុងវិស័យនៃប្រេត (ក៏ប្រាកដ) នេះអកុសលមូល ៣ ព្រះមានព្រះភាគទ្រង់ជ្រាប ទ្រង់ឃើញដូច្នេះ ។ ព្រះមានព្រះភាគ ព្រះអង្គឃើញឫសគល់ ។ បេ ។ ឃើញសមុទ័យ យ៉ាងនេះឯង ។ កុសលមូល មាន៣គឺ អលោភៈ ជាកុសលមូល អទោសៈ ជាកុសលមូល អមោហៈ ជាកុសលមូល ។ ដូចព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា កុសលមូលទាំង ៣ នេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មិនមែនដោយកម្មកើតអំពីអលោភៈ ដោយកម្មកើតអំពីអទោសៈ ដោយកម្មកើតអំពីអមោហៈទេ ដែលនរកប្រាកដ កំណើតតិរច្ឆានប្រាកដ វិស័យនៃប្រេតប្រាកដ ឬក៏ពួកទុគ្គតិឯណានីមួយសូម្បីដទៃ(ប្រាកដ) ម្នាលភិក្ខុទាំងឡាយ តាមពិត ដោយកម្មកើតអំពីអលោភៈ ដោយកម្មកើតអំពីអទោសៈ ដោយកម្មកើតអំពីអមោហៈ ពួកទេវតាទើបប្រាកដ ពួកមនុស្សប្រាកដ ឬក៏ពួកសុគតិ ឯណានីមួយសូម្បីដទៃ ដើម្បីញុំាងអត្តភាពឲ្យកើត ក្នុងទេវតានិងមនុស្ស (ក៏ប្រាកដ) នេះ កុសលមូល ៣ ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញដូច្នេះ ។

៦៧

## បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

ឯវម្បិ ភគវា មូលទស្សាវី ។ បេ ។ សមុទយទស្សាវី ។ វុត្តញ្ហេតំ ភគវតា យេកេចិ ភិក្ខវេ ធម្មា អកុសលា អកុសលភាគិយា អកុសលបក្ខិកា សព្វេ តេ អវិជ្ជាមូលកា អវិជ្ជាសមោសរណា អវិជ្ជាសមុគ្ឃាតា សព្វេ តេ សមុគ្ឃាតំ គច្ឆន្តីតិ ភគវា ជានាតិ បស្សតិ ។ ឯវម្បិ ភគវា មូលទស្សាវី ។ បេ ។ សមុទយទស្សាវី ។ វុត្តញ្ហេតំ ភគវតា យេកេចិ ភិក្ខវេ ធម្មា កុសលា កុសលភាគិយា កុសលបក្ខិកា សព្វេ តេ អប្បមាទមូលកា អប្បមាទសមោសរណា អប្បមាទោ តេសំ ធម្មានំ អគ្គមក្ខាយតីតិ ភគវា ជានាតិ បស្សតិ ។ ឯវម្បិ ភគវា មូលទស្សាវី ។ បេ ។ សមុទយទស្សាវី ។ អថវា ភគវា ជានាតិ បស្សតិ អវិជ្ជា មូលំ សង្ខារានំ សង្ខារា មូលំ វិញ្ញាណស្ស វិញ្ញាណំ មូលំ នាមរូបស្ស នាមរូបំ មូលំ សឡាយតនស្ស សឡាយតនំ មូលំ ផស្សស្ស ផស្សោ មូលំ វេទនាយ វេទនា មូលំ តណ្ហាយ តណ្ហា មូលំ ឧបាទានស្ស ឧបាទានំ មូលំ ភវស្ស ភវោ មូលំ ជាតិយា ជាតិ មូលំ ជរាមរណស្សាតិ ភគវា ជានាតិ បស្សតិ ។

បុណ្ណកមាណវកបញ្ហានិទ្ទេស

ព្រះមានព្រះភាគទ្រង់ឃើញឫសគល់ ។ បេ ។ ឃើញសមុទ័យយ៉ាងនេះឯង ។ មួយទៀត ព្រះមានព្រះភាគត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាអកុសល ជាចំណែកអកុសល ប្រព្រឹត្តទៅក្នុងពួកអកុសល ធម៌ទាំងអស់នោះ មានអវិជ្ជាជាឫស ប្រជុំចុះក្នុងអវិជ្ជា ធម៌ទាំងអស់នោះ ដល់នូវការរបើកឡើង ព្រោះរបើកឡើងនៃអវិជ្ជា ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ឃើញឫសគល់ ។ បេ ។ ឃើញសមុទ័យយ៉ាងនេះឯង ។ មួយវិញទៀត ព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង-ឡាយណានីមួយ ជាកុសល ជាចំណែកកុសល ប្រព្រឹត្តទៅក្នុងពួកកុសល ធម៌ទាំងអស់នោះ មានសេចក្ដីមិនប្រហែសជាឫស ប្រជុំចុះក្នុងសេចក្ដីមិនប្រហែស សេចក្ដីមិនប្រហែសប្រាកដជាកំពូលធម៌ទាំងនោះ ព្រះមានព្រះភាគទ្រង់ជ្រាប ទ្រង់ឃើញដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ។ បេ ។ ឃើញសមុទ័យ យ៉ាងនេះឯង ។ ន័យមួយទៀត ព្រះមានព្រះភាគទ្រង់ជ្រាបទ្រង់ឃើញថា អវិជ្ជាជាមូលនៃសង្ខារ សង្ខារជាមូលនៃវិញ្ញាណ វិញ្ញាណ ជាមូលនៃនាមរូប នាមរូប ជាមូលនៃសឡាយតនៈ សឡាយតនៈ ជាមូលនៃផស្សៈ ផស្សៈ ជាមូលនៃវេទនា វេទនា ជាមូលនៃតណ្ហា តណ្ហា ជាមូលនៃឧបាទាន ឧបាទាន ជាមូលនៃភព ភព ជាមូលនៃជាតិ ជាតិ ជាមូលនៃជរាមរណៈ ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញដូច្នេះ ។

ឯវម្បិ ភគវា មូលទស្សាវី ។ បេ ។ សមុទយទស្សាវី[១] ។ វុត្តញ្ហេតំ[២] ភគវតា យេកេចិ ភិក្ខវេ ធម្មា អកុសលា អកុសលភាគិយា អកុសលបក្ខិកា សព្វេ តេ អវិជ្ជាមូលកា អវិជ្ជាសមោសរណា អវិជ្ជាសមុគ្ឃាតា សព្វេ តេ សមុគ្ឃាតំ គច្ឆន្តីតិ ភគវា ជានាតិ បស្សតិ ។ ឯវម្បិ ភគវា មូលទស្សាវី ហេតុទស្សាវី និទានទស្សាវី សម្ភវទស្សាវី សមុដ្ឋានទស្សាវី អាហារទស្សាវី អារម្មណទស្សាវី បច្ចយទស្សាវី សមុទយទស្សាវីតិ អនេជំ មូលទស្សាវឹ ។ ឥច្ចាយស្មា បុណ្ណកោតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។ បុណ្ណកោតិ តស្ស ព្រាហ្មណស្ស នាមំ ។

[១១៤] អត្ថិ បញ្ហេន អាគមន្តិ បញ្ហត្ថិកម្ហា អាគតា បញ្ហំ បុច្ឆិតុកាមម្ហា អាគតា បញ្ហំ សោតុកាមា អាគតម្ហាតិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។

---

១ ម. ឥតោ បរំ អថវា ជានាតិ បស្សតិ ចក្ខុ មូលំ ចក្ខុរោគានំ សោតំ មូលំ សោតរោគានំ ឃានំ មូលំ ឃានរោគានំ ជិវ្ហា មូលំ ជិវ្ហារោគានំ កាយោ មូលំ កាយរោគានំ មនោ មូលំ ចេតសិកានំ ទុក្ខានន្តិ ភគវា ជានាតិ បស្សតិ ។ ឯវម្បិ ភគវា មូលទស្សាវី ហេតុទស្សាវី ។ ល ។ នាមន្តិ ទិស្សន្តិ ។ ២ ម. វុត្តញ្ហេតំ ភគវា ។ ល ។ គច្ឆន្តីតិ ភគវា ជានាតិ បស្សតីតិ នត្ថិ ។

ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ។ បេ ។ ឃើញសមុទ័យយ៉ាង នេះឯង ។ ហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាអកុសល ជាចំណែកនៃអកុសល ប្រព្រឹត្តទៅ ក្នុងពួកនៃអកុសល ធម៌ទាំងអស់នោះ មានអវិជ្ជាជាឫស ប្រជុំចុះក្នុងអវិជ្ជា ធម៌ទាំងអស់នេះ ដល់នូវការរបើកឡើង ព្រោះរបើកឡើងនៃអវិជ្ជា ព្រះមានព្រះភាគទ្រង់ជ្រាប ទ្រង់ឃើញ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ឃើញឫសគល់ ឃើញហេតុ ឃើញនិទាន ឃើញសម្ភវៈ ឃើញសមុដ្ឋាន ឃើញអាហារ ឃើញអារម្មណ៍ ឃើញបច្ច័យ ឃើញសមុទ័យ យ៉ាងនេះឯង ហេតុនោះ (លោកសួរថា) មិនមានការញាប់ញ័រ ទ្រង់ឃើញនូវមូល ។ ពាក្យថា ដូច្នេះ ក្នុងបទថា ព្រះបុណ្ណកៈមានអាយុ (ក្រាបទូលសួរ) ដូច្នេះ គឺជាពាក្យតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា បុណ្ណកៈ ជាឈ្មោះនៃព្រាហ្មណ៍នោះ ។

[១១៤] ពាក្យថា យើងខ្ញុំ មក ដោយត្រូវការសួរប្រស្នា អធិប្បាយថា យើងខ្ញុំ មក មានសេចក្តីត្រូវការដោយប្រស្នា មក មានប្រាថ្នាសួរប្រស្នា មក មានប្រាថ្នានឹងស្តាប់ប្រស្នា ហេតុនោះ (លោកសួរថា) យើងខ្ញុំ មក ដោយត្រូវការសួរប្រស្នា យ៉ាងនេះឯង ។

៦៩

បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

អថវា បញ្ហត្ថិកានំ បញ្ហំ បុច្ឆិតុកាមានំ បញ្ហំ សោតុកាមានំ អាគមំ អភិក្កមនំ ឧបសង្កមនំ បយិរុបាសនំ អត្ថីតិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។ អថវា បញ្ហាគមោ តុយ្ហំ អត្ថិ ត្វម្បិ បហុ វិសវី[១] អលមត្តោ មយា បុច្ឆិតំ កថេតុំ វិសជ្ជេតុំ សន្ទស្សេតុំ ភណិតុន្តិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។

[១១៩] កឹនិស្សិតា ឥសយោ មនុជាតិ កឹនិស្សិតាតិ កឹ និស្សិតា អាសិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តា ។ ឥសយោតិ ឥសិនាមកា យេកេចិ ឥសិបព្វជ្ជំ បព្វជិតា អាជីវកា និគណ្ឋា ជដិលា តាបសា ។ មនុជាតិ មនុស្សា វុច្ចន្តីតិ កឹនិស្សិតា ឥសយោ មនុជា ។

១ ម. ត្វំបិ ពហុ វីសតិ ។

មួយទៀត ការមក ការឈានមកចំពោះ ការចូលទៅរក ការចូលទៅអង្គុយជិត (នៃយើងខ្ញុំ ជាអ្នកមានសេចក្ដីត្រូវការដោយប្រស្នា ជាអ្នកប្រាថ្នានឹងសួរប្រស្នា ជាអ្នកប្រាថ្នានឹងស្ដាប់ប្រស្នា ហេតុនោះ (លោកសួរថា) យើងខ្ញុំមក ដោយត្រូវការសួរប្រស្នា យ៉ាងនេះឯង ។ មួយវិញទៀត ការមកដោយប្រស្នាមានចំពោះព្រះអង្គ ព្រះអង្គមានបញ្ញាច្រើន មានព្យាយាម អាចដើម្បីសម្ដែង ដោះស្រាយ ពន្យល់ ពោលប្រស្នា ដែលខ្ញុំព្រះអង្គសួរហើយ ហេតុនោះ (លោកសួរថា) យើងខ្ញុំមក ដោយត្រូវការសួរប្រស្នា យ៉ាងនេះឯង ។

[១១៥] ពាក្យថា ចុះពួកមនុស្ស គឺឥសី អាស្រ័យអ្វី ត្រង់ពាក្យថា អាស្រ័យអ្វី គឺអាស្រ័យ ផ្ដេកផ្ដួល ភ្ជាប់ ចូលទៅជិតដល់ ស្របចុះ ជឿនូវអ្វី ។ ពាក្យថា ឥសី គឺជនទាំងឡាយណានីមួយ ជាអាជីវក និគ្រន្ថ ជដិល តាបស ដែលបួសជាឥសី ជនទាំងនោះ ឈ្មោះថា ឥសី ។ ពួកមនុស្ស លោកហៅថា មនុស្ស ហេតុនោះ (លោកសួរថា) ចុះពួកមនុស្ស គឺឥសី អាស្រ័យអ្វី ។

[១១៦] ខត្តិយា ព្រាហ្មណា ទេវតានន្តិ ខត្តិយាតិ យេកេចិ ខត្តិយជាតិកា ។ ព្រាហ្មណាតិ យេកេចិ ភោវាទិកា ។ ទេវតានន្តិ អាជីវកសាវកានំ អាជីវកា ទេវតា និគន្ថសាវកានំ និគន្ថា ទេវតា ជដិលសាវកានំ ជដិលា ទេវតា បរិព្វាជកសាវកានំ បរិព្វាជកា ទេវតា អវរុទ្ធកសាវកានំ អវរុទ្ធកា ទេវតា ហត្ថិវតិកានំ ហត្ថី ទេវតា អស្សវតិកានំ អស្សា ទេវតា គោវតិកានំ គាវោ ទេវតា កុក្កុរវតិកានំ កុក្កុរា ទេវតា កាកវតិកានំ កាកា ទេវតា វាសុទេវវតិកានំ វាសុទេវោ ទេវតា ពលទេវវតិកានំ ពលទេវោ ទេវតា បុណ្ណភទ្ទវតិកានំ បុណ្ណភទ្ទោ ទេវតា មណិភទ្ទវតិកានំ មណិភទ្ទោ ទេវតា អគ្គិវតិកានំ អគ្គិ ទេវតា នាគវតិកានំ នាគា ទេវតា សុវណ្ណវតិកានំ សុវណ្ណា ទេវតា យក្ខវតិកានំ យក្ខា ទេវតា អសុរវតិកានំ អសុរា ទេវតា គន្ធព្វវតិកានំ គន្ធព្វា ទេវតា

[១១៦] អធិប្បាយពាក្យថា ក្សត្រនិងព្រាហ្មណ៍ ទើបបានសម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ ត្រង់ពាក្យថា ក្សត្រ គឺជនទាំងឡាយណានីមួយ មានជាតិជាក្សត្រ ។ ពាក្យថា ព្រាហ្មណ៍ គឺជនទាំងឡាយណានីមួយ ជាភោវាទី ។ ពាក្យថា ដល់ទេវតាទាំងឡាយ គឺពួកអាជីវក ជាទេវតារបស់ពួកសាវ័កនៃអាជីវក ពួកនិគ្រន្ថ ជាទេវតារបស់ពួកសាវ័កនៃនិគ្រន្ថ ពួកជដិល ជាទេវតារបស់ពួកសាវ័កនៃជដិល ពួកបរិព្វាជក ជាទេវតារបស់ពួកសាវ័កនៃបរិព្វាជក ពួកអវរុទ្ធកៈ ជាទេវតារបស់ពួកសាវ័កនៃអវរុទ្ធកៈ ពួកដំរី ជាទេវតារបស់អ្នកប្រព្រឹត្តវត្តដំរី ពួកសេះ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តសេះ ពួកគោ ជាទេវតារបស់អ្នកអ្នកប្រព្រឹត្តវត្តគោ ពួកឆ្កែ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តឆ្កែ ពួកក្អែក ជាទេវតារបស់ពួកអ្នកប្រព្រឹត្តវត្តក្អែក វាសុទេព ជាទេវតារបស់អ្នកប្រព្រឹត្តវត្តវាសុទេព ពលទេព ជាទេវតារបស់អ្នកប្រព្រឹត្តវត្តពលទេព បុណ្ណ-ភទ្ទៈ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តបុណ្ណភទ្ទៈ មណិភទ្ទៈ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តមណិភទ្ទៈ ភ្លើងជាទេវតារបស់អ្នកប្រព្រឹត្តវត្តភ្លើង ពួកនាគ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តនាគ ពួកគ្រុឌ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តគ្រុឌ ពួកយក្ស ជាទេវតារបស់អ្នកប្រព្រឹត្តវត្តយក្ស ពួកអសុរ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តអសុរ ពួកគន្ធព្វ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តគន្ធព្វ

៧១

បុណ្ណកមាណវកបញ្ហានិទ្ទេសោ

មហារាជវតិកានំ មហារាជា ទេវតា ចន្ទវតិកានំ ចន្ទោ ទេវតា សុរិយវតិកានំ សុរិយោ ទេវតា ឥន្ទវតិកានំ ឥន្ទោ ទេវតា ព្រហ្មវតិកានំ ព្រហ្មា ទេវតា ទេវវតិកានំ ទេវា ទេវតា ទិសាវតិកានំ ទិសា ទេវតា យេ យេសំ ទក្ខិណេយ្យា តេ តេសំ ទេវតាតិ ខត្តិយា ព្រាហ្មណា ទេវតានំ ។

[១១៧] យញ្ញមកប្បឹសុ[១] បុថូធ លោកេតិ យញ្ញោ វុច្ចតិ ទេយ្យធម្មោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ ។ យញ្ញមកប្បឹសូតិ យេបិ យញ្ញំ ឯសន្តិ គវេសន្តិ បរិយេសន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ តេបិ យញ្ញំ កប្បេន្តិ ។

១ ម. យញ្ញមកប្បយឹសុ ។

មហារាជ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តមហារាជ ព្រះចន្ទ្រ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រះចន្ទ្រ ព្រះអាទិត្យ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រះអាទិត្យ ព្រះឥន្ទ្រ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រះឥន្ទ្រ ព្រហ្ម ជាទេវតារបស់អ្នកប្រព្រឹត្តវត្តព្រហ្ម ពួកទេវតា ជាទេវតារបស់អ្នកប្រព្រឹត្តវត្តទេវតាទិស ជាទេវតារបស់អ្នកប្រព្រឹត្តវត្តទិស ជនទាំងឡាយណា ជាទក្ខិណេយ្យបុគ្គលរបស់ពួកជនណា ជនទាំងនោះ ជាទេវតារបស់ពួកជននោះ ហេតុនោះ (លោកសួរថា) ក្សត្រនិងព្រាហ្មណ៍ ទើបបានសម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ ។

[១១៧] ពាក្យថា ច្រើននាក់ ក្នុងលោកនេះ ទើបបានសម្រេចយញ្ញៈ សេចក្តីថា ទេយ្យធម៌ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប លោកហៅថា យញ្ញៈ ។ ពាក្យថា ទើបបានសម្រេចយញ្ញៈ គឺពួកជនណា ស្វែងរក ស្វះស្វែងរក ដើររកនូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ពួកជនទាំងនោះ ឈ្មោះថា សម្រេចយញ្ញៈ ។

យេបិ យញ្ញំ អភិសង្ខរោន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ តេបិ យញ្ញំ កប្បេន្តិ ។ យេបិ យញ្ញំ ទេន្តិ យជន្តិ បរិច្ចជន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ តេបិ យញ្ញំ កប្បេន្តិ ។ បុច្ឆាមិ យញ្ញា វា ឯតេ បុច្ឆ យញ្ញយជកា[១] វា ឯតេ បុច្ឆ ទក្ខិណេយ្យា វា ឯតេ បុច្ឆ ។ កតមំ យញ្ញា វា ឯតេ បុច្ឆ[២] ។ ឯតេ យញ្ញា បុច្ឆ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ ឯវំ យញ្ញា វា ឯតេ បុច្ឆ ។ កតមំ យញ្ញយជកា វា ឯតេ បុច្ឆ ។ ឯតេ យញ្ញយជកា បុច្ឆ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ឯវំ យញ្ញយជកា វា ឯតេ បុច្ឆ ។

១ ម. យញ្ញយាជកា ។ ២ ម. បុច្ឆ ពហុកានំ ។

សូម្បីពួកជនណា តាក់តែងនូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ពួកជនទាំងនោះ ក៏ឈ្មោះថា សម្រេចយញ្ញៈ ។ ពួកជនណា ឲ្យ បូជា លះបង់នូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជនទាំងនោះ ក៏ឈ្មោះថា សម្រេចយញ្ញៈ ។ ពាក្យថា ច្រើន គឺពួកយញ្ញទ៉ុះច្រើន ឬពួកអ្នកបូជាយញ្ញៈទ៉ុះច្រើន ឬក៏ពួកជនដែលគួរដល់ទក្ខិណាទ៉ុះ ច្រើន ។ ពួកយញ្ញៈទ៉ុះ ច្រើន តើដូចម្ដេច ។ ពួកយញ្ញៈទ៉ុះ មានច្រើន គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ពួកយញ្ញៈទ៉ុះ មានច្រើន យ៉ាងនេះ ។ ពួកអ្នកបូជាយញ្ញៈទ៉ុះ មានច្រើន តើដូចម្ដេច ។ ពួកអ្នកបូជាយញ្ញៈទ៉ុះ មានច្រើន គឺក្សត្រ ព្រាហ្មណ៍ អ្នកជំនួញ អ្នកគ្រួ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ពួកអ្នកបូជាយញ្ញទ៉ុះ មានច្រើន យ៉ាងនេះ ។

បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

កថំ ទក្ខិណេយ្យា វា ឯតេ បុថូ ។ ឯតេ ទក្ខិណេយ្យា បុថូ សមណព្រាហ្មណា យាចកវណិព្វកសាវកា ឯវំ ទក្ខិណេយ្យា វា ឯតេ បុថូ ។ ឥធ លោកេតិ មនុស្សលោកេតិ យញ្ញមកប្បឹសុ បុថូធ លោកេ ។

[១១៨] បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ បុច្ឆាតិ តិស្សោ បុច្ឆា អទិដ្ឋជោតនា បុច្ឆា ទិដ្ឋសំសន្ទនា បុច្ឆា វិមតិច្ឆេទនា បុច្ឆា ។

កតមា អទិដ្ឋជោតនា បុច្ឆា ។ បកតិយា លក្ខណំ អញ្ញាតំ ហោតិ អទិដ្ឋំ អតុលិតំ អតិរិតំ អវិភាវិតំ អវិភូតំ តស្ស ញាណាយ ទស្សនាយ តុលនាយ តិរណាយ វិភាវនត្ថាយ វិភូតត្ថាយ បញ្ហំ បុច្ឆតិ អយំ អទិដ្ឋជោតនា បុច្ឆា ។

ពួកជនដែលគួរដល់ទក្ខិណាទ៍ុះ មានច្រើន តើដូចម្ដេច ។ ពួកជនដែលគួរដល់ទក្ខិណាទ៍ុះ មានច្រើន គឺសមណព្រាហ្មណ៍ ស្មូម ជនអ្នកពណ៌នា ហើយសូម និងសាវ័ក ពួកជនដែលគួរដល់ទក្ខិណាទ៍ុះ មានច្រើន យ៉ាងនេះ ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងមនុស្សលោក ហេតុនោះ លោកសួរថា ច្រើនគ្នា ក្នុងលោកនេះ សម្រេចយញ្ញៈ ។

[១១៨] អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គ ប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា សួរ បានដល់ ការសួរ ៣ គឺការសួរសម្រាប់បំភ្លឺសេចក្ដីដែលមិនយល់ ១ ការសួរសម្រាប់ប្រៀបផ្ទឹមសេចក្ដីដែលខ្លួនយល់ហើយ ១ ការសួរសម្រាប់កាត់សេចក្ដីសង្ស័យ ១ ។

ការសួរសម្រាប់បំភ្លឺសេចក្ដីដែលមិនយល់ តើដូចម្ដេច ។ លក្ខណៈជាធម្មជាត ដែលបុគ្គលមិនបានដឹង មិនបានឃើញ មិនបានថ្លឹង មិនបានពិចារណា មិនបានយល់ច្បាស់ មិនបានប្រាកដដោយប្រក្រតី បុគ្គលសួរប្រស្នាដើម្បីដឹង ឃើញ ថ្លឹង ពិចារណា ដើម្បីប្រយោជន៍ដល់ការយល់ច្បាស់ ដើម្បីប្រយោជន៍ឲ្យប្រាកដ នូវលក្ខណៈនោះនេះ ការសួរសម្រាប់បំភ្លឺសេចក្ដីដែលមិនយល់ ។

កតមា ទិដ្ឋសំសន្ទនា បុច្ឆា ។ បកតិយា លក្ខណំ ញាតំ ហោតិ ទិដ្ឋំ តុលិតំ តីរិតំ វិភាវិតំ វិភូតំ អញ្ញេហិ បណ្ឌិតេហិ សទ្ធឹ សំសន្ទនត្ថាយ បញ្ហំ បុច្ឆតិ អយំ ទិដ្ឋសំសន្ទនា បុច្ឆា ។

កតមា វិមតិច្ឆេទនា បុច្ឆា ។ បកតិយា សំ-សយំ បក្ខន្ទោ ហោតិ វិមតឹ បក្ខន្ទោ ទ្វេឡ្ហក-ជាតោ ឯវំ នុ ខោ ន នុ ខោ កិន្នុ ខោ កថំ នុខោតិ សោ វិមតិច្ឆេទនត្ថាយ បញ្ហំ បុច្ឆតិ អយំ វិមតិច្ឆេទនា បុច្ឆា ។ ឥមា តិស្សោ បុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា មនុស្សបុច្ឆា អមនុស្ស-បុច្ឆា និម្មិតបុច្ឆា ។

កតមា មនុស្សបុច្ឆា ។ មនុស្សា ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ ភិក្ខូ បុច្ឆន្តិ ភិក្ខុនិយោ បុច្ឆន្តិ ឧបាសកា បុច្ឆន្តិ ឧបាសិកាយោ បុច្ឆន្តិ រាជានោ បុច្ឆន្តិ ខត្តិយា បុច្ឆន្តិ ព្រាហ្មណា បុច្ឆន្តិ វេស្សា បុច្ឆន្តិ សុទ្ទា បុច្ឆន្តិ គហដ្ឋា បុច្ឆន្តិ បព្វ-ជិតា បុច្ឆន្តិ អយំ មនុស្សបុច្ឆា ។

ការសួរសម្រាប់ប្រៀបផ្ទឹមសេចក្តីដែលខ្លួនយល់ហើយ តើដូចម្តេច ។ លក្ខណៈ ជាធម្មជាត ដែលបុគ្គលបានដឹង បានឃើញ បានថ្លឹង បានពិចារណា បានយល់ច្បាស់ ប្រាកដដោយប្រក្រតី បុគ្គលសួរប្រស្នា ដើម្បីប្រយោជន៍ដល់ការប្រៀបផ្ទឹម ជាមួយនឹងបណ្ឌិតទាំងឡាយឯទៀត នេះ ការសួរសម្រាប់ប្រៀបផ្ទឹមសេចក្តីដែលខ្លួនយល់ហើយ ។

ការសួរសម្រាប់កាត់សេចក្តីសង្ស័យ តើដូចម្តេច ។ បុគ្គលស្ទុះទៅកាន់សេចក្តីសង្ស័យដោយប្រក្រតី ស្ទុះទៅកាន់សេចក្តីងឿងឆ្ងល់ មានចិត្តបែកជាពីរថា យ៉ាងនេះទេឬ ឬមិនមែនទេ ហេតុដូចម្តេចហ្ន៎ ប្រការដូចម្តេចហ្ន៎ បុគ្គលនោះ សួរប្រស្នាដើម្បីកាត់សេចក្តីសង្ស័យ នេះ ការសួរសម្រាប់កាត់សេចក្តីសង្ស័យ ។ នេះ ការសួរ ៣ ។

ការសួរ ៣ ដទៃទៀត គឺការសួររបស់មនុស្ស ១ ការសួររបស់អមនុស្ស ១ ការសួររបស់ពុទ្ធនិម្មិត ១ ។

ការសួររបស់មនុស្ស តើដូចម្តេច ។ មនុស្សទាំងឡាយចូលទៅគាល់ព្រះពុទ្ធមានព្រះភាគសួរប្រស្នា គឺពួកភិក្ខុសួរ ពួកភិក្ខុនីសួរ ពួកឧបាសកសួរ ពួកឧបាសិកាសួរ ពួកព្រះរាជាសួរ ពួកក្សត្រសួរ ពួកព្រាហ្មណ៍សួរ ពួកអ្នកជំនួញសួរ ពួកអ្នកគ្រួសួរ ពួកគ្រហស្ថសួរ ពួកបព្វជិតសួរ នេះ ការសួររបស់មនុស្ស ។

៧៤

## បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

កតមា អមនុស្សបុច្ឆា ។ អមនុស្សា ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ នាគា បុច្ឆន្តិ សុបណ្ណា បុច្ឆន្តិ យក្ខា បុច្ឆន្តិ អសុរា បុច្ឆន្តិ គន្ធព្វា បុច្ឆន្តិ មហារាជានោ បុច្ឆន្តិ ឥន្ទា បុច្ឆន្តិ ព្រហ្មានោ បុច្ឆន្តិ ទេវតាយោ បុច្ឆន្តិ អយំ អមនុស្សបុច្ឆា ។

កតមា និម្មិតបុច្ឆា ។ យំ ភគវា រូបំ អភិនិម្មិនាតិ មនោមយំ សព្វង្គប្បច្ចង្គំ អហីនិន្ទ្រិយំ សោ និម្មិតោ ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆតិ ភគវា វិសជ្ជេតិ អយំ និម្មិតបុច្ឆា ។ ឥមា តិស្សោ បុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អត្តត្ថបុច្ឆា បរត្ថបុច្ឆា ឧភយត្ថបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ទិដ្ឋធម្មិកត្ថបុច្ឆា សម្បរាយិកត្ថបុច្ឆា បរមត្ថបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អនវជ្ជត្ថបុច្ឆា និក្កិលេសបុច្ឆា វោទានត្ថបុច្ឆា ។

បុណ្ណកមាណវកប្បញ្ហានិទ្ទេស

ការសួររបស់អមនុស្ស តើដូចម្តេច ។ អមនុស្សទាំងឡាយចូលទៅគាល់ព្រះពុទ្ធមានព្រះភាគ សួរប្រស្នា គឺពួកនាគសួរ ពួកគ្រុឌសួរ ពួកយក្សសួរ ពួកអសុរសួរ ពួកគន្ធព្វសួរ ពួកមហារាជសួរ ពួកព្រះឥន្ទ្រសួរ ពួកព្រហ្មសួរ ពួកទេវតាសួរ នេះ ការសួររបស់អមនុស្ស ។

ការសួររបស់ពុទ្ធនិម្មិត តើដូចម្តេច ។ ព្រះមានព្រះភាគនិម្មិតរូបណាដ៏សម្រេចដោយព្រះទ័យ មានអវយវៈតូចធំគ្រប់សព្វ មានឥន្ទ្រិយមិនខ្វះខាត ពុទ្ធនិម្មិតនោះចូលទៅគាល់ព្រះពុទ្ធមានព្រះភាគសួរប្រស្នា ព្រះមានព្រះភាគទ្រង់ដោះស្រាយ នេះ ការសួររបស់ពុទ្ធនិម្មិត ។ នេះការសួរ ៣ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍របស់ខ្លួន ១ ការសួរប្រយោជន៍របស់បុគ្គលដទៃ ១ ការសួរប្រយោជន៍ទាំងពីរ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ការសួរប្រយោជន៍ក្នុងបរលោក ១ ការសួរប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរប្រយោជន៍មិនមានទោស ១ ការសួរប្រយោជន៍មិនមានសេចក្តីសៅហ្មង ១ ការសួរប្រយោជន៍ដ៏ផូរផង់ ១ ។

អបរាបិ តិស្សោ បុច្ឆា អតីតបុច្ឆា អនាគតបុច្ឆា បច្ចុប្បន្នបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អជ្ឈត្តបុច្ឆា ពហិទ្ធាបុច្ឆា អជ្ឈត្តពហិទ្ធាបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា កុសលបុច្ឆា អកុស-លបុច្ឆា អព្យាកតបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ខន្ធបុច្ឆា ធាតុបុច្ឆា អាយតនបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា សតិប្បដ្ឋានបុច្ឆា សម្ម-ប្បធានបុច្ឆា ឥទ្ធិបាទបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ឥន្ទ្រិយបុច្ឆា ពលបុច្ឆា ពោជ្ឈង្គបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា មគ្គបុច្ឆា ផលបុច្ឆា និព្វានបុច្ឆា ។

ការសួរ ៣ ដទៃទៀត គឺការសួរហេតុជាអតីត ១ ការសួរហេតុជាអនាគត ១ ការសួរហេតុជាបច្ចុប្បន្ន ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរធម៌ខាងក្នុង ១ ការសួរធម៌ខាងក្រៅ ១ ការសួរធម៌ទាំងខាងក្នុងទាំងខាងក្រៅ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរធម៌ជាកុសល ១ ការសួរធម៌ជាអកុសល ១ ការសួរធម៌ជាអព្យាកត ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរខន្ធ ១ ការសួរធាតុ ១ ការសួរអាយតនៈ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរសតិប្បដ្ឋាន ១ ការសួរសម្មប្បធាន ១ ការសួរឥទ្ធិបាទ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរឥន្ទ្រិយ ១ ការសួរពលៈ ១ ការសួរពោជ្ឈង្គៈ ១ ។

ការសួរ ៣ ដទៃទៀត គឺការសួរមគ្គ ១ ការសួរផល ១ ការសួរនិព្វាន ១ ។

៧៧

បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

បុច្ឆាមិ តន្តិ បុច្ឆាមិ តំ យាចាមិ តំ អជ្ឈេសាមិ តំ បសាទេមិ តំ កថេស្សុ មេតិ បុច្ឆាមិ តំ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។ តេនាហ សោ ព្រាហ្មណោ

អនេជំ មូលទស្សាវី (ឥច្ចាយស្មា បុណ្ណកោ)
អត្ថិ បញ្ហេន អាគមំ
កិំនិស្សិតា ឥសយោ មនុជា
ខត្តិយា ព្រាហ្មណា ទេវតានំ
យញ្ញមកប្បឹសុ បុថូធ លោកេ
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ ។

បុណ្ណកមាណវកប្បញ្ហានិទ្ទេស

ពាក្យថា ខ្ញុំព្រះអង្គទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គទូលសួរព្រះអង្គ អង្វរព្រះអង្គ អារាធនាព្រះអង្គ ញ៉ាំងព្រះអង្គឲ្យជ្រះថ្លា សូមព្រះអង្គប្រាប់ (សេចក្តីនោះ) ដល់ខ្ញុំព្រះអង្គ ហេតុនោះ (លោកសួរថា) ខ្ញុំព្រះអង្គទូលសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នេះ គឺពាក្យហៅ ដោយគោរព ។ បេ ។ ការបញ្ញត្តថា មានព្រះភាគ នេះ កើតហើយ ព្រោះការត្រាស់ដឹង ។

ពាក្យថា សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត ផ្តើម បើក ចែករលែក ធ្វើឲ្យរាក់ប្រកាស ហេតុនោះ (លោកសួរថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

(ព្រះបុណ្ណកៈមានអាយុ ក្រាបទូលសួរថា) យើងខ្ញុំមកដោយត្រូវការសួរប្រស្នាចំពោះព្រះអង្គ ជាបុគ្គលមិនមានការញាប់ញ័រ ឃើញនូវមូល បុះពួកមនុស្ស គឺឥសី ក្សត្រនិងព្រាហ្មណ៍ ជាច្រើននាក់ ក្នុងលោកនេះ អាស្រ័យអ្វីទើបបានសម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[១១៩] យេកេចិមេ ឥសយោ មនុជា
(បុណ្ណកាតិ ភគវា)
ខត្តិយា ព្រាហ្មណា ទេវតានំ
យញ្ញមកប្បឹសុ បុថូធ លោកេ
អាសីសមានា បុណ្ណក ឥត្ថត្តំ[១]
ជរំ សិតា យញ្ញមកប្បយឹសុ ។

[១២០] យេកេចិមេ ឥសយោ មនុជាតិ យេកេចិមេតិ[២] សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ យេកេចិមេតិ ។ ឥសយោតិ ឥសិនាមកា យេកេចិ ឥសិបព្វជ្ជំ បព្វជិតា អាជីវកា និគណ្ឋា ជដិលា តាបសា ។ មនុជាតិ មនុស្សា វុច្ចន្តីតិ យេកេចិមេ ឥសយោ មនុជា ។ បុណ្ណកាតិ ភគវា តំ[៣] ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ បុណ្ណកាតិ ភគវា ។

---

១ ម. ឥត្ថិភាវំ ។ ២ ម. យេកេចីតិ ។ ៣ ម. ឥតោ បរំ តំ ព្រាហ្មណន្ត្យាតិ នត្ថិ ។

[១១៩] (ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ) ពួកមនុស្ស ណានីមួយ គឺឥសី ក្សត្រ និងព្រាហ្មណ៍ ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ ម្នាលបុណ្ណកៈ ពួកសត្វទាំងនោះ ប្រាថ្នាភាពនេះ អាស្រ័យ ជរាទើបបានសម្រេចយញ្ញៈឡើង ។

[១២០] ពាក្យថា ពួកមនុស្ស ណានីមួយ គឺឥសី ត្រង់ពាក្យថា ណានីមួយ គឺ សព្វគ្រប់ សព្វទាំងអស់ ឥតសេសសល់ គ្មាន សេសសល់ ពាក្យថា ណានីមួយ នេះជាពាក្យរួបរួម ។ ពាក្យថា ឥសី គឺជនទាំងឡាយ ណានីមួយ ជាអាជីវក និគ្រន្ថ ជដិល តាបស បួសជាឥសី (ជនទាំងនោះ) ឈ្មោះថា ឥសី ។ ពួកមនុស្ស លោកហៅថា មនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកមនុស្ស ណានីមួយ គឺឥសី ។ ពាក្យថា ម្នាលបុណ្ណកៈ គឺព្រះមានព្រះភាគ ទ្រង់ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នេះ ជាពាក្យហៅ ដោយគោរព ។ បេ ។ ការបញ្ញត្តថា មានព្រះភាគ នេះ (កើតហើយ) ព្រោះការត្រាស់ដឹង ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ ។

៧៩

បុណ្ណកមាណវកបញ្ហានិទ្ទេសោ

[១៦១] ខត្តិយា ព្រាហ្មណា ទេវតានន្តិ ខត្តិយាតិ យេកេចិ ខត្តិយជាតិកា ។ ព្រាហ្មណាតិ យេកេចិ ភោវាទិកា ។ ទេវតានន្តិ អាជីវកសាវកានំ អាជីវកា ទេវតា ។ បេ ។ ទិសាវតិកានំ ទិសា ទេវតា យេ យេសំ ទក្ខិណេយ្យា តេ តេសំ ទេវតាតិ ខត្តិយា ព្រាហ្មណា ទេវតានំ ។

[១៦២] យញ្ញមកប្បឹសុ បុថូធ លោកេតិ យញ្ញោ វុច្ចតិ ទេយ្យធម្មោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ ។ យញ្ញមកប្បឹសូតិ យេបិ យញ្ញំ ឯសន្តិ គវេសន្តិ បរិយេសន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ តេបិ យញ្ញំ កប្បេន្តិ ។

បុណ្ណកមាណវកប្បញ្ហានិទ្ទេស

[១២១] ពាក្យថា ក្សត្រនិងព្រាហ្មណ៍ (សម្រេចយញ្ញៈ) ដល់ទេវតាទាំងឡាយ ត្រង់ពាក្យថា ក្សត្រ គឺជនទាំងឡាយ ណានីមួយមានជាតិជាក្សត្រិយ៍ ។ ពាក្យថា ព្រាហ្មណ៍ គឺជនទាំងឡាយណានីមួយ ជាភោវាទី ។ ពាក្យថា ដល់ទេវតាទាំងឡាយ គឺពួកអាជីវកជាទេវតា របស់ពួកសាវ័កនៃអាជីវក ។ បេ ។ ទិសទាំងឡាយ ជាទេវតារបស់អ្នកប្រព្រឹត្តវត្តទិស ពួកជនណា ជាទក្ខិណេយ្យបុគ្គល របស់ពួកជនណា ជនទាំងនោះ ជាទេវតារបស់ពួកជននោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ក្សត្រនិងព្រាហ្មណ៍ (សម្រេចយញ្ញៈ) ដល់ទេវតាទាំងឡាយ ។

[១២២] ពាក្យថា ជាច្រើននាក់ ក្នុងលោកនេះ សម្រេចយញ្ញៈ សេចក្តីថា ទេយ្យធម៌ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប លោកហៅថា យញ្ញៈ ។ ពាក្យថា សម្រេចយញ្ញៈ សេចក្តីថា សូម្បីជនទាំងឡាយណា ប្រាថ្នារក ស្វែងរក ស្វះស្វែងរក នូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់-អាស្រ័យ គ្រឿងប្រទីប ជនទាំងនោះ ឈ្មោះថា សម្រេចយញ្ញៈ ។

បុថូតិ យញ្ញា វា ឯតេ បុថូ យញ្ញយជកា វា ឯតេ បុថូ ទក្ខិណេយ្យា វា ឯតេ បុថូ ។ កថំ យញ្ញា វា ឯតេ បុថូ ។ បេ ។ ឯវំ ទក្ខិណេយ្យា វា ឯតេ បុថូ ។ ឥធ លោកេតិ មនុស្សលោកេតិ យញ្ញមកប្បឹសុ បុថូធ លោកេ ។

[១២៣] អាសីសមានា បុណ្ណក ឥត្ថត្តន្តិ អាសីសមានាតិ រូបប្បដិលាភំ អាសីសមានា សទ្ទប្បដិលាភំ អាសីសមានា គន្ធប្បដិលាភំ អាសីសមានា រសប្បដិលាភំ អាសីសមានា ផោដ្ឋព្វប្បដិលាភំ អាសីសមានា បុត្តប្បដិលាភំ អាសីសមានា ទារប្បដិលាភំ អាសីសមានា ធនប្បដិលាភំ អាសីសមានា យសប្បដិលាភំ អាសីសមានា ឥស្សរិយប្បដិលាភំ អាសីសមានា ខត្តិយមហាសាលកុលេ អត្តភាវប្បដិលាភំ អាសីសមានា ព្រាហ្មណមហាសាលកុលេ អត្តភាវប្បដិលាភំ អាសីសមានា គហបតិមហាសាលកុលេ អត្តភាវប្បដិលាភំ អាសីសមានា

ពាក្យថា ជាច្រើននាក់ គឺយញ្ញៈទាំងនុ៎ះច្រើន ឬពួកអ្នកស្វែងរកយញ្ញៈនោះច្រើន ឬក៏ពួកជនដែលគួរដល់ទក្ខិណានុ៎ះ ច្រើន ។ ពួកយញ្ញៈទាំងនុ៎ះច្រើន តើដោយប្រការដូចម្តេច ។ បេ ។ ពួកជនដែលគួរដល់ទក្ខិណាទាំងនោះច្រើន យ៉ាងនេះ ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងមនុស្សលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ជាច្រើននាក់ ក្នុងលោកនេះសម្រេចយញ្ញៈ ។

[១២៣] អធិប្បាយពាក្យថា ម្នាលបុណ្ណកៈ (ជនទាំងនោះ) ប្រាថ្នានូវភាពនេះ ត្រង់ពាក្យថា ប្រាថ្នា គឺប្រាថ្នាការបានចំពោះរូប ប្រាថ្នាការបានចំពោះសំឡេង ប្រាថ្នាការបានចំពោះក្លិន ប្រាថ្នាការបានចំពោះរស ប្រាថ្នាការបានចំពោះផ្សព្វ ប្រាថ្នាការបានចំពោះកូន ប្រាថ្នាការបានចំពោះប្រពន្ធ ប្រាថ្នាការបានចំពោះទ្រព្យ ប្រាថ្នាការបានចំពោះយស ប្រាថ្នាការបានចំពោះភាពជាឥស្សរៈ ប្រាថ្នាការបានចំពោះអត្តភាព ក្នុងត្រកូលនៃខត្តិយមហាសាល ប្រាថ្នាការបានចំពោះអត្តភាព ក្នុងត្រកូលនៃព្រាហ្មណមហាសាល ប្រាថ្នាការបានចំពោះអត្តភាពក្នុងត្រកូល នៃគហបតិមហាសាល

## បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

ចាតុម្មហារាជិកេសុ ទេវេសុ អត្តភាវប្បដិលាភំ អាសី-
សមានា តាវត្តឹសេសុ ទេវេសុ យាមេសុ ទេវេសុ តុសិ-
តេសុ ទេវេសុ និម្មានរតីសុ ទេវេសុ បរនិម្មិតវសវត្តីសុ
ទេវេសុ ព្រហ្មកាយិកេសុ ទេវេសុ អត្តភាវប្បដិលាភំ
អាសីសមានា ឥច្ឆមានា សាទិយមានា បត្ថយមានា
បិហយមានា អភិជប្បមានាតិ អាសីសមានា ។
បុណ្ណក ឥត្ថតន្តិ ឯត្ថ អត្តភាវាភិនិព្វត្តឹ អាសីសមានា
ឯត្ថ ខត្តិយមហាសាលកុលេ អត្តភាវាភិនិព្វត្តឹ
អាសីសមានា ឯត្ថ ព្រាហ្មណមហាសាលកុលេ
អត្តភាវាភិនិព្វត្តឹ អាសីសមានា ឯត្ថ គហបតិ-
មហាសាលកុលេ អត្តភាវាភិនិព្វត្តឹ អាសីសមានា
ឯត្ថ ចាតុម្មហារាជិកេសុ ទេវេសុ អត្តភាវាភិនិព្វត្តឹ
អាសីសមានា ឯត្ថ តាវត្តឹសេសុ ទេវេសុ ឯត្ថ
យាមេសុ ទេវេសុ ឯត្ថ តុសិតេសុ ទេវេសុ ឯត្ថ
និម្មានរតីសុ ទេវេសុ ឯត្ថ បរនិម្មិតវសវត្តីសុ ទេវេសុ

ប្រាថ្នាការបានចំពោះអត្តភាព ក្នុងពួកទេវតា ជាន់ចាតុម្មហារាជិកៈ ប្រាថ្នាចង់បាន ត្រេកអរ បំណង ស្រឡាញ់ ជាប់ចិត្ត នូវការបាន ចំពោះអត្តភាព ក្នុងពួកទេវតាជាន់តាវត្តិង្ស ក្នុងពួកទេវតាជាន់យាមៈ ក្នុងពួកទេវតាជាន់តុសិត ក្នុងពួកទេវតាជាន់និម្មានរតី ក្នុងពួកទេវតាជាន់ បរនិម្មិតវសវត្តី ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកនៃព្រហ្ម ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រាថ្នា ។ ពាក្យថា ម្នាលបុណ្ណកៈ (ជនទាំងនោះ ប្រាថ្នា) នូវភាពនេះ សេចក្តីថា ប្រាថ្នាការកើតអត្តភាព ក្នុងត្រកូល ទាំងនេះ គឺ ប្រាថ្នាការកើតអត្តភាព ក្នុងត្រកូលខត្តិយមហាសាលនេះ ប្រាថ្នាការកើតអត្តភាព ក្នុងត្រកូលព្រាហ្មណមហាសាលនេះ ប្រាថ្នា ការកើតអត្តភាព ក្នុងត្រកូលគហបតិមហាសាលនេះ ប្រាថ្នាការកើត អត្តភាព ក្នុងពួកទេវតាជាន់ចាតុម្មហារាជិកៈនេះ ប្រាថ្នា ចង់បាន ត្រេកអរ បំណង ស្រឡាញ់ ជាប់ចិត្ត នូវការកើតអត្តភាពក្នុងពួកទេវតា ជាន់តាវត្តិង្សនេះ ក្នុងពួកទេវតាជាន់យាមៈនេះ ក្នុងពួកទេវតាជាន់តុសិត នេះ ក្នុងពួកទេវតាជាន់និម្មានរតីនេះ ក្នុងពួកទេវតាជាន់បរនិម្មិតវសវត្តីនេះ

ឯត្ថ ព្រហ្មកាយិកេសុ ទេវេសុ អត្តភាវាភិនិព្វត្តី អាសីសមានា ឥច្ឆមានា សាទិយមានា បត្ថយមានា បិហាយមានា អភិជប្បមានាតិ អាសីសមានា បុណ្ណក ឥត្ថត្តំ ។

[១២៤] ជរំ សិតា យញ្ញមកប្បយឹសូតិ ជរំ សិតាតិ ជរនិស្សិតា ព្យាធិនិស្សិតា មរណនិស្សិតា សោកបរិទេវទុក្ខទោមនស្សុបាយាសនិស្សិតា យទេវ តេ ជាតិនិស្សិតា វា តទេវ តេ ជរានិស្សិតា យទេវ តេ ជរានិស្សិតា វា តទេវ តេ ព្យាធិនិស្សិតា យទេវ តេ ព្យាធិនិស្សិតា វា តទេវ តេ មរណនិស្សិតា យទេវ តេ មរណនិស្សិតា វា តទេវ តេ សោកបរិទេវទុក្ខទោមនស្សុបាយាសនិស្សិតា យទេវ តេ សោកបរិទេវទុក្ខទោមនស្សុបាយាសនិស្សិតា វា តទេវ តេ គតិនិស្សិតា យទេវ តេ គតិនិស្សិតា វា តទេវ តេ ឧបបត្តិនិស្សិតា យទេវ

ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកព្រហ្មនេះ ហេតុនោះ(ទ្រង់ត្រាស់ថា) ម្នាលបុណ្ណកៈ (ពួកជនទាំងនោះ) ប្រាថ្នាភាពនេះ ។

[១២៤] អធិប្បាយពាក្យថា អាស្រ័យជរា ទើបបានសម្រេចយ័ញ្ញឡើង ត្រង់ពាក្យថា អាស្រ័យជរា គឺអាស្រ័យជរា អាស្រ័យព្យាធិ អាស្រ័យមរណៈ អាស្រ័យសោក សេចក្តីខ្សឹកខ្សួល ទុក្ខ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ សត្វទាំងនោះ អាស្រ័យជាតិ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យជរា ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យជរា ក្នុងកាលណា សត្វទាំងនោះ អាស្រ័យព្យាធិ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យព្យាធិ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យមរណៈ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យមរណៈ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យសោក សេចក្តីខ្សឹកខ្សួល ទុក្ខ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យសោក សេចក្តីខ្សឹកខ្សួល ទុក្ខ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យគតិ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យគតិក្នុងកាលណា សត្វទាំងនោះ អាស្រ័យឧបបត្តិក្នុងកាលនោះ

បុណ្ណកមាណវកបញ្ហានិទ្ទេសោ

តេ ឧបបត្តិនិស្សិតា វា តថេវ តេ បដិសន្ធិនិស្សិតា យថេវ តេ បដិសន្ធិនិស្សិតា វា តថេវ តេ ភវនិស្សិ-តា យថេវ តេ ភវនិស្សិតា វា តថេវ តេ សំសារ-និស្សិតា យថេវ តេ សំសារនិស្សិតា វា តថេវ តេ វដ្តនិស្សិតា អាសិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តាតិ[១] ឥធំ សិតា យញ្ញមកប្បយឹសុ ។ តេនាហ ភគវា

យេកេចិមេ ឥសយោ មនុជា

(បុណ្ណកាតិ ភគវា)

ខត្តិយា ព្រាហ្មណា ទេវតានំ

យញ្ញមកប្បឹសុ បុថូធ លោកេ

អាសីសមានា បុណ្ណក ឥត្ថត្តំ

ឥធំ សិតា យញ្ញមកប្បយឹសូតិ ។

១ ម. ឥមេ បាឋា មរម្មបោត្ថកេន អហោឞិ សោធិតា ។

សត្វទាំងនោះ អាស្រ័យឧបបត្តិក្នុងកាលណា សត្វទាំងនោះ អាស្រ័យបដិសន្ធិក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យបដិសន្ធិ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យភពក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យភព ក្នុងកាលណា សត្វទាំងនោះ អាស្រ័យសង្សារ ក្នុងកាលនោះ សត្វទាំងនោះ អាស្រ័យសង្សារ ក្នុងកាលណា សត្វទាំងនោះ អាស្រ័យវដ្ដៈ អាស្រ័យនៅ ជាប់នៅ ចូលទៅជិតដល់ លិចចុះ ចុះស៊ប់ ក្នុងកាលនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) អាស្រ័យជរា ទើបសម្រេចយញ្ញៈឡើង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ) ពួកមនុស្ស
ណានីមួយ គឺឥសី ក្សត្រ និងព្រាហ្មណ៍ ជាច្រើននាក់
ក្នុងលោកនេះ សម្រេចយញ្ញៈ ដល់ទេវតាទាំងឡាយ
ម្នាលបុណ្ណកៈ ពួកសត្វទាំងនោះ ប្រាថ្នាភាពនេះ អាស្រ័យ
ជរា ទើបសម្រេចយញ្ញៈឡើង ។

[១២៥] យេកេចិមេ ឥសយោ មនុជា
(ឥច្ចាយស្មា បុណ្ណកោ)
ខត្តិយា ព្រាហ្មណា ទេវតានំ
យញ្ញមកប្បឹសុ បុថូធ លោកេ
កច្ចិស្សុ តេ ភគវា យញ្ញបថេ អប្បមត្តា
អតារុំ ជាតិញ្ច ជរញ្ច មារិស
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។

[១២៦] យេកេចិ មេ ឥសយោ មនុជាតិ យេកេចិមេតិ ។ បេ ។ កច្ចិស្សុ តេ ភគវា យញ្ញបថេ អប្បមត្តាតិ កច្ចិស្សូតិ សំសយបុច្ឆា វិមតិបុច្ឆា ទ្វេឡ្ហកបុច្ឆា អនេកំសបុច្ឆា ឯវំ នុ ខោ ន នុ ខោ កិន្នុ ខោ កថំ នុ ខោតិ កច្ចិស្សុ ។ តេតិ យញ្ញយាជកា[១] ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ កច្ចិស្សុ តេ ភគវា ។

១ ម. យញ្ញយាជកា បុច្ឆន្តិ ។

[១២៥] (បុណ្ណកៈ មានអាយុ ទូលសួរដូច្នេះថា) ពួកមនុស្សណា
នីមួយ គឺឥសី ក្សត្រ និងព្រាហ្មណ៍ជាច្រើននាក់ក្នុងលោកនេះ
សម្រេចយ័ញ្ញដល់ទេវតាទាំងឡាយ បពិត្រព្រះមានព្រះភាគ
ពួកមនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយ័ញ្ញ បពិត្រព្រះអង្គ
និរទុក្ខ (មនុស្សទាំងនោះ) ឆ្លងជាតិនិងជរាបានដែរឬ បពិត្រ
ព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គ
ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[១២៦] ពាក្យថា ណានីមួយ ក្នុងបទថា ពួកមនុស្សណានីមួយ គឺឥសី ។ បេ ។ អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ពួកមនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយ័ញ្ញ ឆ្លងជាតិនិងជរាបានដែរឬ ត្រង់ពាក្យថា ដែរឬ គឺការសួរដោយសង្ស័យ ការសួរដោយសេចក្តីងឿងឆ្ងល់ ការសួរដោយចិត្តបែកជាពីរ ការសួរដោយចំណែកច្រើនថា យ៉ាងនេះឬ មិនមែនទេឬ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ ហេតុនោះ (លោកសួរថា) ដែរឬ ។ ពាក្យថា មនុស្សទាំងនោះ បានដល់ពួកមនុស្សអ្នកបូជាយ័ញ្ញ ។ ពាក្យថា មានព្រះភាគ នុ៎ះ ជាពាក្យហៅ ដោយគោរព ។ បេ ។ ការបញ្ញត្តថា មានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (លោកសួរថា) បពិត្រព្រះមានព្រះភាគ មនុស្សទាំងនោះ ដែរឬ ។

យញ្ញបថេ អប្បមត្តាតិ យញ្ញោយេវ វុច្ចតិ យញ្ញបថោ ។ យថា អរិយមគ្គោ អរិយបថោ ទេវមគ្គោ ទេវបថា ព្រហ្មមគ្គោ ព្រហ្មបថោ ឯវមេវ យញ្ញោយេវ វុច្ចតិ យញ្ញបថោ ។ អប្បមត្តាតិ យញ្ញបថេ អប្បមត្តា សក្កច្ចការិនោ សាតច្ចការិនោ អដ្ឋិតការិនោ អនោលីនវុត្តិនោ[១] អនិក្ខិត្តច្ឆន្ទា អនិក្ខិត្តធុរា តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យាតិ[២] យញ្ញបថេ អប្បមត្តា ។ យេបិ យញ្ញំ ឯសន្តិ គវេសន្តិ បរិយេសន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ សក្កច្ចការិនោ ។ បេ ។ តទាធិបតេយ្យា តេបិ យញ្ញបថេ អប្បមត្តា ។ យេបិ យញ្ញំ អភិសង្ខរោន្តិ[៣] ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ សក្កច្ចការិនោ ។ បេ ។

១ ម. អនោលីនវុត្តិកា ។ ២ ម. តទធិបតេយ្យាតិ តេបិ ។ ៣ ម. ឯត្ថន្តរេ យជន្តិ បរិច្ចជន្តីតិ ទិស្សតិ ។

បុណ្ណកមាណវកបញ្ហានិទ្ទេស

ពាក្យថា មិនធ្វេសក្នុងផ្លូវយញ្ញៈ សេចក្តីថា យញ្ញៈហ្នឹងឯង លោកហៅថា ផ្លូវយញ្ញៈ ។ មគ្គប្រសើរ ផ្លូវប្រសើរ មាគ៌ាទេវតា ផ្លូវទេវតា មាគ៌ាព្រហ្ម ផ្លូវព្រហ្មយ៉ាងណា យញ្ញៈហ្នឹងឯង លោកហៅថា ផ្លូវយញ្ញៈ យ៉ាងនោះឯង ។ ពាក្យថា មិនធ្វេស គឺមិនធ្វេស ធ្វើដោយគោរព ធ្វើរឿយៗ មានកិរិយាធ្វើតាំងមាំ មានកិរិយាប្រព្រឹត្តមិនរួញរា មានឆន្ទៈមិនដាក់ចុះ មានធុរៈមិនដាក់ចុះ ប្រព្រឹត្តក្នុងផ្លូវយញ្ញៈនោះ ច្រើនក្នុងផ្លូវយញ្ញៈនោះ ធ្ងន់ក្នុងផ្លូវយញ្ញៈនោះ ឱនទៅក្នុងផ្លូវយញ្ញៈនោះ ទោរទៅក្នុងផ្លូវយញ្ញៈនោះ ញោចទៅក្នុងផ្លូវយញ្ញៈនោះ ចុះស៊ប់ក្នុងផ្លូវយញ្ញៈនោះ មានផ្លូវយញ្ញៈនោះជាអធិបតី ហេតុនោះ (លោកសួរថា) មិនធ្វេសក្នុងផ្លូវយញ្ញៈ ។ សូម្បីពួកជនណា ស្វែង ស្វះស្វែង ស្វែងរកនូវយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជាអ្នកធ្វើដោយគោរព ។ បេ ។ មានផ្លូវយញ្ញៈនោះជាអធិបតី ជនទាំងនោះ ឈ្មោះថា មិនធ្វេសក្នុងផ្លូវយញ្ញៈ ។ សូម្បីពួកជនណា តាក់តែងយញ្ញៈ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជាអ្នកធ្វើដោយគោរព ។ បេ ។

តជាធិបតេយ្យា តេបិ យញ្ញបថេ អប្បមត្តា ។

យេបិ យញ្ញំ ទេន្តិ យជន្តិ បរិច្ចជន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យំ សក្កច្ចការិនោ ។ បេ ។ តជាធិបតេយ្យា តេបិ យញ្ញបថេ អប្បមត្តាតិ កាច្ចិស្សុ តេ ភគវា យញ្ញបថេ អប្បមត្តា ។

[១២៧] អតារុំ ជាតិញ្ច ជរញ្ច មារិសាតិ ជាតិជរាមរណំ អតារឹសុ ឧត្តរឹសុ បតរឹសុ សមតិក្កមឹសុ វីតិវត្តឹសុ ។ មារិសាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ មារិសាតិ អតារុំ ជាតិញ្ច ជរញ្ច មារិស ។

មានផ្លូវយ័ញ្ញនោះ ជាអធិបតី ជនទាំងនោះ ឈ្មោះថា មិនធ្វេសក្នុងផ្លូវយញ្ញៈ សូម្បីពួកជនណា ឲ្យ បូជា លះបង់នូវយ័ញ្ញ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប ជាអ្នកធ្វើដោយគោរព ។ បេ ។ មានផ្លូវយ័ញ្ញនោះ ជាអធិបតី ជនទាំងនោះ ឈ្មោះថា មិនធ្វេសក្នុងផ្លូវយ័ញ្ញ ហេតុនោះ (លោកសួរថា) បពិត្រព្រះមានព្រះភាគ មនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយ័ញ្ញ (ឆ្លងជាតិនិងជរាបាន) ដែរឬ ។

[១២៧] ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ មនុស្សទាំងនោះឆ្លងជាតិនិងជរាបាន (ដែរឬ) គឺឆ្លង ឆ្លងឡើង ឆ្លងទួទៅ កន្លងព្រមប្រព្រឹត្តកន្លង នូវជាតិ ជរា និងមរណៈ បាន (ដែរឬ) ។ ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះគឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះ ជាពាក្យហៅ ដោយគោរព កោតក្រែង ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គនិរទុក្ខ មនុស្សទាំងនោះ ឆ្លងជាតិនិងជរាបាន (ដែរឬ) ។

៨៧

## បុណ្ណកមាណវកបញ្ហានិទ្ទេសោ

[១២៨] បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ បុច្ឆាមិ តន្តិ បុច្ឆាមិ តំ យាចាមិ តំ អជ្ឈេសាមិ តំ បសាទេមិ តំ កថស្សុ មេតិ បុច្ឆាមិ តំ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។ តេនាហ សោ ព្រាហ្មណោ យេកេចិមេ ឥសយោ មនុជា (ឥច្චាយស្មា បុណ្ណកោ)

ខត្តិយា ព្រាហ្មណា ទេវតានំ

យញ្ញមកប្បឹសុ បុថូធ លោកេ

កច្ចិស្សុ តេ ភគវា យញ្ញបថេ អប្បមត្តា

អតារុំ ជាតិញ្ច ជរញ្ច មារិស

បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ ។

បុណ្ណកមាណវកបញ្ហានិទ្ទេស

[១២៨] អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គ ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា ខ្ញុំព្រះអង្គទូលសួរព្រះអង្គ គឺ ខ្ញុំព្រះអង្គ ទូលសួរព្រះអង្គ អង្វរព្រះអង្គ អារាធនាព្រះអង្គ ញ៉ាំងព្រះអង្គឲ្យជ្រះថ្លា សូមព្រះអង្គប្រាប់(សេចក្តីនោះ) ដល់ខ្ញុំព្រះអង្គ ហេតុនោះ (លោកសួរថា) ខ្ញុំព្រះអង្គទូលសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នុ៎ះជាពាក្យហៅដោយគោរព ។ បេ ។ ការបញ្ញត្តថា មានព្រះភាគនេះ(កើត)ព្រោះការត្រាស់ដឹង ។ ពាក្យថា សូមព្រះអង្គប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គប្រាប់ បង្ហាញ សម្តែង បញ្ញត្ត តាំងផ្តើម បើក ចែករំលែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ(លោកសួរថា)បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

(បុណ្ណកៈមានអាយុ ទូលសួរដូច្នេះថា) ពួកមនុស្សណាមួយ
គឺឥសី ក្សត្រ និងព្រាហ្មណ៍ ជាច្រើននាក់ ក្នុងលោកនេះ
សម្រេចយញ្ញៈដល់ទេវតាទាំងឡាយ បពិត្រព្រះមានព្រះភាគ
ពួកមនុស្សទាំងនោះ មិនធ្វេសក្នុងផ្លូវយញ្ញៈ បពិត្រព្រះអង្គ
និរទុក្ខ (មនុស្សទាំងនោះ) ឆ្លងជាតិនិងជរាបានដែរឬ បពិត្រ
ព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គ
ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[១២៩] អាសីសន្តិ(១) ថោមយន្តិ (អភិជប្បន្តិ) ជុហន្តិ
(បុណ្ណកាតិ ភគវា)
កាមាភិជប្បន្តិ បដិច្ច លាភំ
តេ យាជយោគា ភវរាគរត្តា
នាតរិំសុ ជាតិជរន្តិ ព្រូមិ ។

[១៣០] អាសីសន្តិ ថោមយន្តិ អភិជប្បន្តិ ជុហន្តី-តិ អាសីសន្តីតិ រូបប្បដិលាភំ អាសីសន្តិ សទ្ទប្ប-ដិលាភំ អាសីសន្តិ គន្ធប្បដិលាភំ អាសីសន្តិ រសប្ប-ដិលាភំ អាសីសន្តិ ផោដ្ឋព្វប្បដិលាភំ អាសីសន្តិ បុត្តប្បដិលាភំ អាសីសន្តិ ទារប្បដិលាភំ អាសីសន្តិ ធនប្បដិលាភំ អាសីសន្តិ យសប្បដិលាភំ អាសីសន្តិ ឥស្សរិយប្បដិលាភំ អាសីសន្តិ ខត្តិយមហាសាល-កុលេ អត្តភាវប្បដិលាភំ អាសីសន្តិ ព្រាហ្មណមហាសាលកុលេ គហបតិមហាសាលកុលេ ចាតុ-ម្មហារាជិកេសុ ទេវេសុ ។ បេ ។ ព្រហ្មកាយិកេសុ ទេវេសុ អត្តភាវប្បដិលាភំ អាសីសន្តិ សាទិយន្តិ បត្ថយន្តិ បិហយន្តីតិ អាសីសន្តិ ។

១ ម. អាសិសន្តិ ។

[១២៩] (ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ) ជនទាំងឡាយណា ប្រាថ្នា សរសើរ (ជាប់ចិត្ត) បូជា ជាប់ចិត្តក្នុងកាម ព្រោះអាស្រ័យលាភ តថាគតពោលថា ជនទាំងនោះ ប្រកបក្នុងបូជា ត្រេកអរក្នុងភវរាគៈ ឆ្លងជាតិនិងជរាមិនបានទេ ។

[១៣០] អធិប្បាយពាក្យថា ប្រាថ្នា សរសើរ (ជាប់ចិត្ត) បូជា ត្រង់ពាក្យថា ប្រាថ្នា គឺប្រាថ្នាការបាននូវរូប ប្រាថ្នាការបាននូវសំឡេង ប្រាថ្នាការបាននូវក្លិន ប្រាថ្នាការបាននូវរស ប្រាថ្នាការបាននូវផ្សព្វ ប្រាថ្នាការបាននូវកូន ប្រាថ្នាការបាននូវប្រពន្ធ ប្រាថ្នាការបាននូវទ្រព្យ ប្រាថ្នាការបាននូវយស ប្រាថ្នាការបាននូវភាពជាឥស្សរៈ ប្រាថ្នាការបាននូវអត្តភាព ក្នុងត្រកូលខត្តិយ-មហាសាល ប្រាថ្នា ត្រេកអរ បំណង ស្រឡាញ់ នូវការបានចំពោះអត្តភាព ក្នុងត្រកូលនៃព្រាហ្មណមហាសាល ក្នុងត្រកូលនៃគហ-បតិមហាសាល ក្នុងពួកទេវតាជាន់ចាតុម្មហារាជិកៈ ។ បេ ។ ក្នុងពួកទេវតាប្រព្រឹត្តទៅក្នុងពួកព្រហ្ម ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រាថ្នា ។

បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

ថោមយន្តីតិ យញ្ញំ វា ថោមេន្តិ ផលំ វា ថោមេន្តិ ទក្ខិណេយ្យំ វា ថោមេន្តិ ។ កថំ យញ្ញំ ថោមេន្តិ ។ បិយំ ទិន្នំ មនាបំ ទិន្នំ បណីតំ ទិន្នំ កប្បិយំ ទិន្នំ វិចេយ្យំ ទិន្នំ អនវជ្ជំ ទិន្នំ អភិណ្ហំ ទិន្នំ ទទំ ចិត្តំ បសាទិតន្តិ ថោមេន្តិ កិត្តេន្តិ វណ្ណេន្តិ បសំសន្តិ ឯវំ យញ្ញំ ថោមេន្តិ ។ កថំ ផលំ ថោមេន្តិ ។ ឥតោនិទានំ រូបប្បដិលាភោ ភវិស្សតិ សទ្ទប្បដិលាភោ ភវិស្សតិ គន្ធប្បដិលាភោ ភវិស្សតិ រសប្បដិលាភោ ភវិស្សតិ ផោដ្ឋព្វប្បដិលាភោ ភវិស្សតិ ខត្តិយមហាសាលកុលេ ព្រាហ្មណមហាសាលកុលេ ។ បេ ។ ព្រហ្មកាយិកេសុ ទេវេសុ អត្តភាវប្បដិលាភោ ភវិស្សតីតិ ថោមេន្តិ កិត្តេន្តិ វណ្ណេន្តិ បសំសន្តិ ឯវំ ផលំ ថោមេន្តិ ។ កថំ ទក្ខិណេយ្យំ ថោមេន្តិ ។ ទក្ខិណេយ្យា ជាតិសម្បន្នា គោត្តសម្បន្នា អជ្ឈាយកា មន្តធរា តិណ្ណំ វេទានំ ចារគូ សនិឃណ្ឌុកេតុភានំ អក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកា វេយ្យាករណា លោកាយតមហាបុរិសលក្ខណេសុ

## បុណ្ណកមាណវកប្បញ្ហានិទ្ទេស

ពាក្យថា សរសើរ គឺសរសើរយញ្ញៈក្តី សរសើរផលក្តី សរសើរទក្ខិណេយ្យបុគ្គលក្តី ។ សរសើរយញ្ញៈ តើដូចម្តេច ។ ជនទាំងឡាយ សរសើរ សម្តែង ពណ៌នា ស្ញើចថា បុគ្គលឲ្យវត្ថុជាទីស្រឡាញ់ ឲ្យវត្ថុជាទីគាប់ចិត្ត ឲ្យវត្ថុដ៏ថ្លៃថ្លា ឲ្យវត្ថុដ៏គួរ ឲ្យវត្ថុដែលពិចារណារួចហើយ ឲ្យវត្ថុមិនមានទោស ឲ្យរឿយ ៗ កាលឲ្យក៏ញ៉ាំងចិត្តឲ្យជ្រះថ្លា សរសើរយញ្ញៈយ៉ាងនេះ ។ សរសើរផល តើដូចម្តេច ។ ជនទាំងឡាយ សរសើរ សម្តែង ពណ៌នា ស្ញើចថា ព្រោះការឲ្យនេះជាហេតុ នឹងបានរូប នឹងបានសំឡេង នឹងបានក្លិន នឹងបានរស នឹងបានផ្សព្វ នឹងបានអត្តភាពក្នុងត្រកូលនៃខត្តិយមហាសាល ក្នុងត្រកូលនៃព្រាហ្មណ-មហាសាល ។ បេ ។ ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកព្រហ្ម សរ-សើរផល យ៉ាងនេះ ។ សរសើរទក្ខិណេយ្យបុគ្គល តើដូចម្តេច ។ ជនទាំងឡាយ សរសើរ សម្តែង ពណ៌នា ស្ញើចថា ទក្ខិណេយ្យបុគ្គលទាំងឡាយ ជាអ្នកបរិបូណ៌ដោយជាតិ បរិបូណ៌ដោយគោត្រ ជាអ្នកស្វាធ្យាយទ្រទ្រង់មន្ត ដល់នូវត្រើយនៃវេទ ៣ ព្រមទាំងគម្ពីរនិឃណ្ឌុ និងគម្ពីរកេតុភៈ អក្ខរប្បភេទ មានគម្ពីរឥតិហាសៈជាគម្រប់ ៥ ជាអ្នកចេះបទ ជាអ្នកចេះវេយ្យាករណ៍ មិនខ្វះខាត ក្នុងគម្ពីរលោកាយតៈ និងមហាបុរិសលក្ខណៈ

អនវយា វីតរាគា រាគវិនយាយ វា បដិបន្នា វីតទោសា ទោសវិនយាយ វា បដិបន្នា វីតមោហា មោហវិនយាយ វា បដិបន្នា សទ្ធាសម្បន្នា សីលសម្បន្នា សមាធិសម្បន្នា បញ្ញាសម្បន្នា វិមុត្តិសម្បន្នា វិមុត្តិញាណទស្សនសម្បន្នាតិ ថោមេន្តិ កិត្តេន្តិ វណ្ណេន្តិ បសំសន្តិ ឯវំ ទក្ខិណេយ្យំ ថោមេន្តីតិ អាសីសន្តិ ថោមយន្តិ ។

អភិជប្បន្តីតិ រូបប្បដិលាភំ អភិជប្បន្តិ សទ្ទប្បដិលាភំ អភិជប្បន្តិ គន្ធប្បដិលាភំ អភិជប្បន្តិ រសប្បដិលាភំ អភិជប្បន្តិ ផោដ្ឋព្វប្បដិលាភំ អភិជប្បន្តិ ខត្តិយមហាសាលកុលេ អត្តភាវប្បដិលាភំ អភិជប្បន្តិ ។ បេ ។ ព្រហ្មកាយិកេសុ ទេវេសុ អត្តភាវប្បដិលាភំ អភិជប្បន្តីតិ អាសីសន្តិ ថោមយន្តិ អភិជប្បន្តិ ។

ជុហន្តីតិ ជុហន្តិ ទេន្តិ យជន្តិ បរិច្ចជន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ សេយ្យាវសថំ បទីបេយ្យន្តិ អាសីសន្តិ ថោមយន្តិ អភិជប្បន្តិ ជុហន្តិ ។

ជាអ្នកមានរាគៈទៅប្រាសហើយ ឬប្រតិបត្តិដើម្បីបន្ទោបង់រាគៈជាអ្នកមានទោសៈទៅប្រាសហើយ ឬប្រតិបត្តិដើម្បីបន្ទោបង់ទោសៈ មានមោហៈទៅប្រាសហើយ ឬប្រតិបត្តិដើម្បីបន្ទោបង់មោហៈ ជាអ្នកបរិបូណ៌ដោយសទ្ធា បរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយប្រាជ្ញា បរិបូណ៌ដោយវិមុត្តិ បរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈ សរសើរទក្ខិ-ណេយ្យបុគ្គល យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រាជ្ញា សរសើរ ។

ពាក្យថា ជាប់ចិត្ត គឺជាប់ចិត្តត្រង់ការបានរូប ជាប់ចិត្តត្រង់ការបានសំឡេង ជាប់ចិត្តត្រង់ការបានក្លិន ជាប់ចិត្តត្រង់ការបានរស ជាប់ចិត្តត្រង់ការបានផ្សព្វ ជាប់ចិត្តត្រង់ការបានអត្តភាព ក្នុងត្រកូលនៃខត្តិយ-មហាសាល ។ បេ ។ ជាប់ចិត្តត្រង់ការបានអត្តភាព ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកព្រហ្ម ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រាជ្ញា សរសើរជាប់ចិត្ត ។

ពាក្យថា បូជា គឺបូជា ឲ្យ លះ បរិច្ចាគ នូវចីវរ បិណ្ឌបាត សេនា-សនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ បាយ ទឹក សំពត់ យាន ផ្កាកម្រងគ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីបហេតុនោះ (ទ្រង់ត្រាស់ថា) ប្រាជ្ញា សរសើរ ជាប់ចិត្ត បូជា ។

៩១

## បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

បុណ្ណកាតិ ភគវាតិ បុណ្ណកាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ យទិទំ ភគវាតិ បុណ្ណកាតិ ភគវា ។

[១៣១] កាមាភិជប្បន្តិ បដិច្ច លាភន្តិ រូបប្បដិលាភំ បដិច្ច កាមេ អភិជប្បន្តិ សទ្ទប្បដិលាភំ បដិច្ច កាមេ អភិជប្បន្តិ ។ បេ ។ ព្រហ្មកាយិកេសុ ទេវេសុ អត្តភាវប្បដិលាភំ បដិច្ច កាមេ អភិជប្បន្តិ ជប្បន្តិ បជប្បន្តីតិ កាមាភិជប្បន្តិ បដិច្ច លាភំ ។

[១៣២] តេ យាជយោគា ភវរាគរត្តា នាតរីសុ ជាតិជរន្តិ ព្រូមីតិ តេតិ យញ្ញយជកា ។ យាជយោគាតិ យាគេសុ យុត្តា អាយុត្តា សមាយុត្តា តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យាតិ តេ យាជយោគា ។

ពាក្យថា ព្រះមានព្រះភាគ (ត្រាស់ថា) ម្នាលបុណ្ណកៈ ត្រង់ពាក្យថា ម្នាលបុណ្ណកៈ គឺព្រះមានព្រះភាគ ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។ ពាក្យថា មានព្រះភាគ នេះជាពាក្យហៅ ដោយគោរព ។ បេ ។ ថាព្រះមានព្រះភាគនេះ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគ ត្រាស់ថា ម្នាលបុណ្ណកៈ ។

[១៣១] ពាក្យថា ជាប់ចិត្តក្នុងកាម ព្រោះអាស្រ័យលាភ គឺ ជាប់ចិត្តក្នុងកាម ព្រោះអាស្រ័យការបានរូប ជាប់ចិត្តក្នុងកាម ព្រោះអាស្រ័យការបានសំឡេង ។ បេ ។ ជាប់ចិត្ត ជាប់ចិត្តស៊ប់ ជាប់ចំពាក់ក្នុងកាម ព្រោះអាស្រ័យការបានអត្តភាព ក្នុងពួកទេវតាដែលប្រព្រឹត្តទៅក្នុងពួកព្រហ្ម ហេតុនោះ (ទ្រង់ត្រាស់ថា) ជាប់ចិត្តក្នុងកាមព្រោះអាស្រ័យលាភ ។

[១៣២] អធិប្បាយពាក្យថា តថាគតពោលថា ជនទាំងនោះ ជាអ្នកប្រកបក្នុងបូជា ត្រេកអរក្នុងភវាគៈ ឆ្លងជាតិនិងជរាមិនបានទេ ត្រង់ពាក្យថា ជនទាំងនោះ គឺពួកជនអ្នកបូជាយញ្ញៈ ។ ពាក្យថា ប្រកបក្នុងបូជា គឺជាអ្នកប្រកប ប្រកបទូទៅ ប្រកបព្រម ក្នុងបូជាទាំងឡាយ ជាអ្នកប្រព្រឹត្តក្នុងបូជានោះ ច្រើនក្នុងបូជានោះ ធ្ងន់ក្នុងបូជានោះ ឱនទៅក្នុងបូជានោះ ទោរទៅក្នុងបូជានោះ ញោចទៅក្នុងបូជានោះ ចុះស៊ប់ក្នុងបូជានោះ មានបូជានោះ ជាអធិបតី ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងនោះ ជាអ្នកប្រកបក្នុងបូជា ។

ភវរាគរត្តាតិ ភវរាគោ វុច្ចតិ តណ្ហា យោ ភវេសុ ភវច្ឆន្ទោ ភវរាគោ ភវនន្ទិ ភវតណ្ហា ភវសិនេហោ ភវបិបាសា ភវបរិឡាហោ ភវមុច្ឆា ភវជ្ឈោសានំ ភវរាគេន ភវេសុ រត្តា(១) គធិតា មុច្ឆិតា អជ្ឈោបន្នា លគ្គា លគ្គិតា បលិពុទ្ធាតិ តេ យាជយោគា ភវរាគរត្តា ។ នាតរឹសុ ជាតិជរន្តិ ព្រូមីតិ តេ យាជយោគា ភវរាគរត្តា ជាតិជរាមរណំ ន តរឹសុ ន ឧត្តរឹសុ ន បតរឹសុ ន សមតិក្កមឹសុ ន វីតិវត្តឹសុ ជាតិជរាមរណា អនិក្ខន្តា អនិស្សដា អនតិក្កន្តា អសមតិក្កន្តា អវីតិវត្តា អន្តោជាតិជរាមរណេ បរិវត្តន្តិ អន្តោសំសារបថេ បរិវត្តន្តិ ជាតិយា អនុគតា ជរាយ អនុសដា ព្យាធិនា អភិភូតា មរណេន អព្ភាហតា អតាណា អលេណា អសរណា អសរណីភូតាតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ តេ យាជយោគា ភវរាគរត្តា នាតរឹសុ ជាតិជរន្តិ ព្រូមិ ។

១ ម. រត្តា គិទ្ធា ។

ពាក្យថា ត្រេកអរក្នុងភវរាគៈ សេចក្តីថា តណ្ហា ហៅថា ភវរាគៈ បាន ខាងសេចក្តីប៉ុនប៉ងក្នុងភព សេចក្តីត្រេកអរក្នុងភព សេចក្តីប្រាថ្នាក្នុងភព ការស្នេហាក្នុងភព សេចក្តីស្រេកឃ្លានក្នុងភព សេចក្តីក្តៅក្រហាយក្នុងភព សេចក្តីជ្រប់ក្នុងភព សេចក្តីចូលចិត្តមាំក្នុងភព ក្នុងភពទាំងឡាយ ជន ទាំងឡាយ ត្រេកអរ ធ្លាក់ចុះ ជ្រុលជ្រប់ ផុលផប់ ជាប់ ចំពាក់ ព័ន្ធព័ន្ធ ក្នុងភពទាំងឡាយ ដោយសេចក្តីរីករាយក្នុងភព ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងនោះ ជាអ្នកប្រកបក្នុងការបូជា ត្រេកអរក្នុងភវ-រាគៈ ។ ពាក្យថា តថាគតពោលថា ជនទាំងនោះ ឆ្លងជាតិនិង ជរាមិនបានទេ គឺជនទាំងនោះ ជាអ្នកប្រកបក្នុងបូជា ត្រេកអរក្នុងភវរាគៈ ឆ្លងមិនបាន ឆ្លងឡើងមិនបាន ឆ្លងទួទៅមិនបាន កន្លងព្រមមិនបាន ប្រព្រឹត្តកន្លងមិនបាន នូវជាតិជរានិងមរណៈ មិនចេញ មិនរលាស់ចេញ មិនឈានកន្លង មិនឈានកន្លងព្រម មិនប្រព្រឹត្តកន្លង ចាកជាតិជរានិង មរណៈ រមែងវិលវល់នៅតែខាងក្នុង នៃជាតិ ជរា និងមរណៈ វិលវល់ខាង ក្នុងផ្លូវសង្សារ ប្រព្រឹត្តទៅតាមជាតិ ត្រូវជរាជាប់តាម ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈកម្ចាត់ហើយ គ្មានទីពំនាក់ គ្មានទីជ្រកកោន គ្មានទីពឹង គ្មានទីផ្អែក តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើក បែក រំលែក ធ្វើឲ្យរាក់ ប្រកាសដូច្នេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងនោះ ជាអ្នកប្រកបក្នុងបូជា ត្រេកអរក្នុងភវរាគៈ ឆ្លងជាតិនិងជរាមិនបានទេ ។

៩៣

បុណ្ណកមាណវកបញ្ហានិទ្ទេសោ

តេនាហ ភគវា

អាសឹសន្តិ ថោមយន្តិ (អភិជប្បន្តិ) ជុហន្តិ (បុណ្ណកាតិ ភគវា)

កាមាភិជប្បន្តិ បដិច្ច លាភំ

តេ យាជយោគា ភវរាគរត្តា

នាតរឹសុ ជាតិជរន្តិ ព្រូមីតិ ។

[១៣៣] តេ ចេ នាតរឹសុ យាជយោគា (ឥច្ចាយស្មា បុណ្ណកោ)

យញ្ញេហិ ជាតិញ្ច ជរញ្ច មារិស

អថ កោ ចរហិ ទេវមនុស្សលោកេ

អតារិ ជាតិញ្ច ជរញ្ច មារិស

បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។

បុណ្ណកមាណវកបញ្ហានិទ្ទេស

ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ) ជនទាំងឡាយណា ប្រាថ្នា សរសើរ (ជាប់ចិត្ត) លះបង់ ប្រាថ្នាចំពោះនូវកាម ព្រោះអាស្រ័យលាភ តថាគតពោលថា ជនទាំងនោះ ជាអ្នកប្រកប ក្នុងការបូជា ត្រេកអរ ក្នុងភវរាគៈ ឆ្លងជាតិនិងជរា មិនបានទេ ។

[១៣៣] (បុណ្ណកៈមានអាយុ ក្រាបទូលសួរជូច្នេះថា) បពិត្រព្រះអង្គនិរទុក្ខ បើជន ជាអ្នកប្រកប ក្នុងការបូជាទាំងនោះ ឆ្លងជាតិនិងជរា ដោយយ័ញ្ញមិនបានទេ បពិត្រព្រះអង្គនិរទុក្ខ តើអ្នកណា ក្នុងទេវលោកនិងមនុស្សលោក អាចឆ្លងជាតិនិងជរាបាន ក្នុងកាលឥឡូវនេះ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គ សម្តែងសេចក្តីនោះដល់ខ្ញុំព្រះអង្គ ។

[១៣៨] តេ ច នាតរឹសុ យាជយោគាតិ តេ យញ្ញយជកា យាជយោគា ភវាភវត្តា ជាតិជរាមរណំ នាតរឹសុ ន ឧត្តរឹសុ ន បតរឹសុ ន សមតិក្កមឹសុ ន វីតិវត្តឹសុ ជាតិជរាមរណា អនិក្ខន្តា អនិស្សដា អនតិក្កន្តា អសមតិក្កន្តា អវីតិវត្តា អន្តោជាតិជរាមរណេ បរិវត្តន្តិ អន្តោសំសារបថេ បរិវត្តន្តិ ជាតិយា អនុគតា ជរាយ អនុសដា ព្យាធិនា អភិភូតា មរណេន អព្ភាហតា អតាណា អលេណា អសរណា អសរណីភូតាតិ[១] តេ ច នាតរឹសុ យាជយោគា ។ ឥច្ចាយស្មា បុណ្ណកោតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ អាយស្មា បុណ្ណកោតិ ។

[១៣៩] យញ្ញេហិ ជាតិញ្ច ជរញ្ច មារិសាតិ យញ្ញេហិ បហុតេហិ យញ្ញេហិ វិវិធេហិ យញ្ញេហិ បុថូហិ ។

---

១ ម. ឯត្តន្តរេ ព្រូសិ អាចិក្ខសិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរសិ វិភជសិ ឧត្តានីករោសិ បកាសេសីតិ ទិស្សន្តិ ។

[១៣៤] ពាក្យថា បើជន ជាអ្នកប្រកប ក្នុងការបូជាទាំងនោះ ឆ្លងមិនបានទេ សេចក្តីថា ជន ជាអ្នកបូជាយញ្ញ ប្រកបក្នុងការបូជា ត្រេកអរក្នុងភវាគៈ ទាំងនោះ មិនឆ្លងចុះ មិនឆ្លងឡើង មិនឆ្លងទូទៅ មិនកន្លងព្រម មិនប្រព្រឹត្តកន្លងបាន នូវជាតិជរានិងមរណៈ ជនទាំងនោះ មិនចេញ មិនរលាស់ចេញ មិនឈានកន្លង មិនឈានកន្លងព្រម មិនប្រព្រឹត្តកន្លង ចាកជាតិជរានិងមរណៈ វិលវល់ខាងក្នុង នៃជាតិជរានិងមរណៈ វិលវល់ខាងក្នុងផ្លូវនៃសង្សារ ប្រព្រឹត្តទៅតាមជាតិ ត្រូវជរាជាប់តាម ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈកម្ចាត់ហើយ គ្មានទីពំនាក់ គ្មានទីជ្រកកោន គ្មានទីពឹង គ្មានទីផ្អែក ហេតុនោះ (លោកសួរថា) បើជន ជាអ្នកប្រកប ក្នុងការបូជាទាំងនោះ ឆ្លងមិនបានទេ ។ ពាក្យថា ដូច្នេះ ក្នុងបទថា បុណ្ណកៈមានអាយុ ក្រាបទូលសួរ ដូច្នេះ គឺជាបទតភ្ជាប់ ។ បេ ។ បុណ្ណកៈមានអាយុ ។

[១៣៥] ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ (បើជនទាំងឡាយឆ្លង) ជាតិនិងជរាដោយយញ្ញមិនបានទេ សេចក្តីថា ដោយយញ្ញទាំងឡាយដ៏ច្រើន ដោយយញ្ញទាំងឡាយផ្សេងៗ ដោយយញ្ញដ៏ក្រាស់ក្រៃល ។

មារិសាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ មារិសាតិ យញ្ញេហិ ជាតិញ្ច ជរញ្ច មារិស ។

[១៣៦] អថ កោ ចរហិ ទេវមនុស្សលោកេ អតារិ[១] ជាតិញ្ច ជរញ្ច មារិសាតិ អថ កោ ឯសោ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ជាតិជរាមរណំ អតារិ ឧត្តរិ បតរិ សមតិក្កមិ វីតវត្តយិ ។ មារិសាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ មារិសាតិ អថ កោ ចរហិ ទេវមនុស្សលោកេ អតារិ ជាតិញ្ច ជរញ្ច មារិស ។

១ ម. អតរិ ។

ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នុ៎ះជាពាក្យសម្រាប់ហៅ ដោយគោរពកោតក្រែង ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គនិរទុក្ខ (បើជនទាំងឡាយឆ្លង) ជាតិនិងជរាដោយយ័ញ្ញ មិនបានទេ ។

[១៣៦] ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ តើអ្នកណា ក្នុងទេវលោក និងមនុស្សលោក ឆ្លងជាតិនិងជរាបាន ក្នុងកាលឥឡូវនេះ សេចក្តីថា តើអ្នកណា ក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស ឆ្លងចុះ ឆ្លងឡើង ឆ្លងទូទៅ កន្លងព្រម ប្រព្រឹត្តកន្លង នូវជាតិជរានិងមរណៈបាន ។ ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នុ៎ះ ជាពាក្យសម្រាប់ហៅ ដោយគោរពកោតក្រែង ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គនិរទុក្ខ តើអ្នកណា ក្នុងទេវលោកនិងមនុស្សលោក ឆ្លងជាតិនិងជរាបាន ក្នុងកាលឥឡូវនេះ ។

[១៣៧] បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ បុច្ឆាមិ តន្តិ បុច្ឆាមិ តំ យាចាមិ តំ អជ្ឈេសាមិ តំ បសា-ទេមិ តំ កថស្សុ មេតិ បុច្ឆាមិ តំ ។ ភគវាតិ ស-គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។ តេនាហ សោ ព្រាហ្មណោ

តេ ចេ ជាតរិសុ យាជយោគា

(ឥច្ចាយស្មា បុណ្ណកោ)

យញ្ញេហិ ជាតិញ្ច ជរញ្ច មារិស

អថ កោ ចរហិ ទេវមនុស្សលោកេ

អតារិ ជាតិញ្ច ជរញ្ច មារិស

បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ ។

[១៣៧] ពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា ខ្ញុំព្រះអង្គ ទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គទូលសួរព្រះអង្គ អង្វរព្រះអង្គ អារាធនាព្រះអង្គ ញុំាងព្រះអង្គឲ្យជ្រះថ្លា សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ហេតុនោះ (លោកសួរថា) ខ្ញុំព្រះអង្គទូលសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នុ៎ះជាពាក្យសម្រាប់ហៅដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ពាក្យថា សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើកបង្ហាញ ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (លោកសួរថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

(បុណ្ណកៈមានអាយុ ក្រាបទូលសួរដូច្នេះថា) បពិត្រព្រះអង្គនិរទុក្ខ បើជន ជាអ្នកប្រកបក្នុងការបូជាទាំងនោះ ឆ្លងជាតិនិងជរាដោយយ័ញ្ញមិនបានទេ បពិត្រព្រះអង្គនិរទុក្ខ តើអ្នកណា ក្នុងទេវលោកនិងមនុស្សលោក ឆ្លងជាតិនិងជរាបាន ក្នុងកាលឥឡូវនេះ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ

[១៣៨] សង្ខាយ លោកស្មឹ បរោបរានិ
(បុណ្ណកាតិ ភគវា)
យស្សិញ្ជិតំ នត្ថិ កុហិញ្ចិ លោកេ
សន្តោ វិធូមោ អនីឃោ និរាសោ
អតារិ សោ ជាតិជរន្តិ ព្រូមិ ។

[១៣៩] សង្ខាយ លោកស្មឹ បរោបរានីតិ សង្ខា វុច្ចតិ ញាណំ យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ បរោបរានីតិ ឱរំ វុច្ចតិ[១] មនុស្សលោកោ បរំ វុច្ចតិ ទេវលោកោ ឱរំ វុច្ចតិ កាមធាតុ បរំ វុច្ចតិ រូបធាតុ អរូបធាតុ ឱរំ វុច្ចតិ កាមធាតុ រូបធាតុ បរំ វុច្ចតិ អរូបធាតុ ។ សង្ខាយ លោកស្មឹ បរោបរានីតិ បរោបរានិ អនិច្ចតោ សង្ខាយ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ ។ បេ ។

១ ម. បរោបរានីតិ ឱរំ វុច្ចតិ សកត្តភាវោ បរំ វុច្ចតិ បរត្តភាវោ ឱរំ វុច្ចតិ សករូបវេទនា សញ្ញា សង្ខារវិញ្ញាណំ បរំ វុច្ចតិ បររូបវេទនា សញ្ញា សង្ខារវិញ្ញាណំ ឱរំ វុច្ចតិ ឆ អជ្ឈត្តិកានិ អាយតនានិ បរំ វុច្ចតិ ឆ ពាហិរានិ អាយតនានិ ឱរំ វុច្ចតីតិ ទិស្សន្តិ ។

បុណ្ណកមាណវកបញ្ហានិទ្ទេស

[១៣៨] (ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ) សេចក្តីញាប់ញ័រ ក្នុងទីនីមួយ ក្នុងលោក នៃបុគ្គលណា មិនមានទេ ព្រោះដឹងនូវត្រើយនាយនិងត្រើយអាយ ក្នុងលោក តថាគតពោលថា បុគ្គលនោះ ជាអ្នកស្ងប់ អ្នកកម្ចាត់បង់ អ្នកមិនមានទុក្ខ អ្នកមិនមានប្រាថ្នា អាចឆ្លងជាតិនិងជរាបាន ។

[១៣៩] ពាក្យថា ព្រោះដឹង នូវត្រើយនាយនិងត្រើយអាយក្នុងលោក សេចក្តីថា ញាណ លោកហៅថា ការដឹង បានខាងបញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវ ។ ពាក្យថា ត្រើយនាយនិងត្រើយអាយ គឺមនុស្សលោក ហៅថា ត្រើយអាយ ទេវលោក ហៅថា ត្រើយនាយ កាមធាតុ ហៅថា ត្រើយអាយ រូបធាតុនិងអរូបធាតុ ហៅថា ត្រើយនាយ កាមធាតុ និងរូបធាតុ ហៅថា ត្រើយអាយ អរូបធាតុ ហៅថា ត្រើយនាយ ។ ពាក្យថា ព្រោះដឹងនូវត្រើយនាយនិងត្រើយអាយ ក្នុងលោក គឺព្រោះដឹងនូវត្រើយ-នាយនិងត្រើយអាយ ថា មិនទៀង ព្រោះដឹង យល់ ថ្លឹង ពិចារណា សម្តែង ធ្វើឲ្យប្រាកដ ថាជាទុក្ខ ជារោគ ជាបូស ជាសរ ។ បេ ។

អនិស្សរណោតោ[១] សង្ខាយ ជានិត្វា តុលយិត្វា តិរយិ-ត្វា វិភាវយិត្វា វិភូតំ កត្វាតិ សង្ខាយ លោកស្មឹ បរោបរានិ ។ បុណ្ណកាតិ ភគវាតិ បុណ្ណកាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវ-ចនមេតំ ។ បេ ។ យទិទំ ភគវាតិ បុណ្ណកាតិ ភគវា។

[១៤០] យស្សិញ្ជិតំ នត្ថិ កុហិញ្ចិ លោកេតិ យស្សាតិ អរហតោ ខីណាសវស្ស ។ ឥញ្ជិតន្តិ តណ្ហិ-ញ្ជិតំ ទិដ្ឋិញ្ជិតំ កិលេសិញ្ជិតំ មានិញ្ជិតំ កាម្មិញ្ជិតំ ។ យស្សិមេ ឥញ្ជិតា នត្ថិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុ-ប្បត្តិកា ញាណគ្គិនា ទឌ្ឍា ។ កុហិញ្ចីតិ កុហិញ្ចិ កិម្ហិចិ[២] កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វា ។ លោកេតិ អបាយលោកេ ។ បេ ។ អាយតន-លោកេតិ យស្សិញ្ជិតំ នត្ថិ កុហិញ្ចិ លោកេ ។

---

១ ម. និស្សរណោតោ ។ ២ ម. កិស្មិញ្ចិ ។

ថា រលាស់ចេញមិនបាន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះដឹងនូវត្រើយនាយនិងត្រើយអាយ ក្នុងលោក ។ ពាក្យថា ម្នាលបុណ្ណកៈ ក្នុងបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះជាពាក្យហៅដោយគោរព ។ បេ ។ (ការបញ្ញត្ត)ថា ព្រះមានព្រះភាគ នេះ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណកៈ ។

[១៤០] ពាក្យថា សេចក្ដីញាប់ញ័រ ក្នុងទីនីមួយ ក្នុងលោក នៃបុគ្គលណា មិនមានទេ ត្រង់ពាក្យថា នៃបុគ្គលណា គឺនៃព្រះអរហន្តខីណាស្រព ។ ពាក្យថា សេចក្ដីញាប់ញ័រ គឺការញាប់ញ័រដោយតណ្ហា ការញាប់ញ័រដោយទិដ្ឋិ ការញាប់ញ័រដោយកិលេស ការញាប់ញ័រដោយមានះ ការញាប់ញ័រដោយកម្ម ។ ការញាប់ញ័រទាំងនេះ នៃបុគ្គលណា មិនមាន មិនមានព្រម (បុគ្គលនោះ) មិនបាន បានលះបង់ កាត់ផ្ដាច់ ចូលទៅរម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ។ ពាក្យថា ក្នុងទីនីមួយ គឺក្នុងទីនីមួយ តិចតួច ដូចម្ដេចខ្លះ ខាងក្នុងក្ដី ខាងក្រៅក្ដី ទាំងខាងក្នុងខាងក្រៅក្ដី ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ ក្នុងអាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្ដីញាប់ញ័រ ក្នុងទីនីមួយ ក្នុងលោក នៃបុគ្គលណា មិនមានទេ ។

៩៩

## បុណ្ណកមាណវកបញ្ហានិទ្ទេសោ

[១៤១] សង្គោ វិជ្ជមោ អនីឃោ និរាសោ អតារិ សោ ជាតិជរន្តិ ព្រូមីតិ សង្គោតិ រាគស្ស សង្គត្តា សង្គោ ទោសស្ស សង្គត្តា សង្គោ មោហស្ស សង្គត្តា សង្គោ កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស សព្វក្កិលេសានំ សព្វទុច្ចរិតានំ សព្វទរថានំ សព្វបរិឡាហានំ សព្វសន្តាបានំ សព្វាកុសលាភិសង្ខារានំ សន្តត្តា សមិតត្តា វូបសមិតត្តា វិជ្ឈាតត្តា និព្វុតត្តា វិគតត្តា បដិប្បស្សទ្ធត្តា សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ សន្តោ ។ វិធូមោតិ កាយទុច្ចរិតំ វិធូមិតំ វិធមិតំ វិសោសិតំ ព្យន្តីកតំ វចីទុច្ចរិតំ មនោទុច្ចរិតំ វិធូមិតំ វិធមិតំ វិសោសិតំ ព្យន្តីកតំ រាគោ វិធូមិតោ វិធមិតោ វិសោសិតោ ព្យន្តីកតោ ទោសោ មោហោ កោធោ

បុណ្ណកមាណវកបញ្ហានិទ្ទេស

[១៤១] អធិប្បាយពាក្យថា តថាគតពោលថា បុគ្គលនោះជាអ្នកស្ងប់ អ្នកកម្ចាត់បង់ អ្នកមិនមានទុក្ខ អ្នកមិនមានប្រាថ្នា អាចឆ្លងជាតិនិងជរាបាន ត្រង់ពាក្យថា ជាអ្នកស្ងប់ គឺឈ្មោះថា អ្នកស្ងប់ ព្រោះស្ងប់រាគៈ ឈ្មោះថា អ្នកស្ងប់ ព្រោះស្ងប់ទោសៈ ឈ្មោះថា អ្នកស្ងប់ ព្រោះស្ងប់មោហៈ ឈ្មោះថា អ្នកស្ងប់ អ្នករម្ងាប់ អ្នករម្ងាប់ឈឹង អ្នករំលត់ អ្នករម្ងាប់ចំពោះ ព្រោះស្ងប់ រម្ងាប់ រម្ងាប់ឈឹង រលត់ រំលត់ ទៅប្រាស រម្ងាប់ចំពោះ នូវក្រោធ ការចងក្រោធទុក សេចក្ដីលុបគុណ ការវាយឫកស្មើ សេចក្ដីច្រណែន កំណាញ់ កិច្ចកល សេចក្ដីអួតអាង សេចក្ដីរឹងត្អឹង ការប្រណាំងប្រជែង មានះ សេចក្ដីមើលងាយ សេចក្ដីស្រវឹង សេចក្ដីប្រហែស កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្រវល់ក្រវាយទាំងពួង សេចក្ដីក្រហល់ក្រហាយទាំងពួង សេចក្ដីក្ដៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្ងប់ ។ ពាក្យថា អ្នកកម្ចាត់បង់ គឺអ្នកកម្ចាត់បង់ ផ្ដុំបេញ ធ្វើឲ្យរីងស្ងួត ធ្វើឲ្យវិនាសនូវកាយ-ទុច្ចរិត អ្នកកម្ចាត់បង់ ផ្ដុំបេញ ធ្វើឲ្យរីងស្ងួត ធ្វើឲ្យវិនាសនូវវចីទុច្ចរិត នូវមនោទុច្ចរិត អ្នកកម្ចាត់បង់ ផ្ដុំបេញ ធ្វើឲ្យរីងស្ងួត ធ្វើឲ្យវិនាសនូវរាគៈ អ្នកកម្ចាត់បង់ ផ្ដុំបេញ ធ្វើឲ្យរីងស្ងួត ធ្វើឲ្យវិនាសនូវទោសៈ មោហៈ ក្រោធ

ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាថេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ វិជ្ជូមិតោ វិជមិតោ វិសោសិតោ ព្យន្តីកតោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា វិជ្ជូមិតា វិជមិតា វិសោសិតា ព្យន្តីកតា ។ អបិច កោធោ វុច្ចតិ ធូមោ

មានោ ហិ តេ ព្រាហ្មណ ខារិភារោ
កោធោ ធូមោ កម្មនិ[១] មោសវជ្ជំ
ជិវ្ហា សុជា តប្បរស្ស ជោតិដ្ឋានំ[២]
អត្តា សុទន្តោ បុរិសស្ស ជាតិ ។

---

១ ម. ភស្មា ។ ២ ម. ហទយំ ជោតិដ្ឋានន្តិ អដ្ឋកថាយំ ទិស្សតិ ។

ការចង់ក្រោធទុក សេចក្ដីលុបគុណ ការវាយឫកស្មើ សេចក្ដីច្រណែន សេចក្ដីកំណាញ់ កិច្ចកល សេចក្ដីអួតអាង សេចក្ដីរឹងត្អឹង ការប្រណាំងប្រជែង មានះ សេចក្ដីមើលងាយ សេចក្ដីស្រវឹង និងសេចក្ដីប្រហែស អ្នកកម្ចាត់បង់ ផ្ចុំបេញ ធ្វើឲ្យវិនាស ធ្វើឲ្យវិនាសនូវកិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្ដីក្រវល់ក្រវាយទាំងពួង សេចក្ដីក្រហល់ក្រហាយទាំងពួង សេចក្ដីក្ដៅក្រហាយទាំងពួង អភិសង្ខារជាអកុសលទាំងពួង ។ មួយទៀត ក្រោធ លោកពោលថាផ្សែង

ម្នាលព្រាហ្មណ៍ សេចក្ដីពិតថា មានះរបស់អ្នក ទុកជា
អម្រែកដ៏ធ្ងន់ សេចក្ដីក្រោធ ទុកជាផ្សែង ការពោលពាក្យកុហក
ទុកជាផេះ អណ្ដាត ទុកជាវែក ហឫទ័យរបស់អ្នកដែល
យកចិត្តទុកដាក់ ទុកជាកន្លែងភ្លើង ខ្លួនដែលទូន្មានល្អហើយ
ទុកជាជាតិរបស់បុរស ។

១០១

## បុណ្ណកមាណវកបញ្ហានិទ្ទេសោ

អបិច ទសហាការេហិ កោធោ ជាយតិ អនត្ថំ មេ អចរីតិ កោធោ ជាយតិ អនត្ថំ មេ ចរតីតិ កោធោ ជាយតិ អនត្ថំ មេ ចរិស្សតីតិ កោធោ ជាយតិ បិយស្ស មេ មនាបស្ស អនត្ថំ អចរីតិ អនត្ថំ ចរតីតិ អនត្ថំ ចរិស្សតីតិ កោធោ ជាយតិ អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរីតិ អត្ថំ ចរតីតិ អត្ថំ ចរិស្សតីតិ កោធោ ជាយតិ អដ្ឋានេ វា បន កោធោ ជាយតិ ។ យោ ឯវរូបោ ចិត្តស្ស អាឃាតោ បដិឃាតោ បដិឃោ បដិវិរោធោ កោបោ បកោបោ សម្បកោបោ ទោសោ បទោសោ សម្បទោសោ ចិត្តស្ស ព្យាបត្តិ មនោបទោសោ កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អស្សុរោបោ អនត្តមនតា ចិត្តស្ស អយំ វុច្ចតិ កោធោ ។ អបិច កោធស្ស អធិមត្តបរិត្តតា វេទិតព្វា ។

បុណ្ណកមាណវកប្បញ្ហានិទ្ទេស

មួយទៀត ការក្រោធ កើតដោយអាការ ១០ គឺក្រោធកើតដោយគិតថា គេបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ ដល់អញ ១ ក្រោធកើតដោយគិតថា គេកំពុងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញ ១ ក្រោធកើតដោយគិតថា គេនឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញ ១ ក្រោធកើតដោយគិតថា គេបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ ១ ថា កំពុងប្រព្រឹត្តអំពើមិនជា-ប្រយោជន៍ ១ ថានឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ ដល់សត្វនិងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តនៃអញ ១ ក្រោធកើតដោយគិតថា គេបានប្រព្រឹត្តប្រយោជន៍ ១ ថាកំពុងប្រព្រឹត្តប្រយោជន៍ ១ ថានឹងប្រព្រឹត្តប្រយោជន៍ដល់សត្វនិងសង្ខារមិនជាទីស្រឡាញ់មិនជាទីពេញចិត្តនៃអញ ១ ឬសេចក្តីក្រោធកើតក្នុងទីមិនគួរ ១ ។ សេចក្តីគំនុំ ការគុំកួន ការថ្នាំងថ្នាក់ ការតានតឹងនៃចិត្ត សេចក្តីខឹង ការខឹងខ្លាំង ការខឹងក្រៃលែង ទោសៈ ទោសៈខ្លាំង ទោសៈក្រៃលែង ការព្យាបាទនៃចិត្ត ការប្រទូសរ៉ាយក្នុងចិត្ត ការក្រោធ អាការក្រោធ ភាពនៃការក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃការប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃការព្យាបាទ សេចក្តីខឹង ការខឹងខ្លាំង សេចក្តីកាច ការញុំាងទឹកភ្នែកឲ្យហូរធ្លាក់ សេចក្តីមិនរីករាយនៃចិត្ត ឯណា មានសភាពយ៉ាងនេះ នេះហៅថា ការក្រោធ ។ មួយទៀត បណ្ឌិតគប្បីដឹងថា ក្រោធប្រមាណច្រើននិងតិច ។

អត្ថិ កញ្ចិ កាលំ កោជោ ចិត្តាវិលករណមត្តោ ហោតិ ន ច តាវ មុខកុលានវិកុលានោ[1] ហោតិ ។ អត្ថិ កញ្ចិ កាលំ កោជោ មុខកុលានវិកុលាន-មត្តោ ហោតិ ន ច តាវ ហនុសញ្ចោបនោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោជោ ហនុសញ្ចោបនមត្តោ ហោតិ ន ច តាវ ផរុសវាចនិច្ឆារណោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោជោ ផរុសវាចនិច្ឆារណមត្តោ ហោតិ ន ច តាវ ទិសាវិទិសំ អនុវិលោកនោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោជោ ទិសាវិទិសំ អនុវិ-លោកនមត្តោ ហោតិ ន ច តាវ ទណ្ឌសត្ថបរាម-សនោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោជោ ទណ្ឌសត្ថបរាមសនមត្តោ ហោតិ ន ច តាវ ទណ្ឌសត្ថអព្ភុក្កិរណោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោជោ ទណ្ឌសត្ថអព្ភុក្កិរណមត្តោ ហោតិ ន ច តាវ ទណ្ឌសត្ថអភិនិបាតនោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោជោ ទណ្ឌសត្ថអភិនិបាតនមត្តោ ហោតិ ន ច តាវ ឆិន្នវិច្ឆិន្នករណោ ហោតិ ។

១ ម. មុខកុលនវិកុលនំ ។

ក្នុងកាលខ្លះ ក្រោជគ្រាន់តែធ្វើចិត្តឲ្យល្អក់ តែមិនទាន់ធ្វើមុខឲ្យក្រញូវនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែធ្វើមុខឲ្យក្រញូវ តែមិនទាន់ញុំាងចង្កាឲ្យកម្រើកនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែញុំាងចង្កាឲ្យកម្រើក តែមិនទាន់បញ្ចេញវាចាអាក្រក់នៅឡើយ ក៏មិន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែបញ្ចេញវាចាអាក្រក់ តែមិនទាន់ក្រឡេកមើលទិសតូចនិងទិសធំនៅឡើយ ក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែក្រឡេកមើលទិសតូចនិងទិសធំ តែមិនទាន់ចាប់កាន់ដំបងនិងកាំបិតនៅឡើយក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែចាប់កាន់ដំបងនិងកាំបិត តែមិនទាន់ងាឡើងនូវដំបងនិងកាំបិតនៅឡើយ ក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែងាឡើងនូវដំបងនិងកាំបិត តែមិនទាន់សំពងកាប់ដោយដំបងនិងកាំបិតនៅឡើយ ក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែសំពងកាប់ដោយដំបងនិងកាំបិត តែមិនទាន់ធ្វើឲ្យធ្លុះធ្លាយដាច់ដាចនៅឡើយ ក៏មាន ។

១០៣

## បុណ្ណកមាណវកបញ្ហានិទ្ទេសោ

អត្ថិ កញ្ចិ កាលំ កោធោ ឆិន្នវិច្ឆិន្នករណមត្តោ ហោតិ ន ច តាវ សម្ភញ្ជនបរិភញ្ជនោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោធោ សម្ភញ្ជនបរិភញ្ជនមត្តោ ហោតិ ន ច តាវ អង្គមង្គាបកឌ្ឍនោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោធោ អង្គមង្គាបកឌ្ឍនមត្តោ ហោតិ ន ច តាវ ជីវិតបជាសនោ ហោតិ ។ អត្ថិ កញ្ចិ កាលំ កោធោ ជីវិតបជាសនមត្តោ ហោតិ ន ច តាវ សព្វច្ចាគបរិច្ចាគសណ្ឋិតោ ហោតិ ។ យតោ កោធោ បរំ បុគ្គលំ ឃាតេត្វា អត្តានំ ឃាតេតិ ឯត្តាវតា កោធោ បរមុស្សទគតោ បរមវេបុល្លប្បត្តោ ហោតិ ។ យស្សេសោ កោធោ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ សោ វុច្ចតិ វិធូមោ ។ កោធស្ស បហីនត្តា វិធូមោ កោធវត្ថុស្ស បរិញ្ញាតត្តា វិធូមោ កោធហេតុស្ស ឧច្ឆិន្នត្តា វិធូមោតិ វិធូមោ ។

បុណ្ណកមាណវកបញ្ហានិទ្ទេស

ក្នុងកាលខ្លះ ក្រោធគ្រាន់តែធ្វើឲ្យផ្ទុះឆ្ងាយដាច់ដាច តែមិនទាន់បំបាក់បំបែកនៅឡើយ ក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែបំបាក់បំបែក តែមិនទាន់អូសទាញមក នូវអវយវៈតូចនឹងអវយវៈធំនៅឡើយ ក៏មាន ។ ក្នុងកាលខ្លះ ក្រោធគ្រាន់តែទាញកន្ត្រាក់មកនូវអវយវៈតូចនិងអវយវៈធំ តែមិនទាន់ញុំាងជីវិតឲ្យវិនាសនៅឡើយក៏មាន ។ ក្នុងកាលខ្លះក្រោធគ្រាន់តែញុំាងជីវិតឲ្យវិនាស តែមិនទាន់តាំងនៅក្នុងការលះនិងការបរិច្ចាគ(ជីវិត) ទាំងអស់គ្នានៅឡើយក៏មាន ។ ក្នុងកាលណាបុគ្គលអ្នកក្រោធសម្លាប់បុគ្គលដទៃហើយសម្លាប់ខ្លួន ក្នុងកាលនោះ ក្រោធក៏ដល់នូវសភាពដ៏ចម្រើនក្រៃលែង ដល់នូវសភាពដ៏ទូលំទូលាយដ៏ក្រៃលែង ដោយហេតុមានប្រមាណប៉ុណ្ណោះ ។ ក្រោធនុ៎ះ ដែលបុគ្គលណា បានលះបង់ កាត់ផ្តាច់ ចូលទៅរម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ ហៅថា អ្នកកម្ចាត់បង់ ។ បុគ្គលនោះឈ្មោះថា អ្នកកម្ចាត់បង់ ព្រោះលះក្រោធហើយ ឈ្មោះថា អ្នកកម្ចាត់បង់ ព្រោះកំណត់ដឹងនូវវត្ថុក្រោធហើយ ឈ្មោះថា អ្នកកម្ចាត់បង់ ព្រោះកាត់ផ្តាច់នូវហេតុនៃក្រោធ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកកម្ចាត់បង់ ។

អនីឃោតិ រាគោ នីឃោ ទោសោ នីឃោ មោហោ នីឃោ កោធោ នីឃោ ឧបនាហោ នីឃោ ។ បេ ។ សព្វាកុសលាភិសង្ខារា នីឃា ។ យស្សេតេ នីឃា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ អនីឃោ ។ និរាសោតិ អាសា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យស្សេសា អាសា តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ និរាសោ ។ ជាតីតិ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ ។ ជរាតិ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ ។

ពាក្យថា អ្នកមិនមានទុក្ខ សេចក្ដីថា រាគៈជាទុក្ខ ទោសៈជាទុក្ខ មោហៈជាទុក្ខ ក្រោធជាទុក្ខ ការចងក្រោធទុកជាទុក្ខ ។ បេ ។ អភិសង្ខារ ជាអកុសលទាំងពួងជាទុក្ខ ។ ទុក្ខទាំងនុ៎ះ បុគ្គលណា លះបង់ កាត់ផ្ដាច់ ចូលទៅរម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានទុក្ខ ។ ពាក្យថា អ្នកមិនមានសេចក្ដីប្រាថ្នា សេចក្ដីថា តណ្ហា ហៅថា សេចក្ដីប្រាថ្នា បានដល់សេចក្ដីរីករាយ សេចក្ដីរីករាយខ្លាំង ។ បេ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាគឺការប្រាថ្នានុ៎ះ បុគ្គលណា លះបង់ កាត់ផ្ដាច់ ចូលទៅរម្ងាប់ រម្ងាប់ចំពោះ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានសេចក្ដីប្រាថ្នា ។ ពាក្យថា ជាតិ បានដល់ការកើត ការកើតព្រម កិរិយាឈានចុះ ការកើត ការកើតចំពោះ ការកើតប្រាកដនៃខន្ធទាំងឡាយ ការបានចំពោះ នូវអាយតនៈទាំងឡាយ នៃសត្វទាំងឡាយនោះ ៗ ក្នុងពួកនៃសត្វនោះៗ ។ ពាក្យថា ជរា គឺការចាស់ ភាពនៃសេចក្ដីគ្រាំគ្រា ភាពនៃធ្មេញបាក់ ភាពនៃសក់ស្កូវ ភាពនៃស្បែកជ្រីវជ្រួញ សេចក្ដីសាបសូន្យនៃអាយុ សេចក្ដីចាស់ជុំវិញនៃឥន្ទ្រិយ នៃសត្វទាំងឡាយនោះៗ ក្នុងពួកនៃសត្វនោះៗ ។

១០៤

## បុណ្ណកមាណវកបញ្ហានិទ្ទេសោ

សន្តោ វិធូមោ អនីឃោ និរាសោ អតារិ សោ ជាតិ-ជរន្តិ ព្រូមីតិ យោ សន្តោ ច វិធូមោ ច អនីឃោ ច និរាសោ ច សោ ជាតិជរាមរណំ អតារិ ឧត្តារិ បតារិ សមតិក្កមិ វីតិវត្តយីតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ សន្តោ វិធូមោ អនីឃោ និរាសោ អតារិ សោ ជាតិជរន្តិ ព្រូមិ ។ តេនាហ ភគវា

សង្ខាយ លោកស្មឹ បរោបរានិ
(បុណ្ណកាតិ ភគវា)
យស្សិញ្ជិតំ នត្ថិ កុហិញ្ចិ លោកេ
សន្តោ វិធូមោ អនីឃោ និរាសោ
អតារិ សោ ជាតិជរន្តិ ព្រូមីតិ ។

សហ គាថាបរិយោសានា ។ បេ ។ បញ្ជលិកោ ភគវន្តំ នមស្សមានោ និសិន្នោ ហោតិ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

បុណ្ណកមាណវកបញ្ហានិទ្ទេសោ តតិយោ ។

ពាក្យថា តថាគតពោលថា បុគ្គលនោះ ជាអ្នកស្ងប់ អ្នកកម្ចាត់បង់ អ្នកមិនមានទុក្ខ អ្នកមិនមានសេចក្តីប្រាថ្នា អាចឆ្លងជាតិនិងជរាបាន បានសេចក្តីថា តថាគតពោល ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើក ចែក ធ្វើឲ្យរាក់ ប្រកាសថា បុគ្គលណាជាអ្នកស្ងប់ផង អ្នកកម្ចាត់បង់ផង អ្នកមិនមានទុក្ខផង អ្នកមិនមានសេចក្តីប្រាថ្នាផង បុគ្គលនោះបានឆ្លង ឆ្លងឡើង ឆ្លងរំលង ផ្ទោះកន្លង លោតរំលង នូវជាតិ ជរា និងមរណៈបាន ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោលថា បុគ្គលនោះ ជាអ្នកស្ងប់ អ្នកកម្ចាត់បង់ អ្នកមិនមានទុក្ខ អ្នកមិនមានសេចក្តីប្រាថ្នា អាចឆ្លងជាតិនិងជរាបាន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលបុណ្ណកៈ) សេចក្តីញាប់ញ័រក្នុងទីនីមួយក្នុងលោកនៃបុគ្គលណាមិនមានទេព្រោះដឹងនូវត្រើយនាយនិងត្រើយអាយក្នុងលោក តថាគតពោលថា បុគ្គលនោះ ជាអ្នកស្ងប់ អ្នកកម្ចាត់បង់ អ្នកមិនមានទុក្ខ អ្នកមិនមានសេចក្តីប្រាថ្នា អាចឆ្លងជាតិនិងជរាបាន ។

ក្នុងពេលដែលចប់ព្រះគាថា ។ បេ ។ បុណ្ណកៈមានអាយុ អង្គុយប្រណម្យអញ្ជលីនមស្ការព្រះមានព្រះភាគ ពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តានៃខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ បុណ្ណកមាណវកប្បញ្ហានិទ្ទេស ទី ៣ ។

# មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៤២] បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ

(ឥច្ចាយស្មា មេត្តគូ)

មញ្ញាមិ តំ វេទគុំ ភាវិតត្តំ

កុតោ នុ ទុក្ខា សមុទាគតា មេ

យេកេចិ លោកស្មឹ អនេករូបា ។

[១៤៣] បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ បុច្ឆាតិ តិស្សោ បុច្ឆា អទិដ្ឋជោតនា បុច្ឆា ទិដ្ឋសំសន្ទនា បុច្ឆា វិមតិច្ឆេទនា បុច្ឆា ។

កតមា អទិដ្ឋជោតនា បុច្ឆា ។ បកតិយា លក្ខណំ អញ្ញាតំ ហោតិ អទិដ្ឋំ អតុលិតំ អតិរិតំ អវិភាវិតំ អវិភូតំ តស្ស ញាណាយ ទស្សនាយ តុលនាយ តិរណាយ វិភាវនត្ថាយ វិភូតត្ថាយ បញ្ហំ បុច្ឆតិ អយំ អទិដ្ឋជោតនា បុច្ឆា ។

# មេត្តគូមាណវកបញ្ហានិទ្ទេស

[១៨២] (មេត្តគូមាណពមានអាយុទូលសួរដូច្នេះថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់នូវសេចក្តីនោះដល់ខ្ញុំព្រះអង្គឲ្យទាន ខ្ញុំព្រះអង្គសម្គាល់ឃើញថា ព្រះអង្គជាអ្នកដល់នូវវេទ ជាអ្នកមានខ្លួនបានអប់រំហើយ សេចក្តីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការក្នុងលោក សេចក្តីទុក្ខទាំងនេះ កើតមកអំពីទីណាហ្ន៎ ។

[១៨៣] អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់នូវសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា សួរ បានដល់សំណួរ ៣ គឺ អទិដ្ឋជោតនាបុច្ឆា (សំណួរជាគ្រឿងបំភ្លឺហេតុដែលមិនទាន់បានឃើញ) ១ ទិដ្ឋសំសន្ទនាបុច្ឆា (សំណួរជាគ្រឿងប្រៀបផ្ទឹមហេតុ ដែលធ្លាប់ឃើញហើយ) ១ វិមតិច្ឆេទនាបុច្ឆា (សំណួរជាគ្រឿងកាត់សេចក្តីងឿងឆ្ងល់) ១ ។

អទិដ្ឋជោតនាបុច្ឆា តើដូចម្តេច ។ លក្ខណៈដែលបុគ្គលមិនទាន់ដឹង មិនទាន់ឃើញ មិនទាន់ថ្លឹង មិនទាន់ពិចារណា មិនទាន់យល់ច្បាស់ មិនទាន់ប្រាកដ ដោយប្រក្រតី បុគ្គលសួរប្រស្នាដើម្បីការដឹង ការឃើញ ការថ្លឹង ការពិចារណា ដើម្បីប្រយោជន៍ដល់ការយល់ច្បាស់ ដើម្បីប្រយោជន៍ឲ្យប្រាកដនូវលក្ខណៈនោះ នេះអទិដ្ឋជោតនាបុច្ឆា ។

១០៧

## មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

កតមា ទិដ្ឋសំសន្ទនា បុច្ឆា ។ បកតិយា លក្ខណំ ញាតំ ហោតិ ទិដ្ឋំ តុលិតំ តិរិតំ វិភាវិតំ វិភូតំ អញ្ញេហិ បណ្ឌិតេហិ សទ្ធឹ សំសន្ទនត្ថាយ បញ្ហំ បុច្ឆតិ អយំ ទិដ្ឋសំសន្ទនា បុច្ឆា ។

កតមា វិមតិច្ឆេទនា បុច្ឆា ។ បកតិយា សំសយំ បក្ខន្ទោ[១] ហោតិ វិមតឹ បក្ខន្ទោ ទ្វេឡ្ហកជាតោ ឯវំ នុខោ ន នុខោ កិន្នុខោ កថំ នុខោតិ[២] សោ វិមតិច្ឆេទនត្ថាយ បញ្ហំ បុច្ឆតិ អយំ វិមតិច្ឆេទនា បុច្ឆា ។ ឥមា តិស្សោ បុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា មនុស្សបុច្ឆា អមនុស្សបុច្ឆា និម្មិតបុច្ឆា ។

កតមា មនុស្សបុច្ឆា ។ មនុស្សា ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ ភិក្ខូ បុច្ឆន្តិ ភិក្ខុនិយោ បុច្ឆន្តិ ឧបាសកា បុច្ឆន្តិ ឧបាសិកាយោ បុច្ឆន្តិ រាជានោ បុច្ឆន្តិ ខត្តិយា បុច្ឆន្តិ ព្រាហ្មណា បុច្ឆន្តិ វេស្សា បុច្ឆន្តិ សុទ្ទា បុច្ឆន្តិ គហដ្ឋា បុច្ឆន្តិ បព្វជិតា បុច្ឆន្តិ អយំ មនុស្សបុច្ឆា ។

១ ម. បក្ខន្ទោ ។ ២ ម. ននុខោ កតរំ នុខោតិ ។

មេត្តគូមាណវកបញ្ហានិទ្ទេស

ទិដ្ឋសំសន្ទនាបុច្ឆា តើដូចម្ដេច ។ លក្ខណៈដែលបុគ្គលបានដឹង ឃើញ ថ្លឹង ពិចារណា យល់ច្បាស់ ប្រាកដ ដោយប្រក្រតីហើយ បុគ្គលសួរនូវប្រស្នា ដើម្បីប្រយោជន៍ប្រៀបផ្ទឹម ជាមួយនឹងពួកអ្នកប្រាជ្ញដទៃ នេះ ទិដ្ឋសំសន្ទនាបុច្ឆា ។

វិមតិច្ឆេទនាបុច្ឆា តើដូចម្ដេច ។ បុគ្គលស្ទុះទៅកាន់សេចក្ដីសង្ស័យ ស្ទុះទៅកាន់សេចក្ដីងឿងឆ្ងល់ មានគំនិតបែកជាពីរ ដោយប្រក្រតីថា យ៉ាងនេះទេឬ ឬមិនមែនទេ ដូចម្ដេចហ្ន៎ ប្រការដូចម្ដេចហ្ន៎ បុគ្គលនោះសួរប្រស្នា ដើម្បីកាត់សេចក្ដីងឿងឆ្ងល់ នេះ វិមតិច្ឆេទនាបុច្ឆា ។ នេះ បុច្ឆា ៣ ។ បុច្ឆា (សំសួរ) ៣ ដទៃទៀត គឺ មនុស្សបុច្ឆា អមនុស្សបុច្ឆា និម្មិតបុច្ឆា ។

មនុស្សបុច្ឆា តើដូចម្ដេច ។ ពួកមនុស្សចូលទៅគាល់ ព្រះពុទ្ធមានព្រះភាគ ហើយសួរប្រស្នា គឺ ពួកភិក្ខុសួរ ពួកភិក្ខុនីសួរ ពួកឧបាសកសួរ ពួកឧបាសិកាសួរ ពួកព្រះរាជាសួរ ពួកក្សត្រសួរ ពួកព្រាហ្មណ៍សួរ ពួកវេស្សៈសួរ ពួកសុទ្ទៈសួរ ពួកគ្រហស្ថសួរ ពួកបព្វជិតសួរ នេះ មនុស្សបុច្ឆា ។

កតមា អមនុស្សបុច្ឆា ។ អមនុស្សា ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ នាគា បុច្ឆន្តិ សុបណ្ណា បុច្ឆន្តិ យក្ខា បុច្ឆន្តិ អសុរា បុច្ឆន្តិ គន្ធព្វា បុច្ឆន្តិ មហារាជានោ បុច្ឆន្តិ ឥន្ទា បុច្ឆន្តិ ព្រហ្មានោ បុច្ឆន្តិ ទេវតាយោ បុច្ឆន្តិ អយំ អមនុស្សបុច្ឆា ។

កតមា និម្មិតបុច្ឆា ។ យំ ភគវា រូបំ អភិ-និម្មិណាតិ មនោមយំ សព្វង្គប្បច្ចង្គំ អនិន្ទ្រិយំ ។ សោ និម្មិតោ ពុទ្ធំ ភគវន្តំ ឧបសង្កមិត្វា បញ្ហំ បុច្ឆតិ ភគវា វិស្សជ្ជេតិ អយំ និម្មិតបុច្ឆា ។ ឥមា តិស្សោ បុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អត្តត្ថបុច្ឆា បរត្ថបុច្ឆា ឧភយត្ថបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ទិដ្ឋធម្មិកត្ថបុច្ឆា សម្ប-រាយិកត្ថបុច្ឆា បរមត្ថបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អនវជ្ជត្ថបុច្ឆា និក្កិលេ-សត្ថបុច្ឆា វោទានត្ថបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា អតីតបុច្ឆា អនាគតបុច្ឆា បច្ចុប្បន្នបុច្ឆា ។

អមនុស្សបុច្ឆា តើដូចម្តេច ។ ពួកអមនុស្ស ចូលទៅគាល់ព្រះពុទ្ធមានព្រះភាគ ហើយសួរប្រស្នា គឺ ពួកនាគសួរ ពួកគ្រុឌសួរ ពួកយក្ខសួរ ពួកអសុរសួរ ពួកគន្ធព្វសួរ ពួកមហារាជសួរ ពួកព្រះឥន្ទសួរ ពួកព្រហ្មសួរ ពួកទេវតាសួរ នេះ អមនុស្សបុច្ឆា ។

និម្មិតបុច្ឆា តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់និម្មិតរូបណា មានអវយវៈសព្វគ្រប់ មានឥន្ទ្រិយមិនខ្វះខាត ដែលសម្រេចអំពីចិត្ត ។ រូបនិម្មិតនោះ ចូលទៅគាល់ព្រះពុទ្ធមានព្រះភាគ ហើយសួរប្រស្នា ព្រះមានព្រះភាគក៏ទ្រង់ដោះស្រាយ នេះ និម្មិតបុច្ឆា ។ នេះ បុច្ឆា ៣ ។

បុច្ឆា ៣ ដទៃទៀតគឺ បុច្ឆាចំពោះប្រយោជន៍នៃខ្លួន ១ បុច្ឆាចំពោះប្រយោជន៍បុគ្គលដទៃ ១ បុច្ឆាចំពោះប្រយោជន៍ទាំងពីរ ១ ។

បុច្ឆា ៣ ដទៃទៀត គឺ បុច្ឆាចំពោះប្រយោជន៍បច្ចុប្បន្ន ១ បុច្ឆាចំពោះប្រយោជន៍បរលោក ១ បុច្ឆាចំពោះប្រយោជន៍ដ៏ក្រៃលែង ១ ។

បុច្ឆា ៣ ដទៃទៀត គឺ បុច្ឆាចំពោះប្រយោជន៍មិនមានទោស ១ បុច្ឆាចំពោះប្រយោជន៍មិនមានកិលេស ១ បុច្ឆាចំពោះប្រយោជន៍ដ៏ផូរផង់ ១ ។

បុច្ឆា ៣ ដទៃទៀត គឺ អតីតបុច្ឆា ១ អនាគតបុច្ឆា ១ បច្ចុប្បន្នបុច្ឆា ១ ។

១០៩

## មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

អបរាបិ តិស្សោ បុច្ឆា អជ្ឈត្តបុច្ឆា ពហិទ្ធាបុច្ឆា អជ្ឈត្តពហិទ្ធាបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា កុសលបុច្ឆា អកុសលបច្ឆា អព្យាកតបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ខន្ធបុច្ឆា ធាតុបុច្ឆា អាយតនបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា សតិប្បដ្ឋានបុច្ឆា សម្មប្បធានបុច្ឆា ឥទ្ធិបាទបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា ឥន្ទ្រិយបុច្ឆា ពលបុច្ឆា ពោជ្ឈង្គបុច្ឆា ។

អបរាបិ តិស្សោ បុច្ឆា មគ្គបុច្ឆា ផលបុច្ឆា និព្វានបុច្ឆា ។

បុច្ឆាមិ តន្តិ បុច្ឆាមិ តំ យាចាមិ តំ អជ្ឈេសាមិ តំ បសាទេមិ តំ កាថស្សុ មេតិ បុច្ឆាមិ តំ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ចិកា បញ្ញត្តិ យទិទំ ភគវាតិ ។ ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

បុច្ឆា ៣ ដទៃទៀត គឺ បុច្ឆាធម៌ក្នុង ១ បុច្ឆាធម៌ក្រៅ ១ បុច្ឆាធម៌ទាំងក្នុងទាំងក្រៅ ១ ។

បុច្ឆា ៣ ដទៃទៀត គឺ កុសលបុច្ឆា ១ អកុសលបុច្ឆា ១ អព្យាកតបុច្ឆា ១ ។

បុច្ឆា ៣ ដទៃទៀត គឺ ខន្ធបុច្ឆា ១ ធាតុបុច្ឆា ១ អាយតនបុច្ឆា ១ ។

បុច្ឆា ៣ ដទៃទៀត គឺ ១ សតិប្បដ្ឋានបុច្ឆា ១ សម្មប្បធានបុច្ឆា ១ ឥទ្ធិបាទបុច្ឆា ១ ។

បុច្ឆា ៣ ដទៃទៀត គឺ ឥន្ទ្រិយបុច្ឆា ១ ពលបុច្ឆា ១ ពោជ្ឈង្គបុច្ឆា ១ ។

បុច្ឆា ៣ ដទៃទៀត គឺ មគ្គបុច្ឆា ១ ផលបុច្ឆា ១ និព្វានបុច្ឆា ១ ។

ពាក្យថា ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ គឺ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមអង្វរព្រះអង្គ អារាធនាព្រះអង្គ ជ្រះថ្លាចំពោះព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គទូលសួរព្រះអង្គ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ គឺ សូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (លោកពោលថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

ឥច្ចាយស្មា មេត្តគូតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ ឥច្ចាយស្មា មេត្តគូ ។

[១៤៤] មញ្ញាមិ តំ វេទគុំ ភាវិតត្តន្តិ វេទគូតិ តំ មញ្ញាមិ ភាវិតត្តោតិ តំ មញ្ញាមិ ឯវំ មញ្ញាមិ ឯវំ ជានាមិ ឯវំ អាជានាមិ ឯវំ វិជានាមិ ឯវំ បដិវិជានាមិ ឯវំ បដិវិជ្ឈាមិ វេទគូ ភាវិតត្តោតិ ។

កាថញ្ច ភគវា វេទគូ ។ វេទោ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិ-ចយសម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ ។ ភគវា តេហិ វេទេហិ ជាតិជរាមរណស្ស អន្តគតោ អន្តប្បត្តោ កោដិគតោ កោដិប្បត្តោ បរិយន្ត-គតោ បរិយន្តប្បត្តោ វោសានគតោ វោសានប្បត្តោ តាណគតោ តាណប្បត្តោ លេណគតោ លេណប្ប-ត្តោ សរណគតោ សរណប្បត្តោ អភយគតោ អភយប្បត្តោ អច្ចុតគតោ អច្ចុតប្បត្តោ អមតគតោ អមតប្បត្តោ និព្វានគតោ និព្វានប្បត្តោ ។

ពាក្យថា ដូច្នេះ របស់បទថា មេត្តគូមានអាយុ (ទូលសួរ) ដូច្នេះ គឺជាបទតភ្ជាប់ ។ បេ ។ មេត្តគូមានអាយុ (ទូលសួរ) ដូច្នេះ ។

[១៤៤] ពាក្យថា ខ្ញុំព្រះអង្គសម្គាល់ឃើញថា ព្រះអង្គជាអ្នកដល់នូវវេទ ជាអ្នកមានខ្លួនបានអប់រំហើយ អធិប្បាយថា ខ្ញុំព្រះអង្គសម្គាល់ព្រះអង្គថា ជាអ្នកដល់នូវវេទ សម្គាល់ព្រះអង្គថា ជាអ្នកមានខ្លួនអប់រំហើយ ខ្ញុំព្រះអង្គសម្គាល់យ៉ាងនេះ ដឹងយ៉ាងនេះ យល់យ៉ាងនេះ ដឹងច្បាស់យ៉ាងនេះ ដឹងចំពោះយ៉ាងនេះ ចាក់ធ្លុះយ៉ាងនេះថា ព្រះអង្គដល់នូវវេទ មានខ្លួនបានអប់រំហើយ ។

ព្រះមានព្រះភាគឈ្មោះថាទ្រង់ដល់នូវវេទ តើដូចម្តេច ។ ញាណ ប្រាជ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយសម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គ ៤ លោកហៅថា វេទ ។ ព្រះមានព្រះភាគទៅកាន់ទីបំផុត ដល់នូវទីបំផុតនៃជាតិជរានិងមរណៈ ដោយវេទទាំងឡាយនោះ ទៅកាន់ទីខាងចុង ដល់ទីខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីចប់ ដល់ទីចប់ ទៅកាន់ទីពំនាក់ ដល់ទីពំនាក់ ទៅកាន់ទីជ្រកកោន ដល់ទីជ្រកកោន ទៅកាន់ទីពឹង ដល់ទីពឹង ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់អមតៈ ដល់អមតៈ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន ។

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

វេទានំ វា អន្តគតោតិ វេទគូ ។ វេទេហិ វា អន្តគតោតិ វេទគូ ។ សត្តន្នំ វា ធម្មានំ វិទិតត្តា វេទគូ ។ សក្កាយទិដ្ឋិ វិទិតា ហោតិ វិចិកិច្ឆា វិទិតា ហោតិ សីលព្វតបរាមាសោ វិទិតោ ហោតិ រាគោ ទោសោ មោហោ មានោ វិទិតោ ហោតិ ។ វិទិតស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា(១) ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ។

វេទានិ វិចេយ្យ កេវលានិ (សភិយាតិ ភគវា)
សមណានំ យានិ បត្ថិ(២) ព្រាហ្មណានំ
សព្វវេទនាសុ(៣) វីតរាគោ
សព្វំ វេទមតិច្ច(៤) វេទគូ សោ ។

១ ម. សទរថា ។ ២ ម. អត្ថិ ។ ៣ ម. សព្វវោសុ ។ ៤ ម. សព្វវើ បដិច្ច ។

មួយទៀត ព្រះអង្គឈ្មោះថា ទ្រង់ដល់នូវវេទ ព្រោះទ្រង់ដល់ទីបំផុតនៃវេទទាំងឡាយ ។ មួយទៀត ព្រះអង្គឈ្មោះថាទ្រង់ដល់នូវវេទ ព្រោះទ្រង់ដល់ទីបំផុតដោយវេទទាំងឡាយ មួយវិញទៀត ព្រះអង្គ ឈ្មោះថា ទ្រង់ដល់នូវវេទ ព្រោះដឹងច្បាស់នូវធម៌ទាំង ៧ ។ គឺព្រះអង្គទ្រង់ដឹងច្បាស់សក្កាយទិដ្ឋិ ដឹងច្បាស់វិចិកិច្ឆា ដឹងច្បាស់សីលព្វតបរាមាសៈ ដឹងច្បាស់រាគៈ ទោសៈ មោហៈ មានៈ ។ ធម៌ជាអកុសល ដ៏លាមកជាគ្រឿងសៅហ្មង នាំឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានផលជាទុក្ខ មានជាតិ ជរា មរណៈ ប្រព្រឹត្តទៅខាងមុខជាធម៌គឺព្រះអង្គទ្រង់ជ្រាបច្បាស់ហើយ ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសភិយៈ) បុគ្គលណា
ពិនិត្យច្បាស់នូវវេទទាំងអស់ ដែលជារបស់សមណព្រាហ្មណ៍
ទាំងឡាយ ជាអ្នកមានតម្រេកទៅប្រាស ក្នុងវេទនាទាំងពួង
កន្លងផុតនូវវេទទាំងពួង បុគ្គលនោះឈ្មោះថា អ្នកដល់នូវវេទ ។

កថំ ភគវា ភាវិតត្តោ ។ ភគវា ភាវិតកាយោ ភាវិតសីលោ ភាវិតចិត្តោ ភាវិតប្បញ្ញោ ភាវិតស្សតិប្បដ្ឋានោ ភាវិតសម្មប្បធានោ ភាវិតឥទ្ធិបាទោ ភាវិតិន្ទ្រិយោ ភាវិតពលោ ភាវិតពោជ្ឈង្គោ ភាវិតមគ្គោ បហីនក្កិលេសោ បដិវិទ្ធាកុប្បោ សច្ឆិកតនិរោធោ ។ ទុក្ខំ តស្ស បរិញ្ញាតំ[១] សមុទយោ បហីនោ មគ្គោ ភាវិតោ និរោធោ សច្ឆិកតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ សច្ឆិកាតព្វំ សច្ឆិកតំ ។ អបរិត្តោ មហន្តោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាឡ្ហោ ពហុរតនោ សាគរុបមោ ឆឡង្គុបេក្ខាយ សមន្នាគតោ ហោតិ ។

ព្រះមានព្រះភាគ ឈ្មោះថា មានខ្លួនបានអប់រំហើយ តើដូចម្តេច ។ ព្រះមានព្រះភាគ មានព្រះកាយអប់រំហើយ មានសីលអប់រំហើយ មានព្រះទ័យអប់រំហើយ មានប្រាជ្ញាអប់រំហើយ មានសតិប្បដ្ឋានអប់រំហើយ មានសម្មប្បធានអប់រំហើយ មានឥទ្ធិបាទអប់រំហើយ មានឥន្ទ្រិយអប់រំហើយ មានពលៈអប់រំហើយ មានពោជ្ឈង្គអប់រំហើយ មានមគ្គអប់រំហើយ មានកិលេសលះបង់ហើយ មានអកុប្បធម៌ត្រាស់ដឹងហើយ មាននិរោធធ្វើឲ្យជាក់ច្បាស់ហើយ ។ ទុក្ខក៏ព្រះមានព្រះភាគនោះ កំណត់ដឹងហើយ សមុទយៈ ទ្រង់លះបង់ហើយ មគ្គព្រះអង្គចម្រើនហើយ និរោធព្រះអង្គធ្វើឲ្យជាក់ច្បាស់ហើយ គុណជាតដែលគប្បីជ្រាបច្បាស់ ព្រះអង្គជ្រាបច្បាស់ហើយ ធម្មជាតដែលគួរកំណត់ដឹង ព្រះអង្គកំណត់ដឹងហើយ កិលេសជាត ដែលត្រូវលះ ព្រះអង្គលះបង់ហើយ គុណជាតដែលត្រូវចម្រើន ព្រះអង្គចម្រើនហើយ គុណជាតដែលត្រូវធ្វើឲ្យជាក់ច្បាស់ ព្រះអង្គធ្វើឲ្យជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគ មិនមែនជាបុគ្គលតូចតាចទេ ជាបុគ្គលធំ ជាបុគ្គលជ្រៅ មានប្រមាណមិនបាន ដែលអ្នកផងស្ទង់មើលបានដោយក្រ មានរតនៈច្រើន ប្រៀបដូចសាគរ ជាបុគ្គលប្រកបដោយឆឡង្គុបេក្ខា ។

១១៣

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្ម-
នោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ
សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា
ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា
មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ ន
ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ។
ចក្ខុនា រូបំ ទិស្វា មនាបំ[1] នាភិគិជ្ឈតិ នាភិបិ-
ហយតិ[2] ន រាគំ ជនេតិ ។ តស្ស ឋិតោ វ កា-
យោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិ-
មុត្តំ ។ ចក្ខុនា ខោ បនេតំ រូបំ ទិស្វា អមនាបំ
ន មង្កុ ហោតិ អប្បតិដ្ឋីនចិត្តោ អទិនមនសោ[3] អព្យា-
បន្នចេតសោ ។ តស្ស ឋិតោ វ កាយោ ហោតិ
ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។

---

១ ម. មនាបំ រូបំ ។ ២ ម. នាភិហឹសតិ ។ ៣ កត្ថចិ បោត្ថកេ អាទិនមនសោតិ ទិស្សតិ ។

មេត្តគូមាណវកបញ្ហានិទ្ទេស

ព្រះអង្គទតឃើញរូបដោយចក្ខុហើយ មិនត្រេកអរ មិនអាក់អន់ ទ្រង់គង់ព្រងើយកន្តើយ មានស្មារតីជ្រាបច្បាស់ ព្រះអង្គឮសំឡេងដោយសោតៈ ធុំក្លិនដោយឃានៈ លិទ្ធរសដោយជិវ្ហា ពាល់ត្រូវផ្សព្វដោយកាយ ជ្រាបធម្មារម្មណ៍ដោយព្រះទ័យហើយ មិនត្រេកអរ មិនអាក់អន់ ទ្រង់គង់ព្រងើយកន្តើយ មានស្មារតីជ្រាបច្បាស់ ។ ព្រះអង្គទតឃើញរូបដោយចក្ខុហើយ មិនជាប់ មិនស្រឡាញ់ ចំពោះរូបជាទីពេញចិត្ត មិនញុំាងរាគៈឲ្យកើតឡើង ។ ព្រះអង្គមានព្រះកាយខ្ជាប់ខ្ជួន មានព្រះទ័យខ្ជាប់ខ្ជួន ជាព្រះទ័យឋិតនៅដោយល្អខាងក្នុងសន្តាន រួចស្រឡះដោយប្រពៃ ។ ព្រះអង្គទតឃើញរូបនុ៎ះ ដោយចក្ខុហើយ ក៏មិនស្អប់ចំពោះរូបមិនជាទីពេញចិត្ត ព្រះអង្គមានព្រះទ័យមិនអាក់អន់ មានព្រះទ័យមិនរួញរា មានព្រះទ័យមិនគុំក្លួន ។ ព្រះអង្គមានព្រះកាយខ្ជាប់ខ្ជួន មានព្រះទ័យខ្ជាប់ខ្ជួន ជាព្រះទ័យឋិតនៅដោយល្អ ខាងក្នុងសន្តាន ជាព្រះទ័យរួចស្រឡះដោយប្រពៃ ។

សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិ-ត្វា មនសា ធម្មំ វិញ្ញាយ មនាបំ នាភិគិជ្ឈតិ នាភិបិហយតិ ន រាគំ ជនេតិ តស្ស ឋិតោ វ កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ មនសា ខោ បនេតំ ធម្មំ វិញ្ញាយ អមនាបំ ន មង្កុ ហោតិ អប្បតិដ្ឋីនចិត្តោ អទិនមនសោ អព្យាបន្នចេតសោ ។ តស្ស ឋិតោ វ កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។ ចក្ខុនា រូបំ ទិស្វា មនាបាមនាបេសុ រូបេសុ ឋិតោ វ កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុ-សណ្ឋិតំ សុវិមុត្តំ ។ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ មនាបាម-នាបេសុ ធម្មេសុ ឋិតោ វ កាយោ ហោតិ ឋិតំ ចិត្តំ អជ្ឈត្តំ សុសណ្ឋិតំ សុវិមុត្តំ ។

ព្រះអង្គឮសំឡេងដោយសោតៈ ធុំក្លិនដោយឃានៈ លិទ្ធរសដោយជិវ្ហា ពាល់ត្រូវផ្សព្វដោយកាយ ជ្រាបច្បាស់ធម្មារម្មណ៍ដោយព្រះទ័យហើយ មិនជាប់ មិនស្រឡាញ់ ចំពោះអារម្មណ៍ជាទីពេញចិត្ត មិនញុាំងរាគៈឲ្យកើតឡើង ។ ព្រះអង្គមានព្រះកាយខ្ជាប់ខ្ជួន មានព្រះទ័យខ្ជាប់ខ្ជួន ជាព្រះទ័យឋិតនៅដោយល្អ ខាងក្នុងសន្តាន រួចស្រឡះដោយប្រពៃ ។ ព្រះអង្គជ្រាបច្បាស់ នូវធម្មារម្មណ៍នុ៎ះ ដោយព្រះទ័យហើយ មិនស្អប់ចំពោះអារម្មណ៍មិនជាទីពេញចិត្ត មានព្រះទ័យមិនថ្នាំងថ្នាក់ មានព្រះទ័យមិនរួញរា មានព្រះទ័យមិនគុំក្ហួន ។ ព្រះអង្គមានព្រះកាយខ្ជាប់ខ្ជួន មានព្រះទ័យខ្ជាប់ខ្ជួន ជាព្រះទ័យឋិតនៅដោយល្អខាងក្នុងសន្តាន រួចស្រឡះដោយប្រពៃ ។ ព្រះអង្គទតឃើញរូបដោយចក្ខុហើយ មានព្រះកាយខ្ជាប់ខ្ជួនក្នុងរូបទាំងឡាយ ជាទីពេញចិត្តនិងមិនជាទីពេញចិត្ត ព្រះអង្គមានព្រះកាយខ្ជាប់ខ្ជួន មានព្រះទ័យខ្ជាប់ខ្ជួន ជាព្រះទ័យឋិតនៅដោយល្អខាងក្នុងសន្តាន រួចស្រឡះដោយប្រពៃ ។ ព្រះអង្គឮសំឡេងដោយសោតៈ ធុំក្លិនដោយឃានៈ លិទ្ធរសដោយជិវ្ហា ពាល់ត្រូវផ្សព្វដោយព្រះកាយ ជ្រាបធម្មារម្មណ៍ដោយព្រះទ័យហើយ មានព្រះកាយខ្ជាប់ខ្ជួនក្នុងធម្មារម្មណ៍ទាំងឡាយជាទីពេញចិត្ត និងមិនជាទីពេញចិត្ត មានព្រះទ័យខ្ជាប់ខ្ជួន ជាព្រះទ័យឋិតនៅដោយល្អខាងក្នុងសន្តាន រួចស្រឡះដោយប្រពៃ ។

១១៨

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

ចក្ខុនា រូបំ ទិស្វា រជនីយេ ន រជ្ជតិ ទោសនីយេ ន ទុស្សតិ មោហនីយេ ន មុយ្ហតិ កោបនីយេ ន កុប្បតិ មទនីយេ ន មជ្ជតិ កិលេសនីយេ ន កិ-
លិស្សតិ ។ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ រជនីយេ ន រជ្ជតិ ទោសនីយេ ន ទុស្សតិ មោហនីយេ ន មុយ្ហតិ កោបនីយេ ន កុប្បតិ មទនីយេ ន មជ្ជតិ កិលេ-
សនីយេ ន កិលិស្សតិ ។ ទិដ្ឋេ ទិដ្ឋមត្តោ សុតេ សុតមត្តោ មុតេ មុតមត្តោ វិញ្ញាតេ វិញ្ញាតមត្តោ ទិដ្ឋេ ន លិម្បតិ សុតេ ន លិម្បតិ មុតេ ន លិម្បតិ វិញ្ញាតេ ន លិម្បតិ

មេត្តគូមាណវកបញ្ហានិទ្ទេស

ព្រះអង្គទតឃើញរូបដោយចក្ខុហើយ មិនត្រេកអរក្នុងអារម្មណ៍ដែលគួរត្រេកអរ មិនប្រទូស្តក្នុងអារម្មណ៍ដែលគួរប្រទូស្ត មិនវង្វេងក្នុងអារម្មណ៍ដែលគួរវង្វេង មិនកម្រើកក្នុងអារម្មណ៍ដែលគួរកម្រើក មិនស្រវឹងក្នុងអារម្មណ៍ដែលគួរស្រវឹង មិនសៅហ្មងក្នុងអារម្មណ៍ដែលគួរសៅហ្មង ។ ព្រះអង្គឮសំឡេងដោយសោតៈ ធុំក្លិនដោយឃានៈ លិទ្ធរសដោយជិវ្ហា ពាល់ត្រូវផ្សព្វដោយកាយ ជ្រាបច្បាស់ធម្មារម្មណ៍ដោយព្រះទ័យហើយ មិនត្រេកអរក្នុងអារម្មណ៍ដែលគួរត្រេកអរ មិនប្រទូស្តក្នុងអារម្មណ៍ដែលគួរប្រទូស្ត មិនវង្វេងក្នុងអារម្មណ៍ដែលគួរវង្វេង មិនកម្រើកក្នុងអារម្មណ៍ដែលគួរកម្រើក មិនស្រវឹងក្នុងអារម្មណ៍ ដែលគួរស្រវឹង មិនសៅហ្មងក្នុងអារម្មណ៍ដែលគួរសៅហ្មង ។ ព្រះអង្គគ្រាន់តែទតឃើញ ចំពោះរូបដែលឃើញ គ្រាន់តែឮចំពោះសំឡេងដែលឮ គ្រាន់តែប៉ះពាល់ចំពោះអារម្មណ៍ដែលប៉ះពាល់ គ្រាន់តែជ្រាបចំពោះធម្មារម្មណ៍ដែលជ្រាប មិនប្រឡាក់ក្នុងរូបដែលឃើញ មិនប្រឡាក់ក្នុងសំឡេងដែលឮ មិនប្រឡាក់ក្នុងអារម្មណ៍ដែលប៉ះពាល់ មិនប្រឡាក់ក្នុងធម្មារម្មណ៍ដែលជ្រាបហើយ

ទិដ្ឋេ អនុបយោ[១] អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន[២] ចេតសា វិហរតិ សុតេ មុតេ វិញ្ញាតេ អនុបយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សំវិជ្ជតិ ភគវតោ ចក្ខុ បស្សតិ ភគវា ចក្ខុនា រូបំ ឆន្ទរាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។ សំវិជ្ជតិ ភគវតោ សោតំ សុណាតិ ភគវា សោតេន សទ្ទំ ឆន្ទរាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។ សំវិជ្ជតិ ភគវតោ ឃានំ ឃាយតិ ភគវា ឃានេន គន្ធំ ឆន្ទ-រាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។ សំ-វិជ្ជតិ ភគវតោ ជិវ្ហា សាយតិ ភគវា ជិវ្ហាយ រសំ ឆន្ទរាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។

---

១ ម. អនុសយោ អនបាយោ ។ ២ ម. វិសញ្ញុត្តោ វិបរិយាទិកតេន ។

ព្រះអង្គមិនស្រើបស្រាល មិនអាស្រ័យ មិនជាប់ចំពាក់ ក្នុងរូបដែលឃើញ ទ្រង់រួចស្រឡះ ប្រាសចេញ មានព្រះទ័យប្រាសចាកសេចក្តីសល់វល់ ព្រះអង្គមិនស្រើបស្រាល មិនអាស្រ័យ មិនជាប់ចំពាក់ក្នុងសំឡេងដែលឮ ក្នុងអារម្មណ៍ដែលប៉ះពាល់ ក្នុងធម្មារម្មណ៍ដែលជ្រាបច្បាស់ ព្រះអង្គរួចស្រឡះ ប្រាសចេញ មានព្រះទ័យប្រាសចាកសេចក្តីសល់វល់ ។ ចក្ខុរបស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ព្រះមានព្រះភាគ ទតឃើញរូបដោយចក្ខុ តែឆន្ទរាគ នៃព្រះមានព្រះភាគមិនមានទេ (ព្រោះ) ព្រះមានព្រះភាគ មានព្រះទ័យរួចស្រឡះដោយប្រពៃ ។ សោតៈរបស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ ព្រះមានព្រះភាគ ទ្រង់ឮសំឡេង ដោយសោតៈ តែឆន្ទរាគនៃព្រះមានព្រះភាគមិនមានទេ(ព្រោះ)ព្រះមានព្រះភាគ មានព្រះទ័យរួចស្រឡះហើយដោយប្រពៃ ។ ឃានៈរបស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ ព្រះមានព្រះភាគ ទ្រង់ធុំក្លិនដោយឃានៈ តែឆន្ទរាគ នៃព្រះមានព្រះភាគមិនមានទេ (ព្រោះ) ព្រះមានព្រះភាគ មានព្រះទ័យរួចស្រឡះដោយប្រពៃ ។ ជិវ្ហារបស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ ព្រះមានព្រះភាគ ទ្រង់លិទ្ធរសដោយជិវ្ហា តែឆន្ទរាគ នៃព្រះមានព្រះភាគមិនមានទេ (ព្រោះ) ព្រះមានព្រះភាគ មានព្រះទ័យរួចស្រឡះដោយប្រពៃ ។

១១៧

## មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

សំវិជ្ជតិ ភគវតោ កាយោ ផុសតិ ភគវា កាយេន ផោដ្ឋព្វំ ឆន្ទរាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។ សំវិជ្ជតិ ភគវតោ មនោ វិជានាតិ ភគវា មនសា ធម្មំ ឆន្ទរាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។ ចក្ខុ[១] រូបារាមំ រូបរតំ រូបសម្មុទិតំ[២] ភគវតា ទន្តំ គុត្តំ រក្ខិតំ សំវុតំ តស្ស ច សំវរាយ ធម្មំ ទេសេតិ ។ សោតំ សទ្ទារាមំ សទ្ទរតំ ឃានំ គន្ធារាមំ គន្ធរតំ ជិវ្ហា រសារាមា រសរតា រសសម្មុទិតា ភគវតា[៣] ទន្តា គុត្តា រក្ខិតា សំវុតា តស្ស ច សំវរាយ ធម្មំ ទេសេតិ ។ កាយោ ផោដ្ឋព្វារាមោ[៤] មនោ ធម្មារាមោ ធម្មរតោ ធម្មសម្មុទិតោ ភគវតា[៥] ទន្តោ គុត្តោ រក្ខិតោ សំវុតោ តស្ស ច សំវរាយ ធម្មំ ទេសេតិ ។

---

១ ម. ចក្ខុំ ។ ២ ម. រូបសម្មុទិតំ តំ ភគវតោ ។ ៣ ម. សា ភគវតោ ។ ៤ ម. ផោដ្ឋព្វារាមោ ផោដ្ឋព្វរតោ ផោដ្ឋព្វសម្មុទិតោ ។ ៥ ម. សោ ភគវតោ ។

កាយ របស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ ព្រះមានព្រះភាគ ទ្រង់ប៉ះពាល់ផ្សព្វ ដោយកាយ តែឆន្ទរាគ នៃព្រះមានព្រះភាគ មិនមានទេ (ព្រោះ) ព្រះមានព្រះភាគ មានព្រះទ័យរួចស្រឡះដោយប្រពៃ ។ ព្រះទ័យ របស់ព្រះមានព្រះភាគ មានគ្រប់គ្រាន់ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ធម្មារម្មណ៍ ដោយព្រះទ័យ តែឆន្ទរាគ នៃព្រះមានព្រះភាគមិនមានទេ (ព្រោះ) ព្រះមានព្រះភាគ មានព្រះទ័យរួចស្រឡះដោយប្រពៃ ។ ភ្នែកមានរូប ជាទីត្រេកអរ ត្រេកអរហើយក្នុងរូប រីករាយព្រមចំពោះរូប ព្រះមានព្រះភាគ ទ្រង់បានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងទ្រង់សម្តែងធម៌ ដើម្បីការសង្រួមភ្នែកនោះ ។ ត្រចៀកមានសំឡេងជាទីត្រេកអរ ត្រេកអរហើយក្នុងសំឡេង ច្រមុះមានក្លិនជាទីត្រេកអរ ត្រេកអរហើយក្នុងក្លិន អណ្តាតមានរសជាទីត្រេកអរ ត្រេកអរហើយក្នុងរស រីករាយព្រមចំពោះរស ព្រះមានព្រះភាគ ទ្រង់បានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងទ្រង់សម្តែងធម៌ដើម្បីការសង្រួមអណ្តាតនោះ ។ កាយមានផ្សព្វជាទីត្រេកអរ ចិត្តមានធម្មារម្មណ៍ជាទីត្រេកអរ ត្រេកអរហើយក្នុងធម្មារម្មណ៍ រីករាយព្រមចំពោះធម្មារម្មណ៍ ព្រះមានព្រះភាគ ទ្រង់បានទូន្មាន គ្រប់គ្រង រក្សា សង្រួមហើយ ទាំងទ្រង់សម្តែងធម៌ដើម្បីការសង្រួមកាយនោះ ។

ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ
ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យំ តិតិក្ខតិ ។

វរមស្សតរា ទន្តា អាជានិយាវ សិន្ធវា
កុញ្ជរាវ មហានាគា អត្តទន្តោ តតោ វរំ ។

ន ហិ ឯតេហិ យានេហិ គច្ឆេយ្យ អគតំ ទិសំ
យថាត្តនា សុទន្តេន ទន្តោ ទន្តេន គច្ឆតិ ។

វិធាសុ ន វិកម្បន្តិ វិប្បមុត្តា បុនព្ភវា
ទន្តភូមឹ អនុប្បត្តា តេ លោកេ វិជិតាវិនោ ។

យស្សិន្ទ្រិយានិ ភាវិតានិ
អជ្ឈត្តញ្ច ពហិទ្ធា ច សព្វលោកេ
និព្វិជ្ឈិមំ បរញ្ច លោកំ
កាលំ កង្ខតិ ភាវិតោ សុទន្តោតិ ។

ពួកជនរមែងនាំនូវពាហនៈ ដែលហាត់ហើយទៅកាន់ទីប្រជុំ ព្រះរាជារមែងឡើងគង់ពាហនៈដែលហាត់ហើយ បណ្ដាមនុស្សទាំង-ឡាយ មនុស្សណា អត់ធន់នឹងពាក្យពោលទ្រគោះ មនុស្សនោះឈ្មោះថាជាអ្នកហាត់ហើយ ជាបុគ្គលប្រសើរផុត ។ សេះអស្សតរក្ដី សេះសិន្ធពអាជានេយ្យក្ដី ដំរីដ៏ប្រសើរជាកុញ្ជរជាតិក្ដី ដែលគេបង្ហាត់ហើយ ឈ្មោះថាជាសត្វប្រសើរ តែបុគ្គលអ្នកមានខ្លួនទូន្មានហើយ ប្រសើរជាងសត្វទាំងនោះ ។ បុគ្គលមិនគប្បីទៅកាន់ទិសដែលមិនដែលទៅ គឺព្រះនិព្វាន ដោយយានទាំងឡាយនោះបានទេ លុះតែបុគ្គលអ្នកមានខ្លួនទូន្មានហើយ ទើបទៅ(កាន់ទិស គឺព្រះនិព្វាន) ដោយខ្លួនដែលទូន្មានហើយ ទូន្មានល្អហើយ ។ ព្រះអរហន្តទាំងឡាយ រួចចាកភពថ្មី ដល់ហើយនូវទន្តភូមិ គឺអរហត្តផល រមែងមិនកម្រើកក្នុងតណ្ហានិងទិដ្ឋិផ្សេងៗ ព្រះអរហន្តទាំងនោះ ឈ្មោះថា ជាអ្នកមានជ័យជម្នះ ក្នុងលោក ។

ឥន្ទ្រិយទាំងឡាយ ដែលព្រះខីណាស្រពណា ចម្រើនហើយ
ព្រះខីណាស្រពនោះ ឈ្មោះថាមានធម៌ចម្រើនហើយ មាន
ខ្លួនទូន្មានល្អហើយ ដឹងច្បាស់នូវអារម្មណ៍ទាំងខាងក្នុងខាង
ក្រៅ ក្នុងលោកទាំងពួងផង នូវលោកនេះផង នូវលោក
ខាងមុខផង រមែងរង់ចាំនូវកាលកិរិយា តែប៉ុណ្ណោះ ។

ឯវំ ភគវា ភាវិតត្តោតិ មញ្ញាមិ តំ វេទគុំ ភាវិតត្តំ ។

[១៤៨] កុតោនុ ទុក្ខា សមុទាគតាមេតិ កុតោនូតិ សំសយបុច្ឆា វិមតិបុច្ឆា ទ្វេឡ្ហកបុច្ឆា អនេកំសបុច្ឆា ឯវំ នុខោ ន នុខោ កឹ នុខោ កថំ នុខោតិ កុតោនុ ។ ទុក្ខាតិ ជាតិទុក្ខំ ជរាទុក្ខំ ព្យាធិទុក្ខំ មរណទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខំ(១) នេរយិកំ ទុក្ខំ តិរច្ឆានយោនិកំ ទុក្ខំ បិត្តិវិសយិកំ ទុក្ខំ មានុសិកំ ទុក្ខំ គព្ភោក្កន្តិមូលកំ(២) ទុក្ខំ គព្ភេឋិតិមូលកំ ទុក្ខំ គព្ភាវុដ្ឋានមូលកំ ទុក្ខំ ជាតស្សូបនិពន្ធកំ ទុក្ខំ ជាតស្ស បរាធេយ្យកំ ទុក្ខំ អត្តូបក្កមំ ទុក្ខំ បរូបក្កមំ ទុក្ខំ ទុក្ខទុក្ខំ សង្ខារទុក្ខំ វិបរិណាមទុក្ខំ ចក្ខុរោគោ សោតរោគោ ឃានរោគោ ជិវ្ហារោគោ

១ ម. ឯត្ថន្តរេ ព្យសនំ ទុក្ខន្តិ ទិស្សតិ ។ ២ ម. តិរច្ឆានយោនិទុក្ខំ បេត្តិវិសយទុក្ខំ មានុសិកគព្ភេ ឱក្កន្តិ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

ព្រះមានព្រះភាគ ទ្រង់មានខ្លួនបានអប់រំហើយ យ៉ាងនេះ ហេតុនោះ ខ្ញុំព្រះអង្គសម្គាល់ឃើញថា ព្រះអង្គជាអ្នកដល់នូវវេទ ជាអ្នកមានខ្លួនបានអប់រំហើយ ។

[១៤៥] អធិប្បាយពាក្យថា សេចក្តីទុក្ខទាំងនេះ កើតអំពីទីណាហ្ន៎ ត្រង់ពាក្យថា អំពីទីណាហ្ន៎ គឺ ជាសំណួរចំពោះសេចក្តីសង្ស័យ សំណួរចំពោះសេចក្តីងឿងឆ្ងល់ សំណួរចំពោះហេតុដែលបែកជាចំពាមពីរ សំណួរចំពោះហេតុច្រើនយ៉ាង ថាយ៉ាងនេះឬហ្ន៎ មិនមែនទេឬហ្ន៎ ដូចម្តេចហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ ហេតុនោះ (លោកសួរថា) អំពីណាហ្ន៎ ។ ពាក្យថា ទុក្ខ បានដល់ ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខ ទុក្ខក្នុងនរក ទុក្ខក្នុងកំណើតតិរច្ឆាន ទុក្ខក្នុងបិត្តិវិស័យ ទុក្ខជារបស់មនុស្ស ទុក្ខមានការចុះកាន់គភ៌ជាមូល ទុក្ខមានការតាំងនៅក្នុងគភ៌ជាមូល ទុក្ខមានការចេញចាកគភ៌ជាមូល ទុក្ខដែលជាប់ចំពាក់របស់សត្វកើតហើយ ទុក្ខទាក់ទងអំពីអ្នកដទៃ របស់សត្វដែលកើតហើយ ទុក្ខកើតអំពីការព្យាយាមរបស់ខ្លួន ទុក្ខកើតអំពីការព្យាយាម របស់បុគ្គលដទៃ ទុក្ខទុក្ខ[១] សង្ខារទុក្ខ[២] វិបរិណាមទុក្ខ[៣] រោគភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត

---

១ បានដល់ទុក្ខវេទនា ។ ២ ឧបេក្ខាវេទនា ។ ៣ សុខវេទនា ។ អដ្ឋកថានាមសុត្តនិទ្ទេស ។

កាយរោគោ សីសរោគោ កណ្ណរោគោ មុខរោគោ ទន្តរោគោ កាសោ សាសោ បិនាសោ ឌហោ ជរោ កុច្ឆិរោគោ មុច្ឆា បក្ខន្ទិកា សុលា វិសូចិកា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ ទទ្ទុ កណ្ឌុ កច្ឆុ រខសា វិតច្ឆិកា លោហិតំ បិត្តំ មធុមេហោ អំសា បិឡកា ភគន្ទលា បិត្តសមុដ្ឋានា អាពាធា សេម្ហសមុដ្ឋានា អាពាធា វាតសមុដ្ឋានា អាពាធា សន្និបាតិកា អាពាធា ឧតុបរិណាមជា អាពាធា វិសមបរិហារជា អាពាធា ឱបក្កមិកា អាពាធា កម្មវិបាកជា អាពាធា សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ ឌំសមកសវាតាតបសិរឹសបសម្ផស្សទុក្ខំ មាតុមរណំ ទុក្ខំ បិតុមរណំ ទុក្ខំ ភាតុមរណំ ទុក្ខំ ភគិនិមរណំ ទុក្ខំ បុត្តមរណំ ទុក្ខំ ធីតុមរណំ ទុក្ខំ ញាតិព្យសនំ ទុក្ខំ[១] ភោគព្យសនំ ទុក្ខំ សីលព្យសនំ ទុក្ខំ ទិដ្ឋិព្យសនំ ទុក្ខំ ។

១ ម. ឯត្ថន្តរេ រោគព្យសនំ ទុក្ខន្តិ អត្ថិ ។

រោគកាយ រោគក្បាល រោគត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត រោគប្រមុះ រោគក្ដៅក្រហាយ រោគស្គាំងស្គម រោគផ្ទៃ រោគខ្យល់ចាប់ វិលមុខ រោគធ្លាក់ឈាម រោគចុកសៀត រោគចុះរាក ឃ្លង់ បូស ស្រែង រីងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគកើតក្នុងទី ដែលខ្វារ ដោយក្រចក ឃ្លង់ដែក ប្រមាត់ក្រហម ប្រមេះទឹកបាយ ឫសដូងដុះ រលកកែវ ឫសដូងបាត អាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីសន្និបាត (គឺការកម្រើកប្រមាត់ ស្លេស្មនិងខ្យល់ប្រជុំគ្នា) អាពាធកើតអំពីការប្រែប្រួលរដូវ អាពាធកើតអំពីការផ្លាស់ប្ដូរឥរិយាបថមិនស្មើ អាពាធកើតអំពីការព្យាយាមរបស់អ្នកឯទៀត អាពាធកើតអំពីផលកម្ម ត្រជាក់ ក្ដៅ សម្រេក គម្លាន ឧច្ចារៈ បស្សាវៈ ទុក្ខព្រោះសម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃ និងពស់ ទុក្ខគឺមរណៈមាតា ទុក្ខគឺមរណៈបិតា ទុក្ខគឺមរណៈបងប្អូនប្រុស ទុក្ខគឺមរណៈបងប្អូនស្រី ទុក្ខគឺមរណៈបុត្ត ទុក្ខគឺមរណៈធីតា ទុក្ខគឺការវិនាសញាតិ ទុក្ខគឺការវិនាសភោគៈ ទុក្ខគឺការវិនាសសីល ទុក្ខគឺការវិនាសទិដ្ឋិ ។

១២១

## មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

យេសំ ធម្មានំ អាទិតោ សមុទាគមនំ បញ្ញាយតិ អត្ថង្គមតោ និរោធោ បញ្ញាយតិ ។ កម្មសន្និស្សិតោ វិបាកោ វិបាកសន្និស្សិតំ កម្មំ នាមសន្និស្សិតំ រូបំ រូបសន្និស្សិតំ នាមំ ជាតិយា អនុគតំ ជរាយ អនុសដំ ព្យាធិនា អភិភូតំ មរណេន អព្ភាហតំ ទុក្ខេ បតិដ្ឋិតំ អតាណំ អលេណំ អសរណំ អសរណីភូតំ ឥមេ វុច្ចន្តិ ទុក្ខា ។ ឥមេ ទុក្ខា កុតោ សមុទាគតា កុតោ ជាតា កុតោ សញ្ជាតា កុតោ និព្វត្តា កុតោ អភិនិព្វត្តា កុតោ បាតុភូតា កិំនិទានា កឹសមុទយា កឹបភវាតិ ឥមេសំ ទុក្ខានំ មូលំ បុច្ឆតិ ហេតុំ បុច្ឆតិ និទានំ បុច្ឆតិ សម្ភវំ បុច្ឆតិ បភវំ បុច្ឆតិ សមុដ្ឋានំ បុច្ឆតិ អាហារំ បុច្ឆតិ អារម្មណំ បុច្ឆតិ បច្ចយំ បុច្ឆតិ សមុទយំ បុច្ឆតិ យាចតិ អជ្ឈេសតិ បសាទេតីតិ កុតោនុ ទុក្ខា សមុទាគតាមេ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

ការកើតឡើង អំពីខាងដើមនៃធម៌ទាំងឡាយណា ប្រាកដ ការរលត់ដោយការវិនាស (នៃធម៌ទាំងនោះ) ក៏ប្រាកដ ។ ផលអាស្រ័យកម្ម កម្មអាស្រ័យផល រូបអាស្រ័យនាម នាមអាស្រ័យរូប ជារបស់ត្រូវជាតិជាប់តាម ត្រូវជរារួបរឹត ត្រូវព្យាធិញាំញី ត្រូវមរណៈគ្របសង្កត់ តាំងនៅក្នុងទុក្ខ ឥតមានទីពំនាក់ ឥតមានទីជ្រក ឥតមានទីពឹង ឥតមានទីពំនឹង ធម៌ទាំងនេះ លោកហៅថា ទុក្ខ ។ ទុក្ខទាំងនេះ ផ្សំផ្គុំមកអំពីណា កើតមកអំពីណា កើតព្រមអំពីណា លូតលាស់អំពីណា ដុះដាលអំពីណា កើតប្រាកដអំពីណា មានអ្វីជានិទាន មានអ្វីជាទីប្រជុំកើត មានអ្វីជាដែនផ្តើមកើត (មេត្តគូមាណព) សួរឫសគល់ សួរហេតុ សួរនិទាន សួរកំណើត សួរហេតុជាដែនផ្តើមកើត សួរសមុដ្ឋាន សួរអាហារ សួរអារម្មណ៍ សួរបច្ច័យ សួរ សូម អារាធនា ជ្រះថ្លា ចំពោះទីប្រជុំកើត នៃទុក្ខទាំងនេះ ហេតុនោះ (លោកសួរថា) សេចក្តីទុក្ខទាំងនេះ កើតអំពីទីណាហ្ន៎ ។

[១៤៦] យេកេចិ លោកស្មឹ អនេករូបាតិ យេ-
កេចីតិ សព្វេន សព្វំ សព្វថា សព្វំ[១] អសេសំ
និស្សេសំ បរិយាទាយវចនមេតំ យេកេចីតិ ។ លោ-
កស្មិន្តិ អបាយលោកេ មនុស្សលោកេ ទេវលោកេ
ខន្ធលោកេ ធាតុលោកេ អាយតនលោកេ ។ អនេ-
ករូបាតិ អនេកវិធា នានប្បការា ទុក្ខាតិ យេកេចិ
លោកស្មឹ អនេករូបា ។ តេនាហ សោ ព្រាហ្មណោ

បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ

(ឥច្ចាយស្មា មេត្តគូ)

មញ្ញាមិ តំ វេទគុំ ភាវិតត្តំ

កុតោ នុ ទុក្ខា សមុទាគតាមេ

យេកេចិ លោកស្មឹ អនេករូបាតិ ។

[១៤៧] ទុក្ខស្ស វេ មំ បភវំ អបុច្ឆសិ (មេត្តគូតិ ភគវា)

តន្តេ បវក្ខាមិ យថា បជានំ

ឧបធិ និទានា បភវន្តិ ទុក្ខា

យេកេចិ លោកស្មឹ អនេករូបា ។

---

១ ម. សព្វំ សព្វាវន្តំ ។

[១៤៦] ពាក្យថា សេចក្តីទុក្ខទាំងឡាយណាមួយជាច្រើនប្រការក្នុងលោក ត្រង់ពាក្យថាឯណាមួយ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនមានសល់ ឥតសល់ ពាក្យថា ឯណាមួយ នុ៎ះជាពាក្យរួម ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា ជាច្រើនប្រការ គឺទុក្ខទាំងឡាយផ្សេងៗ ជាច្រើន មានប្រការផ្សេងៗ ហេតុនោះ (លោកសួរថា) ទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការ ក្នុងលោក ។ ហេតុនោះ ព្រាហ្មណ៍នោះសួរថា

(មេត្តគូមានអាយុ ទូលសួរដូច្នេះថា) បពិត្រព្រះមានព្រះភាគ
ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់ នូវ
សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ឲ្យទាន ខ្ញុំព្រះអង្គសម្គាល់
ឃើញថា ព្រះអង្គជាអ្នកដល់នូវវេទ ជាអ្នកមានខ្លួនបានអប់រំ
ហើយ សេចក្តីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការ
ក្នុងលោក សេចក្តីទុក្ខទាំងនេះ កើតមកអំពីទីណាហ្ន៎ ។

[១៤៧] (ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ) អ្នកសួរហេតុជាដែន
ផ្តើមកើតនៃសេចក្តីទុក្ខ នឹងតថាគត តថាគតដឹងយ៉ាងណា នឹង
ប្រាប់ហេតុជាដែនផ្តើមកើតនៃសេចក្តីទុក្ខនោះ ដល់អ្នក យ៉ាង
នោះ សេចក្តីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការ ក្នុងលោក
សេចក្តីទុក្ខ (ទាំងនោះ) ផ្តើមកើតឡើងព្រោះឧបធិជានិទាន ។

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៤៨] ទុក្ខស្ស វេ មំ បភវំ អបុច្ឆសីតិ ទុក្ខស្សាតិ ជាតិទុក្ខស្ស ជរាទុក្ខស្ស ព្យាធិទុក្ខស្ស មរណទុ-ក្ខស្ស សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខស្សាតិ ទុក្ខស្ស ។ វេ មំ បភវំ អបុច្ឆសីតិ មំ ទុក្ខស្ស មូលំ បុច្ឆសិ ហេតុំ បុច្ឆសិ និទានំ បុច្ឆសិ សម្ភវំ បុច្ឆសិ បភវំ បុច្ឆសិ សមុដ្ឋានំ បុច្ឆសិ អា-ហារំ បុច្ឆសិ អារម្មណំ បុច្ឆសិ បច្ចយំ បុច្ឆសិ សមុទយំ បុច្ឆសិ យាចសិ អជ្ឈេសសិ បសាទេសីតិ ទុក្ខស្ស វេ មំ បភវំ អបុច្ឆសិ ។ មេត្តគូតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវា-ធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ មេត្តគូតិ ភគវា ។

[១៤៩] តន្តេ បវក្ខាមិ យថា បជានន្តិ តន្តេ បវក្ខាមីតិ តំ តេ ទុក្ខស្ស មូលំ បវក្ខាមិ

មេត្តគូមាណវកបញ្ហានិទ្ទេស

[១៤៨] អធិប្បាយពាក្យថា អ្នកសួរហេតុជាដែនផ្ដើមកើតនៃសេចក្ដីទុក្ខនឹងតថាគត ត្រង់ពាក្យថា នៃសេចក្ដីទុក្ខ គឺ នៃជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) នៃសេចក្ដីទុក្ខ ។ ពាក្យថា អ្នកសួរហេតុជាដែនផ្ដើមកើត (នៃសេចក្ដីទុក្ខ) នឹងតថាគត គឺអ្នកសួរឫសគល់នៃទុក្ខ នឹងតថាគត សួរហេតុ សួរនិទាន សួរកំណើត សួរការផ្ដើមកើត សួរសមុដ្ឋាន សួរអាហារ សួរអារម្មណ៍ សួរបច្ច័យនៃទុក្ខ សួរ សូម អារាធនា ជ្រះថ្លា ចំពោះហេតុជាទីប្រជុំកើត ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកសួរហេតុជាដែនផ្ដើមកើតនៃសេចក្ដីទុក្ខនឹងតថាគត ។ ពាក្យថា មេត្តគូ គឺព្រះមានព្រះភាគទ្រង់ហៅព្រាហ្មណ៍នោះតាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ ។

[១៤៩] អធិប្បាយពាក្យថា តថាគតដឹងយ៉ាងណា នឹងប្រាប់ហេតុជាដែនផ្ដើមកើតនោះ ដល់អ្នក យ៉ាងនោះ ត្រង់ពាក្យថា តថាគតនឹងប្រាប់ហេតុជាដែនផ្ដើមកើតនុ៎ះ គឺ តថាគតនឹងប្រាប់ឫសគល់ នៃទុក្ខនោះ

ហេតុំ បវក្ខាមិ និទានំ បវក្ខាមិ សម្ភវំ បវក្ខាមិ បភវំ បវក្ខាមិ សមុដ្ឋានំ បវក្ខាមិ អាហារំ បវក្ខាមិ អារម្មណំ បវក្ខាមិ បច្ចយំ បវក្ខាមិ សមុទយំ បវក្ខាមិ អាចិក្ខិស្សាមិ ទេសេស្សាមិ បញ្ញបេស្សាមិ បដ្ឋបេស្សាមិ វិវរិស្សាមិ វិភជិស្សាមិ ឧត្តានីករិស្សាមិ បកាសេស្សាមីតិ តន្តេ បវក្ខាមិ ។ យថា បជានន្តិ យថា បជានន្តោ អាជានន្តោ វិជានន្តោ បដិវិជានន្តោ បដិវិជ្ឈន្តោ ន ឥតិហិតិហំ ន ឥតិកិរាយ ន បរម្បរាយ ន បិដកសម្បទាយ ន តក្កហេតុ ន នយហេតុ ន អាការបរិវិតក្កេន ន ទិដ្ឋិនិជ្ឈានក្ខន្តិយា សាមំ សយមភិញ្ញាតំ អត្តបច្ចក្ខំ ធម្មំ កថយិស្សាមីតិ[១] យថា បជានំ ។

---

១ ម. ឯត្តន្តរេ តំ បវក្ខាមីតិ ទិស្សតិ ។

ដល់អ្នក នឹងប្រាប់ហេតុ នឹងប្រាប់និទាន នឹងប្រាប់កំណើត នឹងប្រាប់ហេតុជាដែនផ្តើមកើត នឹងប្រាប់សមុដ្ឋាន នឹងប្រាប់អាហារ នឹងប្រាប់អារម្មណ៍ នឹងប្រាប់បច្ច័យ គឺនឹងប្រាប់ នឹងបង្ហាញ នឹងសម្តែង នឹងបញ្ញត្ត នឹងតាំងទុក នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់ នឹងប្រកាសនូវហេតុជាទីប្រជុំកើត ហេតុនោះ (ទ្រង់ត្រាស់ថា) នឹងប្រាប់ហេតុ ជាដែនផ្តើមកើតនោះ ដល់អ្នក ។ ពាក្យថា តថាគតដឹងយ៉ាងណា គឺតថាគតដឹង ដឹងទូទៅ ដឹងច្បាស់ ដឹងចំពោះ ចាក់ធ្លុះ ដោយប្រការយ៉ាងណា គឺមិនមែនដោយអាងថាដូច្នេះ ៗ មិនមែនដោយឮថាដូច្នេះ មិនមែនដោយតៗ គ្នា មិនមែនដោយការផ្សំតាមតម្រា មិនមែនដោយហេតុនៃសេចក្តីត្រិះរិះ មិនមែនដោយហេតុនៃការយល់ មិនមែនដោយសេចក្តីរិះគិតតាមអាការ មិនមែនតាមសេចក្តីយល់ឃើញ ការពិនិត្យ និងសេចក្តីចូលចិត្តទេ តថាគតសម្តែងធម៌ដែលតថាគតត្រាស់ដឹងឯង ដោយខ្លួនឯង ជាធម៌ជាក់ច្បាស់ចំពោះខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតដឹង យ៉ាងណា ។

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៨០] ឧបធិនិទានា បភវន្តិ ទុក្ខាតិ ឧបធីតិ ទស ឧបធី តណ្ហូបធិ ទិដ្ឋូបធិ កិលេសូបធិ កម្មូបធិ ទុច្ចរិតូបធិ អាហារូបធិ បដិឃូបធិ ចតស្សោ ឧបាទិន្ន-ធាតុយោ ឧបធី ឆ អជ្ឈត្តិកានិ អាយតនានិ ឧបធី ឆ វិញ្ញាណកាយា ឧបធី សព្វំបិ ទុក្ខំ ទុក្ខដ្ឋេន ឧបធិ ឥមេ វុច្ចន្តិ ទស ឧបធី ។ ទុក្ខាតិ ជាតិទុក្ខំ ជរាទុក្ខំ ព្យាធិទុក្ខំ មរណទុក្ខំ សោកបរិទេវទុក្ខ-ទោមនស្សុបាយាសទុក្ខំ ។ បេ ។ ព្យាធិនា អភិភូតំ មរណេន អព្ភាហតំ ទុក្ខេ បតិដ្ឋិតំ អតាណំ អលេណំ អសរណំ អសរណីភូតំ ឥមេ វុច្ចន្តិ ទុក្ខា ។ ឥមេ ទុក្ខា ឧបធិនិទានា ឧបធិហេតុកា ឧបធិប្បច្ចយា ឧបធិការណា ហោន្តិ សម្ភវន្តិ បភវន្តិ ជាយន្តិ សញ្ជាយន្តិ និព្វត្តន្តិ បាតុភវន្តីតិ ឧបធិនិទានា បភវន្តិ ទុក្ខា ។

[១៨១] យេកេចិ លោកស្មឹ អនេករូបាតិ យេកេចីតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ យេកេចីតិ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

[១៥០] ពាក្យថា សេចក្ដីទុក្ខ (ទាំងនោះ) ផ្ដើមកើតឡើងព្រោះឧបធិជានិទាន ត្រង់ពាក្យថា ឧបធិ បានដល់ឧបធិ ១០ គឺតណ្ហូបធិ ទិដ្ឋូបធិ កិលេសូបធិ កម្មូបធិ ទុច្ចរិតូបធិ អាហារូបធិ បដិឃូបធិ ឧបាទិន្នធាតុ ៤ ជាឧបធិ អាយតនៈខាងក្នុង ៦ ជាឧបធិ វិញ្ញាណកាយ ៦ ជាឧបធិ សូម្បីទុក្ខទាំងអស់ ឈ្មោះថា ឧបធិ ដោយសេចក្ដីថាជាទុក្ខ ទាំងនេះ លោកហៅថា ឧបធិ ១០ ។ ពាក្យថា ទុក្ខ បានដល់ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខ ។ បេ ។ ការត្រូវព្យាធិគ្របសង្កត់ ការត្រូវមរណៈកម្ចាត់បង់ ការតាំងនៅក្នុងទុក្ខ ការឥតទីពំនាក់ ការឥតមានទីជ្រកកោន ការឥតទីពឹង ការឥតទីពំនឹង ទាំងនេះ ហៅថា ទុក្ខ ។ ទុក្ខទាំងនេះ មាន កើតមាន ផ្ដើមកើត កើតឡើង លូតលាស់ ដុះដាល ព្រោះឧបធិជានិទាន ព្រោះឧបធិជាហេតុ ព្រោះឧបធិជាបច្ច័យ ព្រោះឧបធិជាការណ៍ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្ដីទុក្ខ (ទាំងនោះ) ផ្ដើមកើតឡើង ព្រោះឧបធិជានិទាន ។

[១៥១] ពាក្យថា សេចក្ដីទុក្ខទាំងឡាយណាមួយជាច្រើនប្រការក្នុងលោក ត្រង់ពាក្យថា ណាមួយ គឺ គ្រប់ទាំងអស់ សព្វទាំងអស់ មិនមានសល់ ឥតសល់ ពាក្យថា ណាមួយ នុ៎ះជាពាក្យប្រមូល ។

លោកស្មិន្តិ អបាយលោកេ មនុស្សលោកេ ទេវ-លោកេ ខន្ធលោកេ ធាតុលោកេ អាយតន-លោកេ ។ អនេករូបាតិ អនេកវិធា នានប្បការា ទុក្ខាតិ យេកេចិ លោកស្មឹ អនេករូបា ។ តេនាហ ភគវា

ទុក្ខស្ស វេ មំ បភវំ អបុច្ឆសិ

(មេត្តគូតិ ភគវា)

តន្តេ បវក្ខាមិ យថា បជានំ

ឧបធិនិទានា បភវន្តិ ទុក្ខា

យេកេចិ លោកស្មឹ អនេករូបាតិ ។

[១៨២] យេ វេ អវិទ្វា ឧបធឹ ករោតិ

បុនប្បុនំ ទុក្ខមុបេតិ មន្ទោ

តស្មា បជានំ ឧបធឹ ន កយិរា

ទុក្ខស្ស ជាតិប្បភវានុបស្សី ។

ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក មនុស្សលោក ទេវ-លោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា ជាច្រើនប្រការ គឺ ទុក្ខទាំងឡាយផ្សេង ៗ ជាច្រើន មានប្រការផ្សេងៗ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្ដីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការ ក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ) អ្នកសួរហេតុជាដែនផ្ដើមកើត នៃសេចក្ដីទុក្ខ នឹងតថាគត តថាគតដឹងយ៉ាងណា នឹងប្រាប់ហេតុ ជាដែនផ្ដើមកើត នៃសេចក្ដីទុក្ខនោះ ដល់អ្នក យ៉ាងនោះ សេចក្ដីទុក្ខទាំងឡាយណាមួយជាច្រើនប្រការ ក្នុងលោក សេចក្ដីទុក្ខ (ទាំងនោះ) ផ្ដើមកើតឡើង ព្រោះឧបធិជានិទាន ។

[១៥២] បុគ្គលណា មិនចេះ តែងធ្វើឧបធិឲ្យកើតឡើង បុគ្គលល្ងង់ខ្លៅនោះ រមែងបានទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ ជាអ្នកពិចារណាឃើញ នូវជាតិជាដែនផ្ដើមកើតនៃទុក្ខ មិនគប្បីធ្វើនូវឧបធិឡើយ ។

១២៧

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៨៣] យោ វេ អវិទ្វា ឧបធឹ ករោតីតិ យោតិ យោ យាទិសោ យថាយុត្តោ យថាវិហិតោ យថាបការោ យំឋានប្បត្តោ យំធម្មសមន្នាគតោ ខត្តិយោ វា ព្រាហ្មណោ វា វេស្សោ វា សុទ្ទោ វា គហដ្ឋោ វា បព្វជិតោ វា ទេវោ វា មនុស្សោ វា ។ អវិទ្វាតិ អវិទ្វា អវិជ្ជាគតោ អញ្ញាណី អវិភាវី ទុប្បញ្ញោ ។ ឧបធឹ ករោតីតិ តណ្ហូបធឹ ករោតិ ទិដ្ឋូបធឹ ករោតិ កិលេសូបធឹ ករោតិ កម្មូបធឹ ករោតិ ទុច្ចរិតូបធឹ ករោតិ អាហារូបធឹ ករោតិ បដិឃូបធឹ ករោតិ ចតស្សោ ឧបាទិន្នធាតុយោ ឧបធី ករោតិ ឆ អជ្ឈត្តិកានិ អាយតនានិ ឧបធី ករោតិ ឆ វិញ្ញាណកាយេ ឧបធី ករោតិ ជនេតិ សញ្ជនេតិ និព្វត្តេតីតិ អវិទ្វា ឧបធឹ ករោតិ ។

[១៨៤] បុនប្បុនំ ទុក្ខមុបេតិ មន្ទោតិ បុនប្បុនំ ទុក្ខមុបេតីតិ បុនប្បុនំ ជាតិទុក្ខំ ជរាទុក្ខំ ព្យាធិទុក្ខំ មរណទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខំ ឯតិ ឧបេតិ ឧបគច្ឆតិ គណ្ហាតិ បរាមសតិ អភិនិវិសតីតិ បុនប្បុនំ ទុក្ខមុបេតិ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

[១៥៣] ពាក្យថា បុគ្គលណា មិនចេះ តែងធ្វើឧបធិឲ្យកើតឡើង ត្រង់ពាក្យថា ណា គឺ ឯណា បែបណា ប្រកបយ៉ាងណា មានបែបផែនយ៉ាងណា មានប្រការយ៉ាងណា ដល់នូវឋានៈយ៉ាងណា ប្រកបដោយធម៌ណា ទោះជាក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សុទ្ទៈក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ។ ពាក្យថា មិនចេះ គឺបុគ្គលជាអ្នកមិនចេះ តាំងនៅក្នុងអវិជ្ជា ជាអ្នកគ្មានញាណ មិនឈ្វេងយល់ អាប់ឥតប្រាជ្ញា ។ ពាក្យថា ធ្វើឧបធិ គឺធ្វើតណ្ហូបធិ ធ្វើទិដ្ឋូបធិ ធ្វើកិលេសូបធិ ធ្វើកម្មូបធិ ធ្វើទុច្ចរិតូបធិ ធ្វើអាហារូបធិ ធ្វើបដិឃូបធិ ធ្វើឧបធិ គឺឧបាទិន្នធាតុ ៤ ធ្វើឧបធិ គឺអាយតនៈខាងក្នុង ៦ ធ្វើ ឲ្យកើត ឲ្យកើតព្រម បង្កើតនូវឧបធិ គឺពួកវិញ្ញាណ ៦ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលណា មិនចេះ តែងធ្វើឧបធិឲ្យកើតឡើង ។

[១៥៤] ពាក្យថា បុគ្គល ល្ងង់ខ្លៅ (នោះ) រមែងបានទុក្ខរឿយ ៗ ត្រង់ពាក្យថា រមែងបានទុក្ខរឿយៗ គឺ ដល់ ចូលដល់ ចូលទៅដល់ កាន់យក ស្ទាបអង្អែល ជាប់ចំពាក់ ចំពោះជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខរឿយៗ ហេតុនោះ (ទ្រង់ត្រាស់ថា) រមែងបានទុក្ខរឿយ ៗ ។

មគ្គោតិ មគ្គោ ម្ឡោ អវិជ្ជា អវិជ្ជាគតោ អញ្ញាណី អវិភាវី ទុប្បញ្ញោតិ ពុនប្បុនំ ទុក្ខមុបេតិ មគ្គោ ។

[១៨៨] តស្មា បជានំ ឧបធឹ ន កយិរាតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ឯតំ អាទីនវំ សម្បស្សមានោ ឧបធីសូតិ តស្មា ។ បជានន្តិ បជានន្តោ អាជានន្តោ វិជានន្តោ បដិវិជា-នន្តោ បដិវិជ្ឈន្តោ សព្វេ សង្ខារា អនិច្ចាតិ បជានន្តោ អាជានន្តោ វិជានន្តោ បដិវិជានន្តោ បដិវិជ្ឈន្តោ សព្វេ សង្ខារា ទុក្ខាតិ សព្វេ ធម្មា អនត្តាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ បជានន្តោ អាជានន្តោ វិជានន្តោ បដិវិជានន្តោ បដិវិជ្ឈន្តោ ។

ពាក្យថា ល្ងង់ខ្លៅ គឺជាអ្នកល្ងង់ វង្វេង មិនចេះ តាំងនៅក្នុងអវិជ្ជា ជាអ្នកគ្មានញាណ មិនឈ្វេងយល់ ឥតប្រាជ្ញា ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលល្ងង់ខ្លៅ (នោះ) រមែងបានទុក្ខរឿយៗ ។

[១៥៥] អធិប្បាយពាក្យថា ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ មិនគប្បីធ្វើនូវឧបធិឡើយ ត្រង់ពាក្យថា ព្រោះហេតុនោះ គឺ ព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ បុគ្គលកាលឃើញច្បាស់នូវទោសនុ៎ះ ក្នុងឧបធិទាំង-ឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ ។ ពាក្យថា កាលដឹងច្បាស់ គឺ កាលដឹងច្បាស់ កាលដឹងទូទៅ កាលដឹងវិសេស កាលដឹងចំពោះ កាលចាក់ធ្លុះថា សង្ខារទាំងពួង មិនទៀង កាលដឹងច្បាស់ កាលដឹងទូទៅ កាលដឹងវិសេស កាលដឹងចំពោះ កាលចាក់ធ្លុះថា សង្ខារទាំងពួង ជាទុក្ខ ថា ធម៌ទាំងពួង ជាអនត្តា ។ បេ ។ កាលដឹងច្បាស់ កាលដឹងទូទៅ កាលដឹងវិសេស កាលដឹងចំពោះ កាលចាក់ធ្លុះថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។

ឧបធី ន កយិរាតិ តណ្ហូបធី ន ករេយ្យ ទិដ្ឋូបធី ន ករេយ្យ កិលេសូបធី ន ករេយ្យ កម្មូបធី ន ករេយ្យ ទុច្ចរិតូបធី ន ករេយ្យ អាហារូបធី ន ករេយ្យ បដិឃូបធី ន ករេយ្យ ចតស្សោ ឧចាទិន្នធាតុយោ ឧបធី ន ករេយ្យ ឆ អជ្ឈត្តិកានិ អាយតនានិ ឧបធី ន ករេយ្យ ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យាតិ តស្មា បជានំ ឧបធី ន កយិរា ។

[១៨៦] ទុក្ខស្សាតិ ជាតិទុក្ខស្ស ជរាទុក្ខស្ស ព្យាធិទុក្ខស្ស មរណទុក្ខស្ស សោកបរិទេវទុក្ខទោមនស្សុចាយាសទុក្ខស្ស បភវានុបស្សី មូលានុបស្សី ហេតានុបស្សី និទានានុបស្សី សម្ភវានុបស្សី សមុដ្ឋានានុបស្សី អាហារានុបស្សី អារម្មណានុបស្សី បច្ចយានុបស្សី សមុទយានុបស្សី ។ អនុបស្សនា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។

ពាក្យថា មិនគប្បីធ្វើឧបធិឡើយ គឺមិនគប្បីធ្វើតណ្ហូបធិ មិនគប្បីធ្វើទិដ្ឋូបធិ មិនគប្បីធ្វើកិលេសូបធិ មិនគប្បីធ្វើកម្មូបធិ មិនគប្បីធ្វើទុច្ចរិតូបធិ មិនគប្បីធ្វើអាហារូបធិ មិនគប្បីធ្វើបដិឃូបធិ មិនគប្បីធ្វើឧបធិ គឺឧបាទិន្នធាតុ ៤ មិនគប្បីធ្វើ មិនគប្បីឲ្យកើត មិនគប្បីឲ្យកើតព្រម មិនគប្បីបង្កើតនូវឧបធិ គឺអាយតនៈខាងក្នុង ៦ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ មិនគប្បីធ្វើឧបធិឡើយ ។

[១៥៦] ពាក្យថា នៃទុក្ខ សេចក្តីថា បុគ្គលពិចារណាឃើញហេតុជាដែនផ្តើមកើត ពិចារណាឃើញឫសគល់ ពិចារណាឃើញហេតុ ពិចារណាឃើញនិទាន ពិចារណាឃើញកំណើត ពិចារណាឃើញសមុដ្ឋាន ពិចារណាឃើញអាហារ ពិចារណាឃើញអារម្មណ៍ ពិចារណាឃើញបច្ច័យ ពិចារណាឃើញទីប្រជុំកើតឡើង នៃជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខ ។ បញ្ញា លោកហៅថា ការពិចារណាឃើញ បានដល់ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ។

ឥមាយ អនុបស្សនាយ បញ្ញាយ ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ សោ វុច្ចតិ អនុបស្សីតិ ទុក្ខស្ស ជាតិប្បភវានុបស្សី ។ តេនាហ ភគវា

យោ វេ អវិទ្វា ឧបធឹ ករោតិ
បុនប្បុនំ ទុក្ខមុបេតិ មន្ទោ
តស្មា បជានំ ឧបធឹ ន កយិរា
ទុក្ខស្ស ជាតិប្បភវានុបស្សីតិ ។

[១៤៧] យន្តំ អបុច្ឆិម្ហ អកិត្តយី នោ
អញ្ញំ តំ បុច្ឆាម តទិង្ឃ ព្រូហិ
កថំ នុ ធីរា វិតរន្តិ ឱឃំ
ជាតិជ្ជរំ សោកបរិទ្ទវញ្ច
តម្មេ មុនី សាធុ វិយាករោហិ
តថា ហិ តេ វិទិតោ ឯស ធម្មោ ។

បុគ្គលជាអ្នកអែបនែប មូលមិត្រ ជិតដិត កៀកកើយ ផ្តេកផ្តួល កើតឡើងជាមួយ ប្រកបដោយការពិចារណាឃើញ គឺបញ្ញានោះ បុគ្គលនោះ លោកហៅថា អ្នកពិចារណាឃើញ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ជាអ្នកពិចារណាឃើញនូវជាតិ ជាដែនផ្តើមកើតនៃទុក្ខ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុគ្គលមិនចេះ តែងធ្វើនូវឧបធិឲ្យកើតឡើង បុគ្គលល្ងង់ខ្លៅនោះ រមែងបានទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ ជាអ្នកពិចារណាឃើញ នូវជាតិជាដែនផ្តើមកើតនៃទុក្ខ មិនគប្បីធ្វើនូវឧបធិឡើយ ។

[១៥៧] (មេត្តគូទូលថា) យើងខ្ញុំ បានទូលសួរសេចក្តីណា ព្រះអង្គបានត្រាស់ប្រាប់សេចក្តីនោះ ដល់យើងខ្ញុំ យើងខ្ញុំសូមសួរសេចក្តីឯទៀត ចំពោះព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ អ្នកប្រាជ្ញទាំងឡាយ ឆ្លងឱឃៈផង ជាតិជរាផង សោកៈនិងបរិទេវៈផង ដោយប្រការដូចម្តេចហ្ន៎ សូមព្រះអង្គជាមុនិដោះស្រាយនូវឧបាយជាគ្រឿងឆ្លងនោះ ដល់យើងខ្ញុំ ព្រោះព្រះអង្គជ្រាបច្បាស់ធម៌នោះហើយ ។

១៣១

## មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៩៨] យន្តំ អបុច្ឆិម្ហ អកិត្តយី នោតិ យំ តំ អបុច្ឆិម្ហ អយាចិម្ហ អជ្ឈេសិម្ហ បសាទិម្ហ ។ អកិត្ត-យី នោតិ នោ អកិត្តិ តំ អាចិក្ខិ តំ ទេសេសិ តំ បញ្ញបិ តំ បដ្ឋបិ តំ វិវរិ តំ វិភជិ តំ ឧត្តា-និមកាសិ តំ បកាសីតិ យន្តំ អបុច្ឆិម្ហ អកិត្តយី នោ ។

[១៩៩] អញ្ញំ តំ បុច្ឆាម តទិង្ឃ ព្រូហិ កថំ នុ ធីរា វិតរន្តិ ឱឃំ ជាតិជ្ជរំ សោកបរិទ្ទវញ្ចាតិ កថំ នូតិ សំសយបុច្ឆា វិមតិបុច្ឆា ទ្វេឡ្ហកបុច្ឆា អនេកំ-សបុច្ឆា ឯវំ នុ ខោ ន នុ ខោ កឹ នុ ខោ កថំ នុ ខោតិ កថំ នុ ។ ធីរាតិ ធីរា បណ្ឌិតា បញ្ញ-វន្តោ ពុទ្ធិមន្តោ ញាណិនោ វិភាវិនោ មេធាវិនោ ។

មេត្តគូមាណវកបញ្ហានិទ្ទេស

[១៥៨] ពាក្យថា យើងខ្ញុំបានទូលសួរនូវសេចក្ដីណា ព្រះអង្គបានត្រាស់ប្រាប់សេចក្ដីនោះដល់យើងខ្ញុំ គឺយើងខ្ញុំបានសួរ បានសូម បានអារាធនា បានជ្រះថ្លាចំពោះសេចក្ដីណា ។ ពាក្យថា ព្រះអង្គបានត្រាស់ប្រាប់សេចក្ដីនោះ ដល់យើងខ្ញុំ គឺ ព្រះអង្គបានសម្ដែងប្រាប់សេចក្ដីនោះ ពន្យល់សេចក្ដីនោះ បញ្ញត្តសេចក្ដីនោះ ផ្ដួចផ្ដើមនូវសេចក្ដីនោះ បើកសេចក្ដីនោះ ចែកសេចក្ដីនោះ ធ្វើឲ្យរាក់សេចក្ដីនោះ ប្រកាសសេចក្ដីនោះ ដល់យើងខ្ញុំ ហេតុនោះ (លោកសួរថា) យើងខ្ញុំបានទូលសួរនូវសេចក្ដីណា ព្រះអង្គបានត្រាស់ប្រាប់សេចក្ដីនោះ ដល់យើងខ្ញុំ ។

[១៥៩] អធិប្បាយពាក្យថា យើងខ្ញុំសូមសួរសេចក្ដីឯទៀតចំពោះព្រះអង្គ សូមព្រះអង្គសម្ដែងសេចក្ដីនោះ អ្នកប្រាជ្ញទាំងឡាយ ឆ្លងឱឃៈផងជាតិជរាផង សោកៈនិងបរិទេវៈផង ដោយប្រការដូចម្ដេចហ្ន៎ ត្រង់ពាក្យថា ដោយប្រការដូចម្ដេចហ្ន៎ គឺជាសំណួរចំពោះសេចក្ដីសង្ស័យ សំណួរចំពោះសេចក្ដីងឿងឆ្ងល់ សំណួរចំពោះផ្លូវបែកជាចំពាមពីរ សំណួរចំពោះហេតុច្រើនយ៉ាង ថា យ៉ាងនេះឬហ្ន៎ មិនមែនទេឬហ្ន៎ ដូចម្ដេចហ្ន៎ ដោយប្រការដូចម្ដេចហ្ន៎ ហេតុនោះ (លោកសួរថា) ដោយប្រការដូចម្ដេចហ្ន៎ ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយ គឺអ្នកប្រាជ្ញ បណ្ឌិត អ្នកមានប្រាជ្ញា អ្នកមានយោបល់ អ្នកមានញាណ អ្នកមានការឈ្វេងយល់ អ្នកមានប្រាជ្ញាផ្ទុះផ្លាយ ។

ឱឃន្តិ កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ ។ ជាតីតិ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ ។ ជរាតិ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ ។ សោកោតិ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិសោកោ អន្តោឌាហោ អន្តោបរិឌាហោ ចេតសោ បរិជ្ឈាយនា ទោមនស្សំ សោកសល្លំ ។

ពាក្យថា ឱឃៈ បានដល់ ឱឃៈគឺកាម ឱឃៈគឺភព ឱឃៈគឺទិដ្ឋិ ឱឃៈគឺអវិជ្ជា ។ ពាក្យថា ជាតិ បានដល់កំណើត ការកើតព្រម ការចុះកាន់គភ៌ ការផ្តួចផ្តើមឡើង ការកើតឡើងចំពោះ ការប្រាកដឡើងនៃខន្ធ ការបានចំពោះនូវអាយតនៈ នៃពួកសត្វនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ។ ពាក្យថា ជរា បានដល់ ការចាស់ ការគ្រាំគ្រា ការរង្គោះរង្គេញ ការស្កូវសក់ ការជ្រួញជ្រីវស្បែក ការរួញថយអាយុ ការចាស់ទុំនៃឥន្ទ្រិយ របស់ពួកសត្វនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ។ ពាក្យថា សោក គឺ ការសោកស្តាយ អាការជាទីសោកស្តាយ ភាពនៃការសោកស្តាយ ការស្ងួតខាងក្នុង ការស្រពោនខាងក្នុង ការក្តៅខាងក្នុង ការពេលពាលខាងក្នុង អាការជាទីសញ្ជប់សញ្ជឹងនៃចិត្ត ការអាក់អន់ចិត្ត សរគឺការសោក របស់បុគ្គល ដែលត្រូវសេចក្តីវិនាសញាតិ ប៉ះពាល់ ឬត្រូវសេចក្តីវិនាសនៃភោគៈ ប៉ះពាល់ ត្រូវសេចក្តីវិនាសគឺរោគ ប៉ះពាល់ ឬត្រូវសេចក្តីវិនាសសីល ប៉ះពាល់ ត្រូវសេចក្តីវិនាសគឺទិដ្ឋិ ប៉ះពាល់ ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយ ប៉ះពាល់ ។

បរិទេវតិ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ លាបោ បលាបោ វិប្បលាបោ លាលប្បោ លាលប្បាយនា លាលប្បាយិតត្តំ ។ កថំ នុ ធីរា វិតរន្តិ ឱឃំ ជាតិជ្ជរំ សោកបរិទ្ទវញ្ចាតិ កថំ ធីរា ឱឃញ្ច ជាតិជ្ជរញ្ច សោកញ្ច បរិទ្ទវញ្ច តរន្តិ ឧត្តរន្តិ បតរន្តិ សមតិក្កមន្តិ វីតិវត្តន្តីតិ កថំ នុ ធីរា វិតរន្តិ ឱឃំ ជាតិជ្ជរំ សោកបរិទ្ទវញ្ច ។

[១៦០] តម្មេ មុនី សាធុ វិយាករោហីតិ តន្តិ យំ បុច្ឆាមិ យំ យាចាមិ យំ អជ្ឈេសាមិ យំ បសាទេមិ ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជាននា ។ បេ ។

ពាក្យថា សេចក្ដីខ្សឹកខ្សួល គឺ ការខ្សឹកខ្សួល អាការយំ អាការខ្សឹកខ្សួល ភាពនៃការយំ ភាពនៃការខ្សឹកខ្សួល ការទួញរៀបរាប់ ការពោលរៀបរាប់ ការរៀបរាប់ដែល ៗ ការពោលរំលឹក អាការនៃការពោលរំលឹក ភាពនៃការពោលរំលឹក នៃបុគ្គលដែលត្រូវសេចក្ដីវិនាសញាតិប៉ះពាល់ ឬត្រូវសេចក្ដីវិនាសភោគៈប៉ះពាល់ ត្រូវសេចក្ដីវិនាសរោគប៉ះពាល់ ឬត្រូវសេចក្ដីវិនាសសីលប៉ះពាល់ ត្រូវសេចក្ដីវិនាសទិដ្ឋិប៉ះពាល់ ឬប្រកបដោយសេចក្ដីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ ។ ពាក្យថា អ្នកប្រាជ្ញទាំងឡាយឆ្លងឱឃៈផង ជាតិជរាផង សោកៈនិងបរិទេវៈផង ដោយប្រការដូចម្ដេចហ្ន៎ បានសេចក្ដីថា អ្នកប្រាជ្ញទាំងឡាយ ឆ្លងឡើង ឆ្លងកាត់ឈានកន្លង ប្រព្រឹត្តកន្លង នូវឱឃៈផង នូវជាតិជរាផង នូវសោកបរិទេវៈផង ដោយប្រការដូចម្ដេច ហេតុនោះ (លោកសួរថា) អ្នកប្រាជ្ញទាំងឡាយឆ្លងឱឃៈផង ជាតិជរាផង សោកៈនិងបរិទេវៈផង ដោយប្រការដូចម្ដេចហ្ន៎ ។

[១៦០] អធិប្បាយពាក្យថា សូមព្រះអង្គ ជាមុនិ ដោះស្រាយនូវឧបាយជាគ្រឿងឆ្លងនោះ ត្រង់ពាក្យថា នោះ គឺខ្ញុំព្រះអង្គទូលសួរសេចក្ដីណា សូមសេចក្ដីណា អារាធនាសេចក្ដីណា ជ្រះថ្លាចំពោះសេចក្ដីណា ។ ពាក្យថា មុនិ សេចក្ដីថា ញាណលោកហៅថា មោនៈ បានខាងប្រាជ្ញា ការដឹងច្បាស់ ។ បេ ។

អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា តេន ញាណេន សមន្នាគតោ មុនិ មោនប្បត្តោ ។ តីណិ មោនេយ្យានិ កាយមោនេយ្យំ វចីមោនេយ្យំ មនោ-មោនេយ្យំ ។

កតមំ កាយមោនេយ្យំ ។ តិវិធានំ កាយទុច្ចរិ-តានំ បហានំ កាយមោនេយ្យំ តិវិធំ កាយសុចរិតំ កាយមោនេយ្យំ កាយារម្មណំ ញាណំ កាយមោនេ-យ្យំ កាយបរិញ្ញា កាយមោនេយ្យំ បរិញ្ញាសហគតោ មគ្គោ កាយមោនេយ្យំ កាយេ ឆន្ទរាគស្ស បហានំ កាយមោនេយ្យំ កាយសង្ខារនិរោធោ ចតុត្ថជ្ឈាន-សមាបត្តិ កាយមោនេយ្យំ ឥទំ កាយមោនេយ្យំ ។

កតមំ វចីមោនេយ្យំ ។ ចតុព្វិធានំ វចីទុច្ចរិ-តានំ បហានំ វចីមោនេយ្យំ ចតុព្វិធំ វចីសុចរិតំ វចីមោនេយ្យំ វាចារម្មណំ ញាណំ វចីមោនេយ្យំ វាចាបរិញ្ញា វចីមោនេយ្យំ បរិញ្ញាសហគតោ មគ្គោ វចីមោនេយ្យំ វាចាយ ឆន្ទរាគស្ស បហានំ វចីមោ-នេយ្យ វចីសង្ខារនិរោធោ ទុតិយជ្ឈានសមាបត្តិ វចី-មោនេយ្យំ ឥទំ វចីមោនេយ្យំ ។

ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ។ ព្រះមានព្រះភាគ ប្រកបដោយញាណនោះ ទើបទ្រង់ព្រះនាមថា មុនិ ព្រះអង្គដល់នូវមោនៈ ។ មោនេយ្យៈ ៣ គឺ កាយមោនេយ្យៈ វចីមោនេយ្យៈ មនោ-មោនេយ្យៈ ។

កាយមោនេយ្យៈ តើដូចម្តេច ។ ការលះបង់កាយទុច្ចរិត ៣ ឈ្មោះថា កាយមោនេយ្យៈ កាយសុចរិត ៣ ឈ្មោះថា កាយមោ-នេយ្យៈ ញាណមានកាយជាអារម្មណ៍ ឈ្មោះថា កាយមោនេយ្យៈ ការកំណត់ដឹងនូវកាយ ឈ្មោះថា កាយមោនេយ្យៈ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថា កាយមោនេយ្យៈ ការលះបង់ឆន្ទរាគក្នុងកាយ ឈ្មោះថា កាយមោនេយ្យៈ ការរលត់កាយសង្ខារគឺចតុត្ថជ្ឈានសមាបត្តិ ឈ្មោះថា កាយមោនេយ្យៈ នេះ កាយមោនេយ្យៈ ។

វចីមោនេយ្យៈ តើដូចម្តេច ។ ការលះបង់វចីទុច្ចរិត ៤ ឈ្មោះថា វចីមោនេយ្យៈ វចីសុចរិត ៤ ឈ្មោះថា វចីមោនេយ្យៈ ញាណមានវាចាជាអារម្មណ៍ ឈ្មោះថា វចីមោនេយ្យៈ ការកំណត់ដឹងនូវវាចា ឈ្មោះថា វចីមោនេយ្យៈ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថា វចីមោនេយ្យៈ ការលះបង់ឆន្ទរាគក្នុងវាចា ឈ្មោះថា វចីមោនេយ្យៈ ការរលត់វចីសង្ខារនិងទុតិយជ្ឈានសមាបត្តិ ឈ្មោះថា វចីមោនេយ្យៈ នេះ វចីមោនេយ្យៈ ។

១៣៤



កតមំ មនោមោនេយ្យំ ។ តិវិធានំ មនោទុច្ចរិតានំ បហានំ មនោមោនេយ្យំ តិវិធំ មនោសុចរិតំ មនោមោនេយ្យំ ចិត្តារម្មណំ ញាណំ មនោមោនេយ្យំ ចិត្តបរិញ្ញា មនោមោនេយ្យំ បរិញ្ញាសហគតោ មគ្គោ មនោមោនេយ្យំ ចិត្តេ ឆន្ទរាគស្ស បហានំ មនោមោនេយ្យំ ចិត្តសង្ខារនិរោធោ សញ្ញាវេទយិតនិរោធសមាបត្តិ មនោមោនេយ្យំ ឥទំ មនោមោនេយ្យំ ។

កាយមុនឹ វាចាមុនឹ មនោមុនិមនាសវំ
មុនឹ មោនេយ្យសម្បន្នំ អាហុ សព្វប្បហាយិនំ
កាយមុនឹ វាចាមុនឹ មនោមុនិមនាសវំ
មុនឹ មោនេយ្យសម្បន្នំ អាហុ និណ្ហាតចាបកន្តិ ។

ឥមេហិ មោនេយ្យេហិ ធម្មេហិ សមន្នាគតា ឆ មុនយោ[១] អាគារមុនយោ អនាគារមុនយោ សេក្ខមុនយោ អសេក្ខមុនយោ បច្ចេកមុនយោ មុនិមុនយោ ។ កតមេ អាគារមុនយោ ។ យេ តេ អាគារិកា ទិដ្ឋបទា វិញ្ញាតសាសនា ឥមេ អាគារមុនយោ ។

១ ម. មុនិនោតិ ។

មេត្តគូមាណវកបញ្ហានិទ្ទេស

មនោមោនេយ្យៈ តើដូចម្តេច ។ ការលះបង់មនោទុច្ចរិត ៣ ឈ្មោះថា មនោមោនេយ្យៈ មនោសុចរិត ៣ ឈ្មោះថា មនោមោនេយ្យៈ ញាណមានចិត្តជាអារម្មណ៍ ឈ្មោះថា មនោមោនេយ្យៈ ការកំណត់ដឹងចិត្ត ឈ្មោះថា មនោមោនេយ្យៈ មគ្គប្រកបដោយការកំណត់ដឹង ឈ្មោះថា មនោមោនេយ្យៈ ការលះបង់ឆន្ទរាគក្នុងចិត្ត ឈ្មោះថា មនោមោនេយ្យៈ ការរលត់ចិត្តសង្ខារគឺសញ្ញាវេទយិតនិរោធសមាបត្តិ ឈ្មោះថា មនោមោនេយ្យៈ នេះ មនោមោនេយ្យៈ ។

អ្នកប្រាជ្ញទាំងឡាយ បានពោលនូវបុគ្គល ជាកាយមុនិ ជាវាចាមុនិ ជាមនោមុនិ ជាអនាសវមុនិ ដែលបរិបូណ៌ដោយមោនេយ្យៈ ថាជាអ្នកលះបង់នូវកិលេសទាំងពួង អ្នកប្រាជ្ញទាំងឡាយបានពោលនូវបុគ្គល ជាកាយមុនិ ជាវាចាមុនិ ជាមនោមុនិ ជាអនាសវមុនិ ដែលបរិបូណ៌ដោយមោនេយ្យៈ ថាជាអ្នកលាងបាបហើយ ។

មុនិ មាន ៦ ពួក ដែលប្រកបដោយមោនេយ្យធម៌ ទាំងនេះ គឺ អាគារមុនិ ១ អនាគារមុនិ ១ សេក្ខមុនិ ១ អសេក្ខមុនិ ១ បច្ចេកមុនិ ១ មុនិមុនិ ១ ។ អាគារមុនិ តើដូចម្តេច ។ ពួកជនណា ជាអ្នកគ្រប់គ្រងផ្ទះទេ តែមានព្រះនិព្វានឃើញហើយ មានសាសនធម៌ដឹងច្បាស់ហើយ ពួកជននេះ ឈ្មោះថា អាគារមុនិ ។

កតមេ អនាគារមុនយោ ។ យេ តេ បព្វជិតា និដ្ឋ-
បនា វិញ្ញាតសាសនា ឥមេ អនាគារមុនយោ ។
សត្ត សេក្ខា សេក្ខមុនយោ ។ អរហន្តោ អសេ-
ក្ខមុនយោ ។ បច្ចេកសម្ពុទ្ធា បច្ចេកមុនយោ ។
តថាគតា អរហន្តោ សម្មាសម្ពុទ្ធា មុនិមុនយោ ។

ន មោនេន មុនិ ហោតិ     មូឡ្ហរូបោ អវិទ្ទសុ
យោ ច តុលំវ បគ្គយ្ហ     វរមាទាយ បណ្ឌិតោ
បាបានិ បរិវជ្ជេតិ     ស មុនិ តេន សោ មុនិ
យោ មុនាតិ ឧភោ លោកេ មុនិ តេន បវុច្ចតិ ។

អសតញ្ច សតញ្ច ញត្វា ធម្មំ
អជ្ឈត្តញ្ច ពហិទ្ធា ច សព្វលោកេ
ទេវមនុស្សេហិ បូជិតោ
យោ សោ សង្គជាលមតិច្ច សោ មុនីតិ ។

អនាគារមុនិ តើដូចម្តេច ។ ពួកបុគ្គលណា ជាបព្វជិត មានព្រះនិព្វានឃើញហើយ មានសាសនធម៌ដឹងច្បាស់ហើយ ពួកបុគ្គលនេះឈ្មោះថា អនាគារមុនិ ។ សេក្ខបុគ្គលទាំងឡាយ ៧ ពួក ឈ្មោះថា សេក្ខមុនិ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ឈ្មោះថា បច្ចេកមុនិ ។ ព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ ឈ្មោះថា មុនិមុនិ ។

បុគ្គលល្ងង់ខ្លៅ ជាអ្នកមិនចេះ មិនឈ្មោះថា មុនិ ដោយការស្ងៀមទេ
លុះតែបុគ្គលណា ជាបណ្ឌិត កាន់យកធម៌ដ៏ប្រសើរ វៀរនូវបាប
ទាំងឡាយ ដូចបុគ្គលអ្នកថ្លឹងនូវរបស់ដោយជញ្ជីង បុគ្គលនោះ
ឈ្មោះថា មុនិ បុគ្គលនោះទើបឈ្មោះថា មុនិ ដោយហេតុនោះ
បុគ្គលណា ដឹងនូវប្រយោជន៍ទាំង ២ ក្នុងលោក បុគ្គលនោះ
លោកហៅថា មុនិ ដោយហេតុនោះ ។

បុគ្គលណា ដឹងនូវធម៌របស់ពួកអសប្បុរសផង របស់ពួក
សប្បុរសផង ដឹងនូវអាយតនៈខាងក្នុងផង ខាងក្រៅផង
ក្នុងលោកទាំងពួង ជាបុគ្គលដែលទេវតានិងមនុស្សទាំង-
ឡាយបូជាហើយ កន្លងផុតនូវបណ្តាញគឺកិលេសជាគ្រឿង
ជាប់ចំពាក់ បុគ្គលនោះ ឈ្មោះថា មុនិ ។

សាធុ វិយាករោហីតិ សាធុ អាចិក្ខាហិ ទេ-សេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តា-នីករោហិ បកាសេហីតិ តម្មេ មុនី សាធុ វិយា-ករោហិ ។

[១៦១] តថា ហិ តេ វិទិតោ ឯស ធម្មោតិ តថា ហិ តេ វិទិតោ ញាតោ តុលិតោ តីរិតោ វិភាវិតោ វិភូតោ ឯស ធម្មោតិ តថា ហិ តេ វិ-ទិតោ ឯស ធម្មោ ។ តេនាហ សោ ព្រាហ្មណោ

យទ្តំ អបុច្ឆិម្ហ អកិត្តយី នោ
អញ្ញំ តំ បុច្ឆាម តទិង្ឃ ព្រូហិ
កថំ នុ ធីរា វិតរន្តិ ឱឃំ
ជាតិជ្ជរំ សោកបរិទ្ទវញ្ច
តម្មេ មុនី សាធុ វិយាករោហិ
តថា ហិ តេ វិទិតោ ឯស ធម្មោតិ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

ពាក្យថា សូមព្រះអង្គដោះស្រាយ គឺសូមព្រះអង្គប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (លោកសួរថា) សូមព្រះអង្គជាមុនិ ដោះស្រាយនូវឧបាយជាគ្រឿងឆ្លងនោះ ។

[១៦១] ពាក្យថា ព្រោះព្រះអង្គជ្រាបច្បាស់ធម៌នោះហើយ គឺព្រោះព្រះអង្គជ្រាប ស្គាល់ ថ្លឹង ពិចារណា ឈ្វេងយល់ប្រាកដនូវធម៌នោះហើយ ហេតុនោះ(លោកសួរថា) ព្រោះព្រះអង្គជ្រាបច្បាស់ធម៌នោះហើយ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

យើងខ្ញុំបានទូលសួរសេចក្តីណា ព្រះអង្គបានត្រាស់ប្រាប់
សេចក្តីនោះ ដល់យើងខ្ញុំ យើងខ្ញុំសូមសួរសេចក្តីឯទៀត
ចំពោះព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ អ្នកប្រាជ្ញទាំង-
ឡាយឆ្លងឱឃៈផង ជាតិជរាផង សោកៈ និងបរិទេវៈផង
ដោយប្រការដូចម្តេចហ្ន៎ សូមព្រះអង្គជាមុនិ ដោះស្រាយនូវ
ឧបាយជាគ្រឿងឆ្លងនោះ ដល់យើងខ្ញុំ ព្រោះព្រះអង្គ
ជ្រាបធម៌នោះហើយ ។

[១៦២] កិត្តយិស្សាមិ តេ ធម្មំ (មេត្តគូតិ ភគវា)
ទិដ្ឋេ ធម្មេ អនីតិហំ
យំ វិទិត្វា សតោ ចរំ
តរេ លោកេ វិសត្តិកំ ។

[១៦៣] កិត្តយិស្សាមិ តេ ធម្មន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចត្តារោ សតិបដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈ-ង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ កិត្តយិស្សាមិ ទេសិស្សាមិ បញ្ញបេស្សាមិ បដ្ឋបេស្សាមិ វិវរិស្សាមិ វិភជិស្សាមិ ឧត្តានីករិស្សាមិ បកាសិស្សាមីតិ កិត្តយិស្សាមិ តេ ធម្មំ ។ មេត្តគូ-តិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។

[១៦២] (ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមេត្តគូ) តថាគតនឹង
សម្តែងធម៌ដល់អ្នក ដែលជាធម៌ ជាក់ច្បាស់ក្នុងខ្លួន ចំពោះ
ធម៌ដែលឃើញហើយ ជាធម៌ដែលបុគ្គលមានសតិ ដឹង
ហើយប្រព្រឹត្ត គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន ។

[១៦៣] ពាក្យថា តថាគតនឹងសម្តែងធម៌ ដល់អ្នក គឺតថាគតនឹងសម្តែង នឹងពន្យល់ នឹងបញ្ញត្ត នឹងតាំងទុក នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់ នឹងប្រកាស នូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ព្រមទាំងអត្ថនិងព្យញ្ជនៈ មានលម្អក្នុងខាងដើម មានលម្អត្រង់កណ្តាល មានលម្អក្នុងទីបំផុតផង នូវសតិប្បដ្ឋាន ៤ ផង នូវសម្មប្បធាន ៤ ផង នូវឥទ្ធិបាទ ៤ ផង នូវឥន្ទ្រិយ ៥ ផង នូវពលៈ ៥ ផង នូវពោជ្ឈង្គៈ ៧ ផង នូវមគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ ផង នូវព្រះនិព្វាន ផង នូវបដិបទាជាដំណើរទៅកាន់ព្រះនិព្វានផង ហេតុនោះ ទ្រង់ត្រាស់ថា តថាគតនឹងសម្តែងធម៌ ដល់អ្នក ។ ពាក្យថា មេត្តគូ គឺព្រះមានព្រះភាគ ទ្រង់ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។

១៣៩

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៦៤] ទិដ្ឋេ ធម្មេ អនីតិហន្តិ ទិដ្ឋេ ធម្មេតិ ទិដ្ឋេ ធម្មេ ញាតេ ធម្មេ តុលិតេ ធម្មេ តីរិតេ ធម្មេ វិភាវិតេ ធម្មេ វិភូតេ ធម្មេ សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ទិដ្ឋេ ធម្មេ ញាតេ ធម្មេ តុលិតេ ធម្មេ តីរិតេ ធម្មេ វិភាវិតេ ធម្មេ វិភូតេ ធម្មេតិ ឯវម្បិ ទិដ្ឋេ ធម្មេ កថយិស្សាមិ ។ អថវា ទុក្ខេ ទិដ្ឋេ ទុក្ខំ កថយិស្សាមិ សមុទយេ ទិដ្ឋេ សមុទយំ កថយិស្សាមិ មគ្គេ ទិដ្ឋេ មគ្គំ កថយិស្សាមិ និរោធេ ទិដ្ឋេ និរោធំ កថយិស្សាមីតិ ឯវម្បិ ទិដ្ឋេ ធម្មេ កថយិស្សាមិ ។ អថវា ទិដ្ឋេ ធម្មេ សន្ទិដ្ឋិកំ អកាលិកំ ឯហិបស្សិកំ ឱបនយិកំ បច្ចត្តំ វេទិតព្វំ វិញ្ញូហីតិ ឯវម្បិ ទិដ្ឋេ ធម្មេ កថយិស្សាមីតិ ទិដ្ឋេ ធម្មេ ។

មេត្តគូមាណវកបញ្ហានិទ្ទេស

[១៦៤] អធិប្បាយពាក្យថា ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួនចំពោះធម៌ដែលឃើញហើយ ត្រង់ពាក្យថា ចំពោះធម៌ដែលឃើញហើយ គឺចំពោះធម៌ដែលឃើញ ធម៌ដែលដឹង ធម៌ដែលថ្លឹង ធម៌ដែលពិចារណា ធម៌ដែលឈ្វេងយល់ ធម៌ដែលច្បាស់ហើយថា សង្ខារធម៌ទាំងពួងមិនទៀង ។ បេ ។ ចំពោះធម៌ដែលឃើញ ធម៌ដែលថ្លឹង ធម៌ដែលពិចារណា ធម៌ដែលឈ្វេងយល់ ធម៌ដែលច្បាស់ហើយថា ធម្មជាតណាមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ហេតុនោះ តថាគតនឹងសម្តែងធម៌ ដែលឃើញហើយ យ៉ាងនេះខ្លះ ។ មួយទៀត តថាគតនឹងសម្តែងទុក្ខ ចំពោះទុក្ខដែលឃើញហើយ នឹងសម្តែងសមុទ័យ ចំពោះសមុទ័យដែលឃើញហើយ នឹងសម្តែងមគ្គ ចំពោះមគ្គដែលឃើញហើយ នឹងសម្តែងនិរោធ ចំពោះនិរោធដែលឃើញហើយ ហេតុនោះ តថាគតនឹងសម្តែង ចំពោះធម៌ ដែលឃើញហើយ យ៉ាងនេះខ្លះ ។ មួយទៀត គុណជាតដែលបុគ្គលគប្បីឃើញជាក់ច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ជាគុណឲ្យផលមិនរង់ចាំកាល ជាធម៌ហាក់ដូចជានឹងហៅថា អ្នកចូរមកមើលចុះ ជាធម៌គួរបង្អោនមកទុកក្នុងខ្លួនបាន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងជាក់ច្បាស់ចំពោះខ្លួន ហេតុនោះ តថាគតនឹងសម្តែងចំពោះធម៌ ដែលឃើញហើយ យ៉ាងនេះខ្លះ ហេតុនោះ (ទ្រង់ត្រាស់ថា) ចំពោះធម៌ដែលឃើញហើយ ។

អជីតិហាត្ថិ ន ឥតិហំ ន ឥតិកិរាយ ន បរម្ប-
រាយ ន បិដកសម្បទាយ ន តក្កហេតុ ន ន-
យហេតុ ន អាការបរិវិតក្កេន ន ទិដ្ឋិនិជ្ឈានក្ខ-
ន្តិយា សាមំ សយមភិញ្ញាតំ អត្តបច្ចក្ខំ ធម្មំ ក-
ថយិស្សាមីតិ ទិដ្ឋេ ធម្មេ អជីតិហំ ។

[១៦៥] យំ វិទិត្វា សតោ ចរន្តិ យំ វិទិតំ
កត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ
កត្វា សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ
សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ វិទិតំ កត្វា
តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។
សតោតិ ចតូហិ ការណេហិ សតោ កាយេ
កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។
សោ វុច្ចតិ សតោ ។ ចរន្តិ ចរន្តោ វិចរន្តោ
ឥរិយន្តោ វត្តេន្តោ បាលេន្តោ យបេន្តោ យាបេ-
ន្តោតិ យំ វិទិត្វា សតោ ចរំ ។

ពាក្យថា ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួន គឺតថាគតសម្តែងធម៌ ដែលត្រាស់ដឹងឯងដោយខ្លួនឯង ជាក់ច្បាស់ចំពោះខ្លួន មិនមែនដោយអាងថាដូច្នេះ ៗ មិនមែនដោយឮថាដូច្នេះៗ មិនមែនដោយទំនៀម មិនមែនដោយការផ្សំតាមតម្រា មិនមែនដោយហេតុនៃសេចក្តីត្រិះរិះ មិនមែនដោយហេតុនៃការយល់ មិនមែនដោយសេចក្តីរិះគិតតាមអាការៈ មិនមែនតាមសេចក្តីឃើញការពិនិត្យនិងសេចក្តីចូលចិត្តទេ ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ។

[១៦៥] ពាក្យថា ជាធម៌ដែលបុគ្គលមានសតិ ដឹងហើយប្រព្រឹត្ត សេចក្តីថា បុគ្គលធ្វើ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដនូវធម៌ណា ឲ្យច្បាស់ថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ធ្វើ ថ្លឹង ពិចារ-ណា ឈ្វេងយល់ ធ្វើឲ្យប្រាកដនូវធម៌ឲ្យច្បាស់ថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា មានសតិ គឺបុគ្គលមានសតិដោយហេតុ ៤ គឺបុគ្គលចម្រើននូវកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា មានសតិ ។ បេ ។ បុគ្គលនោះ លោកហៅថា អ្នកមានសតិ ។ ពាក្យថា ប្រព្រឹត្ត គឺបុគ្គលកាលត្រាច់ រង្គាត់ សម្រេច ប្រព្រឹត្ត រក្សា យាត្រា យាត្រាទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាធម៌ដែលបុគ្គលមានសតិ ដឹងហើយប្រព្រឹត្ត ។

១៤១

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៦៦] តវេ លោកេ វិសត្តិកន្តិ វិសត្តិកា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ វិសត្តិកាតិ កេនដ្ឋេន វិសត្តិកា ។ វិសតាតិ វិសត្តិកា ។ វិសាលាតិ វិសត្តិកា ។ វិសដាតិ វិសត្តិកា ។ វិសក្កតីតិ វិសត្តិកា ។ វិសំហរតីតិ វិសត្តិកា ។ វិសំវាទិកាតិ វិសត្តិកា ។ វិសមូលាតិ វិសត្តិកា ។ វិសផលាតិ វិសត្តិកា ។ វិសបរិភោគាតិ វិសត្តិកា ។ វិសាលា វា បន សា តណ្ហា រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលេ គណេ អាវាសេ លាភេ យសេ បសំសេ សុខេ ចីវរេ បិណ្ឌបាតេ សេនាស-នេ គិលានប្បច្ចយភេសជ្ជបរិក្ខារេ កាមធាតុយា រូបធាតុយា អរូបធាតុយា កាមភវេ រូបភវេ អរូបភវេ សញ្ញាភវេ អសញ្ញាភវេ នេវសញ្ញានាសញ្ញាភវេ ឯកវោការភវេ ចតុវោការភវេ បញ្ចវោការភវេ អតីតេ អនាគតេ បច្ចុប្បន្នេ ទិដ្ឋសុតមុតវិញ្ញាត-ព្វេសុ ធម្មេសុ វិសដា វិត្ថតាតិ វិសត្តិកា ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

[១៦៦] ពាក្យថា គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានដល់រាគៈ រាគៈមាន កម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យ ថា វិសត្តិកា ដែលឈ្មោះថាវិសត្តិកា តើដោយអត្ថដូចម្តេច ។ ឈ្មោះ វិសត្តិកា ព្រោះជាធម្មជាតិផ្សាយទៅ ។ ឈ្មោះវិសត្តិកា ព្រោះ ទូលាយ ។ ឈ្មោះវិសត្តិកា ព្រោះលាទៅ ។ ឈ្មោះវិសត្តិកា ព្រោះ រួញរា ។ ឈ្មោះវិសត្តិកា ព្រោះពោលខុស ។ ឈ្មោះវិសត្តិកា ព្រោះមាន ឫសគល់ជាពិស ។ ឈ្មោះវិសត្តិកា ព្រោះមានផ្លែជាពិស ។ ឈ្មោះ វិសត្តិកា ព្រោះមានគ្រឿងបរិភោគជាពិស ។ មួយទៀត ឈ្មោះវិសត្តិកា ព្រោះតណ្ហានោះ ជាកិលេសជាតិដ៏ទូលាយ ផ្សាយទៅ ត្រដាងទៅ ក្នុងរូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល គណៈ អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលា-នប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន ក្នុងធម៌ទាំងឡាយ ដែលឃើញ ឮ ប៉ះពាល់ ឬគប្បីដឹង ។

លោកោតិ អបាយលោកោ មនុស្សលោកោ ទេវ-លោកោ ខន្ធលោកោ ធាតុលោកោ អាយតន-លោកោ ។ តរេ លោកេ វិសត្តិកន្តិ យា សា លោកេ វិសត្តិកា លោកេ តំ វិសត្តិកំ សតោ តរេយ្យ ឧត្តរេយ្យ បតរេយ្យ សមតិក្កមេយ្យ វីតិវ-ត្តេយ្យាតិ តរេ លោកេ វិសត្តិកំ ។ តេនាហ ភគវា

កិត្តយិស្សាមិ តេ ធម្មំ (មេត្តគូតិ ភគវា)

ទិដ្ឋេ ធម្មេ អនីតិហំ

យំ វិទិត្វា សតោ ចរំ

តរេ លោកេ វិសត្តិកន្តិ ។

[១៦៧] តញ្ចាហំ អភិនន្ទាមិ មហេសី ធម្មមុត្តមំ

យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។

ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។ ពាក្យថា គប្បីឆ្លងវិសត្តិកា-តណ្ហា ក្នុងលោកបាន បានសេចក្តីថា តណ្ហាណា ឈ្មោះវិសត្តិកា ក្នុងលោក បុគ្គលមានសតិ គប្បីឆ្លង ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង នូវតណ្ហាឈ្មោះវិសត្តិកានោះ ក្នុងលោក ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ) តថាគតនឹង
សម្តែងធម៌ដល់អ្នក ដែលជាធម៌ជាក់ច្បាស់ក្នុងខ្លួន ចំពោះ
ធម៌ដែលឃើញហើយ ជាធម៌ដែលបុគ្គលមានសតិ ដឹង
ហើយប្រព្រឹត្ត គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន ។

[១៦៧] (មេត្តគូទូលថា) ព្រះមានព្រះភាគ ព្រះអង្គស្វែងរក
គុណដ៏ធំ មានសតិ ទ្រង់ជ្រាបនូវធម៌ណា ជាធម៌ដ៏ឧត្តម
ហើយប្រព្រឹត្ត គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន
ចំណែកខ្ញុំព្រះអង្គត្រេកអរ ចំពោះធម៌នោះ ។

[១៦៨] តញ្ញាហំ អភិនន្ទាមីតិ តន្តិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសន្ធឹ[1] ។ អភិនន្ទាមីតិ នន្ទាមិ អភិនន្ទាមិ មោទាមិ អនុមោទាមិ ឥច្ឆាមិ សាទិយាមិ យាចាមិ បត្ថយាមិ បិហយាមិ អភិជប្បាមីតិ តញ្ញាហំ អភិនន្ទាមិ ។

[១៦៩] មហេសី ធម្មុត្តមន្តិ មហេសីតិ កេនត្ថេន មហេសី ។ ភគវា មហន្តំ សីលក្ខន្ធំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហន្តំ សមាធិក្ខន្ធំ មហន្តំ បញ្ញាខន្ធំ មហន្តំ វិមុត្តិក្ខន្ធំ មហន្តំ វិមុត្តិញាណទស្សនក្ខន្ធំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ វា តមោកាយស្ស បទាលនំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ វិប្បល្លាសស្ស បភេទនំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ តណ្ហាសល្លស្ស អព្ពុហនំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ ទិដ្ឋិសង្ឃាតស្ស វិនិវេឋនំ ឯសិ គវេសិ បរិយេសីតិ មហេសី ។

១ ម. អនុសាសនំ អនុសិដ្ឋំ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

[១៦៨] ពាក្យថា ខ្ញុំព្រះអង្គត្រេកអរចំពោះធម៌នោះ ត្រង់ពាក្យថា ចំពោះធម៌នោះ គឺ ចំពោះពាក្យ គន្លងពាក្យ ទេសនា អនុសន្ធិ របស់ព្រះអង្គ ។ ពាក្យថា ខ្ញុំព្រះអង្គត្រេកអរ គឺខ្ញុំព្រះអង្គស្រស់ស្រាយ ត្រេកអររីករាយ រីករាយតាម ប្រាថ្នា ចង់បាន សូម ត្រូវការ ស្រឡាញ់ ជាប់ចិត្ត ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គត្រេកអរចំពោះធម៌នោះ ។

[១៦៩] អធិប្បាយពាក្យថា ព្រះអង្គស្វែងរកគុណដ៏ធំ... ជាធម៌ដ៏ឧត្តម សំណួរត្រង់ពាក្យថា ស្វែងរកគុណដ៏ធំ ចុះឈ្មោះថាស្វែងរកគុណដ៏ធំ តើដោយអត្ថដូចម្ដេច ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះព្រះមានព្រះភាគ ទ្រង់រក ស្វែង ស្វះស្វែង នូវសីលក្ខន្ធដ៏ធំ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវសមាធិក្ខន្ធដ៏ធំ បញ្ញាខន្ធដ៏ធំ វិមុត្តិក្ខន្ធដ៏ធំ វិមុត្តិញ្ញាណទស្សនក្ខន្ធដ៏ធំ ។ មួយទៀត ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការទម្លាយនូវគំនរនៃងងឹតដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការបំបែកនូវវិប្បល្លាសដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការដកឡើងនូវសរគឺតណ្ហាដ៏ធំ ។ ឈ្មោះថា ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្វះស្វែង នូវការទម្លុះទម្លាយ នូវឃ្នាបគឺទិដ្ឋិដ៏ធំ ។

មហតោ មានទ្ធជស្ស ចាតនំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ អភិសង្ខារស្ស វូបសមំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ ឱឃស្ស និត្ថរណំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ ភារស្ស និក្ខេបនំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ សំសារវដ្ដស្ស ឧបច្ឆេទំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ សន្តាបស្ស និព្វាបនំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ បរិឡាហស្ស បដិប្បស្សទ្ធឹ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហតោ ធម្មទ្ធជស្ស ឧស្សាបនំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហន្តេ សតិប្បដ្ឋានេ មហន្តេ សម្មប្បធានេ មហន្តេ ឥទ្ធិបាទេ មហន្តានិ ឥន្ទ្រិយានិ មហន្តានិ ពលានិ មហន្តេ ពោជ្ឈង្គេ មហន្តំ អរិយំ អដ្ឋង្គិកំ មគ្គំ មហន្តំ បរមត្ថំ អមតំ និព្វានំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហេសក្ខេហិ វា សត្តេហិ ឯសិតោ គវេសិតោ បរិយេសិតោ កហំ ពុទ្ធោ កហំ ភគវា កហំ ទេវទេវោ កហំ នរាសភោតិ មហេសី ។

ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការទម្លាក់ចុះនូវទង់គឺមានះដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការរម្ងាប់នូវអភិសង្ខារដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការរើឡើងនូវឱឃៈដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការដាក់ចុះនូវភារៈដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការផ្តាច់បង់នូវសំសារវដ្តដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការរំលត់នូវកម្តៅដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការរម្ងាប់សេចក្តីពេលពាលដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវការលើកឡើងនូវទង់គឺធម៌ដ៏ធំ ។ ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែង ស្ទះស្វែង នូវសតិប្បដ្ឋានដ៏ធំ សម្មប្បធានដ៏ធំ ឥទ្ធិបាទដ៏ធំ ឥន្ទ្រិយដ៏ធំ ពលៈដ៏ធំ ពោជ្ឈង្គៈធំ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ដ៏ធំ អមតនិព្វានមានអត្ថដ៏ក្រៃលែងដ៏ធំ ។ មួយទៀត ឈ្មោះថាស្វែងរកគុណដ៏ធំ ព្រោះពួកសត្វ មានសក្តិដ៏ធំ រក ស្វែង ស្ទះស្វែងថា ព្រះពុទ្ធគង់ក្នុងទីណា ព្រះមានព្រះភាគ គង់ក្នុងទីណា ព្រះអង្គជាទេវតាប្រសើរជាងទេវតាគង់ក្នុងទីណា ព្រះអង្គជានរៈដ៏ក្លៀវក្លាគង់ក្នុងទីណា ។

ធម្មមុត្តមន្តិ ធម្មមុត្តមំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ ឧត្តមន្តិ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរំ ធម្មន្តិ មហេសី ធម្មមុត្តមំ ។

[១៧០] យំ វិទិត្វា សតោ ចរន្តិ វិទិតំ កត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ វិទិតំ កត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ វុច្ចតិ សតោ ។ ចរន្តិ ចរន្តោ វិចរន្តោ ឥរិយន្តោ វត្តេន្តោ បាលេន្តោ យបេន្តោ យាបេន្តោតិ យំ វិទិត្វា សតោ ចរំ ។

មេត្តគូមាណវកបញ្ហានិទ្ទេស

ពាក្យថា ជាធម៌ដ៏ឧត្តម សេចក្តីថា អមតនិព្វាន លោកហៅថា ធម៌ដ៏ឧត្តម បានខាង ការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ ពាក្យថា ឧត្តម គឺធម៌ជាកំពូល ប្រសើរ ប្រសើរវិសេស ជាប្រធាន ខ្ពង់ខ្ពស់ ថ្លៃថ្លា ហេតុនោះ (លោកពោលថា) ព្រះអង្គស្វែងរកគុណដ៏ធំ... ជាធម៌ដ៏ឧត្តម ។

[១៧០] ពាក្យថា មានសតិ ជ្រាបច្បាស់ នូវធម៌ណា ហើយប្រព្រឹត្ត គឺធ្វើឲ្យច្បាស់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ធ្វើឲ្យច្បាស់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដថា ធម្មជាតឯណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា មានសតិ សេចក្តីថា មានសតិដោយហេតុ ៤ គឺ បុគ្គលចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា អ្នកមានសតិ ។ បេ ។ បុគ្គលនោះ លោកហៅថា អ្នកមានសតិ ។ ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ត្រួតត្រា សម្រេច ទៅ រក្សា យាត្រា យាត្រាទៅ ហេតុនោះ (លោកពោលថា) មានសតិ ជ្រាបច្បាស់ នូវធម៌ណា ហើយប្រព្រឹត្ត ។

[១៧១] តវេ លោកោ វិសត្តិកាន្តិ វិសត្តិកា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ វិសត្តិកាតិ កេនដ្ឋេន វិសត្តិកា ។ បេ ។ វិសដា វិត្ថតាតិ វិសត្តិកា ។ លោកោតិ អបាយលោកោ ។ បេ ។ អាយតនលោកោ ។ តវេ លោកោ វិសត្តិកាន្តិ យា សា លោកោ វិសត្តិកា លោកោ តំ វិសត្តិកំ សតោ តរេយ្យ ឧត្តរេយ្យ បតរេយ្យ សមតិក្កមេយ្យ វីតិវត្តេយ្យាតិ តវេ លោកោ វិសត្តិកំ ។ តេនាហ សោ ព្រាហ្មណោ

តញ្ចាហំ អភិនន្ទាមិ មហេសី ធម្មមុត្តមំ
យំ វិទិត្វា សតោ ចរំ តវេ លោកោ វិសត្តិកន្តិ ។

[១៧១] ពាក្យថា គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានដល់ រាគៈ រាគៈមានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ចុះឈ្មោះវិសត្តិកា តើដោយអត្ថដូចម្តេច ។ បេ ។ ឈ្មោះវិសត្តិកា ព្រោះផ្សាយទៅ ត្រដាងទៅ ។ ពាក្យថា ក្នុងលោកៈ គឺក្នុងអបាយលោក ។ បេ ។ អាយតនលោក ។ ពាក្យថា គប្បីឆ្លងវិសត្តិកាតណ្ហាក្នុងលោកបានសេចក្តីថា តណ្ហាណា ឈ្មោះវិសត្តិកា ក្នុងលោក ព្រះមហេសីមានសតិ គប្បីឆ្លង ឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លងនូវវិសត្តិកាតណ្ហានោះ ក្នុងលោក ហេតុនោះ (លោកពោលថា) គប្បីឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ព្រះមានព្រះភាគ ព្រះអង្គស្វែងរកនូវគុណដ៏ធំ មានសតិ
ទ្រង់ជ្រាបច្បាស់ នូវធម៌ណា ជាធម៌ដ៏ឧត្តមហើយប្រព្រឹត្ត
គប្បីឆ្លងធម្មវិសត្តិកាតណ្ហាក្នុងលោកបាន ចំណែកខ្ញុំព្រះអង្គ
ត្រេកអរ ចំពោះធម៌នោះ ។

១៤៧

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៧២] យន្តិ៎ត្វំ សម្បជានាសិ (មេត្តគូតិ ភគវា)

ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ

ឯតេសុ នន្ទិញ្ច និវេសនញ្ច

បនុជ្ជ វិញ្ញាណំ ភវេ ន តិដ្ឋេ ។

[១៧៣] យន្តិ៎ត្វំ សម្បជានាសីតិ យន្តិ៎ត្វំ បជានាសិ អាជានាសិ វិជានាសិ បដិវិជានាសិ បដិវិជ្ឈសីតិ យន្តិ៎ត្វំ សម្បជានាសិ ។ មេត្តគូតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ មេត្តគូ ភគវា ។

[១៧៤] ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេតិ ឧទ្ធន្តិ វុច្ចតិ អនាគតំ ។ អធោតិ អតីតំ ។ តិរិយញ្ចាបិ មជ្ឈេតិ បច្ចុប្បន្នំ ។ ឧទ្ធន្តិ វុច្ចតិ ទេវលោកោ ។

មេត្តគូមាណវកបញ្ហានិទ្ទេស

[១៧២] (ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ) អ្នកបើដឹងច្បាស់ នូវធម្មជាតិណាមួយ ទាំងខាងលើ ខាងក្រោម និងទទឹងគឺកណ្តាលហើយ អ្នកចូរបន្ទោបង់ នូវសេចក្តីត្រេកត្រអាលផង សេចក្តីប្រកាន់ផង វិញ្ញាណផង ក្នុងធម៌ទាំងឡាយនុ៎ះចេញ ទើបមិនឋិតនៅក្នុងភព ។

[១៧៣] ពាក្យថា អ្នកបើដឹងច្បាស់នូវធម្មជាតិណាមួយ គឺបើអ្នកដឹងច្បាស់ ដឹងទួទៅ ដឹងវិសេស ដឹងចំពោះ យល់ច្បាស់ នូវធម្មជាតិណាមួយ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកបើដឹងច្បាស់នូវធម្មជាតិណាមួយ ។ ព្រះមានព្រះភាគ ទ្រង់ហៅព្រាហ្មណ៍នោះតាមឈ្មោះ ថាមេត្តគូ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ គឺជាពាក្យហៅដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ ។

[១៧៤] ពាក្យថា ទាំងខាងលើ ខាងក្រោម និងទទឹង គឺកណ្តាល អធិប្បាយថា អនាគត លោកហៅថា ខាងលើ ។ អតីត លោកហៅថា ខាងក្រោម ។ បច្ចុប្បន្ន លោកហៅថា ទទឹងគឺកណ្តាល ។ ទេវលោក លោកហៅថា ខាងលើ ។

អជោតិ និរយលោកោ ។ តិរិយញ្ចាបិ មជ្ឈេតិ មនុស្សលោកោ ។ ឧទ្ធន្តិ កុសលា ធម្មា ។ អជោតិ អកុសលា ធម្មា ។ តិរិយញ្ចាបិ មជ្ឈេតិ អព្យាកតា ធម្មា ។ ឧទ្ធន្តិ អរូបធាតុ ។ អជោតិ កាមធាតុ ។ តិរិយញ្ចាបិ មជ្ឈេតិ រូបធាតុ ។ ឧទ្ធន្តិ សុខា វេទនា ។ អជោតិ ទុក្ខា វេទនា ។ តិរិយញ្ចាបិ មជ្ឈេតិ អទុក្ខមសុខា វេទនា ។ ឧទ្ធន្តិ ឧទ្ធំ ចាទតលា ។ អជោតិ អជោ កេសមត្ថកា ។ តិរិយញ្ចាបិ មជ្ឈេតិ វេមជ្ឈេតិ ឧទ្ធំ អជោ តិរិយញ្ចាបិ មជ្ឈេ ។

[១៧៩] ឯតេសុ នន្ទិញ្ច និវេសនញ្ច បនុជ្ជ វិញ្ញាណំ ភវេ ន តិដ្ឋេតិ ឯតេសូតិ អាចិក្ខិតេសុ ទេសិតេសុ បញ្ញបិតេសុ បដ្ឋបិតេសុ វិវរិតេសុ វិភជិតេសុ ឧត្តានីកតេសុ បកាសិតេសុ ។

និរយលោក លោកហៅថា ខាងក្រោម ។ មនុស្សលោក លោកហៅថា ទទឹងគឺកណ្តាល ។ ពាក្យថា ខាងលើ បានដល់ កុសលធម៌ ។ ពាក្យថា ខាងក្រោម បានដល់ អកុសលធម៌ ។ ពាក្យថា ទទឹងគឺកណ្តាល បានដល់ អព្យាកតធម៌ ។ ពាក្យថា ខាងលើ បានដល់ អរូបធាតុ ។ ពាក្យថា ខាងក្រោម បានដល់ កាមធាតុ ។ ពាក្យថា ទទឹងគឺកណ្តាល បានដល់ រូបធាតុ ។ ពាក្យថា ខាងលើ បានដល់ សុខវេទនា ។ ពាក្យថា ខាងក្រោម បានដល់ទុក្ខវេទនា ។ ពាក្យថា ទទឹងគឺកណ្តាល បានដល់ អទុក្ខមសុខវេទនា ។ ពាក្យថា ខាងលើ គឺខាងលើអំពីបាតជើងឡើងទៅ ។ ពាក្យថា ខាងក្រោម គឺខាងក្រោមតាំងពីចុងសក់ចុះមក ។ ពាក្យថា ទទឹង គឺកណ្តាលបានដល់ ក្នុងទីពាក់កណ្តាលខ្លួន ហេតុនោះ (ទ្រង់ត្រាស់ថា) ខាងលើ ខាងក្រោម និងទទឹងគឺកណ្តាល ។

[១៧៥] អធិប្បាយពាក្យថា អ្នកចូរបន្ទោបង់ នូវសេចក្តីត្រេកត្រអាលផង សេចក្តីប្រកាន់ផង វិញ្ញាណផង ក្នុងធម៌ទាំងឡាយនុ៎ះចេញ ទើបមិនឋិតនៅ ក្នុងភព ត្រង់ពាក្យថា ក្នុងធម៌ទាំងឡាយនុ៎ះ គឺក្នុងធម៌ទាំងឡាយ ដែលតថាគតប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសហើយ ។

នន្ទិ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។
អភិជ្ឈា លោភោ អកុសលមូលំ ។ និវេសនន្តិ ទ្វេ
និវេសនា តណ្ហានិវេសនា ច ទិដ្ឋិនិវេសនា ច ។
កតមា តណ្ហានិវេសនា ។ យាវតា តណ្ហាសង្ខាតេន
។ បេ ។ អយំ តណ្ហានិវេសនា ។ កតមា ទិដ្ឋិនិវេសនា ។
វីសតិវត្ថុកា សក្កាយទិដ្ឋិ ។ បេ ។ អយំ ទិដ្ឋិនិវេស-
នា ។ បនុជ្ជ វិញ្ញាណន្តិ បុញ្ញាភិសង្ខារសហគតំ វិញ្ញា-
ណំ អបុញ្ញាភិសង្ខារសហគតំ វិញ្ញាណំ អនេញ្ជាភិស-
ង្ខារសហគតំ វិញ្ញាណំ ។ ឯតេសុ នន្ទិញ្ច និវេស-
នញ្ច អភិសង្ខារសហគតញ្ច វិញ្ញាណំ នុជ្ជ បនុជ្ជ
នុទ បនុទ ជហ បជហ វិនោទេហិ ព្យន្តីករោហិ
អនភាវង្គមេហីតិ ឯតេសុ នន្ទិញ្ច និវេសនញ្ច បនុជ្ជ
វិញ្ញាណំ ។ ភវេ ន តិដ្ឋេតិ ភវាតិ ទ្វេ ភវា កម្មភវោ
ច បដិសន្ធិកោ ច បុនព្ភវោ ។ កតមោ កម្មភវោ ។
បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អនេញ្ជាភិសង្ខារោ
អយំ កម្មភវោ ។ កតមោ បដិសន្ធិកោ បុនព្ភវោ ។

តណ្ហា លោកហៅថា សេចក្តីត្រេកត្រអាល បានដល់រាគៈ រាគៈមាន កម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា សេចក្តីប្រកាន់ បានដល់សេចក្តីប្រកាន់ ២ គឺ ការប្រកាន់គឺតណ្ហា ១ ការប្រកាន់គឺទិដ្ឋិ ១ ។ ការប្រកាន់ គឺតណ្ហា តើដូចម្តេច ។ ពោល គឺតណ្ហា មានកំណត់ត្រឹមណា ។ បេ ។ នេះ សេចក្តីប្រកាន់ គឺតណ្ហា ។ សេចក្តីប្រកាន់គឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិមានវត្ថុ ២០ ។ បេ ។ នេះ សេចក្តីប្រកាន់គឺទិដ្ឋិ ។ ពាក្យថា ចូរបន្ទោបង់វិញ្ញាណ សេចក្តីថា វិញ្ញាណប្រកប ដោយបុញ្ញាភិសង្ខារ វិញ្ញាណប្រកបដោយ អបុញ្ញាភិសង្ខារ វិញ្ញាណប្រកប ដោយអានេញ្ជាភិសង្ខារ ។ អ្នកចូរ ខ្ជាក់ រលាស់ បន្សាត់ ផាត់ លះ ប្រហាន បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវសេចក្តីត្រេកត្រអាលផង នូវសេចក្តីប្រកាន់ ផង នូវវិញ្ញាណ ប្រកបដោយអភិសង្ខារផង ក្នុងធម៌ទាំងឡាយនោះ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកចូរបន្ទោបង់ សេចក្តីត្រេកត្រអាលផង សេចក្តីប្រកាន់ផង វិញ្ញាណផង ក្នុងធម៌ទាំងឡាយនុ៎ះ ។ ពាក្យថា ភព របស់បទថា មិនឋិតនៅក្នុងភព បានដល់ភព ២ គឺកម្មភព ១ បុនព្ភព គឺបដិសន្ធិ ១ ។ កម្មភព តើដូចម្តេច ។ គឺបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ នេះ កម្មភព ។ បុនព្ភពគឺបដិសន្ធិ តើដូចម្តេច ។

បដិសន្ធិកា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ អយំ បដិសន្ធិកោ បុនព្ភវោ ។ ភវេ ន តិដ្ឋេតិ នន្ទិញ្ច និវេសនញ្ច អភិសង្ខារសហាគតញ្ច វិញ្ញាណំ កម្ម-ភវញ្ច បដិសន្ធិកញ្ច បុនព្ភវំ បជហន្តោ វិនោទេន្តោ ព្យន្តីករោន្តោ អនភាវង្គមេន្តោ កម្មភវេ ន តិដ្ឋេយ្យ បដិសន្ធិកេ បុនព្ភវេ ន តិដ្ឋេយ្យ ន សន្តិដ្ឋេយ្យាតិ បនុជ្ជ វិញ្ញាណំ ភវេ ន តិដ្ឋេ ។ តេនាហ ភគវា

យង្កិញ្ចិ សម្បជានាសិ (មេត្តគូតិ ភគវា)
ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ
ឯតេសុ នន្ទិញ្ច និវេសនញ្ច
បនុជ្ជ វិញ្ញាណំ ភវេ ន តិដ្ឋេតិ ។

[១៧៦] ឯវំវិហារី សតោ អប្បមត្តោ
ភិក្ខុ ចរំ ហិត្វា មមាយិតានិ
ជាតិជ្ជរំ សោកបរិទ្ទវញ្ច
ឥធេវ វិទ្វា បជហេយ្យ ទុក្ខំ ។

រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលប្រកបដោយបដិសន្ធិ នេះ បុនព្ភពគឺបដិសន្ធិ ។ ពាក្យថា មិនឋិតនៅក្នុងភព គឺបុគ្គល កាលលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យមានបែបភាព នូវសេចក្តី ត្រេកត្រអាលផង នូវសេចក្តីប្រកាន់ផង នូវវិញ្ញាណដែលប្រកប ដោយ អភិសង្ខារផង នូវកម្មភពផង នូវបុនព្ភពគឺបដិសន្ធិផង ទើបមិនគប្បី ឋិតក្នុងកម្មភព មិនគប្បីឋិតនៅ មិនគប្បីតាំងនៅ ក្នុងបុនព្ភពគឺបដិសន្ធិ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកចូរបន្ទោបង់វិញ្ញាណ ទើបមិនឋិត នៅក្នុងភព ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលមេត្តគូ) អ្នកបើដឹងច្បាស់នូវ ធម្មជាតិណាមួយ ទាំងខាងលើ ខាងក្រោម និងទទឹង គឺកណ្តាលហើយ អ្នកចូរបន្ទោបង់ នូវសេចក្តីត្រេកត្រអាល ផង សេចក្តីប្រកាន់ផង វិញ្ញាណផង ក្នុងធម៌ទាំងឡាយនុ៎ះ ចេញ ទើបមិនឋិតនៅក្នុងភព ។

[១៧៦] ភិក្ខុមានការនៅយ៉ាងនេះ មានសតិ អ្នកមិនប្រហែស លះបង់សេចក្តីប្រកាន់ ហើយប្រព្រឹត្ត ជាអ្នកចេះដឹង គប្បី លះបង់ នូវទុក្ខ គឺជាតិ ជរា សោកៈ និងបរិទេវៈ ក្នុង លោកនេះបាន ។

១៨១

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៧៧] ឯកវិហារី សតោ អប្បមត្តោតិ ឯកវិហារីតិ ឆន្ទញ្ច និវេសនញ្ច អភិសង្ខារសហគតញ្ច វិញ្ញាណំ កម្មភវញ្ច បដិសន្ធិកញ្ច បុនព្ភវំ បជហន្តោ វិនោទេន្តោ ព្យន្តីករោន្តោ អនភាវង្គមេន្តោតិ ឯកវិហារី ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ ។ បេ ។ សោ វុច្ចតិ សតោ ។ អប្បមត្តោតិ សក្កច្ចការី សាតច្ចការី អដ្ឋិតការី អនោលីនវុត្តី អនិក្ខិត្តច្ឆន្ទោ អនិក្ខិត្តធុរោ អប្បមត្តោ កុសលេសុ ធម្មេសុ កថាហំ អបរិបូរំ វា សីលក្ខន្ធំ បរិបូរេយ្យំ បរិបូរំ វា សីលក្ខន្ធំ តត្ថ[១] បញ្ញាយ អនុគ្គណ្ហេយ្យន្តិ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច អាតប្បំ បធានំ អធិដ្ឋានំ អនុយោគោ អប្បមាទោ កុសលេសុ ធម្មេសុ

១ ម. តត្ថ តត្ថ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

[១៧៧] អធិប្បាយពាក្យថា មានការនៅយ៉ាងនេះ មានសតិ អ្នកមិនប្រហែស ត្រង់ពាក្យថា មានការនៅយ៉ាងនេះ គឺភិក្ខុកាលលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវសេចក្តីត្រេកត្រអាលផង នូវសេចក្តីប្រកាន់ផង នូវវិញ្ញាណដែលប្រកបដោយអភិសង្ខារផង នូវកម្មភពផង នូវបុនព្ភពគឺបដិសន្ធិផង ហេតុនោះ (ទ្រង់ត្រាស់) ថា មានការនៅយ៉ាងនេះ ។ ពាក្យថា មានសតិ គឺបុគ្គលមានសតិដោយហេតុ ៤ គឺបុគ្គលចម្រើនកាយានុបស្សនាសតិប្បដ្ឋាន ក្នុងកាយ ។ បេ ។ បុគ្គលនោះលោកហៅថា អ្នកមានសតិ ។ ពាក្យថា អ្នកមិនប្រហែស គឺអ្នកធ្វើដោយគោរព អ្នកធ្វើមិនឈប់ អ្នកប្រព្រឹត្តមិនរួញរា មានបំណងមិនដាក់ចុះ មានធុរៈមិនដាក់ចុះ អ្នកមិនប្រហែសក្នុងកុសលធម៌ គឺបានខាងបំណង ការព្យាយាម សេចក្តីខ្មីឃ្មាត ការប្រឹងប្រែង ការមិនថយក្រោយ សតិនិងសម្បជញ្ញៈ ការខ្នះខ្នែង ការតម្កល់ទុក ការអធិដ្ឋាន ការប្រកបរឿយៗ ការមិនធ្វេសប្រហែស ក្នុងកុសលធម៌ទាំងនោះថា អង្កាល់ណា អាត្មាអញនឹងបំពេញសីលក្ខន្ធ ដែលមិនទាន់ពេញ ឬជ្រោមជ្រែងទុកនូវសីលក្ខន្ធ ដែលពេញហើយ ដោយប្រាជ្ញា ក្នុងធម៌នោះ

កាជាហំ[1] អបរិបូរំ វា សមាធិក្ខន្ធំ វិមុត្តិក្ខន្ធំ[2] វិមុ-ត្តិញាណទស្សនក្ខន្ធំ បរិបូរេយ្យំ បរិបូរំ វា វិមុត្តិញា-ណទស្សនក្ខន្ធំ តត្ថ បញ្ញាយ អនុគ្គណ្ហេយ្យន្តិ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញ-ញ្ច អាតប្បំ បធានំ អធិដ្ឋានំ អនុយោគោ អប្ប-មាទោ កុសលេសុ ធម្មេសុ កាជាហំ អបរិញ្ញាតំ[3] វា ទុក្ខំ បរិជានេយ្យំ[4] អប្បហីនេ វា កិលេសេ ជហេយ្យំ អភាវិតំ វា មគ្គំ ភាវេយ្យំ អសច្ឆិកាតំ វា និរោធំ សច្ឆិករេយ្យន្តិ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្ប-ដិវានី ច សតិ ច សម្បជញ្ញញ្ច អាតប្បំ បធានំ អធិដ្ឋានំ អនុយោគោ អប្បមាទោ កុសលេសុ ធម្មេសូតិ ឯវំវិហារី សតោ អប្បមត្តោ ។

[១៧៨] ភិក្ខុ ចរំ ហិត្វា មមាយិតានីតិ ភិក្ខូតិ កល្យាណបុថុជ្ជនោ វា ភិក្ខុ សេក្ខោ វា ភិក្ខុ ។

---

១ ម. កថាហំ ។ ២ ម. បញ្ចក្ខន្ធំ ។ ៣ ម. អភិញ្ញាតំ ។ ៤ ម. បរិញ្ញេយ្យំ ។

(ឬ) បំណង ការព្យាយាម សេចក្ដីខ្មីឃ្មាត សេចក្ដីប្រឹងប្រែង ការមិនថយក្រោយ សតិនិងសម្បជញ្ញៈ ការខ្នះខ្នែង ការតម្កល់ទុក ការអធិដ្ឋាន ការប្រកបរឿយៗ ការមិនធ្វេសប្រហែស ក្នុងកុសលធម៌ទាំងនោះថា អង្កាល់ណា អាត្មាអញនឹងបំពេញសមាធិក្ខន្ធ វិមុតិក្ខន្ធ វិមុត្តិញ្ញាណ-ទស្សនក្ខន្ធ ដែលមិនទាន់ពេញ នឹងជ្រោមជ្រែទុក នូវវិមុត្តិញ្ញាណ-ទស្សនក្ខន្ធ ដែលពេញហើយ ដោយបញ្ញា ក្នុងធម៌ទាំងនោះ (ឬក៏) បំណង ការព្យាយាម សេចក្ដីខ្មីឃ្មាត សេចក្ដីប្រឹងប្រែង ការមិនថយក្រោយ សតិនិងសម្បជញ្ញៈ ការខ្នះខ្នែង ការតម្កល់ទុក ការអធិដ្ឋាន ការប្រកបរឿយ ៗ ការមិនធ្វេសប្រហែស ក្នុងកុសលធម៌ទាំងនោះថា អង្កាល់ណា អាត្មាអញនឹងកំណត់ដឹងនូវទុក្ខ ដែលមិនទាន់បានកំណត់ដឹង ឬនឹងលះនូវកិលេសដែលមិនទាន់លះ នឹងចម្រើនមគ្គដែលមិនទាន់ចម្រើន នឹងធ្វើឲ្យជាក់ច្បាស់នូវនិរោធ ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (ទ្រង់ត្រាស់ថា) មានការនៅយ៉ាងនេះ មានសតិ អ្នកមិនប្រហែស ។

[១៧៨] ពាក្យថា ភិក្ខុ របស់បទថា ភិក្ខុលះបង់នូវសេចក្ដីប្រកាន់ហើយប្រព្រឹត្ត បានដល់ ភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខៈ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

ចរន្តិ ចរន្តោ វិចរន្តោ ឥរិយន្តោ វត្តេន្តោ បាលេន្តោ យបេន្តោ យាបេន្តោ ។ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តំ ច ទិដ្ឋិមមត្តំ ច ។ បេ ។ ឥទំ តណ្ហាមមត្តំ ។ បេ ។ ឥទំ ទិដ្ឋិមមត្តំ ។ តណ្ហាមមត្តំ បហាយ ទិដ្ឋិមមត្តំ បដិនិស្សជ្ជិត្វា មមត្តេ ហិត្វា បរិច្ចជិត្វា[1] វិនោទេត្វា ព្យន្តីកត្វា អនភាវង្គមេត្វាតិ ភិក្ខុ ចរំ ហិត្វា មមាយិតានិ ។

[១៧៩] ជាតិជ្ជរំ សោកបរិទ្ទវញ្ច ឥធេវ វិទ្វា បជហេយ្យ ទុក្ខន្តិ ជាតីតិ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ ។ ជរាតិ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ ។

១ ម. ជហិត្វា ចហិត្វា បជហិត្វា ។

ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ត្រួតត្រាមើល សម្រេច ទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ។ ពាក្យថា សេចក្ដីប្រកាន់ បានដល់ សេចក្ដីប្រកាន់ ២ គឺ សេចក្ដីប្រកាន់គឺតណ្ហា ១ សេចក្ដីប្រកាន់គឺទិដ្ឋិ ១ ។ បេ ។ នេះ សេចក្ដីប្រកាន់គឺតណ្ហា ។ បេ ។ នេះ សេចក្ដីប្រកាន់គឺទិដ្ឋិ ។ ភិក្ខុលះបង់ សេចក្ដីប្រកាន់គឺតណ្ហា រលាស់ចោល សេចក្ដីប្រកាន់គឺទិដ្ឋិ លះបង់ លះចោល បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវសេចក្ដីប្រកាន់ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុលះបង់សេចក្ដីប្រកាន់ ហើយប្រព្រឹត្ត ។

[១៧៩] អធិប្បាយពាក្យថា ជាអ្នកចេះដឹង គប្បីលះបង់ទុក្ខ គឺ ជាតិ ជរា សោកៈ និងបរិទេវៈ ក្នុងលោកនេះបាន ត្រង់ពាក្យថា ជាតិ បានដល់ កំណើត ការកើតព្រម ការចុះកាន់គភ៌ ការផ្ដួចផ្ដើមឡើង ការកើតឡើងចំពោះ ការប្រាកដឡើងនៃខន្ធ ការបានចំពោះអាយតនៈ នៃពួកសត្វនោះ ៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា ជរា បានដល់ ការចាស់ ការគ្រាំគ្រា ការរង្គោះធ្មេញ ការស្កូវសក់ ការជ្រួញជ្រីវស្បែក ការរួញថយនៃអាយុ ការចាស់ទុំនៃឥន្ទ្រិយ របស់ពួកសត្វនោះៗ ក្នុងសត្តនិកាយនោះ ៗ ។

សោកោតិ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិសោកោ អន្តោឌាហោ អន្តោបរិឌាហោ ចេតសោ បរិជ្ឈាយនា ទោមនស្សំ សោកសល្លំ ។ បរិទេវោតិ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ លាបោ បលាបោ វិប្បលាបោ លាលប្បោ លាលប្បាយនា លាលប្បាយិតត្តំ ។ ឥធាតិ ឥមិស្សា ទិដ្ឋិយា ។ បេ ។ ឥមស្មឹ មនុស្សលោកេ ។ វិទ្វាតិ វិទ្វា វិជ្ជាគតោ ញាណី វិភាវី មេធាវី ។

ពាក្យថា សោក គឺសោក អាការសោក ភាពនៃសោក ការស្ងួតស្ងប់ក្នុងសន្តាន ការស្រពោនក្នុងសន្តាន ការក្តៅក្នុងសន្តាន ការរោលរាលក្នុងសន្តាន អាការជាទីសញ្ជប់សញ្ជឹងចិត្ត ការអាក់អន់ចិត្ត សរគឺសោក របស់បុគ្គលដែលត្រូវវិនាសញាតិប៉ះពាល់ក្តី ត្រូវវិនាសភោគៈប៉ះពាល់ក្តី ត្រូវវិនាសគឺរោគប៉ះពាល់ក្តី ត្រូវវិនាសសីលប៉ះពាល់ក្តី ត្រូវវិនាស គឺទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយវិនាសណាមួយក្តី ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីខ្សឹកខ្សួល គឺការយំ ការខ្សឹកខ្សួល អាការយំ អាការខ្សឹកខ្សួល ភាពនៃការយំ ភាពនៃការខ្សឹកខ្សួល ការទួញរៀបរាប់ ការពោលរៀបរាប់ ការរៀបរាប់ដដែលៗ ការពោលរំលឹក អាការពោលរៀបរាប់ ភាពនៃការពោលរៀបរាប់ របស់បុគ្គល ដែលត្រូវវិនាសញាតិប៉ះពាល់ក្តី ត្រូវវិនាសភោគៈប៉ះពាល់ក្តី ត្រូវវិនាសគឺរោគប៉ះពាល់ក្តី ត្រូវវិនាសសីលប៉ះពាល់ក្តី ត្រូវវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយវិនាសណាមួយក្តី ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា ក្នុងលោកនេះ គឺក្នុងទិដ្ឋិនេះ ។ បេ ។ ក្នុងមនុស្សលោកនេះ ។ ពាក្យថា ជាអ្នកចេះដឹង បានដល់អ្នកចេះ អ្នកតាំងនៅក្នុងវិជ្ជា មានញាណ មានការឈ្វេងយល់ មានប្រាជ្ញាឆ្ពុះឆ្ពាយ ។

ទុក្ខន្តិ ជាតិទុក្ខំ ។ បេ ។ សោកបរិទេវទុក្ខទោ-មនស្សុបាយាសទុក្ខំ ។ ជាតិជរំ សោកបរិទ្ទវញ្ច ឥធេវ វិទ្វា បជហេយ្យ ទុក្ខន្តិ វិទ្វា វិជ្ជាគតោ ញាណី វិភាវី មេធាវី ឥធេវ ជាតិជរញ្ច សោក-បរិទ្ទវញ្ច បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យាតិ ជាតិជរំ សោកបរិទ្ទវញ្ច ឥធេវ វិទ្វា បជហេយ្យ ទុក្ខំ ។ តេនាហ ភគវា

ឯវំវិហារី សតោ អប្បមត្តោ
ភិក្ខុ ចរំ ហិត្វា មមាយិតានិ
ជាតិជរំ សោកបរិទ្ទវញ្ច
ឥធេវ វិទ្វា បជហេយ្យ ទុក្ខន្តិ ។

[១៨០] ឯតាភិនន្ទាមិ វចោ មហេសិនោ
សុកិត្តិតំ គោតម នូបធីកំ
អទ្ធា ហិ ភគវា បហាសិ ទុក្ខំ
តថា ហិ តេ វិទិតោ ឯស ធម្មោ ។

ពាក្យថា ទុក្ខ បានដល់ជាតិទុក្ខ ។ បេ ។ សោកបរិទេវទុក្ខទោមនស្សុ-បាយាសទុក្ខ ។ ពាក្យថា អ្នកចេះដឹង គប្បីលះបង់ទុក្ខ គឺជាតិ ជរា សោកៈ និងបរិទេវៈ ក្នុងលោកនេះ បានន័យថា បុគ្គលអ្នកចេះ អ្នកតាំងនៅក្នុងវិជ្ជា មានញាណ មានការឈ្វេងយល់ មានប្រាជ្ញាធ្លុះធ្លាយ គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យមានបែបភាព នូវជាតិនិងជរាផង សោកៈ និងបរិទេវៈផង ក្នុងលោកនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកចេះដឹង គប្បីលះបង់ទុក្ខ គឺជាតិ ជរា សោកៈនិងបរិទេវៈ ក្នុងលោកនេះ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ភិក្ខុមានការនៅយ៉ាងនេះ មានសតិ អ្នកមិនប្រហែស លះបង់
សេចក្ដីប្រកាន់ហើយប្រព្រឹត្ត ជាអ្នកចេះដឹង គប្បីលះបង់ នូវ
ទុក្ខ គឺជាតិ ជរា សោកៈ និងបរិទេវៈ ក្នុងលោកនេះបាន ។

[១៨០] (មេត្តគូមាណពទូលថា) ខ្ញុំព្រះអង្គត្រេកអរចំពោះព្រះ
វាចាទ្បុំះ របស់ព្រះមហេសី បពិត្រព្រះគោតម ព្រះនិព្វានជា
គុណជាត មិនមានឧបធិ ព្រះអង្គបានសម្ដែងហើយ ដោយ
ប្រពៃ ព្រះមានព្រះភាគ លះទុក្ខបានដោយពិត ព្រោះធម៌នុ៎ះ
ព្រះអង្គជ្រាបច្បាស់ហើយ ។

[១៨១] ឯតាភិជប្បាមិ វចោ មហេសិនោតិ ឯតន្តិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសដ្ឋី[១] ។ អភិជប្បាមីតិ ជប្បាមិ អភិជប្បាមិ មោទាមិ អនុមោទាមិ ឥច្ឆាមិ សាទិយាមិ យាចាមិ បត្ថយាមិ បិហយាមិ អភិជប្បាមិ ។ មហេសិនោតិ[២] ភគវា មហន្តំ សីលក្ខន្ធំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ បេ ។ កហំ នរាសភោតិ មហេសីតិ ឯតាភិជប្បាមិ វចោ មហេសិនោ ។

[១៨២] សុកិត្តិតំ គោតម នូបធីកន្តិ សុកិត្តិតន្តិ សុកិត្តិតំ សុអាចិក្ខិតំ សុទេសិតំ សុបញ្ញបិតំ សុបដ្ឋបិតំ សុវិវរិតំ សុវិភជិតំ សុឧត្តានីកតំ សុប្បកាសិតន្តិ សុកិត្តិតំ ។ គោតម នូបធីកន្តិ ឧបធិ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។

---

១ ម. អនុសិដ្ឋំ ។ ២ ម. មហេសិនោតិ មហេហិនោតិ មហេសី ។

[១៨១] ពាក្យថា ខ្ញុំព្រះអង្គត្រេកអរចំពោះព្រះវាចាទុំះ របស់ព្រះមហេសី ត្រង់ពាក្យថា ចំពោះព្រះវាចាទុំះ គឺចំពោះពាក្យ គន្ធងនៃពាក្យ ទេសនា អនុសន្ធិ របស់ព្រះអង្គ ។ ពាក្យថា ត្រេកអរចំពោះ គឺខ្ញុំព្រះអង្គស្រស់ស្រាយ ត្រេកអរ រីករាយ រីករាយតាម ប្រាថ្នា ចង់បាន សូម ត្រូវការ ស្រឡាញ់ ជាប់ចិត្ត ។ ពាក្យថា របស់ព្រះមហេសី គឺព្រះមានព្រះភាគ ទ្រង់ព្រះនាមមហេសី ព្រោះទ្រង់ស្វែង ស្វែងរក ស្វះស្វែងនូវសីលក្ខន្ធដ៏ធំ ។ បេ ។ ទ្រង់ព្រះនាមមហេសី ព្រោះព្រះអង្គជានរៈដ៏អង់អាច តាមតែក្នុងទីណា ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គត្រេកអរចំពោះព្រះវាចាទុំះ របស់ព្រះមហេសី ។

[១៨២] អធិប្បាយពាក្យថា បពិត្រព្រះគោតម ព្រះនិព្វានជាគុណជាតមិនមានឧបធិ ព្រះអង្គសម្តែងហើយដោយប្រពៃ ត្រង់ពាក្យថា ព្រះអង្គសម្តែងហើយដោយប្រពៃ គឺព្រះអង្គសម្តែងដោយល្អ ប្រាប់ដោយល្អ ពន្យល់ដោយល្អ សម្តែងដោយប្រពៃ បញ្ញត្តទុកដោយល្អ តាំងទុកដោយល្អ បើកដោយល្អ ចែកដោយល្អ ធ្វើឲ្យរាក់ដោយល្អ ប្រកាសទុកហើយដោយល្អ ហេតុនោះ (លោកពោលថា) ព្រះអង្គសម្តែងហើយដោយប្រពៃ ។ ពាក្យថា បពិត្រព្រះគោតម ព្រះនិព្វានជាគុណជាតមិនមានឧបធិ សេចក្តីថា ពួកកិលេស ខន្ធ និងអភិសង្ខារ លោកហៅថា ឧបធិ ។

ឧបធិប្បហានំ ឧបធិវូបសមំ ឧបធិប្បដិនិស្សគ្គំ ឧបធិប្បដិប្បស្សទ្ធឹ អមតំ និព្វានន្តិ សុកិត្តិតំ គោតម នូបធីកំ ។

[១៨៣] អទ្ធា ហិ ភគវា បហាសិ ទុក្ខន្តិ អទ្ធាតិ ឯកំសវចនំ និស្សំសយវចនំ និក្កង្ខាវចនំ អទ្វេជ្ឈវចនំ អទ្វេឡ្ហកវចនំ និយ្យានវចនំ អបណ្ណកវចនំ អវត្ថានវចនមេតំ អទ្ធាតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ បហាសិ ទុក្ខន្តិ ជាតិទុក្ខំ ជរាទុក្ខំ ព្យាធិទុក្ខំ មរណទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខំ បហាសិ បជហិ វិនោទេសិ ព្យន្តីករោសិ អនភាវង្គមេសីតិ អទ្ធា ហិ ភគវា បហាសិ ទុក្ខំ ។

[១៨៤] តថា ហិ តេ វិទិតោ ឯស ធម្មោតិ តថា ហិ តេ វិទិតោ ញាតោ តុលិតោ តីរិតោ វិភាវិតោ វិភូតោ ឯស ធម្មោតិ តថា ហិ តេ វិទិតោ ឯស ធម្មោ ។ តេនាហ សោ ព្រាហ្មណោ

ការលះឧបធិ ការរម្ងាប់ឧបធិ ការរលាស់ចោលឧបធិ ការស្ងប់រម្ងាប់ឧបធិ ឈ្មោះថា អមតនិព្វាន ហេតុនោះ (លោកពោលថា) បពិត្រព្រះគោតម ព្រះនិព្វានជាគុណជាតមិនមានឧបធិ ព្រះអង្គសម្តែងហើយដោយប្រពៃ ។

[១៨៣] អធិប្បាយពាក្យថា ព្រះមានព្រះភាគ ទ្រង់លះបង់ទុក្ខ ដោយពិត ត្រង់ពាក្យថា ដោយពិត គឺជាពាក្យដាច់ខាត ជាពាក្យឥត សង្ស័យ ជាពាក្យឥតងឿងឆ្ងល់ ជាពាក្យមិនបែកជាពីរ ជាពាក្យមិនមាន ចំពាមពីរ ជាពាក្យស្រោចស្រង់ ជាពាក្យមិនខុស ពាក្យថា ដោយពិត ជាពាក្យតាំងមាំ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយ គោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះ ការត្រាស់ដឹង ។ ពាក្យថា ទ្រង់លះទុក្ខ គឺលះបង់ លះចេញ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យមានបែបភាព នូវជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខ ហេតុនោះ (លោក សួរថា) ព្រះមានព្រះភាគ ទ្រង់លះទុក្ខបានដោយពិត ។

[១៨៤] ពាក្យថា ព្រោះធម៌នុ៎ះ ព្រះអង្គជ្រាបច្បាស់ហើយ គឺ ព្រោះធម៌នុ៎ះ ព្រះអង្គជ្រាបច្បាស់ ដឹង ថ្លឹង ពិចារណា ឈ្វេងយល់ ប្រាកដ ហេតុនោះ (លោកសួរថា) ព្រោះធម៌នុ៎ះព្រះអង្គជ្រាប ច្បាស់ហើយ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ឯតាភិនន្ទាមិ វចោ មហេសិនោ
សុកិត្តិតំ គោតម នូបធីកំ
អទ្ធា ហិ ភគវា បហាសិ ទុក្ខំ
តថា ហិ តេ វិទិតោ ឯស ធម្មោតិ ។

[១៨៥] តេ ចាបិ នូន បជហេយ្យុ ទុក្ខំ
យេ ត្វំ មុនី អដ្ឋិតំ ឱវទេយ្យ
តន្តំ នមស្សាមិ សមេច្ច នាគំ
អប្បេវ មំ ភគវា អដ្ឋិតំ ឱវទេយ្យ ។

[១៨៦] តេ ចាបិ នូន បជហេយ្យុ ទុក្ខន្តិ តេ ចាបីតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច បជហេយ្យុំ ។ ទុក្ខន្តិ ជាតិទុក្ខំ ជរាទុក្ខំ ព្យាធិទុក្ខំ មរណទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខំ បជហេយ្យុំ វិនោទេយ្យុំ ព្យន្តីករេយ្យុំ អនភាវង្គមេយ្យុន្តិ តេ ចាបិ នូន បជហេយ្យុ ទុក្ខំ ។

ខ្ញុំព្រះអង្គ ត្រេកអរចំពោះព្រះវាចាទ្រង់ របស់ព្រះមហេសី
បពិត្រព្រះគោតម ព្រះនិព្វាន ជាគុណជាតមិនមានឧបធិ
ព្រះអង្គសម្តែងហើយដោយប្រពៃ ព្រះមានព្រះភាគ លះ
ទុក្ខបានដោយពិត ព្រោះធម៌ទ្រង់ព្រះអង្គជ្រាបច្បាស់ហើយ ។

[១៨៥] បពិត្រព្រះមុនិ ព្រះអង្គទូន្មានពួកជនណា ដោយត្រឹមត្រូវ
ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត ព្រោះហេតុនោះ
ខ្ញុំព្រះអង្គចូលមក នមស្ការចំពោះព្រះអង្គ ជាព្រះពុទ្ធនាគ
សូមព្រះមានព្រះភាគទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ ។

[១៨៦] ពាក្យថា ពួកជនទាំងនោះ របស់បទថា ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត បានដល់ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ក៏លះបង់ (ទុក្ខបាន) ។ ពាក្យថា ទុក្ខ គឺ គប្បីលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខ ហេតុនោះ (លោកពោលថា) ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត ។

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៨៧] យេ ត្វំ មុនី អដ្ឋិតំ ឱវទេយ្យាតិ យេតិ ខត្តិយេ ច ព្រាហ្មណេ ច វេស្សេ ច សុទ្ទេ ច គហដ្ឋេ ច បព្វជិតេ ច ទេវេ ច មនុស្សេ ច ។ ត្វន្តិ ភគវន្តំ ភណតិ ។ មុនីតិ មោនំ វុច្ចតិ ញាណំ ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ អដ្ឋិតំ ឱវទេយ្យាតិ(១) សក្កច្ចំ ឱវទេយ្យ អភិណ្ហំ ឱវទេយ្យ បុនប្បុនំ ឱវទេយ្យ អនុសាសេយ្យាតិ យេ ត្វំ មុនី អដ្ឋិតំ ឱវទេយ្យ ។

[១៨៨] តន្តំ នមស្សាមិ សមេច្ច នាគន្តិ តន្តិ ភគវន្តំ ភណតិ ។ នមស្សាមីតិ កាយេន វា នមស្សាមិ ចិត្តេន វា នមស្សាមិ អន្វត្ថប្បដិបត្តិយា វា នមស្សាមិ ធម្មានុធម្មប្បដិបត្តិយា វា នមស្សាមិ សក្ករោមិ គរុករោមិ មានេមិ បូជេមិ ។ សមេច្ចាតិ សមេច្ច អភិសមេច្ច សមាគន្ត្វា អភិសមាគន្ត្វា សម្មុខា តំ នមស្សាមិ ។ នាគន្តិ នាគោ ។

១ ម. អដ្ឋិតំ ឱវទេយ្យាតិ អដ្ឋិតំ ឱវទេយ្យ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

[១៨៧] ពាក្យថា ណា របស់បទថា បពិត្រព្រះមុនិ ព្រះអង្គទូន្មានពួកជនណា ដោយត្រឹមត្រូវ បានដល់ ពួកជនជាក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតានិងមនុស្ស ។ ពាក្យថា ព្រះអង្គ គឺព្រាហ្មណ៍ពោលចំពោះព្រះមានព្រះភាគ ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ ។ បេ ។ ព្រះមុនិនោះកន្លងនូវបណ្តាញគឺកិលេសជាគ្រឿងជាប់ចំពាក់ ។ ពាក្យថា ទូន្មានដោយត្រឹមត្រូវ គឺគប្បីទូន្មាន ទូន្មានដោយគោរព ទូន្មានរឿយៗ ទូន្មានប្រៀនប្រដៅញយៗ ដាស់តឿន ហេតុនោះ (លោកពោលថា) បពិត្រព្រះមុនិ ព្រះអង្គទូន្មានពួកជនណា ដោយត្រឹមត្រូវ ។

[១៨៨] អធិប្បាយពាក្យថា ខ្ញុំព្រះអង្គចូលមក នមស្ការចំពោះព្រះអង្គជាព្រះពុទ្ធនាគ ត្រង់ពាក្យថា ចំពោះព្រះអង្គ គឺព្រាហ្មណ៍ពោលចំពោះព្រះមានព្រះភាគ ។ ពាក្យថា នមស្ការ គឺខ្ញុំព្រះអង្គសូមថ្វាយបង្គំដោយកាយក្តី ថ្វាយបង្គំដោយចិត្តក្តី ថ្វាយបង្គំដោយសេចក្តីប្រតិបត្តិដ៏សមគួរដល់អត្ថក្តី ថ្វាយបង្គំដោយសេចក្តីប្រតិបត្តិដ៏សមគួរដល់ធម៌ក្តី ធ្វើសក្ការៈ គោរព រាប់អាន បូជា ។ ពាក្យថា ចូលមក គឺខ្ញុំព្រះអង្គសំដៅមក សំដៅមកចំពោះ មកត្រង់ ឆ្ពោះមក នមស្ការព្រះអង្គចំពោះព្រះភក្ត្រ ពាក្យថា ព្រះពុទ្ធនាគ គឺព្រះមានព្រះភាគជាបុគ្គលដ៏ប្រសើរ ។

ភគវា អាគុំ ន ករោតីតិ នាគោ ។ ន គច្ឆតីតិ នាគោ ។ ន អាគច្ឆតីតិ នាគោ ។

កថំ ភគវា អាគុំ ន ករោតីតិ នាគោ ។ អាគូ វុច្ចន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា ពោនោព្ភវិកា សទរា[១] ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ។

អាគុំ ន ករោតិ កិញ្ចិ លោកេ
សព្វសំយោគេ វិសជ្ជ ពន្ធនានិ
សព្វត្ថ ន សជ្ជតី វិមុត្តោ
នាគោ តាទិ បវុច្ចតេ តថត្តាតិ ។

ឯវំ ភគវា អាគុំ ន ករោតីតិ នាគោ ។

---

១ ឱ. ម. នន្ទិរាគា ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនធ្វើអំពើអាក្រក់ ។ ព្រះនាមថា នាគ ព្រោះទ្រង់មិនលុះ ។ ព្រះនាមថា នាគ ព្រោះទ្រង់មិនមក ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគមិនធ្វើអំពើអាក្រក់ តើដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានផលជាទុក្ខ គួរដល់ជាតិ ជរា មរណៈតទៅ លោកពោលថា អំពើអាក្រក់ ។

ព្រះមានព្រះភាគ មិនធ្វើអំពើអាក្រក់ណាមួយ ក្នុងលោក
ទ្រង់ស្រាយចំណងគឺកិលេស ក្នុងការប្រកបទុកនូវសត្វទាំង
ពួង ព្រះអង្គរួចហើយ មិនជាប់ក្នុងអារម្មណ៍ទាំងពួង ព្រះ
អង្គជាបុគ្គលនឹងធឹង ទើបហៅថា នាគ ព្រោះព្រះអង្គជា
បុគ្គលទៀង ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនធ្វើអំពើអាក្រក់យ៉ាងនេះឯង ។

១៦១

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

កថំ ភគវា ន គច្ឆតីតិ នាគោ ។ ភគវា ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ន រាគវសេន គច្ឆតិ ន ទោសវសេន គច្ឆតិ ន មោហវសេន គច្ឆតិ ន ទិដ្ឋិវសេន គច្ឆតិ ន មានវសេន គច្ឆតិ ន ឧទ្ធច្ចវសេន គច្ឆតិ ន វិចិកិច្ឆាវសេន គច្ឆតិ ន អនុសយវសេន គច្ឆតិ ន វគ្គេហិ ធម្មេហិ យាយតិ និយ្យតិ វុយ្ហតិ សំហរិយតិ ឯវំ ភគវា ន គច្ឆតីតិ នាគោ ។

កថំ ភគវា ន អាគច្ឆតីតិ នាគោ ។ សោតាបត្តិមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតិ សកនាគាមិមគ្គេន អនាគាមិមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតិ អរហត្តមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតិ

មេត្តគូមាណវកប្បញ្ហានិទ្ទេស

ព្រះនាមថា នាគ ព្រោះទ្រង់មិនលុះ តើដូចម្តេច ។ ព្រះមានព្រះភាគមិនលុះឆន្ទាគតិ មិនលុះទោសាគតិ មិនលុះមោហាគតិ មិនលុះភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ គឺព្រះអង្គមិនទៅ មិនឃ្លាត មិនរសាត់ មិនដោយតាមធម៌ជាពួកទាំងឡាយ ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនលុះ យ៉ាងនេះឯង ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគ មិនមក តើដូចម្តេច ។ កិលេសទាំងឡាយណា ដែលព្រះអង្គលះហើយ ដោយសោតាបត្តិមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មក កាន់កិលេសទាំងនោះវិញ កិលេសទាំងឡាយណា ដែលព្រះអង្គលះហើយ ដោយសកទាគាមិមគ្គ អនាគាមិមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មក កាន់កិលេសទាំងនោះវិញ កិលេសទាំងឡាយណា ដែលព្រះអង្គលះហើយ ដោយអរហត្តមគ្គ ព្រះអង្គមិនមក មិនបែរមក មិនត្រឡប់មក កាន់កិលេសទាំងនោះវិញទេ

ឯវំ ភគវា ន អាគច្ឆតីតិ ជាតោតិ តន្តំ នមស្សាមិ សមេច្ច ជាតំ ។

[១៨៩] អប្បេវ មំ ភគវា អដ្ឋិតំ ឱវទេយ្យាតិ អប្បេ-វ មំ ភគវា អដ្ឋិតំ ឱវទេយ្យ សក្កច្ចំ ឱវទេយ្យ អ-ភិណ្ហំ ឱវទេយ្យ បុនប្បុនំ ឱវទេយ្យ អនុសាសេយ្យាតិ អប្បេវ មំ ភគវា អដ្ឋិតំ ឱវទេយ្យ ។ តេនាហ សោ ព្រាហ្មណោ

តេ ចាបិ នូន បជហេយ្យ ទុក្ខំ
យេ ត្វំ មុនី អដ្ឋិតំ ឱវទេយ្យ
តន្តំ នមស្សាមិ សមេច្ច ជាតំ
អប្បេវ មំ ភគវា អដ្ឋិតំ ឱវទេយ្យាតិ ។

[១៩០] យំ ព្រាហ្មណំ វេទគុំ អភិជញ្ញា
អកិញ្ចនំ កាមភវេ អសត្តំ
អទ្ធា ហិ សោ ឱឃមិមំ អតារិ
តិណ្ណោ ច បារំ អខិលោ អកង្ខោ ។

ព្រះនាមថា នាគ ព្រោះព្រះមានព្រះភាគមិនមក យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គ ចូលមកនមស្ការ ព្រះអង្គជាព្រះពុទ្ធនាគ ។

[១៨៩] ពាក្យថា សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ គឺសូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវ សូមទូន្មានដោយគោរព ទូន្មានរឿយៗ ទូន្មាន ប្រៀនប្រដៅញយៗ ហេតុនោះ (លោកពោលថា) សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ ។ ហេតុនោះ ព្រាហ្មណ៍ពោលថា

បពិត្រព្រះមុនិ ព្រះអង្គទូន្មានពួកជនណា ដោយត្រឹមត្រូវ ពួកជនទាំងនោះ ក៏លះទុក្ខបានដោយពិត ព្រោះហេតុនោះ ខ្ញុំព្រះអង្គចូលមក នមស្ការចំពោះព្រះអង្គ ជាព្រះពុទ្ធនាគ សូមព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គ ដោយត្រឹមត្រូវចុះ ។

[១៩០] (ព្រះមានព្រះភាគត្រាស់តបថា) បុគ្គលគប្បីដឹងច្បាស់នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព ព្រាហ្មណ៍នោះ ឈ្មោះថា បានឆ្លងឱឃៈនេះ ដោយពិត ទាំងឆ្លងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្តីសង្ស័យ ។

១៦៣

## មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

[១៩១] យំ ព្រាហ្មណំ វេទគុំ អភិជញ្ញាតិ ព្រាហ្មណាន្តិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ ។ សក្កាយទិដ្ឋិ ពាហិតា ហោតិ វិចិកិច្ឆា ពាហិតា ហោតិ សីលព្វតបរាមាសោ ពាហិតោ ហោតិ រាគោ ពាហិតោ ហោតិ ទោសោ ពាហិតោ ហោតិ មោហោ ពាហិតោ ហោតិ មានោ ពាហិតោ ហោតិ ។ ពាហិតស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណិយា ។

ពាហេត្វា សព្វបាបកានិ (សភិយាតិ ភគវា)
ភគវា វិមលោ សាធុសមាហិតោ ឋិតត្តោ[១]
សំសារមតិច្ច កេវលី សោ
អនិស្សិតោ តាទិ បវុច្ចតេ ព្រហ្មា ។

វេទគូតិ វេទោ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ ។ បេ ។ សព្វវេទមតិច្ច វេទគូ សោតិ ។ អភិជញ្ញាតិ អភិជានេយ្យ អាជានេយ្យ វិជានេយ្យ បដិវិជានេយ្យ បដិវិជ្ឈេយ្យាតិ យំ ព្រាហ្មណំ វេទគុំ អភិជញ្ញា ។

១ ម. ជិតត្តោ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

[១៩១] អធិប្បាយពាក្យថា បុគ្គលគប្បីដឹងច្បាស់ នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ ត្រង់ពាក្យថា ព្រាហ្មណ៍ សេចក្ដីថា ដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌ ៧ ។ គឺបន្សាត់បង់សក្កាយទិដ្ឋិ បន្សាត់បង់វិចិកិច្ឆា បន្សាត់បង់សីលព្វតបរាមាសៈ បន្សាត់បង់រាគៈ បន្សាត់បង់ទោសៈ បន្សាត់បង់មោហៈ បន្សាត់បង់មានះ ។ លោកបានលះបង់ នូវអកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្ដីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានផលជាទុក្ខ ជាទីតាំងនៃជាតិ ជរា មរណៈតទៅ ។

(ព្រះមានព្រះភាគត្រាស់ថា ម្នាលសភិយៈ) ព្រះមានព្រះភាគ
បន្សាត់បង់នូវបាបទាំងពួង ជាបុគ្គលប្រាសចាកមន្ទិល មាន
ព្រះហឫទ័យតម្កល់នៅដោយល្អ មានខ្លួនខ្ជាប់ខ្ជួន ព្រះមាន
ព្រះភាគនោះ ជាបុគ្គលបរិសុទ្ធ កន្លងនូវសំសារ មិនអាស្រ័យ
(តណ្ហានិងទិដ្ឋិ) ជាបុគ្គលនឹងធឹង លោកហៅថា ព្រាហ្មណ៍ ។

ពាក្យថា អ្នកដល់នូវវេទ សេចក្ដីថា ញាណក្នុងមគ្គ ៤ លោកហៅថា វេទ ។ បេ ។ បុគ្គលនោះដល់នូវវេទ កន្លងនូវវេទទាំងពួង ។ ពាក្យថា គប្បីដឹងច្បាស់ គឺគប្បីដឹងចំពោះ ដឹងទូទៅ ដឹងវិសេស ដឹងច្បាស់ យល់ច្បាស់ ហេតុនោះ (ទ្រង់ត្រាស់ថា) គប្បីដឹងច្បាស់នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ ។

[១៩២] អភិញ្ញេយ្យំ កាមភវេ អសត្តន្តិ អភិញ្ញេ-ជន្តិ រាគាភិញ្ញេយ្យំ ទោសាភិញ្ញេយ្យំ មោហាភិញ្ញេយ្យំ មា-នាភិញ្ញេយ្យំ ទិដ្ឋាភិញ្ញេយ្យំ កិលេសាភិញ្ញេយ្យំ ទុច្ចរិតាភិញ្ញេ-យ្យំ ។ យស្សេតេ អភិញ្ញា បហីនា សមុច្ឆិន្នា វូប-សន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ អភិញ្ញេជោ ។ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ ភវាតិ ទ្វេ ភវា កម្មភវោ ច បដិសន្ធិកោ ច បុនព្ភវោ ។ បេ ។ អយំ កម្ម-ភវោ ។ បេ ។ អយំ បដិសន្ធិកោ បុនព្ភវោ ។ អ-ភិញ្ញេយ្យំ កាមភវេ អសត្តន្តិ អភិញ្ញេយ្យំ[១] កាមភវេ អសត្តំ អលគ្គំ អលគ្គិតំ អបលិពុទ្ធន្តិ[២] អភិញ្ញេយ្យំ កាមភវេ អសត្តំ ។

[១៩៣] អទ្ធា ហិ សោ ឱឃមិមំ អតារីតិ អទ្ធាតិ ឯកំសវចនំ ។ បេ ។ អវត្ថានវចនមេតំ អទ្ធាតិ ។

---

១ ម. អភិញ្ញេនំ បុគ្គលំ ។ ២ ម. ឯត្តន្តរេ និក្ខន្តំ និស្សដំ វិប្បមុត្តំ វិសញ្ញុត្តំ វិមរិយាទិកតេន ចេតសា វិហរន្តន្តីតិ ទិស្សតិ ។

[១៩២] អធិប្បាយពាក្យថា អ្នកមិនមានកង្វល់ មិនជាប់នៅ ក្នុងកាមភព ត្រង់ពាក្យថា អ្នកមិនមានកង្វល់ សេចក្តីថា កង្វល់គឺរាគៈ កង្វល់គឺទោសៈ កង្វល់គឺមោហៈ កង្វល់គឺមានះ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត ។ គ្រឿងកង្វល់ទាំងឡាយនុ៎ះ ព្រះខីណាស្រពណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ព្រះខីណាស្រពនោះ លោកហៅថា អ្នកមិនមានកង្វល់ ។ ពាក្យថា កាម បើតាមឧទ្ទានបានដល់ កាម ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះ ហៅថា វត្ថុកាម ។ បេ ។ នេះ ហៅថា កិលេសកាម ។ ពាក្យថា ភព បានដល់ភព ២ គឺ កម្មភព ១ បុនព្ភពគឺបដិសន្ធិ ១ ។ បេ ។ នេះ កម្មភព ។ បេ ។ នេះ បុនព្ភពគឺបដិសន្ធិ ។ ពាក្យថា អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព គឺអ្នកមិនមានកង្វល់ មិនជាប់នៅ មិនជ្លក់នៅ មិនស្អិតនៅ មិនចាក់កណ្តាញ់នៅ ក្នុងកាមភព ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមិនមានកង្វល់ មិនជាប់នៅ ក្នុងកាមភព ។

[១៩៣] ពាក្យថា ព្រាហ្មណ៍នោះ ឈ្មោះថា បានឆ្លងឱឃៈនេះ ដោយពិត ត្រង់ពាក្យថា ដោយពិត គឺជាពាក្យដាច់ខាត ។ បេ ។ ពាក្យថា ដោយពិត នុ៎ះ ជាពាក្យប្រាកដ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

ឱឃន្តិ កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ ។ អតារីតិ អតារិ ឧត្តរិ បតរិ សមតិក្កមិ វីតិវត្តីតិ អទ្ធា ហិ សោ ឱឃមិមំ អតារិ ។

[១៩៤] តិណ្ណោ ច បារំ អខិលោ អកង្ខោតិ តិណ្ណោតិ កាមោឃំ តិណ្ណោ ភវោឃំ តិណ្ណោ ទិដ្ឋោឃំ តិណ្ណោ អវិជ្ជោឃំ តិណ្ណោ ឧត្តិណ្ណោ និត្តិណ្ណោ អតិក្កន្តោ វីតិវត្តោ សោ វុដ្ឋវាសោ ចិណ្ណចរណោ គតទ្ធោ គតទិសោ គតកោដិកោ បាលិតព្រហ្មចរិយោ ឧត្តមទិដ្ឋិប្បត្តោ ភាវិតមគ្គោ បហីនក្កិលេសោ បដិវិទ្ធាកុប្បោ សច្ឆិកតនិរោធោ ។ ទុក្ខំ តស្ស បរិញ្ញាតំ សមុទយោ បហីនោ មគ្គោ ភាវិតោ និរោធោ សច្ឆិកតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ សច្ឆិកាតព្វំ សច្ឆិកតំ ។

ពាក្យថា ឱឃៈ បានដល់ ឱឃៈគឺកាម ឱឃៈគឺភព ឱឃៈគឺទិដ្ឋិ ឱឃៈគឺអវិជ្ជា ។ ពាក្យថា បានឆ្លង គឺបានឆ្លងឡើង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះ ឈ្មោះថា បានឆ្លងឱឃៈនេះ ដោយពិត ។

[១៩៤] អធិប្បាយពាក្យថា ទាំងឆ្លងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្តីងឿងឆ្ងល់ ត្រង់ពាក្យថា ឆ្លង គឺព្រាហ្មណ៍ណាឆ្លងកាមោឃៈ ឆ្លងភវោឃៈ ឆ្លងទិដ្ឋោឃៈ ឆ្លងអវិជ្ជោឃៈ ឆ្លងឡើង ឆ្លងចេញ កន្លង ប្រព្រឹត្តកន្លង ព្រាហ្មណ៍នោះ ឈ្មោះថាជាអ្នកមានព្រហ្មចរិយធម៌អប់រំហើយ មានចរណធម៌ប្រព្រឹត្តហើយ មានកាលវែងកន្លងហើយ មានទិសគឺនិព្វានដល់ហើយ មានទីបំផុតដល់ហើយ មានព្រហ្មចរិយធម៌រក្សាហើយ ដល់នូវសម្មាទិដ្ឋិដ៏ឧត្តម មានមគ្គចម្រើនហើយ មានកិលេសលះបង់ហើយ មានអកុប្បធម៌ត្រាស់ដឹងហើយ មាននិរោធធម៌ធ្វើឲ្យជាក់ច្បាស់ហើយ ។ ព្រះអរិយបុគ្គលនោះ កំណត់ដឹងទុក្ខហើយ លះបង់សមុទយៈហើយ ចម្រើនមគ្គហើយ ធ្វើឲ្យជាក់ច្បាស់នូវនិរោធហើយ ត្រាស់ដឹងនូវគុណជាត ដែលគប្បីត្រាស់ដឹង កំណត់ដឹងទុក្ខដែលគប្បីកំណត់ដឹង លះបង់នូវកិលេសជាតដែលគប្បីលះ ចម្រើននូវធម្មជាតដែលគប្បីចម្រើន ធ្វើឲ្យជាក់ច្បាស់នូវគុណជាតដែលគប្បីធ្វើឲ្យជាក់ច្បាស់ ។

សោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិក្ខោ អព្ពូឡ្ហេសិកោ និ-
រគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ វិសំយុត្តោ បញ្ចង្គ-
វិប្បហីនោ ឆឡង្គសមន្នាគតោ ឯការក្ខោ ចតុរាប-
ស្សេនោ បនុណ្ណប្បច្ចេកសច្ចោ សមវាយសដ្ឋេសនោ
អនាវិលសង្កប្បោ បស្សទ្ធកាយសង្ខារោ សុវិមុត្តចិត្តោ
សុវិមុត្តប្បញ្ញោ កេវលី វុសិតវា ឧត្តមបុរិសោ បរមបុរិ-
សោ បរមប្បត្តិប្បត្តោ ។ សោ នេវ អាចិនាតិ ន អបចិនា-
តិ អបចិនិត្វា ឋិតោ នេវ បជហាតិ ន ឧបាទិយតិ បជហិ-
ត្វា ឋិតោ នេវ វិសិនេតិ ន ឧស្សិនេតិ វិសិនេត្វា ឋិតោ
នេវ វិធូបេតិ ន សន្ធូបេតិ ធូបេត្វា ឋិតោ អសេក្ខេន
សីលក្ខន្ធេន សមន្នាគតត្តា ឋិតោ អសេក្ខេន សមា-
ធិក្ខន្ធេន អសេក្ខេន បញ្ញាក្ខន្ធេន អសេក្ខេន វិមុត្តិ-
ក្ខន្ធេន អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន
សមន្នាគតត្តា ឋិតោ សច្ចំ[១] បដិបាទយិត្វា[២] ឋិតោ

---

១ ម. សច្ចន្តិ អដ្ឋកថាយំ ទិស្សតិ ។ ២ ម. សំបដិបាទិយិត្វា ។

ព្រះអរិយបុគ្គលនោះ មានសសរគោល (គឺអវិជ្ជា) ដកចេញហើយ មានស្នាមភ្លោះគឺសំសារលុបចោលហើយ មានសសរគឺតណ្ហាដកចេញហើយ មានសន្ទះទ្វារគឺនីវរណៈបើកចេញហើយ មានទង់គឺមានះដកចេញហើយ មានភារៈដាក់ចេញហើយ ជាអ្នកប្រាសចាក (វដ្តៈ) ជាអ្នកមានអង្គ ៥ លះបង់ហើយ ជាអ្នកប្រកបដោយអង្គ ៦ មានការរក្សាតែមួយគឺសតិ មានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាង មានសច្ចធម៌ផ្សេងបន្ទោបង់ហើយ មានការស្វែងរកទាំងអស់លះបង់ហើយ មានការត្រិះរិះមិនល្អក់ មានកាយសង្ខារស្ងប់រម្ងាប់ មានចិត្តរួចស្រឡះដោយប្រពៃ មានប្រាជ្ញារួចស្រឡះប្រពៃ ជាបុគ្គលបរិសុទ្ធ មានព្រហ្មចរិយធម៌ប្រព្រឹត្តចប់ហើយ ជាឧត្តមបុរស ជាបរមបុរស ជាអ្នកដល់នូវគុណជាតជាគ្រឿងដល់ដ៏ក្រៃលែង ។ អរិយបុគ្គលនោះ មិនសន្សំ មិនប្រមូល ឈ្មោះថាខ្ជាប់ខ្ជួនព្រោះមិនប្រមូល មិនលះបង់ មិនប្រកាន់ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះលះបង់ មិនចាក់ស្រេះ មិនក្រអឺតក្រអោង ឈ្មោះថាអ្នកខ្ជាប់ខ្ជួនព្រោះលែងចាក់ស្រេះ មិនលត់ មិនបង្កាត់ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះរលត់ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ ដោយបញ្ញាខន្ធជាអសេក្ខៈ ដោយវិមុត្តិក្ខន្ធជាអសេក្ខៈ ដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះសម្រេចនូវកិច្ចទាំងពួង

១៦៧



ឯវំ សមតិក្កមិត្វា ឋិតោ កិលេសក្តី បរិយាទយិត្វា ឋិតោ អបរិគមនតាយ ឋិតោ កដំ(១) សមាទាយ ឋិ-តោ វិមុត្តិប្បដិសេវនតាយ ឋិតោ មេត្តាយ ចារិសុទ្ធិយា ឋិតោ ករុណាយ មុទិតាយ ឧបេក្ខាយ ចារិសុទ្ធិ-យា ឋិតោ អច្ចន្តចារិសុទ្ធិយា ឋិតោ អកម្មញ្ញតាយ(២) ឋិតោ វិមុត្តត្តា ឋិតោ សន្តចិត្តតាយ ឋិតោ ខន្ធបរិ-យន្តេ ឋិតោ ធាតុបរិយន្តេ ឋិតោ អាយតនបរិយន្តេ ឋិតោ គតិបរិយន្តេ ឋិតោ ឧបបត្តិបរិយន្តេ ឋិតោ បដិ-សន្ធិបរិយន្តេ ឋិតោ ភវបរិយន្តេ ឋិតោ សំសារបរិ-យន្តេ ឋិតោ វដ្តបរិយន្តេ ឋិតោ អន្តិមភវេ ឋិតោ អន្តិ-មសមុស្សយេ ឋិតោ អន្តិមទេហធរោ អរហា ។

តស្សាយំ បច្ឆិមកោ ភវោ ចរិមោយំ សមុស្សយោ
ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ។

---

១ ម. កុដន្តិ អ.ទិ ។ ២ ម. អកម្មយតាយាតិ ភវិតព្វំ ។ អកម្មយតាយាតិ តណ្ហា ទិដ្ឋិ មានា កម្មយាតិ វុច្ចន្តិ តេសំ អភាវោ អកម្យតា ។ កាមសុត្តនិទ្ទេសវណ្ណនាយំ ។

ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះកន្ទង(តណ្ហា) យ៉ាងនេះ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះរំលត់ភ្លើងគឺកិលេស ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះកិរិយាមិនត្រឡប់មកវិញ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះកាន់យកនូវជ័យជម្នះ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះកិរិយាសេពនូវវិមុត្តិ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះការបរិសុទ្ធដោយមេត្តា ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះការបរិសុទ្ធដោយករុណា មុទិតា ឧបេក្ខា ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះសេចក្តីបរិសុទ្ធដ៏ក្រៃលែង ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះភាពនៃលោក មិនគួរដល់ការងារ[១] ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះលោករួចស្រឡះ ឈ្មោះថាអ្នកខ្ជាប់ខ្ជួន ព្រោះភាពនៃលោកមានចិត្តស្ងប់ ឈ្មោះថាអ្នកខ្ជាប់ខ្ជួនក្នុងទីបំផុតខន្ធ ខ្ជាប់ខ្ជួនក្នុងទីបំផុតធាតុ ខ្ជាប់ខ្ជួនក្នុងទីបំផុតអាយតនៈ ខ្ជាប់ខ្ជួនក្នុងទីបំផុតគតិ ខ្ជាប់ខ្ជួនក្នុងទីបំផុតការកើត ខ្ជាប់ខ្ជួនក្នុងទីបំផុតបដិសន្ធិ ខ្ជាប់ខ្ជួនក្នុងទីបំផុតភព ខ្ជាប់ខ្ជួនក្នុងទីបំផុតសំសារ ខ្ជាប់ខ្ជួនក្នុងទីបំផុតវដ្ដៈ ខ្ជាប់ខ្ជួនក្នុងភពទីបំផុត ខ្ជាប់ខ្ជួនក្នុងរាងកាយជាទីបំផុត ឈ្មោះថាព្រះអរហន្តទ្រទ្រង់នូវអត្តភាពជាទីបំផុត ។

ភពនេះនៃព្រះអរហន្តនោះ ចាត់ថាមានក្នុងទីបំផុត រាងកាយ
នេះ ចាត់ថាមានជាខាងក្រោយបង្អស់ ភពថ្មីគឺការអន្ទោល
ទៅដោយជាតិ ជរា និងមរណៈ នៃព្រះអរហន្តនោះមិនមាន ។

---

១ ពាក្យថា ការងារ ក្នុងទីនេះ បានដល់ តណ្ហា ទិដ្ឋិ មានៈ ។ អដ្ឋកថា ។

តិណ្ណោ ច ចារន្តិ ចារំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ ត-ណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ សោ ចារ-គតោ ចារប្បត្តោ អន្តគតោ អន្តប្បត្តោ កោដិគតោ កោដិប្បត្តោ បរិយន្តគតោ បរិយន្តប្បត្តោ វោសាន-គតោ វោសានប្បត្តោ តាណគតោ តាណប្បត្តោ លេណគតោ លេណប្បត្តោ សរណគតោ សរណ-ប្បត្តោ អភយគតោ អភយប្បត្តោ អច្ចុតគតោ អច្ចុ-តប្បត្តោ អមតគតោ អមតប្បត្តោ និព្វានគតោ និព្វា-នប្បត្តោ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។ ជា-តិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ តិណ្ណោ ច ចារំ ។ អខិលោតិ រាគោ ខិលោ ទោសោ ខិលោ មោហោ ខិលោ កោធោ ខិលោ ឧបនាហោ ខិលោ ។ បេ ។ សព្វាកុសលាភិសង្ខារា ខិលា ។

ពាក្យថា ទាំងឆ្ងងដល់ត្រើយ សេចក្តីថា អមតនិព្វាន លោកហៅថា ត្រើយ បានដល់ ការរម្ងាប់នូវសង្ខារទាំងពួង ការរលាស់ចេញនូវឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ទីរលត់ និព្វាន ។ ព្រះអរហន្តនោះ ទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ខាងចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីចប់ ដល់ទីចប់ ទៅកាន់ទីពំនាក់ ដល់ទីពំ-នាក់ ទៅកាន់ទីជ្រកកោន ដល់ទីជ្រកកោន ទៅកាន់ទីពឹង ដល់ទីពឹង ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីមិនច្យុត ដល់ទីមិនច្យុត ទៅកាន់អមតៈ ដល់អមតៈ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន ព្រះអរហន្តនោះ មានការអប់រំនៅស្រេចហើយ មានចរណ-ធម៌ប្រព្រឹត្តហើយ ។ បេ ។ ភពថ្មីគឺការអន្ទោលទៅ ដោយជាតិជរានិងមរណៈរបស់ព្រះអរហន្តនោះមិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងឆ្លងទៅដល់ត្រើយ ។ ពាក្យថា មិនមានបង្គោល សេចក្តីថា បង្គោលគឺរាគៈ បង្គោលគឺទោសៈ បង្គោលគឺមោហៈ បង្គោលគឺកោធៈ បង្គោលគឺឧបនាហៈ ។ បេ ។ បង្គោលគឺការតាក់តែងអកុសលទាំងពួង ។

១៦៩

## មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

យស្សេតេ ខិលា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ អខិលោ ។ អកង្ខោតិ ទុក្ខេ កង្ខា ទុក្ខសមុទយេ កង្ខា ទុក្ខនិរោធេ កង្ខា ទុក្ខនិរោ-ធគាមិនិយា បដិបទាយ កង្ខា បុព្វន្តេ កង្ខា អបរន្តេ កង្ខា បុព្វន្តាបរន្តេ កង្ខា ឥទប្បច្ចយ-តាបដិច្ចសមុប្បន្នេសុ ធម្មេសុ កង្ខា យា ឯវរូបា កង្ខា កង្ខាយនា កង្ខាយិតត្តំ វិមតិ វិចិកិច្ឆា ទ្វេឡ្ហកំ ទ្វេធាបថោ សំសយោ អនេកំសគ្គាហោ អាសប្បនា បរិសប្បនា អបរិយោគាហនា ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ ។ យស្សេតា កង្ខា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចត្តិ អកង្ខោតិ តិណ្ណោ ច ចារំ អខិលោ អកង្ខោ ។ តេនាហ ភគវា

បង្គោលទាំងនោះ ព្រះអរហន្តណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ព្រះអរហន្តនោះ លោកហៅថា អ្នកមិនមានបង្គោល ។ ពាក្យថា មិនមានសេចក្តីងឿងឆ្ងល់ សេចក្តីថា ការងឿងឆ្ងល់ក្នុងទុក្ខ ការងឿងឆ្ងល់ក្នុងសមុទយ ការងឿងឆ្ងល់ក្នុងទុក្ខនិរោធ ការងឿងឆ្ងល់ក្នុងទុក្ខនិរោធគាមិនីបដិបទា ការងឿងឆ្ងល់ក្នុងទីបំផុតខាងដើម ការងឿងឆ្ងល់ក្នុងទីបំផុតខាងចុង ការងឿងឆ្ងល់ ក្នុងទីបំផុតខាងដើមនិងខាងចុង ការងឿងឆ្ងល់ក្នុងធម៌ទាំងឡាយ ដែលកើតឡើង ព្រោះអាស្រ័យឥទប្បច្ច័យ គឺបានដល់សេចក្តីងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពនៃសេចក្តីងឿងឆ្ងល់ ការប្រាសចាកគំនិត សេចក្តីសង្ស័យ ហេតុបែកជាពីរ ផ្លូវបែកជាពីរ ការអល់ឯក ការកាន់យកច្រើនយ៉ាង ការកន្ទះរា ការអង្អឹអង្អែ ការមិនចុះស៊ប់ ភាពនៃចិត្តស្ទន់ស្ទោ ការប្រេះឆានៃចិត្ត មានសភាពយ៉ាងនេះ ។ សេចក្តីងឿងឆ្ងល់ទាំងនុ៎ះ ព្រះអរហន្តណា បានលះបង់ ផ្តាច់ផ្តិល ស្ងប់រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ព្រះអរហន្តនោះ លោកពោលថា អ្នកមិនមានសេចក្តីងឿងឆ្ងល់ ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងឆ្លងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្តីងឿងឆ្ងល់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

យំ ព្រាហ្មណំ វេទគុំ អភិជញ្ញា
អកិញ្ចនំ កាមភវេ អសត្តំ
អទ្ធា ហិ សោ ឱឃមិមំ អតារិ
តិណ្ណោ ច បារំ អខិលោ អកង្ខោតិ ។

[១៩៥] វិទ្វា ច យោ វេទគូ នរោ ឥធ
ភវាភវេ សង្គមិមំ វិសជ្ជ
សោ វីតតណ្ហោ អនីឃោ និរាសោ
អតារិ សោ ជាតិជរន្តិ ព្រូមិ ។

[១៩៦] វិទ្វា ច យោ វេទគូ នរោ ឥធាតិ វិជ្ជាគតោ ញាណី វិភាវី មេធាវី ។ យោតិ យោ យាទិសោ ។ បេ ។ មនុស្សោ[១] វា ។ វេទគូតិ វេទោ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ ។ បេ ។ សព្វវេទមតិច្ច វេទគូ សោតិ ។ នរោតិ សត្តោ នរោ មាណវោ បោសោ បុគ្គលោ ជីវោ ជាតុ ជន្តុ ឥន្ទគូ មនុជោ ។ ឥធាតិ ឥមិស្សា ទិដ្ឋិយា ។ បេ ។ ឥមស្មឹ មនុស្ស-លោកេតិ វិទ្វា ច យោ វេទគូ នរោ ឥធ ។

១ ម. យោតិ យោ យាទិសោ ។ បេ ។ មនុស្សោ វាតិ នត្ថិ ។

បុគ្គលគប្បីដឹងច្បាស់ នូវព្រាហ្មណ៍ណា ដែលជាអ្នកដល់នូវវេទ អ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព ព្រាហ្មណ៍នោះ ឈ្មោះថា បានឆ្លងឱឃៈនេះ ដោយពិត ទាំងឆ្លងដល់ត្រើយ ជាអ្នកមិនមានបង្គោល មិនមានសេចក្តីងឿងឆ្ងល់ ។

[១៩៥] នរៈណា ជាអ្នកចេះដឹង អ្នកដល់នូវវេទ ក្នុងលោកនេះ បាន ស្រាយនូវការជាប់ចំពាក់នេះ ក្នុងភពតូចនិងភពធំ តថាគតពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមាន សេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ បានឆ្លងនូវជាតិនិងជរា ។

[១៩៦] ពាក្យថា នរៈណា ជាអ្នកចេះដឹង អ្នកដល់នូវវេទក្នុង លោកនេះ សេចក្តីថា នរៈដែលសម្រេចវិជ្ជា មានញាណ មានការឃើញ យល់ មានប្រាជ្ញាផ្ទុះផ្ទាយ (ឈ្មោះថា ជាអ្នកចេះដឹង) ។ ពាក្យថា ណា គឺ អ្នកណា បែបណា ។ បេ ។ ទោះជាមនុស្សក្តី ។ ពាក្យថា អ្នកដល់នូវ វេទ សេចក្តីថា ញាណក្នុងមគ្គ ៤ លោកហៅថា វេទ ។ បេ ។ បុគ្គលនោះដល់នូវវេទ ព្រោះកន្លងនូវវេទទាំងពួង ។ ពាក្យថា នរៈ បានដល់ សត្វ នរៈ មាណព បុរស បុគ្គល ជីវៈ ជនជាតិ សត្វ ជាតុ សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា ក្នុង លោកនេះ គឺក្នុងទិដ្ឋិនេះ ។ បេ ។ ក្នុងមនុស្សលោកនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) នរៈណា ជាអ្នកចេះដឹង អ្នកដល់នូវវេទក្នុងលោកនេះ

១៧១

## មេត្តគូមាណវកបញ្ហានិទ្ទេសោ

[១៩៧] ភវាភវេ សង្គមិមំ វិសជ្ជាតិ ភវាភវេតិ ភវាភវេ កម្មភវេ បុនព្ភវេ កាមភវេ កម្មភវេ កាមភវេ បុនព្ភវេ រូបភវេ កម្មភវេ រូបភវេ បុនព្ភវេ អរូបភវេ កម្មភវេ អរូបភវេ បុនព្ភវេ បុនប្បុនំ ភវេ បុនប្បុនំ គតិយា បុនប្បុនំ ឧបបត្តិយា បុនប្បុនំ បដិសន្ធិយា បុនប្បុនំ អត្តភាវាភិនិព្វត្តិយា ។ សង្គន្តិ សត្ត សង្គា រាគសង្គោ ទោសសង្គោ មោហសង្គោ មានសង្គោ ទិដ្ឋិសង្គោ កិលេសសង្គោ ទុច្ចរិតសង្គោ ។ វិសជ្ជាតិ សង្គេ វោស្សជ្ជិត្វា វា វិសជ្ជ ។ អថវា សង្គេ ពន្ធេ[១] អាពន្ធេ លគ្គេ លគ្គិតេ បលិពុទ្ធេ ពន្ធនេ មោចយិត្វា[២] វា វិសជ្ជ យថា ច យានំ វា វយ្ហំ វា រថំ វា សកដំ វា សន្ទមានិកំ វា សជ្ជំ វិសជ្ជំ ករោន្តិ វិកោបេន្តិ ឯវមេវ តេ សង្គេ វោស្សជ្ជិត្វា វា វិសជ្ជ អថវា សង្គេ ពន្ធេ អាពន្ធេ លគ្គេ លគ្គិតេ បលិពុទ្ធេ ពន្ធនេ មោចយិត្វា វា វិសជ្ជាតិ ភវាភវេ សង្គមិមំ វិសជ្ជ ។

១ ម. ពន្ធេ វិពន្ធេ ។ ២ ម. ពោជយិត្វា ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

[១៩៧] ពាក្យថា បានស្រាយនូវការជាប់ចំពាក់នេះ ក្នុងភពតូចនិងភពធំ ត្រង់ពាក្យថាក្នុងភពតូចនិងភពធំ គឺក្នុងកម្មភព បុនព្ភព ឈ្មោះថាភពតូចនឹងភពធំ កាមភព ឈ្មោះថាកម្មភព កាមភព ឈ្មោះថាបុនព្ភព រូបភព ឈ្មោះថាកម្មភព រូបភព ឈ្មោះថាបុនព្ភព អរូបភព ឈ្មោះថាកម្មភព អរូបភពឈ្មោះថាបុនព្ភព គឺក្នុងការកើតរឿយៗ ក្នុងការទៅរឿយៗ ក្នុងការចូលទៅរឿយ ៗ ក្នុងបដិសន្ធិរឿយ ៗ ក្នុងការកើតអត្តភាពរឿយ ៗ ។ ពាក្យថា ការជាប់ចំពាក់ បានដល់ ការជាប់ចំពាក់ ៧ គឺការជាប់ចំពាក់គឺរាគៈ ការជាប់ចំពាក់គឺទោសៈ ការជាប់ចំពាក់គឺមោហៈ ការជាប់ចំពាក់គឺមានះ ការជាប់ចំពាក់គឺទិដ្ឋិ ការជាប់ចំពាក់គឺកិលេស ការជាប់ចំពាក់គឺទុច្ចរិត ។ ពាក្យថា ស្រាយ គឺលោះបង់ចោលឬដោះ នូវការជាប់ចំពាក់ទាំងឡាយ ។ មួយទៀត បុគ្គលដោះឬស្រាយ នូវការជាប់ចំពាក់ គឺ ចំណងដែលចង ចងទូទៅ ថ្ពក់ទាក់ ចំពាក់ ពួកជនរុះរើ ធ្វើឲ្យខ្ទេចខ្ទី នូវយានក្តី វក្តី រថក្តី រទេះក្តី រថទ្រង់គ្រឿងក្តី យ៉ាងណាមិញ បុគ្គលលោះបង់ចោលឬលះចេញ នូវការជាប់ចំពាក់ទាំងនោះ ក៏យ៉ាងនោះដែរ មួយវិញទៀត បុគ្គលដោះចេញ ឬស្រាយ នូវការជាប់ចំពាក់ គឺចំណង ដែលចង ចងទូទៅ ថ្ពក់ ទាក់ ចំពាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) បានស្រាយនូវការជាប់ចំពាក់នេះ ក្នុងភពតូចនិងភពធំ ។

[១៩៨] សោ វីតតណ្ហោ អនិឃោ និរាសោ អត្តារិ សោ ជាតិជរន្តិ ព្រូមីតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ យស្សេសា តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ វីតតណ្ហោ ចត្តតណ្ហោ វន្តតណ្ហោ មុត្តតណ្ហោ បហីនតណ្ហោ បដិនិស្សដ្ឋតណ្ហោ វីតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ សោ វីតតណ្ហោ ។ អនិឃោតិ រាគោ នីឃោ ទោសោ នីឃោ មោហោ នីឃោ កោធោ នីឃោ ឧបនាហោ នីឃោ ។ បេ ។ សព្វាកុសលាភិសង្ខារា នីឃា ។

[១៩៨] អធិប្បាយពាក្យថា តថាគតពោលថា នរៈនោះជាអ្នកប្រាស ចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ បានឆ្លងនូវជាតិនិងជរា ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហានុ៎ះ នរៈណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ នរៈនោះលោកហៅថា អ្នកប្រាសចាកតណ្ហា លះចោលតណ្ហា ខ្ជាក់ចោលតណ្ហា ផុតចាកតណ្ហា បន្សាត់ចោលតណ្ហា រលាស់ចេញចាកតណ្ហា ប្រាសចាករាគៈ លះចោលរាគៈ ខ្ជាក់ចោលរាគៈ ផុតចាករាគៈ បន្សាត់ចោលរាគៈ រលាស់ចេញចាករាគៈ មិនមានសេចក្តីប្រាថ្នា រលត់ទុក្ខ មានចិត្តត្រជាក់ សោយសុខ មានចិត្តត្រជាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) នរៈនោះប្រាសចាកតណ្ហា ។ ពាក្យថា មិនមានសេចក្តីតានតឹង សេចក្តីថា រាគៈ ជាសេចក្តីតានតឹង ទោសៈ ជាការតានតឹង មោហៈ ជាការតានតឹង កោធៈ ជាការតានតឹង ឧបនាហៈ ជាការតានតឹង ។ បេ ។ ការតាក់តែង នូវអកុសលទាំងពួង ជាការតានតឹង ។

មេត្តគូមាណវកប្បញ្ហានិទ្ទេសោ

យស្សេតេ នីឃា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្ប-
ស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ
អនីឃោ ។ និរាសោតិ អាសា វុច្ចតិ តណ្ហា យោ
រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុស-
លមូលំ ។ យស្សេសា អាសា តណ្ហា បហីនា
សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណ-
គ្គិនា ទឌ្ឍា សោ វុច្ចតិ និរាសោ ។ ជាតីតិ យា តេសំ
តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ
សញ្ជាតិ ឱក្កន្តិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ បាតុ-
ភាវោ អាយតនានំ បដិលាភោ ។ ជរាតិ យា
តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា
ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ
សំហានិ ឥន្ទ្រិយានំ បរិបាកោ ។ មរណន្តិ
យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិ-
កាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ
មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវ-
រស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ។

មេត្តគូមាណវកប្បញ្ហានិទ្ទេស

សេចក្តីតានតឹងទាំងនុ៎ះ នរៈណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ឲ្យស្ងប់ រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ នរៈនោះ លោកហៅថា អ្នកមិនមានសេចក្តីតានតឹង ។ ពាក្យថា មិនមានសេចក្តីប៉ុនប៉ង សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប៉ុនប៉ង បានដល់ រាគៈ រាគៈមានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាគឺសេចក្តីប៉ុនប៉ងនោះ នរៈណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ ឲ្យស្ងប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងញាណហើយ នរៈនោះ លោកហៅថា អ្នកមិនមានសេចក្តីប៉ុនប៉ង ។ ពាក្យថា ជាតិ បានដល់ កំណើត ការកើតព្រម ការចុះកាន់គភ៌ ការផ្តួចផ្តើម ការចម្រើនឡើង ការកើតប្រាកដនៃខន្ធ ការបានចំពោះនូវអាយតនៈ នៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា ជរា បានដល់ ការចាស់ ការគ្រាំគ្រា ការបាក់ធ្មេញ ការស្កូវសក់ ការជ្រួញជ្រីវស្បែក ការរួញថយនៃអាយុ ការចាស់ឥន្ទ្រិយ នៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ។ ពាក្យថា មរណៈ បានដល់ ការចុតិ ការឃ្លាត ការបែកធ្លាយ ការអន្តរធាន មច្ចុ មរណៈ កាលកិរិយា ការបែកធ្លាយខន្ធ ការដាក់ចោលនូវសាកសព ការដាច់សូន្យជីវិតិន្ទ្រិយ នៃពួកសត្វនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ។

សោ វីតតណ្ហោ អនិឃោ និរាសោ អត្តារិ សោ ជាតិ-ជរន្តិ ព្រូមីតិ យោ សោ វីតតណ្ហោ ច អនីឃោ ច និរាសោ ច សោ ជាតិជរាមរណំ អត្តារិ បតរិ សមតិក្កមិ វីតិវត្តីតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ សោ វីតតណ្ហោ អនិឃោ និរាសោ អត្តារិ សោ ជាតិជរន្តិ ព្រូមិ ។ តេនាហ ភគវា

វិទ្វា ច យោ វេទគូ នរោ ឥធ
ភវាភវេ សង្គមិមំ វិសជ្ជ
សោ វីតតណ្ហោ អនិឃោ និរាសោ
អត្តារិ សោ ជាតិជរន្តិ ព្រូមីតិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

មេត្តគូមាណវកបញ្ហានិទ្ទេសោ ចតុត្ថោ ។

ពាក្យថា តថាគតពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះបានឆ្លងនូវជាតិ និងជរា បានសេចក្តីថា តថាគត ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសថា នរៈណានោះ ប្រាសចាកតណ្ហាផង មិនមានសេចក្តីតានតឹងផង មិនមានសេចក្តីប៉ុនប៉ងផង នរៈនោះ បានឆ្លង ឆ្លងកាត់ ឈានកន្លង ប្រព្រឹត្តកន្លង នូវជាតិជរានិងមរណៈ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះបានឆ្លងនូវជាតិនិងជរា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

នរៈណា ជាអ្នកចេះដឹង អ្នកដល់នូវវេទ ក្នុងលោកនេះ បាន
ស្រាយ នូវការជាប់ចំពាក់នេះ ក្នុងភពតូចនិងភពធំ តថាគត
ពោលថា នរៈនោះ ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តី
តានតឹង មិនមានសេចក្តីប៉ុនប៉ង ទាំងពោលថា នរៈនោះ
បានឆ្លងនូវជាតិនិងជរា ។

(មេត្តគូបានប្រកាសខ្លួន) ដំណាលគ្នានឹងកាលជាទីចប់គាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ មេត្តគូមាណវកប្បញ្ហានិទ្ទេស ទី ៤ ។

# ធោតកមាណវកប្បញ្ហានិទ្ទេសោ

[១៩៩] បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ

(ឥច្ចាយស្មា ធោតកោ)

វាចាភិកង្ខាមិ មហេសិ តុយ្ហំ

តវ សុត្វាន និគ្ឃោសំ

សិក្ខេ និព្វានមត្តនោ ។

[២០០] បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ បុច្ឆាមីតិ តិស្សោ បុច្ឆា អទិដ្ឋជោតនា បុច្ឆា ទិដ្ឋសំសន្ទនា បុច្ឆា វិមតិច្ឆេទនា បុច្ឆា ។ បេ ។ ឥមា តិស្សោ បុច្ឆា ។ បេ ។ និព្វានបុច្ឆា ។ បុច្ឆាមិ តន្តិ បុច្ឆាមិ តំ យាចាមិ តំ អជ្ឈេសាមិ តំ បសាទេមិ តំ កថស្សុ[១] មេតិ បុច្ឆាមិ តំ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។

១ ម. កថយស្សុ ។

# ធោតកមាណវកប្បញ្ហានិទ្ទេស

[១៩៩] *ធោតកៈមានអាយុ (ទូលសួរដូច្នេះថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ បពិត្រព្រះមហេសី ខ្ញុំព្រះអង្គប្រាថ្នា (ស្តាប់) ព្រះពុទ្ធដីការបស់ព្រះអង្គ (ព្រោះថា) បុគ្គលស្តាប់ទេសនា របស់ព្រះអង្គហើយ នឹងសិក្សានូវការរំលត់ (កិលេស) របស់ខ្លួនបាន ។*

[២០០] *អធិប្បាយពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គ សម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា សូមសួរ បានដល់បុច្ឆា ៣ គឺ អទិដ្ឋជោតនាបុច្ឆា ១ ទិដ្ឋសំសន្ទនាបុច្ឆា ១ វិមតិច្ឆេទនាបុច្ឆា ១ ។ បេ ។ នេះ បុច្ឆា ៣ ។ បេ ។ និព្វានបុច្ឆា ។ ពាក្យថា ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គ សូមសួរចំពោះព្រះអង្គ សូមអង្វរព្រះអង្គ សូមអារាធនាព្រះអង្គ សូមជ្រះថ្លានឹងព្រះអង្គ សូមព្រះអង្គសម្តែង ដល់ខ្ញុំព្រះអង្គ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ ។ ពាក្យថា ព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ។*

ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។ ឥច្ចាយស្មា ជោតកណ្ណីតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ[១] ។ ជោតកណ្ណីតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្មា ជោតកណ្ណី ។

[២០១] វាចាភិកង្ខាមិ មហេសិ តុយ្ហន្តិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសន្ធិំ កង្ខាមិ អភិកង្ខាមិ ឥច្ឆាមិ សាទិយាមិ បត្ថយាមិ បិហេមិ អភិជប្បាមិ ។ មហេសីតិ កេនដ្ឋេន មហេសី ។ ភគវា មហន្តំ សីលក្ខន្ធំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ បេ ។ កហំ នរាសភោតិ មហេសីតិ វាចាភិកង្ខាមិ មហេសិ តុយ្ហំ ។

១ ម. បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។

ពាក្យថា សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ (លោកពោលថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងសេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គ ។ ពាក្យថា ដូច្នេះ នៃបទថា ធោតកៈមានអាយុ ពោលដូច្នេះ គឺជាបទតភ្ជាប់ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា ធោតក-មាណព ជាឈ្មោះ ។ បេ ។ ជាពាក្យហៅ របស់ព្រាហ្មណ៍នោះ ។ ហេតុនោះ (មានពាក្យថា) ធោតកៈមានអាយុ ទូលសួរដូច្នេះ ។

[២០១] ពាក្យថា បពិត្រព្រះមហេសី ខ្ញុំព្រះអង្គប្រាថ្នា (ស្តាប់) ព្រះពុទ្ធដីកា របស់ព្រះអង្គ គឺខ្ញុំព្រះអង្គ ប្រាថ្នា ប្រាថ្នាចំពោះ ប៉ង ជ្រះថ្លា ផ្គង ស្រឡាញ់ ជាប់ចិត្ត នូវព្រះពុទ្ធដីកា គន្ធងនៃព្រះពុទ្ធដីកា ទេសនា អនុសន្ធិ របស់ព្រះអង្គ ។ សំណួរត្រង់ពាក្យថា មហេសី ចុះឈ្មោះថា មហេសី ដោយអត្ថដូចម្តេច ។ ឈ្មោះថា មហេសី ព្រោះព្រះមានព្រះភាគ ទ្រង់រក ស្វែង ស្វះស្វែង នូវកងសីលដ៏ធំ ។ បេ ។ ឈ្មោះថា មហេសី ព្រោះព្រះអង្គ ជានរៈប្រសើរ គង់ក្នុងទីណា ហេតុនោះ (លោកពោលថា) បពិត្រព្រះមហេសី ខ្ញុំព្រះអង្គ ប្រាថ្នា (ស្តាប់) ព្រះពុទ្ធដីកា របស់ព្រះអង្គ ។

ធោតកមាណវកបញ្ហានិទ្ទេសោ

[២០២] តវ សុត្វាន និគ្ឃោសន្តិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសន្ធឹ សុត្វាន សុណិត្វា ឧគ្គណ្ហិត្វា ឧបធារយិត្វា ឧបលក្ខយិត្វាតិ តវ សុត្វាន និគ្ឃោសំ ។

[២០៣] សិក្ខេ និព្វានមត្តនោតិ សិក្ខាតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ បេ ។ អយំ អធិប្បញ្ញាសិក្ខា ។ និព្វានមត្តនោតិ(១) រាគស្ស និព្វាបនាយ ទោសស្ស និព្វាបនាយ មោហស្ស និព្វាបនាយ កោធស្ស និព្វាបនាយ ឧបនាហស្ស និព្វាបនាយ ។ បេ ។ សព្វាកុសលាភិសង្ខារានំ សមាយ ឧបសមាយ វូបសមាយ និព្វាបនាយ បដិនិស្សគ្គាយ បដិប្បស្សទ្ធិយា អធិសីលម្បិ សិក្ខេយ្យ អធិចិត្តម្បិ សិក្ខេយ្យ អធិប្បញ្ញម្បិ សិក្ខេយ្យ ឥមា តិស្សោ សិក្ខា អាវជ្ជេន្តោ សិក្ខេយ្យ ជានន្តោ សិក្ខេយ្យ បស្សន្តោ សិក្ខេយ្យ បច្ចវេក្ខន្តោ សិក្ខេយ្យ ចិត្តំ អធិដ្ឋហន្តោ(២) សិក្ខេយ្យ សទ្ធាយ អធិមុច្ចន្តោ សិក្ខេយ្យ វីរិយំ បគ្គណ្ហន្តោ សិក្ខេយ្យ សតឹ ឧបដ្ឋបេន្តោ សិក្ខេយ្យ ចិត្តំ សមាទហន្តោ សិក្ខេយ្យ បញ្ញាយ បជានន្តោ សិក្ខេយ្យ

១ ម. ឯត្តន្តរេ អត្តនោ អត្ថិ ។ ២ ម. បទហន្តោ ។

ធោតកមាណវកបញ្ហានិទ្ទេស

[២០២] ពាក្យថា បុគ្គលស្តាប់ទេសនា របស់ព្រះអង្គហើយ គឺ បុគ្គលស្តាប់ ឮ រៀន ទ្រទ្រង់ កំណត់ទុកហើយ នូវព្រះពុទ្ធដីកា គន្ធងព្រះពុទ្ធដីកា ទេសនា អនុសន្ធិ របស់ព្រះអង្គ ហេតុនោះ (លោក ពោលថា) បុគ្គលស្តាប់ទេសនា របស់ព្រះអង្គហើយ ។

[២០៣] អធិប្បាយពាក្យថា សិក្សា នូវការរំលត់ (កិលេស) របស់ខ្លួនបាន ត្រង់ពាក្យថា សិក្សា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ បេ ។ នេះ អធិប្បញ្ញាសិក្ខា ។ ពាក្យថា នូវការរំលត់ (កិលេស) របស់ខ្លួនបាន គឺនឹងសិក្សាអធិសីលផង នឹងសិក្សាអធិចិត្តផង នឹងសិក្សាអធិប្បញ្ញាផង ដើម្បីការរំលត់រាគៈ រំលត់ ទោសៈ រំលត់មោហៈ រំលត់កោធៈ រំលត់ឧបនាហៈ ។ បេ ។ ដើម្បី សេចក្តីស្ងប់ រម្ងាប់ ចូលទៅជិតស្ងប់ រំលត់ លះបង់ លះបង់ផ្តាច់ នូវ អភិសង្ខារ ជាអកុសលទាំងពួង គឺ នឹងពិចារណាសិក្សា នូវសិក្ខាទាំង ៣ នេះ នឹងដឹងសិក្សា នឹងឃើញសិក្សា នឹងពិចារណាសិក្សា នឹងតាំងចិត្ត សិក្សា នឹងចុះចិត្តស៊ប់ដោយសទ្ធាសិក្សា នឹងផ្គងព្យាយាមសិក្សា នឹង ប្រុងសតិសិក្សា នឹងតម្កល់ចិត្តឲ្យស្រួលសិក្សា នឹងដឹងដោយប្រាជ្ញាសិក្សា

១៧៨



អភិញ្ញាយ អភិជានន្តោ សិក្ខេយ្យ បរិញ្ញាយ បរិជានន្តោ សិក្ខេយ្យ បហាតព្វំ បជហន្តោ សិក្ខេយ្យ ភាវេតព្វំ ភាវេន្តោ សិក្ខេយ្យ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខេយ្យ សមាទាយ ចរេយ្យ សមាទាយ វត្តេយ្យាតិ សិក្ខេ និព្វានមត្តនោ ។ តេនាហ សោ ព្រាហ្មណោ

បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ
(ឥច្ចាយស្មា ធោតកោ)
វាចាភិកង្ខាមិ មហេសិ តុយ្ហំ
តវ សុត្វាន និគ្ឃោសំ
សិក្ខេ និព្វានមត្តនោតិ ។

[២០៤] តេនហាតប្បំ ករោហិ
(ធោតកាតិ ភគវា)
ឥធេវ និបកោ សតោ
ឥតោ សុត្វាន និគ្ឃោសំ
សិក្ខេ និព្វានមត្តនោ ។

នឹងដឹងជាក់ដោយអភិញ្ញាសិក្សា នឹងកំណត់ដឹងដោយបរិញ្ញាសិក្សា នឹងលះបង់នូវធម៌ដែលគួរលះបង់សិក្សា នឹងចម្រើននូវធម៌ដែលគួរចម្រើនសិក្សា នឹងធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា នឹងប្រព្រឹត្តសមាទាននឹងប្រតិបត្តិសមាទាន ហេតុនោះ លោកពោលថាសិក្សា នូវការរំលត់ (កិលេស) របស់ខ្លួនបាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ
សូមព្រះអង្គសម្តែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ បពិត្រព្រះ
មហេសី ខ្ញុំព្រះអង្គប្រាថ្នា(ស្តាប់) ព្រះពុទ្ធដីការបស់ព្រះ
អង្គ (ព្រោះថា) បុគ្គលស្តាប់ទេសនារបស់ព្រះអង្គហើយ
នឹងសិក្សានូវការរំលត់ (កិលេស) របស់ខ្លួនបាន ។

[២០៤] (ព្រះមានព្រះភាគ ត្រាស់ថា) ម្នាលធោតកៈ បើដូច្នោះ
ចូរអ្នកធ្វើសេចក្តីព្យាយាមចុះ បុគ្គលក្នុងលោកនេះ ជាអ្នកមាន
បញ្ញាចាស់ក្វា មានស្មារតី ស្តាប់ទេសនាអំពីទីនេះហើយ នឹង
សិក្សានូវការរំលត់ (កិលេស)របស់ខ្លួនបាន ។

១៧៩

ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២០៥] តេនហាតប្បំ ករោហីតិ អាតប្បំ ករោហិ ឧស្សាហំ ករោហិ ឧស្សោឡ្ហឹ ករោហិ វាយាមំ(១) ករោហិ ធិតឹ ករោហិ វីរិយំ ករោហិ ឆន្ទំ ជនេហិ សញ្ជនេហិ ឧបដ្ឋបេហិ(២) និព្វត្តេហិ អភិនិព្វត្តេហីតិ តេនហាតប្បំ ករោហិ ។ ធោតកាតិ ភគវាតិ ធោតកាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ធោតកាតិ ភគវា ។

[២០៦] ឥធេវ និបកោ សតោតិ ឥធាតិ ឥមិស្សា ទិដ្ឋិយា ឥមិស្សា ខន្តិយា ឥមិស្សា រុចិយា ឥមស្មឹ អាទាយេ ឥមស្មឹ ធម្មេ ឥមស្មឹ វិនយេ ឥមស្មឹ ធម្មវិនយេ ឥមស្មឹ បាវចនេ ឥមស្មឹ ព្រហ្មចរិយេ ឥមស្មឹ សត្ថុសាសនេ ឥមស្មឹ អត្តភាវេ ឥមស្មឹ មនុស្សលោកេ ។

---

១ ម. ថាមំ ។ ២ ម. ឧបដ្ឋបេហិ សមុដ្ឋបេហិ ។

ធោតកមាណវកបញ្ហានិទ្ទេស

[២០៥] ពាក្យថា បើដូច្នោះ ចូរអ្នកធ្វើសេចក្ដីព្យាយាមចុះ គឺអ្នកចូរធ្វើសេចក្ដីព្យាយាម ចូរធ្វើឧស្សាហ៍ ចូរធ្វើសេចក្ដីប្រឹងប្រែង ចូរធ្វើសេចក្ដីសង្វាត ចូរធ្វើសេចក្ដីឱហាត ចូរធ្វើសេចក្ដីខ្នះខ្នែង ចូរធ្វើសេចក្ដីខ្មីឃ្មាត ចូរញ៉ាំងសេចក្ដីពេញចិត្តឲ្យកើត ឲ្យកើតព្រម ឲ្យតាំងនៅស៊ប់សួន ឲ្យដុះ ឲ្យដុះចំពោះ ហេតុនោះ (ទ្រង់ត្រាស់ថា) បើដូច្នោះ អ្នកចូរធ្វើសេចក្ដីព្យាយាមចុះ ។ ពាក្យថា ធោតកៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតកៈ គឺព្រះមានព្រះភាគ ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគនេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគនេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតកៈ ។

[២០៦] អធិប្បាយពាក្យថា បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ត្រង់ពាក្យថា ក្នុងលោកនេះ គឺក្នុងទិដ្ឋិនេះ ក្នុងសេចក្ដីពេញចិត្តនេះ ក្នុងសេចក្ដីគាប់ចិត្តនេះ ក្នុងការកាន់យកនេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងធម្មវិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចារ្យនេះ ក្នុងសាសនាព្រះសាស្ដានេះ ក្នុងអត្តភាពនេះ ក្នុងមនុស្សលោកនេះ ។

និបកោតិ និបកោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ វុច្ចតិ សតោតិ ឥធេវ និបកោ សតោ ។

[២០៧] ឥតោ សុត្វាន និគ្ឃោសន្តិ ឥតោ មយ្ហំ វចនំ ព្យបថំ ទេសនំ អនុសន្ធឹ សុត្វាន សុណិត្វា ឧគ្គហិត្វា ឧបធារយិត្វា ឧបលក្ខយិត្វាតិ ឥតោ សុត្វាន និគ្ឃោសំ ។

[២០៨] សិក្ខេ និព្វានមត្តនោតិ សិក្ខេតិ តិស្សោ សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ បេ ។ អយំ អធិប្បញ្ញាសិក្ខា ។ និព្វានមត្តនោតិ រាគស្ស និព្វាបនាយ ទោសស្ស និព្វាបនាយ មោហស្ស និព្វាបនាយ កោធស្ស និព្វាបនាយ ឧបនាហស្ស និព្វាបនាយ ។ បេ ។

ពាក្យថា មានបញ្ញាចាស់ក្លា គឺ មានបញ្ញាធ្ងន់ ជាបណ្ឌិតមានប្រាជ្ញា មានការចេះដឹង មានញាណ ជាអ្នកប្រាជ្ញ មានប្រាជ្ញាជាគ្រឿងទម្លាយបង់នូវកិលេស ។ ពាក្យថា មានស្មារតី គឺមានស្មារតី ដោយហេតុ ៤ គឺ បុគ្គលកំពុងចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា អ្នកមានស្មារតី ។ បេ ។ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ។

[២០៧] ពាក្យថា ស្តាប់ទេសនា អំពីទីនេះហើយ គឺស្តាប់ ត្រងត្រាប់ រៀន ទ្រទ្រង់ កំណត់ទុក នូវពាក្យ គន្លងពាក្យ ទេសនា អនុសន្ធិ របស់តថាគត អំពីទីនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ស្តាប់នូវទេសនា អំពីទីនេះហើយ ។

[២០៨] អធិប្បាយពាក្យថា នឹងសិក្សានូវការរំលត់ (កិលេស) របស់ខ្លួន ត្រង់ពាក្យថា នឹងសិក្សា បានដល់សិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ បេ ។ នេះ អធិប្បញ្ញាសិក្ខា ។ ពាក្យថា ការរំលត់ (កិលេស) របស់ខ្លួន គឺនឹងសិក្សាអធិសីលផង នឹងសិក្សាអធិចិត្តផង នឹងសិក្សាអធិប្បញ្ញាផង ដើម្បីការរំលត់រាគៈ ការរំលត់ទោសៈ ការរំលត់មោហៈ ការរំលត់កោធៈ ការរំលត់ឧបនាហៈ ។ បេ ។

១៨១

ធោតកមាណវកប្បញ្ហានិទ្ទេសោ

សព្វាកុសលាភិសង្ខារានំ សមាយ ឧបសមាយ វូបស-
មាយ និព្វាបនាយ បដិនិស្សគ្គាយ បដិប្បស្សទ្ធិយា
អធិសីលម្បិ សិក្ខេយ្យ អធិចិត្តម្បិ សិក្ខេយ្យ អធិ-
បញ្ញម្បិ សិក្ខេយ្យ ឥមា តិស្សោ សិក្ខា អាវជ្ជេន្តោ
សិក្ខេយ្យ ជានន្តោ សិក្ខេយ្យ ។ បេ ។ សច្ឆិកាតព្វំ
សច្ឆិករោន្តោ សិក្ខេយ្យ សមាទាយ[១] ចរេយ្យ សមា-
ទាយ វត្តេយ្យាតិ សិក្ខេ និព្វានមត្តនោ ។ តេនាហ ភគវា

តេនហាតប្បំ ករោហិ [ធោតកាតិ ភគវា]
ឥធេវ និបកោ សតោ
ឥតោ សុត្វាន និគ្ឃោសំ សិក្ខេ និព្វានមត្តនោតិ ។

[២០៩] បស្សាមហំ ទេវ មនុស្សលោកេ
អកិញ្ចនំ ព្រាហ្មណំ ឥរិយមានំ
តន្តំ នមស្សាមិ សមន្តចក្ខុ
បមុញ្ច មំ សក្ក កថំកថាហិ ។

១ ម. អាទាយ សមាទាយ ។

ធោតកមាណវកបញ្ហានិទ្ទេស

ដើម្បីការស្ងប់ រម្ងាប់ ស្ងប់រម្ងាប់ រំលត់ លះបង់ រម្ងាប់ នូវអភិសង្ខារជាអកុសលទាំងពួង នឹងពិចារណាសិក្សា នូវសិក្ខាទាំង ៣ នេះ នឹងដឹងសិក្សា ។ បេ ។ នឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់សិក្សា នឹងប្រព្រឹត្តសមាទាន នឹងប្រតិបត្តិសមាទាន ហេតុនោះ (ទ្រង់ត្រាស់ថា) នឹងសិក្សានូវការរំលត់ (កិលេស) របស់ខ្លួនបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលធោតកៈ បើដូច្នោះ ចូរអ្នកធ្វើសេចក្តីព្យាយាមចុះ បុគ្គលក្នុងលោកនេះ ជាអ្នកមានបញ្ញាចាស់ក្លា មានស្មារតី ស្តាប់ទេសនាអំពីទីនេះហើយ នឹងសិក្សា នូវការរំលត់ (កិលេស) របស់ខ្លួនបាន ។

[២០៩] (ធោតកៈពោលថា) ខ្ញុំព្រះអង្គបានឃើញព្រះអង្គ ជាទេវតាក្នុងមនុស្សលោក ព្រះអង្គមិនមានកង្វល់ ជាព្រាហ្មណ៍កំពុងប្រព្រឹត្ត បពិត្រព្រះអង្គជាសមន្តចក្ខុ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គដោះខ្ញុំព្រះអង្គឲ្យផុតចាកសេចក្តីសង្ស័យទាំងឡាយ ។

[២១០] បស្សាមហំ ទេវ មនុស្សលោកេតិ ទេវា-
តិ តយោ ទេវា សម្មតិទេវា ច ឧបបត្តិទេវា ច
វិសុទ្ធិទេវា ច ។ កតមេ សម្មតិទេវា ។ សម្មតិទេវា
វុច្ចន្តិ រាជានោ ច រាជកុមារា ច ទេវិយោ ច ។
កតមេ ឧបបត្តិទេវា ។ ឧបបត្តិទេវា វុច្ចន្តិ ចាតុម្មហា-
រាជិកា ទេវា តាវត្តឹសា ទេវា យាមា ទេវា តុសិតា
ទេវា និម្មានរតី ទេវា បរនិម្មិតវសវត្តី ទេវា ព្រហ្មកា-
យិកា ទេវា យេ ច ទេវា តត្រុបរិ ។ កតមេ វិសុទ្ធិ-
ទេវា ។ វិសុទ្ធិទេវា វុច្ចន្តិ តថាគតសាវកា អរហ-
ន្តោ ខីណាសវា យេ ច បច្ចេកសម្ពុទ្ធា ។ ភគវា
សម្មតិទេវានញ្ច ឧបបត្តិទេវានញ្ច វិសុទ្ធិទេវានញ្ច
ទេវោ ច អតិទេវោ ច ទេវាតិទេវោ ច សីហាសី-
ហោ នាគនាគោ គណិគណី មុនិមុនី រាជរាជា ។

[២១០] *អធិប្បាយពាក្យថា ខ្ញុំព្រះអង្គបានឃើញព្រះអង្គ ជាទេវតាក្នុងមនុស្សលោក ត្រង់ពាក្យថា ទេវតា បានដល់ ពួកទេព ៣ គឺ សម្មតិទេព ១ ឧបបត្តិទេព ១ វិសុទ្ធិទេព ១ ។ សម្មតិទេព តើដូចម្តេច ។ ពួកព្រះរាជា ព្រះរាជកុមារ និងព្រះទេពី លោកហៅថា សម្មតិទេព ។ ឧបបត្តិទេព តើដូចម្តេច ។ ពួកទេពឋិតនៅ ក្នុងចាតុម្មហារាជិកា ពួកទេពឋិតនៅក្នុងតាវត្តិង្ស ពួកទេពឋិតនៅក្នុងយាមា ពួកទេពឋិតនៅក្នុងតុសិត ពួកទេពឋិតនៅ ក្នុងនិម្មានរតី ពួកទេពឋិតនៅក្នុងបរនិម្មិត-វសវត្តី និងពួកទេពជាពួកនៃព្រហ្ម ជាពួកទេពដែលឋិតនៅខាងលើពួកទេពទាំងនុ៎ះ លោកហៅថា ឧបបត្តិទេព ។ វិសុទ្ធិទេព តើដូចម្តេច ។ ពួកព្រះអរហន្ត ខីណាស្រព ជាសាវ័ករបស់ព្រះតថាគត និងពួកព្រះខីណាស្រព ដែលជាព្រះបច្ចេកពុទ្ធ លោកហៅថា វិសុទ្ធិ-ទេព ។ ព្រះមានព្រះភាគ ជាទេពរបស់ពួកសម្មតិទេព ឧបបត្តិទេព និងវិសុទ្ធិទេព ជាទេពដ៏ក្រៃលែងផង ជាទេពធំកន្លងជាងពួកទេពផង ជាសីហៈធំជាងសីហៈផង ជានាគធំជាងនាគផង ជាមេគណៈធំជាងមេគណៈផង ជាមុនីធំជាងមុនីផង ជាព្រះរាជាធំជាងព្រះរាជាផង ។*

បស្សាមហំ ទេវ មនុស្សលោកេតិ មនុស្សលោកេ ទេវំ បស្សាមិ អតិទេវំ បស្សាមិ ទេវាតិទេវំ បស្សាមិ ទក្ខាមិ ឱលោកេមិ និជ្ឈាយាមិ ឧបបរិក្ខាមីតិ បស្សាមហំ ទេវ មនុស្សលោកេ ។

[២១១] អកិញ្ចនំ ព្រាហ្មណំ ឥរិយមានន្តិ អកិញ្ចនន្តិ រាគកិញ្ចនំ ទោសកិញ្ចនំ មោហកិញ្ចនំ មានកិញ្ចនំ ទិដ្ឋិកិញ្ចនំ កិលេសកិញ្ចនំ ទុច្ចរិតកិញ្ចនំ តេ កិញ្ចនា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អកិញ្ចនោ ។ ព្រាហ្មណន្តិ ភគវា សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ សក្កាយទិដ្ឋិ ពាហិតា ហោតិ វិចិកិច្ឆា ពាហិតា ហោតិ សីលព្វតបរាមាសោ ពាហិតោ ហោតិ រាគោ ពាហិតោ ហោតិ ទោសោ ពាហិតោ ហោតិ មោហោ ពាហិតោ ហោតិ មានោ ពាហិតោ ហោតិ ពាហិតស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹជាតិជរាមរណីយា ។

ពាក្យថា ខ្ញុំព្រះអង្គបានឃើញព្រះអង្គជាទេវតា ក្នុងមនុស្សលោក បានន័យថា ខ្ញុំព្រះអង្គឃើញព្រះអង្គជាទេវតា គឺខ្ញុំព្រះអង្គឃើញព្រះអង្គជាទេវតាកន្លងទេវតា ឃើញ ប្រទះឃើញ រមិលឃើញ សម្លឹងមើល ពិចារណាមើល នូវព្រះអង្គជាទេពធំជាងពួកទេព ហេតុនោះ លោកពោលថា ខ្ញុំព្រះអង្គបានឃើញព្រះអង្គជាទេវតា ក្នុងមនុស្សលោក ។

[២១១] អធិប្បាយពាក្យថា ព្រះអង្គមិនមានកង្វល់ ជាព្រាហ្មណ៍ កំពុងប្រព្រឹត្ត ត្រង់ពាក្យថា ព្រះអង្គមិនមានកង្វល់ បានដល់ កង្វល់គឺរាគៈ កង្វល់គឺទោសៈ កង្វល់គឺមោហៈ កង្វល់គឺមានះ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត កង្វល់ទាំងនុ៎ះ ព្រះពុទ្ធមានព្រះភាគ ទ្រង់លះបង់ ផ្ដាច់ផ្តិលឫសគល់ ធ្វើឲ្យនៅតែទីកើតដូចដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជារបស់មានសភាពមិនកើតតទៅទៀត ហេតុនោះ ព្រះពុទ្ធឈ្មោះថា មិនមានកង្វល់ ។ ពាក្យថា ជាព្រាហ្មណ៍ គឺព្រះមានព្រះភាគ ឈ្មោះថាព្រាហ្មណ៍ ព្រោះទ្រង់បន្សាត់ចោលធម៌ ៧ គឺ បន្សាត់សក្កាយទិដ្ឋិ បន្សាត់វិចិកិច្ឆា បន្សាត់សីលព្វតបរាមាសៈ បន្សាត់រាគៈ បន្សាត់ទោសៈ បន្សាត់មោហៈ បន្សាត់មានះ ទាំងអកុសលធម៌ដ៏លាមកទាំងឡាយ ប្រឡូកប្រឡំដោយសេចក្ដីសៅហ្មង នាំឲ្យកើតក្នុងភពថ្មី ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានទុក្ខជាផល ជាទីតាំងនៃជាតិ ជរា និងមរណៈទៅខាងមុខ ព្រះអង្គបន្សាត់ចោលហើយ ។

ពាហេត្វា សព្វបាបកានិ (សភិយាតិ ភគវា)
ភគវា វិមលោ សាធុសមាហិតោ ឋិតត្តោ[(១)]
សំសារមតិច្ច កេវលី សោ
អនិស្សិតោ តាទិ បវុច្ចតេ ព្រហ្មា ។

ឥរិយមានន្តិ ចរន្តំ វិចរន្តំ ឥរិយន្តំ វត្តេន្តំ បាលេន្តំ យបេន្តំ យាបេន្តន្តិ អភិញ្ញាតំ ព្រាហ្មណំ ឥរិយមានំ ។

[២១២] តន្តំ នមស្សាមិ សមន្តចក្ខូតិ តន្តិ ភគវន្តំ ភណតិ ។ នមស្សាមីតិ កាយេន វា នមស្សាមិ វាចាយ វា នមស្សាមិ ចិត្តេន វា នមស្សាមិ អន្វត្ថប្បដិបត្តិយា វា នមស្សាមិ ធម្មានុធម្មប្បដិបត្តិយា វា នមស្សាមិ សក្ករោមិ គរុករោមិ មានេមិ បូជេមិ ។ សមន្តចក្ខូតិ សមន្តចក្ខុ វុច្ចតិ សព្វញ្ញុតញ្ញាណំ ។ ភគវា តេន សព្វញ្ញុតញ្ញាណេន ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ ។

១ ម. ធិតត្តោ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ ព្រះមានព្រះភាគ បន្សាត់បង់នូវបាបទាំងពួង ទ្រង់មិនមានមន្ទិល មានព្រះទ័យតម្កល់ដោយប្រពៃ មានព្រះទ័យនឹងនួន ព្រះមានព្រះភាគនោះ ព្រះអង្គបរិបូណ៌ដោយគុណគ្រប់យ៉ាង កន្លងបង់នូវសំសារ មិនអាស្រ័យ (តណ្ហានិងទិដ្ឋិ) ទ្រង់មិនញាប់ញ័រ (ដោយលោកធម៌) ទើបលោកហៅថា ព្រាហ្មណ៍ ។

ពាក្យថា កំពុងប្រព្រឹត្ត គឺកំពុងត្រាច់ទៅ ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្ត-ទៅ រក្សា យាត្រា យាត្រាទៅ ហេតុនោះ (លោកពោលថា) ព្រះអង្គមិនមានកង្វល់ ជាព្រាហ្មណ៍ កំពុងប្រព្រឹត្ត ។

[២១២] ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ ត្រង់ពាក្យថា ព្រះអង្គ គឺលោកហៅ ព្រះមានព្រះភាគ ។ ពាក្យថា សូមនមស្ការ គឺសូមនមស្ការដោយកាយក្តី សូមនមស្ការដោយវាចាក្តី សូមនមស្ការដោយចិត្តក្តី សូមនមស្ការដោយសេចក្តីប្រតិបត្តិដែលមានប្រយោជន៍ជាលំដាប់ៗ ក្តី សូមនមស្ការ ធ្វើសក្ការៈ ធ្វើគោរព រាប់អាន បូជា ដោយធម្មានុធម្មប្បដិបត្តិក្តី ។ ពាក្យថា សមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ដល់ ដល់ព្រម មកដល់ មកដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយដោយសព្វញ្ញុតញ្ញាណនោះ ។

ធោតកមាណវកប្បញ្ហានិទ្ទេសោ

ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ
អថោ អវិញ្ញាតមជានិតព្វំ
សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ
តថាគតោ តេន សមន្តចក្ខូតិ ។

តន្តំ នមស្សាមិ សមន្តចក្ខុ ។

[២១៣] បមុញ្ច មំ សក្ក កថង្កថាហីតិ សក្កាតិ ភគវា សក្យកុលា បព្វជិតោតិបិ សក្កោ ។ អថវា អឌ្ឍោ មហទ្ធនោ ធនវាតិបិ សក្កោ ។ តស្សិមានិ ធនានិ សេយ្យថីទំ សទ្ធាធនំ សីលធនំ ហិរិធនំ ឱត្តប្បធនំ សុតធនំ ចាគធនំ បញ្ញាធនំ សតិប្បដ្ឋានធនំ សម្មប្បធានធនំ ឥទ្ធិបាទធនំ ឥន្ទ្រិយធនំ ពលធនំ ពោជ្ឈង្គធនំ មគ្គធនំ ផលធនំ និព្វានធនំ ។

វត្ថុនីមួយក្នុងលោកនេះ ដែលព្រះមានព្រះភាគមិនឃើញ ឬ
មិនដឹង មិនគប្បីដឹង មិនមានទេ ព្រះតថាគត ទ្រង់ជ្រាប
ច្បាស់នូវវត្ថុទាំងអស់ ដែលគួរជ្រាប ហេតុនោះ ព្រះតថា-
គត ឈ្មោះថា សមន្តចក្ខុ ។

ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គ ជាសមន្តចក្ខុ ខ្ញុំព្រះអង្គ សូមនមស្ការព្រះអង្គ ។

[២១៣] អធិប្បាយពាក្យថា បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ ត្រង់ពាក្យថា បពិត្រព្រះអង្គជាសក្កៈ សេចក្ដីថា ព្រះមានព្រះភាគ ចេញចាកសក្យ-ត្រកូល ហើយទ្រង់បព្វជ្ជា ហេតុនោះ ទើបទ្រង់ព្រះនាមថា សក្កៈ ក៏មាន ។ មួយទៀត ព្រះមានព្រះភាគ ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យធន ហេតុនោះ ទើបទ្រង់ព្រះនាមថា សក្កៈ ក៏មាន ។ ទ្រព្យទាំងនោះ របស់ព្រះអង្គ គឺ ទ្រព្យសទ្ធា ទ្រព្យសីល ទ្រព្យហិរិ ទ្រព្យឱត្តប្បៈ ទ្រព្យសុតៈ ទ្រព្យចាគៈ ទ្រព្យបញ្ញា ទ្រព្យសតិប្បដ្ឋាន ទ្រព្យសម្មប្បធាន ទ្រព្យឥទ្ធិបាទ ទ្រព្យឥន្ទ្រិយ ទ្រព្យពលៈ ទ្រព្យពោជ្ឈង្គៈ ទ្រព្យមគ្គៈ ទ្រព្យផល ទ្រព្យព្រះនិព្វាន ។

ឥមេហិ អនេកវិធេហិ ធនរតនេហិ អឌ្ឍោ មហទ្ធនោ ធនវាតិបិ សក្កោ ។ អថវា សក្កោ បហុ វិសវី អលមត្តោ សូរោ វីរោ[១] វិក្កន្តោ អភិរុ អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោតិបិ សក្កោ ។ កថង្កថា វុច្ចតិ វិចិកិច្ឆា ទុក្ខេ កង្ខា ទុក្ខសមុទយេ កង្ខា ទុក្ខនិរោធេ កង្ខា ទុក្ខនិរោធគាមិនិយា បដិបទាយ កង្ខា បុព្វន្តេ កង្ខា អបរន្តេ កង្ខា បុព្វន្តាបរន្តេ កង្ខា ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ កង្ខា យា ឯវរូបា កង្ខា កង្ខាយនា កង្ខាយិតត្តំ វិមតិ វិចិកិច្ឆា ទ្វេឡ្ហកំ ទ្វេធាបថោ សំសយោ អនេកំសគ្គាហោ អាសប្បនា បរិសប្បនា អបរិយោគាហនា ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ ។

១ ម. ធីរោ ។

ព្រះមានព្រះភាគ ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យធន ដោយទ្រព្យប្រសើរទាំងឡាយ ច្រើនប្រការនេះ ហេតុនោះ ទើបទ្រង់ព្រះនាមថា សក្កៈក៏មាន ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់អង់អាចអាចហ៊ាន ក្លាហាន មោះមុត ក្លៀវក្លា មានព្យាយាម ធ្លាប់ចូលកាន់សង្គ្រាម មិនខ្លាច មិនរន្ធត់ មិនតក់ស្លុត មិនរត់ចោលលះភ័យគួរខ្លាច ទ្រង់មិនព្រឺរោម ហេតុនោះ ទើបទ្រង់ព្រះនាមថាសក្កៈ ក៏មាន ។ សេចក្តីស្ទាក់ស្ទើរ លោកហៅថា សេចក្តីសង្ស័យគឺសង្ស័យក្នុងទុក្ខ សង្ស័យក្នុងតណ្ហា ជាហេតុឲ្យកើតទុក្ខ សង្ស័យក្នុងសេចក្តីរំលត់ទុក្ខ សង្ស័យក្នុងបដិបទា ជាដំណើរទៅដើម្បីរំលត់ទុក្ខ សង្ស័យក្នុងចំណែកខាងដើម សង្ស័យក្នុងចំណែកខាងចុង សង្ស័យទាំងចំណែកខាងដើមនិងខាងចុង សង្ស័យក្នុងធម៌ទាំងឡាយ ដែលកើតឡើងអាស្រ័យព្រោះបច្ច័យនេះ គឺបានខាងការសង្ស័យ អាការនៃការសង្ស័យ ភាពនៃការសង្ស័យ ការងឿងឆ្ងល់ ការស្ទាក់ស្ទើរ ការយល់ជាពីរយ៉ាង ការបែកគំនិតជាពីរផ្លូវ ការសន្ទិះសង្ស័យ ការប្រកាន់ច្រើនចំណែក ការរសេមរសាម ការស្ទុគស្ទាញ ការប្រកាន់ឆ្វេង ភាពនៃចិត្តញាប់ញ័រ គំនូសនៃចិត្ត មានសភាពយ៉ាងនេះ ។

១៨៧

ធោតកមាណវកប្បញ្ហានិទ្ទេសោ

បមុញ្ច មំ សក្ក កថង្កថាហីតិ មុញ្ច មំ មោចេហិ មំ បមោចេហិ មំ ឧទ្ធរ មំ សមុទ្ធរ មំ វុដ្ឋាបេហិ មំ កថង្កថាសល្លតោតិ បមុញ្ច មំ សក្ក កថង្ក-ថាហិ ។ តេនាហ សោ ព្រាហ្មណោ

បស្សាមហំ ទេវ មនុស្សលោកេ
អកិញ្ចនំ ព្រាហ្មណំ ឥរិយមានំ
តន្តំ នមស្សាមិ សមន្តចក្ខុ
បមុញ្ច មំ សក្ក កថង្កថាហីតិ ។

[២១៤] នាហំ សមិស្សាមិ បមោចនាយ
កថង្កថឹ ធោតក កញ្ចិ លោកេ
ធម្មញ្ច សេដ្ឋំ អាជានមានោ
ឯវំ តុវំ ឱឃមិមំ តរេសិ ។

ពាក្យថា បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គ ដោះខ្ញុំព្រះអង្គឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ បានន័យថា សូមព្រះអង្គ ដោះខ្ញុំព្រះអង្គ សូមស្រាយខ្ញុំព្រះអង្គ សូមលែងខ្ញុំព្រះអង្គ សូមជ្រោងឡើងនូវខ្ញុំព្រះអង្គ សូមស្រង់ឡើងនូវខ្ញុំព្រះអង្គ សូមញ៉ាំងខ្ញុំព្រះអង្គឲ្យរួចផុតស្រឡះអំពីសរ គឺសេចក្ដីសង្ស័យ ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គ ដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

> ខ្ញុំព្រះអង្គ បានឃើញព្រះអង្គ ជាទេវតាក្នុងមនុស្សលោក ព្រះអង្គមិនមានកង្វល់ ជាព្រាហ្មណ៍ កំពុងប្រព្រឹត្ត បពិត្រព្រះអង្គជាសមន្តចក្ខុ ខ្ញុំព្រះអង្គ សូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាសក្កៈ សូមព្រះអង្គ ដោះខ្ញុំព្រះអង្គ ឲ្យផុតចាកសេចក្ដីសង្ស័យទាំងឡាយ ។

[២១៤] (ព្រះមានព្រះភាគត្រាស់ថា) ម្នាលធោតកៈ តថាគតមិនអាចដើម្បីដោះអ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្ដីសង្ស័យបានទេ ប៉ុន្តែកាលបើអ្នកបានដឹងច្បាស់ នូវធម៌ដ៏ប្រសើរយ៉ាងនេះ នឹងឆ្លងឱឃៈនេះបាន ។

[២១៤] ជាហំ សមិស្សាមិ បមោចនាយាតិ ជាហន្តំ សក្កោមិ មុញ្ចិតុំ បមុញ្ចិតុំ មោចេតុំ បមោចេតុំ ឧទ្ធរិតុំ ឧទ្ធរាបេតុំ វុដ្ឋាបេតុំ[១] កថង្កថាសល្លតោតិ ឯវម្បិ ជាហំ សមិស្សាមិ បមោចនាយ ។ អថវា ន ឦហាមិ ន សហាមិ ន ឧស្សហាមិ ន វាយមាមិ ន ឧស្សាហំ ករោមិ ន ឧស្សោឡ្ហឹ ករោមិ ន ថាមំ ករោមិ ន ធិតឹ ករោមិ ន វីរិយំ ករោមិ ន ឆន្ទំ ជនេមិ ន សញ្ជនេមិ ន និព្វត្តេមិ ន អភិនិព្វត្តេមិ អស្សទ្ធេ បុគ្គលេ អច្ឆន្ទិកេ កុសីតេ ហីនវីរិយេ អប្បដិបជ្ជមានេ ធម្មទេសនាយាតិ ឯវម្បិ ជាហំ សមិស្សាមិ បមោចនាយ ។ អថវា នត្ថញ្ញោ កោចិ មោចេតុំ[២] តេ យទិ មុញ្ចេយ្យុំ សកេន ថាមេន សកេន ពលេន សកេន វីរិយេន សកេន បរក្កមេន សកេន បុរិសត្ថាមេន សកេន បុរិសពលេន សកេន បុរិសវីរិយេន សកេន បុរិសបរក្កមេន អត្តនា សម្មាបដិបទំ អនុលោមប្បដិបទំ[៣] អនត្តប្បដិបទំ ធម្មានុធម្មប្បដិបទំ បដិបជ្ជមានា មុញ្ចេយ្យុន្តិ

១ ម. សមុទ្ធរិតុំ ឧដ្ឋាបេតុំ សមុដ្ឋាបេតុំ ។ ២ កត្ថចិ ស្យាមបោត្ថកេ មោចេតាតិបិ បាឋោ ។ ម. មោចេតា ។ ៣ ម. ឯត្ថន្តរេ អបច្ចនីកបដិបទំ អត្ថិ ។

[២១៥] ពាក្យថា តថាគត មិនអាចដើម្បីដោះ អធិប្បាយថា តថាគត មិនអាចដោះអ្នក ស្រាយចេញ ស្រាយលែង ដោះលែង ជ្រោងឡើង ស្រង់ឡើង ឲ្យក្រោកចេញ អំពីសរគឺសេចក្ដីសង្ស័យបាន ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត មិនអាចដើម្បីដោះ យ៉ាងនេះខ្លះ ។ មួយទៀត តថាគត មិនខ្វល់ខ្វាយ មិនខ្វល់ខ្វាយខ្លាំង មិនឧស្សាហ៍ មិនព្យាយាម មិនធ្វើឧស្សាហ៍ មិនធ្វើសេចក្ដីប្រឹងប្រែង មិនធ្វើនូវសេចក្ដីខ្នះខ្នែង មិនធ្វើសេចក្ដីឱហាត មិនធ្វើព្យាយាម មិនញុំាងឆន្ទៈឲ្យកើត មិនឲ្យកើតព្រម មិនឲ្យដុះ មិនឲ្យដុះដាល (ដើម្បីដោះ) នូវពួកបុគ្គល មិនមានឆន្ទៈ ខ្ជិលច្រអូសថយព្យាយាម មិនប្រតិបត្តិតាម ដោយធម្មទេសនាបានទេ ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត មិនអាចដោះ យ៉ាងនេះខ្លះ ។ មួយទៀត បុគ្គលដទៃណាមួយ ញុំាងបុគ្គលដទៃឲ្យរួចបានមិនមានទេ ត្រូវតែបុគ្គលទាំងនោះ រួចដោយសេចក្ដីព្យាយាមដ៏តឹងរុងរបស់ខ្លួន ដោយកម្លាំងរបស់ខ្លួន ដោយការព្យាយាមរបស់ខ្លួន ដោយសេចក្ដីប្រឹងប្រែងរបស់ខ្លួន ដោយការព្យាយាមដ៏តឹងរ៉ឹងនៃបុរសរបស់ខ្លួន ដោយកម្លាំងបុរសរបស់ខ្លួន ដោយការព្យាយាមបុរសរបស់ខ្លួន ដោយសេចក្ដីប្រឹងប្រែងបុរសរបស់ខ្លួន គឺប្រតិបត្តិនូវសម្មាបដិបទា អនុលោមប្បដិបទា អនុត្តប្បដិបទា ធម្មានុធម្មប្បដិបទា ដោយខ្លួនឯង ទើបរួចបាន

១៨៩

## ធោតកមាណវកប្បញ្ហានិទ្ទេសោ

ឯវម្បិ នាហំ សមិស្សាមិ បមោចនាយ ។ វុត្តញ្ហេតំ ភគវតា សោ វត ចុន្ទ អត្តនា បលិបបលិបន្នោ បរំ បលិបបលិបន្នំ ឧទ្ធរិស្សតីតិ នេតំ ឋានំ វិជ្ជតិ សោ វត ចុន្ទ អត្តនា អទន្តោ អវិនីតោ អបរិនិព្វុតោ បរំ ទមេស្សតិ វិនេស្សតិ បរិនិព្វាបេស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ឯវម្បិ នាហំ សមិស្សាមិ បមោចនាយ ។ វុត្តញ្ហេតំ ភគវតា

អត្តនាវ កតំ បាបំ     អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ     អត្តនាវ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ     នាញ្ញោ អញ្ញំ វិសោធយេតិ[១] ។

ឯវម្បិ នាហំ សមិស្សាមិ បមោចនាយ ។ វុត្តញ្ហេតំ ភគវតា ឯវមេវ ខោ ព្រាហ្មណ តិដ្ឋតេវ និព្វានំ តិដ្ឋតិ និព្វានគាមិមគ្គោ[២] តិដ្ឋាមហំ សមាទបេតា

---

១ វិមោចយេតិបិ បាឋោ ។ ២ ម. និព្វានគាមិមគ្គោ ។

ហេតុនោះ ទ្រង់ត្រាស់ថា តថាគត មិនអាចដើម្បីដោះ យ៉ាងនេះខ្វះ ។ សមដូចព្រះពុទ្ធតម្រាស់នេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចុន្ទៈ បុគ្គលនោះ លិចចុះក្នុងភក់ខ្លួនឯង នឹងស្រង់បុគ្គលដទៃ ដែលលិចចុះក្នុងភក់បាន ហេតុនេះមិនដែលមានទេ ម្នាលចុន្ទៈ បុគ្គលនោះ មិនបានទូន្មាន មិនបានប្រៀនប្រដៅ មិនបានរំលត់កិលេសដោយខ្លួនឯង នឹងទូន្មានប្រៀនប្រដៅបុគ្គលដទៃ ឬថា ញ៉ាំងកិលេសរបស់បុគ្គលដទៃឲ្យរលត់បាន ហេតុនេះ មិនដែលមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត មិនអាចដោះ យ៉ាងនេះខ្វះ ។ មួយទៀត សមដូចព្រះពុទ្ធ-តម្រាស់នេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា

បុគ្គលធ្វើបាប ដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង
មិនធ្វើបាបដោយខ្លួនឯង រមែងស្អាតដោយខ្លួនឯង សេចក្តី
បរិសុទ្ធ និងសេចក្តីមិនបរិសុទ្ធ មានចំពោះខ្លួន បុគ្គលដទៃ
មិនគប្បីញ៉ាំងបុគ្គលដទៃឲ្យស្អាតបានទេ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគត មិនអាចដោះ យ៉ាងនេះខ្វះ ។ មួយទៀត សមដូចព្រះពុទ្ធតម្រាស់នេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ព្រះនិព្វាន ក៏មាននៅស្រាប់ ទាំងផ្លូវទៅកាន់ព្រះនិព្វាន ក៏មាននៅស្រាប់ តថាគតជាអ្នកបបួល ក៏មាននៅស្រាប់

អថ ច បន មម សាវកា មយា ឯវំឱវទិយមានា ឯវំអនុសាសិយមានា អប្បេកច្ចេ អច្ចន្តនិដ្ឋំ និព្វានំ អារាធេន្តិ ឯកច្ចេ នារាធេន្តិ ឯត្ថ ក្យាហំ ព្រាហ្មណ ករោមិ មគ្គក្ខាយី ព្រាហ្មណ តថាគតោ មគ្គំ បុដ្ឋោ(១) អាចិក្ខតិ អត្តនា បដិបជ្ជមានា មុញ្ចេយ្យុន្តិ ឯវម្បិ នាហំ សមិស្សាមិ បមោចនាយ ។

[២១៦] កថង្កថី ធោតក កាញ្ចិ លោកេតិ ក-ថង្កថី បុគ្គលំ សកង្ខំ សវិលំ ទ្វេឡ្ហកំ(២) សវិចិកិច្ឆំ ។ កញ្ចីតិ កញ្ចិ ខត្តិយំ វា ព្រាហ្មណំ វា វេស្សំ វា សុទ្ទំ វា គហដ្ឋំ វា បព្វជិតំ វា ទេវំ វា មនុស្សំ វា ។ លោកេតិ អបាយលោកេ ។ បេ ។ អាយតនលោកេតិ កថង្កថី ធោតក កាញ្ចិ លោកេ ។

១ ម. ពុទ្ធោ ។ ២ ម. សទ្វេឡ្ហកំ ។

តែថា ពួកសាវ័ករបស់តថាគត ដែលតថាគតទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ពួកខ្លះ បានសម្រេចព្រះនិព្វានជាទីបំផុតដោយពិត ពួកខ្លះក៏មិនបានសម្រេច ម្នាលព្រាហ្មណ៍ តថាគតនឹងធ្វើដូចម្តេចក្នុងបុគ្គលពួកនេះ ម្នាលព្រាហ្មណ៍ ព្រះតថាគត ជាអ្នកប្រាប់ផ្លូវ បើគេសួរផ្លូវហើយ ទើបព្រះតថាគតប្រាប់បាន បុគ្គលកាលប្រតិបត្តិដោយខ្លួនឯងគប្បីរួចបាន ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតមិនអាចដោះ យ៉ាងនេះខ្លះ ។

[២១៦] ពាក្យថា ម្នាលធោតកៈ (តថាគតមិនអាចដើម្បីដោះ) អ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្តីសង្ស័យបានទេ គឺបុគ្គលដែលមានសេចក្តីសង្ស័យ ប្រកបដោយសេចក្តីងឿងឆ្ងល់ មានសេចក្តីរឹងរូស មានការយល់ជាពីរផ្លូវ មានសេចក្តីស្ទាក់ស្ទើរ ។ ពាក្យថា អ្នកណាមួយ គឺក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សុទ្ទៈក្តី គ្រហស្ថក្តី បព្វជិតក្តី ទេវតាក្តី មនុស្សក្តី ណាមួយ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ ក្នុងអាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលធោតកៈ តថាគតមិនអាចដើម្បីដោះ អ្នកណាមួយ ក្នុងលោកនេះ ដែលមានសេចក្តីសង្ស័យបានទេ ។

ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២១៧] ជម្មញ្ច សេដ្ឋំ អាជានមានោតិ ជម្មំ សេដ្ឋំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្ពុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ សេដ្ឋន្តិ អគ្គំ សេដ្ឋំ វិសេដ្ឋំ ចាមោក្ខំ ឧត្តមំ បវរំ ជម្មំ ។ អាជានមានោតិ អាជានមានោ វិជានមានោ បដិវិជានមានោ បដិវិជ្ឈមានោតិ ជម្មញ្ច សេដ្ឋំ អាជានមានោ ។

[២១៨] ឯវំ តុវំ ឱឃមិមំ តរេសីតិ ឯវំ តុវំ កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ តរេយ្យាសិ[១] សមតិក្កមេយ្យាសិ វីតិវត្តេយ្យាសីតិ ឯវំ តុវំ ឱឃមិមំ តរេសិ ។ តេនាហ ភគវា

ជាហំ សមិស្សាមិ បមោចនាយ
កថង្កថី ធោតក កញ្ចិ លោកេ
ជម្មញ្ច សេដ្ឋំ អាជានមានោ
ឯវំ តុវំ ឱឃមិមំ តរេសីតិ ។

១ ឯត្ថន្តរេ ឧត្តរេយ្យាសិ តរេយ្យាសីតិ ទិស្សតិ ។

ជោតកមាណវកប្បញ្ហានិទ្ទេស

[២១៧] ពាក្យថា ប៉ុន្តែ កាលបើអ្នកបានដឹងច្បាស់នូវធម៌ដ៏ប្រសើរ សេចក្តីថា អមតនិព្វាន លោកហៅថា ធម៌ដ៏ប្រសើរ បានខាង ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការ ប្រាសចាករាគៈ ការរលត់ និព្វាន ។ ពាក្យថា ប្រសើរ គឺធម៌ ដ៏លើស ដ៏ប្រសើរ ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ។ ពាក្យថា ដឹងច្បាស់ គឺដឹងប្រាកដ យល់ច្បាស់ ជ្រាបច្បាស់ ចាក់ ធ្លុះចំពោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ប៉ុន្តែ កាលបើអ្នកបានដឹង ច្បាស់ នូវធម៌ដ៏ប្រសើរ ។

[២១៨] ពាក្យថា យ៉ាងនេះ នឹងឆ្លងនូវឱឃៈនេះបាន គឺអ្នកគប្បី ឆ្លង គប្បីឈានកន្លង គប្បីប្រព្រឹត្តកន្លង នូវកាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) យ៉ាងនេះ នឹងឆ្លង ឱឃៈនេះបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលជោតកៈ តថាគតមិនអាចដើម្បីដោះអ្នកណាមួយ ក្នុង
លោកនេះ ដែលមានសេចក្តីសង្ស័យបានទេ ប៉ុន្តែ កាល
បើអ្នកបានដឹងច្បាស់នូវធម៌ដ៏ប្រសើរ យ៉ាងនេះ នឹងឆ្លងឱឃៈ
នេះបាន ។

[២១៩] អនុសាស ព្រហ្មេ ករុណាយមានោ
វិវេកធម្មំ យមហំ វិជញ្ញំ
យថាហំ អាកាសោ ច អព្យាបជ្ជមានោ
ឥធេវ សន្តោ អសិតោ ចរេយ្យំ ។

[២២០] អនុសាស ព្រហ្មេ ករុណាយមានោតិ អនុសាស ព្រហ្មេតិ អនុសាស ព្រហ្មេ អនុគ្គណ្ហ ព្រហ្មេ អនុកម្ប ព្រហ្មេតិ អនុសាស ព្រហ្មេ ។ ករុណាយមានោតិ ករុណាយមានោ អនុទ្ទយមានោ អនុរក្ខមានោ អនុគ្គណ្ហមានោ អនុកម្បមានោតិ អនុសាស ព្រហ្មេ ករុណាយមានោ ។

[២២១] វិវេកធម្មំ យមហំ វិជញ្ញន្តិ វិវេកធម្មំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ យមហំ វិជញ្ញន្តិ យំ អហំ ជានេយ្យំ វិជានេយ្យំ បដិវិជានេយ្យំ បដិវិជ្ឈេយ្យន្តិ[១] វិវេកធម្មំ យមហំ វិជញ្ញំ ។

១ ម. ជានេយ្យំ អាជានេយ្យំ វិជានេយ្យំ បដិវិជានេយ្យំ បដិវិជ្ឈេយ្យំ អធិគច្ឆេយ្យំ បស្សេយ្យំ សច្ឆិករេយ្យន្តិ ។

[២១៩] (ធោតកៈក្រាបទូលថា) បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀនប្រដៅ នូវវិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ ដើម្បីកុំឲ្យខ្ញុំព្រះអង្គទើសទាក់ ដូចអាកាស ជាបុគ្គលស្ងប់ មិនអាស្រ័យនៅ (ដោយកិលេស)ប្រព្រឹត្តក្នុងទីនេះឯង ។

[២២០] ពាក្យថា បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គប្រៀនប្រដៅ នៃបទថា បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណាប្រៀនប្រដៅ គឺ បពិត្រព្រហ្ម សូមព្រះអង្គប្រៀនប្រដៅ បពិត្រព្រហ្ម សូមព្រះអង្គអនុគ្រោះ បពិត្រព្រហ្ម សូមព្រះអង្គស្រោចស្រង់ ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គប្រៀនប្រដៅ ។ ពាក្យថា ទ្រង់ព្រះករុណា គឺទ្រង់ព្រះករុណា ទ្រង់អាណិត ទ្រង់អាសូរ ទ្រង់អនុគ្រោះ ទ្រង់ស្រោចស្រង់ ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀនប្រដៅ ។

[២២១] ពាក្យថា វិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ សេចក្តីថា អមតនិព្វាន លោកហៅថា វិវេកធម៌ បានដល់ ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ និព្វាន ។ ពាក្យថា ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ គឺឲ្យខ្ញុំព្រះអង្គចេះដឹង ដឹងច្បាស់ យល់ច្បាស់ ចាក់ធ្លុះចំពោះ ហេតុនោះ (លោកពោលថា) នូវវិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ ។

១៩៣

## ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២២២] យថាហំ អាកាសោ ច អព្យាបជ្ជមានោតិ យថា អាកាសោ នប្បជ្ជតិ ន ពជ្ឈតិ[១] ន បលិពជ្ឈតិ ឯវំ អបជ្ជមានោ អពជ្ឈមានោ[២] អបលិពជ្ឈមានោតិ ឯវម្បិ អាកាសោ ច[៣] អព្យាបជ្ជមានោ ។ យថា អាកាសោ នរជ្ជតិ លាខាយ វា ហលិទ្ទេន វា នីលេន វា មញ្ជេដ្ឋាយ វា ឯវំ អរជ្ជមានោ អទុស្សមានោ អមុយ្ហមានោ អកិលិយមានោតិ ឯវម្បិ អាកាសោ ច អព្យាបជ្ជមានោ ។ យថា អាកាសោ ន កុប្បតិ ន ព្យាបជ្ជតិ ន បដិលីយតិ ន បដិហញ្ញតិ ឯវំ អកុប្បមានោ អព្យាបជ្ជមានោ អប្បដិលីយមានោ អប្បដិហញ្ញមានោតិ[៤] ឯវម្បិ អាកាសោ ច អព្យាបជ្ជមានោ ។

[២២៣] ឥធេវ សន្តោ អសិតោ ចរេយ្យន្តិ ឥធេវ សន្តោតិ ឥធេវ សន្តោ សមានោ ឥធេវ និសីទន្តោ សមានោ ឥមស្មឹយេវ អាសនេ និសិន្នោ សមានោ

១ ម. ន គណ្ហាតិ ន ពជ្ឈតិ ។ ២ ម. អគណ្ហមានោ អពជ្ឈមានោ ។ ៣ ម. វ ។ ៤ ម. អប្បដិហញ្ញមានោ ។ អប្បដិហតមានោតិ ។

ធោតកមាណវកប្បញ្ហានិទ្ទេស

[២២២] ពាក្យថា ដើម្បីកុំឲ្យខ្ញុំព្រះអង្គទើសទាក់ ដូចអាកាស គឺឲ្យខ្ញុំព្រះអង្គមិនទើសទាល់ មិនជាប់ចំពាក់ មិនជាប់ស្អិត ដូចអាកាស មិនទើសទាល់ មិនជាប់ចំពាក់ មិនជាប់ស្អិត ដូច្នោះឯង ហេតុនោះ (លោកពោលថា) មិនទើសទាក់ ដូចអាកាស ដោយប្រការដូច្នេះខ្លះ ។ ឲ្យខ្ញុំព្រះអង្គ មិនត្រេកអរ មិនប្រទូស្ត មិនវង្វេង មិនលំបាកដូចអាកាស មិនជិតដោយល័ខ ឬដោយល្មៀត ដោយវត្ថុពណ៌ខៀវ ឬដោយវត្ថុពណ៌ហង្សបាទ ដូច្នោះឯង ហេតុនោះ (លោកពោលថា) មិនទើសទាក់ ដូចអាកាស ដោយប្រការដូច្នេះខ្លះ ។ ឲ្យខ្ញុំព្រះអង្គ មិនក្រោធ មិនបៀតបៀន មិនវិលវល់នៅ មិនលំបាក ដូចអាកាស មិនកម្រើក មិនបៀតបៀន មិនវិលវល់នៅ មិនលំបាក ដូច្នោះឯង ហេតុនោះ (លោកពោលថា) មិនទើសទាក់ដូចអាកាស ដោយប្រការដូច្នេះខ្លះ ។

[២២៣] អធិប្បាយពាក្យថា ជាបុគ្គលស្ងប់ មិនអាស្រ័យនៅ (ដោយកិលេស) ប្រព្រឹត្ត ក្នុងទីនេះឯង ត្រង់ពាក្យថា ជាបុគ្គលស្ងប់ក្នុងទីនេះឯង គឺជាអ្នកនៅក្នុងទីនេះឯង ជាអ្នកកំពុងអង្គុយក្នុងទីនេះឯង ជាអ្នកអង្គុយ លើអាសនៈនេះឯង ជាអ្នកអង្គុយក្នុងបរិស័ទនេះឯង

ឥមិស្សាយេវ បរិសាយ និសិន្នោ សមានោតិ ឯវម្បិ ឥធេវ សន្តោ ។ អថវា ឥធេវ សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោតិ ឯវម្បិ ឥធេវ សន្តោ ។ អសិតោតិ ទ្វេ និស្សយា តណ្ហានិស្សយោ ច ទិដ្ឋិនិស្សយោ ច ។ បេ ។ អយំ តណ្ហានិស្សយោ ។ បេ ។ អយំ ទិដ្ឋិនិស្សយោ ។ តណ្ហានិស្សយំ បហាយ ទិដ្ឋិនិស្សយំ បដិនិស្សជ្ជិត្វា ចក្ខុំ អនិស្សិតោ សោតំ អនិស្សិតោ ឃានំ អនិស្សិតោ ជិវ្ហំ អនិស្សិតោ កាយំ អនិស្សិតោ មនំ អនិស្សិតោ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរំ បិណ្ឌបាតំ សេនាសនំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ កាមធាតុំ រូបធាតុំ អរូបធាតុំ កាមភវំ រូបភវំ អរូបភវំ សញ្ញាភវំ អសញ្ញាភវំ នេវសញ្ញានាសញ្ញាភវំ ឯកវោការភវំ ចតុវោការភវំ បញ្ចវោការភវំ អតីតំ អនាគតំ បច្ចុប្បន្នំ[១]

---

១ ម. កុលេ គណេ អាវាសេ ។ ល ។ អតីតេ អនាគតេ បច្ចុប្បន្នេ ។

ហេតុនោះ (លោកពោលថា) ជាបុគ្គលស្ងប់ក្នុងទីនេះឯង ដោយប្រការដូច្នេះខ្លះ ។ មួយទៀត ជាអ្នកមានចិត្តស្ងប់រម្ងាប់ មានចិត្តស្ងប់រម្ងាប់ មានចិត្តរលត់ មានចិត្តស្ងប់ស្ងាត់ ក្នុងទីនេះឯង ហេតុនោះ (លោកពោលថា) ជាអ្នកស្ងប់ក្នុងទីនេះឯង ដោយប្រការដូច្នេះខ្លះ ។ ពាក្យថា មិនអាស្រ័យ សេចក្តីថា ការអាស្រ័យ ២ គឺ ការអាស្រ័យគឺតណ្ហា ១ ការអាស្រ័យគឺទិដ្ឋិ ១ ។ បេ ។ នេះ ការអាស្រ័យគឺតណ្ហា ។ បេ ។ នេះ ការអាស្រ័យគឺទិដ្ឋិ ។ បុគ្គលលះបង់ នូវការអាស្រ័យគឺតណ្ហា លះលែងនូវការអាស្រ័យគឺទិដ្ឋិ មិនអាស្រ័យភ្នែក មិនអាស្រ័យត្រចៀក មិនអាស្រ័យច្រមុះ មិនអាស្រ័យអណ្តាត មិនអាស្រ័យកាយ មិនអាស្រ័យចិត្ត រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន

ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ អនិស្សិតោ[១] អនល្លីនោ អនុបគតោ អនជ្ឈោសិតោ អនធិមុត្តោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិមរិយាទិកតេន[២] ចេតសា វិហរតីតិ អសិតោ ។ ចរេយ្យន្តិ ចរេយ្យំ វិចរេយ្យំ ឥរិយេយ្យំ វត្តេយ្យំ បាលេយ្យំ យបេយ្យំ យាបេយ្យន្តិ ឥធេវ សន្តោ អសិតោ ចរេយ្យំ ។ តេនាហ សោ ព្រាហ្មណោ

អនុសាស ព្រហ្មេ ករុណាយមានោ
វិវេកធម្មំ យមហំ វិជញ្ញំ
យថាហំ អាកាសោ ច អព្យាបជ្ជមានោ
ឥធេវ សន្តោ អសិតោ ចរេយ្យន្តិ ។

[២២៤] កិត្តយិស្សាមិ តេ សន្តឹ [ធោតកាតិ ភគវា]
ទិដ្ឋេ ធម្មេ អនីតិហំ
យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។

---

១ ម. អសិតោ អនិស្សិតោ ។ ២ ម. និស្សដោ វិប្បមុត្តោ វិសំយុត្តោ វិបរិយាទិកតេន ។

មិនអាស្រ័យ មិនផ្តេកផ្តិត មិនចូលទៅជិត មិនជាប់ចុះ មិនលង់ចុះ ដាក ចេញ មិនជាប់ រលាស់ចេញ នូវធម៌ដែលឃើញ ឮ ប៉ះពាល់ ឬ គប្បីដឹង ជាបុគ្គលមានចិត្តមិនសល់រល់ ហេតុនោះ (លោកពោលថា) មិនអាស្រ័យ ។ ពាក្យថា ប្រព្រឹត្ត គឺនៅ ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្ត ទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (លោកពោលថា) ជា អ្នកស្ងប់ មិនអាស្រ័យនៅ (ដោយកិលេស) ប្រព្រឹត្ត ក្នុងទីនេះឯង ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

> បពិត្រព្រះអង្គជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណា ប្រៀន ប្រដៅនូវវិវេកធម៌ ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ ដើម្បីកុំឲ្យខ្ញុំព្រះអង្គ ទើសទាក់ ដូចអាកាស ជាបុគ្គលស្ងប់ មិនអាស្រ័យនៅ (ដោយកិលេស) ប្រព្រឹត្ត ក្នុងទីនេះឯង ។

[២២៤] (ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ម្នាលធោតកៈ បុគ្គល មានស្មារតី ដឹងច្បាស់នូវសន្តិបទណា ហើយគប្បីប្រព្រឹត្តឆ្លងនូវ វិសត្តិកាតណ្ហា ក្នុងលោកបាន តថាគត នឹងសម្តែងប្រាប់អ្នក នូវសន្តិបទនោះ ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ ដែលឃើញហើយ ។

[២២៨] កិត្តយិស្សាមិ តេ សន្តិន្តិ រាគស្ស សន្តឹ ទោសស្ស សន្តឹ មោហស្ស សន្តឹ កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស សព្វកិលេសានំ សព្វទុច្ចរិតានំ សព្វទរថានំ សព្វបរិឡាហានំ សព្វសន្តាបានំ សព្វាកុសលាភិសង្ខារានំ សន្តឹ ឧបសន្តឹ វូបសន្តឹ និព្វុតឹ បដិប្បស្សទ្ធឹ កិត្តយិស្សាមិ អាចិក្ខិស្សាមិ ទេសិស្សាមិ បញ្ញបេស្សាមិ បដ្ឋបេស្សាមិ វិវរិស្សាមិ វិភជិស្សាមិ ឧត្តានីករិស្សាមិ បកាសិស្សាមីតិ កិត្តយិស្សាមិ តេ សន្តឹ ។ ធោតកាតិ ភគវា តិ ធោតកាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ធោតកាតិ ភគវា ។

[២២៥] ពាក្យថា តថាគតនឹងសម្តែងប្រាប់អ្នកនូវសន្តិបទនោះ គឺតថា-គត នឹងត្រាស់ ប្រាប់ សម្តែង បញ្ញត្ត តែងតាំង បើក បែក ធ្វើឲ្យងាយ ប្រកាសនូវការស្ងប់រាគៈ ការស្ងប់ទោសៈ ការស្ងប់មោហៈ នូវការរម្ងាប់ ការស្ងប់ ការរំលត់ ការស្ងប់ស្ងាត់នៃកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ ពួកកិលេសទាំងពួង ទុច្ចរិតទាំងពួង ការក្រវល់ក្រវាយទាំងពួង ការក្រហល់ក្រហាយទាំងពួង ការក្តៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួង ព្រោះហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតនឹងសម្តែងប្រាប់អ្នកនូវសន្តិបទនោះ ។ ពាក្យថា ម្នាលធោតកៈ នៃបទថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលធោតកៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលធោតកៈ ។

## ធោតកមាណវកបញ្ហានិទ្ទេសោ

[២២៦] ទិដ្ឋេ ធម្មេ អនីតិហន្តិ ទិដ្ឋេ ធម្មេតិ ទិដ្ឋេ ធម្មេ ញាតេ ធម្មេ តុលិតេ ធម្មេ តិរិតេ ធម្មេ វិភាវិតេ ធម្មេ វិភូតេ ធម្មេ សព្វេ[១] សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ទិដ្ឋេ ធម្មេ ញាតេ ធម្មេ តុលិតេ ធម្មេ តិរិតេ ធម្មេ វិភាវិតេ ធម្មេ វិភូតេ ធម្មេតិ ឯវម្បិ ទិដ្ឋេ ធម្មេ ។ អថវា ទុក្ខេ ទិដ្ឋេ ទុក្ខំ កថយិស្សាមិ សមុទយេ ទិដ្ឋេ សមុទយំ កថយិស្សាមិ មគ្គេ ទិដ្ឋេ មគ្គំ កថយិស្សាមិ និរោធេ ទិដ្ឋេ និរោធំ កថយិស្សាមីតិ ឯវម្បិ ទិដ្ឋេ ធម្មេ ។ អថវា ទិដ្ឋេ ធម្មេ[២] សន្ទិដ្ឋិកំ អកាលិកំ ឯហិបស្សិកំ ឱបនយិកំ បច្ចត្តំ វេទិតព្វំ វិញ្ញូហីតិ

---

១ ម. សព្វេ សង្ខារា ។ បេ ។ ធម្មេតិ នត្ថិ ។ ២ ម. ទិដ្ឋេ ធម្មេតិ នត្ថិ ។

ធោតកមាណវកប្បញ្ហានិទ្ទេស

[២២៦] អធិប្បាយពាក្យថា ដែលតថាគតជាក់ច្បាស់ ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ត្រង់ពាក្យថា ចំពោះធម៌ដែលឃើញហើយ គឺ ចំពោះធម៌ដែលឃើញ ធម៌ដែលដឹង ធម៌ដែលថ្លឹង ធម៌ដែលពិចារណា ធម៌ដែលចម្រើន ធម៌ដែលកើតប្រាកដហើយថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ចំពោះធម៌ដែលឃើញ ធម៌ដែលដឹង ធម៌ដែលថ្លឹង ធម៌ដែលពិចារណា ធម៌ដែលចម្រើន ធម៌ដែលប្រាកដហើយថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងពួងនោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) ចំពោះធម៌ដែលឃើញហើយ ដោយប្រការដូច្នេះខ្លះ ។ មួយទៀត តថាគត នឹងសម្ដែងនូវសេចក្ដីទុក្ខ ក្នុងទុក្ខដែលឃើញហើយ សម្ដែងនូវសមុទ័យ ក្នុងសមុទ័យដែលឃើញហើយ សម្ដែងនូវមគ្គ ក្នុងមគ្គដែលឃើញហើយ សម្ដែងនិរោធ ក្នុងនិរោធដែលឃើញហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ចំពោះធម៌ដែលឃើញហើយ ដោយប្រការដូច្នេះខ្លះ ។ មួយទៀត (តថាគតនឹងសម្ដែងធម៌) ដែលឃើញច្បាស់ដោយខ្លួនឯង ដែលឲ្យផលមិនរង់ចាំកាល ដែលគួរនឹងហៅថា អ្នកចូរមកមើលចុះ ដែលគួរបង្អោនចូលមក ដែលពួកវិញ្ញូជនគប្បីដឹងចំពោះខ្លួន ចំពោះធម៌ដែលតថាគតឃើញហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ចំពោះធម៌ដែលឃើញហើយ ដោយប្រការដូច្នេះខ្លះ

ឯវម្បិ ទិដ្ឋេ ធម្មេតិ ទិដ្ឋេ ធម្មេ ។ អនីតិហន្តិ ន ឥតិហំ ន ឥតិកិរាយ[១] ន បរម្បរាយ ន បិដកសម្បទាយ ន តក្កហេតុ ន នយហេតុ ន អាការបរិវិតក្កេន ន ទិដ្ឋិនិជ្ឈានក្ខន្តិយា សាមំ សយមភិញ្ញាតំ អត្តបច្ចក្ខំ ធម្មំ[២] កថយិស្សាមីតិ ទិដ្ឋេ ធម្មេ អនីតិហំ ។

[២២៧] យំ វិទិត្វា សតោ ចរន្តិ យំ វិទិតំ កត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ វិទិតំ កត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ វុច្ចតិ សតោ ។ ចរន្តិ ចរន្តោ វិចរន្តោ ឥរិយន្តោ វត្តេន្តោ បាលេន្តោ យបេន្តោ យាបេន្តោតិ យំ វិទិត្វា សតោ ចរំ ។

---

១ ម. ន កិរិយាយ ។ ២ ម. អត្តបច្ចក្ខធម្មំ តំ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ចំពោះធម៌ដែលឃើញហើយ ។ ពាក្យថា ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន គឺ តថាគតនឹងសម្តែងធម៌ដែលដឹងច្បាស់ចំពោះខ្លួនឯង ជាក់ច្បាស់ក្នុងខ្លួន មិនមែនដោយជឿស្តាប់បុគ្គលដទៃ មិនមែនជឿដោយអាងថាឮមកដូច្នេះ មិនមែនដោយឮត ៗ គ្នា មិនមែនដោយការផ្ទៀងផ្ទាត់នឹងក្បួន មិនមែនដោយហេតុនៃការត្រិះរិះ មិនមែនដោយហេតុនៃការត្រេះត្រាន់ មិនមែនដោយការជញ្ជឹងនូវអាការៈ មិនមែនដោយហេតុដែលខ្លួនយល់ ខ្លួនពិនិត្យ ខ្លួនចូលចិត្តហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ។

[២២៧] ពាក្យថា បុគ្គលមានស្មារតី ដឹងច្បាស់នូវសន្តិបទណា ហើយគប្បីប្រព្រឹត្ត សេចក្តីថា បុគ្គលធ្វើឲ្យដឹង ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យជាក់ច្បាស់នូវធម៌ណា ថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ធ្វើឲ្យដឹង ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដថា ធម្មជាតណាមួយមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ ពាក្យថា មានស្មារតី គឺមានស្មារតីដោយហេតុ ៤ គឺ បុគ្គលចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថាអ្នកមានស្មារតី ។ បេ ។ បុគ្គលនោះលោកហៅថា អ្នកមានស្មារតី ។ ពាក្យថា ប្រព្រឹត្ត គឺប្រតិបត្តិ ប្រព្រឹត្តផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមានស្មារតី គួរដឹងច្បាស់នូវសន្តិបទណា ហើយប្រព្រឹត្ត ។

១៩៩

ធោតកមាណវកប្បញ្ហានិទ្ទេសោ

[២២៨] តរេ លោកេ វិសត្តិកន្តិ វិសត្តិកា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ វិសត្តិកាតិ កេនដ្ឋេន វិសត្តិកា ។ បេ ។ វិសដា វិត្ថតាតិ វិសត្តិកា ។ លោកេតិ អបាយលោកេ ។ បេ ។ អាយតនលោកេ ។ តរេ លោកេ វិសត្តិកន្តិ យា សា លោកេ វិសត្តិកា លោកេ តំ វិសត្តិកំ សតោ តរេយ្យ ឧត្តរេយ្យ បតរេយ្យ សមតិក្កមេយ្យ វីតិវត្តេយ្យាតិ តរេ លោកេ វិសត្តិកំ ។ តេនាហ ភគវា

កិត្តយិស្សាមិ តេ សន្តឹ [ធោតកាតិ ភគវា]

ទិដ្ឋេ ធម្មេ អនីតិហំ

យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកន្តិ ។

ធោតកមាណវកប្បញ្ហានិទ្ទេស

[២២៨] ពាក្យថា ធ្វង់វិសត្តិកាតណ្ហា ក្នុងលោក បាន សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានខាង តម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរ ត្រង់ពាក្យថា វិសត្តិកា ចុះតណ្ហាឈ្មោះថា វិសត្តិកា ដោយអត្ថដូចម្តេច ។ បេ ។ ឈ្មោះថា វិសត្តិកា ព្រោះជាធម្មជាតិផ្សាយទូទៅ ផ្សព្វផ្សាយ ទៅ ។ ពាក្យថា ក្នុងលោក គឺ ក្នុងអបាយលោក ។ បេ ។ ក្នុងអាយ-តនលោក ។ ពាក្យថា ធ្វង់វិសត្តិកាតណ្ហា ក្នុងលោកបាន មាន ន័យថា តណ្ហាណា ដែលផ្សាយទៅកាន់អារម្មណ៍ផ្សេងៗ ក្នុងលោក បុគ្គលមានស្មារតី គប្បីធ្វង ធ្វងឡើង ធ្វងរំលង ធ្វងកាត់ ផ្ទោះរំលង នូវតណ្ហាដែលផ្សាយទៅកាន់អារម្មណ៍ផ្សេងនោះៗ ក្នុងលោកបាន ហេតុ នោះ (ទ្រង់ត្រាស់ថា) ធ្វងនូវវិសត្តិកាតណ្ហា ក្នុងលោកបាន ។ ហេតុ នោះ ព្រះមានព្រះភាគ ត្រាស់ថា

ម្នាលធោតកៈ បុគ្គលមានស្មារតី ដឹងច្បាស់នូវសន្តិ-
បទណា ហើយគប្បីប្រព្រឹត្តធ្វងវិសត្តិកាតណ្ហា ក្នុងលោក
បាន តថាគតនឹងសម្តែងប្រាប់អ្នក នូវសន្តិបទនោះ ដែល
តថាគតជាក់ច្បាស់ក្នុងខ្លួន ចំពោះធម៌ដែលឃើញហើយ ។

[២២៩] តញ្ចាហំ អភិជប្បាមិ មហេសី សន្តិមុត្តមំ
យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។

[២៣០] តញ្ចាហំ អភិជប្បាមីតិ តន្តិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសន្ធិំ ។ អភិជប្បាមីតិ ជប្បាមិ អភិជប្បាមិ មោចាមិ អនុមោចាមិ សាធិយាមិ បត្ថ-យាមិ បិហយាមិ អភិជប្បាមីតិ តញ្ចាហំ អភិជប្បាមិ មហេសី សន្តិមុត្តមន្តិ មហេសីតិ ភគវា មហន្តំ សីលក្ខន្ធំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ មហន្តំ សមាធិក្ខន្ធំ ។ បេ ។ កហំ ទេវទេវោ កហំ នរាសភោតិ មហេសី ។ សន្តិមុត្តមន្តិ សន្តិ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ ឧត្តមន្តិ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរន្តិ មហេសី សន្តិមុត្តមំ ។

[២២៩] (ជោតកៈ ក្រាបទូលថា) បពិត្រព្រះមហេសី បុគ្គលមានស្មារតី ដឹងនូវសន្តិបទណា ហើយគប្បីប្រព្រឹត្តឆ្លងនូវវិសត្តិកាតណ្ហាក្នុងលោកបាន ខ្ញុំព្រះអង្គនឹងត្រេកអរចំពោះសន្តិបទដ៏ឧត្តមនោះ ។

[២៣០] អធិប្បាយពាក្យថា ខ្ញុំព្រះអង្គនឹងត្រេកអរ ចំពោះសន្តិបទនោះ ត្រង់ពាក្យថា ចំពោះសន្តិបទនោះ គឺចំពោះព្រះពុទ្ធដីកា គន្ទងព្រះពុទ្ធដីកា ទេសនា អនុសន្ធិរបស់ព្រះអង្គ ។ ពាក្យថា នឹងត្រេកអរ គឺខ្ញុំព្រះអង្គនឹងត្រេកអរ ត្រេកអរចំពោះ រីករាយ រីករាយតាម ជ្រះថ្លា ប្រាថ្នាស្រឡាញ់ជាប់ចិត្ត ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គនឹងត្រេកអរចំពោះសន្តិបទនោះ ។ ពាក្យថា បពិត្រព្រះមហេសី... សន្តិបទដ៏ឧត្តម ត្រង់ពាក្យថា ព្រះមហេសី សេចក្តីថា ព្រះនាមថា មហេសីព្រោះព្រះមានព្រះភាគទ្រង់រក ស្វែង ស្វះស្វែង នូវកងសីលដ៏ធំ ។ ព្រះនាមថាមហេសី (ព្រោះព្រះមានព្រះភាគស្វែងរក) នូវកងសមាធិដ៏ធំ ។ បេ ។ ព្រះពុទ្ធជាទេវតាកន្ទងជាងទេវតា គង់ ក្នុងទីណា ព្រះពុទ្ធជានរៈអង់អាច គង់ ក្នុងទីណា ។ ពាក្យថា សន្តិបទដ៏ឧត្តម សេចក្តីថា អមតនិព្វាន លោកហៅថា សន្តិបទ បានខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ និព្វាន ។ ពាក្យថា ដ៏ឧត្តម គឺ ប្រសើរ ប្រសើរផុត ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ហេតុនោះ (លោកពោលថា) បពិត្រព្រះមហេសី.....សន្តិបទដ៏ឧត្តម ។

ធោតកមាណវកប្បញ្ញានិទ្ទេសោ

[២៣១] យំ វិជិត្វា សតោ ចរន្តិ យំ វិជិតំ កត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ យំ វិជិតំ កត្វា តុលយិត្វា តិ-រយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិ-ប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ វុច្ចតិ សតោ ។ ចរន្តិ ចរន្តោ វិចរន្តោ ឥរិយន្តោ វត្តេន្តោ ចាលេន្តោ យបេន្តោ យាបេន្តោតិ យំ វិជិត្វា សតោ ចរំ ។

[២៣២] តរេ លោកេ វិសត្តិកន្តិ វិសត្តិកា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ វិសត្តិកាតិ កេនដ្ឋេន វិសត្តិកា ។ បេ ។ វិសដា វិត្ថតាតិ វិសត្តិកា ។ លោកេតិ អបាយលោកេ ។ បេ ។

ធោតកមាណវកប្បញ្ហានិទ្ទេស

[២៣១] ពាក្យថា បុគ្គលមានស្មារតី ដឹងនូវសន្តិបទណា ហើយគប្បីប្រព្រឹត្ត គឺបុគ្គលធ្វើឲ្យដឹង ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដ នូវធម៌ណាថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ធ្វើឲ្យដឹង ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដ នូវធម៌ណាថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ ពាក្យថា មានស្មារតី គឺមានស្មារតី ដោយហេតុ ៤ គឺ បុគ្គលចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថា អ្នកមានស្មារតី ។ បេ ។ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ។ ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (លោកពោលថា) មានស្មារតី ដឹងនូវសន្តិបទណា ហើយគប្បីប្រព្រឹត្ត ។

[២៣២] អធិប្បាយពាក្យថា ឆ្លងវិសត្តិកាតណ្ហា ក្នុងលោកបាន សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានខាង តម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរ ត្រង់ពាក្យថា វិសត្តិកា ចុះតណ្ហាឈ្មោះថា វិសត្តិកា ដោយអត្ថដូចម្តេច ។ បេ ។ តណ្ហាឈ្មោះវិសត្តិកា ព្រោះផ្សាយទួទៅ ផ្សព្វផ្សាយទៅ ។ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។

អាយតនលោកេ ។ តរេ លោកេ វិសត្តិកន្តិ យា សា លោកេ វិសត្តិកា លោកេ តំ វិសត្តិកំ សតោ តរេយ្យ ឧត្តរេយ្យ បតរេយ្យ សមតិក្កមេយ្យ វីតិវត្តេយ្យាតិ តរេ លោកេ វិសត្តិកំ ។ តេនាហ សោ ព្រាហ្មណោ

តញ្ចាហំ អភិនន្ទាមិ មហេសី សន្តិមុត្តមំ
យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកន្តិ ។

[២៣៣] យង្កិញ្ចិ សម្បជានាសិ (ធោតកាតិ ភគវា)
ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ
ឯតំ វិទិត្វា សង្គោតិ លោកេ
ភវាភវាយ មាកាសិ តណ្ហំ ។

[២៣៤] យង្កិញ្ចិ សម្បជានាសីតិ យង្កិញ្ចិ សម្បជានាសិ វិជានាសិ បដិវិជានាសិ បដិវិជ្ឈសីតិ យង្កិញ្ចិ សម្បជានាសិ ។ ធោតកាតិ ភគវាតិ ធោតកាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។

ក្នុងអាយតនលោក ។ ពាក្យថា ឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោកបាន សេចក្តីថា តណ្ហាឈ្មោះ វិសត្តិកា ណា ក្នុងលោក បុគ្គលមានស្មារតី គប្បីឆ្លង ឆ្លងឡើង ឆ្លងរំលង ឆ្លងកាត់ ផ្លោះរំលង នូវតណ្ហាឈ្មោះ វិសត្តិកានោះ ក្នុងលោកបាន ហេតុនោះ (លោកពោលថា) ឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោកបាន ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

បពិត្រព្រះមហេសី បុគ្គលមានស្មារតី ដឹងនូវសន្តិបទណា ហើយគប្បីប្រព្រឹត្តឆ្លង នូវវិសត្តិកាតណ្ហា ក្នុងលោកបាន ខ្ញុំព្រះអង្គនឹងត្រេកអរ ចំពោះសន្តិបទដ៏ឧត្តមនោះ ។

[២៣៣] (ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ម្នាលធោតកៈ បើអ្នកដឹងច្បាស់ នូវអារម្មណ៍ណាមួយ ក្នុងចំណែកខាងលើ ក្នុងចំណែកខាងក្រោម និងក្នុងចំណែកទទឹងគឺកណ្តាល លុះអ្នកបានដឹងនូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោកយ៉ាងនេះហើយ អ្នកកុំធ្វើនូវចំណង់ ក្នុងភពតូចភពធំឡើយ ។

[២៣៤] ពាក្យថា បើអ្នកដឹងច្បាស់នូវអារម្មណ៍ណាមួយ គឺបើអ្នកដឹងច្បាស់ យល់ច្បាស់ យល់ជាក់ ជ្រាបច្បាស់ នូវអារម្មណ៍ណាមួយ ហេតុនោះ (ទ្រង់ត្រាស់ថា) បើអ្នកដឹងច្បាស់នូវអារម្មណ៍ណាមួយ ។ ពាក្យថា ម្នាលធោតកៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតកៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។

ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ចិកា បញ្ញត្តិ យទិទំ ភគវាតិ ធោតកាតិ ភគវា ។

[២៣៥] ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេតិ ឧទ្ធន្តិ វុច្ចតិ អនាគតំ អធោតិ អតីតំ តិរិយញ្ចាបិ មជ្ឈេតិ បច្ចុប្បន្នំ ។ អថវា ឧទ្ធន្តិ សុខា វេទនា អធោតិ ទុក្ខា វេទនា តិរិយញ្ចាបិ មជ្ឈេតិ អទុក្ខមសុខា វេទនា ។ ឧទ្ធន្តិ កុសលា ធម្មា អធោតិ អកុសលា ធម្មា តិរិយញ្ចាបិ មជ្ឈេតិ អព្យាកតា ធម្មា ។ ឧទ្ធន្តិ ទេវលោកោ អធោតិ អបាយលោកោ តិរិយញ្ចាបិ មជ្ឈេតិ មនុស្សលោកោ ។ ឧទ្ធន្តិ អរូបធាតុ អធោតិ កាមធាតុ តិរិយញ្ចាបិ មជ្ឈេតិ រូបធាតុ ។ ឧទ្ធន្តិ ឧទ្ធំ បាទតលា អធោតិ អធោ កេសមត្ថកា តិរិយញ្ចាបិ មជ្ឈេតិ វេមជ្ឈេតិ ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ ។

ពាក្យថា ព្រះមានព្រះភាគ នេះជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលធោតកៈ ។

[២៣៩] ពាក្យថា ខាងលើ ខាងក្រោម និងទទឹងគឺកណ្តាល សេចក្តីថា អនាគត លោកហៅថា ខាងលើ អតីត លោកហៅថា ខាងក្រោម បច្ចុប្បន្ន លោកហៅថា ទទឹងគឺកណ្តាល ។ មួយទៀត សុខវេទនា លោកហៅថា ខាងលើ ទុក្ខវេទនា លោកហៅថា ខាងក្រោម អទុក្ខមសុខវេទនា លោកហៅថា ទទឹងគឺកណ្តាល ។ ពួកកុសលធម៌ លោកហៅថា ខាងលើ ពួកអកុសលធម៌ លោកហៅថា ខាងក្រោម ពួកធម៌អព្យាក្រឹត លោកហៅថា ទទឹងគឺកណ្តាល ។ ទេវលោក លោកហៅថា ខាងលើ អបាយលោក លោកហៅថា ខាងក្រោម មនុស្សលោក លោកហៅថា ទទឹងគឺកណ្តាល ។ អរូបធាតុ លោកហៅថា ខាងលើ កាមធាតុ លោកហៅថា ខាងក្រោម រូបធាតុ លោកហៅថា ទទឹងគឺកណ្តាល ។ តាំងអំពីផ្ទៃបាតជើងឡើងមក ហៅថា ខាងលើ តាំងអំពីចុងសក់ចុះទៅ ហៅថា ខាងក្រោម ត្រង់ទីពាក់កណ្តាលខ្លួន ហៅថា ទទឹងគឺកណ្តាល ហេតុនោះ (ទ្រង់ត្រាស់ថា) ខាងលើ ខាងក្រោម ទទឹង គឺកណ្តាល ។

[២៣៦] ឯតំ វិទិត្វា សង្គោតិ លោកេតិ សង្គោ ឯសោ លគ្គនំ ឯតំ ពន្ធនំ ឯតំ បលិពោធោ ឯសោតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ឯតំ វិទិត្វា សង្គោតិ លោកេ ។

[២៣៧] ភវាភវាយ មាកាសិ តណ្ហន្តិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ភវាភវាយាតិ ភវាភវាយ កម្មភវាយ បុនព្ភវាយ កាមភវាយ កម្មភវាយ កាមភវាយ បុនព្ភវាយ រូបភវាយ កម្មភវាយ រូបភវាយ បុនព្ភវាយ អរូបភវាយ កម្មភវាយ អរូបភវាយ បុនព្ភវាយ បុនប្បុនំ ភវាយ បុនប្បុនំ គតិយា បុនប្បុនំ ឧបបត្តិយា បុនប្បុនំ បដិសន្ធិយា បុនប្បុនំ អត្តភាវាភិនិព្វត្តិយា តណ្ហំ មាកាសិ មា ជនេសិ មា សញ្ជនេសិ មា និព្វត្តេសិ មា អភិនិព្វត្តេសិ បជហិ វិនោទេហិ ព្យន្តីករោហិ អនភាវង្គមេហីតិ ភវាភវាយ មាកាសិ តណ្ហំ ។ តេនាហ ភគវា

[២៣៦] ពាក្យថា លុះអ្នកបានដឹង នូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោក គឺបុគ្គលដឹង យល់ ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដថា នុ៎ះការជាប់ នុ៎ះការចំពាក់ នុ៎ះចំណង នុ៎ះកង្វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) លុះអ្នកបានដឹងនូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោក ។

[២៣៧] ពាក្យថា អ្នកកុំធ្វើនូវចំណង់ ក្នុងភពតូចភពធំឡើយ គឺចំណង់ក្នុងរូប ចំណង់ក្នុងសំឡេង ចំណង់ក្នុងក្លិន ចំណង់ក្នុងរស ចំណង់ក្នុងផ្សព្វ ចំណង់ក្នុងធម្មារម្មណ៍ ។ ពាក្យថា ក្នុងភពតូចភពធំ គឺអ្នកកុំធ្វើ កុំបង្កើត កុំបង្កើតព្រម កុំបង្កើតប្រាកដ កុំបង្កើតឡើង ចំពោះ គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពតទៅនូវចំណង់ក្នុងភពតូចភពធំ គឺកម្មភព បុនព្ភព គឺថា ក្នុងកាមភព កម្មភព ក្នុងកាមភព បុនព្ភព ក្នុងរូបភព កម្មភព ក្នុងរូបភព បុនព្ភព ក្នុងអរូបភព កម្មភព ក្នុងអរូបភព បុនព្ភព គឺក្នុងកំណើតរឿយៗ ក្នុងដំណើររឿយៗ ក្នុងការកើតរឿយៗ ក្នុងបដិសន្ធិរឿយៗ ក្នុងការបាននូវអត្តភាពរឿយ ៗ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកកុំធ្វើនូវចំណង់ ក្នុងភពតូចភពធំឡើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

២០៤

ធោតកមាណវកបញ្ហានិទ្ទេសោ

យង្កិញ្ចិ សម្បជានាសិ (ធោតកាតិ ភគវា)
ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ
ឯតំ វិទិត្វា សង្គោតិ លោកេ
ភវាភវាយ មាកាសិ តណ្ហន្តិ ។

សហគាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ធោតកមាណវកបញ្ហានិទ្ទេសោ បញ្ចមោ ។

---

ធោតកមាណវកប្បញ្ហានិទ្ទេស

ម្នាលធោតកៈ បើអ្នកដឹងច្បាស់នូវអារម្មណ៍ណាមួយ ក្នុងចំណែកខាងលើ ក្នុងចំណែកខាងក្រោម និងក្នុងចំណែកទទឹង គឺកណ្តាល លុះអ្នកបានដឹងនូវអារម្មណ៍នុ៎ះ ថាជាគ្រឿងជាប់នៅក្នុងលោកយ៉ាងនេះហើយ អ្នកកុំធ្វើនូវចំណង់ក្នុងភពតូចភពធំឡើយ ។

លុះចប់គាថាហើយ ។ បេ ។ (ធោតកៈ ក៏ប្រកាសខ្លួនថា) បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាព្រះសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ ធោតកមាណវកប្បញ្ហានិទ្ទេស ទី ៥ ។

# ឧបសីវមាណវកប្បញ្ហានិទ្ទេសោ

[២៣៨] ឯកោ អហំ សក្ក មហន្តមោឃំ
(ឥច្ចាយស្មា ឧបសីវោ)
អនិស្សិតោ នោ វិសហាមិ តារិតុំ
អារម្មណំ ព្រូហិ សមន្តចក្ខុ
យំ និស្សិតោ ឱឃមិមំ តរេយ្យំ ។

[២៣៩] ឯកោ អហំ សក្ក មហន្តមោឃន្តិ ឯកោតិ បុគ្គលោ វា មេ ទុតិយោ នត្ថិ ធម្មោ វា មេ ទុតិយោ នត្ថិ យំ វា បុគ្គលំ និស្សាយ ធម្មំ វា និស្សាយ មហន្តំ កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ តរេយ្យំ ឧត្តរេយ្យំ បតរេយ្យំ សមតិក្កមេ-យ្យំ វីតិវត្តេយ្យន្តិ ឯកោ ។ សក្កាតិ សក្កោ ។ ភគវា សក្យកុលា បព្វជិតោតិបិ សក្កោ ។ អថវា អឌ្ឍោ មហទ្ធនោ ធនវាតិបិ សក្កោ ។ តស្សិមានិ ធនានិ សេយ្យថីទំ សទ្ធាធនំ សីលធនំ ហិរិធនំ ឱត្តប្ប-ធនំ សុតធនំ ចាគធនំ បញ្ញាធនំ សតិប្បដ្ឋានធនំ ។ បេ ។

# ឧបសីវមាណវកប្បញ្ហានិទ្ទេស

[២៣៨] (ឧបសីវៈ មានអាយុ ទូលសួរដូច្នេះថា) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គម្នាក់ឯង មិនបានអាស្រ័យ(បុគ្គល ឬធម៌) ទើបមិនអាចឆ្លងអន្លង់ដ៏ធំបាន បពិត្រព្រះអង្គជាសមន្តចក្ខុ សូមព្រះអង្គ សម្តែងនូវអារម្មណ៍ ដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យហើយឆ្លងនូវអន្លង់នេះបាន ។

[២៣៩] អធិប្បាយពាក្យថា បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គម្នាក់ឯង... អន្លង់ធំបាន ត្រង់ពាក្យថា ម្នាក់ឯង គឺ បុគ្គលជាគម្រប់ពីរនឹងខ្ញុំមិនមាន ឬធម៌ជាគម្រប់ពីរនឹងខ្ញុំមិនមាន ដែលជាបុគ្គល ឬជាធម៌ដែលខ្ញុំព្រះអង្គអាស្រ័យហើយ គប្បីឆ្លង ឆ្លងឡើង ឆ្លងរំលង ឆ្លងកាត់ផ្ទោះរំលង នូវអន្លង់គឺកាម អន្លង់គឺភព អន្លង់គឺទិដ្ឋិ អន្លង់គឺអវិជ្ជាដ៏ធំបាន ហេតុនោះ (លោកពោលថា) ម្នាក់ឯង ។ ពាក្យថា បពិត្រព្រះអង្គ ជាសក្កៈ គឺព្រះមានព្រះភាគ ទ្រង់ព្រះនាមថា សក្កៈ ។ ព្រះមានព្រះភាគទ្រង់ព្រះនាមសក្កៈ ព្រោះទ្រង់ចេញចាកសក្យត្រកូល ហើយបព្វជ្ជា ក៏បាន ។ មួយទៀត ទ្រង់ព្រះនាមសក្កៈ ព្រោះទ្រង់ស្តុកស្តម្ភមានទ្រព្យច្រើន មានទ្រព្យធន ក៏បាន ។ ទ្រព្យទាំងឡាយនេះ របស់ព្រះមានព្រះភាគនោះ គឺ ទ្រព្យសទ្ធា ទ្រព្យសីល ទ្រព្យហិរិ ទ្រព្យឱត្តប្បៈ ទ្រព្យសុតៈ ទ្រព្យចាគៈ ទ្រព្យបញ្ញា ទ្រព្យសតិប្បដ្ឋាន ។ បេ ។

និព្វានគមនំ ។ ឥមេហិ អនេកវិធេហិ ធនវតេហិ អឌ្ឍោ មហទ្ធនោ ធនវាតិបិ សក្កោ ។ អថវា សក្កោ បហុ វិសវី អលមត្តោ សូរោ វីរោ វិក្កន្តោ អភីរុ អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោតិបិ សក្កោតិ ឯកោ អហំ សក្ក មហន្តមោឃំ ។ ឥច្ចាយស្មា ឧបសីវោតិ ឥច្ចាតិ[១] បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។ ឧបសីវោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្មា ឧបសីវោ ។

[២៤០] អនិស្សិតោ នោ វិសហាមិ តារិតុន្តិ អនិស្សិតោតិ បុគ្គលំ វា អនិស្សិតោ ធម្មំ វា អនិស្សិតោ ។ នោ វិសហាមីតិ ន ឧស្សហាមិ ន សក្កោមិ ន បដិពលោ ។ តារិតុន្តិ មហន្តំ កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ តារិតុំ ឧត្តរិតុំ បតរិតុំ សមតិក្កមិតុំ

១ ម. ឧបសីវោ ឥច្ចាតិ បទសន្ធិ ។ ល ។ ឧបសីវោតិ នត្ថិ ។

ទ្រព្យគឺនិព្វាន ។ ព្រះនាមថាសក្កៈ ព្រោះទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យធន ដោយធនរតន៍ទាំងនេះ ច្រើនប្រការ ក៏បាន ។ ឬថា ព្រះនាមថាសក្កៈ ព្រោះព្រះមានព្រះភាគ ទ្រង់អង់អាច អាចហានក្លាហាន មោះមុត ក្លៀវក្លា មានព្យាយាម ធ្លាប់ចូលកាន់សង្គ្រាម មិនខ្លាច មិនរន្ធត់ មិនតក់ស្លុត មិនរត់ចោល លះភ័យគួរខ្លាច មិនព្រឺរោម ក៏បាន ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គម្នាក់ឯង... អន្លង់ធំ ក៏បាន ។ ពាក្យថា ដូច្នេះ នៃបទថា ឧបសីវៈ មានអាយុ ទូលសួរដូច្នេះ គឺជាពាក្យតភ្ជាប់ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា ឧបសីវៈ គឺជានាម របស់ព្រាហ្មណ៍នោះ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) ឧបសីវៈ មានអាយុ ទូលសួរដូច្នេះ ។

[២៤០] ពាក្យថា ខ្ញុំព្រះអង្គមិនបានអាស្រ័យ (បុគ្គលឬធម៌) ទើបមិនអាចឆ្លង ត្រង់ពាក្យថា មិនបានអាស្រ័យ គឺមិនបានអាស្រ័យបុគ្គល ឬមិនបានអាស្រ័យធម៌ ។ ពាក្យថា មិនអាច គឺមិនអាច មិនហ៊ាន មិនប្រតិពល ។ ពាក្យថា ឆ្លង គឺរំលង ឆ្លងឡើង ឆ្លងរំលង ឆ្លងកាត់ ផ្ទោះរំលង នូវអន្លង់គឺកាម[១] អន្លង់គឺភព[២] អន្លង់គឺទិដ្ឋិ[៣] អន្លង់គឺអវិជ្ជា[៤] ដ៏ធំ

---

១ ដែលថាឆ្លងអន្លង់ គឺឆ្លងអន្លង់កាម ដោយអនាគាមិមគ្គ ។ ២ ឆ្លងអន្លង់ភពដោយអរហត្តមគ្គ ។ ៣ ឆ្លងអន្លង់ទិដ្ឋិ ដោយសោតាបត្តិមគ្គ ។ ៤ ឆ្លងអន្លង់អវិជ្ជា ដោយអរហត្តមគ្គ ។ អដ្ឋកថា ។

វីតិវត្តិតុន្តិ អនិស្សិតោ ជោ វិសហាមិ តារិតុំ ។

[២៤១] អារម្មណំ ព្រូហិ សមន្តចក្ខូតិ អារម្មណំ ព្រូហីតិ អារម្មណំ អាលម្ពណំ និស្សយំ ឧបនិស្សយំ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ អារម្មណំ ព្រូហិ ។ សមន្តចក្ខូតិ សមន្តចក្ខុ វុច្ចតិ សព្វញ្ញុតញ្ញាណំ ។ ភគវា តេន សព្វញ្ញុតញ្ញាណេន ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ ។

ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ
អថោ អវិញ្ញាតមជានិតព្វំ
សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ
តថាគតោ តេន សមន្តចក្ខូតិ ។

អារម្មណំ ព្រូហិ សមន្តចក្ខុ ។

ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គមិនបានអាស្រ័យ (បុគ្គល ឬធម៌) ទើបមិនអាចឆ្លង ។

[២៤១] ពាក្យថា បពិត្រព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គសម្តែងអារម្មណ៍ ត្រង់ពាក្យថា សូមព្រះអង្គសម្តែងអារម្មណ៍ គឺសូមព្រះអង្គពោល ប្រាប់ បង្ហាញ បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ប្រកាស នូវសភាពត្រេកអរ ជាទីតោង ជាទីអាស្រ័យ ជាទីពឹងផ្អែក ហេតុនោះ (លោកពោលថា) សូមព្រះអង្គសម្តែងអារម្មណ៍ ។ ពាក្យថា សមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ដល់ ដល់ព្រម មកដល់ មកដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយ ដោយសព្វញ្ញុតញ្ញាណនោះ ។

អ្វីមួយក្នុងលោក ដែលព្រះតថាគតនោះមិនឃើញ មិនជ្រាប
ឬមិនគប្បីជ្រាប មិនមានទេ របស់ណាដែលគួរដឹង ព្រះ
តថាគត ទ្រង់ជ្រាបរបស់ទាំងអស់នោះ ហេតុនោះ ព្រះ
តថាគត ទ្រង់ព្រះនាមថា សមន្តចក្ខុ ។

ហេតុនោះ (ទើបមានពាក្យថា) បពិត្រព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គសម្តែងអារម្មណ៍ ។

២០៩

ឧបសីវមាណវកបញ្ហានិទ្ទេសោ

[២៤២] យំ និស្សិតោ ឱឃមិមំ តរេយ្យន្តិ យំ និស្សិតោតិ យំ វា បុគ្គលំ និស្សិតោ ធម្មំ វា និស្សិតោ ។ ឱឃមិមំ តរេយ្យន្តិ មហន្តំ កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ តរេយ្យំ ឧត្តរេយ្យំ បតរេយ្យំ សមតិក្កមេយ្យំ វីតិវត្តេយ្យន្តិ យំ និស្សិតោ ឱឃមិមំ តរេយ្យំ ។ តេនាហ សោ ព្រាហ្មណោ

ឯកោ អហំ សក្ក មហន្តមោឃំ

(ឥច្ចាយស្មា ឧបសីវោ)

អនិស្សិតោ នោ វិសហាមិ តារិតុំ

អារម្មណំ ព្រូហិ សមន្តចក្ខុ

យំ និស្សិតោ ឱឃមិមំ តរេយ្យន្តិ ។

[២៤៣] អាកិញ្ចញ្ញំ បេក្ខមានោ សតិមា

(ឧបសីវាតិ ភគវា)

នត្ថីតិ និស្សាយ តរស្សុ ឱឃំ

កាមេ បហាយ វិរតោ កថាហិ

តណ្ហាក្ខយំ រត្តមហាភិបស្ស ។

ឧបសីវមាណវកបញ្ហានិទ្ទេស

[២៤២] ពាក្យថា ដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យ ហើយគប្បីឆ្លង អន្លង់នេះបាន ត្រង់ពាក្យថា ដែលនាំឲ្យអាស្រ័យ គឺអាស្រ័យបុគ្គល ឬអាស្រ័យធម៌ ។ ពាក្យថា គប្បីឆ្លងអន្លង់នេះបាន គឺគប្បីឆ្លង ឆ្លងរំលង ឆ្លងកាត់ ផ្លោះរំលង នូវអន្លង់គឺកាម អន្លង់គឺភព អន្លង់ គឺទិដ្ឋិ អន្លង់គឺអវិជ្ជា ដ៏ធំ ហេតុនោះ (លោកពោលថា) ដែលនាំឲ្យ ខ្ញុំព្រះអង្គអាស្រ័យ ហើយឆ្លងអន្លង់នេះបាន ។ ហេតុនោះ ព្រាហ្មណ៍ នោះ ពោលថា

បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គម្នាក់ឯង មិនបានអាស្រ័យ (បុគ្គលឬធម៌) ទើបមិនអាចឆ្លងនូវអន្លង់ដ៏ធំបាន បពិត្រ ព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គសម្តែងអារម្មណ៍ដែលនាំ ឲ្យខ្ញុំព្រះអង្គអាស្រ័យ ហើយឆ្លងអន្លង់នេះ ។

[២៤៣] (ព្រះមានព្រះភាគត្រាស់ថា) ម្នាលឧបសីវៈ អ្នកចូរមានស្មារតី សម្លឹងអាកិញ្ចញ្ញាយតនជ្ឈាន អាស្រ័យ (អាកិញ្ចញ្ញាយតនស- មាបត្តិ) ដោយបរិកម្មថាមិនមានៗ ហើយឆ្លងអន្លង់ចុះ អ្នកចូរ លះបង់កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ ហើយសម្លឹងនូវការអស់តណ្ហា ទាំងយប់ទាំងថ្ងៃ ។

[២៤៤] អាកិញ្ចញ្ញំ បេក្ខមានោ សតិមាតិ សោ ព្រាហ្មណោ បកតិយា អាកិញ្ចញ្ញាយតនសមាបត្តឹ លាភីយេវ និស្សយំ ន ជានាតិ អយំ មេ និស្សយោតិ ។ តស្ស ភគវា និស្សយញ្ច អាចិក្ខតិ ឧត្តរិញ្ច និយ្យានបថំ អាចិក្ខតិ នេវសញ្ញានាសញ្ញាយតនសមាបត្តឹ សមាបជ្ជិត្វា តតោ វុដ្ឋហិត្វា តត្ថ ជាតេ ចិត្តចេតសិកេ ធម្មេ អនិច្ចតោ បេក្ខមានោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បលោកតោ ឦតិតោ ឧបទ្ទវតោ អសាតតោ ភយតោ ឧបសគ្គតោ ចលតោ បភង្គុតោ អទ្ធុវតោ អតាណតោ អលេណតោ អសរណតោ អសរណីភូតតោ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ អាទីនវតោ វិបរិណាមធម្មតោ អសារកតោ អឃមូលតោ វិភវតោ សាសវតោ វធកតោ សង្ខតតោ មារាមិសតោ

[២៤៤] ពាក្យថា អ្នកចូរមានស្មារតី សម្លឹងអាកិញ្ចញ្ញាយត-នដ្ឋាន អធិប្បាយថា ព្រាហ្មណ៍នោះ បានអាកិញ្ចញ្ញាយតនសមាបត្តិតាមប្រក្រតី តែមិនដឹងការអាស្រ័យថា អាកិញ្ចញ្ញាយតនសមាបត្តិនេះជាទីអាស្រ័យរបស់អាត្មាទេ ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់ទីអាស្រ័យផង ទ្រង់ប្រាប់ផ្លូវជាទីស្រោចស្រង់តទៅទៀតផង ដល់ព្រាហ្មណ៍នោះថា អ្នកចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ហើយចេញអំពីសមាបត្តិនោះ ហើយពិចារណាធម៌គឺចិត្តនិងចេតសិកទាំងឡាយ ដែលកើតហើយក្នុងសមាបត្តិនោះ ដោយសភាពថាមិនទៀង ពិចារណាមើល រំពឹងមើល សម្លឹងមើល រមិលមើល ដោយសភាពថាជាទុក្ខ ជារោគ ជាបូស ជាសរ ជាអន្តរាយ ជាជំងឺ ជារបស់អ្នកដទៃ ជារបស់វិនាស ជាចង្រៃ ជាឧបទ្រព ជារបស់មិនគួរប្រាថ្នា ជាភ័យ ជាឧបស័គ្គ ជារបស់ញាប់ញ័រ ជារបស់ពុករលួយ ជារបស់មិនឋិតថេរ ជារបស់ឥតទីពឹងផ្អែក ជារបស់ឥតទីពួន ជារបស់ឥតទីរឭក ជារបស់ឥតទីពំនឹង ជារបស់ឥតអំពើ ជារបស់ទទេ ជារបស់សូន្យ មិនមែនជារបស់ខ្លួន ជាទោស ជាសភាវៈប្រែប្រួល ជារបស់ឥតខ្លឹម ជារបស់ជាទីតាំងនៃទោស ជារបស់ប្រាសចាកសេចក្តីចម្រើន ជារបស់ប្រកបដោយអាសវៈ ជាអ្នកសម្លាប់ ជាទីតាក់តែង ជានុយរបស់មារ

ជាតិធម្មតោ ជរាធម្មតោ ព្យាធិធម្មតោ មរណធម្មតោ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មតោ សមុទយធម្មតោ អត្ថង្គមតោ អនស្សាទតោ អាទីនវតោ អនិស្សរណតោ បេក្ខមានោ ឱលោកយមានោ និជ្ឈាយមានោ ឧបបរិក្ខមានោ ។ សតិមាតិ យា សតិ អនុស្សតិ បដិស្សតិ ។ បេ ។ សម្មាសតិ អយំ វុច្ចតិ សតិ ។ ឥមាយ សតិយា ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ សោ វុច្ចតិ សតិមាតិ អាកិញ្ចញ្ញំ បេក្ខមានោ សតិមា ។ ឧបសីវាតិ ភគវាតិ ឧបសីវាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ឧបសីវាតិ ភគវា ។

[២៤៥] នត្ថីតិ និស្សាយ តរស្សុ ឱឃន្តិ នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនសមាបត្តិ ។ កឹការណា នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនសមាបត្តិ ។

មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានមរណៈជាធម្មតា មានសោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈជាធម្មតា ជារបស់មានធម៌ជាគ្រឿងប្រជុំកើត ជាធម្មតា ជារបស់ដល់នូវការវិនាសជាធម្មតា ជារបស់មិនមានអានិសង្ស ជារបស់មានទោស មិនជាទីរលាស់ចេញជាធម្មតា ។ ពាក្យថា មានស្មារតី សេចក្តីថា ស្មារតី ការរឭករឿយៗ ការរឭកចំពោះ ។ បេ ។ ការរឭកប្រពៃ ណា នេះ ហៅថា ស្មារតី ។ បុគ្គលណាដល់ ដល់ព្រម ចូលទៅដល់ ចូលទៅដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយដោយស្មារតីនេះ បុគ្គលនោះ លោកហៅថា អ្នកមានស្មារតី ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកចូរមានស្មារតី សម្លឹងអាកិញ្ចញ្ញាយតនដ្ឋាន ។ ពាក្យថា ម្នាលឧបសីវៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ គឺព្រះមានព្រះភាគ ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។ ពាក្យថាព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យច្បាស់លាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ។

[២៤៥] ពាក្យថា អាស្រ័យ (អាកិញ្ចញ្ញាយតនសមាបត្តិ) ដោយបរិកម្មថាមិនមាន ៗ ហើយឆ្លងអន្លង់ចុះ បានដល់ គឺអាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ។ ចុះ អាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា វត្ថុតិចតួចមិនមាន តើព្រោះហេតុអ្វី ។

វិញ្ញាណញ្ចាយតនសមាបត្តឹ សតោ សមាបជ្ជិត្វា តតោ វុដ្ឋហិត្វា តញ្ញេវ វិញ្ញាណំ អភាវេតិ វិភាវេតិ អន្តរធាបេតិ នត្ថិ កិញ្ចីតិ បស្សតិ តំការណា នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនសមាបត្តិ ។ តំ និស្សាយ ឧបនិស្សាយ អារម្មណំ អាលម្ពណំ ករិត្វា កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ តរស្សុ ឧត្តរស្សុ បតរស្សុ សមតិក្កមស្សុ វីតិវត្តស្សុតិ នត្ថីតិ និស្សាយ តរស្សុ ឱឃំ ។

[២៤៦] កាមេ បហាយ វិរតោ កថាហីតិ កាមេតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ កាមេ បហាយាតិ វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ កាមេ បហាយ ។ វិរតោ កថាហីតិ កថង្កថា វុច្ចតិ វិចិកិច្ឆា ។

បុគ្គលមានស្មារតី ចូលវិញ្ញាណញ្ចាយតនសមាបត្តិ ចេញអំពីសមាបត្តិនោះហើយ មិនចម្រើន មិនអប់រំ ធ្វើឲ្យវិនាស នូវវិញ្ញាណនោះឯង ទើបឃើញថា វត្ថុតិចតួចមិនមាន ព្រោះហេតុនោះ អាកិញ្ចញ្ញាយតន-សមាបត្តិ ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ។ អ្នកចូរអាស្រ័យ អាស្រ័យស៊ប់នូវអាកិញ្ចញ្ញាយតនសមាបត្តិនោះ ហើយធ្វើឲ្យជាអារម្មណ៍ ឲ្យជាទីតោង ហើយឆ្លង ឆ្លងឡើង ឆ្លងរំលង ឆ្លងកាត់ ផ្លោះរំលង នូវអន្លង់គឺកាម អន្លង់គឺភព អន្លង់គឺទិដ្ឋិ អន្លង់គឺអវិជ្ជា ហេតុនោះ (ទ្រង់ត្រាស់ថា) អាស្រ័យ (អាកិញ្ចញ្ញាយតនសមាបត្តិ) ដោយបរិកម្មថា មិនមានៗ ហើយឆ្លងអន្លង់ចុះ ។

[២៤៦] អធិប្បាយពាក្យថា អ្នកចូរលះបង់កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ បើតាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះ លោកហៅថា វត្ថុកាម ។ បេ ។ នេះ លោកហៅថា កិលេសកាម ។ ពាក្យថា អ្នកចូរលះបង់កាមទាំងឡាយ គឺអ្នកចូរកំណត់ដឹងវត្ថុកាម ហើយលះបង់ បោះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាពតទៅ នូវកិលេសកាមទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកចូរលះបង់កាមទាំងឡាយ ។ ពាក្យថា វៀរចាកកថាទាំងឡាយ សេចក្តីថា វិចិកិច្ឆា លោកហៅថា កថង្កថា ។

ទុក្ខេ កង្ខា ។ បេ ។ ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ ។ កថង្កថាយ អារតោ វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ឯវម្បិ វិរតោ កថាហិ ។ អថវា ទ្វត្តឹសាយ តិរច្ឆានកថាយ អារតោ វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសំយុត្តោ វិមរិយា-ទិកតេន ចេតសា វិហរតីតិ ឯវម្បិ វិរតោ កថាហីតិ កាមេ បហាយ វិរតោ កថាហិ ។

[២៤៧] តណ្ហាក្ខយំ រត្តមហាភិបស្សាតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វ-តណ្ហា ធម្មតណ្ហា ។ រត្តន្តិ រត្តិ ។ អហោតិ ទិវសោ ។ រត្តិញ្ច ទិវា ច តណ្ហាក្ខយំ រាគក្ខយំ ទោសក្ខយំ មោ-ហក្ខយំ គតិក្ខយំ ឧបបត្តិក្ខយំ បដិសន្ធិក្ខយំ ភវ-ក្ខយំ សំសារក្ខយំ វដ្ដក្ខយំ បស្ស អភិបស្ស ទក្ខ ឱលោកយ និជ្ឈាយ ឧបបរិក្ខាតិ តណ្ហាក្ខយំ រត្តម-ហាភិបស្ស ។ តេនាហ ភគវា

សេចក្ដីងឿងឆ្ងល់ក្នុងទុក្ខ ។ បេ ។ ភាពនៃចិត្តញាប់ញ័រ ការរសេមរសាមនៃចិត្ត ។ បុគ្គលវៀរ វៀរស្រឡះ លះបង់ ចេញផុត លះលែងរួចស្រឡះ ប្រាសចេញចាកសេចក្ដីសង្ស័យ ជាអ្នកមានចិត្តមិនសល់រំលង បុគ្គលវៀរចាកកថាទាំងឡាយ ដោយប្រការដូច្នេះ ក៏បាន ។ មួយទៀត បុគ្គលវៀរ វៀរស្រឡះ លះបង់ ចេញផុត លះលែង រួចស្រឡះ ប្រាសចេញចាកតិរច្ឆានកថា ៣២ ជាបុគ្គលមានចិត្តមិនសល់រំលង បុគ្គលវៀរចាកកថាទាំងឡាយ ដោយប្រការដូច្នេះ ក៏បាន ហេតុដូច្នោះ (ទ្រង់ត្រាស់ថា) អ្នកចូរលះបង់កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ ។

[២៤៧] អធិប្បាយពាក្យថា សម្លឹងនូវការអស់តណ្ហាទាំងយប់ទាំងថ្ងៃ ត្រង់ពាក្យថា តណ្ហា គឺរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា យប់ គឺរាត្រី ។ ពាក្យថា ថ្ងៃ គឺវេលាដែលមានពន្លឺព្រះអាទិត្យប្រាកដ ។ អ្នកចូរមើល មើលចំពោះ ចូរឃើញ ចូររមិលមើល ចូរសម្លឹងមើល ចូរពិចារណា នូវការអស់តណ្ហា ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ការអស់គតិ នូវការអស់ឧបបត្តិ ការអស់បដិសន្ធិ ការអស់ភព ការអស់សង្សារ ការអស់វដ្ដៈ ទាំងយប់ទាំងថ្ងៃ ហេតុនោះ (ទ្រង់ត្រាស់ថា) សម្លឹង នូវការអស់តណ្ហា ទាំងយប់ទាំងថ្ងៃ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អាកិញ្ចញ្ញំ បេក្ខមានោ សតិមា

(ឧបសីវាតិ ភគវា)

នត្ថីតិ និស្សាយ តរស្សុ ឱឃំ

កាមេ បហាយ វិរតោ កថាហិ

តណ្ហក្ខយំ រត្តមហាភិបស្សាតិ ។

[២៤៨] សព្វេសុ កាមេសុ យោ វីតរាគោ

(ឥច្ចាយស្មា ឧបសីវោ)

អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ

សញ្ញាវិមោក្ខេ បរមេធិមុត្តោ[១]

តិដ្ឋេ នុ សោ តត្ថ អនានុយាយី ។

[២៤៩] សព្វេសុ កាមេសុ យោ វីតរាគោតិ សព្វេសូតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ សព្វេសូតិ ។ កាមេសូតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុ-កាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។

១ ឱ. វិមុត្តោ ។

(ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ) អ្នកចូរមានស្មារតី សម្លឹងអាកិញ្ចញ្ញាយតនជ្ឈាន អាស្រ័យអាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា មិនមានៗ ហើយឆ្លងអន្លង់ចុះ អ្នកចូរលះបង់កាមទាំងឡាយ ហើយវៀរចាកកថាទាំងឡាយចេញ ហើយសម្លឹងនូវការអស់តណ្ហា ទាំងយប់ទាំងថ្ងៃ ។

[២៤៨] (ឧបសីវៈ មាណព មានអាយុ ទូលសួរដូច្នេះថា) បុគ្គលណាមិនមានតម្រេក ក្នុងកាមទាំងឡាយទាំងពួង លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះ ជាអ្នកមិនឃ្លាតគប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាន បានដែរឬទេ ។

[២៤៩] អធិប្បាយពាក្យថា បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង ត្រង់ពាក្យថា ទាំងពួង គឺសព្វទាំងអស់ គ្រប់ទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ទាំងពួង នេះជាពាក្យរួបរួម ។ ពាក្យថា ក្នុងកាមទាំងឡាយ បើតាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះហៅថា វត្ថុកាម ។ បេ ។ នេះហៅថា កិលេសកាម ។

សព្វេសុ កាមេសុ យោ វីតរាគោតិ សព្វេសុ កាមេសុ យោ វីតរាគោ[១] ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ វិក្ខម្ភិតរាគោតិ សព្វេសុ កាមេសុ យោ វីតរាគោ ។ ឥច្ចាយស្មា ឧបសីវោតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។ ឧបសីវោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្មា ឧបសីវោ ។

[២៥០] អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញន្តិ ហេដ្ឋិមា ឆ សមាបត្តិយោ ហិត្វា វជ្ជេត្វា[២] បរិច្ចជិត្វា អតិក្កមិត្វា សមតិក្កមិត្វា វីតិវត្តិត្វា អាកិញ្ចញ្ញាយតនសមាបត្តឹ និស្សិតោ អល្លីនោ ឧបាគតោ សមុបាគតោ អជ្ឈោសិតោ អធិមុត្តោតិ អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ ។

[២៥១] សញ្ញាវិមោក្ខេ បរមេធិមុត្តោតិ សញ្ញាវិមោក្ខា វុច្ចន្តិ សត្ត សញ្ញាសមាបត្តិយោ ។

---

១ ម. វិគតរាគោ ។ ២ ម. ចជិត្វា ។

ឧបសីវមាណវកបញ្ហានិទ្ទេស

ពាក្យថា បុគ្គលណា មិនមានតម្រេក ក្នុងកាមទាំងឡាយទាំងពួង មានន័យថា បុគ្គលណា មិនមានរាគៈ ខ្វាក់រាគៈ ខ្វាក់ចោលរាគៈ ផុតរាគៈ លះបង់រាគៈ លះបង់ផ្តាច់រាគៈ សង្កត់សង្កិនរាគៈ ក្នុងកាមទាំងឡាយទាំងពួង ហេតុនោះ (លោកសួរថា) បុគ្គលណា មិនមានតម្រេក ក្នុងកាមទាំងឡាយទាំងពួង ។ ពាក្យថា ដូច្នេះ នៃបទថា ឧបសីវៈមានអាយុសួរដូច្នេះ ជាពាក្យតភ្ជាប់ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា ឧបសីវៈ ជាឈ្មោះនៃព្រាហ្មណ៍នោះ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍នុ៎ះ ហេតុនោះ (មានពាក្យថា) ឧបសីវៈមានអាយុសួរដូច្នេះ ។

[២៥០] ពាក្យថា លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន គឺលះបង់ វៀរបង់ បោះបង់ កន្លងបង់ កន្លងរំលងប្រព្រឹត្តកន្លង នូវសមាបត្តិទាំង ៦ ពួដ៏ខាងក្រោម ហើយអាស្រ័យ ផ្អែកផ្អិត ចូលមកជិត ចូលមកជិតព្រម មានចិត្តឱនចុះ មានចិត្តឱនចុះស៊ប់ កាន់អាកិញ្ចញ្ញាយតនសមាបត្តិ ហេតុនោះ (លោកសួរថា) លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ។

[២៥១] ពាក្យថា ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ សេចក្តីថា សញ្ញាសមាបត្តិ ទាំង ៧ លោកហៅថា សញ្ញាវិមោក្ខ ។

តាសំ សញ្ញាសមាបត្តីនំ អាកិញ្ចញ្ញាយតនសមាបត្តិ វិមោក្ខា អគ្គា ច សេដ្ឋា ច វិសេដ្ឋា ច ចាមោក្ខា ច ឧត្តមា ច បវរា ច ។ បរមេ អគ្គេ សេដ្ឋេ វិសេដ្ឋេ ចាមោក្ខេ ឧត្តមេ បវរេ អធិមុត្តិវិមោក្ខេន អធិមុត្តោ តត្រាធិមុត្តោ តទធិមុត្តោ តច្ចរិតោ តព្ពហុលោ តគ្គរុកោ តន្និន្នោ តប្បោណោ តប្បព្ភារោ តទាធិបតេយ្យោតិ[១] សញ្ញាវិមោក្ខេ បរមេធិមុត្តោ ។

[២៤២] តិដ្ឋេ នុ សោ តត្ថ អនានុយាយីតិ[២] តិដ្ឋេយ្យ នុ សំសយបុច្ឆា[៣] វេមតិកបុច្ឆា អនេកំសបុច្ឆា ឯវំ នុ ខោ ន នុ ខោ កឹ នុ ខោ កថំ នុ ខោតិ តិដ្ឋេ នុ ។ តត្ថាតិ អាកិញ្ចញ្ញាយតនេ ។ អនានុយាយីតិ អនានុយាយី អវេធមានោ អវិគច្ឆមានោ អនន្តរធាយមានោ អបរិហិយមានោ[៤] ។

---

១ ម. តទធិមុត្តោ ទទធិបតេយ្យោតិ ។ ២ ម. អនានុវាយីតិ ។ ៣ ម. សំសយបុច្ឆា វិមតិបុច្ឆា ។ ៤ ម. អបរិហាយមានោ ។

អាកិញ្ចញ្ញាយតនសមាបត្តិ ជាវិមោក្ខដ៏ប្រសើរផង វិសេសផង ប្រសើរវិសេសផង ជាប្រធានផង ឧត្តមផង ថ្លៃថ្លាផង ជាងសញ្ញាសមាបត្តិទាំងនោះ ។ បុគ្គលចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ ជាកំពូល វិសេសប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ដោយអធិមុត្តវិមោក្ខ ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខនោះ មានចិត្តឱនចុះ ក្នុងសញ្ញាវិមោក្ខនោះ មានចិត្តជឿស៊ប់ក្នុងសញ្ញាវិមោក្ខនោះ ត្រាច់ទៅកាន់សញ្ញាវិមោក្ខនោះ ច្រើនដោយសញ្ញាវិមោក្ខនោះ ធូន់ក្នុងសញ្ញាវិមោក្ខនោះ ឱនទៅកាន់សញ្ញា-វិមោក្ខនោះ ទោរទៅកាន់សញ្ញាវិមោក្ខនោះ ឈមទៅកាន់សញ្ញា-វិមោក្ខនោះ មានសញ្ញាវិមោក្ខនោះជាអធិបតី ហេតុនោះ (លោកសួរថា) ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខ ដ៏ប្រសើរ ។

[២៥២] ពាក្យថា បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអា-កិញ្ចញ្ញាយតនដ្ឋានបានដែរឬទេ ត្រង់ពាក្យថា គប្បីតាំងនៅបានដែរឬទេ គឺជាពាក្យសួរដោយសង្ស័យ សួរដោយចិត្តបែកជាចំពាមពីរ សួរដោយការយល់ច្រើនយ៉ាងថា យ៉ាងនេះទេឬៗ មិនមែនទេ ដូចម្ដេចហ្ន៎ ដោយប្រការដូចម្ដេចហ្ន៎ ហេតុនោះ (លោកសួរថា) គប្បីតាំងនៅបានដែរឬទេ ។ ពាក្យថា ក្នុងនោះ គឺក្នុងអាកិញ្ចញ្ញាយតនៈ ។ ពាក្យថា ជាអ្នកមិនឃ្លាត គឺជាអ្នកមិនបែកចេញ មិនកម្រើក មិនប្រាស មិនវិនាស មិនសាបសូន្យ ។

អថវា អវជ្ជមានោ អទុស្សមានោ អមុយ្ហមានោ អកិ-លិយមានោតិ តិដ្ឋេ នុ សោ តត្ថ អនានុយាយី ។ តេនាហ សោ ព្រាហ្មណោ

សព្វេសុ កាមេសុ យោ វីតរាគោ

(ឥច្චាយស្មា ឧបសីវោ)

អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ

សញ្ញាវិមោក្ខេ បរមេធិមុត្តោ

តិដ្ឋេ នុ សោ តត្ថ អនានុយាយីតិ ។

[២៤៣] សព្វេសុ កាមេសុ យោ វីតរាគោ

(ឧបសីវាតិ ភគវា)

អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ

សញ្ញាវិមោក្ខេ បរមេធិមុត្តោ

តិដ្ឋេយ្យ សោ តត្ថ អនានុយាយី ។

[២៤៤] សព្វេសុ កាមេសុ យោ វីតរាគោតិ សព្វេសូតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ សព្វេសូតិ ។

ឬថា ជាអ្នកមិនត្រេកអរ មិនប្រទូស្ត មិនវង្វេង មិនលំបាក ហេតុនោះ (លោកសួរថា) បុគ្គលនោះជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញា-យតនជ្ឈានបានដែរឬទេ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

បុគ្គលណាមិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាន បានដែរឬទេ ។

[២៥៣] (ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបសីវៈ) បុគ្គលណា មិនមានតម្រេក ក្នុងកាមទាំងឡាយទាំងពួង លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះបាន ។

[២៥៤] អធិប្បាយពាក្យថា បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង ត្រង់ពាក្យថា ទាំងពួង គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ទាំងពួង នេះ ជាពាក្យរួបរួម ។

កាមេសូតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ សព្វេសុ កាមេសុ យោ វីតរាគោតិ សព្វេសុ កាមេសុ យោ វីតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ វិក្ខម្ភិតរាគោតិ សព្វេសុ កាមេសុ យោ វីតរាគោ ។ ឧបសីវាតិ ភគវាតិ ឧបសីវាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ឧបសីវាតិ ភគវា ។

[២៨៨] អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញន្តិ ហេដ្ឋិមា ឆ សមាបត្តិយោ ហិត្វា វជ្ជេត្វា បរិច្ចជិត្វា អតិក្កមិត្វា សមតិក្កមិត្វា វីតិវត្តិត្វា អាកិញ្ចញ្ញាយតនសមាបត្តឹ និស្សិតោ[១] អល្លីនោ ឧបាគតោ សមុបាគតោ អជ្ឈោសិតោ អធិមុត្តោតិ អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ ។

១ ម. និស្សិតោ អាសិតោ ។

ពាក្យថា ក្នុងកាមទាំងឡាយ បើតាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះ ហៅថា វត្ថុកាម ។ បេ ។ នេះហៅថា កិលេសកាម ។ ពាក្យថា បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង បានសេចក្តីថា បុគ្គលណាមិនមានរាគៈ លះរាគៈ ខ្ជាក់រាគៈ លែងរាគៈ ចោលរាគៈ លះបង់រាគៈ សង្កត់សង្កិនរាគៈ ក្នុងកាមទាំងឡាយទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលណាមិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង ។ ពាក្យថា ម្នាលឧបសីវៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ គឺព្រះមានព្រះភាគទ្រង់ហៅព្រាហ្មណ៍នោះ ដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគនេះជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគនេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ។

[២៥៥] ពាក្យថា លះបង់ សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន គឺលះបង់ វៀរបង់ បោះបង់ កន្លងបង់ កន្លងរំលង ប្រព្រឹត្តកន្លងនូវសមាបត្តិទាំង ៦ ខាងក្រោម ហើយអាស្រ័យ ផ្តេកផ្តិត ចូលមកជិត ចូលមកជិតព្រម ឱនចុះ ចុះស៊ប់កាន់អាកិញ្ចញ្ញាយតនសមាបត្តិ ហេតុនោះ (ទ្រង់ត្រាស់ថា) លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ។

ឧបសីវមាណវកប្បញ្ហានិទ្ទេសោ

[២៤៦] សញ្ញាវិមោក្ខេ បរមេធិមុត្តោតិ សញ្ញាវិ-
មោក្ខា វុច្ចន្តិ សត្ត សញ្ញាសមាបត្តិយោ ។ តាសំ
សញ្ញាសមាបត្តីនំ អាកិញ្ចញ្ញាយតនសមាបត្តិ វិមោ-
ក្ខា អគ្គា ច សេដ្ឋា ច វិសេដ្ឋា ច ធាមោក្ខា
ច ឧត្តមា ច បវរា ច ។ បរមេ អគ្គេ សេដ្ឋេ
វិសេដ្ឋេ ធាមោក្ខេ ឧត្តមេ បវរេ អធិមុត្តវិមោក្ខេន
អធិមុត្តោ តត្រាធិមុត្តោ តទធិមុត្តោ តច្ចរិតោ តព្ព-
ហុលោ តគ្គរុកោ តន្និន្នោ តប្បោណោ តប្បព្ភារោ
តទាធិបតេយ្យោតិ សញ្ញាវិមោក្ខេ បរមេធិមុត្តោ ។

[២៤៧] តិដ្ឋេយ្យ សោ តត្ថ អនានុយាយីតិ
តិដ្ឋេយ្យាតិ តិដ្ឋេយ្យ សដ្ឋីកប្បសហស្សានិ ។
តត្ថាតិ អាកិញ្ចញ្ញាយតនេ ។ អនានុយាយីតិ
អនានុយាយី អវេធមានោ អវិគច្ឆមានោ[១] អនន្តរ-
ធាយមានោ អបរិហិយមានោ ។ អថវា អរជ្ជមា-
នោ អទុស្សមានោ អមុយ្ហមានោ អកិលិយមានោតិ

១ ម. អធិគច្ឆមានោ ។

ឧបសីវមាណវកប្បញ្ហានិទ្ទេស

[២៥៦] ពាក្យថា ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ សេចក្តីថា សញ្ញាសមាបត្តិទាំង ៧ ហៅថា សញ្ញាវិមោក្ខ ។ អាកិញ្ចញ្ញាយតនសមាបត្តិ ជាវិមោក្ខដ៏ប្រសើរផង វិសេសផង ប្រសើរវិសេសផង ជាប្រធានផង ឧត្តមផង ថ្លៃថ្លាផង ជាងសញ្ញាសមាបត្តិទាំងនោះ ។ បុគ្គលចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ ជាកំពូល វិសេស ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ដោយអធិមុត្តវិមោក្ខ មានចិត្តឱនចុះក្នុងសញ្ញាវិមោក្ខនោះ ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខនោះ ត្រាច់ទៅកាន់សញ្ញាវិមោក្ខនោះ ច្រើនដោយសញ្ញាវិមោក្ខនោះ ធ្ងន់ក្នុងសញ្ញាវិមោក្ខនោះ ឱនទៅកាន់សញ្ញាវិមោក្ខនោះ ទោរទៅកាន់សញ្ញាវិមោក្ខនោះ ឈមទៅកាន់សញ្ញាវិមោក្ខនោះ មានសញ្ញាវិមោក្ខនោះជាអធិបតីហេតុនោះ (ទ្រង់ត្រាស់ថា) ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ ។

[២៥៧] ពាក្យថា បុគ្គលនោះ ជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនដ្ឋាននោះបាន ត្រង់ពាក្យថា គប្បីតាំងនៅ គឺគប្បីតាំងនៅអស់ពាន់នៃកប្ប ៦០ ។ ពាក្យថា ក្នុងអាកិញ្ចញ្ញាយតនដ្ឋាននោះ គឺក្នុងអាកិញ្ចញ្ញាយតនៈ ។ ពាក្យថា ជាអ្នកមិនឃ្លាត គឺជាអ្នកមិនបោះបង់ មិនកម្រើក មិនទៅប្រាស មិនវិនាស មិនសាបសូន្យ ។ ឬថា មិនត្រេកអរ មិនប្រទូស្ត មិនវង្វេង មិនលំបាក

តិដ្ឋេយ្យ សោ តត្ថ អនានុយាយី ។ តេនាហ ភគវា

សព្វេសុ កាមេសុ យោ វីតរាគោ

(ឧបសីវាតិ ភគវា)

អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ

សញ្ញាវិមោក្ខេ បរមេធិមុត្តោ

តិដ្ឋេយ្យ សោ តត្ថ អនានុយាយីតិ ។

[២៨៨] តិដ្ឋេ ចេ សោ តត្ថ អនានុយាយី

បូគម្បិ វស្សានំ(១) សមន្តចក្ខុ

តត្ថេវ សោ សីតិ សិយា វិមុត្តោ

ភវេថ(២) វិញ្ញាណំ តថាវិធស្ស ។

[២៨៩] តិដ្ឋេ ចេ សោ តត្ថ អនានុយាយីតិ តិដ្ឋេ ចេ សោតិ សចេ សោ តិដ្ឋេយ្យ សដ្ឋីកប្ប-សហស្សានិ ។ តត្ថាតិ អាកិញ្ចញ្ញាយតនេ ។

---

១ ម. វស្សានិ ។ ២ ម. ចវេថ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ) បុគ្គលណា មិនមានតម្រេកក្នុងកាមទាំងឡាយទាំងពួង លះបង់សមាបត្តិដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះជាអ្នកមិនឃ្លាត គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះបាន ។

[២៥៨] (ឧបសីវមាណពទូលសួរថា) បពិត្រព្រះអង្គជាសមន្តចក្ខុ បើបុគ្គលនោះជាអ្នកសាបសូន្យ គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះ ក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះឯង ចុះវិញ្ញាណ របស់បុគ្គលមានសភាពដូច្នោះ ត្រូវកើតទៀតឬទេ ។

[២៥៩] ពាក្យថា បើបុគ្គលនោះ ជាអ្នកមិនសាបសូន្យ គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ ត្រង់ពាក្យថា បើបុគ្គលនោះ គប្បីតាំងនៅ គឺ ប្រសិនបើបុគ្គលនោះ គប្បីតាំងនៅ អស់ពាន់នៃកប្ប ៦០ ។ ពាក្យថា ក្នុងនោះ គឺក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ។

អនានុយាយីតិ អនានុយាយី អវេធមានោ អវិកម្បមា-នោ អនន្តរាយមានោ អបរិហាយមានោ អថវា អវដ្ឋមានោ អទុស្សមានោ អមុយ្ហមានោ អកិលិយ-មានោតិ តិដ្ឋេ ចេ សោ តត្ថ អនានុយាយី ។

[២៦០] បូគម្បិ វស្សានំ សមន្តចក្ខូតិ បូគម្បិ វស្សានន្តិ បូគម្បិ វស្សានំ[១] ពហុន្នំ វស្សានំ ពហុន្នំ វស្សសតានំ ពហុន្នំ វស្សសហស្សានំ ពហុន្នំ វស្ស-សតសហស្សានំ ពហុន្នំ កប្បសតានំ ពហុន្នំ កប្ប-សហស្សានំ ពហុន្នំ កប្បសតសហស្សានំ ។ សមន្ត-ចក្ខូតិ សមន្តចក្ខុ វុច្ចតិ សព្វញ្ញុតញ្ញាណំ ។ បេ ។ តថាគតោ តេន សមន្តចក្ខូតិ បូគម្បិ វស្សានំ សម-ន្តចក្ខុ ។

[២៦១] តត្ថេវ សោ សីតិ សិយា វិមុត្តោ ចវេថ វិញ្ញាណំ តថាវិធស្សាតិ តត្ថេវ សោ សីតិ-ភាវមនុប្បត្តោ ធុវោ[២] សស្សតោ អវិបរិណាម-ធម្មោ សស្សតិសមំ តត្ថេវ តិដ្ឋេយ្យ អថវា

១ ម. វស្សានិ ពហូនិ វស្សានិ ពហូនិ ។ បេ ។ កប្បសតសហស្សានិ ។ ២ ម. និច្ចោ ធុវោ។

ពាក្យថា ជាអ្នកមិនសាបសូន្យ គឺជាអ្នកមិនឃ្លាត មិនកម្រើក មិនទៅប្រាស មិនវិនាស មិនសាបសូន្យ ឬថា ជាអ្នកមិនក្រេកអរ មិនប្រទូស្ត មិនវង្វេង មិនលំបាក ហេតុនោះ (លោកសួរថា) បើបុគ្គលនោះ ជាអ្នកមិនសាបសូន្យ គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនដ្ឋាននោះ ។

[២៦០] ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ ... សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ ត្រង់ពាក្យថា សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ គឺសូម្បីអស់ពួកនៃឆ្នាំទាំងឡាយ នៃឆ្នាំដ៏ច្រើន នៃរយឆ្នាំដ៏ច្រើន នៃពាន់ឆ្នាំដ៏ច្រើន នៃសែនឆ្នាំដ៏ច្រើន នៃរយកប្បដ៏ច្រើន នៃពាន់កប្បដ៏ច្រើន នៃសែនកប្បដ៏ច្រើន ។ ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ ហៅថា សមន្តចក្ខុ ។ បេ ។ ព្រះតថាគត ព្រះនាមថា សមន្តចក្ខុ ដោយហេតុនោះ ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គជាសមន្តចក្ខុ... សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ ។

[២៦១] ពាក្យថា បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះក្នុងអាកិញ្ចញ្ញាយតនដ្ឋាននោះឯង ចុះវិញ្ញាណរបស់បុគ្គលមានសភាពដូច្នោះ ត្រូវកើតទៀតឬទេ គឺ ព្រះឧបសីវៈ សួរនូវការទៀងទាត់ផង ការដាច់សូន្យផង របស់បុគ្គល ដែលកើតហើយក្នុងអាកិញ្ចញ្ញាយតនៈថា បុគ្គលនោះ ដល់នូវភាពជាអ្នកត្រជាក់ ក្នុងអាកិញ្ចញ្ញៈនោះឯង ជាបុគ្គលទៀង បិតថេរ មិនប្រែប្រួលជាធម្មតា គប្បីនៅក្នុងអាកិញ្ចញ្ញៈ

តស្ស វិញ្ញាណំ ចវេយ្យ ឧច្ឆិជ្ជេយ្យ វិនស្សេយ្យ ន ភវេយ្យ ន បដិសន្ធិវិញ្ញាណំ និព្វត្តេយ្យ កាមធាតុយា វា រូបធាតុយា វា អរូបធាតុយា វាតិ អាកិញ្ចញ្ញាយតនេ ឧប្បន្នស្ស សស្សតញ្ច ឧច្ឆេទញ្ច បុច្ឆតិ ឧទាហុ តត្ថេវ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយេយ្យ អថវា តស្ស វិញ្ញាណំ ចវេយ្យ បុន បដិសន្ធិវិញ្ញាណំ និព្វត្តេយ្យ កាមធាតុយា វា រូបធាតុយា វា អរូបធាតុយា វាតិ អាកិញ្ចញ្ញាយតនេ ឧប្បន្នស្ស បរិនិព្វានញ្ច បដិសន្ធិញ្ច បុច្ឆតិ ។ តថាវិធស្សាតិ តថាវិធស្ស តាទិសស្ស តស្សណ្ឋិតស្ស តប្បការស្ស តប្បដិភាគស្ស អាកិញ្ចញ្ញាយតនេ ឧប្បន្នស្សាតិ តត្ថេវ សោ សីតិ សិយា វិមុត្តោ ភវេថ វិញ្ញាណំ តថាវិធស្ស ។ តេនាហ សោ ព្រាហ្មណោ

តិដ្ឋេ ចេ សោ តត្ថ អនានុយាយី
បូគម្បិ វស្សានំ សមន្តចក្ខុ
តត្ថេវ សោ សីតិ សិយា វិមុត្តោ
ភវេថ វិញ្ញាណំ តថាវិធស្សាតិ ។

នោះឯង ស្មើដោយសស្សតិវត្ថុ ឬថា វិញ្ញាណរបស់បុគ្គលនោះ គប្បីឃ្លាត ដាច់សូន្យ វិនាស មិនគប្បីកើត គឺបដិសន្ធិវិញ្ញាណ មិនគប្បីកើតក្នុងកាមធាតុក្តី ក្នុងរូបធាតុក្តី ក្នុងអរូបធាតុក្តី មួយទៀត លោកសួរនូវបរិនិព្វានផង បដិសន្ធិផង របស់បុគ្គលដែលកើតហើយក្នុងអាកិញ្ចញ្ញាយតនៈថា (បុគ្គលនោះ) គប្បីបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងអាកិញ្ចញ្ញាយតនៈនោះឯង ឬថា វិញ្ញាណរបស់បុគ្គលនោះ គប្បីឃ្លាត គឺបដិសន្ធិវិញ្ញាណ គប្បីកើតទៀត ក្នុងកាមធាតុក្តី ក្នុងរូបធាតុក្តី ក្នុងអរូបធាតុក្តី ។ ពាក្យថា របស់បុគ្គល មានសភាពដូច្នោះ គឺរបស់បុគ្គល មានសភាពបែបនោះ ប្រហែលដូច្នោះ ទ្រង់ទ្រាយដូច្នោះ មានប្រការដូច្នោះ មានចំណែកប្រៀបដូច្នោះ កើតហើយក្នុងអាកិញ្ចញ្ញាយតនៈ ហេតុនោះ (លោកសួរថា) បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះក្នុងអាកិញ្ចញ្ញាយតនដ្ឋាននោះឯង ចុះវិញ្ញាណរបស់បុគ្គល មានសភាពដូច្នោះ គប្បីកើតទៀតឬទេ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះអង្គជាសមន្តចក្ខុ បើបុគ្គលនោះ ជាអ្នកមិនសាបសូន្យ គប្បីតាំងនៅក្នុងអាកិញ្ចញ្ញាយតនដ្ឋាននោះ សូម្បីអស់គំនរនៃឆ្នាំទាំងឡាយ បុគ្គលនោះ គប្បីជាអ្នកត្រជាក់ រួចស្រឡះក្នុងអាកិញ្ចញ្ញាយតនដ្ឋាននោះឯង ចុះវិញ្ញាណរបស់បុគ្គលមានសភាពដូច្នោះ ត្រូវកើតទៀតឬទេ ។

[២៦២] អច្ចិ យថា វាតវេគេន ខិត្តំ

(ឧបសីវាតិ ភគវា)

អត្ថំ បលេតិ ន ឧបេតិ សង្ខំ

ឯវំ មុនិ នាមកាយា វិមុត្តោ

អត្ថំ បលេតិ ន ឧបេតិ សង្ខំ ។

[២៦៣] អច្ចិ យថា វាតវេគេន ខិត្តន្តិ អច្ចិ វុច្ចតិ ជាលសិខា ។ វាតាតិ បុរត្ថិមា វាតា បច្ឆិមា វាតា ឧត្តរា វាតា ទក្ខិណា វាតា សរជា វាតា អបរជា វាតា សីតា វាតា ឧណ្ហា វាតា អធិមត្តា[1] វាតា វេរម្ភវាតា បក្ខវាតា សុបណ្ណវាតា តាលបណ្ណវាតា វិធូបនវាតា ។ វាតវេគេន ខិត្តន្តិ វាតវេគេន ខិត្តំ ឧក្ខិត្តំ នុន្នំ បនុន្នំ ខម្ភិតំ វិក្ខម្ភិតន្តិ[2] អច្ចិ យថា វាតវេគេន ខិត្តំ ។ ឧបសីវាតិ ភគវាតិ ឧបសីវាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។

---

១ ម. បរិត្តា វាតា កាលវាតា ។ ២ ម. ខិត្តា ឧក្ខិត្តា នុណ្ណា បនុណ្ណា ខម្ភិតា វិខម្ភិតាតិ ។

ឧបសីវមាណវកប្បញ្ហានិទ្ទេស

[២៦២] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលឧបសីវៈ) អណ្តាតភ្លើង ដែលត្រូវកម្លាំងខ្យល់ផាត់ហើយ រមែង ដល់នូវការរលត់ មិនដល់នូវការរាប់ (ថាទៅក្នុងទីណា) យ៉ាងណា មុនិ រួចស្រឡះហើយចាកនាមកាយ រមែង ដល់នូវការរលត់ មិនដល់នូវការរាប់ (ថាទៅក្នុងទីណា) ក៏យ៉ាងនោះដែរ ។

[២៦៣] ពាក្យថា អណ្តាតភ្លើង ដែលត្រូវកម្លាំងខ្យល់ផាត់ ហើយ យ៉ាងណា សេចក្តីថា អណ្តាតនៃភ្លើង លោកហៅថា អណ្តាត ភ្លើង ។ ពាក្យថា ខ្យល់ គឺ ខ្យល់ទិសខាងកើត ខ្យល់ទិសខាងលិច ខ្យល់ទិសខាងជើង ខ្យល់ទិសខាងត្បូង ខ្យល់មានធូលី ខ្យល់មិនមាន ធូលី ខ្យល់ត្រជាក់ ខ្យល់ក្តៅ ខ្យល់ខ្លាំងក្លា ខ្យល់កំបុតត្បូង ខ្យល់ អំពីស្លាបសត្វ ខ្យល់អំពីគ្រុឌ ខ្យល់អំពីស្លឹកត្នោត ខ្យល់កើតអំពីការ បក់ ។ ពាក្យថា ដែលត្រូវកម្លាំងខ្យល់ផាត់ហើយ គឺកម្លាំងខ្យល់ ផាត់ហើយ ផាត់ឡើងហើយ បន្ទោបង់ហើយ បន្ទោបង់ចោលហើយ ញាំញីហើយ សង្កត់សង្កិនហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) អណ្តាត ភ្លើង ដែលត្រូវកម្លាំងខ្យល់ផាត់ហើយ យ៉ាងណា ។ ត្រង់ពាក្យថា ម្នាលឧបសីវៈ នៃបទថា ព្រះមានព្រះភាគ ត្រាស់ថា ម្នាលឧបសីវៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះ ដោយចំឈ្មោះ ។

ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ឧបសីវាតិ ភគវា ។

[២៦៤] អត្ថំ បលេតិ ន ឧបេតិ សង្ខន្តិ អត្ថំ បលេតីតិ អត្ថំ បលេតិ អត្ថំ គមេតិ អត្ថំ គច្ឆតិ និរុជ្ឈតិ វូបសមតិ បដិប្បស្សម្ភតិ ។ ន ឧបេតិ សង្ខន្តិ អមុកាំ នាម ទិសំ គតោតិ សង្ខំ ន ឧបេតិ ឧទ្ទេសំ ន ឧបេតិ គណនំ ន ឧបេតិ បណ្ណត្តឹ ន ឧបេតីតិ អត្ថំ បលេតិ ន ឧបេតិ សង្ខំ ។

[២៦៥] ឯវំ មុនិ នាមកាយា វិមុត្តោតិ ឯវន្តិ ឱបម្មសម្បដិបាទនំ ។ មុនីតិ មោនំ វុច្ចតិ ញាណំ ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ នាមកាយា វិមុត្តោតិ សោ មុនិ បកតិយា បុព្វេ នាមកាយា វិមុត្តោ ច រូបកាយា វិមុត្តោ ច តទង្គសមតិក្កមាវិក្ខម្ភនប្បហានេន បហីនោ តស្ស មុនិនោ ភវង្គំ[១]

១ ម. ភគវន្តំ ។

ពាក្យថា ព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (ទើបមានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ។

[២៦៤] ពាក្យថា ដល់នូវការរលត់ មិនដល់នូវការរាប់ ត្រង់ពាក្យថា ដល់នូវការរលត់ គឺដល់នូវការបាត់ ទៅបាត់ ដល់នូវការបាត់រលត់ រម្ងាប់ ស្ងប់រម្ងាប់ ។ ពាក្យថា មិនដល់នូវការរាប់ គឺមិនដល់នូវការពោល មិនដល់នូវការសម្តែងឡើង មិនដល់នូវការគណនា មិនដល់នូវការបញ្ញត្តថា (ភ្លើងនោះ) ទៅកាន់ទិសឯណោះ ហេតុនោះ (ទ្រង់ត្រាស់ថា) ដល់នូវការរលត់ មិនដល់នូវការរាប់ ។

[២៦៥] ពាក្យថា មុនិរួចស្រឡះហើយ ចាកនាមកាយ ក៏យ៉ាងនោះដែរ ត្រង់ពាក្យ យ៉ាងនោះ គឺជាពាក្យញុំាំងសេចក្តីឧបមាឲ្យសម្រេច ។ ពាក្យថាមុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ ។ បេ ។ មុនិនោះប្រព្រឹត្តកន្លងនូវបណ្តាញនៃសេចក្តីជាប់ចំពាក់ ។ ពាក្យថា រួចស្រឡះហើយចាកនាមកាយ គឺមុនិនោះ រួចស្រឡះហើយ ចាកនាមកាយក្នុងកាលមុនដោយប្រក្រតីផង រួចស្រឡះហើយ ចាករូបកាយផងលះបង់ហើយដោយវិក្ខម្ភនប្បហានៈ ព្រោះប្រព្រឹត្តកន្លងនូវតទង្គប្បហានៈ

អាគម្ម ចត្តារោ អរិយមគ្គា បដិលទ្ធា ហោន្តិ ចតុន្នំ អរិយមគ្គានំ បដិលទ្ធត្តា នាមកាយោ ច រូបកាយោ ច បរិញ្ញាតា ហោន្តិ នាមកាយស្ស ច រូបកាយស្ស ច បរិញ្ញាតត្តា នាមកាយា ច រូបកាយា ច មុត្តោ វិមុត្តោ អច្ចន្តវិមោក្ខេនាតិ ឯវំ មុនិ នាមកាយា វិមុត្តោ ។

[២៦៦] អត្ថំ បលេតិ ន ឧបេតិ សង្ខន្តិ អត្ថំ បលេតីតិ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយតិ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វុតោតិ ន ឧបេតិ សង្ខន្តិ សង្ខំ ន ឧបេតិ ឧទ្ទេសំ ន ឧបេតិ គណនំ ន ឧបេតិ បណ្ណត្តឹ ន ឧបេតិ ខត្តិយោតិ វា ព្រាហ្មណោតិ វា វេស្សោតិ វា សុទ្ទោតិ វា គហដ្ឋោតិ វា បព្វជិតោតិ វា ទេវោតិ វា មនុស្សោតិ វា រូបីតិ វា អរូបីតិ វា សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាសញ្ញីតិ វា សោ ហេតុ នត្ថិ បច្ចយោ នត្ថិ ការណំ នត្ថិ យេន សង្ខំ គច្ឆេយ្យាតិ

អរិយមគ្គទាំង ៤ មុនិនោះ អាស្រ័យ នូវភពទីបំផុត បានហើយ ឯនាមកាយនិងរូបកាយ លោកកំណត់ដឹងហើយ ព្រោះបាននូវអរិយមគ្គទាំង ៤ លោក រួចហើយ រួចស្រឡះហើយ ចាកនាមកាយនិងរូបកាយ ព្រោះកំណត់ដឹងនាមកាយ និងរូបកាយ ដោយអច្ចន្តវិមោក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) មុនិ រួចស្រឡះហើយ ចាកនាមកាយ ក៏យ៉ាងនេះដែរ ។

[២៦៦] ពាក្យថា ដល់នូវការរលត់ មិនដល់ការរាប់ ត្រង់ពាក្យថា ដល់នូវការរលត់ គឺមុនិបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ បរិ-និព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ។ ពាក្យថា មិនដល់នូវការរាប់ គឺមិនដល់នូវការពោល មិនដល់នូវការសម្តែងឡើង មិនដល់នូវការគណនា មិនដល់នូវការបញ្ញត្តថា ថាក្សត្រិយ៍ក្តី ថាព្រាហ្មណ៍ក្តី ថាវេស្សៈក្តី ថាសុទ្ទៈក្តី ថាគ្រហស្ថក្តី ថាបព្វជិតក្តី ថាទេវតាក្តី ថាមនុស្សក្តី ថាមានរូបក្តី ថាឥតរូបក្តី ថាមានសញ្ញាក្តី ថាឥតសញ្ញាក្តី ថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី មុនិគប្បីដល់នូវការរាប់ ដោយហេតុណា ហេតុនោះមិនមាន បច្ច័យមិនមាន សមុដ្ឋានមិនមាន

អត្ថំ បលេតិ ន ឧបេតិ សង្ខំ ។ តេនាហ ភគវា

អច្ចិ យថា វាតវេគេន ខិត្តំ

(ឧបសីវាតិ ភគវា)

អត្ថំ បលេតិ ន ឧបេតិ សង្ខំ

ឯវំ មុនិ នាមកាយា វិមុត្តោ

អត្ថំ បលេតិ ន ឧបេតិ សង្ខន្តិ ។

[២៦៧] អដ្ឋង្គតោ សោ ឧទ វា សោ នត្ថិ

ឧទាហុ វេ សស្សតិយា អរោគោ

តម្មេ មុនី សាធុ វិយាករោហិ

តថាហិ តេ វិទិតោ ឯស ធម្មោ ។

[២៦៨] អដ្ឋង្គតោ សោ ឧទ វា សោ នត្ថីតិ សោ អដ្ឋង្គតោ ឧទាហុ សោ នត្ថិ សោ និរុទ្ធោ ឧច្ឆិន្នោ វិនដ្ឋោតិ អដ្ឋង្គតោ សោ ឧទ វា សោ នត្ថិ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) ដល់នូវការរលត់ មិនដល់នូវការរាប់ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ) អណ្តាតភ្លើង ដែលត្រូវកម្លាំងខ្យល់ផាត់ហើយ រមែងដល់នូវការរលត់ មិនដល់នូវការរាប់ (ថាទៅក្នុងទីណា) យ៉ាងណា មុនិរួច ស្រឡះហើយចាកនាមកាយ រមែងដល់នូវការរលត់ មិន ដល់នូវការរាប់ (ថាទៅក្នុងទីណា) ក៏យ៉ាងនោះដែរ ។

[២៦៧] (ឧបសីវមាណព ក្រាបទូលថា) បុគ្គលនោះ ដល់នូវការ រលត់ ឬថាបុគ្គលនោះ លែងមាន ពុំនោះសោត បុគ្គល នោះ មិនមានរោគ ប្រៀបដោយសស្សតិវត្ថុ បពិត្រព្រះមុនិ សូមព្រះអង្គសម្តែងប្រាប់ខ្ញុំព្រះអង្គ ឲ្យជាក់ច្បាស់ នូវហេតុនោះ ដ្បិតថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ ។

[២៦៨] ពាក្យថា បុគ្គលនោះ ដល់នូវការរលត់ ឬថាបុគ្គលនោះ លែងមាន គឺបុគ្គលនោះ ដល់នូវការបាត់ ឬថាបុគ្គលនោះ មិនមាន គឺថា បុគ្គលនោះរលត់ ដាច់សូន្យ វិនាសហើយ ហេតុនោះ (លោក សួរថា) បុគ្គលនោះ ដល់នូវការរលត់ ឬថា បុគ្គលនោះ លែងមាន ។

២២៧

ឧបសីវមាណវកប្បញ្ហានិទ្ទេសោ

[២៦៩] ឧជាហុ វេ សស្សតិយា អកោតោតិ ឧជាហុ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តត្ថេវ តិដ្ឋេយ្យាតិ ឧជាហុ វេ សស្សតិយា អកោតោ ។

[២៧០] តម្មេ មុនី សាធុ វិយាករោហីតិ តន្តិ យំ បុច្ឆាមិ យំ យាចាមិ យំ អជ្ឈេសាមិ យំ បសាទេមិ ។ មុនីតិ មោនំ វុច្ចតិ ញាណំ ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ សាធុ វិយាករោហីតិ សាធុ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហិ តម្មេ មុនី សាធុ វិយាករោហីតិ ។

[២៧១] តថាហិ តេ វិទិតោ ឯស ធម្មោតិ តថាហិ តេ វិទិតោ ញាតោ តុលិតោ តិរិតោ វិភាវិតោ វិភូតោ ឯស ធម្មោតិ តថាហិ តេ វិទិតោ ឯស ធម្មោ ។ តេនាហ សោ ព្រាហ្មណោ

ឧបសីវមាណវកប្បញ្ហានិទ្ទេស

[២៦៩] ពាក្យថា ពុំនោះសោត បុគ្គលនោះ មិនមានរោគ ប្រៀបដោយសស្សតិវត្ថុ គឺ ពុំនោះសោត បុគ្គលនោះ ទៀងទាត់ ឋិត ថេរ មិនប្រែប្រួលជាធម្មតា គប្បីឋិតនៅក្នុងអាកិញ្ចញ្ញាយតនៈនោះឯង ស្មើដោយសស្សតិវត្ថុ ហេតុនោះ (លោកសួរថា) ពុំនោះសោត បុគ្គលនោះ មិនមានរោគ ប្រៀបដោយសស្សតិវត្ថុ ។

[២៧០] ពាក្យថា នោះ នៃបទថា បពិត្រព្រះមុនិ សូមព្រះអង្គសម្តែង ប្រាប់ខ្ញុំព្រះអង្គ ឲ្យជាក់ច្បាស់ នូវហេតុនោះ គឺខ្ញុំព្រះអង្គសួរនូវហេតុណា អង្វរនូវហេតុណា អារាធនានូវហេតុណា ជ្រះថ្លានូវហេតុណា ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ ។ បេ ។ មុនិនុ៎ះ ប្រព្រឹត្តកន្លង នូវបណ្តាញគឺសេចក្តីជាប់ចំពាក់ ។ ពាក្យថា សូមព្រះអង្គសម្តែងឲ្យជាក់ច្បាស់ គឺសូមព្រះអង្គប្រាប់ សម្តែង បញ្ញត្ត តែងតាំង បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (លោកសួរថា) បពិត្រព្រះមុនិ សូមព្រះអង្គសម្តែង ប្រាប់ខ្ញុំព្រះអង្គ ឲ្យជាក់ច្បាស់ នូវហេតុនោះ ។

[២៧១] ពាក្យថា ដ្បិតថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ គឺ ព្រោះថា ធម៌នុ៎ះ ព្រះអង្គជ្រាប យល់ ថ្លឹង ពិចារណា ចម្រើន ធ្វើឲ្យប្រាកដហើយ ហេតុនោះ (លោកសួរថា) ដ្បិតថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

អជ្ឈត្តតោ សោ ឧទ វា សោ នត្ថិ
ឧទាហុ វេ សស្សតិយា អរោគោ
តម្មេ មុនី សាធុ វិយាករោហិ
តថាហិ តេ វិទិតោ ឯស ធម្មោតិ ។

[២៧២] អត្ថង្គតស្ស ន បមាណមត្ថិ
(ឧបសីវាតិ ភគវា)
យេន នំ វជ្ជុ តំ តស្ស នត្ថិ
សព្វេសុ ធម្មេសុ សមូហតេសុ
សមូហតា វាទបថាបិ សព្វេ ។

[២៧៣] អត្ថង្គតស្ស ន បមាណមត្ថីតិ អត្ថង្គតស្ស អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វុតស្ស រូបប្បមាណំ នត្ថិ វេទនាបមាណំ នត្ថិ សញ្ញាបមាណំ នត្ថិ សង្ខារប្បមាណំ នត្ថិ វិញ្ញាណប្បមាណំ នត្ថិ ន សំវិជ្ជតិ ន ឧបលព្ភតិ បហីនំ សមុច្ឆិន្នំ វូបសន្តំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍន្តិ អត្ថង្គតស្ស ន បមាណមត្ថិ ។

បុគ្គលនោះ ដល់នូវការរលត់ ឬថា បុគ្គលនោះលែងមាន ពុំនោះសោត (បុគ្គលនោះ) មិនមានរោគប្រៀបដោយសស្សតិវត្ថុ បពិត្រព្រះមុនិ សូមព្រះអង្គ សម្ដែងប្រាប់ខ្ញុំព្រះអង្គឲ្យជាក់ច្បាស់ នូវហេតុនោះ ដ្បិតថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ ។

[២៧២] (ព្រះមានព្រះភាគ ត្រាស់ថា ម្នាលឧបសីវៈ) បុគ្គលដែលរលត់ហើយ ប្រមាណពុំមានទេ បុគ្គលទាំងឡាយពោលចំពោះបុគ្គលនោះ ដោយកិលេសណា កិលេសនុ៎ះរបស់បុគ្គលនោះ មិនមានឡើយ កាលបើធម៌ទាំងពួង បុគ្គលគាស់រំលើងអស់ហើយ សូម្បីគន្លង នៃវាទៈទាំងពួង ក៏បុគ្គលនោះ គាស់រំលើងហើយដែរ ។

[២៧៣] ពាក្យថា បុគ្គលដែលរលត់ហើយ ប្រមាណពុំមានទេ សេចក្ដីថា បុគ្គលដែលរលត់ហើយ គឺដែលបរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ប្រមាណ គឺរូបមិនមាន ប្រមាណ គឺវេទនាមិនមាន ប្រមាណ គឺសញ្ញាមិនមាន ប្រមាណ គឺសង្ខារមិនមាន ប្រមាណ គឺវិញ្ញាណមិនមាន មិនមានសោះ ដែលមិនបាន គឺលោកលះបង់ហើយ លះបង់ផ្ដាច់ហើយ រម្ងាប់ហើយ ស្ងប់រម្ងាប់ហើយ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលដែលរលត់ហើយ ប្រមាណពុំមានទេ ។

ឧបសីវមាណវកប្បញ្ហានិទ្ទេសោ

ឧបសីវាតិ ភគវាតិ ឧបសីវាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ឧបសីវាតិ ភគវា ។

[២៧៤] យេន នំ វជ្ជុ តំ តស្ស នត្ថីតិ យេន រាគេន វទេយ្យុំ យេន ទោសេន វទេយ្យុំ យេន មោហេន វទេយ្យុំ យេន មានេន វទេយ្យុំ យាយ ទិដ្ឋិយា វទេយ្យុំ យេន ឧទ្ធច្ចេន វទេយ្យុំ យាយ វិចិកិច្ឆាយ វទេយ្យុំ យេហិ អនុសយេហិ វទេយ្យុំ រត្តោតិ វា ទុដ្ឋោតិ វា មូឡ្ហោតិ វា វិនិពទ្ធោតិ វា បរាមដ្ឋោតិ វា វិក្ខេបគតោតិ វា អនិដ្ឋង្គតោតិ វា ថាមគតោតិ វា តេ អភិសង្ខារា បហីនា អភិសង្ខារានំ បហីនត្តា គតិយា យេន វទេយ្យុំ នេរយិកោតិ វា តិរច្ឆានយោនិកោតិ វា បិត្តិវិសយិកោតិ វា មនុស្សោតិ វា ទេវោតិ វា រូបីតិ វា អរូបីតិ វា

ពាក្យថា ម្នាលឧបសីវៈ នៃបទថា ព្រះមានព្រះភាគត្រាស់ថាម្នាលឧបសីវៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះ ដោយចំណោះ ។ ពាក្យថា ព្រះមានព្រះភាគ នេះជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ ។

[២៧៤] ពាក្យថា បុគ្គលទាំងឡាយ ពោលចំពោះបុគ្គលនោះ ដោយកិលេសណា កិលេសនុ៎ះ របស់បុគ្គលនោះ មិនមានឡើយ អធិប្បាយថា បុគ្គលទាំងឡាយ គប្បីពោលដោយរាគៈណា ពោលដោយទោសៈណា ពោលដោយមោហៈណា ពោលដោយមានះណា ពោលដោយទិដ្ឋិណា ពោលដោយឧទ្ធច្ចៈណា ពោលដោយវិចិកិច្ឆាណា ពោលដោយអនុស័យណា ថា បុគ្គលនេះជាអ្នកត្រេកអរ ឬជាអ្នកប្រទូស្ត ជាអ្នកវង្វេង ឬជាអ្នកជាប់ចំពាក់ ជាអ្នកស្ទាបអង្អែល ឬជាអ្នកដល់នូវការរាយមាយ ជាអ្នកដល់នូវការមិនសម្រេច ឬជាអ្នកដល់នូវកម្លាំង អភិសង្ខារទាំងនោះ បុគ្គលនោះលះបង់ហើយ ព្រោះលះបង់អភិសង្ខារទាំងឡាយហើយ ជនទាំងឡាយ គប្បីពោលដោយហេតុណា តាមគតិថា បុគ្គលនោះជាសត្វនរក ឬជាអ្នកយកកំណើតជាតិរច្ឆាន ជាបិត្តិវិស័យ ជាមនុស្ស ទេវតា ជារបស់មានរូប ឥតរូប

សញ្ញីតិ វា អសញ្ញីតិ វា នេវសញ្ញីនាសញ្ញីតិ វា សោ ហេតុ នត្ថិ បច្ចយោ នត្ថិ ការណំ នត្ថិ យេន វទេយ្យុំ កថេយ្យុំ ភណេយ្យុំ ទីបេយ្យុំ វោហារេយ្យុន្តិ យេន នំ វជ្ជុ តំ តស្ស នត្ថិ ។

[២៧៥] សព្វេសុ ធម្មេសុ សមូហតេសូតិ សព្វេសុ ធម្មេសុ សព្វេសុ ខន្ធេសុ សព្វេសុ អាយតនេសុ សព្វាសុ ធាតូសុ សព្វាសុ គតីសុ សព្វាសុ ឧប-បត្តីសុ សព្វាសុ បដិសន្ធីសុ សព្វេសុ ភវេសុ សព្វេសុ សំសារេសុ សព្វេសុ វដ្ដេសុ ឩហតេសុ សមូហតេសុ ឧទ្ធតេសុ សមុទ្ធតេសុ ឧប្បាតិតេសុ សមុប្បាតិតេសុ បហីនេសុ សមុច្ឆិន្នេសុ វូបសន្តេសុ បដិប្បស្សទ្ធេសុ អភព្វុប្បត្តិកេសុ ញាណគ្គិនា ទឌ្ឍេ-សូតិ សព្វេសុ ធម្មេសុ សមូហតេសុ ។

[២៧៦] សមូហតា វាទបថាបិ សព្វេតិ វាទបថា វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ តស្ស វាទា ច វាទបថា ច អធិវចនានិ ច អធិវចនបថា ច និរុត្តិ ច និរុត្តិបថា ច បញ្ញត្តិ ច បញ្ញត្តិបថា ច

មានសញ្ញា ឥតសញ្ញា ឬថាជាសត្វមានសញ្ញាក៏មិនមែនឥតសញ្ញាក៏មិនមែន បុគ្គលគប្បីពោល និយាយ ហៅ ដោយហេតុណា ហេតុនោះមិនមាន បច្ច័យមិនមាន សមុដ្ឋានមិនមាន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលទាំងឡាយ ពោលនូវបុគ្គលនោះ ដោយកិលេសណា កិលេសនុ៎ះ របស់បុគ្គលនោះ មិនមានទេ ។

[២៧៥] ពាក្យថា កាលបើធម៌ទាំងពួង បុគ្គលនោះគាស់រំលើងអស់ហើយ គឺកាលបើធម៌ទាំងអស់ ខន្ធទាំងអស់ អាយតនៈទាំងអស់ ធាតុទាំងអស់ គតិទាំងអស់ ឧបបត្តិទាំងអស់ បដិសន្ធិទាំងអស់ ភពទាំងអស់ សំសារទាំងអស់ វដ្ដៈទាំងអស់ បុគ្គលនោះ គាស់ គាស់រំលើង រើ រើឡើង បោចពោច បោចពោចឡើង លះបង់ ក្របែល រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលបើធម៌ទាំងពួង បុគ្គលនោះ គាស់រំលើងអស់ហើយ ។

[២៧៦] ពាក្យថា សូម្បីគន្លងនៃវាទៈទាំងពួង បុគ្គលនោះ គាស់រំលើងអស់ហើយដែរ សេចក្ដីថា កិលេស ខន្ធនិងអភិសង្ខារទាំងឡាយ លោកហៅថា គន្លងនៃវាទៈ ។ វាទៈ គន្លងនៃវាទៈ ឈ្មោះ គន្លងនៃឈ្មោះ សម្ដី គន្លងនៃសម្ដី បញ្ញត្តិនិងគន្លងនៃបញ្ញត្តិទាំងឡាយ

២៣១

ឧបសីវមាណវកប្បញ្ហានិទ្ទេសោ

ឩហតា សមូហតា ឧទ្ធតា សមុទ្ធតា ឧប្បាតិតា សមុប្បាតិតា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ សមូហតា វាទបថាបិ សព្វេ ។ តេនាហ ភគវា

អដ្ឋង្គតស្ស ន បមាណមត្ថិ (ឧបសីវាតិ ភគវា)
យេន នំ វជ្ជុ តំ តស្ស នត្ថិ
សព្វេសុ ធម្មេសុ សមូហតេសុ
សមូហតា វាទបថាបិ សព្វេតិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ឧបសីវមាណវកប្បញ្ហានិទ្ទេសោ ឆដ្ឋោ ។

បុគ្គលនោះគាស់រំលើង គាស់រំលើងឡើង រើ រើឡើង បោចពោច បោចពោចឡើង លះបង់ ក្របែល រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) សូម្បីគន្ធនៃវាទៈទាំងពួង បុគ្គលនោះ គាស់រំលើងអស់ហើយដែរ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ) បុគ្គលដែលរលត់ហើយ ប្រមាណពុំមានទេ បុគ្គលទាំងឡាយ ពោលចំពោះបុគ្គលនោះ ដោយកិលេសណា កិលេសនុ៎ះ របស់បុគ្គលនោះ មិនមានឡើយ កាលបើធម៌ទាំងពួង បុគ្គលនោះគាស់រំលើងហើយ សូម្បីគន្ធនៃវាទៈទាំងពួង ក៏បុគ្គលនោះគាស់រំលើងហើយដែរ ។

លុះចប់គាថាហើយ ។ បេ ។ (ឧបសីវមាណព ប្រកាសខ្លួន) ថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាព្រះសាស្តា របស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ ឧបសីវមាណវកបញ្ហានិទ្ទេសទី ៦ ។

# នន្ទមាណវកបញ្ហានិទ្ទេសោ

[២៧៧] សន្តិ លោកេ មុនយោ (ឥច្ចាយស្មា នន្ទោ)
ជនា វទន្តិ តយិទំ កថំសុ
ញាណូបបន្នំ មុនិ នោ វទន្តិ
ឧទាហុ វេ ជីវិតេនូបបន្នំ ។

[២៧៨] សន្តិ លោកេ មុនយោតិ សន្តីតិ សន្តិ សំវិជ្ជន្តិ[១] ឧបលព្ភន្តិ ។ លោកេតិ អបាយលោកេ ។ បេ ។ អាយតនលោកេ[២] ។ មុនយោតិ មុនិនាមកា អាជីវកា និគណ្ឋា ជដិលា តាបសាតិ សន្តិ លោកេ មុនយោ[៣] ។ ឥច្ចាយស្មា នន្ទោតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។ នន្ទោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតិ[៤] ឥច្ចាយស្មា នន្ទោ ។

[២៧៩] ជនា វទន្តិ តយិទំ កថំសូតិ ជនាតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច

១ ម. ឯត្តន្តរេ អត្ថីតិ ទិស្សតិ ។ ២ ម. លោកេតិ អបាយលោកេ ។ ល ។ អាយតនលោកេតិ ន ទិស្សន្តិ ។ ៣ ម. តាបសា ទេវា លោកេ មុនយោតិ សញ្ជានន្តិ ។ ន ច តេ មុនយោតិ សន្តិ លោកេ មុនយោ ទិស្សន្តិ ។ ៤ ម. ឥច្ចាយស្មា នន្ទោតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។ នន្ទោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតីតិ ន ទិស្សន្តិ ។

# នន្ទមាណវកបញ្ហានិទ្ទេស

[២៧៧] (នន្ទៈមានអាយុ ទូលសួរដូច្នេះថា) ជនទាំងឡាយតែង ពោលថា ពួកមុនិរមែងមានក្នុងលោក ដំណើរនោះតើយ៉ាង ណា ជនទាំងឡាយតែងហៅបុគ្គល ដែលប្រកបដោយ ញាណ ថាជាមុនិឬ ឬក៏ហៅបុគ្គលដែលប្រកបដោយការ ចិញ្ចឹមជិវិត (ថាជាមុនិ) ។

[២៧៨] ពាក្យថា ពួកមុនិរមែងមានក្នុងលោក ត្រង់ពាក្យថា រមែងមាន គឺរមែងមាន មានព្រម កើតមាន ។ ពាក្យថា ក្នុងលោក គឺក្នុង អបាយលោក ។ បេ ។ ក្នុងអាយតនលោក ។ ពាក្យថា ពួកមុនិ គឺ ពួកអាជីវក និគ្រន្ថ ជដិល តាបស មានឈ្មោះថា មុនិ ហេតុ នោះ (លោកសួរថា) ពួកមុនិរមែងមានក្នុងលោក ។ ពាក្យថា ដូច្នេះ របស់បទថា នន្ទៈមានអាយុទូលសួរដូច្នេះ គឺជាតំណបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា នន្ទៈ ជា ឈ្មោះ ។ បេ ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) នន្ទៈមានអាយុទូលសួរដូច្នេះ ។

[២៧៩] ពាក្យថា ជនទាំងឡាយតែងពោល ដំណើរនោះតើយ៉ាងណា ត្រង់ពាក្យថា ជនទាំងឡាយ បានដល់ក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ

គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ វទន្តីតិ[១] កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ ។ តយិទំ កថំសូតិ សំសយបុច្ឆា វិមតិបុច្ឆា ទ្វេឡ្ហកបុច្ឆា អនេកំសបុច្ឆា ឯវំ នុខោ ន នុខោ កឹ នុខោ កថំ នុខោតិ ជនា វទន្តិ តយិទំ កថំសុ ។

[២៨០] ញាណូបបន្នំ មុនិ នោ វទន្តីតិ អដ្ឋសមាបត្តិញាណេន វា បញ្ចាភិញ្ញាញាណេន វា ឧបេតំ សមុបេតំ ឧបាគតំ សមុបាគតំ ឧបបន្នំ សមុបបន្នំ[២] សមន្នាគតំ មុនឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ញាណូបបន្នំ មុនិ នោ វទន្តិ ។

[២៨១] ឧទាហុ វេ ជីវិតេនូបបន្នន្តិ ឧទាហុ អនេកវិវិធអតិបរមទុក្ករការិកលូខជីវិកានុយោគេន ឧបេតំ សមុបេតំ ឧបាគតំ សមុបាគតំ ឧបបន្នំ សមុបបន្នំ សមន្នាគតំ មុនឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ

---

១ ម. តេ លោកេ មុនយោតិ វទន្តីតិ ទិស្សតិ ។ ២ ម. សម្បន្នំ ។

គ្រហស្ថ បព្វជិត ទេវតានិងមនុស្ស ។ ពាក្យថា ពោល គឺ សម្តែង ពណ៌នា បំភ្លឺ ថ្លែង ។ ពាក្យថា ដំណើរនោះ តើយ៉ាងណា គឺការសួរដោយសង្ស័យ សួរដោយសេចក្តីងឿងឆ្ងល់ សួរដោយការព្រេកចិត្ត សួរដោយចំណែកជាអនេកថា យ៉ាងនេះ ឬហ្ន៎ មិនមែនទេឬហ្ន៎ ដូចម្តេចទៅហ្ន៎ ដោយប្រការដូចម្តេចហ្ន៎ ហេតុនោះ (លោកសួរថា) ជនទាំងឡាយតែងពោលដំណើរនោះ តើយ៉ាងណា ។

[២៨០] ពាក្យថា ជនទាំងឡាយ តែងហៅបុគ្គល ដែលប្រកបដោយញាណ ថាជាមុនិឬ សេចក្តីថា ជនទាំងឡាយ តែងពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវបុគ្គលដែលប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ដល់ ដល់ព្រម បរិបូណ៌ ដោយអដ្ឋសមាបត្តិញ្ញាណក្តី ដោយបញ្ចអភិញ្ញាញាណក្តី ថាជាមុនិ ឬហេតុនោះ (លោកសួរថា) ជនទាំងឡាយ តែងហៅបុគ្គលអ្នកប្រកបដោយញាណថាជាមុនិឬ ។

[២៨១] ពាក្យថា ឬក៏ហៅបុគ្គល ដែលប្រកបដោយការចិញ្ចឹមជីវិត ថាជាមុនិ សេចក្តីថា ជនទាំងឡាយ តែងពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវបុគ្គលដែលប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ដល់ ដល់ព្រម បរិបូណ៌ ដោយការប្រកបរឿយៗ នូវការចិញ្ចឹមជីវិត ដ៏សៅហ្មង ជាអំពើដែលបុគ្គល គប្បីធ្វើបានដោយកម្រលើសលុប មានប្រការផ្សេងៗ ជាអនេក ថាជាមុនិ

ឧទាហុ វេ ជីវិកេនូបបន្នំ ។ តេនាហ សោ ព្រាហ្មណោ

សន្តិ លោកេ មុនយោ
(ឥច្ចាយស្មា នន្ទោ)
ជនា វទន្តិ តយិទំ កថំសុ
ញាណូបបន្នំ មុនិ នោ វទន្តិ
ឧទាហុ វេ ជីវិកេនូបបន្នន្តិ ។

[២៨២] ន ទិដ្ឋិយា ន សុតិយា ន ញាណេន
មុនីធ នន្ទ កុសលា វទន្តិ
វិសេនិកត្វា អនីឃា និរាសា
ចរន្តិ យេ តេ មុនយោតិ ព្រូមិ ។

[២៨៣] ន ទិដ្ឋិយា ន សុតិយា ន ញាណេនាតិ ន ទិដ្ឋិ-យាតិ ន ទិដ្ឋសុទ្ធិយា ។ ន សុតិយាតិ ន សុតសុទ្ធិយា ។

ហេតុនោះ (លោកសួរថា) ឬក៏ហៅបុគ្គលប្រកបដោយការចិញ្ចឹមជីវិតថាជាមុនិ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

(នន្ទៈមានអាយុ ទូលសួរដូច្នេះថា) ជនទាំងឡាយ តែងពោលថា ពួកមុនិរមែងមានក្នុងលោក ដំណើរនោះតើយ៉ាងណា ជនទាំងឡាយ តែងហៅបុគ្គល ដែលប្រកបហើយដោយញាណ ថាជាមុនិឬ ឬក៏ហៅបុគ្គលដែលប្រកបដោយការចិញ្ចឹមជីវិត ថាជាមុនិ ។

[២៨២] (ព្រះមានព្រះភាគត្រាស់ថា) ម្នាលនន្ទៈ ជនអ្នកឈ្លាសវៃទាំងឡាយ តែងហៅបុគ្គលថាមុនិ ក្នុងលោកនេះ មិនមែនព្រោះការឃើញ មិនមែនព្រោះការឮ មិនមែនព្រោះញាណទេ ពួកបុគ្គលណា ធ្វើសេនាឲ្យវិនាស ជាអ្នកមិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ប្រព្រឹត្តទៅ តថាគតហៅពួកបុគ្គលនោះ ថាមុនិ ។

[២៨៣] ពាក្យថា មិនមែន ព្រោះការឃើញ មិនមែនព្រោះការឮ មិនមែន ព្រោះញាណទេ ត្រង់ពាក្យថា មិនមែន ព្រោះការឃើញ គឺ មិនមែន ព្រោះស្អាតដោយការឃើញ ។ ពាក្យថា មិនមែន ព្រោះការឮ គឺ មិនមែន ព្រោះស្អាតដោយការស្តាប់ ។

ន ញាណេនាតិ នបិ អដ្ឋសមាបត្តិញាណេន នបិ មិច្ឆាញាណេនាតិ ន ទិដ្ឋិយា ន សុតិយា ន ញាណេន ។

[២៨៤] មុនីធ នន្ទ កុសលា វទន្តីតិ កុសលាតិ យេ តេ ខន្ធកុសលា ធាតុកុសលា អាយតនកុសលា បដិច្ចសមុប្បាទកុសលា សតិប្បដ្ឋានកុសលា សម្មប្បធានកុសលា ឥទ្ធិបាទកុសលា ឥន្ទ្រិយកុសលា ពលកុសលា ពោជ្ឈង្គកុសលា មគ្គកុសលា ផលកុសលា និព្វានកុសលា តេ កុសលា ទិដ្ឋិសុទ្ធិយា វា សុតសុទ្ធិយា វា អដ្ឋសមាបត្តិញាណេន វា មិច្ឆាញាណេន វា[១] ឧបេតំ សមុបេតំ ឧបាគតំ សមុបាគតំ ឧបបន្នំ សមុបបន្នំ សមន្នាគតំ មុនឹ ន វទន្តិ ន កថេន្តិ ន ភណន្តិ ន ទីបយន្តិ ន វោហរន្តីតិ មុនីធ នន្ទ កុសលា វទន្តិ ។

---

១ ម. បញ្ចាភិញ្ញាញាណេន វា មិច្ឆាញាណេន វា ទិដ្ឋេន វា សុតេន វាតិ ទិស្សតិ ។

ពាក្យថា មិនមែន ព្រោះញាណ គឺមិនមែន ព្រោះអដ្ឋសមាបត្តិញ្ញាណផង មិនមែន ព្រោះមិច្ឆាញាណផង ហេតុនោះ (ទ្រង់ត្រាស់ថា) មិនមែនព្រោះការឃើញ មិនមែនព្រោះការឮ មិនមែនព្រោះញាណទេ ។

[២៨៤] អធិប្បាយពាក្យថា ម្នាលនន្ទៈ ជនអ្នកឈ្លាសវៃទាំងឡាយ តែងហៅបុគ្គលថាមុនិក្នុងលោកនេះ ត្រង់ពាក្យថាអ្នកឈ្លាសវៃទាំងឡាយ បានដល់ ពួកបុគ្គលណា ជាអ្នកឈ្លាសវៃក្នុងខន្ធ អ្នកឈ្លាសវៃក្នុងធាតុ អ្នកឈ្លាសវៃក្នុងអាយតនៈ អ្នកឈ្លាសវៃក្នុងបដិច្ចសមុប្បាទ អ្នកឈ្លាសវៃក្នុងសតិប្បដ្ឋាន អ្នកឈ្លាសវៃក្នុងសម្មប្បធាន អ្នកឈ្លាសវៃក្នុងឥទ្ធិ-បាទ អ្នកឈ្លាសវៃក្នុងឥន្ទ្រិយ អ្នកឈ្លាសវៃក្នុងពលៈ អ្នកឈ្លាសវៃក្នុងពោជ្ឈង្គ អ្នកឈ្លាសវៃក្នុងមគ្គ អ្នកឈ្លាសវៃក្នុងផល អ្នកឈ្លាសវៃក្នុងនិព្វាន បុគ្គលអ្នកឈ្លាសវៃទាំងឡាយនោះ មិនពោល មិនសម្តែង មិនពណ៌នា មិនបំភ្លឺ មិនថ្លែង នូវបុគ្គល ដែលប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ដល់ ដល់ព្រម បរិបូណ៌ ដោយការស្អាតព្រោះការឃើញក្តី ដោយការស្អាតព្រោះការឮក្តី ដោយអដ្ឋសមា-បត្តិញ្ញាណក្តី ដោយមិច្ឆាញាណក្តី ថាជាមុនិទេ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលនន្ទៈ ជនអ្នកឈ្លាសវៃទាំងឡាយ តែងហៅបុគ្គលថាមុនិ ក្នុងលោកនេះ ។

[២៨៥] វិសេនិកត្វា អនិឃា និរាសា ចរន្តិ យេ តេ មុនយោតិ ព្រូមីតិ សេនា វុច្ចតិ មារសេនា ។ កាយ-ទុច្ចរិតំ មារសេនា វចីទុច្ចរិតំ មារសេនា មនោទុច្ចរិតំ មារសេនា រាគោ មារសេនា ទោសោ មារសេនា មោ-ហោ មារសេនា កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មា-នោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា មារសេនា ។ វុត្តំ ហេតំ ភគវតា

កាមា តេ បឋមា សេនា ទុតិយារតិ វុច្ចតិ
តតិយា ខុប្បិបាសា តេ ចតុត្ថី តណ្ហា បវុច្ចតិ
បញ្ចមំ[១] ថីនមិទ្ធន្តេ ឆដ្ឋា ភិរូ បវុច្ចតិ
សត្តមី វិចិកិច្ឆា តេ មក្ខោ ថម្ភោ តេ អដ្ឋមោ
លាភោ សិលោកោ សក្ការោ មិច្ឆាលទ្ធោ ច យោ យសោ
យោ ចត្តានំ សមុក្កំសេ បរេ ច អវជានតិ
ឯសា តេ ន មុចិ សេនា កណ្ហស្សាភិប្បហារិណី
ន នំ អសូរោ ជិនាតិ ជេត្វា ច លភតេ សុខន្តិ ។

១ ម. បញ្ចមី ។

[២៨៥] ពាក្យថា ពួកបុគ្គលណា ធ្វើសេនាឲ្យវិនាស ជាអ្នកមិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ប្រព្រឹត្តនៅ តថាគតហៅពួកបុគ្គលនោះថា មុនិ អធិប្បាយថា មារសេនា លោកហៅថា សេនា ។ កាយទុច្ចរិតជាមារសេនា វចីទុច្ចរិតជាមារសេនា មនោទុច្ចរិតជាមារសេនា រាគៈជាមារសេនា ទោសៈជាមារសេនា មោហៈជាមារសេនា កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្រហល់ក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួងជាមារសេនា ។ សមដូចព្រះពុទ្ធដីកានេះដែលព្រះមានព្រះភាគត្រាស់ថា

កាមជាសេនាទី ១ របស់អ្នក សេចក្តីមិនត្រេកអរហៅថាសេនាទី២
សេចក្តីស្រេកឃ្លានជាសេនាទី៣ របស់អ្នក តណ្ហាហៅថាសេនាទី៤
ថីនមិទ្ធៈជាសេនាទី៥ របស់អ្នក សេចក្តីតក់ស្លុតហៅថាសេនាទី៦
វិចិកិច្ឆាជាសេនាទី៧ របស់អ្នក សេចក្តីលុបគុណ សេចក្តីរឹងត្អឹង
ជាសេនាទី៨ របស់អ្នក លាភ សេចក្តីសរសើរ សក្ការៈ
យសដែលបានខុសផង បុគ្គលលើកតម្កើងខ្លួនឯងផង បង្អាប់
បង្អោនអ្នកដទៃផង ម្នាលមារ នុ៎ះជាសេនារបស់អ្នក ជាកិលេស
បំផ្លាញនូវបុគ្គលចិត្តខ្មៅ ឯបុគ្គលអ្នកមិនក្លៀវក្លា រមែងមិនឈ្នះ
នូវកិលេសនោះទេ លុះតែបុគ្គលឈ្នះហើយ ទើបបានសុខ ។

## ២៣៧

ននូមាណវកប្បញ្ហានិទ្ទេសោ

យតោ ចតូហិ អរិយមគ្គេហិ សព្វា ច មារសេនា សព្វេ[១] ច កិលេសា ជិតា បរាជិតា បភគ្គា វិប្បលុត្តា បរម្មុខា តេ វុច្ចន្តិ វិសេនិកត្វា ។ អនិឃាតិ រាគោ នីឃោ ទោសោ នីឃោ មោហោ នីឃោ កោធោ នីឃោ ឧបនាហោ នីឃោ ។ បេ ។ សព្វាកុសលាភិសង្ខារា នីឃា ។ យេសំ ឯតេ នីឃា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា តេ វុច្ចន្តិ អនីឃា ។ និរាសាតិ អាសា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យេសំ ឯសា អាសា តណ្ហា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា តេ វុច្ចន្តិ និរាសា[២] ។ វិសេនិកត្វា អនីឃា និរាសា ចរន្តិ យេ តេ មុនយោតិ ព្រូមីតិ យេ តេ អរហន្តោ ខីណាសវា វិសេនិកត្វា ច អនីឃា ច និរាសា ច ចរន្តិ ឥរិយន្តិ វត្តេន្តិ បាលេន្តិ យបេន្តិ យាបេន្តិ

១ ម. សព្វេ ច វិសេនី កត្វា ។ ២ ម. ឯត្ថន្តរេ យេតិ អរហន្តោ ខីណាសវាតិ ទិស្សតិ ។

កាលណា មារសេនាទាំងពួងផង កិលេសទាំងពួងផង បុគ្គលបានឈ្នះហើយ ផ្ចាញ់ហើយ បំបាត់ចោលហើយ លុបលាងចោលហើយ ក្នុងទីកំបាំងមុខ ដោយអរិយមគ្គទាំង ៤ បុគ្គលទាំងនោះ លោកពោលថាធ្វើសេនាឲ្យវិនាស ។ ពាក្យថា មិនមានទុក្ខ សេចក្តីថា រាគៈជាទុក្ខ ទោសៈជាទុក្ខ មោហៈជាទុក្ខ កោធៈជាទុក្ខ ឧបនាហៈជាទុក្ខ ។ បេ ។ អកុសលាភិសង្ខារទាំងអស់ជាទុក្ខ ។ ទុក្ខទាំងនោះ បុគ្គលទាំងឡាយណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្រប់សង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលទាំងនោះ លោកហៅថា អ្នកមិនមានទុក្ខ ។ ពាក្យថា មិនមានសេចក្តីប្រាថ្នា សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានខាង តម្រេក តម្រេកដ៏មានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីប្រាថ្នាគឺតណ្ហានុ៎ះ បុគ្គលទាំងឡាយណា បានលះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្រប់សង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលទាំងនោះ លោកហៅថា អ្នកមិនមានសេចក្តីប្រាថ្នា ។ ពាក្យថា ពួកបុគ្គលណា ធ្វើសេនាឲ្យវិនាស មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ប្រព្រឹត្តទៅ តថាគតហៅពួកបុគ្គលទាំងនោះ ថាមុនិ បានសេចក្តីថា ព្រះអរហន្តខីណាស្រពទាំងឡាយណា ធ្វើសេនាឲ្យវិនាសផង មិនមានទុក្ខផង មិនមានសេចក្តីប្រាថ្នាផង ត្រាច់ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ

តេ លោកេ មុនយោតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ វិសេនិកត្វា អនីឃា និរាសា ចរន្តិ យេ តេ មុនយោតិ ព្រូមិ ។ តេនាហ ភគវា

ន ទិដ្ឋិយា ន សុតិយា ន ញាណេន
មុនីធ នន្ទ កុសលា វទន្តិ
វិសេនិកត្វា អនិឃា និរាសា
ចរន្តិ យេ តេ មុនយោតិ ព្រូមីតិ ។

[២៨៦] យេកេចិមេ សមណព្រាហ្មណា សេ
(ឥច្ចាយស្មា នន្ទោ)
ទិដ្ឋសុតេនាបិ[១] វទន្តិ សុទ្ធឹ
សីលព្វតេនាបិ វទន្តិ សុទ្ធឹ
អនេករូបេន វទន្តិ សុទ្ធឹ
កច្ចិស្សុ តេ (ភគវា) តត្ថ យតា ចរន្តា
អតារុ ជាតិញ្ច ជរញ្ច មារិស
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។

១ ឱ. ទិដ្ឋេន សុតេនាបិ ។

តថាគត ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យរាក់ ប្រកាស នូវព្រះអរហន្តខីណាស្រពទាំងនោះ ថាមុនិ ក្នុងលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកបុគ្គលណាធ្វើសេនាឲ្យវិនាស មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ប្រព្រឹត្តនៅ តថាគត ហៅពួកបុគ្គលទាំងនោះ ថាមុនិ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលនន្ទៈ ជនអ្នកឈ្លាសវៃទាំងឡាយ តែងហៅបុគ្គលថាមុនិ ក្នុងលោកនេះ មិនមែនព្រោះការឃើញ មិនមែនព្រោះការឮ មិនមែនព្រោះញាណទេ ពួកបុគ្គលណា ធ្វើសេនាឲ្យវិនាស ជាអ្នកមិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ប្រព្រឹត្តនៅ តថាគតហៅពួកបុគ្គលទាំងនោះ ថាមុនិ ។

[២៨៦] (នន្ទៈមានអាយុ ទូលសួរ ដូច្នេះថា) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ពោលថាសេចក្តីបរិសុទ្ធព្រោះសីលនិងវតខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ (បពិត្រព្រះមានព្រះភាគ) អ្នកនិទ៌ុក្ខ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួមប្រព្រឹត្តក្នុងវតនោះ តើបានឆ្លងផុតជាតិនិងជរាខ្លះដែរឬ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

## នន្ទមាណវកប្បញ្ហានិទ្ទេសោ

[២៨៧] យេកេចិមេ សមណព្រាហ្មណាសេតិ យេកេចីតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយ វចនមេតំ យេកេចីតិ ។ សមណាតិ យេកេចិ ឥតោ ពហិទ្ធា បព្វជ្ជូបគតា បរិព្វាជសមាបន្នា ។ ព្រាហ្មណាតិ យេកេចិ ភោវាទិកាតិ យេកេចិមេ សមណព្រាហ្មណាសេ ។ ឥច្ចាយស្មា នន្ទោតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។ នន្ទោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាចោតិ ឥច្ចាយស្មា នន្ទោ ។

[២៨៨] ទិដ្ឋស្សុតេនាបិ វទន្តិ សុទ្ធិន្តិ ទិដ្ឋេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ សុតេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ ទិដ្ឋស្សុតេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ

នន្ទមាណវកប្បញ្ហានិទ្ទេស

[២៨៧] ពាក្យថា សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ត្រង់ពាក្យថា ណាមួយ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ណាមួយ នេះជាពាក្យប្រមូល ។ ពាក្យថា សមណៈទាំងឡាយ គឺបុគ្គលណាមួយ ចូលកាន់បព្វជ្ជា ខាងក្រៅអំពីសាសនានេះ បួសជាបរិព្វាជក ។ ពាក្យថា ព្រាហ្មណ៍ទាំងឡាយ គឺបុគ្គលណាមួយជាភោវាទី ហេតុនោះ (លោកសួរថា) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ។ ពាក្យថា ដូច្នេះ របស់បទថា នន្ទៈមានអាយុទូលសួរដូច្នេះ គឺជាតំណបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា នន្ទៈ ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។ បេ ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) នន្ទៈមានអាយុទូលសួរដូច្នេះ ។

[២៨៨] ពាក្យថា ពោលថាសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឃើញក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឮក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឃើញ ឬដែលឮក្តី

ទិដ្ឋសុតេនាបិ វទន្តិ សុទ្ធឹ ។

[២៨៩] សីលព្វតេនាបិ វទន្តិ សុទ្ធិន្តិ សីលេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ វត្តេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ សីលព្វតេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ សីលព្វតេនាបិ វទន្តិ សុទ្ធឹ ។

[២៩០] អនេករូបេន វទន្តិ សុទ្ធិន្តិ អនេកវិធវត្តកុតូហលមង្គលេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ អនេករូបេន វទន្តិ សុទ្ធឹ ។

[២៩១] កច្ចិស្សុ តេ (ភគវា) តត្ថ យតា ចរន្តាតិ

ហេតុនោះ (លោកសួរថា) ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ។

[២៨៩] ពាក្យថា ពោលថាសេចក្តីបរិសុទ្ធ ព្រោះសីលនិងវ័តខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីលក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះវ័តក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីលនិងវ័តក្តី ហេតុនោះ (លោកសួរថា) ពោលនូវសេចក្តីបរិសុទ្ធ ព្រោះសីលនិងវ័តខ្លះ ។

[២៩០] ពាក្យថា ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះវ័តនិងមង្គលភ្ញាក់ផ្អើលមានប្រការផ្សេងៗ ជាអនេក ហេតុនោះ (លោកសួរថា) ពោលនូវសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ ។

[២៩១] អធិប្បាយពាក្យថា (បពិត្រព្រះមានព្រះភាគ) សមណ-ព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងវ័តនោះ ... ដែរឬ

កច្ចិស្សូតិ សំសយបុច្ឆា វិមតិបុច្ឆា ទ្វេឡ្ហកបុច្ឆា អនេកំសបុច្ឆា ឯវំ នុ ខោ ន នុ ខោ កិន្នុ ខោ កថំ នុ ខោតិ កច្ចិស្សុ ។ តេតិ ទិដ្ឋិគតិកា ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ចិកា បញ្ញត្តិ យទិទំ ភគវាតិ កច្ចិស្សុ តេ ភគវា ។ តត្ថ យតា ចរន្តាតិ តត្ថាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា ។ យតាតិ យតា បដិយតា គោបិតា រក្ខិតា សំវុតា ។ ចរន្តាតិ ចរន្តា វិចរន្តា ឥរិយន្តា វត្តេន្តា បាលេន្តា យបេន្តា យាបេន្តាតិ កច្ចិស្សុ តេ (ភគវា) តត្ថ យតា ចរន្តា ។

[២៩២] អតារុ ជាតិញ្ច ជរញ្ច មារិសាតិ ជាតិជរាមរណំ អតរីសុ ឧត្តរីសុ បតរីសុ សមតិក្កមីសុ វីតិវត្តីសុ ។

ត្រង់ពាក្យថា ដែរឬ គឺជាសំណួរដោយសេចក្តីសង្ស័យ សំណួរដោយសេចក្តីងឿងឆ្ងល់ សំណួរដោយសេចក្តីកន្ទែកចិត្ត សំណួរដោយចំណែកជាអនេកថា យ៉ាងនេះឬហ្ន៎ មិនមែនទេឬហ្ន៎ ដូចម្តេចទៅហ្ន៎ ដោយប្រការដូចម្តេចទៅហ្ន៎ ហេតុនោះ (លោកសួរថា) ដែរឬ ។ ពាក្យថា បុគ្គលទាំងនោះ បានដល់ពួកបុគ្គលអ្នកលុះក្នុងទិដ្ឋិ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (លោកសួរថា) បពិត្រព្រះមានព្រះភាគ សមណព្រាហ្មណ៍ទាំងនោះ ... ដែរឬ ។ ពាក្យថា ជាអ្នកសង្រួម ប្រព្រឹត្តក្នុងវត្តនោះ ត្រង់ពាក្យថា ក្នុងវត្តនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្តីគួររបស់ខ្លួន ក្នុងសេចក្តីគាប់ចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកសង្រួម សង្រួមចំពោះ គ្រប់គ្រង រក្សា រវាំង ។ ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ប្រព្រឹត្តផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (លោកសួរថា) (បពិត្រព្រះមានព្រះភាគ) សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងវត្តនោះ... ដែរឬ ។

[២៩២] ពាក្យថា (បពិត្រព្រះអង្គ) អ្នកនិទ៌ុក្ខ សមណព្រាហ្មណ៍ទាំងនោះ តើបានឆ្លងជាតិនិងជរា (ដែរឬ) គឺឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លងព្រម ប្រព្រឹត្តកន្លង នូវជាតិជរានិងមរណៈ ។

មារិសាតិ បិយវចនំ សគារវសប្បតិស្សាធិវចនមេតំ មារិសាតិ អតារុ ជាតិញ្ច ជរញ្ច មារិស ។

[២៩៣] បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ បុច្ឆាមិ តន្តិ បុច្ឆាមិ តំ យាចាមិ តំ អជ្ឈេសាមិ តំ បសាទេ-មិ តំ កថស្សុ មេតិ បុច្ឆាមិ តំ ។ ភគវាតិ គារវាធិវ-ចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេ-ហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកា-សេហីតិ បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។ តេនាហ សោ ព្រាហ្មណោ

ពាក្យថា អ្នកនិរទុក្ខ គឺពាក្យជាទីស្រឡាញ់ ពាក្យថា អ្នកនិរទុក្ខ នេះជាពាក្យពោលដោយគោរព កោតខ្លាច ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គអ្នកនិរទុក្ខ សមណព្រាហ្មណ៍ទាំងនោះ តើបានឆ្លងជាតិនិងជរាដែរឬ ។

[២៩៣] ពាក្យថា ខ្ញុំសូមសួរព្រះអង្គ របស់បទថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា ខ្ញុំព្រះអង្គសូមសួរព្រះអង្គ គឺខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមអង្វរព្រះអង្គ សូមអារាធនាព្រះអង្គ សូមជ្រះថ្លានឹងព្រះអង្គ សូមព្រះអង្គប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ហេតុនោះ (លោកសួរថា) ខ្ញុំព្រះអង្គសូមសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នេះជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ប្រកាស ហេតុនោះ (លោកសួរថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

២៤៣

នន្ទមាណវកប្បញ្ហានិទ្ទេសោ

យេកេចិមេ សមណព្រាហ្មណាសេ
(ឥច្চាយស្មា នន្ទោ)
ទិដ្ឋសុតេនាបិ វទន្តិ សុទ្ធឹ
សីលព្វតេនាបិ វទន្តិ សុទ្ធឹ
អនេករូបេន វទន្តិ សុទ្ធឹ
កច្ចិស្សុ តេ (ភគវា) តត្ថ យតា ចរន្តា
អតារុ ជាតិញ្ច ជរញ្ច មារិស
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ ។
[២៩៤] យេកេចិមេ សមណព្រាហ្មណាសេ
(នន្ទាតិ ភគវា)
ទិដ្ឋសុតេនាបិ វទន្តិ សុទ្ធឹ
សីលព្វតេនាបិ វទន្តិ សុទ្ធឹ
អនេករូបេន វទន្តិ សុទ្ធឹ
កិញ្ចាបិ តេ តត្ថ យតា ចរន្តិ
នាតរីសុ ជាតិជរន្តិ ព្រូមិ ។

[២៩៥] យេកេចីតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ យេកេចីតិ ។

(នន្ទៈមានអាយុ ទូលសួរដូច្នេះថា) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ពោលថាសេចក្តីបរិសុទ្ធព្រោះសីលនឹងវត្តខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ (បពិត្រព្រះមានព្រះភាគ) អ្នកនិទុក្ខ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងវត្តនោះ តើបានឆ្លងជាតិនិងជរាខ្លះដែរឬ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គ ។

[២៩៤] (ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនន្ទៈ) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ពោលថាសេចក្តីបរិសុទ្ធព្រោះសីលនិងវត្តខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងសភាវៈនោះ ក៏ពិតមែនហើយ (ប៉ុន្តែ) តថាគតពោលថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងជាតិនិងជរា មិនបានទេ ។

[២៩៥] ពាក្យថា ណាមួយ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ណាមួយ នេះពាក្យប្រមូល ។

សមណាតិ យេកេចិ ឥតោ ពហិទ្ធា បព្វជ្ជូបគតា បរិព្វាជសមាបន្នា ។ ព្រាហ្មណាតិ យេកេចិ ភោវាទិកាតិ យេកេចិមេ សមណព្រាហ្មណាសេ ។ ជន្តាតិ ភគវាតិ ជន្តាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ជន្តាតិ ភគវា ។

[២៩៦] ទិដ្ឋសុតេនាបិ វទន្តិ សុទ្ធិន្តិ ទិដ្ឋេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ សុតេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ ទិដ្ឋសុតេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ទិដ្ឋសុតេនាបិ វទន្តិ សុទ្ធឹ ។

ពាក្យថា សមណៈ គឺបុគ្គល ណាមួយ ចូលកាន់បព្វជ្ជា ខាងក្រៅអំពីសាសនានេះ បួសជាបរិព្វាជក ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលណាមួយជាភោវាទី ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ណាមួយនេះ ។ ពាក្យថា នន្ទៈ របស់បទថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនន្ទៈ គឺព្រះមានព្រះភាគហៅព្រាហ្មណ៍នោះតាមឈ្មោះ ។ ពាក្យថាព្រះមានព្រះភាគ នេះជាពាក្យពោលដោយគោរព ។បេ។ ការបញ្ញត្តថា ព្រះមានព្រះភាគនេះ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនន្ទៈ ។

[២៩៦] ពាក្យថា ពោលថាសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឃើញក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឮក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឃើញឬឮក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ពោលថាសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ។

នន្ទមាណវកប្បញ្ហានិទ្ទេសោ

[២៩៧] សីលព្វតេនាបិ វទន្តិ សុទ្ធិន្តិ សីលេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ វត្តេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ សីលព្វតេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ សីលព្វតេនាបិ វទន្តិ សុទ្ធឹ ។

[២៩៨] អនេករូបេន វទន្តិ សុទ្ធិន្តិ អនេកវិធ-វត្តកុតូហលមង្គលេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ អនេករូបេន វទន្តិ សុទ្ធឹ ។

[២៩៩] កិញ្ចាបិ តេ តត្ថ យតា ចរន្តីតិ កិញ្ចាបីតិ បទសន្ធិ បទសំសគ្គោ បទចារិបូរិ អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វកាមេតំ កិញ្ចាបីតិ ។

នន្ទមាណវកបញ្ហានិទ្ទេស

[២៩៧] ពាក្យថា ពោលថាសេចក្តីបរិសុទ្ធ ព្រោះសីលនិងវត្ត ខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាត វិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីលក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្តក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីលនិងវត្តក្តី ហេតុនោះ (ទ្រង់ត្រាស់ ថា) ពោលថាសេចក្តីបរិសុទ្ធ ព្រោះសីលនិងវត្តខ្លះ ។

[២៩៨] ពាក្យថា ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាង ខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាត វិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្តនិងមង្គល ភ្ញាក់ផ្អើលមានប្រការផ្សេងៗ ជាអនេក ហេតុនោះ (ទ្រង់ត្រាស់ថា) ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ ។

[២៩៩] ពាក្យថា សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួមប្រព្រឹត្តក្នុង សភាវៈនោះ ក៏ពិតមែនហើយ ត្រង់ពាក្យថា ក៏ពិតមែនហើយ គឺជាពាក្យតំ- ណបទ ជាពាក្យទាក់ទងដោយបទ ជាពាក្យបំពេញបទ ជាពាក្យប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ក៏ពិតមែនហើយ នេះជាលំដាប់បទ ។

តេតិ ទិដ្ឋិគតិកា ។ តត្ថាតិ សកាយ ទិដ្ឋិយា សកាយ ខន្តិយា សកាយ រុចិយា សកាយ លទ្ធិយា ។ យតាតិ យតា បដិយតា គោបិតា រក្ខិតា សំវុតា ។ ចរន្តីតិ ចរន្តិ វិចរន្តិ ឥរិយន្តិ វត្តេន្តិ បាលេន្តិ យបេន្តិ យាបេន្តីតិ កិញ្ចាបិ តេ តត្ថ យតា ចរន្តិ ។

[៣០០] ជាតរីសុ ជាតិជរន្តិ ព្រូមីតិ ជាតិជរាមរណំ ន តរីសុ ន ឧត្តរីសុ ន បតរីសុ ន សមតិក្កមឹសុ ន វីតិវត្តឹសុ ជាតិជរាមរណា អនិក្ខន្តា អនិស្សដ្ឋា អនតិក្កន្តា(១) អវីតិវត្តា អន្តោជាតិជរាមរណេ បរិវត្តេន្តិ អន្តោសំសារបថេ បរិវត្តេន្តិ ជាតិយា អនុគតា ជរាយ អនុសដា ព្យាធិនា អភិភូតា មរណេន អព្ភាហតា អតាណា អលេណា អសរណា អសរណីភូតាតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ ជាតរីសុ ជាតិជរន្តិ ព្រូមិ ។

១ ម. ឯត្ថន្តរេ អសមតិក្កន្តាតិ ទិស្សតិ ។

ពាក្យថា សមណព្រាហ្មណ៍ទាំងនោះ បានដល់បុគ្គលអ្នកលុះក្នុងទិដ្ឋិ ។ ពាក្យថា ក្នុងសភាវៈនោះ គឺក្នុងទិដ្ឋិរបស់ខ្លួន ក្នុងសេចក្ដីគួររបស់ខ្លួន ក្នុងសេចក្ដីគាប់ចិត្តរបស់ខ្លួន ក្នុងលទ្ធិរបស់ខ្លួន ។ ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកសង្រួម សង្រួមចំពោះ គ្រប់គ្រង រក្សា រវាំង ។ ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ប្រព្រឹត្តផ្សេងៗ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) សមណព្រាហ្មណ៍ ទាំងនោះ ជាអ្នកសង្រួម ប្រព្រឹត្តក្នុងសភាវៈនោះ ក៏ពិតមែនហើយ ។

[៣០០] ពាក្យថា ប៉ុន្តែតថាគតពោលថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងជាតិនិងជរាមិនបានទេ គឺតថាគត ពោល ប្រាប់ សម្ដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងមិនបាន ឆ្លងឡើងមិនបាន ឆ្លងកាត់មិនបាន កន្លងមិនបាន ប្រព្រឹត្តកន្លងមិនបាន នូវជាតិជរានិងមរណៈ គឺថា ជាអ្នកមិនឃ្លាតចេញ មិនរលាស់ចេញ មិនកន្លង មិនប្រព្រឹត្តកន្លង ចាកជាតិ ជរានិងមរណៈ តែងនៅវិលវល់ ក្នុងខាងក្នុងនៃជាតិជរានិងមរណៈ តែងវិលវល់ក្នុងខាងក្នុងនៃគន្លងសង្សារ ត្រូវជាតិជាប់តាមហើយ ត្រូវជរារឹតរួតហើយ ត្រូវព្យាធិសង្កត់សង្កិនហើយ ត្រូវមរណៈកម្ចាត់ហើយ ឥតមានទីជ្រក ឥតមានទីពួន ឥតមានទីរឭក ឥតមានបុគ្គលជាទីរឭក ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោលថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងជាតិនិងជរាមិនបានទេ ។

២៤៧

នន្ទមាណវកប្បញ្ហានិទ្ទេសោ

តេនាហ ភគវា

យេកេចិមេ សមណព្រាហ្មណាសេ
(នន្ទាតិ ភគវា)
ទិដ្ឋសុតេនាបិ វទន្តិ សុទ្ធឹ
សីលព្វតេនាបិ វទន្តិ សុទ្ធឹ
អនេករូបេន វទន្តិ សុទ្ធឹ
កិញ្ចាបិ តេ តត្ថ យតា ចរន្តិ
នាតរឹសុ ជាតិជរន្តិ ព្រូមីតិ ។

[៣០១] យេកេចិមេ សមណព្រាហ្មណាសេ
(ឥច្චាយស្មា នន្ទោ)
ទិដ្ឋសុតេនាបិ វទន្តិ សុទ្ធឹ
សីលព្វតេនាបិ វទន្តិ សុទ្ធឹ
អនេករូបេន វទន្តិ សុទ្ធឹ
តេ ចេ មុនី ព្រូសិ អនោឃតិណ្ណេ
អថ កោ ចរហិ ទេវមនុស្សលោកេ
អតារិ ជាតិញ្ច ជរញ្ច មារិស
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។

ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលនន្ទៈ) សមណព្រាហ្មណ៍ទាំងឡាយ ណាមួយនេះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះសីលនិងវត្តខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកសង្រួមប្រព្រឹត្តក្នុងសភាវៈនោះ ក៏ពិតមែនហើយ (ប៉ុន្តែ) តថាគតពោលថាសមណព្រាហ្មណ៍ទាំងនោះ ឆ្លងជាតិនិងជរាមិនបានទេ ។

[៣០១] (នន្ទៈមានអាយុពោលដូច្នេះថា) សមណព្រាហ្មណ៍ទាំង-ឡាយណាមួយនេះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះសីលនិងវត្តខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ បពិត្រព្រះមុនិ បើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ បពិត្រព្រះអង្គទ្រង់និរទុក្ខ កាលបើដូច្នេះ តើនរណាក្នុងទេវលោក និងមនុស្សលោក ទើបឆ្លងជាតិនិងជរាបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គទ្រង់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[៣០២] យេកេចិមេ សមណព្រាហ្មណាសេតិ យេកេចីតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ យេកេចីតិ ។ សមណាតិ យេកេចិ ឥតោ ពហិទ្ធា បព្វជ្ជូបគតា បរិព្វាជសមាបន្នា ។ ព្រាហ្មណាតិ យេកេចិ ភោវាទិកាតិ យេកេចិមេ សមណព្រាហ្មណាសេ ។ ឥច្ចាយស្មា ជតុកណ្ណីតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។ ជតុកណ្ណីតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្មា ជតុកណ្ណី ។

[៣០៣] ទិដ្ឋសុតេនាបិ វទន្តិ សុទ្ធិន្តិ ទិដ្ឋេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ សុតេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ ទិដ្ឋសុតេនបិ សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ ទិដ្ឋសុតេនាបិ វទន្តិ សុទ្ធឹ ។

[៣០២] ពាក្យថា ណាមួយ របស់បទថា សមណព្រាហ្មណ៍ទាំងឡាយ ណាមួយនេះ គឺគ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ណាមួយ នេះជាពាក្យប្រមូល ។ ពាក្យថា សមណៈ គឺបុគ្គលណាមួយ ចូលកាន់ផ្នួសខាងក្រៅ អំពីសាសនានេះ បួសជាបរិព្វាជក ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលណាមួយជាភោវាទី ហេតុនោះ (លោកសួរថា) សមណព្រាហ្មណ៍ទាំងឡាយណាមួយនេះ ។ ពាក្យថា ដូច្នេះ របស់បទថា នន្ទៈមានអាយុពោលដូច្នេះ គឺជាតំណបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា នន្ទៈ ជាឈ្មោះនៃព្រាហ្មណ៍នោះ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) នន្ទៈមានអាយុពោលដូច្នេះ ។

[៣០៣] ពាក្យថា ពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ គឺពោល សម្តែង ពណ៌នា បំភ្លឺថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឃើញក្តី ពោល សម្តែង ពណ៌នា បំភ្លឺថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះអារម្មណ៍ដែលឃើញឬឮក្តី ហេតុនោះ (លោកសួរថា) ពោលថាសេចក្តីបរិសុទ្ធព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ។

នន្ទមាណវកប្បញ្ហានិទ្ទេសោ

[៣០៤] សីលព្វតេនាបិ វទន្តិ សុទ្ធិន្តិ សីលេនបិ សុទ្ធី វិសុទ្ធី បរិសុទ្ធី មុត្តី វិមុត្តី បរិមុត្តី វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ វត្តេនបិ សុទ្ធី វិសុទ្ធី បរិសុទ្ធី មុត្តី វិមុត្តី បរិមុត្តី វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តិ សីលព្វតេនបិ សុទ្ធី វិសុទ្ធី បរិសុទ្ធី មុត្តី វិមុត្តី បរិមុត្តី វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ សីលព្វតេនាបិ វទន្តិ សុទ្ធី ។

[៣០៥] អនេករូបេន វទន្តិ សុទ្ធិន្តិ អនេកវិធវត្តកុតូហលមង្គលេន សុទ្ធី វិសុទ្ធី បរិសុទ្ធី មុត្តី វិមុត្តី បរិមុត្តី វទន្តិ កថេន្តិ ភណន្តិ ទីបយន្តិ វោហរន្តីតិ អនេករូបេន វទន្តិ សុទ្ធី ។

[៣០៦] តេ ចេ មុនី ព្រូសិ អនោឃតិណ្ណេតិ តេ ចេតិ ទិដ្ឋិគតិកេ ។ មុនីតិ មោនំ វុច្ចតិ ញាណំ ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។

នន្ទមាណវកប្បញ្ហានិទ្ទេស

[៣០៤] ពាក្យថា ពោលថាសេចក្តីបរិសុទ្ធ ព្រោះសីលនិងវត្តខ្លះ គឺ ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីលក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្តក្តី ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះសីលនិងវត្តក្តី ហេតុនោះ (លោកសួរថា) ពោលថាសេចក្តីបរិសុទ្ធ ព្រោះសីលនិងវត្តខ្លះ ។

[៣០៥] ពាក្យថា ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ គឺ ពោល សម្តែង ពណ៌នា បំភ្លឺ ថ្លែង នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្តនិងមង្គលភ្ញាក់ផ្អើលមានប្រការផ្សេងៗ ជាអនេក ហេតុនោះ (លោកសួរថា) ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ ។

[៣០៦] ពាក្យថា បពិត្រព្រះមុនិ បើព្រះអង្គត្រាស់ថាសមណព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ ត្រង់ពាក្យថា សមណព្រាហ្មណ៍ទាំងនោះ គឺពួកបុគ្គលអ្នកលុះក្នុងទិដ្ឋិ ។ ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ។ បេ ។ មុនិនោះ បានកន្លងនូវបណ្តាញគឺការជាប់ចំពាក់ ។

ព្រូសិ អនោយតិណ្ណោតិ កាមោឃំ ភវោឃំ ទិដ្ឋោឃំ អវិជ្ជោឃំ អតិណ្ណោ អនុត្តិណ្ណោ អនិត្តិណ្ណោ អនតិក្កន្តោ អសមតិក្កន្តោ អវីតិវត្តោ អន្តោជាតិជរាមរណោ បរិវត្តន្តោ អន្តោសំសារបថេ បរិវត្តន្តោ ជាតិយា អនុគតេ ជរា-យ អនុសដេ ព្យាធិនា អភិភូតេ មរណេន អព្ភា-ហតេ អតាណោ អលេណោ អសរណោ អសរណី-ភូតេ ។ ព្រូសីតិ ព្រូសិ អាចិក្ខសិ ទេសេសិ បញ្ញ-បេសិ បដ្ឋបេសិ វិវរសិ វិភជសិ ឧត្តានីករោសិ បកា-សេសីតិ តេ ចេ មុនី ព្រូសិ អនោយតិណ្ណោ ។

[៣០៧] អថ កោ ចរហិ ទេវមនុស្សលោកេ អតារិ ជាតិញ្ច ជរញ្ច មារិសាតិ អថ កោ ឃសោ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្ស-មណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ជាតិ-ជរាមរណំ អតារិ ឧត្តារិ បតរិ សមតិក្កមិ វីតិវត្តយិ ។

ពាក្យថា បើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ គឺឆ្លងមិនបាន ឆ្លងឡើងមិនបាន ឆ្លងចេញមិនបាន ឆ្លងរំលងមិនបាន កន្លងមិនបាន ប្រព្រឹត្តកន្លងមិនបាន នូវឱឃៈគឺកាមឱឃៈគឺភព ឱឃៈគឺទិដ្ឋិ ឱឃៈគឺអវិជ្ជា គឺវិលវល់នៅ ក្នុងខាងក្នុងនៃជាតិជរានិងមរណៈ វិលវល់នៅ ក្នុងខាងក្នុងគន្លងសង្សារ ត្រូវជាតិជាប់តាមហើយ ត្រូវជរារឹតរួតហើយ ត្រូវព្យាធិសង្កត់សង្កិនហើយ ត្រូវមរណៈកម្ចាត់ហើយ ជាអ្នកឥតមានទីជ្រក ឥតមានទីពួន ឥតមានទីរឭក ឥតមានបុគ្គលជាទីរឭក ។ ពាក្យថា ត្រាស់ គឺ ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (លោកសួរថា) បពិត្រព្រះមុនិ បើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ ។

[៣០៧] ពាក្យថា បពិត្រព្រះអង្គទ្រង់និរទុក្ខ កាលបើដូច្នេះ តើនរណាក្នុងទេវលោកនិងមនុស្សលោក ទើបឆ្លងជាតិនិងជរាបាន គឺកាលបើដូច្នេះ តើនរណា ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ក្នុងពួកមនុស្ស ជាសម្មតិទេព និងមនុស្សសាមញ្ញ ឆ្លង ឆ្លងឡើង ឆ្លងកាត់ កន្លង ប្រព្រឹត្តកន្លង នូវជាតិជរានិងមរណៈបាន ។

មារិសាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិ-
វចនមេតំ មារិសាតិ អថ កោ ចរហិ ទេវមនុស្ស-
លោកេ អតារិ ជាតិញ្ច ជរញ្ច មារិស ។

[៣០៨] បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ
បុច្ឆាមិ តន្តិ បុច្ឆាមិ តំ យាចាមិ តំ អជ្ឈេសាមិ
តំ បសាទេមិ តំ កថយស្សុ មេតិ បុច្ឆាមិ តំ ។
ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ
យទិទំ ភគវាតិ ។ ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខា-
ហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជា-
ហិ ឧត្តានីករោហិ បកាសេហីតិ បុច្ឆាមិ តំ ភគវា
ព្រូហិ មេ តំ ។ តេនាហ សោ ព្រាហ្មណោ

ពាក្យថា បពិត្រព្រះអង្គទ្រង់និរទុក្ខ គឺពាក្យជាទីស្រឡាញ់ ពាក្យជាទីគោរព ពាក្យថា បពិត្រព្រះអង្គទ្រង់និរទុក្ខ នេះជាពាក្យពោលដោយគោរពកោតខ្លាច ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គទ្រង់និរទុក្ខ កាលបើដូច្នេះ តើនរណា ក្នុងទេវលោកនិងមនុស្សលោក ឆ្លងជាតិនិងជរាបាន ។

[៣០៨] ពាក្យថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គទ្រង់ប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ គឺខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមអង្វរព្រះអង្គ សូមអារាធនាព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គ ហេតុនោះ (លោកសួរថា) ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ ។ ពាក្យថា បពិត្រព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថាព្រះមានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា សូមប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គ គឺសូមទ្រង់ប្រាប់ បង្ហាញ សម្តែង បញ្ញត្តតាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (លោកសួរថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គទ្រង់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

យេកេចិមេ សមណព្រាហ្មណាសេ

(ឥច្ចាយស្មា ជន្តោ)

ទិដ្ឋសុតេនាបិ វទន្តិ សុទ្ធឹ

សីលព្វតេនាបិ វទន្តិ សុទ្ធឹ

អនេកសុបេន វទន្តិ សុទ្ធឹ

តេ ចេ មុនី ព្រូសិ អនោឃតិណ្ណេ

អថ កោ ចរហិ ទេវមនុស្សលោកេ

អតារិ ជាតិញ្ច ជរញ្ច មារិស

បុច្ឆាមិ តំ ភគវា ព្រូហិ មេ តន្តិ ។

[៣០៩] នាហំ សព្វេ សមណព្រាហ្មណាសេ

(ជន្តាតិ ភគវា)

ជាតិជរាយ និវុតាតិ ព្រូមិ

យេសីធ ទិដ្ឋំវ សុតំ មុតំ វា

សីលព្វតំ វាបិ បហាយ សព្វំ

អនេករូបម្បិ បហាយ សព្វំ

តណ្ហំ បរិញ្ញាយ អនាសវា យេ

តេ វេ នរា ឱឃតិណ្ណាតិ ព្រូមិ ។

(នន្ទៈមានអាយុ ពោលដូច្នេះថា) សមណព្រាហ្មណ៍ទាំង-ឡាយណាមួយនេះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ឮខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះសីលនិងវត្តខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ បពិត្រព្រះមុនិ បើព្រះអង្គត្រាស់ថាសមណ-ព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ បពិត្រព្រះអង្គទ្រង់និរទុក្ខ កាលបើដូច្នេះ តើនរណា ក្នុងទេវលោកនឹងមនុស្សលោក ទើបឆ្លងជាតិនិងជរាបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គទ្រង់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

[៣០៩] (ព្រះមានព្រះភាគត្រាស់ថា ម្នាលនន្ទៈ) តថាគតមិនបានពោលថា ពួកសមណព្រាហ្មណ៍ទាំងអស់ ត្រូវជាតិនិងជរាបិទបាំងទេ តថាគតពោលថា ជនទាំងឡាយណា ក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីលនិងវត្តក្តី លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថាឆ្លងផុតឱឃៈបាន ។

២៤៣

## នន្ទមាណវកបញ្ហានិទ្ទេសោ

[៣១០] នាហំ សព្វេ សមណព្រាហ្មណាសេ (នន្ទាតិ ភគវា) ជាតិជរាយ និវុតាតិ ព្រូមីតិ នាហំ នន្ទ សព្វេ សមណព្រាហ្មណា ជាតិជរាយ អាវុតា និវុតា ឱផុដា បិហិតា បដិច្ឆន្នា បកុជ្ជិតាតិ វទាមិ អត្ថិ តេ សមណព្រាហ្មណា យេសំ ជាតិ ច ជរាមរណញ្ច បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មាតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមីតិ នាហំ សព្វេ សមណព្រាហ្មណាសេ (នន្ទាតិ ភគវា) ជាតិជរាយ និវុតាតិ ព្រូមិ ។

[៣១១] យេសីធ ទិដ្ឋំវ សុតំ មុតំ វា សីលព្វតំ វាបិ បហាយ សព្វន្តិ យេ សព្វា ទិដ្ឋសុទ្ធិយោ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វា យេ សព្វា សុតសុទ្ធិយោ

នន្ទមាណវកបុច្ឆានិទ្ទេស

[៣១០] ពាក្យថា (ព្រះមានព្រះភាគ ពោលថា ម្នាលនន្ទៈ) តថាគតមិនបានពោលថា ពួកសមណព្រាហ្មណ៍ទាំងអស់ ត្រូវជាតិនិងជរាបិទបាំងទេ សេចក្តីថា ម្នាលនន្ទៈ តថាគតមិនបានពោលថា សមណ-ព្រាហ្មណ៍ទាំងអស់ ត្រូវជាតិជរា ខ្ទប់ រាំង ហ៊ុមភ្ជិត បិទ បង្រួម ផ្កាប់ហើយ តថាគត ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើកបែក ធ្វើឲ្យរាក់ថា ជាតិក្តី ជរានិងមរណៈក្តី ដែលសមណព្រាហ្មណ៍ទាំងឡាយណា លះបង់ហើយ ផ្តាច់ឫសគល់ហើយ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យកើតមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត សមណព្រាហ្មណ៍ទាំងនោះគង់មាន ហេតុនោះ (មានពាក្យថា) (ព្រះមានព្រះភាគពោលថា ម្នាលនន្ទ) តថាគតមិនបានពោលថា ពួកសមណព្រាហ្មណ៍ទាំងអស់ ត្រូវជាតិនិងជរាបិទបាំងទេ ។

[៣១១] ពាក្យថា ជនទាំងឡាយណាក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីលនិងវត្តក្តី សេចក្តីថា ជនទាំងឡាយណា លះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាសដល់នូវការមិនកើតមាន នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញទាំងអស់ ជនទាំងឡាយណា លះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាព នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឮទាំងអស់

យេ សត្តា ទិដ្ឋសុតសុទ្ធិយោ យេ សត្តា មុតសុទ្ធិយោ យេ សត្តា សីលសុទ្ធិយោ យេ សត្តា វត្តសុទ្ធិយោ យេ សត្តា សីលព្វតសុទ្ធិយោ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ យេសីធ ទិដ្ឋំវ សុតំ មុតំ វា សីលព្វតំ វាបិ បហាយ សព្វំ ។

[៣១២] អនេករូបម្បិ បហាយ សព្វន្តិ អនេកវិធវត្តកុតូហលមង្គលេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ អនេករូបម្បិ បហាយ សព្វំ ។

[៣១៣] តណ្ហំ បរិញ្ញាយ អនាសវា យេ តេ វេ នរា ឱឃតិណ្ណាតិ ព្រូមីតិ តណ្ហាន្តិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ បរិញ្ញាយាតិ តណ្ហំ តីហិ បរិញ្ញាហិ បរិជានិត្វា ញាតបរិញ្ញាយ តិរណបរិញ្ញាយ បហានបរិញ្ញាយ ។

នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ ដែលឃើញដែលឮទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលប៉ះពាល់ទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះសីលទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះវត្តទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះសីលនិងវត្តទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងឡាយណា ក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីលនិងវត្តក្តី ។

[៣១២] ពាក្យថា លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី គឺលះបង់ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាពនូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះដោយវត្តនិងមង្គល ភ្ញាក់ផ្អើលមានប្រការផ្សេងៗ ជាអនេក ហេតុនោះ (ទ្រង់ត្រាស់ថា) លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ។

[៣១៣] អធិប្បាយពាក្យថា តថាគតពោលថា... ឬជនទាំង-ឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថាឆ្លងផុតឱឃៈបាន ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា កំណត់ដឹង គឺកំណត់ដឹងនូវតណ្ហា ដោយបរិញ្ញា ៣ គឺ ញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។

នន្ទមាណវកប្បញ្ហានិទ្ទេសោ

កតមា ញាតបរិញ្ញា ។ តណ្ហំ បជានាតិ អយំ រូបតណ្ហា អយំ សទ្ទតណ្ហា អយំ គន្ធតណ្ហា អយំ រសតណ្ហា អយំ ផោដ្ឋព្វតណ្ហា អយំ ធម្មតណ្ហាតិ បជានាតិ បស្សតិ អយំ ញាតបរិញ្ញា ។

កតមា តិរណបរិញ្ញា ។ ឯវំ ញាតំ កត្វា តណ្ហំ តិរេតិ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ ។ បេ ។ អនិស្សរណតោ តិរេតិ អយំ តិរណបរិញ្ញា ។

កតមា បហានបរិញ្ញា ។ ឯវំ តិរេត្វា តណ្ហំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។ វុត្តំ ហេតំ ភគវតា យោ ភិក្ខវេ តណ្ហាយ ឆន្ទ-រាគោ តំ បជហថ ឯវំ សា តណ្ហា បហីនា ភវិស្សតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មាតិ អយំ បហានបរិញ្ញា ។ តណ្ហំ ឥមាហិ តីហិ បរិញ្ញាហិ បរិជានិត្វាតិ តណ្ហំ បរិញ្ញាយ ។

នន្ទមាណវកប្បញ្ហានិទ្ទេស

ញាតបរិញ្ញា តើដូចម្តេច ។ បុគ្គលដឹងច្បាស់នូវតណ្ហា គឺដឹងច្បាស់ ឃើញច្បាស់ថា នេះរូបតណ្ហា នេះសទ្ទតណ្ហា នេះគន្ធតណ្ហា នេះរសតណ្ហា នេះផោដ្ឋព្វតណ្ហា នេះធម្មតណ្ហាដូច្នេះ នេះញាតបរិញ្ញា ។

តិរណបរិញ្ញា តើដូចម្តេច ។ បុគ្គលធ្វើការដឹងយ៉ាងនេះហើយ ត្រិះរិះនូវតណ្ហា ថាមិនទៀង ជាទុក្ខ ជារោគ ជាបូស ។ បេ ។ ត្រិះរិះនូវតណ្ហាថា មិនមែនជាគ្រឿងរលាស់ចេញដូច្នេះ នេះតិរណបរិញ្ញា ។

បហានបរិញ្ញា តើដូចម្តេច ។ បុគ្គលត្រិះរិះយ៉ាងនេះហើយ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាព នូវតណ្ហា ។ សមដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ឆន្ទរាគៈក្នុងតណ្ហាណា អ្នកទាំងឡាយ ចូរលះបង់ឆន្ទរាគៈនោះចេញ កាលបើធ្វើបានយ៉ាងនេះ តណ្ហានោះ ឈ្មោះថា ជាធម្មជាតិដែលអ្នកលះបង់ហើយ ផ្តាច់ឫសចោលហើយ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យកើតមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ដូច្នេះ នេះបហានបរិញ្ញា ។ បុគ្គលកំណត់ដឹងតណ្ហា ដោយបរិញ្ញាទាំង ៣ នេះ ហេតុនោះ (ទ្រង់ត្រាស់ថា) កំណត់ដឹងនូវតណ្ហា ។

អនាសវាតិ ចត្តារោ អាសវា កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ យេសំ ឥមេ អាសវា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តេ វុច្ចន្តិ អនាសវា ។ យេតិ អរហន្តោ ខីណាសវា ។

តណ្ហំ បរិញ្ញាយ អនាសវា យេ តេ វេ នរា ឱឃតិណ្ណាតិ ព្រូមីតិ យេ តណ្ហំ បរិញ្ញាយ អនាសវា តេ កាមោឃំ តិណ្ណា ភវោឃំ តិណ្ណា ទិដ្ឋោឃំ តិណ្ណា អវិជ្ជោឃំ តិណ្ណា សព្វំ សំសារបថំ តិណ្ណា ឧត្តិណ្ណា និត្តិណ្ណា អតិក្កន្តា សមតិក្កន្តា វីតិវត្តាតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ តណ្ហំ បរិញ្ញាយ អនាសវា យេ តេ វេ នរា ឱឃតិណ្ណាតិ ព្រូមិ ។

តេនាហ ភគវា

ពាក្យថា មិនមានអាសវៈ សេចក្តីថា អាសវៈ ៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ អាសវៈទាំងនេះ បុគ្គលទាំងឡាយណា បានលះបង់ ផ្តាច់ឫសចោល ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យកើតមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត បុគ្គលទាំងនោះ លោកហៅថា អ្នកមិនមានអាសវៈ ។ ពាក្យថា បុគ្គលទាំង-ឡាយណា គឺ ព្រះអរហន្តខីណាស្រព ។

ពាក្យថា តថាគតពោលថា... ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងឡាយនោះឯង ឈ្មោះថាឆ្លងផុតឱឃៈបាន បានន័យថា តថាគតពោល ប្រាប់ សម្តែង បញ្ញត្តតាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសថា ជនទាំងឡាយណា កំណត់ដឹងតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះ ឆ្លងឱឃៈគឺកាម ឆ្លងឱឃៈគឺភព ឆ្លងឱឃៈគឺទិដ្ឋិ ឆ្លងឱឃៈគឺអវិជ្ជា ឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លង កន្លងព្រម ប្រព្រឹត្តកន្លង នូវគន្លងសង្សារទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតពោលថា....ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថាឆ្លងផុតឱឃៈបាន ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

២៤៧

នន្ទមាណវកបញ្ហានិទ្ទេសោ

ជាហំ សព្វេ សមណព្រាហ្មណាសេ

(ឧដ្ឋាតិ ភគវា)

ជាតិជរាយ និវុតាតិ ព្រូមិ

យេសីធ ទិដ្ឋំវ សុតំ មុតំ វា

សីលព្វតំ វាបិ បហាយ សព្វំ

អនេករូបម្បិ បហាយ សព្វំ

តណ្ហំ បរិញ្ញាយ អនាសវា យេ

តេ វេ នរា ឱឃតិណ្ណាតិ ព្រូមីតិ ។

[៣១៤] ឯតាភិនន្ទាមិ វចោ មហេសិនោ

សុកិត្តិតំ គោតម នូបធីកំ

យេសីធ ទិដ្ឋំវ សុតំ មុតំ វា

សីលព្វតំ វាបិ បហាយ សព្វំ

អនេករូបម្បិ បហាយ សព្វំ

តណ្ហំ បរិញ្ញាយ អនាសវា យេ

អហម្បិ តេ ឱឃតិណ្ណាតិ ព្រូមិ ។

នន្ទមាណវកប្បញ្ហានិទ្ទេស

(ព្រះមានព្រះភាគត្រាស់ថា ម្នាលនន្ទៈ) តថាគតមិនបាន ពោលថា ពួកសមណព្រាហ្មណ៍ទាំងអស់ ត្រូវជាតិនិងជរាបិទបាំងទេ តថាគតពោលថាជនទាំងឡាយណា ក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីលនិងវត្តក្តី លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថាឆ្លងផុតឱឃៈបាន ។

[៣១៤] ខ្ញុំព្រះអង្គ រីករាយចំពោះពាក្យនុ៎ះ របស់ព្រះអង្គទ្រង់ស្វែរកគុណដ៏ធំ បពិត្រព្រះគោតម ព្រះនិព្វានមិនមានឧបធិ ព្រះអង្គត្រាស់ទុកល្អហើយថា តថាគតពោលថាជនទាំងឡាយណាក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីលនិងវត្តក្តី លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថាឆ្លងផុតឱឃៈបាន ។

[៣១៥] ឯតាភិនន្ទាមិ វចោ មហេសិនោតិ ឯតន្តិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសន្ធឹ នន្ទាមិ អភិនន្ទាមិ មោទាមិ អនុមោទាមិ ឥច្ឆាមិ សាទិយាមិ បត្ថយាមិ បិហយាមិ អភិជប្បាមិ ។ មហេសិនោតិ មហេសី ភគវា ។ មហន្តំ សីលក្ខន្ធំ ឯសិ គវេសិ បរិយេសីតិ មហេសី ។ បេ ។ កហំ ទេវទេវោ កហំ នរាសភោតិ មហេសីតិ ឯតាភិនន្ទាមិ វចោ មហេសិនោ ។

[៣១៦] សុកិត្តិតំ គោតម នូបធីកន្តិ សុកិត្តិតន្តិ សុអាចិក្ខិតំ សុទេសិតំ សុបញ្ញបិតំ សុបដ្ឋបិតំ សុវិវរិតំ សុវិភត្តំ សុឧត្តានីកតំ សុបកាសិតំ ។ គោតម នូបធីកន្តិ ឧបធិ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ ឧបធិបហានំ ឧបធិវូបសមោ ឧបធិបដិនិស្សគ្គោ ឧបធិបដិប្បស្សទ្ធិ[១] អមតំ និព្វានន្តិ សុកិត្តិតំ គោតម នូបធីកំ ។

១ ម. ឧបធិវូបសមំ ឧបធិបដិនិស្សគ្គំ ឧបធិបដិប្បស្សទ្ធំ ។

[៣១៥] អធិប្បាយពាក្យថា ខ្ញុំព្រះអង្គ រីករាយ ចំពោះពាក្យទុំះ របស់ព្រះអង្គ ទ្រង់ស្វែងរកគុណដ៏ធំ ត្រង់ពាក្យថា ទុំះ គឺខ្ញុំព្រះអង្គត្រេកអរ ត្រេកអរចំពោះ រីករាយ រីករាយតាម ចង់បាន ជ្រះថ្លា ប្រាថ្នា ស្រឡាញ់ ជាប់ចិត្តចំពោះពាក្យ ចំពោះកិរិយាពោល ចំពោះទេសនា ចំពោះអនុសន្ធិ របស់ព្រះអង្គ ។ ពាក្យថា ទ្រង់ស្វែងរកគុណដ៏ធំ គឺព្រះមានព្រះភាគ ទ្រង់ស្វែងរកគុណដ៏ធំ ឈ្មោះថា ទ្រង់ស្វែងរកគុណដ៏ធំ ព្រោះទ្រង់រក ស្វែងស្វះស្វែង នូវសីលក្ខន្ធដ៏ធំ ឈ្មោះថា ទ្រង់ស្វែងរកគុណដ៏ធំ ព្រោះត្រូវគេស្វែងរកថា ។ បេ ។ ព្រះពុទ្ធជាទេវតា ធំជាងទេវតា (គង់) ក្នុងទីណា ព្រះពុទ្ធជានរៈដ៏អង់អាច (គង់) ក្នុងទីណា ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គរីករាយចំពោះពាក្យទុំះ របស់ព្រះអង្គ ទ្រង់ស្វែងរកគុណដ៏ធំ ។

[៣១៦] អធិប្បាយថា បពិត្រព្រះគោតម ព្រះនិព្វានមិនមានឧបធិ ព្រះអង្គត្រាស់ទុកល្អហើយ ត្រង់ពាក្យថា ត្រាស់ល្អហើយ គឺព្រះអង្គ ប្រាប់ល្អ សម្តែងល្អ បញ្ញត្តល្អ តាំងទុកល្អ បើកល្អ ចែកល្អ ធ្វើឲ្យរាក់ល្អ ប្រកាសល្អហើយ ។ ពាក្យថា បពិត្រព្រះគោតម ព្រះនិព្វានមិនមានឧបធិ សេចក្តីថា កិលេសផង ខន្ធផង អភិសង្ខារផង លោកហៅថា ឧបធិ ។ គឺការលះបង់ឧបធិ ការរម្ងាប់ឧបធិ ការរលាស់ចោលឧបធិ ការស្ងប់ឧបធិ អមតនិព្វាន ហេតុនោះ (លោកពោលថា) បពិត្រព្រះគោតម ព្រះនិព្វានមិនមានឧបធិ ព្រះអង្គទ្រង់ត្រាស់ល្អហើយ ។

នន្ទមាណវកប្បញ្ហានិទ្ទេសោ

[៣១៧] យេសីធ ឥដ្ឋំវ សុតំ មុតំ វា សីលព្វតំ វាបិ បហាយ សព្វន្តិ យេ សព្វា ទិដ្ឋសុទ្ធិយោ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វា យេ សព្វា សុតសុទ្ធិយោ យេ សព្វា ទិដ្ឋសុតសុទ្ធិយោ យេ សព្វា មុតសុទ្ធិយោ យេ សព្វា សីលសុទ្ធិយោ យេ សព្វា វត្តសុទ្ធិយោ យេ សព្វា សីលព្វតសុទ្ធិយោ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ យេសីធ ទិដ្ឋំវ សុតំ មុតំ វា សីលព្វតំ វាបិ បហាយ សព្វំ ។

[៣១៨] អនេករូបម្បិ បហាយ សព្វន្តិ អនេកវិធវត្តកុតូហលមង្គលេន សុទ្ធឹ វិសុទ្ធឹ បរិសុទ្ធឹ មុត្តឹ វិមុត្តឹ បរិមុត្តឹ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ អនេករូបម្បិ បហាយ សព្វំ ។

នន្ទមាណវកបញ្ហានិទ្ទេស

[៣១៧] ពាក្យថា ជនទាំងឡាយណា ក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីលនិងវត្តក្តី សេចក្តីថា ជនទាំងឡាយណា លះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាព នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញទាំងអស់ ជនទាំងឡាយណា លះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាព នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញ ឬឮទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលប៉ះពាល់ទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះសីលទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះវត្តទាំងអស់ នូវសេចក្តីបរិសុទ្ធ ព្រោះសីលនិងវត្តទាំងអស់ ហេតុនោះ (លោកពោលថា) ជនទាំងឡាយណា ក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីលនិងវត្តក្តី ។

[៣១៨] ពាក្យថា លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី គឺលះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាព នូវការស្អាត ស្អាតវិសេស បរិសុទ្ធិ ការរួច រួចវិសេស រួចស្រឡះ ព្រោះវត្តនិងមង្គលភ្ញាក់ផ្អើលមានប្រការផ្សេងៗ ជាអនេក ហេតុនោះ (លោកពោលថា) លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ។

[៣១៩] តណ្ហំ បរិញ្ញាយ អនាសវា យេ អហម្បិ តេ ឱឃតិណ្ណាតិ ព្រូមីតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហំ បរិញ្ញាយាតិ តណ្ហំ តីហិ បរិញ្ញាហិ បរិជានិត្វា[១] ញាតបរិញ្ញាយ តិរណបរិញ្ញាយ បហានបរិញ្ញាយ ។

កាតមា ញាតបរិញ្ញា ។ តណ្ហំ បជានាតិ អយំ រូបតណ្ហា អយំ សទ្ទតណ្ហា អយំ គន្ធតណ្ហា អយំ រសតណ្ហា អយំ ផោដ្ឋព្វតណ្ហា អយំ ធម្មតណ្ហាតិ បជានាតិ បស្សតិ អយំ ញាតបរិញ្ញា ។

កាតមា តិរណបរិញ្ញា ។ ឯវំ ញាតំ កត្វា តណ្ហំ តិរេតិ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោក-តោ ឦតិតោ ឧបទ្ទវតោ ភយតោ ឧបសគ្គតោ ចលតោ បភង្គុតោ អទ្ធុវតោ អតាណតោ អលេ-ណតោ អសរណតោ អសរណីភូតតោ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ អាទីនវតោ វិបរិណាមធម្មតោ អសារកតោ អឃមូលកតោ វធកតោ សាសវតោ

១ ម. បរិជានេយ្យ ។

[៣១៩] អធិប្បាយពាក្យថា តថាគតពោលថា... ឬជនទាំងឡាយណា កំណត់ដឹងតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងឡាយនោះឯង ឈ្មោះថាឆ្លងផុតឱឃៈបាន ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ។ ពាក្យថា កំណត់ដឹងនូវតណ្ហា គឺកំណត់ដឹងនូវតណ្ហាដោយបរិញ្ញា ៣ គឺញាតបរិញ្ញា ១ តិរណបរិញ្ញា ១ បហានបរិញ្ញា ១ ។

ញាតបរិញ្ញា តើដូចម្តេច ។ បុគ្គលដឹងច្បាស់នូវតណ្ហា គឺដឹងច្បាស់ឃើញច្បាស់ថា នេះរូបតណ្ហា នេះសទ្ទតណ្ហា នេះគន្ធតណ្ហា នេះរសតណ្ហា នេះផោដ្ឋព្វតណ្ហា នេះធម្មតណ្ហា ដូច្នេះ នេះញាតបរិញ្ញា ។

តិរណបរិញ្ញា តើដូចម្តេច ។ បុគ្គលធ្វើ នូវការដឹង យ៉ាងនេះ ហើយត្រិះរិះ នូវតណ្ហា គឺត្រិះរិះថា មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាសរ ជាសេចក្តីតានតឹង ជាអាពាធ ជារបស់បុគ្គលដទៃ ជារបស់សាបសូន្យ ជាចង្រៃ ជាឧបទ្រព ជាភ័យ ជាឧបសគ្គ ជារបស់ប្រែប្រួល ជារបស់ពុករលួយ ជារបស់មិនឋិតថេរ ឥតទីពឹង ឥតទីជ្រក ឥតទីរឭក ឥតបុគ្គលជាទីរឭក គ្មាន ទទេ សោះសូន្យ មិនមែនខ្លួន ជាទោស ជារបស់ប្រែប្រួលជាធម្មតា ឥតខ្លឹម ជាទីតាំង នៃសេចក្តីតានតឹង ជាអ្នកសម្លាប់ ប្រកបដោយអាសវៈ

២៦១



សង្ខតតោ មារាមិសតោ ជាតិធម្មតោ ជរាធម្មតោ ព្យាធិធម្មតោ មរណធម្មតោ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មតោ[១] សមុទយតោ អត្ថង្គមតោ អស្សាទតោ អាទីនវតោ និស្សរណតោ តីរេតិ អយំ តីរណបរិញ្ញា ។

កតមា បហានបរិញ្ញា ។ ឯវំ តីរេត្វា តណ្ហំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ អយំ បហានបរិញ្ញា ។ តំ តណ្ហំ ឥមាហិ តីហិ បរិញ្ញាហិ បរិជានិត្វាតិ តណ្ហំ បរិញ្ញាយ ។

អនាសវាតិ ចត្តារោ អាសវា កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។ យេសំ ឥមេ អាសវា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តេ វុច្ចន្តិ អនាសវា ។ យេតិ អរហន្តោ ខីណាសវា ។

តណ្ហំ បរិញ្ញាយ អនាសវា យេ អហម្បិ តេ ឱឃតិណ្ណាតិ ព្រូមីតិ យេ តណ្ហំ បរិញ្ញាយ អនាសវា

១ ម. ឯត្ថន្តរេ សង្កិលេសធម្មតោតិ ទិស្សតិ ។

ជារបស់មានបច្ច័យតាក់តែង ជាអាមិសនៃមារ មានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា មានសេចក្តីស្លាប់ជាធម្មតា មានការសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ជាធម្មតា ជាហេតុឲ្យកើត ជារបស់វិនាស ជារបស់ឥតសង្ឃឹម ជាទោស មិនជាទីរលាស់ចេញ នេះ តិរណបរិញ្ញា ។

បហានបរិញ្ញា តើដូចម្តេច ។ បុគ្គលត្រិះរិះយ៉ាងនេះហើយ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមានបែបភាព នូវតណ្ហានេះបហានបរិញ្ញា ។ បុគ្គលកំណត់ដឹង នូវតណ្ហា ដោយបរិញ្ញា ៣ នេះ ហេតុនោះ (លោកពោលថា) កំណត់ដឹងនូវតណ្ហា ។

ពាក្យថា ជាអ្នកមិនមានអាសវៈ សេចក្តីថា អាសវៈ ៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។ អាសវៈទាំងនេះ បុគ្គលទាំងឡាយណា បានលះបង់ ផ្តាច់ឫសចោល ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យកើតមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ជនទាំងនោះ លោកហៅថា អ្នកមិនមានអាសវៈ ។ ពាក្យថា ជនទាំងឡាយណា បានដល់ ពួកព្រះអរហន្តខីណាស្រព ។

ពាក្យថា តថាគតពោលថា... ឬជនទាំងឡាយណាកំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថាឆ្លងផុតឱឃៈ បានសេចក្តីថា ជនទាំងឡាយណា កំណត់ដឹងតណ្ហា ជាអ្នកមិនមានអាសវៈ

អហម្បិ តេ កាមោឃំ តិណ្ណា ភវោឃំ តិណ្ណា ទិដ្ឋោឃំ តិណ្ណា អវិជ្ជោឃំ តិណ្ណា សព្វំ សំសារបថំ តិណ្ណា ឧត្តិណ្ណា និត្តិណ្ណា អតិក្កន្តា សមតិក្កន្តា វីតិវត្តាតិ ព្រូមិ វទាមីតិ តណ្ហំ បរិញ្ញាយ អនាសវា យេ អហម្បិ តេ ឱឃតិណ្ណាតិ ព្រូមិ ។ តេនាហ សោ ព្រាហ្មណោ

ឯតាភិនន្ទាមិ វចោ មហេសិនោ
សុកិត្តិតំ គោតម នូបធីកំ
យេសីធ ទិដ្ឋំវ សុតំ មុតំ វា
សីលព្វតំ វាបិ បហាយ សព្វំ
អនេករូបម្បិ បហាយ សព្វំ
តណ្ហំ បរិញ្ញាយ អនាសវា យេ
អហម្បិ តេ ឱឃតិណ្ណាតិ ព្រូមីតិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

នន្ទមាណវកបញ្ហានិទ្ទេសោ សត្តមោ ។

តថាគតពោល និយាយថា ជនទាំងនោះ បានឆ្លងឱឃៈ គឺកាម ឆ្លងឱឃៈគឺភព ឆ្លងឱឃៈគឺទិដ្ឋិ ឆ្លងឱឃៈគឺអវិជ្ជា ឆ្លងឡើង ឆ្លងចេញ កន្លង រំលង ប្រព្រឹត្តកន្លង នូវគន្លងនៃសង្សារទាំងអស់ ហេតុនោះ (លោកពោលថា) តថាគតពោលថា... ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថាឆ្លងផុតឱឃៈបាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ខ្ញុំព្រះអង្គរីករាយចំពោះពាក្យនុ៎ះ របស់ព្រះអង្គ ទ្រង់ស្វែងរកគុណដ៏ធំ បពិត្រព្រះគោតម ព្រះនិព្វានមិនមានឧបធិ ព្រះអង្គត្រាស់ទុកល្អហើយថា តថាគតពោលថា ជនទាំង-ឡាយណាក្នុងលោកនេះ លះបង់នូវអារម្មណ៍ទាំងអស់ ដែលឃើញក្តី ដែលឮក្តី ដែលប៉ះពាល់ក្តី នូវសីលនិងវត្តក្តី លះបង់នូវវិធីច្រើនប្រការទាំងអស់ក្តី ឬជនទាំងឡាយណា កំណត់ដឹងនូវតណ្ហា ជាអ្នកមិនមានអាសវៈ ជនទាំងនោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ។

លុះចប់គាថាហើយ ។ បេ ។ នន្ទៈពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ នន្ទមាណវកបញ្ហានិទ្ទេស ទី ៧ ។

# ហេមកមាណវកប្បញ្ហានិទ្ទេសោ

[៣២០] យេមេ បុព្វេ វិយាកំសុ
(ឥច្ចាយស្មា ហេមកោ)
ហុរំ គោតមសាសនា
ឥច្ចាសិ ឥតិ ភវិស្សតិ
សព្វន្តំ ឥតិហីតិហំ
សព្វន្តំ តក្កវឌ្ឍនំ
នាហំ តត្ថ អភិរមឹ ។

[៣២១] យេមេ បុព្វេ វិយាកំសូតិ យេតិ យោ ច ពាវរី ព្រាហ្មណោ យេ ចញ្ញេ តស្ស អាចរិយា តេ សកំ ទិដ្ឋឹ សកំ ខន្តឹ សកំ រុចឹ សកំ លទ្ធឹ សកំ អជ្ឈាសយំ សកំ អធិប្បាយំ ព្យាករឹសុ អាចិក្ខឹសុ ទេសយឹសុ បញ្ញបឹសុ បដ្ឋបឹសុ វិវរឹសុ វិភជឹសុ ឧត្តានីមកំសុ បកាសេសុន្តិ យេមេ បុព្វេ វិយាកំសុ ។ ឥច្ចាយស្មា ហេមកោតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ បទានុបុព្វតាមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។

# ហេមកមាណវកប្បញ្ហានិទ្ទេស

[៣២០] (ហេមកៈមានអាយុទូលសួរដូច្នេះថា) ក្នុងកាលមុន អំពីសាសនាព្រះគោតម ជនទាំងឡាយណា ព្យាករ ថា ហេតុធ្លាប់មានហើយដូច្នេះ នឹងមានដូច្នេះ ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ខ្ញុំព្រះអង្គមិនត្រេកអរ ក្នុងពាក្យនោះឡើយ ។

[៣២១] អធិប្បាយពាក្យថា ជនទាំងឡាយណាព្យាករ ត្រង់ពាក្យថា ជនទាំងឡាយណា គឺពាវរីព្រាហ្មណ៍ណាផង ព្រាហ្មណ៍ទាំងឡាយដទៃណា ជាអាចារ្យរបស់ពាវរីព្រាហ្មណ៍នោះផង ព្រាហ្មណ៍ទាំងនោះព្យាករ ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសហើយ នូវទិដ្ឋិរបស់ខ្លួន សេចក្តីគួររបស់ខ្លួន សេចក្តីគាប់ចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្រ័យរបស់ខ្លួន សេចក្តីប៉ុនប៉ងរបស់ខ្លួន ហេតុនោះ (លោកពោលថា) ជនទាំងឡាយណា ព្យាករ ។ ពាក្យថា ដូច្នេះ របស់បទថា ហេមកៈមានអាយុទូលសួរដូច្នេះ ជាពាក្យតំណបទ ។ បេ ។ ពាក្យថា ដូច្នេះ នេះ ជាលំដាប់លំដោយនៃបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នេះជាពាក្យពោលដោយគោរព កោតខ្លាច ។

ហោមកោតិ ជាមំ ។ បេ ។ អភិលាចោតិ ឥច្ចាយស្មា ហោមកោ ។

[៣២២] ហុរំ គោតមសាសនាតិ ហុរំ គោតមសាសនា បរំ គោតមសាសនា បុរេ គោតមសាសនា បឋមតរំ គោតមសាសនា ពុទ្ធសាសនា ជិនសាសនា តថាគតសាសនា[១] អរហន្តសាសនាតិ ហុរំ គោតមសាសនា ។

[៣២៣] ឥច្ចាសិ ឥតិ ភវិស្សតីតិ ឯវំ កិរ អសិ ឯវំ កិរ ភវិស្សតីតិ ឥច្ចាសិ ឥតិ ភវិស្សតិ ។

[៣២៤] សព្វន្តំ ឥតិហីតិហន្តិ សព្វន្តំ ឥតិហីតិហំ ឥតិកិរាយ បរម្បរាយ បិដកសម្បទាយ តក្កហេតុ នយហេតុ អាការបរិវិតក្កេន ទិដ្ឋិនិជ្ឈានក្ខន្តិយា ន សាមំ សយមភិញ្ញាតំ ន អត្តបច្ចក្ខំ ធម្មំ កថយឹសុតិ សព្វន្តំ ឥតិហីតិហំ ។

១ ម. ឯត្តន្តរេ ទេវសាសនាតិ ទិស្សតិ ។

ពាក្យថា ហេមកៈ គឺជាឈ្មោះ ។ បេ ។ ជាពាក្យសម្រាប់ហៅ ហេតុនោះ (មានពាក្យថា) ហេមកៈមានអាយុទូលសួរដូច្នេះ ។

[៣២២] ពាក្យថា ក្នុងកាលមុនអំពីសាសនាព្រះគោតម គឺមុនអំពីសាសនានៃព្រះគោតម ខាងនាយអំពីសាសនារបស់ព្រះគោតម ខាងដើមអំពីសាសនារបស់ព្រះគោតម ដំបូងបង្អស់អំពីសាសនារបស់ព្រះគោតម អំពីសាសនារបស់ព្រះពុទ្ធ អំពីសាសនារបស់ព្រះជិនស្រី អំពីសាសនារបស់ព្រះតថាគត អំពីសាសនារបស់ព្រះអរហន្ត ហេតុនោះ (លោកពោលថា) ក្នុងកាលមុនអំពីសាសនាព្រះគោតម ។

[៣២៣] ពាក្យថា ហេតុធ្លាប់មានហើយដូច្នេះ នឹងមានដូច្នេះ គឺ ឮថា ហេតុយ៉ាងនេះមានមកហើយ ឮថា ហេតុយ៉ាងនេះនឹងមាន ហេតុនោះ (លោកពោលថា) ហេតុធ្លាប់មានហើយដូច្នេះ នឹងមានដូច្នេះ ។

[៣២៤] ពាក្យថា ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ គឺពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ សេចក្តីថា ព្រាហ្មណ៍ទាំងឡាយសម្តែងធម៌ ដោយឮថាដូច្នេះៗ ដោយឮតៗ គ្នា ដោយការផ្សេផ្សំនឹងក្បួន ដោយហេតុនៃការត្រិះរិះ ដោយហេតុនៃការត្រេរត្រានំ ដោយការជញ្ជឹងនូវអាការៈ ដោយហេតុដែលខ្លួនយល់ ខ្លួនពិនិត្យ ខ្លួនចូលចិត្ត មិនមែនត្រាស់ដឹងចំពោះខ្លួនឯង មិនមែនជាក់ច្បាស់ចំពោះខ្លួន ហេតុនោះ (លោកពោលថា) ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ ។

ហេមកមាណវកប្បញ្ហានិទ្ទេសោ

[៣២៥] សព្វន្តំ តក្កវឌ្ឍនន្តិ សព្វន្តំ តក្កវឌ្ឍនំ វិតក្កវឌ្ឍនំ សង្កប្បវឌ្ឍនំ កាមវិតក្កវឌ្ឍនំ ព្យាបាទ-វិតក្កវឌ្ឍនំ វិហឹសាវិតក្កវឌ្ឍនំ ញាតិវិតក្កវឌ្ឍនំ ជនប-ទវិតក្កវឌ្ឍនំ អមរវិតក្កវឌ្ឍនំ បរានុទ្ទយតាបដិសំ-យុត្តវិតក្កវឌ្ឍនំ លាភសក្ការសិលោកប្បដិសំយុត្តវិ-តក្កវឌ្ឍនំ អនវញ្ញត្តិប្បដិសំយុត្តវិតក្កវឌ្ឍនន្តិ សព្វន្តំ តក្កវឌ្ឍនំ ។

[៣២៦] ណាហំ តត្ថ អភិរមិន្តិ ន វិន្ទឹ ណាដិកច្ចឹ ន បដិលភិន្តិ ណាហំ តត្ថ អភិរមឹ ។ តេនាហ សោ ព្រាហ្មណោ

យេមេ បុព្វេ វិយាកំសុ
(ឥច្ចាយស្មា ហេមកោ)
ហុរំ គោតមសាសនា
ឥច្ចាសិ ឥតិ ភវិស្សតិ
សព្វន្តំ ឥតិហីតិហំ
សព្វន្តំ តក្កវឌ្ឍនំ
ណាហំ តត្ថ អភិរមិន្តិ ។

[៣២៥] ពាក្យថា ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន គឺ ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះផ្សេងៗ ឲ្យចម្រើន ធ្វើតម្រិះឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងកាមឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងព្យាបាទឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងការបៀតបៀនឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះញាតិឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះជនបទឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះការមិនស្លាប់ឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះដែលប្រកបដោយសេចក្តីអាណិត ចំពោះបុគ្គលដទៃឲ្យច្រើន ធ្វើសេចក្តីត្រិះរិះដែលប្រកបដោយលាភៈ សក្ការៈ និងសេចក្តីសរសើរឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ដែលប្រកបដោយសេចក្តីមិនមើលងាយឲ្យចម្រើន ហេតុនោះ (លោកពោលថា) ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ។

[៣២៦] ពាក្យថា ខ្ញុំព្រះអង្គមិនត្រេកអរក្នុងពាក្យនោះឡើយ គឺ ខ្ញុំព្រះអង្គ មិនបាន មិនលុះ មិនបានចំពោះហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គមិនត្រេកអរក្នុងពាក្យនោះឡើយ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

(ហេមកៈមានអាយុ ទូលសួរដូច្នេះថា) ក្នុងកាលមុនអំពីសាសនា
ព្រះគោតម ជនទាំងឡាយណា ព្យាករថា ហេតុធ្លាប់មាន
ហើយដូច្នេះ នឹងមានដូច្នេះ ពាក្យទាំងអស់នោះ ជាពាក្យជឿ
ស្តាប់បុគ្គលដទៃ ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តី
ត្រិះរិះឲ្យចម្រើន ខ្ញុំព្រះអង្គមិនត្រេកអរ ក្នុងពាក្យនោះឡើយ ។

[៣២៧] តុយ្ហញ្ច មេ ធម្មមក្ខាហិ តណ្ហានិគ្ឃាតនំ មុនិ
យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។

[៣២៨] តុយ្ហញ្ច មេ ធម្មមក្ខាហីតិ តុយ្ហន្តិ ភគវន្តំ ភណតិ ។ ធម្មមក្ខាហីតិ ធម្មន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចត្តារោ សតិប្បដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ អក្ខាហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ តុយ្ហញ្ច មេ ធម្មមក្ខាហិ ។

[៣២៩] តណ្ហានិគ្ឃាតនំ មុនីតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហានិគ្ឃាតនន្តិ តណ្ហានិគ្ឃាតនំ តណ្ហាបហានំ តណ្ហាវូបសមំ តណ្ហាបដិនិស្សគ្គំ តណ្ហាបដិប្បស្សទ្ធឹ អមតំ និព្វានំ ។

[៣២៧] បពិត្រព្រះមុនិ សូមព្រះអង្គ សម្តែងធម៌ សម្រាប់ដកចេញនូវតណ្ហា ជាធម៌ដែលនាំឲ្យបុគ្គលដឹងច្បាស់ មានសតិប្រព្រឹត្តឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោក ដល់ខ្ញុំព្រះអង្គ ។

[៣២៨] ពាក្យថា សូមព្រះអង្គ សម្តែងធម៌ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា ព្រះអង្គ គឺ ព្រាហ្មណ៍ពោល ចំពោះព្រះមានព្រះភាគ ។ ពាក្យថា ធម៌ របស់បទថា សូមសម្តែងធម៌ គឺ សូមព្រះអង្គ ពោលប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាសនូវធម៌ មានពីរោះបទខាងដើម មានពីរោះបទកណ្តាល មានពីរោះបទខាងចុង នូវព្រហ្មចរិយៈ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌ សព្វគ្រប់ នូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរព្រះនិព្វាន និងបដិបទាជាដំណើរទៅកាន់ព្រះនិព្វាន ហេតុនោះ (លោកពោលថា) សូមព្រះអង្គ សម្តែងធម៌ ដល់ខ្ញុំព្រះអង្គ ។

[៣២៩] ពាក្យថា បពិត្រព្រះមុនិ...សម្រាប់ដកចេញនូវតណ្ហា ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា សម្រាប់ដកចេញនូវតណ្ហា គឺជាគ្រឿងធ្វើតណ្ហាឲ្យវិនាស ជាគ្រឿងលះបង់តណ្ហា ជាគ្រឿងរម្ងាប់តណ្ហា ជាគ្រឿងរលាស់ចោលតណ្ហា ជាគ្រឿងស្ងប់រម្ងាប់តណ្ហា អមតនិព្វាន ។

មុនីតិ មោនំ វុច្ចតិ ញាណំ ។ បេ ។ សង្គជាលមតិច្ចសោ មុនីតិ តណ្ហានិក្ខាតនំ មុនិ ។

[៣៣០] យំ វិទិត្វា សតោ ចរន្តិ យំ វិទិតំ កត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ វិទិតំ កត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា ទុក្ខាតិ សព្វេ ធម្មា អនត្តាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ វិទិតំ កត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ សតោតិ ចតូហាការេហិ សតោ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ វុច្ចតិ សតោ ។ ចរន្តិ ចរន្តោ វិចរន្តោ ឥរិយន្តោ វត្តេន្តោ បាលេន្តោ យបេន្តោ យាបេន្តោតិ យំ វិទិត្វា សតោ ចរំ ។

[៣៣១] តរេ លោកេ វិសត្តិកន្តិ វិសត្តិកា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ វិសត្តិកាតិ កេនដ្ឋេន វិសត្តិកា ។ បេ ។

ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ ។ បេ ។ មុនិនោះ បានកន្លងនូវបណ្តាញ គឺការជាប់ចំពាក់ ហេតុនោះ (លោកពោលថា) បពិត្រព្រះមុនិ...សម្រាប់ដកចេញនូវតណ្ហា ។

[៣៣០] ពាក្យថា ដែលនាំឲ្យបុគ្គលដឹងច្បាស់ មានសតិ ប្រព្រឹត្ត គឺធ្វើឲ្យដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ នូវធម៌ណា គឺធ្វើឲ្យដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួង មិនទៀង ថា សង្ខារទាំងពួង ជាទុក្ខ ថា ធម៌ទាំងពួង ជាអនត្តា ។ បេ ។ ធ្វើឲ្យដឹង ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ ពាក្យថា មានសតិ គឺ មានសតិ ដោយអាការ ៤ គឺ បុគ្គលកំពុងចម្រើនកាយេកាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា អ្នកមានសតិ ។ បេ ។ បុគ្គលនោះ ហៅថា អ្នកមានសតិ ។ ពាក្យថា ប្រព្រឹត្ត គឺប្រព្រឹត្ត ប្រព្រឹត្តផ្សេងៗ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (លោកពោលថា) ដែលនាំឲ្យបុគ្គលដឹងច្បាស់ មានសតិ ប្រព្រឹត្ត ។

[៣៣១] ពាក្យថា ឆ្លងវិសត្តិកាតណ្ហាក្នុងលោក សេចក្តីថា តណ្ហា លោកហៅថា វិសត្តិកា បានខាង តម្រេក តម្រេកដ៏មានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ចុះវិសត្តិកា ដោយអត្ថដូចម្តេច ។ បេ ។

វិសជា វិត្ថតាតិ វិសត្តិកា ។ លោកេតិ អចាយលោកេ មនុស្សលោកេ ទេវលោកេ ខន្ធលោកេ ជាតុលោកេ អាយតនលោកេ ។ តវេ លោកេ វិសត្តិកន្តិ យា សា លោកេ វិសត្តិកា លោកេ តំ វិសត្តិកំ សតោ តវេយ្យ ឧត្តវេយ្យ បតវេយ្យ សមតិក្កមេយ្យ វីតិវត្តេយ្យាតិ តវេ លោកេ វិសត្តិកំ ។ តេនាហ សោ ព្រាហ្មណោ

ត្វញ្ច មេ ជម្មមក្ខាហិ តណ្ហានិគ្ឃាតនំ មុនិ
យំ វិទិត្វា សតោ ចរំ តវេ លោកេ វិសត្តិកន្តិ ។

[៣៣២] ឥជ ទិដ្ឋ សុតមុតំ (វិញ្ញាតេសុ) បិយរូបេសុ
ហេមក ឆន្ទរាគវិនោទនំ និព្វានបទមច្ចុតំ ។

[៣៣៣] ឥជ ទិដ្ឋសុតមុតំ វិញ្ញាតេសូតិ ទិដ្ឋន្តិ ចក្ខុនា ទិដ្ឋំ ។ សុតន្តិ សោតេន សុតំ ។ មុតន្តិ មុតំ ឃានេន ឃាយិតំ ជិវ្ហាយ សាយិតំ កាយេន ផុដ្ឋំ ។

ឈ្មោះវិសត្តិកា ព្រោះហេតុជាធម្មជាតិលាត ផ្សាយទៅ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុ-លោក អាយតនលោក ។ ពាក្យថា ឆ្លងវិសត្តិកាតណ្ហា ក្នុងលោក បានសេចក្តីថា តណ្ហាណា ឈ្មោះវិសត្តិកា ក្នុងលោក បុគ្គលមានសតិគប្បីឆ្លង ឆ្លងឡើង ឆ្លងកាត់ កន្លង ប្រព្រឹត្តកន្លង នូវធម្មជាតិឈ្មោះវិសត្តិកា ក្នុងលោក ហេតុនោះ (លោកពោលថា) ឆ្លងនូវវិសត្តិកា-តណ្ហា ក្នុងលោក ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះមុនិ សូមព្រះអង្គសម្តែងធម៌ សម្រាប់ដកចេញ
នូវតណ្ហា ជាធម៌ដែលនាំឲ្យបុគ្គលដឹងច្បាស់ មានសតិ
ប្រព្រឹត្តឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោក ដល់ខ្ញុំព្រះអង្គ ។

[៣៣២] (ព្រះមានព្រះភាគត្រាស់ថា) ម្នាលហេមកៈ និព្វានបទ
ជាធម្មជាតមិនឃ្លៀងឃ្លាត ជាគ្រឿងបន្ទោបង់ឆន្ទរាគ ក្នុង
អារម្មណ៍ទាំងឡាយ មានសភាពជាទីស្រឡាញ់ ដែល
ឃើញ ឮ ប៉ះពាល់ (ឬដឹងច្បាស់) ក្នុងលោកនេះ ។

[៣៣៣] ពាក្យថា ដែលឃើញ ឮ ប៉ះពាល់ឬដឹងច្បាស់ ក្នុងលោកនេះ ត្រង់ពាក្យថា ដែលឃើញ គឺដែលឃើញដោយភ្នែក ។ ពាក្យថា ឮ គឺឮដោយត្រចៀក ។ ពាក្យថា ប៉ះពាល់ គឺ ប៉ះពាល់ គឺ ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សដោយអណ្តាត ប៉ះពាល់ដោយកាយ ។

២៦៩

ហេមកមាណវកប្បញ្ហានិទ្ទេសោ

វិញ្ញាតន្តិ មនសា ញាតន្តិ ឥទ ចិដ្ឋសុតមុតំ វិញ្ញា-តេសុ ។

[៣៣៤] បិយរូបេសុ ហេមកាតិ កិញ្ច លោកេ បិយរូបំ សាតរូបំ ។ ចក្ខុំ លោកេ បិយរូបំ សា-តរូបំ សោតំ ឃានំ ជិវ្ហា កាយោ មនោ លោ-កេ បិយរូបំ សាតរូបំ រូបំ លោកេ បិយរូបំ សា-តរូបំ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា លោកេ បិយរូបំ សាតរូបំ ចក្ខុវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោវិញ្ញាណំ លោកេ បិយ-រូបំ សាតរូបំ ចក្ខុសម្ផស្សោ លោកេ បិយរូបំ សាតរូបំ សោតសម្ផស្សោ ឃានសម្ផស្សោ ជិវ្ហាសម្ផ-ស្សោ កាយសម្ផស្សោ មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ ចក្ខុសម្ផស្សជា វេទនា លោកេ

ពាក្យថា ដឹងច្បាស់ គឺដឹងដោយចិត្ត ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលឃើញ ឮ ប៉ះពាល់ ឬដឹងច្បាស់ ក្នុងលោកនេះ ។

[៣៣៤] អធិប្បាយពាក្យថា ម្នាលហេមកៈ... ក្នុងអារម្មណ៍ទាំងឡាយ មានសភាពជាទីស្រឡាញ់ សំណួរថា អារម្មណ៍ដូចម្តេច មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ។ ចក្ខុ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សោតៈ ឃានៈ ជិវ្ហា កាយ ចិត្ត មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក រូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ ធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ចក្ខុវិញ្ញាណ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ចក្ខុសម្ផស្ស មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស មានសភាពជាទីស្រឡាញ់ មានសភាព ជាទីត្រេកអរ ក្នុងលោក វេទនា កើតអំពីចក្ខុសម្ផស្ស

២៧០



បិយរូបំ សាតរូបំ សោតសម្ផស្សជា វេទនា ឃានសម្ផស្សជា វេទនា ជិវ្ហាសម្ផស្សជា វេទនា កាយសម្ផស្សជា វេទនា មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា លោកេ បិយរូបំ សាតរូបំ រូបសញ្ចេតនា លោកេ បិយរូបំ សាតរូបំ សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ រូបតណ្ហា លោកេ បិយរូបំ សាតរូបំ សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ រូបវិតក្កោ លោកេ បិយរូបំ សាតរូបំ សទ្ទវិតក្កោ គន្ធវិតក្កោ រសវិតក្កោ ផោដ្ឋព្វវិតក្កោ ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ រូបវិចារោ លោកេ

មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក វេទនាកើតអំពីសោតសម្ផស្ស វេទនាកើតអំពីឃានសម្ផស្ស វេទនាកើតអំពីជិវ្ហាសម្ផស្ស វេទនាកើតអំពីកាយសម្ផស្ស វេទនាកើតអំពីមនោសម្ផស្ស មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីសម្គាល់ក្នុងរូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីសម្គាល់ក្នុងសំឡេង សេចក្តីសម្គាល់ក្នុងក្លិន សេចក្តីសម្គាល់ក្នុងរស សេចក្តីសម្គាល់ក្នុងផ្សព្វ សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ការគិតរូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ការគិតសំឡេង ការគិតក្លិន ការគិតរស ការគិតផ្សព្វ ការគិតធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីប្រាថ្នារូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីប្រាថ្នាសំឡេង សេចក្តីប្រាថ្នាក្លិន សេចក្តីប្រាថ្នារស សេចក្តីប្រាថ្នាផ្សព្វ សេចក្តីប្រាថ្នាក្នុងធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីត្រិះរិះរូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក សេចក្តីត្រិះរិះសំឡេង សេចក្តីត្រិះរិះក្លិន សេចក្តីត្រិះរិះរស សេចក្តីត្រិះរិះផ្សព្វ សេចក្តីត្រិះរិះធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក

បិយរូបំ សាតរូបំ សទ្ទវិចារោ គន្ធវិចារោ រសវិចារោ ផោដ្ឋព្វវិចារោ ធម្មវិចារោ លោកេ បិយរូបំ សាតរូបន្តិ បិយរូបេសុ ។ ហេមកាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។

[៣៣៥] ឆន្ទរាគវិនោទនន្តិ ឆន្ទរាគោតិ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទី កាមតណ្ហា កាមសិនេហោ កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ កាមោឃោ កាមយោគោ កាមុបាទានំ កាមច្ឆន្ទនីវរណំ ។ ឆន្ទរាគវិនោទនន្តិ ឆន្ទរាគប្បហានំ ឆន្ទរាគវូបសមំ ឆន្ទរាគប្បដិនិស្សគ្គំ ឆន្ទរាគប្បដិប្បស្សទ្ធឹ អមតំ និព្វានន្តិ ឆន្ទរាគវិនោទនំ ។

[៣៣៦] និព្វានបទមច្ចុតន្តិ និព្វានបទំ តាណបទំ លេណបទំ បរាយនបទំ[១] អភយបទំ ។

១ ម. សរណបទំ ។

ការពិចារណារូប មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ការពិចារណាសំឡេង ការពិចារណាក្លិន ការពិចារ-ណារស ការពិចារណាផ្សព្វ ការពិចារណាធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ មានសភាពជាទីត្រេកអរ ក្នុងលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ក្នុងអារម្មណ៍ មានសភាពជាទីស្រឡាញ់ ។ ពាក្យថា ម្នាលហេមកៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះ តាមឈ្មោះ ។

[៣៣៥] ពាក្យថា ជាគ្រឿងបន្ទោបង់ឆន្ទរាគ ត្រង់ពាក្យថា ឆន្ទ-រាគ បានខាងកាមច្ឆន្ទៈ ក្នុងកាមទាំងឡាយ តម្រេកក្នុងកាម សេចក្តីរីករាយក្នុងកាម សេចក្តីប្រាថ្នាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីក្តៅក្រហាយក្នុងកាម ការជ្រប់ចុះក្នុងកាម ការវង្វេងក្នុងកាម អន្ទង់គឺកាម ធម៌ជាគ្រឿងប្រកបគឺកាម សេចក្តីប្រកាន់គឺកាម នីវរណៈគឺកាមច្ឆន្ទ ។ ពាក្យថា ជាគ្រឿងបន្ទោបង់ឆន្ទរាគ បានន័យថា គ្រឿងលះបង់ឆន្ទរាគ រម្ងាប់ឆន្ទរាគ រលាស់ចោលឆន្ទរាគ គ្របសង្កត់ឆន្ទរាគ អមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ជាគ្រឿងបន្ទោបង់ឆន្ទរាគ ។

[៣៣៦] ពាក្យថា និព្វានបទ ជាធម្មជាត មិនឃ្លៀងឃ្លាត សេចក្តីថា បទ គឺ និព្វាន បទ គឺ ទីពឹង បទ គឺ ទីជ្រក បទ គឺ ធម៌ជាគ្រឿងប្រព្រឹត្តទៅខាងមុខ បទ គឺ ទីមិនមានភ័យ ។

អច្ចុតន្តិ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មន្តិ និព្វា-
នបទមច្ចុតំ ។ តេនាហ ភគវា

ឥធ ទិដ្ឋសុតមុតំ (វិញ្ញាតេសុ) បិយរូបេសុ ហេមក
ឆន្ទរាគវិនោទនំ និព្វានបទមច្ចុតន្តិ ។

[៣៣៧] ឯតទញ្ញាយ យេ សតា ទិដ្ឋធម្មាភិនិព្វុតា
ឧបសន្តា ច តេ សទា តិណ្ណា លោកេ វិសត្តិកំ ។

[៣៣៨] ឯតទញ្ញាយ យេ សតាតិ ឯតន្តិ អមតំ
និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិ-
និស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។
អញ្ញាយាតិ អញ្ញាយ ជានិត្វា តុលយិត្វា តិរយិត្វា វិភា-
វយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ អញ្ញាយ
ជានិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា
សព្វេ សង្ខារា ទុក្ខាតិ សព្វេ ធម្មា អនត្តាតិ ។ បេ ។

ពាក្យថា មិនឃៀងឃ្លាត គឺទៀងទាត់ ឋិតថេរ ខ្ជាប់ខ្ជួន មិនប្រែប្រួលជាធម្មតា ហេតុនោះ (ទ្រង់ត្រាស់ថា) និព្វានបទ ជាធម្មជាត មិនឃៀងឃ្លាត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ម្នាលហេមកៈ និព្វានបទ ជាធម្មជាត មិនឃៀងឃ្លាត ជាគ្រឿងបន្ទោបង់ឆន្ទរាគ ក្នុងអារម្មណ៍ មានសភាពគួរស្រឡាញ់ ដែលឃើញ ឮ ប៉ះពាល់ (ឬដឹងច្បាស់) ក្នុងលោកនេះ ។

[៣៣៧] ជនទាំងឡាយ ណា ដឹងនិព្វានន៉ុះ ជាអ្នកមានសតិ មានធម៌ឃើញហើយ រលត់កិលេសហើយ ជនទាំងនោះ ជាអ្នកស្ងប់រម្ងាប់ សព្វកាល ឈ្មោះថាឆ្លង នូវវិសត្តិកាតណ្ហា ក្នុងលោកបាន ។

[៣៣៨] អធិប្បាយពាក្យថា ជនទាំងឡាយណា ដឹងនិព្វានន៉ុះ ជាអ្នកមានសតិ ត្រង់ពាក្យថា និព្វានន៉ុះ គឺអមតនិព្វាន បានខាងការរម្ងាប់សង្ខារ ទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរំលត់ទុក្ខ និព្វាន ។ ពាក្យថា ដឹង គឺ ដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ គឺ ដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួង មិនទៀង ដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងពួង ជាទុក្ខ ថា ធម៌ទាំងពួងជាអនត្តា ។ បេ ។

យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ អញ្ញាយ ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ យេតិ អរហន្តោ ខីណាសវា ។ សតាតិ ចតូហិ ការណេហិ សតា កាយេ កាយានុបស្សនាសតិបដ្ឋានំ ភាវេន្តា សតា ។ បេ ។ តេ វុច្ចន្តិ សតាតិ ឯតទញ្ញាយ យេ សតា ។

[៣៣៩] ទិដ្ឋធម្មាភិនិព្វុតាតិ ទិដ្ឋធម្មា ញាតធម្មា តុលិតធម្មា តីរិតធម្មា វិភាវិតធម្មា វិភូតធម្មា សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ទិដ្ឋធម្មា ញាតធម្មា តុលិតធម្មា តីរិតធម្មា វិភាវិតធម្មា វិភូតធម្មា ។ អភិនិព្វុតាតិ រាគស្ស និព្វាបិតត្តា អភិនិព្វុតា ទោសស្ស និព្វាបិតត្តា អភិនិព្វុតា មោហស្ស និព្វាបិតត្តា អភិនិព្វុតា កោធស្ស ឧបនាហស្ស ។ បេ ។ សព្វាកុសលាភិសង្ខារានំ និព្វាបិតត្តា អភិនិព្វុតាតិ ទិដ្ឋធម្មាភិនិព្វុតា ។

ថារបស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅជាធម្មតា ។ ពាក្យថា ជនទាំងឡាយណា បានដល់ពួកព្រះអរហន្តខីណាស្រព ។ ពាក្យថា ជាអ្នកមានសតិ គឺមានសតិ ដោយហេតុ ៤ គឺ បុគ្គលកំពុងចម្រើនកាយេកាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថា អ្នកមានសតិ ។ បេ ។ បុគ្គលទាំងនោះ លោកហៅថា អ្នកមានសតិ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងឡាយណា ដឹងនិព្វានន៎ុះ ជាអ្នកមានសតិ ។

[៣៣៩] ពាក្យថា មានធម៌ឃើញហើយ រំលត់កិលេសហើយ គឺមានធម៌ឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ត្រិះរិះហើយ មានធម៌ជាក់ច្បាស់ហើយ មានធម៌ប្រាកដហើយ ថាសង្ខារទាំងពួងមិនទៀង ។ បេ ។ មានធម៌ឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ត្រិះរិះហើយ មានធម៌ជាក់ច្បាស់ហើយ មានធម៌ប្រាកដហើយថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅជាធម្មតា ។ ពាក្យថា រលត់ហើយ គឺឈ្មោះថារលត់ហើយ ព្រោះរំលត់រាគៈ រលត់ហើយព្រោះរំលត់ទោសៈ រលត់ហើយ ព្រោះរំលត់មោហៈ កោធៈ ឧបនាហៈ ។ បេ ។ រលត់ហើយ ព្រោះរលត់អកុសលាភិសង្ខារទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) មានធម៌ឃើញហើយ រលត់កិលេសហើយ ។

[៣៤០] ឧបសន្តា ច តេ សទាតិ ឧបសន្តាតិ រាគស្ស សន្តត្តា[១] ឧបសន្តា ទោសស្ស សន្តត្តា ឧបសន្តា មោហស្ស សន្តត្តា ឧបសន្តា កោធស្ស ឧបនាហស្ស ។ បេ ។ សព្វាកុសលាភិសង្ខារានំ សន្តត្តា សមិតត្តា វិជ្ឈាតត្តា[២] និព្វុតត្តា វិគតត្តា បដិប្បស្សទ្ធត្តា សន្តា ឧបសន្តា វូបសន្តា និព្វុតា បដិប្បស្សទ្ធាតិ ឧបសន្តា ។ តេតិ អរហន្តោ ខីណាសវា ។ សទាតិ សទា សព្វទា សព្វកាលំ និច្ចកាលំ ធុវកាលំ សតតំ សមិតំ អព្វោកិណ្ណំ បោខានុបោខំ ឧទកុម្មិជាតំ[៣] អវីចិ សន្តតិ សហិតំ ផុសិតំ បុរេភត្តំ បច្ឆាភត្តំ បុរិមយាមេ មជ្ឈិមយាមេ បច្ឆិមយាមេ កាឡេ ជុណ្ហេ វស្សេ ហេមន្តេ គិម្ហេ បុរិមេ វយោខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេតិ ឧបសន្តា ច តេ សទា ។

---
១ ម. ឧបសមិតត្តា និព្វាបិតត្តា។ ២ ម. វូបសមិតត្តា និជ្ឈាតត្តា ។ ៣ ម. ឧទកុម្មិកជាតំ ។

[៣៤០] ពាក្យថា ជនទាំងនោះ ជាអ្នកស្ងប់រម្ងាប់ សព្វកាល ត្រង់ពាក្យថា ជាអ្នកស្ងប់រម្ងាប់ គឺស្ងប់រម្ងាប់ ព្រោះស្ងប់រាគៈ ស្ងប់រម្ងាប់ ព្រោះស្ងប់ទោសៈ ស្ងប់រម្ងាប់ ព្រោះស្ងប់មោហៈ កោធៈ ឧបនាហៈ ។ បេ ។ ជាអ្នកស្ងប់ រម្ងាប់ ចូលទៅរម្ងាប់ រំលត់ ស្ងប់រម្ងាប់ ព្រោះស្ងប់រម្ងាប់ ដុត រលត់ ទៅប្រាស គ្រប់សង្កត់ នូវអកុសលាភិសង្ខារទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកស្ងប់រម្ងាប់ ។ ពាក្យថា ជនទាំងនោះ បានដល់ពួកព្រះអរហន្តខីណាស្រព ។ ពាក្យថា សព្វកាល គឺសព្វកាល គ្រប់កាល អស់កាលទាំងពួង អស់កាលជានិច្ច អស់កាលដ៏ទៀងទាត់ អស់កាលមិនដាច់ អស់កាលរឿយៗ មិនប្រឡូកប្រឡំ ថែមហើយថែមទៀត ជាប់តគ្នា មិនមានចន្លោះដូចរលកទឹក បន្តគ្នា ប៉ះពាល់គ្នា អស់បុរេភត្ត បច្ឆាភត្ត បឋមយាម មជ្ឈិមយាម បច្ឆិមយាម កាឡបក្ខ សុក្កបក្ខ វស្សានរដូវ ហេមន្តរដូវ គិម្ហរដូវ ចំណែកបឋមវ័យ ចំណែកមជ្ឈិមវ័យ ចំណែកបច្ឆិមវ័យ ហេតុនោះ (ទ្រង់ត្រាស់ថា) ជនទាំងឡាយនោះ ជាអ្នកស្ងប់រម្ងាប់ សព្វកាល ។

២៧៨

## ហេមកមាណវកប្បញ្ហានិទ្ទេសោ

[៣៤១] តិណ្ណា លោកេ វិសត្តិកន្តិ វិសត្តិកា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ វិសត្តិកាតិ កេនដ្ឋេន វិសត្តិកា ។ បេ ។ វិសដា វិត្ថតាតិ វិសត្តិកា ។ លោកេតិ អបាយលោកេ ។ បេ ។ អាយតនលោកេ ។ តិណ្ណា លោកេ វិសត្តិកន្តិ យា សា លោកេ វិសត្តិកា លោកេ តំ វិសត្តិកំ តិណ្ណា ឧត្តិណ្ណា និត្តិណ្ណា អតិក្កន្តា សមតិក្កន្តា វីតិវត្តាតិ តិណ្ណា លោកេ វិសត្តិកំ ។ តេនាហ ភគវា

ឯតទញ្ញាយ យេ សតា ទិដ្ឋធម្មាភិនិព្វុតា
ឧបសន្តា ច តេ សទា តិណ្ណា លោកេ វិសត្តិកន្តិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ហេមកមាណវកប្បញ្ហានិទ្ទេសោ អដ្ឋមោ ។

## ហេមកមាណវកប្បញ្ញានិទ្ទេស

[៣៤១] ពាក្យថា ឈ្មោះថាឆ្លង នូវវិសត្តិកាតណ្ហា ក្នុងលោក សេចក្ដីថា តណ្ហា លោកហៅថា វិសត្តិកា បានខាង តម្រេក តម្រេកដ៏មានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សំណួរត្រង់ពាក្យថា វិសត្តិកា ចុះវិសត្តិកា ដោយអត្ថដូចម្ដេច ។ បេ ។ ឈ្មោះវិសត្តិកា ព្រោះហេតុជាធម្មជាតិលាត ផ្សាយទៅ ។ ពាក្យថាក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ អាយតនលោក ។ ពាក្យថា ឈ្មោះថាឆ្លង នូវវិសត្តិកាតណ្ហា ក្នុងលោក គឺតណ្ហាណា ឈ្មោះវិសត្តិកា ក្នុងលោក ជនទាំងឡាយ បានឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លង រំលង ប្រព្រឹត្តកន្លង នូវតណ្ហាឈ្មោះវិសត្តិកានោះ ក្នុងលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ឆ្លងនូវវិសត្តិកាតណ្ហា ក្នុងលោក ។ ហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា

ជនទាំងឡាយណា ដឹងនិព្វានទុំះ ជាអ្នកមានសតិ មានធម៌
ឃើញហើយ រលត់កិលេសហើយ ជនទាំងនោះ ជាអ្នក
ស្ងប់រម្ងាប់ សព្វកាល ឈ្មោះថា ឆ្លងនូវវិសត្តិកាតណ្ហា ក្នុង
លោកបាន ។

លុះចប់គាថាហើយ ។ បេ ។ (ហេមកមាណពប្រកាសខ្លួនថា) បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្ដារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ ហេមកមាណវកប្បញ្ញានិទ្ទេស ទី ៨ ។

# តោទេយ្យមាណវកប្បញ្ហានិទ្ទេសោ

[៣៨២] យស្មឹ កាមា ន វសន្តិ
(ឥច្ចាយស្មា តោទេយ្យោ)
តណ្ហា យស្ស ន វិជ្ជតិ
កថង្កថា ច យោ តិណ្ណោ
វិមោក្ខោ តស្ស កីទិសោ ។

[៣៨៣] យស្មឹ កាមា ន វសន្តីតិ យស្មឹ កាមា ន វសន្តិ ន សំវសន្តិ ន អាវសន្តិ[១] ។ ឥច្ចាយស្មា តោទេយ្យោតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ បទានុបុព្វកាមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។ តោទេយ្យោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាចោតិ ឥច្ចាយស្មា តោទេយ្យោ ។

[៣៨៤] តណ្ហា យស្ស ន វិជ្ជតីតិ តណ្ហា យស្ស នត្ថិ[២] ន សំវិជ្ជតិ នុបលព្ភតិ បហីនា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា[៣] ញាណគ្គិនា ទឌ្ឍាតិ តណ្ហា យស្ស ន វិជ្ជតិ ។

---

១ ម. ឯត្ថន្តរេ ន បរិវសន្តីតិ យស្មឹ កាមា ន វសន្តីតិ ទិស្សតិ ។ ២ ម. ឯត្ថន្តរេ ន សន្តីតិ ទិស្សតិ ។ ៣ បហីនា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកាតិ ន ទិស្សន្តិ ។

# តោទេយ្យមាណវកបញ្ហានិទ្ទេស

[៣៤២] (*តោទេយ្យ មានអាយុ ទូលសួរដូច្នេះថា*) *កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណា មិនមាន មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបានហើយ វិមោក្ខធម៌ របស់បុគ្គលនោះ តើដូចម្តេចទៅ ។*

[៣៤៣] *ពាក្យថា កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា គឺកាមទាំងឡាយ មិនមាននៅ មិននៅព្រម មិននៅទូទៅក្នុងបុគ្គលណា ។ ពាក្យថា ដូច្នេះ របស់បទថា តោទេយ្យ មានអាយុ ពោលដូច្នេះ ជាតំណបទ ។ បេ ។ ពាក្យថា ដូច្នេះ នេះ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យថា ជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នេះជាពាក្យពោល ដោយសេចក្តីគោរព កោតខ្លាច ។ ពាក្យថា តោទេយ្យ ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។ បេ ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ* (មានពាក្យថា) *តោទេយ្យ មានអាយុ ទូលសួរដូច្នេះ ។*

[៣៤៤] *ពាក្យថា តណ្ហា របស់បុគ្គលណា មិនមាន គឺតណ្ហា នៃបុគ្គលណា មិនមាន មិនមានព្រម មិនកើតមាន គឺបុគ្គលណា លះបង់ រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ* (*លោកពោលថា*) *តណ្ហារបស់បុគ្គលណា មិនមាន ។*

២៧៧

## តោទេយ្យមាណវកប្បញ្ហានិទ្ទេសោ

[៣៤៥] កថង្កថា ច យោ តិណ្ណោតិ កថង្កថា ច យោ តិណ្ណោ ឧត្តិណ្ណោ និត្តិណ្ណោ អតិក្កន្តោ សមតិក្កន្តោ វីតិវត្តោតិ កថង្កថា ច យោ តិណ្ណោ ។

[៣៤៦] វិមោក្ខោ តស្ស កីទិសោតិ វិមោក្ខោ តស្ស កីទិសោ កឹសណ្ឋិតោ កឹបការោ កឹបដិភាគោ ឥច្ឆិតព្វោតិ វិមោក្ខំ បុច្ឆតីតិ វិមោក្ខោ តស្ស កីទិសោ ។ តេនាហ សោ ព្រាហ្មណោ

យស្មឹ កាមា ន វសន្តិ
(ឥច្ចាយស្មា តោទេយ្យោ)
តណ្ហា យស្ស ន វិជ្ជតិ
កថង្កថា ច យោ តិណ្ណោ
វិមោក្ខោ តស្ស កីទិសោតិ ។

[៣៤៧] យស្មឹ កាមា ន វសន្តិ
(តោទេយ្យាតិ ភគវា)
តណ្ហា យស្ស ន វិជ្ជតិ
កថង្កថា ច យោ តិណ្ណោ
វិមោក្ខោ តស្ស នាបរោ ។

តោទេយ្យមាណវកប្បញ្ហានិទ្ទេស

[៣៤៥] ពាក្យថា មួយទៀត បុគ្គលណា ឆ្លងសេចក្ដីសង្ស័យបាន គឺ មួយទៀត បុគ្គលណា ឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លង រំលង ប្រព្រឹត្តកន្លង សេចក្ដីសង្ស័យបាន ហេតុនោះ (លោកពោលថា) មួយទៀត បុគ្គលណា ឆ្លងសេចក្ដីសង្ស័យបានហើយ ។

[៣៤៦] ពាក្យថា វិមោក្ខធម៌ របស់បុគ្គលនោះ តើដូចម្ដេច គឺ តោទេយ្យមាណពសួរវិមោក្ខធម៌ថា វិមោក្ខធម៌របស់បុគ្គលនោះ ដូចម្ដេចទៅ តាំងនៅដូចម្ដេច មានប្រការដូចម្ដេច មានចំណែកប្រៀបដូចម្ដេច ដែលបុគ្គលគប្បីប្រាថ្នា ហេតុនោះ (លោកពោលថា) វិមោក្ខធម៌ របស់បុគ្គលនោះ តើដូចម្ដេចទៅ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

(តោទេយ្យ មានអាយុ ទូលសួរដូច្នេះថា) កាមទាំងឡាយ
មិនមាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណា មិនមាន
មួយទៀត បុគ្គលណា ឆ្លងសេចក្ដីសង្ស័យ បានហើយ
វិមោក្ខធម៌ របស់បុគ្គលនោះ តើដូចម្ដេចទៅ ។

[៣៤៧] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលតោទេយ្យ) កាម
ទាំងឡាយ មិនមាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គល
ណាមិនមាន មួយទៀត បុគ្គលណាឆ្លងសេចក្ដីសង្ស័យបាន
ហើយ វិមោក្ខធម៌របស់បុគ្គលនោះ មិនមែនទៅជាដទៃទេ ។

[៣៤៨] យស្មឹ កាមា ន វសន្តីតិ យស្មិន្តិ អរហន្តេ ខីណាសវេ ។ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ ន វសន្តីតិ យស្មឹ កាមា ន វសន្តិ ន សំវសន្តិ ន អាវសន្តីតិ យស្មឹ កាមា ន វសន្តិ ។ តោទេយ្យាតិ ភគវាតិ តោទេយ្យាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ តោទេយ្យាតិ ភគវា ។

[៣៤៩] តណ្ហា យស្ស ន វិជ្ជតីតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ យស្សាតិ អរហតោ ខីណាសវស្ស ។ តណ្ហា យស្ស ន វិជ្ជតីតិ តណ្ហា យស្ស នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ តណ្ហា យស្ស ន វិជ្ជតិ ។

[៣៤៨] ពាក្យថា កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា ត្រង់ពាក្យថា ក្នុងបុគ្គលណា គឺក្នុងព្រះអរហន្តខីណាស្រព ។ ពាក្យថា កាមទាំងឡាយ តាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ នេះ វត្ថុកាម ។ បេ ។ នេះ កិលេសកាម ។ ពាក្យថា មិនមាននៅ គឺកាមទាំងឡាយ មិននៅ មិននៅព្រម មិននៅទូទៅ ក្នុងបុគ្គលណា ហេតុនោះ (ទ្រង់ត្រាស់ថា) កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា ។ ពាក្យថា តោទេយ្យ របស់បទថា ព្រះមានព្រះភាគ ត្រាស់ថា ម្នាលតោទេយ្យ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះ តាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នេះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលតោទេយ្យ ។

[៣៤៩] ពាក្យថា តណ្ហា របស់បុគ្គលណា មិនមាន ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា របស់បុគ្គលណា គឺរបស់ព្រះអរហន្តខីណាស្រព ។ ពាក្យថា តណ្ហា របស់បុគ្គលណាមិនមាន គឺតណ្ហា នៃបុគ្គលណាមិនមាន មិនមានព្រម មិនកើតមាន គឺបុគ្គលណា លះបង់ រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) តណ្ហា របស់បុគ្គលណា មិនមាន ។

## ២៧៩

### តោទេយ្យមាណវកប្បញ្ហានិទ្ទេសោ

[៣៩០] កាមេសុ ច យោ តិណ្ណោតិ កាមេសុ- ជា វុច្ចតិ វិចិកិច្ឆា ទុក្ខេ កង្ខា ។ បេ ។ ធម្មិតត្ថំ ចិត្តស្ស មនោវិលេខោ ។ យោតិ យោ សោ ខី- ណាសវោ ។ កាមេសុ ច យោ តិណ្ណោតិ កាមេសុ ច យោ តិណ្ណោ ឧត្តិណ្ណោ និត្តិណ្ណោ អតិក្កន្តោ ស- មតិក្កន្តោ វីតិវត្តោតិ កាមេសុ ច យោ តិណ្ណោ ។

[៣៩១] វិមោក្ខោ តស្ស នាបរោតិ នត្ថិ តស្ស អបរោ វិមោក្ខោ យេន វិមោក្ខេន វិមុច្ចេយ្យ[១] កាមំ តស្ស វិមោក្ខេន ករណីយន្តិ វិមោក្ខោ តស្ស នា- បរោ ។ តេនាហ ភគវា

យស្មឹ កាមា ន វសន្តិ (តោទេយ្យាតិ ភគវា)
តណ្ហា យស្ស ន វិជ្ជតិ
កាមេសុ ច យោ តិណ្ណោ
វិមោក្ខោ តស្ស នាបរោតិ ។

---

១ ម. ឯត្តន្តរេ វិមុត្តោ សោតិ ទិស្សតិ ។

តោទេយ្យមាណវកបញ្ហានិទ្ទេស

[៣៥០] ពាក្យថា មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន សេចក្តីថា វិចិកិច្ឆា លោកហៅថា សេចក្តីសង្ស័យ គឺសេចក្តីងឿងឆ្ងល់ ក្នុងទុក្ខ ។ បេ ។ ភាពនៃចិត្តញាប់ញ័រ ការស្ទាកស្ទាមនៃចិត្ត ។ ពាក្យថា ណា គឺព្រះខីណាស្រពណា ។ ពាក្យថា មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន បានន័យថា មួយទៀត បុគ្គលណា ឆ្លង ឆ្លងឡើង ឆ្លងចេញ កន្លង រំលង ប្រព្រឹត្តកន្លងនូវសេចក្តីសង្ស័យ ហេតុនោះ (ទ្រង់ត្រាស់ថា) មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន ។

[៣៥១] ពាក្យថា វិមោក្ខធម៌របស់បុគ្គលនោះ មិនមែនទៅជាដទៃទេ គឺវិមោក្ខធម៌ដទៃ របស់បុគ្គលនោះ មិនមាន បុគ្គលគប្បីរួចដោយវិមោក្ខណា កិច្ចដែលបុគ្គលនោះ គប្បីធ្វើដោយវិមោក្ខនោះ ដូចម្តេចកើត ហេតុនោះ (ទ្រង់ត្រាស់ថា) វិមោក្ខធម៌របស់បុគ្គលនោះ មិនមែនទៅជាដទៃទេ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

(ព្រះមានព្រះភាគ ត្រាស់ថា ម្នាលតោទេយ្យ) កាមទាំងឡាយ មិនមាននៅក្នុងបុគ្គលណា តណ្ហា របស់បុគ្គលណា មិនមាន មួយទៀត បុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន វិមោក្ខធម៌ របស់បុគ្គលនោះ មិនមែនទៅជាដទៃទេ ។

[៣៨២] និរាសសោ សោ ឧទ អាសសានោ
បញ្ញាណវា សោ ឧទ បញ្ញកប្បី
មុនឹ អហំ សក្ក យថា វិជញ្ញំ
តម្មេ វិយាចិក្ខ សមន្តចក្ខុ ។

[៣៨៣] និរាសសោ សោ ឧទ អាសសានោតិ និត្តណ្ហោ សោ ឧទាហុ សតណ្ហោ រូបំ អាសីសតិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលំ គណំ អាវាសំ លាភំ យសំ បសំសំ សុខំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ កាមធាតុំ រូបធាតុំ អរូបធាតុំ កាមភវំ រូបភវំ អរូបភវំ សញ្ញាភវំ អសញ្ញាភវំ នេវសញ្ញានាសញ្ញាភវំ ឯកវោការភវំ ចតុវោការភវំ បញ្ចវោការភវំ អតីតំ អនាគតំ បច្ចុប្បន្នំ[១] ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ អាសីសតិ ឥច្ឆតិ សាទិយតិ បត្ថេតិ បិហេតិ អភិជប្បតីតិ និរាសសោ សោ ឧទ អាសសានោ ។

---

១ ម. កុលេ គណេ ។ បេ ។ អតីតេ អនាគតេ បច្ចុប្បន្នេ ។

[៣៩២] (តោទេយ្យព្រាហ្មណ៍ទូលសួរថា) បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នាទេ ឬនៅមាន សេចក្តីប្រាថ្នា បុគ្គលនោះ មានបញ្ញា ឬមានការកំណត់ដោយបញ្ញា បពិត្រព្រះសក្កៈ ខ្ញុំព្រះអង្គគប្បីស្គាល់នូវមុនិណា បពិត្រព្រះអង្គជាសមន្តចក្ខុ សូមព្រះអង្គត្រាស់ប្រាប់មុនិនោះ ដល់ខ្ញុំព្រះអង្គ ។

[៣៩៣] ពាក្យថា បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នាទេ ឬនៅមានសេចក្តីប្រាថ្នា គឺបុគ្គលនោះ មិនមានតណ្ហាទេ ឬប្រកបដោយតណ្ហា គឺប៉ង់នូវរូប នឹកប៉ង់ ចង់បាន ត្រេកអរ ប្រាថ្នា ស្រឡាញ់ជាប់ចិត្ត នូវសំឡេង ក្លិន រស ផ្សព្វ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ និង គិលានប្បច្ច័យភេសជ្ជបរិក្ខារ កាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព អតីត អនាគត បច្ចុប្បន្ន អារម្មណ៍ដែលឃើញ ឮ ប៉ះពាល់ ឬដឹងច្បាស់ ហេតុនោះ (លោកសួរថា) បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នាទេ ឬនៅមានសេចក្តីប្រាថ្នា ។

២៨១

## តោទេយ្យមាណវកប្បញ្ហានិទ្ទេសោ

[៣៨៤] បញ្ញាណវា សោ ឥធ បញ្ញកប្បីតិ បញ្ញាណវា សោតិ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី ។ ឥធ បញ្ញកប្បីតិ ឥធាហុ អដ្ឋសមាបត្តិញ្ញាណេន វា បញ្ចាភិញ្ញាញាណេន វា មិច្ឆាញាណេន វា តណ្ហាកប្បំ វា ទិដ្ឋិកប្បំ វា កប្បេតិ ជនេតិ សញ្ជនេតិ និព្វត្តេតិ អភិនិព្វត្តេតីតិ បញ្ញាណវា សោ ឥធ បញ្ញកប្បី ។

[៣៨៥] មុនី អហំ សក្ក យថា វិជញ្ញន្តិ សក្កាតិ សក្កោ ។ អថវា សក្យកុលា បព្វជិតោតិបិ សក្កោ ។ អថវា អឌ្ឍោ មហទ្ធនោ ធនវាតិបិ សក្កោ ។ តស្សិមានិ ធនានិ សេយ្យថីទំ សទ្ធាធនំ សីលធនំ ហិរិធនំ ឱត្តប្បធនំ សុតធនំ ចាគធនំ បញ្ញាធនំ សតិប្បដ្ឋានធនំ សម្មប្បធានធនំ ឥទ្ធិបាទធនំ ឥន្ទ្រិយធនំ ពលធនំ ពោជ្ឈង្គធនំ មគ្គធនំ ផលធនំ និព្វានធនំ ។

តោទេយ្យមាណវកប្បញ្ហានិទ្ទេស

[៣៥៤] ពាក្យថា បុគ្គលនោះមានបញ្ញា ឬមានការកំណត់ដឹងដោយបញ្ញា ត្រង់ពាក្យថា បុគ្គលនោះមានបញ្ញា គឺបុគ្គលនោះ ជាបណ្ឌិត មានប្រាជ្ញា មានប្រាជ្ញាជាគ្រឿងត្រាស់ដឹង មានញាណ មានប្រាជ្ញាភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ។ ពាក្យថា ឬមានការកំណត់ ដោយបញ្ញា គឺ កំណត់ បង្កើត បង្កើតព្រម បង្កើតបង្កើតចំពោះ នូវតណ្ហាកប្បៈ ឬទិដ្ឋិកប្បៈ ដោយញាណដែលប្រកបដោយសមាបត្តិ ៨ ក្តី ដោយញាណ ដែលប្រកបដោយអភិញ្ញា ៥ ក្តី ដោយមិច្ឆាញាណក្តី ហេតុនោះ (លោកសួរថា) បុគ្គលនោះ មានបញ្ញា ឬមានការកំណត់ដោយបញ្ញា ។

[៣៥៥] ពាក្យថា បពិត្រព្រះសក្កៈ ខ្ញុំព្រះអង្គ គប្បីស្គាល់នូវមុនិណា ត្រង់ពាក្យថា ព្រះសក្កៈ បានដល់ព្រះមានព្រះភាគជាសក្កៈ ។ម្យ៉ាងទៀត ព្រះនាមថា សក្កៈ ព្រោះហេតុទ្រង់ចេញចាកសាក្យត្រកូលមកបួស ក៏បាន ។ ឬថា ព្រះនាមថាសក្កៈ ព្រោះទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យ ក៏បាន ។ ទ្រព្យទាំងនេះ របស់ព្រះមានព្រះភាគនោះគឺ ទ្រព្យគឺសទ្ធា ទ្រព្យគឺសីល ទ្រព្យគឺហិរិ ទ្រព្យគឺឱត្តប្បៈ ទ្រព្យគឺសុតៈ ទ្រព្យគឺចាគៈ ទ្រព្យគឺបញ្ញា ទ្រព្យគឺសតិប្បដ្ឋាន ទ្រព្យគឺសម្មប្បធាន ទ្រព្យគឺឥទ្ធិបាទ ទ្រព្យគឺឥន្ទ្រិយ ទ្រព្យគឺពលៈ ទ្រព្យគឺពោជ្ឈង្គ ទ្រព្យគឺមគ្គ ទ្រព្យគឺផល ទ្រព្យគឺនិព្វាន ។

តេហិ អនេកវិធេហិ ជនវតនេហិ អឌ្ឍោ មហទ្ធនោ ជនភាតិបិ សង្ខោ ។ អថវា បហុ វិសវី អល-មត្តោ សូរោ វីរោ វិក្កន្តោ អភិរុ អច្ឆម្ភី អនុត្រាសី អបលាយិ បហីនភយភេរវោ វិគតលោមហំសោតិបិ សង្ខោ ។ មុនឹ អហំ សក្ក យថា វិជញ្ញន្តិ យំ សក្ក មុនឹ ជានេយ្យំ វិជានេយ្យំ បដិវិជានេយ្យំ បដិវិជ្ឈេយ្យន្តិ មុនឹ អហំ សក្ក យថា វិជញ្ញំ ។

[៣៨៦] តម្មេ វិយាចិក្ខ សមន្តចក្ខូតិ តន្តិ យំ បុច្ឆាមិ យំ យាចាមិ យំ អជ្ឈេសាមិ យំ បសា-ទេមិ ។ វិយាចិក្ខាតិ អាចិក្ខ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកា-សេហិ ។ សមន្តចក្ខូតិ សមន្តចក្ខុ វុច្ចតិ សព្វញ្ញុ-តញ្ញាណំ ។ បេ ។ តថាគតោ តេន សមន្តចក្ខូតិ តម្មេ វិយាចិក្ខ សមន្តចក្ខុ ។ តេនាហ សោ ព្រាហ្មណោ

ព្រះនាមថាសក្កៈ ព្រោះហេតុទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានទ្រព្យដោយរតនៈ ទ្រព្យទាំងនោះ មានប្រការជាអនេក ក៏បាន ។ ឬថា ព្រះនាមថាសក្កៈ ព្រោះហេតុមានព្យាយាមច្រើន មានចិត្តអង់អាច ក្លៀវក្លាប្រកបដោយព្យាយាម មានព្យាយាមមោះមុត មិនខ្លាច មិនព្រឺរោម មិនតក់ស្លុត មិនរត់ មានភ័យគួរខ្លាច លះបង់ហើយ ប្រាសចាកការព្រឺរោម ក៏បាន ។ ពាក្យថា បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គ គប្បីដឹងនូវមុនិណា គឺបពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គ គប្បីដឹង គប្បីដឹងច្បាស់ គប្បីដឹងចំពោះ គប្បីចាក់ធ្លុះនូវមុនិណា ហេតុនោះ (លោកសួរថា) បពិត្រព្រះសក្កៈ ខ្ញុំព្រះអង្គ គប្បីស្គាល់ នូវមុនិណា ។

[៣៥៦] ពាក្យថា បពិត្រព្រះអង្គជាសមន្តចក្ខុ សូមព្រះអង្គត្រាស់ប្រាប់នូវមុនិនោះ ដល់ខ្ញុំព្រះអង្គ ត្រង់ពាក្យថា មុនិនោះ គឺខ្ញុំសួរនូវមុនិណា អង្វរមុនិណា អារាធនាមុនិណា ដណ្តឹងនូវមុនិណា ។ ពាក្យថា សូមត្រាស់ប្រាប់ គឺសូមប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ។ ពាក្យថា សមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ បេ ។ ព្រះតថាគតទ្រង់ព្រះនាមសមន្តចក្ខុ ដោយហេតុនោះ ហេតុនោះ (លោកសួរថា) បពិត្រព្រះអង្គជាសមន្តចក្ខុ សូមព្រះអង្គត្រាស់ប្រាប់នូវមុនិនោះ ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះ ទូលសួរថា

និរាសសោ សោ ឧទ អាសសានោ
បញ្ញាណវា សោ ឧទ បញ្ញកប្បី
មុនឹ អហំ សក្ក យថា វិជញ្ញំ
តម្មេ វិយាចិក្ខ សមន្តចក្ខុតិ ។

[៣៨៧] និរាសសោ សោ ន ច អាសសានោ(១)
បញ្ញាណវា សោ ន ច(២) បញ្ញកប្បី
ឯវម្បិ តោទេយ្យ មុនឹ វិជាន
អកិញ្ចនំ កាមភវេ អសត្តំ ។

[៣៨៨] និរាសសោ សោ ន ច អាសសានោតិ និត្តណ្ហោ សោ ន សតណ្ហោ រូបំ នាសីសតិ សទ្ទេ គន្ធេ ។ បេ ។ ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ នាសីសតិ ន ឥច្ឆតិ ន សាទិយតិ ន បត្ថេតិ ន បិហេតិ នាភិជប្បតីតិ និរាសសោ សោ ន ច អាសសានោ ។

១ ម. និរាសសោ ន សោ អាសសានោ ។ ២ ម. សោ ។

បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នាទេ ឬនៅមានសេចក្តីប្រាថ្នា បុគ្គលនោះ មានបញ្ញា ឬមានការកំណត់ដោយបញ្ញា បពិត្រព្រះសក្កៈ ខ្ញុំព្រះអង្គ គប្បីស្គាល់នូវមុនិណា បពិត្រព្រះអង្គ ជាសមន្តចក្ខុ សូមព្រះអង្គ ត្រាស់ប្រាប់នូវមុនិនោះ ដល់ខ្ញុំព្រះអង្គ ។

[៣៥៧] (ព្រះមានព្រះភាគត្រាស់ថា) បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នា ទាំងមិនប្រកបដោយសេចក្តីប្រាថ្នាទេ បុគ្គលនោះ ជាអ្នកមានបញ្ញា ទាំងមិនមានការកំណត់ដោយបញ្ញាទេ ម្នាលតោទេយ្យ អ្នកចូរស្គាល់នូវបុគ្គលនោះថាជាមុនិ ជាអ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមនិងភព យ៉ាងនេះចុះ ។

[៣៥៨] ពាក្យថា បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នា ទាំងមិនប្រកបដោយសេចក្តីប្រាថ្នាទេ គឺ បុគ្គលនោះ ជាអ្នកមិនមានតណ្ហា មិនប្រកបដោយតណ្ហា គឺមិនប៉ងចំពោះនូវរូប សទ្ទៈ គន្ធៈ ។ បេ ។ មិនប៉ង មិនចង់បាន មិនត្រេកអរ មិនប្រាថ្នា មិនស្រឡាញ់ មិនជាប់ចិត្ត នូវអារម្មណ៍ដែលឃើញ ឮ ប៉ះពាល់ ឬដឹងច្បាស់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះជាអ្នកមិនមានសេចក្តីប្រាថ្នា ទាំងមិនប្រកបដោយសេចក្តីប្រាថ្នាទេ ។

[៣៥៩] បញ្ញាណវា សោ ន ច បញ្ញកប្បីតិ បញ្ញាណវា សោតិ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី ។ ន ច បញ្ញកប្បីតិ អដ្ឋសមាបត្តិញាណេន វា បញ្ចាភិញ្ញាញាណេន វា មិច្ឆាញាណេន វា តណ្ហាកប្បំ វា ទិដ្ឋិកប្បំ វា ន កប្បេតិ ន ជនេតិ ន សញ្ជនេតិ ន និព្វត្តេតិ នាភិនិព្វត្តេតីតិ បញ្ញាណវា សោ ន ច បញ្ញកប្បី ។

[៣៦០] ឯវម្បិ តោទេយ្យ មុនឹ វិជានាតិ មុនិន្តិ មោនំ វុច្ចតិ ញាណំ ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ ឯវម្បិ តោទេយ្យ មុនឹ វិជានាតិ តោទេយ្យ ឯវំ មុនឹ ជាន វិជាន បដិវិជានាតិ[១] ឯវម្បិ តោទេយ្យ មុនឹ វិជាន ។

១ ម. បដិជាន ។ បដិវិជាន បដិវិជ្ឈាតិ ។

[៣៥៩] ពាក្យថា បុគ្គលនោះ ជាអ្នកមានបញ្ញា ទាំងមិនមានការកំណត់ដោយបញ្ញា ត្រង់ពាក្យថា បុគ្គលនោះជាអ្នកមានបញ្ញា គឺជាបណ្ឌិត មានប្រាជ្ញា មានប្រាជ្ញាជាគ្រឿងត្រាស់ដឹង មានញាណ មានប្រាជ្ញាភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយបង់នូវកិលេស ។ ពាក្យថា ទាំងមិនមានការកំណត់ ដោយបញ្ញា គឺ មិនកំណត់ មិនបង្កើត មិនបង្កើតព្រម មិនបង្កើត មិនបង្កើតចំពោះ នូវតណ្ហាកប្បៈ ឬទិដ្ឋិកប្បៈ ដោយញាណប្រកបដោយសមាបត្តិ ៨ ក្តី ដោយញាណគឺអភិញ្ញា ៥ ក្តី ដោយមិច្ឆាញាណក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលនោះ ជាអ្នកមានបញ្ញា ទាំងមិនមានការកំណត់ដោយបញ្ញា ។

[៣៦០] ពាក្យថា មុនិ របស់បទថា ម្នាលតោទេយ្យ អ្នកចូរស្គាល់នូវបុគ្គលនោះថាជាមុនិ យ៉ាងនេះចុះ ត្រង់ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ ។ បេ ។ មុនិនោះ កន្លងហើយនូវបណ្តាញ គឺកិលេសជាគ្រឿងជាប់ចំពាក់ ។ ពាក្យថា ម្នាលតោទេយ្យ អ្នកចូរស្គាល់នូវបុគ្គលនោះថាជាមុនិ យ៉ាងនេះចុះ បានសេចក្តីថា ម្នាលតោទេយ្យ អ្នកចូរដឹង ចូរដឹងច្បាស់ ចូរដឹងចំពោះ នូវបុគ្គលនោះថាជាមុនិ យ៉ាងនេះចុះ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលតោទេយ្យ អ្នកចូរស្គាល់នូវបុគ្គលនោះថាជាមុនិ យ៉ាងនេះចុះ ។

តោទេយ្យមាណវកប្បញ្ហានិទ្ទេសោ

[៣៦១] អភិញ្ញំ កាមភវេ អសត្តន្តិ អភិញ្ញនន្តិ រាគាភិញ្ញំ ទោសាភិញ្ញំ មោហាភិញ្ញំ មានាភិញ្ញំ ទិដ្ឋាភិញ្ញំ កិលេសាភិញ្ញំ ទុច្ចរិតាភិញ្ញំ យស្សេតេ អភិញ្ញា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា សោ វុច្ចតិ អភិញ្ញនោ ។ កាមភវេតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ ភវាតិ ទ្វេ ភវា កម្មភវោ ច បដិសន្ធិកោ ច បុនព្ភវោ ។ បេ ។ អយំ បដិសន្ធិកោ បុនព្ភវោ ។ អភិញ្ញំ កាមភវេ អសត្តន្តិ អភិញ្ញំ[១] កាមេ ច ភវេ ច អសត្តំ អលគ្គំ អលគ្គិតំ អបលិពុទ្ធំ និក្ខន្តំ និស្សដ្ឋំ វិប្បមុត្តំ វិសំយុត្តំ វិមរិយាទិកតេន ចេតសា វិហរន្តន្តិ អភិញ្ញំ កាមភវេ អសត្តំ ។ តេនាហ ភគវា

១ ម. ឯត្តន្តរេ បុគ្គលន្តិ ទិស្សតិ ។

តោទេយ្យមាណវកបញ្ហានិទ្ទេស

[៣៦១] អធិប្បាយពាក្យថា ជាអ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមនិងភព ត្រង់ពាក្យថា ជាអ្នកមិនមានកង្វល់ សេចក្តីថា កង្វល់គឺរាគៈ កង្វល់គឺទោសៈ កង្វល់គឺមោហៈ កង្វល់គឺមានះ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត កង្វល់ទាំងនុ៎ះ បុគ្គលណាបានលះបង់ ផ្តាច់បង់ រម្ងាប់ ឲ្យរម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ បុគ្គលនោះ លោកហៅថា អ្នកមិនមានកង្វល់ ។ ពាក្យថា កាមទាំងឡាយ របស់បទថា ក្នុងកាមនិងភព តាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះ លោកហៅថា វត្ថុកាម ។ បេ ។ ទាំងនេះ លោកហៅថា កិលេស-កាម ។ ពាក្យថា ភព បានដល់ភព ២ គឺកម្មភព ១ បុនព្ភព គឺបដិសន្ធិ ១ ។ បេ ។ នេះ បុនព្ភព គឺបដិសន្ធិ ។ ពាក្យថា ជាអ្នកមិនមានកង្វល់ មិនជាប់នៅ ក្នុងកាមនិងភព បានសេចក្តីថាមិនមានកង្វល់ មិនជាប់ មិនចំពាក់ មិនជាប់ចំពាក់ មិនខ្វល់នៅ គឺជាអ្នកចេញទៅ រលាស់ចោល រួចស្រឡះ មិនប្រកប ក្នុងកាមផង ក្នុងភពផង នៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (ទ្រង់ត្រាស់ថា) មិនមានកង្វល់ មិនជាប់នៅ ក្នុងកាមនិងភព ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

និរាសសោ សោ ន ច អាសសានោ
បញ្ញាណវា សោ ន ច បញ្ញកប្បី
ឯវម្បិ តោទេយ្យ មុនឹ វិជាន
អកិញ្ចនំ កាមភវេ អសត្តន្តិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

តោទេយ្យមាណវកប្បញ្ហានិទ្ទេសោ នវមោ ។

---

បុគ្គលនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នា ទាំងមិនប្រកប ដោយសេចក្តីប្រាថ្នាទេ បុគ្គលនោះ ជាអ្នកមានបញ្ញា ទាំង មិនមានការកំណត់ដោយបញ្ញាទេ ម្នាលតោទេយ្យ អ្នកចូរ ស្គាល់នូវបុគ្គលនោះថាជាមុនិ ជាអ្នកមិនមានកង្វល់ មិន ជាប់នៅ ក្នុងកាមនិងភព យ៉ាងនេះចុះ ។

លុះចប់គាថាហើយ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តា របស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ តោទេយ្យមាណវកប្បញ្ហានិទ្ទេស ទី ៩ ។

# កប្បមាណវកប្បញ្ហានិទ្ទេសោ

[៣៦២] មជ្ឈេ សរស្មឹ[១] តិដ្ឋតំ (ឥច្ចាយស្មា កប្បោ)
ឱឃេ ជាតេ មហព្ភយេ
ជរាមច្ចុបរេតានំ
ទីបំ បព្រូហិ មារិស
ត្វញ្ច មេ ទីបមក្ខាហិ
យថាយិទំ នាបរំ សិយា ។

[៣៦៣] មជ្ឈេ សរស្មឹ តិដ្ឋតន្តិ សរោ វុច្ចតិ សំសារោ អាគមនំ គមនំ គមនាគមនំ កាលំ គតិ ភវាភវោ ចុតិ ច ឧបបត្តិ ច និព្វត្តិ ច ភេទោ ច ជាតិ ច ជរា ច មរណញ្ច ។ សំសារស្ស បុរិមាបិ កោដិ ន បញ្ញាយតិ បច្ឆិមាបិ កោដិ ន បញ្ញាយតិ ។ មជ្ឈេ ច សំសារេ សត្តា ឋិតា បតិដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តា កថំ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកា ជាតិយោ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ[២] ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ ជាតិសតានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។

១ ម. បរស្មឹ ។ ២ ម. ន វត្តតីតិ ។

# កប្បមាណវកប្បញ្ហានិទ្ទេស

[៣៦២] (កប្បមាណពមានអាយុ ទូលសួរដូច្នេះថា) បពិត្រព្រះអង្គនិរទុក្ខ សូមព្រះអង្គត្រាស់ប្រាប់ នូវទីពឹង របស់ពួកសត្វអ្នកឋិតនៅក្នុងកណ្តាលនៃស្រះ ដែលត្រូវជរានិងមច្ចុគ្របសង្កត់ ព្រោះឱឃៈជាភ័យធំកើតឡើងហើយ ចុះសេចក្តីទុក្ខ (ក្នុងស្រះ) នេះ មិនគប្បីមានតទៅទៀត ដោយប្រការណា សូមព្រះអង្គប្រាប់ នូវទីពឹងដល់ខ្ញុំព្រះអង្គ ដោយប្រការនោះ ។

[៣៦៣] ពាក្យថា អ្នកឋិតនៅក្នុងកណ្តាលនៃស្រះ អធិប្បាយថា សង្សារ លោកហៅថា ស្រះ បានដល់ដំណើរមក ដំណើរទៅ ដំណើរទៅនិងមក កាលៈ គតិ ភពតូចធំ ការចុតិផង ការចាប់កំណើតផង ការកើតផង ការបែកធ្លាយផង ជាតិផង ជរាផង មរណៈផង ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ ទាំងទីបំផុតខាងចុង ក៏មិនប្រាកដ ។ ពួកសត្វដែលឋិតនៅ តាំងនៅ ជាប់ស្អិតនៅកុះករ ជ្រុលជ្រប់ ចុះស៊ប់ក្នុងសង្សារ តែត្រង់កណ្តាល ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ តើដូចម្តេច ។ វដ្តៈវិលទៅហើយអស់ជាតិទាំងឡាយប៉ុណ្ណេះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។

ឯត្តកានិ ជាតិសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ ជាតិសតសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ ជាតិកោដិយោ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ ជាតិកោដិសតានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ ជាតិកោដិសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ ជាតិកោដិសតសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ វស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ វស្សសតានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។

វដ្ដៈវិលទៅហើយ អស់រយនៃជាតិប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្ដៈវិលទៅហើយ អស់ពាន់នៃជាតិប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្ដៈវិលទៅហើយ អស់សែនកោដិនៃជាតិប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុត ខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្ដៈវិលទៅហើយ អស់រយកោដិនៃជាតិប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្ដៈវិលទៅហើយ អស់រយកោដិនៃជាតិប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្ដៈវិលទៅហើយ អស់សែនកោដិនៃជាតិប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្ដៈវិលទៅហើយ អស់ឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្ដៈវិលទៅហើយ អស់រយនៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។

កប្បមាណវកប្បញ្ញានិទ្ទេសោ

ឯត្តកានិ វស្សសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្ត-តិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ វស្សសតសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកា វស្សកោដិយោ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ វស្សកោដិសតានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសា-រស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ វស្ស-កោដិសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញា-យតិ ។ ឯត្តកានិ វស្សកោដិសតសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសា-រស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ កប្បានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។

វដ្ដៈវិលទៅហើយ អស់ពាន់នៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើម នៃសង្សារ មិនប្រាកដ យ៉ាងនេះខ្វះ ។ វដ្ដៈវិលទៅហើយ អស់សែន នៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួស អំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្វះ ។ វដ្ដៈវិលទៅហើយ អស់កោដិនៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើម នៃសង្សារ មិនប្រាកដ យ៉ាងនេះខ្វះ ។ វដ្ដៈវិលទៅហើយ អស់រយកោដិនៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើម នៃសង្សារ មិនប្រាកដ យ៉ាងនេះខ្វះ ។ វដ្ដៈវិលទៅហើយ អស់ពាន់កោដិនៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើម នៃសង្សារ មិនប្រាកដយ៉ាងនេះខ្វះ ។ វដ្ដៈវិលទៅហើយ អស់សែនកោដិនៃឆ្នាំប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើម នៃសង្សារ មិនប្រាកដ យ៉ាងនេះខ្វះ ។ វដ្ដៈវិលទៅហើយ អស់កប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើម នៃសង្សារ មិនប្រាកដ យ៉ាងនេះខ្វះ ។

ឯត្តកានិ កប្បសតានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ កប្បសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ កប្បសតសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកា កប្បកោដិយោ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ កប្បកោដិសតានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ កប្បកោដិសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ កប្បកោដិសតសហស្សានិ វដ្ដំ វត្តិ តតោ បរំ ន វត្តតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។

វដ្តៈវិលទៅហើយ អស់រយនៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដយ៉ាងនេះខ្វះ ។ វដ្តៈវិលទៅហើយ អស់ពាន់នៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដយ៉ាងនេះខ្វះ ។ វដ្តៈវិលទៅហើយ អស់សែននៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើម នៃសង្សារ មិនប្រាកដ យ៉ាងនេះខ្វះ ។ វដ្តៈវិលទៅហើយ អស់កោដិនៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើម នៃសង្សារ មិនប្រាកដ យ៉ាងនេះខ្វះ ។ វដ្តៈវិលទៅហើយអស់រយកោដិនៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើម នៃសង្សារ មិនប្រាកដយ៉ាងនេះខ្វះ ។ វដ្តៈវិលទៅហើយ អស់ពាន់កោដិនៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដយ៉ាងនេះខ្វះ ។ វដ្តៈវិលទៅហើយអស់សែនកោដិនៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដយ៉ាងនេះខ្វះ ។

វុត្តំ ហេតំ ភគវតា អនមតគ្គោយំ ភិក្ខវេ សំសារស្ស បុព្វកោដិ[១] ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ឯវំ ទីឃរត្តំ ខោ ភិក្ខវេ ទុក្ខំ បច្ចនុភូតំ តិព្វំ ព្យសនំ កដសីវឌ្ឍិតំ[២] យាវញ្ចិទំ ភិក្ខវេ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ មុច្ចិតុន្តិ[៣] ។ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។

កថំ សំសារស្ស បច្ឆិមា កោដិ ន បញ្ញាយតិ ។ ឯត្តកា ជាតិយោ វដ្ដំ វត្តិស្សតិ តតោ បរំ ន វត្តិស្សតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បច្ឆិមា កោដិ ន បញ្ញាយតិ ។ ឯត្តកានិ ជាតិសតានិ ឯត្តកានិ ជាតិសហស្សានិ ឯត្តកានិ ជាតិសតសហស្សានិ ។ បេ ។ ឯត្តកា ជាតិកោដិយោ ឯត្តកានិ ជាតិកោដិសតានិ ឯត្តកានិ ជាតិកោដិសហស្សានិ ឯត្តកានិ ជាតិកោដិសតសហស្សានិ

---

១ អនមតគ្គាយំ ភិក្ខវេ សំសារោ បុព្វា កោដិ ។ ២ ម. បច្ចនុភូតំ តិព្វំ បច្ចនុភូតំ ព្យសនំ បច្ចនុភូតំ កដសីវឌ្ឍិតានិ ។ ៣ ម. វិមុច្ចិតុន្តិ ។

*សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតដឹងមិនបាន ទីបំផុតខាងដើមនៃសង្សារមិនប្រាកដទេ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលត្រូវអវិជ្ជាជាគ្រឿងរារាំងមានតណ្ហា ជាគ្រឿងប្រកបទុក រង្គាត់ទៅ អន្ទោលទៅ ទទួលទុក្ខយ៉ាងខ្លាំងជាគ្រឿងវិនាស ញុំាងព្រៃស្មសានឲ្យចម្រើន អស់កាលយូរយារយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គួរតែនឿយណាយ គួរតែប្រាស គួរតែគេចចេញ ចាកសង្ខារទាំងពួង ។ ទីបំផុតខាងដើម នៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។*

*ទីបំផុតខាងចុងនៃសង្សារ មិនប្រាកដ តើដូចម្ដេច។ វដ្ដៈនឹងវិលទៅអស់ជាតិប៉ុណ្ណេះ នឹងមិនវិល ហួសអំពីនោះ ការដឹងយ៉ាងនេះមិនមានទេ ទីបំផុតខាងចុងនៃសង្សារ មិនប្រាកដ យ៉ាងនេះខ្លះ ។ វដ្ដៈនឹងវិលទៅ អស់រយនៃជាតិប៉ុណ្ណេះ អស់ពាន់នៃជាតិប៉ុណ្ណេះ អស់សែននៃជាតិប៉ុណ្ណេះ ។ បេ ។ អស់កោដិនៃជាតិប៉ុណ្ណេះ អស់រយកោដិនៃជាតិប៉ុណ្ណេះ អស់ពាន់កោដិនៃជាតិប៉ុណ្ណេះ អស់សែនកោដិនៃជាតិប៉ុណ្ណេះ*

ឯត្តកានិ វស្សានិ ឯត្តកានិ វស្សសតានិ ឯត្តកានិ វស្សសហស្សានិ ឯត្តកានិ វស្សសតសហស្សានិ ឯត្តកា វស្សកោដិយោ ឯត្តកានិ វស្សកោដិសតានិ ឯត្តកានិ វស្សកោដិសហស្សានិ ឯត្តកានិ វស្សកោដិសតសហស្សានិ ឯត្តកានិ កប្បានិ ឯត្តកានិ កប្បសតសហស្សានិ ឯត្តកានិ កប្បកោដិយោ ឯត្តកានិ កប្បកោដិសតានិ ឯត្តកានិ កប្បកោដិសហស្សានិ ឯត្តកានិ កប្បកោដិសតសហស្សានិ កប្បសតសហស្សានិ ឯត្តកា កប្បកោដិសហស្សានិ វដ្តំ វត្តិស្សតិ តតោ បរំ ន វត្តិស្សតិ ហេវំ នត្ថិ ឯវម្បិ សំសារស្ស បច្ឆិមា កោដិ ន បញ្ញាយតិ ។ ឯវំ សំសារស្ស បុរិមាបិ កោដិ ន បញ្ញាយតិ បច្ឆិមាបិ កោដិ ន បញ្ញាយតិ ។ មជ្ឈេវ សំសារេ សត្តា ឋិតា បតិដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តាតិ មជ្ឈេ សរស្មឹ តិដ្ឋតំ ។ ឥច្ចាយស្មា កប្បោតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ បទានុបុព្វកាមេតំ ឥច្ចាតិ ។

អស់ឆ្នាំប៉ុណ្ណោះ អស់រយនៃឆ្នាំប៉ុណ្ណោះ អស់ពាន់នៃឆ្នាំប៉ុណ្ណោះ អស់សែននៃឆ្នាំប៉ុណ្ណោះ អស់កោដិនៃឆ្នាំប៉ុណ្ណោះ អស់រយកោដិនៃឆ្នាំប៉ុណ្ណោះ អស់ពាន់កោដិនៃឆ្នាំប៉ុណ្ណោះ អស់សែនកោដិនៃឆ្នាំប៉ុណ្ណោះ អស់កប្បប៉ុណ្ណោះ អស់រយនៃកប្បប៉ុណ្ណោះ អស់ពាន់នៃកប្បប៉ុណ្ណោះ អស់សែននៃកប្បប៉ុណ្ណោះ អស់កោដិនៃកប្បប៉ុណ្ណោះ អស់រយកោដិនៃកប្បប៉ុណ្ណោះ អស់ពាន់កោដិនៃកប្បប៉ុណ្ណោះ អស់សែនកោដិនៃកប្បប៉ុណ្ណោះ នឹងមិនវិលហួសអំពីនោះ ការដឹងយ៉ាងនេះ មិនមានទេ ទីបំផុតខាងចុងនៃសង្សារមិនប្រាកដ យ៉ាងនេះខ្លះ ។ ទីបំផុតខាងដើមនៃសង្សារ ក៏មិនប្រាកដទាំងទីបំផុតខាងចុងនៃសង្សារ ក៏មិនប្រាកដយ៉ាងនេះឯង ។ ពួកសត្វអ្នកឋិតនៅ តាំងនៅ ជាប់ស្អិត ចូលទៅ នៅ កុះករ ជ្រុលជ្រប់ ចុះស៊ប់ហើយ ក្នុងសង្សារតែត្រង់កណ្តាល ហេតុនោះ(លោកសួរថា) អ្នកនៅក្នុងកណ្តាលនៃស្រះ ។ ពាក្យថា ដូច្នេះ របស់បទថា កប្បមាណពមានអាយុទូលសួរដូច្នេះ ជាពាក្យតបទ ។ បេ ។ ពាក្យថា ដូច្នេះនុ៎ះ ជាលំដាប់បទ ។

កប្បមាណវកប្បញ្ហានិទ្ទេសោ

អាយស្មាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សា-ធិវចនមេតំ អាយស្មាតិ ។ កប្បោតិ តស្ស ព្រាហ្ម-ណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្មា កប្បោ ។

[៣៦៤] ឱឃេ ជាតេ មហព្ភយេតិ កាមោឃេ ភវោឃេ ទិដ្ឋោឃេ អវិជ្ជោឃេ ជាតេ សញ្ជាតេ និព្វត្តេ អភិនិព្វត្តេ បាតុភូតេ មហព្ភយេតិ ជាតិភ-យេ ជរាភយេ ព្យាធិភយេ មរណភយេតិ ឱឃេ ជាតេ មហព្ភយេ ។

[៣៦៥] ជរាមច្ចុបរេតានន្តិ ជរាយ ផុដ្ឋានំ បរេ-តានំ សមោហិតានំ សមន្នាគតានំ មច្ចុនា ផុដ្ឋានំ បរេតានំ សមោហិតានំ សមន្នាគតានំ ជាតិយា អនុគតានំ ជរាយ អនុសដានំ ព្យាធិនា អភិភូតា-នំ មរណេន អព្ភាហតានំ អត្តាណានំ អលេណានំ អសរណានំ អសរណីភូតានន្តិ ជរាមច្ចុបរេតានំ ។

ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នុ៎ះ ជាពាក្យពោលដោយគោរពកោតក្រែង ។ ពាក្យថា កប្បៈ ជាឈ្មោះរបស់ព្រាហ្មណ៍ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) កប្បមាណពមានអាយុ ទូលសួរដូច្នេះ ។

[៣៦៤] ពាក្យថា ព្រោះឱឃៈជាភ័យធំកើតឡើងហើយ គឺ ព្រោះកាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ កើត កើតព្រម កកើត កើតចំពោះ កើតប្រាកដ ។ ពាក្យថា ភ័យធំ បានដល់ ភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ហេតុនោះ (លោកសួរថា) ព្រោះឱឃៈជាភ័យធំ កើតឡើងហើយ ។

[៣៦៥] ពាក្យថា ដែលត្រូវជរានិងមច្ចុ គ្របសង្កត់ គឺត្រូវជរា ប៉ះពាល់ គ្របសង្កត់ រួបរឹត ទន្ទ្រាន ត្រូវមច្ចុប៉ះពាល់ គ្របសង្កត់ រួបរឹត ទន្ទ្រាន ត្រូវជាតិជាប់តាម ត្រូវជរាជ្រួតជ្រាបចូល ត្រូវព្យាធិ គ្របសង្កត់ ត្រូវមរណៈកម្ចាត់ មិនមានទីការពារ មិនមានទីជ្រក មិនមានទីពឹង មិនមានបុគ្គលជាទីពំនាក់ ហេតុនោះ (លោកសួរថា) ដែលត្រូវជរានិងមច្ចុ គ្របសង្កត់ ។

[៣៦៦] ទីបំ បព្រូហិ មារិសាតិ ទីបំ តាណំ លេណំ សរណំ គតិបរាយនំ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហិ ។ មារិសាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ មារិសាតិ ទីបំ ព្រូហិ មារិស ។

[៣៦៧] ត្វញ្ច មេ ទីបមក្ខាហីតិ ត្វន្តិ ភគវន្តំ ភណតិ ។ ទីបមក្ខាហីតិ ទីបំ តាណំ លេណំ សរណំ គតិបរាយនំ អក្ខាហិ អាចិក្ខាហិ ទេសេ-ហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានី-ករោហិ បកាសេហីតិ ត្វញ្ច មេ ទីបមក្ខាហិ ។

[៣៦៨] យថាយិទំ នាបរំ សិយាតិ យថា ឥទំ ទុក្ខំ ឥធេវ និរុជ្ឈេយ្យ វូបសមេយ្យ អត្ថំ គច្ឆេយ្យ បដិប្បស្សម្ភេយ្យ បុន បដិសន្ធិកំ ទុក្ខំ ន និព្វត្តេ-យ្យ កាមធាតុយា វា រូបធាតុយា វា អរូបធាតុ-យា វា កាមភវេ វា រូបភវេ វា អរូបភវេ វា

[៣៦៦] ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ សូមព្រះអង្គត្រាស់ប្រាប់ នូវទីពឹង គឺ សូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស នូវទីពឹង ទីការពារ ទីជ្រក ទីពំនាក់ ទីពឹង ការប្រព្រឹត្តនៃដំណើរ ។ ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ គឺពាក្យ ជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា បពិត្រព្រះអង្គនិរទុក្ខ នេះជា ពាក្យពោលដោយគោរព កោតក្រែង ហេតុនោះ (លោកសួរថា) បពិត្រ ព្រះអង្គនិរទុក្ខ សូមព្រះអង្គត្រាស់ប្រាប់ នូវទីពឹង ។

[៣៦៧] ពាក្យថា ព្រះអង្គ របស់បទថា សូមព្រះអង្គប្រាប់នូវ ទីពឹង ដល់ខ្ញុំព្រះអង្គ គឺកប្បមាណពពោល ចំពោះព្រះមានព្រះភាគ ។ ពាក្យថា សូមត្រាស់ប្រាប់នូវទីពឹង គឺ សូមព្រះអង្គពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស នូវទីពឹង នូវទី ការពារ នូវទីជ្រក នូវទីពំនាក់ នូវការប្រព្រឹត្តទៅនៃគតិ ហេតុនោះ (លោកសួរថា) សូមព្រះអង្គប្រាប់ នូវទីពឹង ដល់ខ្ញុំព្រះអង្គ ។

[៣៦៨] ពាក្យថា ចុះសេចក្តីទុក្ខ (ក្នុងស្រះ) នេះ មិនគប្បីមានតទៅ ទៀត ដោយប្រការណា សេចក្តីថា ទុក្ខនេះ គប្បីរលត់ រម្ងាប់ ដល់នូវ ការវិនាស ស្ងប់រម្ងាប់ ក្នុងស្រះនេះឯង គឺសេចក្តីទុក្ខដែលកើតអំពីបដិសន្ធិ ទៀតមិនគប្បីកើតបាន គឺថាមិនគប្បីកើត មិនគប្បីកើតព្រម មិនគប្បីកកើត ក្នុងកាមធាតុក្តី រូបធាតុក្តី អរូបធាតុក្តី កាមភពក្តី រូបភពក្តី អរូបភពក្តី

សញ្ញាភវេ វា អសញ្ញាភវេ វា នេវសញ្ញានាសញ្ញាភវេ វា ឯកវោការភវេ វា ចតុវោការភវេ វា បញ្ចវោការភវេ វា បុន គតិយា វា បុន ឧបបត្តិយា វា បុន បដិសន្ធិ-យា វា ភវេ វា សំសារេ វា វដ្ដេ វា ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ[១] ឥធេវ និរុជ្ឈេយ្យ វូបស-មេយ្យ អត្ថំ គច្ឆេយ្យ បដិប្បស្សម្ភេយ្យាតិ យថាយិទំ នាបរំ សិយា ។ តេនាហ សោ ព្រាហ្មណោ

មជ្ឈេ សរស្មឹ តិដ្ឋតំ (ឥច្ចាយស្មា កប្បោ)
ឱឃេ ជាតេ មហព្ភយេ
ជរាមច្ចុបរេតានំ
ទីបំ បព្រូហិ មារិស
ត្វញ្ច មេ ទីបមក្ខាហិ
យថាយិទំ នាបរំ សិយាតិ ។

[៣៦៩] មជ្ឈេ សរស្មឹ តិដ្ឋតំ (កប្បាតិ ភគវា)
ឱឃេ ជាតេ មហព្ភយេ
ជរាមច្ចុបរេតានំ
ទីបំ បព្រូមិ កប្ប តេ ។

---
១ ម. ឯត្ថន្តរេ នាភិនិព្វត្តេយ្យាតិ ទិស្សតិ ។

សញ្ញាភពក្តី អសញ្ញាភពក្តី នេវសញ្ញានាសញ្ញាភពក្តី ឯកវោការភពក្តី ចតុវោការភពក្តី បញ្ចវោការភពក្តី គតិទៀតក្តី ឧបបត្តិទៀតក្តី បដិសន្ធិទៀតក្តី ភពក្តី សង្សារក្តី វដ្តៈក្តី គឺថា សេចក្តីទុក្ខនេះ គប្បីរលត់រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងស្រះនេះឯង ដោយប្រការណា ហេតុនោះ (លោកសួរថា) ចុះសេចក្តីទុក្ខ (ក្នុងស្រះ) នេះ មិនគប្បីមានតទៅទៀត ដោយប្រការណា ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

(កប្បមាណពមានអាយុ ទូលសួរដូច្នេះថា) បពិត្រព្រះអង្គនិរទុក្ខ សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹង របស់ពួកសត្វអ្នកឋិតនៅក្នុងកណ្តាលនៃស្រះ ដែលត្រូវជរានិងមច្ចុគ្របសង្កត់ ព្រោះឱឃៈ ជាភ័យធំកើតឡើងហើយ ចុះសេចក្តីទុក្ខ (ក្នុងស្រះ) នេះ មិនគប្បីមានតទៅទៀត ដោយប្រការណា សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹង ដល់ខ្ញុំព្រះអង្គ ដោយប្រការនោះ ។

[៣៦៩] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកប្បៈ) តថាគតនឹងប្រាប់អ្នកនូវទីពឹង របស់ពួកសត្វ អ្នកឋិតនៅក្នុងកណ្តាលនៃស្រះ ដែលត្រូវជរានិងមច្ចុគ្របសង្កត់ ព្រោះឱឃៈជាភ័យធំកើតឡើងហើយ ។

[៣៧០] មជ្ឈេ សរស្មឹ តិដ្ឋតន្តិ សរោ វុច្ចតិ សំសារោ អាគមនំ គមនំ គមនាគមនំ កាលំ គតិ ភវាភវោ ចុតិ ច ឧបបត្តិ ច និព្វត្តិ ច ភេទោ ច ជាតិ ច ជរា ច មរណញ្ច ។ សំសារស្ស បុរិមាបិ កោដិ ន បញ្ញាយតិ បច្ឆិមាបិ កោដិ ន បញ្ញាយតិ ។ បេ ។ មជ្ឈេ ច សំសារេ សត្តា ឋិតា បតិដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តា ។ កថំ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ បេ ។ ឯវម្បិ សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ ។ កថំ សំសារស្ស បច្ឆិមា កោដិ ន បញ្ញាយតិ ។ បេ ។ ឯវម្បិ សំសារស្ស បច្ឆិមា កោដិ ន បញ្ញាយតិ ។ ឯវំ សំសារស្ស បុរិមាបិ កោដិ ន បញ្ញាយតិ បច្ឆិមាបិ កោដិ ន បញ្ញាយតិ ។ មជ្ឈេវ សំសារេ សត្តា ឋិតា បតិដ្ឋិតា អល្លីនា ឧបគតា អជ្ឈោសិតា អធិមុត្តាតិ មជ្ឈេ សរស្មឹ តិដ្ឋតំ ។ កប្បាតិ ភគវាតិ កប្បាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ កប្បាតិ ភគវា ។

[៣៧០] ពាក្យថា អ្នកឋិតនៅក្នុងកណ្តាលនៃស្រះ អធិប្បាយថា សង្សារ លោកហៅថា ស្រះ បានដល់ដំណើរមក ដំណើរទៅ ដំណើរទៅនិងមក មរណកាល គតិ ភពតូច ភពធំ ការច្យុតផង ការចាប់កំណើតផង ការកើតផង ការបែកធ្លាយផង ជាតិផង ជរាផង មរណៈផង ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ ទាំងទីបំផុតខាងចុង ក៏មិនប្រាកដ ។ បេ ។ ពួកសត្វឋិតនៅ តាំងនៅ ជាប់ស្អិត នៅកុះករ ជ្រុលជ្រប់ ចុះស៊ប់ហើយក្នុងសង្សារ តែត្រង់កណ្តាល ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដ តើដូចម្តេច ។ បេ ។ ទីបំផុតខាងដើមនៃសង្សារ មិនប្រាកដយ៉ាងនេះខ្វះ ។ ទីបំផុតខាងចុងនៃសង្សារ មិនប្រាកដ តើដូចម្តេច ។ បេ ។ ទីបំផុតខាងចុងនៃសង្សារ មិនប្រាកដយ៉ាងនេះខ្វះ ។ ទីបំផុតខាងដើមនៃសង្សារ ក៏មិនប្រាកដ ទាំងទីបំផុតខាងចុង ក៏មិនប្រាកដយ៉ាងនេះ ។ ពួកសត្វឋិតនៅ តាំងនៅ ជាប់ស្អិតនៅ កុះករ ជ្រុលជ្រប់ ចុះស៊ប់ហើយក្នុងសង្សារ តែត្រង់កណ្តាល ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកឋិតនៅក្នុងកណ្តាលនៃស្រះ ។ ពាក្យថា ម្នាលកប្បៈ របស់បទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលកប្បៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះតាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកប្បៈ ។

កប្បមាណវកប្បញ្ហានិទ្ទេសោ

[៣៧១] ឱឃេ ជាតេ មហព្ភយេតិ កាមោឃេ ភវោឃេ ទិដ្ឋោឃេ អវិជ្ជោឃេ ជាតេ សញ្ជាតេ និព្វត្តេ អភិនិព្វត្តេ ចាតុភូតេ ។ មហព្ភយេតិ ជាតិភយេ ជរាភយេ ព្យាធិភយេ មរណភយេតិ ឱឃេ ជាតេ មហព្ភយេ ។

[៣៧២] ជរាមច្ចុបរេតានន្តិ ជរាយ ផុដ្ឋានំ បរេតានំ សមោហិតានំ សមន្នាគតានំ មច្ចុនា ផុដ្ឋានំ បរេតានំ សមោហិតានំ សមន្នាគតានំ ជាតិយា អនុគតានំ ជរាយ អនុសដានំ ព្យាធិនា អភិភូតានំ មរណេន អព្ភាហតានំ អត្តាណានំ អលេណានំ អសរណានំ អសរណីភូតានន្តិ ជរាមច្ចុបរេតានំ ។

[៣៧៣] ទីបំ បព្រូមិ កប្ប តេតិ ទីបំ តាណំ លេណំ សរណំ គតិបរាយនំ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមីតិ ទីបំ បព្រូមិ ។ កប្ប តេតិ កប្បាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតីតិ ទីបំ បព្រូមិ កប្ប តេ ។ តេនាហ ភគវា

[៣៧១] ពាក្យថា ព្រោះឱឃៈជាភ័យធំ កើតឡើងហើយ គឺ ព្រោះកាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ កើត កើតព្រម កកើត ដុះដាល កើតប្រាកដ ។ ពាក្យថា ជាភ័យធំ គឺជាភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះឱឃៈជាភ័យធំកើតឡើងហើយ ។

[៣៧២] ពាក្យថា ដែលត្រូវជរានិងមច្ចុ គ្របសង្កត់ គឺត្រូវជរា ប៉ះពាល់ គ្របសង្កត់ ប្រជុំចុះ ទន្ទ្រាន ត្រូវមច្ចុប៉ះពាល់ គ្របសង្កត់ ប្រជុំចុះ ទន្ទ្រាន ត្រូវជាតិជាប់តាម ត្រូវជរាជ្រួតជ្រាបចូល ត្រូវព្យាធិ គ្របសង្កត់ ត្រូវមរណៈកម្ចាត់ មិនមានទីការពារ មិនមានទីជ្រក មិន មានទីពឹង មិនមានបុគ្គលជាទីសង្ឃឹម ហេតុនោះ (ទ្រង់ត្រាស់ថា) ដែល ត្រូវជរានិងមច្ចុគ្របសង្កត់ ។

[៣៧៣] ពាក្យថា ម្នាលកប្បៈ តថាគតនឹងប្រាប់អ្នក នូវ ទីពឹង គឺ តថាគតនឹងពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ នូវទីពឹង ទីការពារ ទីជ្រក ទីពំនាក់ ការប្រព្រឹត្តទៅនៃគតិ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតនឹងប្រាប់នូវទីពឹង ។ ពាក្យថា ម្នាល កប្បៈ របស់បទថា ម្នាលកប្បៈ... ដល់អ្នក គឺព្រះមានព្រះភាគ ហៅ ព្រាហ្មណ៍នោះតាមឈ្មោះ ហេតុនោះ(ទ្រង់ត្រាស់ថា) ម្នាលកប្បៈ តថា-គត នឹងប្រាប់អ្នក នូវទីពឹង ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

មជ្ឈេ សរស្មឹ តិដ្ឋតំ (កប្បាតិ ភគវា)
ឱឃេ ជាតេ មហព្ភយេ
ជរាមច្ចុបរេតានំ
ទីបំ បព្រូមិ កប្ប តេតិ ។

[៣៧៤] អកិញ្ចនំ អនាទានំ ឯតំ ទីបំ អនាបរំ
និព្វានំ ឥតិ នំ ព្រូមិ ជរាមច្ចុបរិក្ខយំ ។

[៣៧៥] អកិញ្ចនំ អនាទានន្តិ អកិញ្ចនន្តិ រាគកិញ្ចនំ ទោសកិញ្ចនំ មោហកិញ្ចនំ មានកិញ្ចនំ ទិដ្ឋិកិញ្ចនំ កិលេសកិញ្ចនំ ទុច្ចរិតកិញ្ចនំ កិញ្ចនប្បហានំ កិញ្ចនវូបសមោ[1] កិញ្ចនប្បដិនិស្សគ្គោ កិញ្ចនប្បដិប្បស្សទ្ធិ អមតំ និព្វានន្តិ អកិញ្ចនំ ។ អនាទានន្តិ អាទានំ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ អាទានប្បហានំ អាទានវូបសមោ អាទានប្បដិនិស្សគ្គោ អាទានប្បដិប្បស្សទ្ធិ អមតំ និព្វានន្តិ អកិញ្ចនំ អនាទានំ ។

---

១ ម. កិញ្ចនវូបសមំ កិញ្ចនប្បដិនិស្សគ្គំ ។ ល ។ អាទានប្បដិប្បស្សទ្ធំ ។

(ព្រះមានព្រះភាគត្រាស់ថា) ម្នាលកប្បៈ តថាគតនឹងប្រាប់អ្នក នូវទីពឹង របស់ពួកសត្វ អ្នកឋិតនៅ ក្នុងកណ្តាលនៃស្រះ ដែលត្រូវជរានិងមច្ចុគ្របសង្កត់ ព្រោះឱឃៈជាភ័យធំ កើតឡើងហើយ ។

[៣៧៨] ការមិនកង្វល់ ការមិនប្រកាន់មាំ នុ៎ះឯងជាទីពឹង ឯទីពឹងក្រៅពីនេះ ពុំមានទេ តថាគតហៅនូវទីពឹងនោះ ថានិព្វាន ជាទីអស់ជរានិងមច្ចុ ដោយប្រការដូច្នេះ ។

[៣៧៩] ពាក្យថា ការមិនកង្វល់ ការមិនប្រកាន់មាំ ត្រង់ពាក្យថា ការមិនកង្វល់ សេចក្តីថា កង្វល់គឺរាគៈ កង្វល់គឺទោសៈ កង្វល់គឺមោហៈ កង្វល់គឺមានះ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត ការលះបង់កង្វល់ ការរម្ងាប់កង្វល់ ការរលាស់កង្វល់ ការស្ងប់កង្វល់ អមតនិព្វានហេតុនោះ (ទ្រង់ត្រាស់ថា) ការមិនកង្វល់ ។ ពាក្យថា ការមិនប្រកាន់មាំ សេចក្តីថា តណ្ហា លោកហៅថា ការប្រកាន់មាំ បានដល់រាគៈ រាគៈមានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ការលះបង់ សេចក្តីប្រកាន់មាំ ការរម្ងាប់ សេចក្តីប្រកាន់ ការរលាស់បោល សេចក្តីប្រកាន់មាំ ការស្ងប់ សេចក្តីប្រកាន់មាំ អមតនិព្វានហេតុនោះ (ទ្រង់ត្រាស់ថា) ការមិនកង្វល់ ការមិនប្រកាន់មាំ ។

កប្បមាណវកប្បញ្ហានិទ្ទេសោ

[៣៧៦] ឯតំ ទីបំ អនាបរន្តិ ឯតំ ទីបំ តាណំ លេណំ សរណំ គតិបរាយនំ ។ អនាបរន្តិ តម្ហា[១] បរោ អញ្ញោ ទីបោ នត្ថិ អថខោ សោយេវ ទីបោ អគ្គោ ច សេដ្ឋោ ច វិសេដ្ឋោ ច បាមោក្ខោ ច ឧត្តមោ ច បវរោ ចាតិ ឯតំ ទីបំ អនាបរំ ។

[៣៧៧] និព្វានំ ឥតិ នំ ព្រូមីតិ វានំ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ វានប្បហានំ វានវូបសមោ វានប្បដិនិស្សគ្គោ វានប្បដិប្បស្សទ្ធិ អមតំ និព្វានំ ។ ឥតីតិ បទសន្ធិ ។ បេ ។ បទានុបុព្វតាមេតំ ឥតីតិ ។ ព្រូមីតិ ព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ បកាសេមីតិ និព្វានំ ឥតិ នំ ព្រូមិ ។

[៣៧៨] ជរាមច្ចុបរិក្ខយន្តិ ជរាមរណស្ស បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ ជរាមច្ចុបរិក្ខយំ ។ តេនាហ ភគវា

---

១ ម. តេន ។

កប្បមាណវកប្បញ្ហានិទ្ទេស

[៣៧៦] ពាក្យថា នុ៎ះឯងជាទីពឹង ឯទីពឹងក្រៅពីនេះ ពុំមានទេ គឺ នុ៎ះជាទីពឹង ជាទីការពារ ជាទីជ្រក ជាទីពំនាក់ ជាដំណើរប្រព្រឹត្ត ទៅនៃគតិ ។ ពាក្យថា ឯទីពឹងក្រៅពីនេះ ពុំមានទេ គឺទីពឹងដទៃ ឯទៀត អំពីទីពឹងនោះ មិនមាន មានតែទីពឹងនោះឯង ជាគុណដ៏ លើសផង ប្រសើរផុតផង វិសេសផង ជាប្រធានផង ខ្ពង់ខ្ពស់ផង ថ្លៃថ្លាផង ហេតុនោះ (ទ្រង់ត្រាស់ថា) ឯទីពឹងក្រៅពីនេះ ពុំមានទេ ។

[៣៧៧] អធិប្បាយពាក្យថា តថាគតហៅ នូវទីពឹងនោះថា និព្វាន ដោយប្រការដូច្នេះ សេចក្តីថា តណ្ហា លោកហៅថា វាន: បានដល់ រាគ: រាគ:ដ៏មានកម្លាំង ។ បេ ។ អភិជ្ឈា លោភ: អកុសលមូល ការលះបង់វាន: រម្ងាប់វាន: រលាស់ចោលវាន: ស្ងប់វាន: អមត-និព្វាន ។ ពាក្យថា ដោយប្រការដូច្នេះ ជាពាក្យភ្ជាប់បទ ។ បេ ។ ពាក្យថា ដោយប្រការដូច្នេះ នុ៎ះ ជាលំដាប់បទ ។ ពាក្យថា តថាគតហៅ គឺ តថាគត ពោល ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតហៅ នូវ ទីពឹងនោះ ថានិព្វាន ដោយប្រការដូច្នេះ ។

[៣៧៨] ពាក្យថា ជាទីអស់ជរានិងមច្ចុ គឺការលះបង់ ការរម្ងាប់ ការ រលាស់ ការស្ងប់រម្ងាប់ នូវជរានិងមរណៈ អមតនិព្វាន ហេតុនោះ (ទ្រង់ ត្រាស់ថា) ជាទីអស់ជរានិងមច្ចុ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អកិញ្ចនំ អនាទានំ ឯតំ ទីបំ អនាបរំ
និព្វានំ ឥតិ នំ ព្រូមិ ជរាមច្ចុបរិក្ខយន្តិ ។

[៣៧៩] ឯតទញ្ញាយ យេ សតា ទិដ្ឋធម្មាភិនិព្វុតា
ន តេ មារវសានុគា ន តេ មារស្ស បទ្ធគូ ។

[៣៨០] ឯតទញ្ញាយ យេ សតាតិ ឯតន្តិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ អញ្ញាយាតិ អញ្ញាយ ជានិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ អញ្ញាយ ជានិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ យេតិ អរហន្តោ ខីណាសវា ។ សតាតិ ចតូហិ ការណេហិ សតា កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តា សតា ។ បេ ។ តេន វុច្ចន្តិ សតាតិ ឯតទញ្ញាយ យេ សតា ។

ការមិនមានកង្វល់ ការមិនប្រកាន់មាំ នុ៎ះឯងជាទីពឹង ឯ
ទីពឹងក្រៅពីនេះ ពុំមានទេ តថាគតហៅ នូវទីពឹងនោះ
ថានិព្វាន ជាទីអស់ជរានិងមច្ចុ ដោយប្រការដូច្នេះ ។

[៣៧៩] ពួកជនណា ជាអ្នកមានសតិ ដឹងនូវទីពឹងនុ៎ះ មាន
ធម៌ឃើញហើយ ជាអ្នករំលត់ហើយ ពួកជននោះ ជាអ្នក
មិនលុះអំណាចមារ ពួកជននោះ ជាអ្នកមិនដល់ នូវភាព
ជាអ្នកបម្រើមារ ។

[៣៨០] ពាក្យថា ពួកជនណា ជាអ្នកមានសតិ ដឹងនូវទីពឹងនុ៎ះ ត្រង់ពាក្យថា ទីពឹងនុ៎ះ គឺអមតនិព្វាន បានដល់ការរម្ងាប់សង្ខារទាំងពួង ការលះឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ ពាក្យថា ដឹង គឺដឹងច្បាស់ ស្គាល់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា សង្ខារទាំងឡាយទាំងពួងមិនទៀង ។ បេ ។ ដឹងច្បាស់ ថ្លឹង ពិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដថា វត្ថុណាមួយ មានកិរិយាកើតឡើងជាធម្មតា វត្ថុទាំងអស់នោះ មានកិរិយារលត់វិញជាធម្មតា ។ ពាក្យថា ពួកជនណា បានដល់ពួកព្រះអរហន្តខីណាស្រព ។ ពាក្យថា មានសតិ គឺមានសតិដោយហេតុ ៤ គឺ កំពុងចម្រើន កាយេកាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថាមានសតិ ។ បេ ។ ហេតុនោះ ពួកនោះលោកហៅថា អ្នកមានសតិ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនណា មានសតិដឹងនូវទីពឹងនុ៎ះ ។

កប្បមាណវកប្បញ្ហានិទ្ទេសោ

[៣៨១] ទិដ្ឋធម្មាភិនិព្វុតាតិ ទិដ្ឋធម្មា(១) ញាតធម្មា តុលិតធម្មា តីរិតធម្មា វិភាវិតធម្មា វិភូតធម្មា ។ អភិនិព្វុតាតិ រាគស្ស និព្វាបិតត្តា និព្វុតា ទោសស្ស និព្វាបិតត្តា និព្វុតា មោហស្ស និព្វាបិតត្តា និព្វុតា កោធស្ស ឧបនាហស្ស ។ បេ ។ សព្វាកុសលាភិសង្ខារានំ និព្វាបិតត្តា និព្វុតា បដិប្បស្សទ្ធាតិ ទិដ្ឋធម្មាភិនិព្វុតា ។

[៣៨២] ន តេ មារវសានុគាតិ មារោតិ យោ សោ មារោ កណ្ហោ អធិបតិ អន្តគូ នមុចិ បមត្តពន្ធុ ។ ន តេ មារវសានុគាតិ ន តេ មារស្ស វសេ វត្តន្តិ នបិ មារោ តេសុ វសំ វត្តេតិ តេ មារញ្ច មារបក្ខញ្ច មារបាសញ្ច មារពឡិសញ្ច មារាមិសញ្ច មារវិសយញ្ច មារនិវាសញ្ច មារគោចរញ្ច មារពន្ធនញ្ច អភិភុយ្យ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទយិត្វា មទ្ទិត្វា វិហរន្តិ ឥរិយន្តិ វត្តន្តិ បាលេន្តិ យបេន្តិ យាបេន្តីតិ ន តេ មារវសានុគា ។

កប្បមាណវកប្បញ្ញានិទ្ទេស

[៣៨១] ពាក្យថា មានធម៌ឃើញហើយ ជាអ្នករំលត់ហើយ គឺមានធម៌ឃើញហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ពិចារណាហើយ មានធម៌យល់ច្បាស់ហើយ មានធម៌ប្រាកដហើយ ។ ពាក្យថា ជាអ្នករំលត់ គឺ ជាអ្នករំលត់ ព្រោះរំលត់រាគៈ ជាអ្នករំលត់ ព្រោះរំលត់ទោសៈ ជាអ្នករំលត់ ព្រោះរំលត់មោហៈ ជាអ្នករំលត់ ព្រោះរំលត់កោធៈ ឧបនាហៈ ។ បេ ។ ជាអ្នករំលត់ ព្រោះរំលត់អភិសង្ខារជាអកុសលទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា មានធម៌ឃើញហើយ ជាអ្នករំលត់ហើយ ។

[៣៨២] ពាក្យថា ពួកជននោះជាអ្នកមិនលុះក្នុងអំណាចមារ ត្រង់ពាក្យថា មារ បានដល់ អ្នកសម្លាប់ អ្នកមានធម៌ខ្មៅ អ្នកជាអធិបតី អ្នកដល់នូវទីបំផុត (អកុសលកម្ម) អ្នកមិនលែង អ្នកជាផៅពង្ស នៃបុគ្គលធ្វេសប្រហែស ។ ពាក្យថា ពួកជននោះ ជាអ្នកមិនលុះ អំណាចមារ បានសេចក្តីថា ពួកជននោះ ជាអ្នកមិនលុះក្នុងអំណាចមារ ទាំងមារក៏មិនញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងពួកជននោះបាន ពួកជននោះ គ្របសង្កត់ញ៉ាំញី រួបរឹត រារាំង ជិះជាន់ នូវមារផង ពួកមារផង អន្ទាក់មារផង សន្ទូចមារផង នុយមារផង វិស័យមារផង លំនៅមារផង គោចរមារផង ចំណងមារផង ហើយនៅ ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជននោះ ជាអ្នកមិនលុះក្នុងអំណាចមារ ។

[៣៨៣] ន តេ មារស្ស បទ្ធគូតិ ន តេ មារស្ស បទ្ធា បទ្ធចរា បរិចារិកា បេសិយា(១) តេ ពុទ្ធស្ស ភគវតោ បទ្ធា បទ្ធចរា បរិចារិកា បេសិយាតិ(២) ន តេ មារស្ស បទ្ធគូ ។ តេនាហ ភគវា

ឯតទញ្ញាយ យេ សតា ទិដ្ឋធម្មាភិនិព្វុតា
ន តេ មារវសានុគា ន តេ មារស្ស បទ្ធគូតិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

កប្បមាណវកប្បញ្ហានិទ្ទេសោ ទសមោ ។

---

១ ម. សិយាតិ ។

[៣៨៣] ពាក្យថា ពួកជននោះ ជាអ្នកមិនដល់នូវភាពជាអ្នកបម្រើមារ គឺពួកជននោះ មិនមែនជាអ្នកប្រើប្រាស់ ជាអ្នកប្រព្រឹត្តក្នុងការប្រើប្រាស់ ជាអ្នកបម្រើបម្រាស់ ជាអ្នកបម្រើ របស់មារទេ ពួកជននោះ ជាអ្នកប្រើប្រាស់ ប្រព្រឹត្តក្នុងការប្រើប្រាស់ ជាអ្នកបម្រើបម្រាស់ ជាអ្នកបម្រើ របស់ព្រះពុទ្ធមានជោគ ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជននោះជាអ្នកមិនដល់នូវភាពជាអ្នកបម្រើមារ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ពួកជនណា ជាអ្នកមានសតិ ដឹងនូវទីពឹងនុ៎ះ មានធម៌ឃើញ
ហើយ ជាអ្នករំលត់ហើយ ពួកជននោះ ជាអ្នកមិនលុះអំណាច
មារ ពួកជននោះ ជាអ្នកមិនដល់នូវភាពជាអ្នកបម្រើមារ ។

ដំណាលគ្នានឹងកាលជាទីចប់ នៃគាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ កប្បមាណវកប្បញ្ហានិទ្ទេស ទី ១០ ។

---

# ជតុកណ្ណិមាណវកប្បញ្ហានិទ្ទេសោ

[៣៨៤] សុត្វានហំ វីរ អកាមកាមឹ
(ឥច្චាយស្មា ជតុកណ្ណិ)
ឱឃាតិគំ បុដ្ឋុមកាមមាគមំ
សន្តិបទំ ព្រូហិ សហាជនេត្ត
យថាតច្ឆំ ភគវា ព្រូហិ មេ តំ ។

[៣៨៥] សុត្វានហំ វីរ អកាមកាមិន្តិ សុត្វា សុណិត្វា ឧគ្គហេត្វា ឧបធារេត្វា ឧបលក្ខយិត្វា ឥតិបិ សោ ភគវា អរហំ ។ បេ ។ ពុទ្ធោ ភគវាតិ សុត្វានហំ ។ វីរាតិ វីរោ ។ ភគវា វីរិយវាតិ វីរោ ។ បហូតិ វីរោ ។ វិសវីតិ វីរោ ។ អលមត្តោតិ វីរោ ។ សូរោ[១] វិក្កន្តោ អភិរុ អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោតិ វីរោ ។

---

១ ម. សូរោតិ វីរោ ។

# ជតុកណ្ណិមាណវកបញ្ហានិទ្ទេស

[៣៨៤] (ជតុកណ្ណិមាណវកទូលសួរដូច្នេះថា) បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮហើយ ទើបមក ដើម្បីទូលសួរព្រះអង្គ ទ្រង់មិនមានប្រាថ្នាក្នុងកាម ទ្រង់ឆ្លងឱឃៈ ទ្រង់មិនមានសេចក្តីប្រាថ្នា បពិត្រព្រះអង្គមានព្រះនេត្រកើតព្រមគ្នា សូមព្រះអង្គសម្តែងនូវសន្តិបទ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គ សម្តែងនូវសន្តិបទនោះ ដែលជាធម៌ពិតដល់ខ្ញុំព្រះអង្គ ឲ្យទាន ។

[៣៨៥] ពាក្យថា បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮហើយ...ទ្រង់មិនមានប្រាថ្នាក្នុងកាម អធិប្បាយថា ខ្ញុំព្រះអង្គឮ ស្តាប់ រៀន ចាំទុក កំណត់ទុកថា ព្រះមានព្រះភាគព្រះអង្គនោះ ជាព្រះអរហន្តព្រោះហេតុដូច្នេះខ្លះ ។ បេ ។ ព្រះអង្គត្រាស់ដឹងហើយ ព្រះអង្គមានចំណែកធម៌ ហេតុនោះ (លោកពោលថា)ខ្ញុំព្រះអង្គបានឮហើយ ។ ពាក្យថា បពិត្រព្រះអង្គជាវីរបុរស គឺព្រះពុទ្ធជាវីរជន ។ ព្រះមានព្រះភាគជាវីរបុរស ព្រោះទ្រង់មានសេចក្តីព្យាយាម ។ ជាវីរបុរស ព្រោះព្រះអង្គជាអ្នកសម្បូណ៌ដោយគុណ ។ ជាវីរបុរស ព្រោះព្រះអង្គញុាំងសេចក្តីព្យាយាមឲ្យកើត (ក្នុងសន្តានរបស់អ្នកដទៃ) ។ ជាវីរបុរស ព្រោះព្រះអង្គមានព្រះហឫទ័យអង់អាច ។ ជាវីរបុរស ព្រោះព្រះអង្គជាបុគ្គលក្លៀវក្លា មោះមុត មិនខ្លាច មិនរន្ធត់ មិនស្ញន់ មិនរត់ បានលះបង់នូវសេចក្តីខ្លាចនិងសេចក្តីញ័របំប្រប់ ប្រាសចាកសេចក្តីព្រឺព្រួចរោម ។

វិរតោ ឥធ សព្វបាបកេហិ
និរយទុក្ខមតិច្ច វីរិយវា សោ
សោ វីរិយវា បធានវា
វីរោ តាទិ បវុច្ចតេ តថត្តាតិ ។

សុត្វានហំ វីរ ។ អកាមកាមិន្តិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ ពុទ្ធស្ស ភគវតោ វត្ថុកាមា បរិញ្ញាតា កិលេសកាមា បហីនា វត្ថុកាមានំ បរិញ្ញាតត្តា កិលេសកាមានំ បហីនត្តា ភគវា ន កាមេ កាមេតិ កាមា សេដ្ឋាតិ ន កាមេ បមោទតិ ន កាមេ អភិជប្បតិ តស្មា ពុទ្ធោ អកាមោ និក្កាមោ ចត្តកាមោ វន្តកាមោ មុត្តកាមោ បហីនកាមោ បដិនិស្សដ្ឋកាមោ វីតរាគោ វិគតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ សុត្វានហំ វីរ អកាមកាមឹ ។

ព្រះខីណាស្រព វៀរហើយចាកបាបទាំងពួង ក្នុងលោកនេះ
មានកិរិយាអប់រំ ដោយសេចក្តីព្យាយាម កន្ទងនិរយទុក្ខ
លោកមានព្យាយាម មានសេចក្តីប្រឹងប្រែង មិនញាប់ញ័រ
មានសភាពដូច្នោះ ទើបលោកហៅថា វីរបុរស ។

ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮហើយ ។ ពាក្យថា កាម របស់បទថា ទ្រង់មិនមានប្រាថ្នាក្នុងកាម បើតាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះលោកហៅថា វត្ថុកាម ។ បេ ។ ទាំងនេះ លោកហៅថា កិលេសកាម ។ វត្ថុកាម ព្រះពុទ្ធមានជោគ ទ្រង់កំណត់ដឹងហើយ កិលេសកាម ព្រះអង្គលះបង់ហើយ ព្រោះទ្រង់កំណត់ដឹងវត្ថុកាម ព្រោះលះបង់កិលេសកាម ព្រះមានព្រះភាគ ទើបមិនត្រូវការនឹងកាមទាំងឡាយ មិនរីករាយរកកាមទាំងឡាយ មិនប្រាថ្នាកាមទាំងឡាយថា កាមទាំងឡាយប្រសើរបំផុត ហេតុនោះ ព្រះពុទ្ធឈ្មោះថា មិនប្រាថ្នាកាម ចេញចាកកាម លះចោលកាម ខ្ជាក់ចោលកាម លែងកាម លះកាម រលាស់ចោលកាម ប្រាសចាករាគៈ ឃ្លាតចាករាគៈ លះចោលរាគៈ ខ្ជាក់ចោលរាគៈ លែងរាគៈ លះរាគៈ រលាស់ចោលរាគៈ មិនមានប្រាថ្នា រលត់ទុក្ខ ត្រជាក់ សោយសុខ មានព្រះទ័យប្រសើរ ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮហើយ... ទ្រង់មិនមានប្រាថ្នាក្នុងកាម ។

ឥច្ចាយស្មា ជតុកណ្ណីតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ បទានុបុព្វតាមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។ ជតុកណ្ណីតិ តស្ស ព្រាហ្មណស្ស គោត្តំ ។ បេ ។ វោហារោតិ ឥច្ចាយស្មា ជតុកណ្ណី ។

[៣៨៦] ឱឃាតិគំ បុដ្ឋុមកាមមាគមន្តិ ឱឃាតិគន្តិ ឱឃាតិគំ ឱឃំ អតិក្កន្តំ សមតិក្កន្តំ វីតិវត្តន្តិ ឱឃាតិគំ ។ បុដ្ឋន្តិ បុដ្ឋុំ បុច្ឆិតុំ យាចិតុំ អជ្ឈេសិតុំ បសាទេតុំ ។ អកាមមាគមន្តិ អកាមំ បុដ្ឋុំ និក្កាមំ ចត្តកាមំ វន្តកាមំ មុត្តកាមំ បហីនកាមំ បដិនិស្សដ្ឋកាមំ វីតរាគំ ចត្តរាគំ វន្តរាគំ មុត្តរាគំ បហីនរាគំ បដិនិស្សដ្ឋរាគំ អាគម្ហា អាគតម្ហា ឧបាគតម្ហា សម្បត្តម្ហា តយា សទ្ធឹ សមាគតម្ហាតិ ឱឃាតិគំ បុដ្ឋុមកាមមាគមំ ។

ពាក្យថា ដូច្នេះ របស់បទថា ជតុកណ្ណិមានអាយុ ទូលសួរដូច្នេះ គឺជាពាក្យតបទ ។ បេ ។ ពាក្យថា ដូច្នេះ នុ៎ះ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ពាក្យថា មានអាយុ នុ៎ះ ជាពាក្យពោលដោយគោរព កោតក្រែង ។ ពាក្យថា ជតុកណ្ណិ គឺជាគោត្រ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) ជតុកណ្ណិ មានអាយុ ទូលសួរដូច្នេះ ។

[៣៨៦] អធិប្បាយពាក្យថា ទើបមក ដើម្បីទូលសួរព្រះអង្គទ្រង់ធ្ងន់ឱឃៈ ទ្រង់មិនមានសេចក្តីប្រាថ្នា ត្រង់ពាក្យថា ទ្រង់ធ្ងន់ឱឃៈ គឺទ្រង់កន្លងឱឃៈ ឈានកន្លង រំលងផុត ប្រព្រឹត្តកន្លងឱឃៈ ហេតុនោះ (លោកពោលថា) ទ្រង់ធ្ងន់ឱឃៈ ។ ពាក្យថា ដើម្បីទូលសួរ គឺដើម្បីសាកសួរ ដើម្បីដណ្តឹង ដើម្បីសូម ដើម្បីអារាធនា ដើម្បីឲ្យជ្រះថ្លា ។ ពាក្យថា ទើបមក...ទ្រង់មិនមានសេចក្តីប្រាថ្នា គឺយើងខ្ញុំមកហើយ ជាអ្នកមកហើយ ចូលមកហើយ សំដៅមកហើយ គឺជាអ្នកមកជួបនឹងព្រះអង្គ ដើម្បីទូលសួរព្រះអង្គ ទ្រង់មិនមានប្រាថ្នា ទ្រង់ចេញចាកកាម ទ្រង់ចោលកាម ទ្រង់ខ្ជាក់កាម ទ្រង់លែងកាម ទ្រង់លះកាម ទ្រង់រលាស់កាម ទ្រង់ប្រាសចាករាគៈ ទ្រង់ចោលរាគៈ ទ្រង់ខ្ជាក់រាគៈ ទ្រង់លែងរាគៈ ទ្រង់លះរាគៈ ទ្រង់រលាស់ចោលរាគៈហេតុនោះ(លោកទូលសួរថា) ខ្ញុំព្រះអង្គទើបមកដើម្បីទូលសួរព្រះអង្គទ្រង់ធ្ងន់ឱឃៈ ទ្រង់មិនមានសេចក្តីប្រាថ្នា ។

[៣៨៧] សន្តិបទំ ព្រូហិ សហាជនេត្តាតិ សន្តីតិ ឯកេន អាការេន សន្តិបិ សន្តិបទំបិ តញ្ញេវ អមតំ និព្វានំ[១] យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ វុត្តញ្ហេតំ ភគវតា សន្តមេតំ បទំ បណីតមេតំ បទំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ អថាបរេនាការេន យេ ធម្មា សន្តាធិគមាយ សន្តិផុសនាយ សច្ឆិកិរិយាយ សំវត្តន្តិ សេយ្យថីទំ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្តពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ឥមេ វុច្ចន្តិ សន្តិបទា ។ សន្តិបទំ តាណបទំ លេណបទំ សរណបទំ អភយបទំ អច្ចុតបទំ អមតបទំ និព្វានបទំ ព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហិ ។ សហាជនេត្តាតិ នេត្តំ វុច្ចតិ សព្វញ្ញុតញ្ញាណំ ។

---

១ ម. សន្តិបទន្តិ តំយេវ អមតំយេវ អមតំ និព្វានំ ។

[៣៨៧] អធិប្បាយពាក្យថា បពិត្រព្រះអង្គមានព្រះនេត្រកើតព្រមគ្នា សូមព្រះអង្គសម្តែងនូវសន្តិបទ ត្រង់ពាក្យថា សន្តិ សេចក្តីថា សន្តិក្តី សន្តិបទក្តី ដោយអាការតែមួយ គឺអមតនិព្វាននោះឯង បានដល់ការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ សមដូចពាក្យនេះដែលព្រះមានព្រះភាគត្រាស់ថា នុ៎ះ ជាចំណែកដ៏ស្ងប់ នុ៎ះជាចំណែកដ៏ឧត្តម គឺការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ ព្រះនិព្វាន ។ មួយទៀត បើដោយអាការដទៃ ពួកធម៌ណាប្រព្រឹត្តទៅ ដើម្បីកិរិយាបានសេចក្តីស្ងប់ ដើម្បីការពាល់ត្រូវសេចក្តីស្ងប់ ដើម្បីការធ្វើឲ្យជាក់លាក់ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គ ប្រកបដោយអង្គ ៨ ពួកធម៌នេះ លោកហៅថា សន្តិបទ ។ សូមព្រះអង្គ ពោល ប្រាប់ សម្តែង បញ្ញត្ត បើក បែក ធ្វើឲ្យរាក់ប្រកាស នូវសន្តិបទ ឧបាយជាគ្រឿងការពារ ឧបាយជាគ្រឿងជ្រក ឧបាយជាគ្រឿងពឹង ឧបាយមិនមានភ័យ ឧបាយមិនច្យុត ឧបាយមិនមានស្លាប់ ឧបាយគឺព្រះនិព្វាន ។ ពាក្យថា បពិត្រព្រះអង្គ ទ្រង់មានព្រះនេត្រកើតព្រមគ្នា គឺសព្វញ្ញុតញ្ញាណ លោកហៅថា ព្រះនេត្រ ។

៣០៧

ជតុកណ្ណិមាណវកប្បញ្ហានិទ្ទេសោ

ពុទ្ធស្ស ភគវតោ ធេតព្វ ជិនភាវេ ច ពោធិយា មូលេ អបុព្វំ អចរិមំ ឯកាស្មឹ ខណេ ឧប្បន្នោ តស្មា ពុទ្ធោ សហាជនេត្តោតិ សន្តិបទំ ព្រូហិ សហាជនេត្ត ។

[៣៨៨] យថាតច្ឆំ ភគវា ព្រូហិ មេ តន្តិ យថា-តច្ឆំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខា-រសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ ព្រូហិ មេ តន្តិ ព្រូហិ អាចិក្ខាហិ ។ បេ ។ បកាសេហីតិ យថា-តច្ឆំ ភគវា ព្រូហិ មេ តំ ។ តេនាហ សោ ព្រាហ្មណោ

ព្រះពុទ្ធមានព្រះភាគ មានព្រះនេត្រ និងភាពនៃព្រះជិនសិរី (អ្នកឈ្នះកិលេស) កើតឡើងមិនមុនមិនក្រោយ គឺក្នុងខណៈតែមួយ ទៀបគល់នៃពោធិព្រឹក្ស ហេតុនោះ ព្រះពុទ្ធឈ្មោះថា មានព្រះនេត្រកើតដំណាលគ្នា ហេតុនោះ (លោកទូលសួរថា) បពិត្រព្រះអង្គ មានព្រះនេត្រកើតព្រមគ្នា សូមព្រះអង្គ សម្តែងនូវសន្តិបទ ។

[៣៨៨] ពាក្យថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវសន្តិបទនោះ ដែលជាធម៌ពិត ដល់ខ្ញុំព្រះអង្គ សេចក្តីថា អមតនិព្វាន លោកហៅថា ធម៌ពិត បានខាង ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ។ ពាក្យថា សូមព្រះអង្គសម្តែង នូវសន្តិបទនោះ ដល់ខ្ញុំព្រះអង្គ គឺសូមព្រះអង្គ សម្តែង ប្រាប់ ។ បេ ។ ប្រកាស ហេតុនោះ (លោកពោលថា) បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែង នូវសន្តិបទនោះ ដែលជាធម៌ពិត ដល់ខ្ញុំព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

សុត្វានហំ វីរ អកាមកាមឹ
(ឥច្ចាយស្មា ជតុកណ្ណី)
ឱឃាតិគំ បុដ្ឋុមកាមមាគមំ
សន្តិបទំ ព្រូហិ សហាជនេត្ត
យថាតច្ឆំ ភគវា ព្រូហិ មេ តន្តិ ។
[៣៨៩] ភគវា ហិ កាមេ អភិភុយ្យ ឥរិយតិ
(អាទិច្ចោវ បឋវឹ តេជី តេជសា)
បរិត្តបញ្ញស្ស មេ ភូរិបញ្ញោ
អាចិក្ខ ធម្មំ យមហំ វិជញ្ញំ
ជាតិជរាយ ឥធ វិប្បហានំ ។

[៣៩០] ភគវា ហិ កាមេ អភិភុយ្យ ឥរិយតីតិ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ។ កាមេតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។

(ជតុកណ្ណីមានអាយុ ទូលសួរដូច្នេះថា) បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮហើយ ទើបមក ដើម្បីទូលសួរព្រះអង្គ ទ្រង់មិនមានប្រាថ្នាក្នុងកាម ទ្រង់ឆ្លងឱឃៈ ទ្រង់មិនមានសេចក្តីប្រាថ្នា បពិត្រព្រះអង្គ មានព្រះនេត្រកើតព្រមគ្នា សូមព្រះអង្គសម្តែងនូវសន្តិបទ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គ ស-ម្តែងនូវសន្តិបទនោះ ដែលជាធម៌ពិត ដល់ខ្ញុំព្រះអង្គឲ្យទាន ។

[៣៨៩] ព្រោះថា ព្រះមានព្រះភាគ ប្រព្រឹត្តគ្របសង្កត់នូវកាម ដូចព្រះអាទិត្យ មានតេជះ គ្របសង្កត់ នូវប្រឹថពីមណ្ឌល ដោយតេជះ សូមព្រះអង្គមានប្រាជ្ញាស្មើដោយផែនដី ត្រាស់ប្រាប់ធម៌ ដែលល្មមខ្ញុំព្រះអង្គយល់បាន ជាគ្រឿងលះបង់ស្រឡះនូវជាតិនិងជរា ក្នុងលោកនេះ ដល់ខ្ញុំព្រះអង្គជាអ្នកមានប្រាជ្ញាស្តួចស្តើង ឲ្យទាន ។

[៣៩០] អធិប្បាយពាក្យថា ព្រោះថា ព្រះមានព្រះភាគ ប្រព្រឹត្តគ្របសង្កត់ នូវកាម ត្រង់ពាក្យថា ព្រះមានព្រះភាគ នេះ គឺជាពាក្យពោលដោយសេចក្តីគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ។ ពាក្យថា កាម បើតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះ លោកហៅថា វត្ថុកាម ។ បេ ។ ទាំងនេះ លោកហៅថា កិលេសកាម ។

ភគវា វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហាយ អភិភុយ្យ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទយិត្វា មទ្ទិត្វា ចរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតីតិ ភគវា ហិ កាមេ អភិភុយ្យ ឥរិយតិ ។

[៣៩១] អាទិច្ចោវ បថវឹ តេជី តេជសាតិ អាទិច្ចោ វុច្ចតិ សុរិយោ ។ បថវី វុច្ចតិ ឱភា[១] ។ យថា សុរិយោ តេជី តេជសា តេជេន សមន្នាគតោ បថវឹ អភិភុយ្យ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទយិត្វា សន្តាបយិត្វា សព្វំ អាកាសគតំ[២] អភិវិហច្ច អន្ធការំ វិធមិត្វា អាលោកំ ទស្សេត្វា[៣] អាកាសេ អន្តលិក្ខេ គមនបថេ[៤] គច្ឆតិ ឯវមេវ ភគវា ញាណតេជី ញាណតេជេន សមន្នាគតោ សព្វំ អភិសង្ខារសមុទយំ ។ បេ ។ កិលេសតមំ អវិជ្ជន្ធការំ វិធមិត្វា ញាណាលោកំ ទស្សេត្វា វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហាយ អភិភុយ្យ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទយិត្វា មទ្ទិត្វា ចរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតីតិ អាទិច្ចោវ បថវឹ តេជី តេជសា ។

---

១ ម. ជគតិ ។ ២ ម. ឯត្តន្តរេ តមគតន្តិ ទិស្សតិ ។ ៣ ម. ទស្សយិត្វា ។ ៤ ម. វេគេន បថេ ។

ព្រះមានព្រះភាគ កំណាត់ដីងវត្ថុកាមទាំងឡាយ លះបង់ គ្របសង្កត់ បៀតបៀន រួបរឹត ឈ្វេចឈ្វី ញាំញី នូវកិលេសកាមទាំងឡាយហើយ ត្រាច់ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ លោកពោលថា ព្រោះថា ព្រះមានព្រះភាគ ប្រព្រឹត្តគ្របសង្កត់ នូវកាម ។

[៣៩១] ពាក្យថា ដូចព្រះអាទិត្យ មានតេជះ គ្របសង្កត់នូវប្រឹថពីមណ្ឌល ដោយតេជះ សេចក្តីថា សុរិយទេវបុត្រ លោកហៅថា ព្រះអាទិត្យ ។ ផែនដី លោកហៅថា ប្រឹថពី ។ សុរិយទេវបុត្រមានតេជះ ដោយតេជះ ប្រកបដោយតេជះ គ្របសង្កត់ បៀតបៀន រួបរឹត ឈ្វេចឈ្វី កម្តៅ នូវប្រឹថពី ញុំាងវត្ថុដែលតាំងនៅក្នុងអាកាសទាំងអស់ ឲ្យវិនាស កម្ចាត់បង់ងងឹត ធ្វុះនូវពន្លឺ ហើយចរទៅ ក្នុងផ្លូវជាទីចរទៅគឺអាកាសទទេ យ៉ាងណាមិញ ព្រះមានព្រះភាគមានតេជះគឺញាណ ប្រកបដោយតេជះគឺញាណ កម្ចាត់បង់នូវកិរិយាកើតឡើង នៃអភិសង្ខារទាំងពួង ។ បេ ។ នូវងងឹតគឺកិលេស នូវងងឹតគឺអវិជ្ជា សម្តែងនូវពន្លឺគឺញាណ កំណាត់ដីងវត្ថុកាមទាំងឡាយ លះបង់ គ្របសង្កត់ ឃាត់បង់ រួបរឹត ឈ្វេចឈ្វី ញាំញី នូវកិលេសកាមទាំងឡាយ ហើយត្រាច់ទៅ ប្រព្រឹត្តទៅ រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ (លោកពោលថា) ដូចព្រះអាទិត្យ មានតេជះ គ្របសង្កត់នូវប្រឹថពីមណ្ឌល ដោយតេជះ ។

[៣៩២] បរិត្តបញ្ញស្ស មេ ភូរិបញ្ញោតិ អហាមស្មិ បរិត្តប្បញ្ញោ ឱមកប្បញ្ញោ ជតុកប្បញ្ញោ ត្វំបិ មហាបញ្ញោ បុថុប្បញ្ញោ ហាសប្បញ្ញោ ជវនប្បញ្ញោ តិក្ខប្បញ្ញោ និព្វេធិកប្បញ្ញោ ភូរិ វុច្ចតិ បថវី តាយ បថវីសមាយ បញ្ញាយ វិបុលាយ វិត្ថតាយ សមន្នាគតោតិ បរិត្តបញ្ញស្ស មេ ភូរិបញ្ញោ ។

[៣៩៣] អាចិក្ខ ធម្មំ យមហំ វិជញ្ញន្តិ អាចិក្ខ ធម្មន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចត្តារោ សតិប្បដ្ឋានេ ។ បេ ។ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ អាចិក្ខ ធម្មំ ។ យមហំ វិជញ្ញន្តិ យមហំ ជានេយ្យំ វិជានេយ្យំ បដិវិជានេយ្យំ បដិវិជ្ឈេយ្យំ អធិគច្ឆេយ្យំ ផុសេយ្យំ សច្ឆិករេយ្យន្តិ អាចិក្ខ ធម្មំ យមហំ វិជញ្ញំ ។

[៣៩២] ពាក្យថា ព្រះអង្គមានប្រាជ្ញាស្មើដោយផែនដី...ដល់ខ្ញុំព្រះអង្គ ជាអ្នកមានប្រាជ្ញាស្ដួចស្ដើង គឺខ្ញុំព្រះអង្គជាបុគ្គលមានប្រាជ្ញាតិច មានប្រាជ្ញាឱនថយ មានប្រាជ្ញាជ្រោកជ្រាក ចំណែកខាងព្រះអង្គមានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញាលឿន មានប្រាជ្ញាមុត មានប្រាជ្ញាធ្លុះធ្លាយ ប្រឹថពី ហៅថា ផែនដី ព្រះអង្គប្រកបដោយប្រាជ្ញាស្មើដោយផែនដីនោះ ជាបញ្ញាដ៏ទូលាយ ជ្រាលជ្រៅ ហេតុនោះ (លោកពោលថា) ព្រះអង្គមានប្រាជ្ញាស្មើដោយផែនដី... ដល់ខ្ញុំព្រះអង្គ ជាអ្នកមានប្រាជ្ញាស្ដួចស្ដើង ។

[៣៩៣] ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ធម៌ ដែលល្មមខ្ញុំព្រះអង្គយល់បាន ត្រង់ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ធម៌ គឺសូមព្រះអង្គប្រាប់ សម្ដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស នូវព្រហ្មចរិយៈ មានលម្អក្នុងខាងដើម មានលម្អក្នុងកណ្ដាល មានលម្អក្នុងទីបំផុត ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ បរិបូណ៌ទាំងអស់ ដ៏បរិសុទ្ធ នូវសតិប្បដ្ឋាន ៤ ។ បេ ។ នូវព្រះនិព្វានផង នូវបដិបទា ជាដំណើរទៅ កាន់ព្រះនិព្វានផង ហេតុនោះ (លោកពោលថា) សូមព្រះអង្គត្រាស់ប្រាប់ ធម៌ ។ ពាក្យថា ដែលល្មមខ្ញុំព្រះអង្គយល់បាន គឺដែលល្មមខ្ញុំព្រះអង្គដឹង យល់ច្បាស់ ចាក់ធ្លុះ ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់បាន ហេតុនោះ (លោកពោលថា) សូមព្រះអង្គត្រាស់ប្រាប់ធម៌ ដែលល្មមខ្ញុំព្រះអង្គយល់បាន ។

៣១១

ជតុកណ្ណីមាណវកបញ្ហានិទ្ទេសោ

[៣៩៤] ជាតិជ្ជរាយ ឥធ វិប្បហានន្តិ ឥធេវ ជាតិយា ជរាមរណស្ស បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ ជាតិជ្ជរាយ ឥធ វិប្បហានំ ។ តេនាហ សោ ព្រាហ្មណោ

ភគវា ហិ កាមេ អភិភុយ្យ ឥរិយតិ
អាទិច្ចោវ បថវឹ តេជី តេជសា
បរិត្តបញ្ញស្ស មេ ភូរិបញ្ញោ
អាចិក្ខ ធម្មំ យមហំ វិជញ្ញំ
ជាតិជ្ជរាយ ឥធ វិប្បហានន្តិ ។

[៣៩៥] កាមេសុ វិនយ គេធំ (ជតុកណ្ណីតិ ភគវា)
នេក្ខម្មំ ទដ្ឋុ ខេមតោ
ឧគ្គហិតំ និរត្តំ វា
មា តេ វិជ្ជិត្ថ កិញ្ចនំ

[៣៩៦] កាមេសុ វិនយ គេធន្តិ កាមេសូតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។

[៣៩៤] ពាក្យថា ជាគ្រឿងលះបង់ស្រឡះ នូវជាតិ និងជរា ក្នុងលោកនេះ គឺជាគ្រឿងលះបង់ រម្ងាប់ រលាស់ចេញ ស្ងប់រម្ងាប់ នូវជាតិ ជរា និងមរណៈ ក្នុងលោកនេះឯង គឺអមតនិព្វាន ហេតុនោះ (លោកពោលថា) ជាគ្រឿងលះបង់ស្រឡះ នូវជាតិ និងជរា ក្នុងលោក នេះ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

ព្រោះថា ព្រះមានព្រះភាគ ប្រព្រឹត្តគ្របសង្កត់នូវកាម ដូច
ព្រះអាទិត្យ មានតេជះ គ្របសង្កត់ប្រឹថពីមណ្ឌល ដោយ
តេជះ សូមព្រះអង្គមានប្រាជ្ញាស្មើដោយផែនដី ត្រាស់ប្រាប់
ធម៌ ដែលល្មមខ្ញុំព្រះអង្គយល់បាន ជាគ្រឿងលះបង់ស្រឡះ
នូវជាតិនិងជរា ក្នុងលោកនេះ ដល់ខ្ញុំព្រះអង្គ ជាអ្នកមាន
ប្រាជ្ញាស្តួចស្តើង ឲ្យទាន ។

[៣៩៥] (ព្រះមានព្រះភាគត្រាស់ថា ម្នាលជតុកណ្ណិ) អ្នកចូរឃើញ
នូវនេក្ខម្មៈ ថាជាសេចក្តីក្សេម ហើយកម្ចាត់បង់នូវសេចក្តី
ប្រាថ្នា ក្នុងកាមទាំងឡាយចេញ ការប្រកាន់ក្តី ការ
ត្រូវរលាស់ចេញក្តី កង្វល់ក្តី កុំមានដល់អ្នកឡើយ ។

[៣៩៦] អធិប្បាយពាក្យថា កម្ចាត់បង់នូវសេចក្តីប្រាថ្នា ក្នុងកាមទាំង ឡាយចេញ ត្រង់ពាក្យថា ក្នុងកាមទាំងឡាយ គឺតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះ ហៅថា វត្ថុកាម ។ បេ ។

ឥមេ វុច្ចន្តិ កិលេសកាមា ។ គេធន្តិ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ កាមេសុ វិនយគេធន្តិ វិនយ បដិវិនយ បជហ វិនោទេហិ ព្យន្តីករោហិ អនភាវង្គមេហីតិ កាមេសុ វិនយ គេធំ ។ ជតុកណ្ណីតិ ភគវា តំ ព្រាហ្មណំ គោត្តេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ជតុកណ្ណីតិ ភគវា ។

[៣៩៧] នេក្ខម្មំ ទដ្ឋុ ខេមតោតិ នេក្ខម្មន្តិ សម្មាបដិបទំ អនុលោមប្បដិបទំ អបច្ចនីកប្បដិបទំ អន្វត្ថប្បដិបទំ ធម្មានុធម្មប្បដិបទំ សីលេសុ បរិបូរិការិតំ ឥន្ទ្រិយេសុ គុត្តទ្វារតំ ភោជនេ មត្តញ្ញុតំ ជាគរិយានុយោគំ សតិសម្បជញ្ញំ ចត្តារោ សតិប្បដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ

ទាំងនេះហៅថា កិលេសកាម ។ ពាក្យថា សេចក្តីប្រាថ្នា សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានដល់រាគៈ រាគៈមានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា កម្ចាត់នូវសេចក្តីប្រាថ្នា ក្នុងកាមទាំងឡាយចេញ គឺកម្ចាត់ កម្ចាត់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន ហេតុនោះ (ទ្រង់ត្រាស់ថា) កម្ចាត់បង់នូវសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយចេញ ។ ពាក្យថា ម្នាលជតុកណ្ណិ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះ តាមគោត្រ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញត្តថា ព្រះមានព្រះភាគនេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ(មានពាក្យថា)ព្រះមានព្រះភាគត្រាស់ថា ម្នាលជតុកណ្ណិ ។

[៣៩៧]ពាក្យថា នេក្ខម្មៈ របស់បទថា អ្នកចូរឃើញនូវនេក្ខម្មៈ ថាជាសេចក្តីក្សេម គឺអ្នកចូរឃើញ យល់ ថ្លឹង ពិចារណា ឈ្វេងយល់ ធ្វើឲ្យប្រាកដ នូវសេចក្តីប្រតិបត្តិដោយប្រពៃ សេចក្តីប្រតិបត្តិដ៏សមគួរ សេចក្តីប្រតិបត្តិជាសឹកសត្រូវ សេចក្តីប្រតិបត្តិសមគួរដល់ប្រយោជន៍ សេចក្តីប្រតិបត្តិធម៌សមគួរដល់ធម៌ ការធ្វើឲ្យពេញលេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭក សតិនិងសម្បជញ្ញៈ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ព្រះនិព្វាន និងបដិបទាជាដំណើរទៅកាន់ព្រះនិព្វាន

ខេមតោ តាណតោ លេណតោ សរណតោ សរណី-
ភូតតោ អភយតោ អច្ចុតតោ អមតតោ និព្វានតោ
ទដ្ឋុំ បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ
កត្វាតិ នេក្ខម្មំ ទដ្ឋុ ខេមតោ ។

[៣៩៨] ឧគ្គហិតំ និរត្តំ វាតិ ឧគ្គហិតន្តិ តណ្ហា-
វសេន ទិដ្ឋិវសេន គហិតំ បរាមដ្ឋំ អភិនិវិដ្ឋំ អ-
ជ្ឈោសិតំ អធិមុត្តំ ។ និរត្តំ វាតិ និរត្តំ វា មុញ្ចិ-
តព្វំ បជហិតព្វំ វិនោទេតព្វំ ព្យន្តីកាតព្វំ អនភាវង្គ-
មេតព្វន្តិ ឧគ្គហិតំ និរត្តំ វា ។

[៣៩៩] មា តេ វិជ្ជិត្ថ កិញ្ចនន្តិ រាគកិញ្ចនំ
ទោសកិញ្ចនំ មោហកិញ្ចនំ មានកិញ្ចនំ ទិដ្ឋិកិ-
ញ្ចនំ កិលេសកិញ្ចនំ ទុច្ចរិតកិញ្ចនំ ឥទំ កិញ្ចនំ[១]
តុយ្ហំ មា វិជ្ជិត្ថ មា បវិជ្ជិត្ថ មា សំវិជ្ជិត្ថ បជហ
វិនោទេហិ ព្យន្តីករោហិ អនភាវង្គមេហីតិ មា តេ
វិជ្ជិត្ថ កិញ្ចនំ ។ តេនាហ ភគវា

---

១ ម. ឥមេ កិញ្ចនា ។

ថាជាសេចក្តីក្សេម ថាជាទីការពារ ថាជាទីជ្រក ថាជាទីពឹង ថាជាទីពំនាក់ ថាជាទីមិនមានភ័យ ថាជាទីមិនច្យុត ថាជាទីមិនមានសេចក្តីស្លាប់ ថាជាទីចេញចាកវាន: ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកចូរឃើញនូវនេក្ខម្ម: ថាជាសេចក្តីក្សេម ។

[៣៩៨] ពាក្យថា ការប្រកាន់ របស់បទថា ការប្រកាន់ក្តី ការត្រូវរលាស់ចេញក្តី គឺ ការប្រកាន់ ការស្ទាបអង្អែល ការជាប់ចំពាក់ ការជ្រុលជ្រប់ ការចុះស៊ប់ ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ ។ ពាក្យថា ការត្រូវរលាស់ចេញ គឺ ការត្រូវលះលែង ការត្រូវដកចេញ ការត្រូវលះបង់ ការត្រូវធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការប្រកាន់ក្តី ការត្រូវរលាស់ចេញក្តី ។

[៣៩៩] ពាក្យថា កង្វល់ក្តី កុំមានដល់អ្នកឡើយ សេចក្តីថា កង្វល់គឺរាគ: កង្វល់គឺទោស: កង្វល់គឺមោហ: កង្វល់គឺមានះ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត កង្វល់នេះ កុំមាន កុំជិតដល់ កុំមានប្រាកដដល់អ្នក គឺថា អ្នកចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន ហេតុនោះ (ទ្រង់ត្រាស់ថា) កង្វល់ក្តី កុំមានដល់អ្នកឡើយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

កាមេសុ វិនយ គេធំ
(ជតុកណ្ណីតិ ភគវា)
នេក្ខម្មំ ទដ្ឋុ ខេមតោ
ឧគ្គហិតំ និរត្តំ វា
មា តេ វិជ្ជិត្ថ កិញ្ចនន្តិ ។

[៤០០] យំ បុព្វេ តំ វិសោសេហិ បច្ឆា តេ មាហុ កិញ្ចនំ មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសិ ។

[៤០១] យំ បុព្វេ តំ វិសោសេហីតិ អតីតេ សង្ខារេ អារព្ភ យេ កិលេសា ឧប្បជ្ជេយ្យុំ តេ កិលេសេ សោសេហិ វិសោសេហិ សុក្ខាបេហិ វិសុក្ខាបេហិ អពីជំ ករោហិ បជហ វិនោទេហិ ព្យន្តីករោហិ អនភាវង្គមេហីតិ ឯវម្បិ យំ បុព្វេ តំ វិសោសេហិ ។ អថវា យេ អតីតា កម្មាភិសង្ខារា អវិបក្កវិបាកា តេ កម្មាភិសង្ខារេ សោសេហិ វិសោសេហិ សុក្ខាបេហិ វិសុក្ខាបេហិ អពីជំ ករោហិ បជហ វិនោទេហិ ព្យន្តីករោហិ អនភាវង្គមេហីតិ

*(ព្រះមានព្រះភាគត្រាស់ថា ម្នាលជតុកណ្ណិ) អ្នកចូរឃើញនូវនេក្ខម្មៈ ថាជាសេចក្តីក្សេម ហើយកម្ចាត់បង់នូវសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយចេញ មួយទៀត ការប្រកាន់ក្តី ការត្រូវលះចេញក្តី កង្វល់ក្តី កុំមានដល់អ្នកឡើយ ។*

[៤០០] *កិលេសជាតណា (ធ្លាប់មានហើយ) ក្នុងកាលមុន អ្នកចូរញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួតទៅ កង្វល់ខាងក្រោយ កុំមានដល់អ្នកឡើយ បើអ្នកនឹងមិនកាន់យកខន្ធជាកណ្តាលទេ អ្នកនឹងជាបុគ្គលស្ងប់ ត្រាច់ទៅ ។*

[៤០១] *ពាក្យថា កិលេសជាតណា (ធ្លាប់មានហើយ) ក្នុងកាលមុន អ្នកចូរញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួតទៅ គឺពួកកិលេសណា គប្បីកើត ព្រោះប្រារព្ធសង្ខារទាំងឡាយជាអតីត អ្នកចូរញ៉ាំងកិលេសទាំងនោះ ឲ្យរីង ឲ្យស្ងួត ឲ្យខះ ឲ្យហួតហែង ចូរធ្វើកុំឲ្យមានពូជ ចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន ហេតុនោះ (ទ្រង់ត្រាស់ថា) កិលេសជាតណា (ធ្លាប់មានហើយ) ក្នុងកាលមុន អ្នកចូរញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួតទៅ យ៉ាងនេះក៏មាន ។ មួយទៀត ពួកកម្មាភិសង្ខារ ណា ជាអតីត មានវិបាកចាស់ក្អាហើយ អ្នកចូរញ៉ាំងកម្មាភិសង្ខារទាំងនោះ ឲ្យរីង ឲ្យស្ងួត ឲ្យខះ ឲ្យហួតហែង ចូរធ្វើកុំឲ្យមានពូជ ចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន*

ឯវម្បិ យំ បុព្វេ តំ វិសោសេហិ ។

[៤០២] បច្ឆា តេ មាហុ កិញ្ចនន្តិ បច្ឆា វុច្ចតិ អនាគតំ កិញ្ចនំ អនាគតេ សង្ខារេ អារព្ភ រាគ-កិញ្ចនំ ទោសកិញ្ចនំ មោហកិញ្ចនំ មានកិញ្ចនំ ទិដ្ឋិកិញ្ចនំ កិលេសកិញ្ចនំ ទុច្ចរិតកិញ្ចនំ ឥទំ កិញ្ចនំ តុយ្ហំ មា អាហុ មា អហោសិ មា ជនេហិ មា សញ្ជនេហិ មា និព្វត្តេហិ បជហ វិនោទេហិ ព្យន្តី-ករោហិ អនភាវង្គមេហីតិ បច្ឆា តេ មាហុ កិញ្ចនំ ។

[៤០៣] មជ្ឈេ ចេ នោ គហេស្សសីតិ មជ្ឈេ វុច្ចតិ បច្ចុប្បន្នំ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណំ បច្ចុប្បន្នេ សង្ខារេ តណ្ហាវសេន ទិដ្ឋិវសេន នោ គហេស្សសិ ន គណ្ហិស្សសិ ន បរាមសិស្សសិ ន នន្ទិស្សសិ ន អជ្ឈោសិស្សសិ អភិនន្ទនំ[១] អជ្ឈោ-សានំ គាហំ បរាមាសំ អភិនិវេសំ បជហិស្សសិ វិនោទេស្សសិ ព្យន្តីករិស្សសិ អនភាវង្គមេស្សសីតិ មជ្ឈេ ចេ នោ គហេស្សសិ ។

១ ម. ឯត្តន្តរេ អតិវទេនន្តិ ទិស្សតិ ។

ហេតុនោះ (ទ្រង់ត្រាស់ថា) កិលេសជាតណា (ធ្លាប់មានហើយ) ក្នុងកាលមុន អ្នកចូរញុំាងកិលេសជាតនោះ ឲ្យរីងស្ងួតទៅ យ៉ាងនេះក៏មាន ។

[៤០២] ពាក្យថា កង្វល់ខាងក្រោយកុំមានដល់អ្នកឡើយ សេចក្តីថា កង្វល់ជាអនាគត ហៅថា កង្វល់ខាងក្រោយ បានដល់កង្វល់គឺរាគៈ កង្វល់គឺទោសៈ កង្វល់គឺមោហៈ កង្វល់គឺមានះ កង្វល់គឺទិដ្ឋិ កង្វល់គឺកិលេស កង្វល់គឺទុច្ចរិត ព្រោះប្រារព្ធសង្ខារទាំងឡាយជាអនាគត កង្វល់នេះ កុំមាន កុំឲ្យកើតមាន ដល់អ្នក អ្នកចូរកុំញុំាងកង្វល់ឲ្យកើត កុំបង្កើ កុំឲ្យលូតលាស់ឡើង ចូរលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន ហេតុនោះ (ទ្រង់ត្រាស់ថា) កង្វល់ខាងក្រោយកុំមានដល់អ្នកឡើយ ។

[៤០៣] ពាក្យថា បើអ្នកនឹងមិនកាន់យក ខន្ធជាកណ្តាលទេ សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាបច្ចុប្បន្នលោកហៅថា ខន្ធជាកណ្តាល អ្នកនឹងមិនកាន់យក មិនចាប់ មិនស្ទាបអង្អែល មិនរីករាយ មិនជ្រុលជ្រប់ ចំពោះសង្ខារទាំងឡាយ ជាបច្ចុប្បន្ន ដោយអំណាចតណ្ហា ដោយអំណាចទិដ្ឋិ គឺថាបើអ្នកនឹងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវសេចក្តីរីករាយ ការជ្រុលជ្រប់ ការប្រកាន់ ការស្ទាបអង្អែល ការជាប់ចំពាក់ ហេតុនោះ (ទ្រង់ត្រាស់ថា) បើអ្នកនឹងមិនកាន់យកខន្ធជាកណ្តាលទេ ។

[៤០៤] ឧបសន្តោ ចរិស្សសីតិ រាគស្ស សន្តត្តា ឧបសន្តោ ទោសស្ស សន្តត្តា ឧបសន្តោ មោហស្ស សន្តត្តា ឧបសន្តោ កោធស្ស ឧបនាហស្ស ។ បេ ។ សព្វាកុសលាភិសង្ខារានំ សន្តត្តា សមិតត្តា វូបសមិតត្តា វិជ្ឈាតត្តា និព្វាបិតត្តា វិគតត្តា បដិប្បស្សទ្ធត្តា សន្តោ ឧបសន្តោ វូបសន្តោ និព្វុតោ បដិប្បស្សទ្ធោ ចរិស្សសិ វិចរិស្សសិ វត្តិស្សសិ ចាលេស្សសិ យបេស្សសិ យាបេស្សសីតិ ឧបសន្តោ ចរិស្សសិ ។ តេនាហ ភគវា

យំ បុព្វេ តំ វិសោសេហិ បច្ឆា តេ មាហុ កិញ្ចនំ
មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសីតិ ។

[៤០៥] សព្វសោ នាមរូបស្មឹ វីតគេធស្ស ព្រាហ្មណ
អាសវស្ស ន វិជ្ជន្តិ យេហិ មច្ចុវសំ វជេ ។

[៤០៦] សព្វសោ នាមរូបស្មឹ វីតគេធស្ស ព្រាហ្មណាតិ សព្វសោតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ

[៤០៤] ពាក្យថា អ្នកនឹងជាបុគ្គលស្ងប់ត្រាច់ទៅ គឺឈ្មោះថាអ្នកស្ងប់ ព្រោះស្ងប់រាគៈ ឈ្មោះថាអ្នកស្ងប់ ព្រោះស្ងប់ទោសៈ ឈ្មោះថាអ្នកស្ងប់ ព្រោះស្ងប់មោហៈ ឈ្មោះថាអ្នកស្ងប់ ស្ងប់រម្ងាប់ រម្ងាប់សូន្យ រលត់ រសាយ រលាយ ព្រោះស្ងប់ រម្ងាប់ រម្ងាប់សូន្យ ផុតរំលត់ ទៅប្រាស រសាយ រលាយ នូវកោធៈ ឧបនាហៈ ។ បេ ។ អភិសង្ខារជាអកុសលទាំងពួង ហើយនឹងត្រាច់ទៅ ត្រាច់ទៅផ្សេងៗ ប្រព្រឹត្ត រក្សា យាត្រា យាត្រាទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកនឹងជាបុគ្គលស្ងប់ត្រាច់ទៅ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

កិលេសជាតណា (ធ្លាប់មានហើយ) ក្នុងកាលមុន អ្នកចូរ
ញ៉ាំងកិលេសជាតនោះ ឲ្យរីងស្ងួតទៅ កង្វល់ខាងក្រោយ
កុំមានដល់អ្នកឡើយ បើអ្នកនឹងមិនកាន់យកខន្ធជាកណ្តាល
ទេ អ្នកនឹងជាបុគ្គលស្ងប់ ត្រាច់ទៅ ។

[៤០៥] ម្នាលព្រាហ្មណ៍ បុគ្គលតែងលុះអំណាចមច្ចុ ដោយអាសវៈ
ទាំងឡាយណា អាសវៈ (ទាំងនោះ) របស់បុគ្គលដែលប្រាស
ចាកតម្រេកក្នុងនាមរូបដោយប្រការទាំងពួងនោះ មិនមានទេ ។

[៤០៦] អធិប្បាយពាក្យថា ម្នាលព្រាហ្មណ៍...ដែលប្រាសចាកតម្រេកក្នុងនាមរូប ដោយប្រការទាំងពួង ត្រង់ពាក្យថា ដោយប្រការទាំងពួង គឺ គ្រប់ទាំងអស់ សព្វទាំងអស់ មិនមានសល់ ឥតសេសសល់

បរិយាទាយវចនមេតំ សព្វសោតិ ។ នាមន្តិ ចត្តារោ អរូបិនោ ខន្ធា ។ រូបន្តិ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ គេធោ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ សព្វសោ នាមរូបស្មឹ វីតគេធស្ស ព្រាហ្មណាតិ សព្វសោ នាមរូបស្មឹ វីតគេធស្ស វិគតគេធស្ស ចត្តគេធស្ស វន្តគេធស្ស មុត្តគេធស្ស បហីនគេធស្ស បដិនិស្សដ្ឋគេធស្ស វីតរាគស្ស វិគតរាគស្ស ចត្តរាគស្ស វន្តរាគស្ស មុត្តរាគស្ស បហីនរាគស្ស បដិនិស្សដ្ឋរាគស្សាតិ សព្វសោ នាមរូបស្មឹ វីតគេធស្ស ព្រាហ្មណ ។

[៤០៧] អាសវស្ស ន វិជ្ជន្តីតិ អាសវាតិ ចត្តារោ អាសវា កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។ អស្សាតិ អរហតោ ខីណាសវស្ស ។ ន វិជ្ជន្តីតិ ឥមេ អាសវា តស្ស នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ អាសវស្ស ន វិជ្ជន្តិ ។

ពាក្យថា ដោយប្រការទាំងពួងនុ៎ះ ជាពាក្យប្រមូល ។ ពាក្យថា នាម បានដល់អរូបក្ខន្ធ ៤ ។ ពាក្យថា រូប បានដល់មហាភូតរូប ៤ និងឧបាទាយ-រូបរបស់មហាភូតរូប ៤ ។ តណ្ហាលោកហៅថា តម្រេក បានដល់រាគៈ រាគៈមានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ម្នាលព្រាហ្មណ៍... ដែលប្រាសចាកតម្រេកក្នុងនាមរូប ដោយប្រការទាំងពួង បានសេចក្តីថា ប្រាសចាកប្រាថ្នា ឃ្លាតចាកប្រាថ្នា ចោលប្រាថ្នា ខ្ជាក់ប្រាថ្នា លែងប្រាថ្នា លះប្រាថ្នា រលាស់ប្រាថ្នា គឺជាអ្នកប្រាសចាករាគៈ ឃ្លាតចាករាគៈ ចោលរាគៈ ខ្ជាក់រាគៈ លែងរាគៈ លះរាគៈ រលាស់រាគៈ ក្នុងនាមរូប ដោយប្រការទាំងពួង ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលព្រាហ្មណ៍... ដែលប្រាសចាកតម្រេក ក្នុងនាមរូប ដោយប្រការទាំងពួង ។

[៤០៧] អធិប្បាយពាក្យថា អាសវៈទាំងឡាយ របស់បុគ្គលនោះ មិនមានទេ ត្រង់ពាក្យថា អាសវៈ បានដល់ អាសវៈ ៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។ ពាក្យថា របស់បុគ្គលនោះ គឺរបស់ព្រះអរហន្តខីណាស្រព ។ ពាក្យថា មិនមាន គឺអាសវៈទាំងនេះ របស់ព្រះអរហន្តនោះ មិនមាន ឥតមាន លែងមាន គឺលោកមិនបាន លោកលះបង់ ផ្តាច់ផ្តិល រម្ងាប់ ធ្វើឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) អាសវៈទាំងឡាយ របស់បុគ្គលនោះ មិនមានទេ ។

[៤០៨] យេហិ មច្ចុវសំ វជេតិ យេហិ អាសវេហិ មច្ចុនោ វា វសំ គច្ឆេយ្យ មរណស្ស វា វសំ គច្ឆេយ្យ មារបក្ខស្ស វា វសំ គច្ឆេយ្យ តេ អាសវា អស្ស នត្ថិ ន សន្តិ ន សំវិជ្ជន្តិ នុបលព្ភន្តិ បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍាតិ យេហិ មច្ចុវសំ វជេ ។ តេនាហ ភគវា

សព្វសោ នាមរូបស្មឹ វីតគេធស្ស ព្រាហ្មណ
អាសវស្ស ន វិជ្ជន្តិ យេហិ មច្ចុវសំ វជេតិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ជតុកណ្ណីមាណវកប្បញ្ហានិទ្ទេសោ ឯកាទសមោ ។

---

[៤០៨] ពាក្យថា បុគ្គលតែងលុះអំណាចមច្ចុ ដោយអាសវៈទាំងឡាយណា សេចក្តីថា បុគ្គលតែងលុះអំណាចមច្ចុក្តី លុះអំណាចមរណៈក្តី លុះអំណាចមារក្តី ដោយអាសវៈទាំងឡាយណា អាសវៈទាំងនោះរបស់ព្រះអរហន្តនោះ មិនមាន ឥតមាន លែងមាន គឺលោកមិនបាន លោកលះបង់ ផ្តាច់ផ្តិល ឲ្យស្ងប់ រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលតែងលុះអំណាចមច្ចុ ដោយអាសវៈទាំងឡាយ ណា ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

ម្នាលព្រាហ្មណ៍ បុគ្គលតែងលុះអំណាចមច្ចុ ដោយអាសវៈ
ទាំងឡាយណា អាសវៈ (ទាំងនោះ) របស់បុគ្គល ដែល
ប្រាសចាកតម្រេក ក្នុងនាមរូប ដោយប្រការទាំងពួង នោះ
មិនមានទេ ។

ដំណាលគ្នានឹងកាលជាទីចប់នៃគាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។

ចប់ ជតុកណ្ណិមាណវកបញ្ហានិទ្ទេស ទី ១១ ។

---

# ភទ្រាវុធមាណវកប្បញ្ហានិទ្ទេសោ

[៤០៩] ឱកញ្ជហំ តណ្ហាច្ឆិទំ អនេជំ

(ឥច្ចាយស្មា ភទ្រាវុធោ)

នន្ទិញ្ជហំ ឱឃតិណ្ណំ វិមុត្តំ

កប្បញ្ជហំ អភិយាចេ សុមេធំ

សុត្វាន នាគស្ស អបនមិស្សន្តិ ឥតោ ។

[៤១០] ឱកញ្ជហំ តណ្ហាច្ឆិទំ អនេជន្តិ ឱកញ្ជហន្តិ រូបធាតុយា យោ ឆន្ទោ យោ រាគោ យា នន្ទិ យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ ឱកញ្ជហោ ។ វេទនាធាតុយា សញ្ញាធាតុយា សង្ខារធាតុយា វិញ្ញាណធាតុយា

# ភទ្រាវុធមាណវកប្បញ្ហានិទ្ទេស

[៦០៩] (ភទ្រាវុធមានអាយុ ពោលដូច្នេះថា) ខ្ញុំព្រះអង្គសូមអារាធនាព្រះមានព្រះភាគ ព្រះអង្គលះបង់ ទីលំនៅ កាត់បង់តណ្ហា មិនមានការញាប់ញ័រ លះបង់សេចក្តីត្រេកអរ ឆ្លងអន្លង់ មានព្រះទ័យរួចស្រឡះ លះបង់គ្រឿងកំណត់ មានបញ្ញាល្អ ពួកជនបានស្តាប់ (ព្រះតម្រាស់) របស់ព្រះអង្គ ជាព្រះពុទ្ធនាគហើយ នឹងចៀសចេញអំពីទីនេះ ។

[៦១០] អធិប្បាយពាក្យថា ព្រះអង្គលះបង់ទីលំនៅ កាត់បង់តណ្ហា មិនមានការញាប់ញ័រ ត្រង់ពាក្យថា ព្រះអង្គលះបង់ទីលំនៅ សេចក្តីថា ឆន្ទៈណា រាគៈណា នន្ទិណា តណ្ហាណា ការចូលទៅជិតប្រកាន់ជាគ្រឿងតាំងស៊ប់របស់ចិត្ត ជាទីមកដេកត្រាំជាប់ណា ក្នុងរូបធាតុ កិលេសទាំងនោះ ព្រះពុទ្ធមានជោគលះបង់ ផ្តាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព មិនឲ្យកើតឡើងជាធម្មតាតទៅ ហេតុនោះ ព្រះពុទ្ធឈ្មោះថាលះបង់ទីលំនៅ ។ ឆន្ទៈណា រាគៈណា នន្ទិណា តណ្ហាណា ការចូលទៅជិតប្រកាន់ ជាគ្រឿងតាំងស៊ប់របស់ចិត្ត ជាទីមកដេកត្រាំជាប់ណា ក្នុងវេទនាធាតុ សញ្ញាធាតុ សង្ខារធាតុ វិញ្ញាណធាតុ

យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា យេ ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ ឱកញ្ជហោ ។ តណ្ហាច្ឆិទន្តិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា សា តណ្ហា ពុទ្ធស្ស ភគវតោ ឆិន្នា ឧច្ឆិន្នា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា តស្មា ពុទ្ធោ តណ្ហាច្ឆិទោ ។ អនេជន្តិ ឯជា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ សា ឯជា តណ្ហា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អនេជោ ។ ឯជាយ បហីនត្តា អនេជោ ។ ភគវា លាភេបិ ន ឥញ្ជតិ អលាភេបិ ន ឥញ្ជតិ យសេបិ ន ឥញ្ជតិ អយសេបិ ន ឥញ្ជតិ បសំសាយ ន ឥញ្ជតិ និន្ទាយបិ ន ឥញ្ជតិ សុខេបិ ន ឥញ្ជតិ ទុក្ខេបិ ន ឥញ្ជតិ

កិលេសទាំងនោះ ព្រះពុទ្ធមានព្រះភាគលះបង់ ផ្តាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព មិនឲ្យកើតឡើងជាធម្មតាតទៅ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាលះបង់ទីលំនៅ ។ ពាក្យថាតណ្ហា របស់បទថា កាត់បង់តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា តណ្ហានោះ ព្រះពុទ្ធមានព្រះភាគកាត់បង់ ផ្តាច់បង់ ផ្តិលផ្តាច់ រម្ងាប់ ឲ្យស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ព្រះពុទ្ធឈ្មោះថាកាត់បង់តណ្ហា ។ ពាក្យថា មិនមានការញាប់ញ័រ សេចក្តីថា តណ្ហា ហៅថា ការញាប់ញ័រ បានដល់រាគៈ រាគៈមានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ការញាប់ញ័រ គឺតណ្ហានោះ ព្រះពុទ្ធមានជោគ លះបង់ ផ្តាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ដល់នូវការមិនមានបែបភាព មិនឲ្យកើតឡើងជាធម្មតាតទៅ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានការញាប់ញ័រ ។ ព្រះពុទ្ធឈ្មោះថាមិនមានការញាប់ញ័រ ព្រោះទ្រង់លះបង់ការញាប់ញ័រហើយ ។ ព្រះមានព្រះភាគមិនរំភើប ក្នុងលាភផង មិនរំភើបក្នុងអលាភផង មិនរំភើបក្នុងយសផង មិនរំភើបក្នុងអយសផង មិនរំភើបក្នុងបសំសាផង មិនរំភើបក្នុងនិន្ទាផង មិនរំភើបក្នុងសុខផង មិនរំភើប មិនកម្រើក មិនញាប់ញ័រ មិនរញ្ជួយ មិនកក្រើក ក្នុងទុក្ខផង

ន ចលតិ ន វេធតិ ន បវេធតិ ន សម្បវេធតិ តស្មា ពុទ្ធោ អនេជោតិ ឱកញ្ជហំ តណ្ហាច្ឆិទំ អនេជំ ។ ឥច្ចាយស្មា ភទ្រាវុធោតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ បទានុបុព្វតាមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។ ភទ្រាវុធោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្មា ភទ្រាវុធោ ។

[៤១១] នន្ទិញ្ជហំ ឱឃតិណ្ណំ វិមុត្តន្តិ នន្ទិ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ សា នន្ទិ តណ្ហា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ នន្ទិញ្ជហោ ។ ឱឃតិណ្ណន្តិ ភគវា កាមោឃំ តិណ្ណោ ភវោឃំ តិណ្ណោ ទិដ្ឋោឃំ តិណ្ណោ អវិជ្ជោឃំ តិណ្ណោ សព្វំ សំសារបថំ តិណ្ណោ ឧត្តិណ្ណោ និត្តិណ្ណោ អតិក្កន្តោ សមតិក្កន្តោ វីតិវត្តោ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។

ហេតុនោះ ព្រះពុទ្ធ ឈ្មោះថា មិនមានការញាប់ញ័រ ហេតុនោះ (លោកពោលថា) ព្រះអង្គលះបង់លំនៅ កាត់បង់តណ្ហា មិនមានការញាប់ញ័រ ។ ពាក្យថា ដូច្នេះ របស់បទថា ភទ្រាវុធមានអាយុ ពោលដូច្នេះ ជាពាក្យតបទ ។ បេ ។ ពាក្យថា ដូច្នេះ នុ៎ះ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុ នុ៎ះ ជាពាក្យពោលដោយគោរព កោតក្រែង ។ ពាក្យថា ភទ្រាវុធ ជាឈ្មោះ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) ភទ្រាវុធមានអាយុ ពោលដូច្នេះ ។

[៤១១] ពាក្យថា លះបង់សេចក្តីត្រេកអរ ធ្ងង់អន្ទង់ មានព្រះទ័យរួចស្រឡះ អធិប្បាយថា តណ្ហា លោកហៅថា សេចក្តីត្រេកអរ បានដល់រាគៈ រាគៈមានកម្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្តីត្រេកអរ គឺតណ្ហានោះ ព្រះពុទ្ធមានព្រះភាគ លះបង់ផ្តាច់ឫសគល់ ធ្វើមិនឲ្យមានទីកើត ដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព មិនឲ្យកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធទើបឈ្មោះថា លះបង់សេចក្តីត្រេកអរ ។ ពាក្យថា ធ្ងង់អន្ទង់ គឺព្រះមានព្រះភាគ ទ្រង់ធ្ងង់កាមោឃៈ ធ្ងង់ភវោឃៈ ធ្ងង់ទិដ្ឋោឃៈ ធ្ងង់អវិជ្ជោឃៈ ធ្ងង់ធ្ងង់ឡើង ធ្ងង់កាត់ កន្លង ឈានរំលង ផុតរំលង នូវផ្លូវគឺសង្សារទាំងអស់ ព្រះអង្គមានការអប់រំនៅហើយ មានចរណៈប្រព្រឹត្តហើយ ។ បេ ។

ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ នត្ថិ-ញ្ញូហំ ឱយតិណ្ណំ ។ វិមុត្តន្តិ ភគវតោ រាគា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ ទោសា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ មោហា ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តំ កោធា ឧបនាហា ។ បេ ។ សព្វាកុសលាភិសង្ខារេហិ ចិត្តំ មុត្តំ វិមុត្តំ សុវិមុត្តន្តិ នត្ថិញ្ញូហំ ឱយតិណ្ណំ វិមុត្តំ ។

[៤១២] កប្បញ្ជហំ អភិយាចេ សុមេធន្តិ កប្បាតិ ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។ បេ ។ អយំ តណ្ហាកប្បោ ។ បេ ។ អយំ ទិដ្ឋិកប្បោ ។ ពុទ្ធស្ស ភគវតោ តណ្ហាកប្បោ បហីនោ ទិដ្ឋិកប្បោ ។ បដិនិស្សដ្ឋោ តណ្ហាកប្បស្ស បហីនត្តា ទិដ្ឋិកប្ប-ស្ស បដិនិស្សដ្ឋត្តា ពុទ្ធោ កប្បញ្ជហោ ។ អភិយា-ចេតិ យាចាមិ អភិយាចាមិ អជ្ឈេសាមិ សាទិយាមិ បត្ថយាមិ បិហេមិ អភិជប្បាមិ ។ សុមេធន្តិ មេ-ធា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។ បេ ។

ភពថ្មី គឺជាតិ ជរា មរណៈ និងសង្សារ នៃព្រះអង្គ មិនមានឡើយ ហេតុនោះ ទើបឈ្មោះថា ទ្រង់លះបង់សេចក្តីត្រេកអរ ធ្ងង់អន្ទង ។ ពាក្យថា មានព្រះទ័យរួចស្រឡះ គឺព្រះហឫទ័យ របស់ព្រះមានព្រះ-ភាគ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាករាគៈ ព្រះហឫទ័យ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាកទោសៈ ព្រះហឫទ័យ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាកមោហៈ ព្រះហឫទ័យ ផុត រួចស្រឡះ រួចស្រឡះដោយប្រពៃ ចាកកោធៈ ឧបនាហៈ ។ បេ ។ អកុសលាភិសង្ខារ ទាំងអស់ ហេតុនោះ (លោកពោលថា) លះបង់ សេចក្តីត្រេកអរ ធ្ងង់អន្ទង់ មានព្រះហឫទ័យរួចស្រឡះ ។

[៤១២] ពាក្យថា ខ្ញុំព្រះអង្គសូមអារាធនាព្រះមានព្រះភាគ ទ្រង់ លះបង់គ្រឿងកំណត់ មានបញ្ញាល្អ ត្រង់ពាក្យថា គ្រឿងកំណត់ បានដល់ កប្បៈ (គ្រឿងកំណត់) ២ គឺតណ្ហាកប្បៈ ១ ទិដ្ឋិកប្បៈ ១ ។ បេ ។ នេះ តណ្ហាកប្បៈ ។ បេ ។ នេះ ទិដ្ឋិកប្បៈ ។ ព្រះពុទ្ធមានព្រះភាគ លះបង់ តណ្ហាកប្បៈ រលាស់ចោលទិដ្ឋិកប្បៈ ព្រះពុទ្ធ ឈ្មោះថា លះបង់កប្បៈ ព្រោះលះបង់តណ្ហាកប្បៈ ព្រោះរលាស់ចោលទិដ្ឋិកប្បៈ ។ ពាក្យថា សូមអារាធនា គឺ ខ្ញុំព្រះអង្គ សូមអង្វរ អារាធនា និមន្ត ត្រេកអរ ប្រាថ្នា ស្រឡាញ់ ប៉ុនប៉ង ។ ពាក្យថា មានបញ្ញាល្អ សេចក្តីថា ប្រាជ្ញា ហៅថា បញ្ញា បានដល់ ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។

អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា ឥមាយ មេធាយ បញ្ញាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា ពុទ្ធោ សុមេធោតិ កប្បញ្ជហំ អភិយាចេ សុមេធំ ។

[៤១៣] សុត្វាន នាគស្ស អបនមិស្សន្តិ ឥតោតិ នាគស្សាតិ នាគោ ។ ភគវា អាគុំ ន ករោតីតិ នាគោ ។ ន គច្ឆតីតិ នាគោ ។ ន អាគច្ឆតីតិ នាគោ ។ បេ ។ ឯវំ ភគវា ន អាគច្ឆតីតិ នាគោ ។ សុត្វាន នាគស្ស អបនមិស្សន្តិ ឥតោតិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសន្ធឹ សុត្វា សុណិត្វា ឧគ្គហេត្វា ឧបធារយិត្វា ឧបលក្ខយិត្វា ឥតោ អបនមិស្សន្តិ វជិស្សន្តិ ទិសាវិទិសំ គមិស្សន្តីតិ[១] សុត្វាន នាគស្ស អបនមិស្សន្តិ ឥតោ ។ តេនាហ សោ ព្រាហ្មណោ

១ ម. បក្កមិស្សន្តិ ទិសំ គមិស្សន្តីតិ ។

សេចក្តីមិនវង្វេង ការពិនិត្យធម៌ ឃើញត្រូវ ។ ព្រះមានព្រះភាគ ប្រកប ប្រកបព្រម ចូលទៅប្រកប ចូលទៅប្រកបព្រម ចូលដល់ ចូលដល់ព្រម មកដល់ព្រម ដោយបញ្ញាជាគ្រឿងកម្ចាត់នេះឯង ហេតុនោះ ព្រះពុទ្ធ ទើបឈ្មោះថា មានបញ្ញាដ៏ល្អ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គ សូមអារាធនាព្រះអង្គ ទ្រង់លះបង់គ្រឿងកំណត់ មានបញ្ញាល្អ ។

[៤១៣] ពាក្យថា ពួកជនបានស្តាប់ (ព្រះតម្រាស់) របស់ព្រះអង្គ ជាព្រះពុទ្ធនាគហើយ នឹងចៀសចេញអំពីទីនេះ ត្រង់ពាក្យថា នាគ គឺ (ព្រះពុទ្ធ) ទ្រង់ព្រះនាមថា ព្រះនាគ ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាម ថា នាគ ព្រោះមិនធ្វើអំពើអាក្រក់ ។ ទ្រង់ព្រះនាមថា នាគ ព្រោះមិនលុះ (អគតិ) ។ ទ្រង់ព្រះនាមថា នាគ ព្រោះមិនមក ។ បេ ។ ព្រះមាន ព្រះភាគ ព្រះនាមថា នាគ ព្រោះមិនមក យ៉ាងនេះឯង ។ ពាក្យថា ពួកជនស្តាប់(ព្រះតម្រាស់) របស់ព្រះអង្គជាព្រះពុទ្ធនាគហើយ នឹងចៀស ចេញអំពីទីនេះ គឺ ពួកជនស្តាប់ ឮ ក្តួចកាន់ ចាំទុក កំណត់ទុក នូវព្រះតម្រាស់ គន្លងនៃវាចា ទេសនា អនុសន្ធិ របស់ព្រះអង្គហើយ នឹងចៀសចេញ នឹងគេចចេញ អំពីទីនេះ ទៅកាន់ទិសផ្សេង ៗ ហេតុនោះ (លោកពោលថា) ពួកជនស្តាប់ (ព្រះតម្រាស់) របស់ព្រះអង្គ ជាព្រះពុទ្ធនាគហើយ នឹងចៀសចេញអំពីទីនេះ ។ ហេតុនោះ ព្រាហ្មណ៍ នោះ ពោលថា

ឱកញ្ជហំ តណ្ហាច្ឆិទំ អនេជំ
(ឥច្ចាយស្មា ភទ្រាវុធោ)
នន្ទិញ្ជហំ ឱឃតិណ្ណំ វិមុត្តំ
កប្បញ្ជហំ អភិយាចេ សុមេធំ
សុត្វាន នាគស្ស អបនមិស្សន្តិ ឥតោតិ ។

[៤១៤] នានាជនា ជនបទេហិ សង្គតា
តវ វីរ វាក្យំ អភិកង្ខមានា
តេសំ តុវំ សាធុ វិយាករោហិ
តថា ហិ តេ វិទិតោ ឯស ធម្មោ ។

[៤១៥] នានាជនា ជនបទេហិ សង្គតាតិ នានាជនាតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ ជនបទេហិ សង្គតាតិ អង្គា ច មគធា ច កាសិយា ច កោសលា ច វជ្ជិយា ច មល្លា ច ចេតិយម្ហា ច សាគរម្ហា ច បញ្ចាលា ច អវន្តិយា ច យោនា ច កម្ពោជា ច ។ សង្គតាតិ សង្គតា សមាគតា សមោហិតា សន្និបតិតាតិ នានាជនា ជនបទេហិ សង្គតា ។

(កទ្រាវុធមានអាយុ ពោលដូច្នេះថា) ខ្ញុំព្រះអង្គសូមអារាធនា ព្រះមានព្រះភាគ ព្រះអង្គលះលំនៅ កាត់បង់តណ្ហា មិន មានការញាប់ញ័រ លះបង់សេចក្តីត្រេកអរ ឆ្លងអន្លង់ មាន ព្រះហឫទ័យរួចស្រឡះ លះបង់គ្រឿងកំណត់ មានបញ្ញាល្អ ពួកជនបានស្តាប់ (ព្រះតម្រាស់) របស់ព្រះអង្គ ជាព្រះពុទ្ធនាគ ហើយ នឹងចៀសចេញ អំពីទីនេះ ។

[៤១៤] បពិត្រព្រះអង្គជាវីរបុរស ពួកជនផ្សេងៗ ចេញអំពីជនបទទាំងឡាយ មកប្រជុំគ្នា ត្រូវការព្រះតម្រាស់របស់ព្រះអង្គ សូមព្រះអង្គសម្តែងដោះប្រស្នា ដើម្បីជនទាំងនោះ ព្រោះថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ ដោយពិត ។

[៤១៤] អធិប្បាយពាក្យថា ពួកជនផ្សេងៗ ចេញអំពីជនបទទាំងឡាយ មកប្រជុំគ្នា ត្រង់ពាក្យថា ពួកជនផ្សេងៗ បានដល់ ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ។ ពាក្យថា ចេញ អំពីជនបទទាំងឡាយ មកប្រជុំគ្នា គឺចេញអំពីជនបទ ឈ្មោះអង្គៈផង មគធៈផង កាសីផង កោសលៈផង វជ្ជីផង មល្លៈផង ចេតិយៈផង សាគរៈផង បញ្ចាលៈផង អវន្តិផង យោនៈផង កម្ពោជៈផង ។ ពាក្យថា មកប្រជុំគ្នា គឺមកផ្តុំ មកព្រមគ្នា មកស្រុះគ្នា មកជួបជុំគ្នា ហេតុនោះ(លោក ពោលថា) ពួកជនផ្សេងៗ ចេញអំពីជនបទទាំងឡាយ មកប្រជុំគ្នា ។

[៤១៦] តវ វីរ វាក្យំ អភិកង្ខមានាតិ វីរាតិ វីរោ ។ ភគវា វីរិយវាតិ វីរោ ។ បហូតិ វីរោ ។ វិសវីតិ វីរោ ។ អលមត្តោតិ វីរោ ។ បេ ។ វិគតលោមហំសោតិ វីរោ ។

វិរតោ ឥធ សព្វបាបកេហិ
និរយទុក្ខមតិច្ច វីរិយវា សោ
សោ វីរិយវា បធានវា
វីរោ តាទិ បវុច្ចតេ តថត្តាតិ ។

តវ វីរ ។ វាក្យំ អភិកង្ខមានាតិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសន្ធឹ ។ អភិកង្ខមានាតិ កង្ខមានា អភិកង្ខមានា ឥច្ឆមានា សាទិយមានា បត្ថមានា បិហយមានា អភិជប្បមានាតិ តវ វីរ វាក្យំ អភិកង្ខមានា ។

[៤១៧] តេសំ តុវំ សាធុ វិយាករោហីតិ តេសន្តិ តេសំ ខត្តិយានំ ព្រាហ្មណានំ វេស្សានំ សុទ្ទានំ គហដ្ឋានំ បព្វជិតានំ ទេវានំ មនុស្សានំ ។

ភទ្រាវុធមាណវកប្បញ្ហានិទ្ទេស

[៤១៦] ពាក្យថា បពិត្រព្រះអង្គជាវីរបុរស (ពួកជន) ត្រូវការព្រះតម្រាស់របស់ព្រះអង្គ ត្រង់ពាក្យថា បពិត្រព្រះអង្គជាវីរបុរស គឺព្រះពុទ្ធជាវីរបុរស ។ ព្រះមានព្រះភាគ ព្រះនាមថា វីរបុរស ព្រោះទ្រង់មានព្យាយាម ។ ព្រះនាមថា វីរបុរស ព្រោះទ្រង់សម្បូណ៌ដោយគុណ ។ ព្រះនាមថា វីរបុរស ព្រោះទ្រង់ជាអ្នកបណ្តុះសេចក្តីព្យាយាម ។ ព្រះនាមថាវីរបុរស ព្រោះទ្រង់អង់អាច ។ បេ ។ ព្រះនាមថា វីរបុរស ព្រោះទ្រង់ប្រាសចាកការព្រឺរោម ។

បុគ្គលណាវៀរហើយ ចាកបាបទាំងពួង ក្នុងលោកនេះ ជាអ្នក
មានព្យាយាមជាលំនៅ កន្លងនិរយទុក្ខ បុគ្គលនោះ ជាអ្នក
មានព្យាយាម មានសេចក្តីប្រឹងប្រែង មានសភាពដូច្នោះ
លោកហៅថា វីរបុរស ជាបុគ្គលមិនកម្រើក ។

ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គ ជាវីរបុរស... របស់ព្រះអង្គ ។ ពាក្យថា ត្រូវការព្រះតម្រាស់ គឺព្រះតម្រាស់ គន្លងនៃវាចា ទេសនា អនុសន្ធិ របស់ព្រះអង្គ ។ ពាក្យថា ត្រូវការ គឺប៉ុនប៉ង ត្រូវការ ប្រាថ្នា ត្រេកអរ ចង់បាន ស្រឡាញ់ ជាប់ចិត្ត ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាវីរបុរស ពួកជនត្រូវការព្រះតម្រាស់របស់ព្រះអង្គ ។

[៤១៧] ពាក្យថា សូមព្រះអង្គសម្តែងដោះប្រស្នា ដើម្បីជនទាំងនោះ ត្រង់ពាក្យថា ដើម្បីជនទាំងនោះ គឺដើម្បីជនទាំងនោះ បានដល់ក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្ស ។

តុវដ្ដ ភគវន្តំ ភណាតិ ។ សាធុ វិយាករោហីតិ សាធុ អា-
ចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ
ឧត្តានីករោហិ បកាសេហីតិ[១] សាធុ វិយាករោហិ ។

[៤១៨] តថាហិ តេ វិទិតោ ឯស ធម្មោតិ តថាហិ
តេ វិទិតោ ញាតោ តុលិតោ តីរិតោ វិភាវិតោ
វិភូតោ ឯស ធម្មោតិ តថាហិ តេ វិទិតោ ឯស
ធម្មោ ។ តេនាហ សោ ព្រាហ្មណោ

នានាជនា ជនបទេហិ សង្គតា
តវ វីរ វាក្យំ អភិកង្ខមានា
តេសំ តុវំ សាធុ វិយាករោហិ
តថាហិ តេ វិទិតោ ឯស ធម្មោតិ ។

[៤១៩] អាទានតណ្ហំ វិនយេថ សព្វំ (ភទ្រាវុធាតិ ភគវា)
ឧទ្ធំ អធោ តិរិយំ វាបិ មជ្ឈេ
យំ យំ ហិ លោកស្មឹ ឧបាទិយន្តិ
តេនេវ មារោ អន្វេតិ ជន្តុំ ។

[៤២០] អាទានតណ្ហំ វិនយេថ សព្វន្តិ អាទានតណ្ហា
វុច្ចតិ រូបតណ្ហា ។ កឹការណា អាទានតណ្ហា វុច្ចតិ

១ ម. ឯត្ថន្តរេ តេសំ តុវំ សាធុ វិយាករោហីតិ ទិស្សន្តិ ។

ពាក្យថា ព្រះអង្គ គឺកទ្រាវុធនិយាយចំពោះព្រះមានព្រះភាគ ។ ពាក្យថា សូមព្រះអង្គសម្តែង គឺសូមព្រះអង្គប្រាប់ សម្តែង បញ្ញត្ត ផ្តើម បើក ចែក ធ្វើឲ្យរាក់ ប្រកាស ហេតុនោះ (លោកពោលថា) សូមព្រះអង្គសម្តែង ។

[៤១៨] ពាក្យថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ ដោយពិត គឺធម៌នុ៎ះ ព្រះអង្គជ្រាប ដឹង ថ្លឹង ពិចារណា ឈ្វេងយល់ ប្រាកដ ដោយពិត ហេតុនោះ (លោកពោលថា) ធម៌នុ៎ះ ព្រះអង្គជ្រាបហើយដោយពិត ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

បពិត្រព្រះអង្គជាវីរបុរស ពួកជនផ្សេងៗ ចេញអំពីជនបទ
ទាំងឡាយ មកប្រជុំគ្នា ត្រូវការព្រះតម្រាស់របស់ព្រះអង្គ
សូមព្រះអង្គសម្តែង ដោះប្រស្នា ដើម្បីជនទាំងនោះ
ព្រោះថា ធម៌នុ៎ះ ព្រះអង្គជ្រាបហើយ ដោយពិត ។

[៤១៩] (ព្រះមានព្រះភាគត្រាស់ថា ម្នាលកទ្រាវុធ) បុគ្គលគប្បី
កម្ចាត់អាទានតណ្ហា (តណ្ហាជាគ្រឿងប្រកាន់) ទាំងអស់
ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹងគឺកណ្តាល ព្រោះថា
ពួកសត្វប្រកាន់ នូវខន្ធបញ្ចកៈ ណាៗ ក្នុងលោក មារតែង
ជាប់តាម នូវសត្វ ដោយអភិសង្ខារ គឺកម្មនោះឯង ។

[៤២០] ពាក្យថា បុគ្គលត្រូវកម្ចាត់អាទានតណ្ហាទាំងអស់ គឺ រូបតណ្ហា ហៅថា អាទានតណ្ហា ។ ព្រោះហេតុអ្វី រូបតណ្ហា ហៅថា អាទានតណ្ហា ។

រូបតណ្ហា ។ តាយ រូបំ អាទិយន្តិ ឧបាទិយន្តិ គណ្ហន្តិ បរាមសន្តិ អភិនិវិសន្តិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ គតឹ ឧបបត្តឹ បដិសន្ធឹ ភវំ សំសារំ វដ្ដំ អាទិយន្តិ ឧបាទិយន្តិ គណ្ហន្តិ បរាមសន្តិ អភិនិវិសន្តិ តំការណា អាទានតណ្ហា វុច្ចតិ រូបតណ្ហា ។ អាទានតណ្ហំ វិនយេថ សព្វន្តិ សព្វំ អាទានតណ្ហំ វិនយេថ វិនេយ្យ បជហេយ្យ វិនោទេយ្យ អនភាវង្គ-មេយ្យាតិ អាទានតណ្ហំ វិនយេថ សព្វំ ។ ភទ្រាវុធា-តិ ភគវាតិ ភទ្រាវុធាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ភទ្រា-វុធាតិ ភគវា ។

[៤២១] ឧទ្ធំ អធោ តិរិយំ វាបិ មជ្ឈេតិ ឧទ្ធន្តិ វុច្ចតិ អនាគតំ ។ អធោតិ អតីតំ ។ តិរិយំ វាបិ មជ្ឈេតិ បច្ចុប្បន្នំ ។ ឧទ្ធន្តិ កុសលា ធម្មា ។ អធោតិ អកុស-លា ធម្មា ។ តិរិយំ វាបិ មជ្ឈេតិ អព្យាកតា ធម្មា ។ ឧទ្ធន្តិ ទេវលោកោ ។ អធោតិ អបាយលោកោ ។

ពួកសត្វរមែងកាន់ ប្រកាន់ ក្ដួចកាន់ ស្ទាបអង្អែល ជាប់ចំពាក់ ចំពោះរូប ដោយតណ្ហានោះ កាន់ ប្រកាន់ ក្ដួចកាន់ ស្ទាបអង្អែល ជាប់ចំពាក់ចំពោះវេទនា សញ្ញា ពួកសង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សង្សារ វដ្ដៈ ហេតុនោះ រូបតណ្ហា ហៅថា អាទានតណ្ហា ។ ពាក្យថា បុគ្គលត្រូវកម្ចាត់អាទានតណ្ហាទាំងអស់ គឺបុគ្គល ត្រូវកម្ចាត់ បណ្ដេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានបែបភាព នូវអាទានតណ្ហាទាំងអស់ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលត្រូវកម្ចាត់អាទានតណ្ហាទាំងអស់ ។ ពាក្យថា ភទ្រាវុធ របស់បទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលភទ្រាវុធ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះ តាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយគោរព ។ បេ ។ ការបញ្ញតថា មានព្រះភាគ នេះ (កើត) ព្រោះការធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលភទ្រាវុធ ។

[៤២១] ពាក្យថា ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹង គឺកណ្ដាល សេចក្ដីថា អនាគត ហៅថា ខាងលើ ។ អតីត ហៅថា ខាងក្រោម ។ បច្ចុប្បន្ន ហៅថា ទទឹង គឺកណ្ដាល ។ ពួកកុសលធម៌ ហៅថា ខាងលើ ។ ពួកអកុសលធម៌ ហៅថា ខាងក្រោម ។ ពួកអព្យាកតធម៌ ហៅថា ទទឹង គឺកណ្ដាល ។ ទេវលោក ហៅថា ខាងលើ ។ អបាយលោក ហៅថា ខាងក្រោម ។

តិរិយំ វាបិ មជ្ឈេតិ មនុស្សលោកោ ។ ឧទ្ធន្តិ សុខា វេទនា ។ អធោតិ ទុក្ខា វេទនា ។ តិរិយំ វាបិ មជ្ឈេតិ អទុក្ខមសុខា វេទនា ។ ឧទ្ធន្តិ អរូបធាតុ ។ អធោតិ កាមធាតុ ។ តិរិយំ វាបិ មជ្ឈេតិ រូបធាតុ ឧទ្ធន្តិ ឧទ្ធំ ចាទតលា ។ អធោតិ អធោ កេសមត្ថកា ។ តិរិយំ វាបិ មជ្ឈេតិ វេមជ្ឈេតិ ឧទ្ធំ អធោ តិរិយំ វាបិ មជ្ឈេ ។

[៤២២] យំ យំ ហិ លោកស្មឹ ឧបាទិយន្តីតិ យំ យំ ហិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ អាទិយន្តិ ឧបាទិយន្តិ គណ្ហន្តិ បរាមសន្តិ អភិនិវិសន្តិ ។ លោកស្មិន្តិ អបាយលោកេ ។ បេ ។ អាយតនលោកេតិ យំ យំ ហិ លោកស្មឹ ឧបាទិយន្តិ ។

[៤២៣] តេនេវ មារោ អន្វេតិ ជន្តុន្តិ តេនេវ កម្មាភិសង្ខារវសេន បដិសន្ធិកោ ខន្ធមារោ ធាតុមារោ អាយតនមារោ គតិមារោ ឧបបត្តិមារោ បដិសន្ធិមារោ ភវមារោ សំសារមារោ វដ្ដមារោ អន្វេតិ អនុគច្ឆតិ អន្វាយិកោ ហោតិ ។

មនុស្សលោក ហៅថា ទទឹង គឺកណ្តាល ។ សុខវេទនា ហៅថា ខាងលើ ។ ទុក្ខវេទនា ហៅថា ខាងក្រោម ។ អទុក្ខមសុខវេទនា ហៅថា ទទឹង គឺកណ្តាល ។ អរូបធាតុ ហៅថា ខាងលើ ។ កាមធាតុ ហៅថា ខាងក្រោម ។ រូបធាតុ ហៅថា ទទឹង គឺកណ្តាល ។ សរីរៈខាងលើ អំពីបាតជើងឡើងទៅ ហៅថា ខាងលើ ។ សរីរៈខាងក្រោម អំពីចុងសក់ចុះមក ហៅថា ខាងក្រោម ។ សរីរៈ ត្រង់ពាក់កណ្តាល ហៅថា ទទឹង គឺកណ្តាល ហេតុនោះ (ទ្រង់ត្រាស់ថា) ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹងគឺកណ្តាល ។

[៤២២] ពាក្យថា ព្រោះពួកសត្វប្រកាន់នូវខន្ធបញ្ចកៈណាៗ ក្នុងលោក គឺព្រោះពួកសត្វកាន់ ក្តួចកាន់ ប្រកាន់ ស្ទាបអង្អែល ជាប់ចំពាក់ចំពោះរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណាៗ ។ ពាក្យថា ក្នុងលោក គឺក្នុងអបាយលោក ។ បេ ។ ក្នុងអាយតនលោក ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកសត្វប្រកាន់នូវខន្ធបញ្ចកៈណាៗ ក្នុងលោក ។

[៤២៣] ពាក្យថា មារតែងជាប់តាមនូវសត្វ ដោយអភិសង្ខារគឺកម្មនោះឯង បានដល់ មារគឺខន្ធ មារគឺធាតុ មារគឺអាយតនៈ មារគឺគតិ មារគឺឧបបត្តិ មារគឺបដិសន្ធិ មារគឺភព មារគឺសង្សារ មារគឺវដ្តៈ ដែលប្រកបដោយបដិសន្ធិ តែងជាប់តាម ទៅតាម ប្រព្រឹត្តតាម ដោយអំណាច នៃអភិសង្ខារ គឺកម្មនោះឯង ។

៣២៩

## ភទ្រាវុធមាណវកប្បញ្ហានិទ្ទេសោ

ជន្តុន្តិ សត្តំ នរំ មាណវំ បោសំ បុគ្គលំ ជីវំ ជាតុំ[១] ជន្តុំ ឥន្ទគុំ មនុជន្តិ តេនេវ មារោ អន្វេតិ ជន្តុំ ។ តេនាហ ភគវា

អាទានតណ្ហំ វិនយេថ សព្វំ (ភទ្រាវុធាតិ ភគវា)
ឧទ្ធំ អធោ តិរិយំ វាបិ មជ្ឈេ
យំ យំ ហិ លោកស្មឹ ឧបាទិយន្តិ
តេនេវ មារោ អន្វេតិ ជន្តុន្តិ ។

[៤២៤] តស្មា បជានំ ន ឧបាទិយេថ
ភិក្ខុ សតោ កិញ្ចនំ សព្វលោកេ
អាទានសត្តេ ឥតិ បេក្ខមានោ
បជំ ឥមំ មច្ចុធេយ្យេ វិសត្តំ ។

[៤២៥] តស្មា បជានំ ន ឧបាទិយេថាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ឯតំ អាទីនវំ សម្បស្សមានោ អាទានតណ្ហាយាតិ តស្មា ។ បជានន្តិ ជានន្តោ បជានន្តោ អាជានន្តោ វិជានន្តោ បដិវិជានន្តោ បដិវិជ្ឈន្តោ សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។

---
១ ម. ជគុំ ។

ពាក្យថា សត្វ គឺសត្វ នរៈ មាណព បុរស បុគ្គល ជីវៈ សត្វមានជាតិ មានជរា សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) មារតែងជាប់តាមនូវសត្វ ដោយអភិសង្ខារគឺកម្មនោះឯង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលភទ្រាវុធ) បុគ្គលត្រូវកម្ចាត់អាទានតណ្ហាទាំងអស់ ទាំងខាងលើ ទាំងខាងក្រោម ទាំងទទឹង គឺកណ្តាល ព្រោះថា ពួកសត្វប្រកាន់នូវខន្ធបញ្ចកៈណាៗក្នុងលោក មារតែងជាប់តាមសត្វ ដោយអភិសង្ខារគឺកម្មនោះឯង ។

[៤២៨] ព្រោះហេតុដូច្នោះ ភិក្ខុដឹងច្បាស់ នឹករលឹកឃើញ កាលសម្លឹងឃើញ នូវពួកសត្វដែលជាប់ ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ នូវប្រជាជននេះ ដែលជាប់ចំពាក់ក្នុងហេតុជាទីតាំងនៃមច្ចុ ដូច្នេះ មិនគប្បីប្រកាន់នូវខន្ធបញ្ចកៈនីមួយ ក្នុងលោកទាំងពួង ។

[៤២៩] ពាក្យថា ព្រោះហេតុដូច្នោះ... ដឹងច្បាស់... មិនគប្បីប្រកាន់ គឺ ព្រោះហេតុដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ឃើញច្បាស់នូវទោសនុ៎ះ ក្នុងអាទានតណ្ហា ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុដូច្នោះ ។ ពាក្យថា ដឹងច្បាស់ គឺ ដឹង ដឹងច្បាស់ យល់ច្បាស់ ដឹងវិសេស យល់ធ្លុះធ្លាយ ត្រាស់ដឹងថា សង្ខារទាំងឡាយ ទាំងពួង មិនទៀង ។ បេ ។

យត្ថិញ្ចិ សមុទយធម្មំ សព្ពន្តំ និរោធធម្មន្តិ ជានន្តោ បជានន្តោ អាជានន្តោ វិជានន្តោ បដិវិជានន្តោ បដិវិជ្ឈន្តោ ។ ន ឧចាធិយេថាតិ រូបំ ធាធិយេយ្យ ន ឧចាធិយេយ្យ ន គណ្ហេយ្យ ន បរាមសេយ្យ ជាភិនិវិសេយ្យ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ គតឹ ឧបបត្តឹ បដិសន្ធឹ ភវំ សំសារំ វដ្តំ ធាធិយេយ្យ ន ឧចាធិយេយ្យ ន គណ្ហេយ្យ ន បរាមសេយ្យ ជាភិនិវិសេយ្យាតិ តស្មា បជានំ ន ឧចាធិយេថ ។

[៤២៦] ភិក្ខុ សតោ កិញ្ចនំ សព្ពលោកេតិ ភិក្ខូតិ កល្យាណបុថុជ្ជនោ វា ភិក្ខុ សេក្ខោ វា ភិក្ខូតិ ភិក្ខុ ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិប្បដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ វុច្ចតិ សតោតិ ភិក្ខុ សតោ ។ កិញ្ចនន្តិ កិញ្ចិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ ។ សព្ពលោកេតិ សព្ពអបាយលោកេ សព្ពទេវលោកេ សព្ពមនុស្សលោកេ សព្ពក្ខន្ធលោកេ សព្ពអាយតនលោកេ សព្ពធាតុលោកេតិ ភិក្ខុ សតោ កិញ្ចនំ សព្ពលោកេ ។

ដឹង ដឹងច្បាស់ យល់ច្បាស់ ដឹងវិសេស យល់ធ្លុះធ្លាយ ត្រាស់ដឹងថា ធម្មជាតណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ពាក្យថា មិនគប្បីប្រកាន់ គឺមិនត្រូវក្ដួចកាន់ មិនត្រូវកាន់យក មិនត្រូវស្ទាបអង្អែល មិនត្រូវជាប់ចំពាក់ចំពោះរូប មិនត្រូវប្រកាន់ មិនត្រូវក្ដួចកាន់ មិនត្រូវកាន់យក មិនត្រូវស្ទាបអង្អែល មិនត្រូវចំពាក់ ចំពោះវេទនា សញ្ញា ពួកសង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សង្សារ វដ្ដៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រោះហេតុដូច្នោះ ដឹងច្បាស់ មិនគប្បីប្រកាន់ ។

[៤២៦] ពាក្យថា ភិក្ខុនឹករលឹកឃើញនូវខន្ធបញ្ចកៈនីមួយ ក្នុងលោកទាំងពួង ត្រង់ពាក្យថាភិក្ខុ គឺភិក្ខុជាកល្យាណបុថុជ្ជន ឬភិក្ខុជាសេក្ខៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុ ។ ពាក្យថា នឹករលឹកឃើញ គឺនឹករលឹកដោយហេតុ ៤ គឺកំពុងចម្រើន កាយេកាយានុបស្សនាសតិប្បដ្ឋាន ឈ្មោះថានឹករលឹកឃើញ ។ បេ ។ ភិក្ខុនោះលោកហៅថាអ្នករលឹកឃើញ ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនឹករលឹកឃើញ ។ ពាក្យថា ខន្ធបញ្ចកៈនីមួយ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ណានីមួយ ។ ពាក្យថា ក្នុងលោកទាំងពួង គឺក្នុងអបាយលោកទាំងមូល ក្នុងទេវលោកទាំងមូល ក្នុងមនុស្សលោកទាំងមូល ក្នុងខន្ធលោកទាំងមូល ក្នុងអាយតនលោកទាំងមូល ក្នុងធាតុលោកទាំងមូល ហេតុនោះ (ទ្រង់ត្រាស់ថា) ភិក្ខុនឹរលឹកឃើញខន្ធបញ្ចកៈនីមួយ ក្នុងលោកទាំងពួង ។

៣៣១

## ភទ្រាវុធមាណវកប្បញ្ហានិទ្ទេសោ

[៤២៧] អាទានសត្តេ ឥតិ បេក្ខមានោតិ អាទានសត្តា វុច្ចន្តិ យេ រូបំ អាទិយន្តិ ឧបាទិយន្តិ គណ្ហន្តិ បរាមសន្តិ អភិនិវិសន្តិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ គតឹ ឧបបត្តឹ បដិសន្ធឹ ភវំ សំសារំ វដ្ដំ អាទិយន្តិ ឧបាទិយន្តិ គណ្ហន្តិ បរាមសន្តិ អភិនិវិសន្តិ ។ ឥតីតិ បទសន្ធិ ។ បេ ។ បទានុបុព្វតាមេតំ ឥតីតិ ។ បេក្ខមានោតិ ទក្ខមានោ ទិស្សមានោ បស្សមានោ ឱលោកយមានោ និជ្ឈាយមានោ ឧបបរិក្ខមានោតិ អាទានសត្តេ ឥតិ បេក្ខមានោ ។

[៤២៨] បជំ ឥមំ មច្ចុធេយ្យេ វិសត្តន្តិ បជន្តិ សត្តាធិវចនំ ។ មច្ចុធេយ្យេតិ មច្ចុធេយ្យា វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ បជា មច្ចុធេយ្យេ មារធេយ្យេ មរណធេយ្យេ វិសត្តា អាសត្តា លគ្គា លគ្គិតា បលិពុទ្ធា ។

ភទ្រាវុធមាណវកប្បញ្ហានិទ្ទេស

[៤២៧] ពាក្យថា កាលសម្លឹងឃើញនូវពួកសត្វដែលជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ដូច្នេះ គឺពួកសត្វណា កាន់ ក្ដួចកាន់ ប្រកាន់ស្ទាប អង្អែល ជាប់ចំពាក់ ចំពោះរូប កាន់ ក្ដួចកាន់ ប្រកាន់ ស្ទាបអង្អែល ជាប់ចំពាក់ ចំពោះវេទនា សញ្ញា ពួកសង្ខារ វិញ្ញាណ គតិ ឧបបត្តិ បដិសន្ធិ ភព សង្សារ វដ្ដៈ សត្វទាំងនោះ លោកហៅថា អ្នកជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ ។ ពាក្យថា ដូច្នេះ គឺជាពាក្យតបទ ។ បេ ។ ពាក្យថា ដូច្នេះ នុ៎ះ ជាលំដាប់បទ ។ ពាក្យថា កាលសម្លឹងឃើញ គឺកាលឃើញមើលឃើញ យល់ឃើញ រមិលមើល គន់មើល ពិចារណាមើល ហេតុនោះ (ទ្រង់ត្រាស់ថា) កាលសម្លឹងឃើញនូវពួកសត្វដែលជាប់ក្នុងអារម្មណ៍ជាគ្រឿងប្រកាន់ ដូច្នេះ ។

[៤២៨] ពាក្យថា ប្រជាជននេះ ដែលជាប់ចំពាក់ ក្នុងហេតុជាទីតាំងនៃមច្ចុ ត្រង់ពាក្យថា ប្រជាជន គឺជាឈ្មោះ នៃសត្វ ។ ពាក្យថា ហេតុជាទីតាំងនៃមច្ចុ គឺ ពួកកិលេសក្ដី ខន្ធក្ដី អភិសង្ខារក្ដី លោកហៅថា ហេតុជាទីតាំងនៃមច្ចុ ។ ប្រជាជន ជាប់ ជាប់ទួទៅ ជ្ពក់ ទាក់ ជាប់ចំពាក់ ក្នុងហេតុជាទីតាំងនៃមច្ចុ ហេតុជាទីតាំងនៃមារ ហេតុជាទីតាំងនៃមរណៈ ។

យថា ភិត្តិខិលេ វា នាគទន្តេ វា ភណ្ឌំ វិសត្តំ អាសត្តំ លគ្គំ លគ្គិតំ បលិពុទ្ធំ ឯវមេវ បជា មច្ចុធេយ្យេ មារធេយ្យេ មរណធេយ្យេ វិសត្តា អាសត្តា លគ្គា លគ្គិតា បលិពុទ្ធាតិ បជំ ឥមំ មច្ចុធេយ្យេ វិសត្តំ ។ តេនាហ ភគវា

តស្មា បជានំ ន ឧបាទិយេថ
ភិក្ខុ សតោ កិញ្ចនំ សព្វលោកេ
អាទានសត្តេ ឥតិ បេក្ខមានោ
បជំ ឥមំ មច្ចុធេយ្យេ វិសត្តន្តិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ភទ្រាវុធមាណវកប្បញ្ហានិទ្ទេសោ ទ្វាទសមោ ។

---

វត្ថុដែលជាប់ ជាប់ទូទៅ ជ្លក់ ទាក់ ជាប់ចំពាក់ ត្រង់ចម្រឹងជញ្ជាំង ឬដៃ-កែវ យ៉ាងណា ពួកសត្វជាប់ ជាប់ទូទៅ ជ្លក់ ទាក់ ជាប់ចំពាក់ក្នុងហេតុជាទីតាំងនៃមច្ចុ ក្នុងហេតុជាទីតាំងនៃមារ ក្នុងហេតុជាទីតាំងនៃមរណៈ ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ប្រជាជននេះ ដែលជាប់ក្នុងហេតុជាទីតាំងនៃមច្ចុ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រោះហេតុដូច្នោះ ភិក្ខុដឹងច្បាស់ នឹករឭកឃើញ កាល
សម្លឹងឃើញ នូវពួកសត្វដែលជាប់ ក្នុងអារម្មណ៍ជាគ្រឿង
ប្រកាន់ នូវប្រជាជននេះ ដែលជាប់ចំពាក់ ក្នុងហេតុជាទី
តាំងនៃមច្ចុ ដូច្នេះ មិនគប្បីប្រកាន់នូវខន្ធបញ្ចកៈនីមួយ
ក្នុងលោកទាំងពួង ។

ដំណាលគ្នានឹងកាលជាទីចប់នៃគាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គ ជាសាវ័ក ។

ចប់ ភទ្រាវុធមាណវកប្បញ្ហានិទ្ទេស ទី ១២ ។

---

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស  ចូឡនិទ្ទេសោ

# បឋមោ  ភាគោ

---

## មាតិកា                                   អង្កេ


ចូឡនិទ្ទេសេ   វត្ថុគាថា ........................................ ១

*អាវរី  សសិស្សោ* ........................................ "

*អជិតមាណវកប្បញ្ហានិទ្ទេសោ* ........................................ ១១

*និវុយោទយោ  លោកា* ........................................ "

*អវិជ្ជាយ  និវុតោ  លោកោ* ........................................ ១៣

*វេវិច្ឆា  នប្បកាសតិ  លោកា* ........................................ ១៧

*ជប្បា  លោកស្ស  អភិលេបនំ* ........................................ ១៨

*ទុក្ខំ  លោកស្ស  មហព្ភយំ* ........................................ ២០

*តណ្ហាទីនិ  លោកស្មឹ  សោតានិ* ........................................ ២៥

*សតិ  សោតានំ  និវារណំ* ........................................ "

*សោតានិ  បញ្ញាយ  បច្ឆិជ្ជន្តិ* ........................................ ២៦

*បញ្ញាទីនិ  វិញ្ញាណនិរោធេន  និរុជ្ឈន្តិ* ........................................ ៣៣

*អធិសីលសិក្ខា* ........................................ ៣៧

# សុត្តន្តបិដក

# ខុទ្ទកនិកាយស្ស  ចូឡនិទ្ទេស

# បឋមភាគ

---

មាតិកា ទំព័រ


ចូឡនិទ្ទេស  វត្ថុគាថា .......................................... ១

*ពាវរីព្រាហ្មណ៍  ព្រមទាំងសិស្ស* ..................................... "

អជិតមាណវកប្បញ្ហានិទ្ទេស ................... ១១

*លោកមាននរកជាដើម* .................................................... "

*លោកគឺអវិជ្ជាបិទបាំងហើយ* ............................................ ១៣

*លោកមិនភ្លឺស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេងៗ* .................. ១៧

*តណ្ហាជាគ្រឿងជាប់នៃលោក* ........................................... ១៨

*ទុក្ខ  ជាមហាភ័យនៃលោក* ............................................. ២០

*តណ្ហាជាដើម ជាខ្សែក្នុងលោក* ....................................... ២៥

*សតិជាគ្រឿងបិទខ្សែគឺតណ្ហាជាដើម* .............................. "

*ខ្សែ(មានតណ្ហាជាដើម)ដាច់សូន្យដោយបញ្ញា* ................ ២៦

*បញ្ញាជាដើមរលត់ព្រោះរលត់វិញ្ញាណ* ........................... ៣៣

*អធិសីលសិក្ខា* ................................................................. ៣៧

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| **ចូឡនិទ្ទេសេ អជិតមាណវកប្បញ្ហានិទ្ទេសោ** | |
| *អធិចិត្តសិក្ខា* | ៣៧ |
| *អធិប្បញ្ញាសិក្ខា* | ៣៨ |
| *កាមេសុ នាភិគិជ្ឈេយ្យ* | ៤១ |
| *ទ្វេ កាមា* | " |
| *មនសានាវិលោ សិយា* | ៤៣ |
| *សព្វធម្មានំ កុសលោ សិយា* | ៤៤ |
| *សតោ ភិក្ខុ បរិព្វជេ* | ៤៦ |
| **តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេសោ** | ៥០ |
| *កាមេសុ ព្រហ្មចរិយវា ភិក្ខុ* | " |
| *អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ* | " |
| *វីតតណ្ហោ សទា សតោ* | ៥៥ |
| *បតូហិ ការណេហិ សតោ* | ៥៦ |
| *សង្ខាយ និព្វុតោ ភិក្ខុ* | " |
| *អរហតោ ឥញ្ជិតំ នត្ថិ* | ៥៧ |

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ

### ចូឡនិទ្ទេស អជិតមាណវកបញ្ហានិទ្ទេស


*អធិចិត្តសិក្ខា* .................................... ៣៧

*អធិប្បញ្ញាសិក្ខា* .................................... ៣៨

*មិនគប្បីជាប់ចំពាក់ក្នុងកាម* .................................... ៤១

*កាម ២ យ៉ាង* .................................... "

*មិនគប្បីធ្វើចិត្តឲ្យល្អក់* .................................... ៤៣

*គប្បីឈ្លាសវៃក្នុងធម៌ទាំងពួង* .................................... ៤៤

*គប្បីមានសតិជាភិក្ខុប្រព្រឹត្តទៅ* .................................... ៤៦

**តិស្សមេត្តេយ្យមាណវកបញ្ហានិទ្ទេស** .................................... ៥០

*ភិក្ខុមានព្រហ្មចរិយៈក្នុងកាមទាំងឡាយ* .................................... "

*មគ្គមានអង្គ៨ជាព្រហ្មចរិយៈ* .................................... "

*អ្នកប្រាសចាកតណ្ហាមានស្មារតីគ្រប់កាល* .................................... ៥៥

*អ្នកមានស្មារតីដោយហេតុ៤យ៉ាង* .................................... ៥៦

*ភិក្ខុរលត់ទុក្ខព្រោះពិចារណា* .................................... "

*ព្រះអរហន្តមិនមានការញាប់ញ័រ* .................................... ៥៧

# មាតិកាបត្តានិ

## មាតិកា អង្កេ

## ចូឡនិទ្ទេសេ តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេសោ


*ទ្វេ លេបា* ............................................................ ៥៨

*វិមុត្តចិត្តោ មហាបុរិសោ* .......................................... ៦១

*បហីនតណ្ហោ សិព្វិនិមច្ចគា* ...................................... ៦២

បុណ្ណកមាណវកប្បញ្ហានិទ្ទេសោ ៦៤

*តីណិ អកុសលមូលានិ* ............................................ ៦៥

*តីណិ និទានានិ* ...................................................... ៦៥

*ភគវា មូលទស្សាវី* .................................................. ៦៦

*តិស្សោ បុច្ឆា* .......................................................... ៧៣

*អបរាបិ តិស្សោ បុច្ឆា* ............................................. ៧៤

*ជរំ សិតា យញ្ញមកប្បយឹសុ* ........................................ ៨២

*យញ្ញផលទក្ខិណេយ្យជោមនា* ...................................... ៨៩

*ទសហាការេហិ កោធោ ជាយតិ* ................................... ១០១

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

## ចូឡនិទ្ទេស តិស្សមេត្តេយ្យមាណវកប្បញ្ហានិទ្ទេស

គ្រឿងជាប់ ២ យ៉ាង........................................................ ៥៨

អ្នកមានចិត្តផុតស្រឡះ ឈ្មោះថាមហាបុរស.................... ៦១

អ្នកលះតណ្ហា បានកន្ទង់គ្រឿងចាក់ស្រេះ ....................... ៦២

## បុណ្ណកមាណវកប្បញ្ហានិទ្ទេស .. ៦៤

មូលនៃអកុសល ៣ យ៉ាង ........................................... ៦៥

និទាន (ហេតុ) ៣ យ៉ាង............................................ "

ព្រះមានព្រះភាគទ្រង់ឃើញនូវមូល ................................ ៦៦

ការសួរ ៣ យ៉ាង ......................................................... ៧៣

ការសួរ ៣ យ៉ាងដទៃទៀត........................................... ៧៤

អាស្រ័យជរា ទើបបានតាក់តែងយញ្ញ............................ ៨២

ការសរសើរផលយញ្ញនិងទក្ខិណេយ្យបុគ្គល.................... ៨៩

គ្រោធកើតដោយអាការៈ ១០ យ៉ាង ................................ ១០១

## មាតិកាបត្ថាធិ


មាតិកា អង្កេ

ចូឡធិទ្ទេសេ មេត្តគូមាណវកបញ្ញាធិទ្ទេសោ ១០៦

*តិស្សោ បុច្ឆា* .................................................. "

*អបរាបិ តិស្សោ បុច្ឆា* ..........................................១០៧

*ភគវា វេទគូ* ..................................................... ១១០

*ចតូសុ មគ្គេសុ ញាណំ វេទោ* .................................. "

*ភគវា ភាវិតកាយោ* ...............................................១១២

*ភគវា សុវិមុត្តចិត្តោ* ..............................................១១៦

*ជាតិទុក្ខាទីនិ* .....................................................១១៩

*ឧបធិនិទានា បភវន្តិ ទុក្ខា* ......................................១២៥

*ទស ឧបធី* ........................................................ "

*អវិទ្វា ឧបធឹ ករោតិ* ...............................................១២៧

*បុនប្បុនំ ទុក្ខមុបេតិ មន្ទោ* ........................................ "

*ឧបធឹ ន កយិរា* .....................................................១២៨

*តីណិ មោនេយ្យានិ* ................................................១៣៤

*វិសត្តិកា តណ្ហា* ...................................................១៤១

# សន្លឹកប្រាប់មាតិកា


មាតិកា ទំព័រ

## ចូឡនិទ្ទេស មេត្តគូមាណវកប្បញ្ហានិទ្ទេស .. ១០៦

*ការសួរ ៣ យ៉ាង* ................................................. "

*ការសួរ ៣ យ៉ាងដទៃទៀត* ........................................ ១០៧

*ព្រះមានព្រះភាគទ្រង់ដល់នូវវេទ* ................................ ១១០

*ញាណក្នុងមគ្គ ៤ ហៅថាវេទ* ..................................... "

*ព្រះមានព្រះភាគមានកាយចម្រើនហើយ* ............................ ១១២

*ព្រះមានព្រះភាគមានព្រះទ័យផុតស្រឡះ* ......................... ១១៦

*ទុក្ខមានជាតិទុក្ខជាដើម* ........................................ ១១៩

*ទុក្ខកើតព្រោះឧបធិជាហេតុ* ..................................... ១២៥

*ឧបធិ ១០ យ៉ាង* ................................................ "

*ជនមិនដឹង រមែងសាងឧបធិ* ..................................... ១២៧

*ជនល្ងង់ រមែងចូលទៅកាន់ទុក្ខរឿយៗ* ........................... "

*មិនគប្បីសាងឧបធិ* ............................................. ១២៨

*មោនេយ្យៈ ៣ យ៉ាង* ............................................ ១៣៤

*តណ្ហា ជាវិសត្តិកា (ផ្សាយទៅ)* ................................ ១៤១

# មាតិកាបត្ថានិ

## មាតិកា អង្កេ

## ចូឡនិទ្ទេសេ មេត្តគូមាណវកប្បញ្ហានិទ្ទេសោ


តណ្ហា អកុសលមូលំ ........................ ១៤១
កេនត្ថេន មហេសី ........................ ១៤៣
ទ្វេ និវេសនា ........................ ១៤៩
ទ្វេ ភវា ........................ "
ទ្វេ មមត្តា ........................ ១៥៣
បជហេយ្យ ទុក្ខំ ........................ ១៥៥
អាគូ អកុសលា ធម្មា ........................ ១៦០
កេនត្ថេន នាគោ ........................ "
កេនត្ថេន ព្រាហ្មណោ ........................ ១៦៣
រាគាទីនិ កិញ្ចនានិ ........................ ១៦៤
បារំ អមតំ និព្វានំ ........................ ១៦៨
រាគាទយោ ខិលា ........................ "
ទុក្ខេ កង្ខាទិកា ........................ ១៦៩
សត្ត សង្គា ........................ ១៧១
តណ្ហា អាសា ........................ ១៧៣

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ

## ចូឡនិទ្ទេស មេត្តគូមាណវកប្បញ្ហានិទ្ទេស


*តណ្ហា ជាអកុសលមូល* ................................................ ១៤១

*ព្រះនាមថា ព្រះមហេសី ដោយអត្ថដូចម្តេច* ...............១៤៣

*ការប្រកាន់ ២ យ៉ាង* .................................................. ១៤៩

*ភព ២ យ៉ាង* .............................................................. "

*សេចក្តីប្រកាន់ ២ យ៉ាង* ..............................................១៥៣

*គប្បីលះទុក្ខ* ............................................................. ១៥៥

*អកុសលធម៌ ឈ្មោះថាអាគូ (អំពើអាក្រក់)* .................. ១៦០

*ព្រះនាមថានាគៈដោយអត្ថដូចម្តេច* ................................ "

*ឈ្មោះថាព្រាហ្មណ៍ដោយអត្ថដូចម្តេច* ............................១៦៣

*គ្រឿងកង្វល់មានរាគៈជាដើម* .......................................... ១៦៤

*អមតនិព្វាន ឈ្មោះថាត្រើយ* ......................................... ១៦៨

*កិលេសមានរាគៈជាដើមឈ្មោះខិលៈ* ............................. "

*ការសង្ស័យក្នុងទុក្ខជាដើម* ............................................. ១៦៩

*កិលេសជាគ្រឿងជាប់*.....................................................១៧១

*តណ្ហា ឈ្មោះថាអាសា* .................................................. ១៧៣

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| ចូឡនិទ្ទេសេ ជោតកមាណវកប្បញ្ហានិទ្ទេសោ | ១៧៤ |
| *តិស្សោ បុច្ឆា* | " |
| *តិស្សោ សិក្ខា* | *១៧៧* |
| *សិក្ខេ និព្វានមត្តនោ* | *១៨០* |
| *តយោ ទេវា* | *១៨២* |
| *កេនត្តេន សក្កោ* | *១៨៥* |
| *សទ្ធាធនាទីនិ* | " |
| *កថង្កថា វិចិកិច្ឆា* | *១៨៦* |
| *វិវេកធម្មោ អមតំ និព្វានំ* | *១៩២* |
| *ទ្វេ និស្សយា* | *១៩៤* |
| *តរេ លោកេ វិសត្តិកំ* | *២០១* |
| ឧបសីវមាណវកប្បញ្ហានិទ្ទេសោ | ២០៦ |
| *ទ្វេ កាមា* | *២១២* |
| *កិលេសាទយោ វាទបថា* | *២៣០* |

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

ចូឡនិទ្ទេស ធោតកមាណវកប្បញ្ហានិទ្ទេស .....១៧៥

*ការសួរ ៣ យ៉ាង* ........................................................ "

*សិក្ខា ៣ យ៉ាង* ........................................................១៧៧

*គប្បីសិក្សានូវនិព្វាននៃខ្លួន* .......................................... ១៨០

*ទេវតា ៣ យ៉ាង* ........................................................១៨២

*ព្រះនាមថាសក្កៈដោយហេតុដូចម្តេច* .............................. ១៨៥

*ទ្រព្យគឺសទ្ធាជាដើម* ........................................................ "

*សេចក្តីសង្ស័យ ឈ្មោះថាកថង្កថា* ................................ ១៨៦

*អមតនិព្វានជាវិវេកធម៌* .................................................... ១៩២

*និស្ស័យ ២ យ៉ាង* ........................................................ ១៩៤

*គប្បីឆ្លងតណ្ហាជាវិសត្តិកា* ................................................ ២០១

ឧបសីវមាណវកប្បញ្ហានិទ្ទេស ២០៦

*កាម ២ យ៉ាង* ............................................................. ២១២

*កិលេសជាដើម ឈ្មោះថាវាទបថ* ...................................២៣០

# មាតិកាបត្ថានិ


| មាតិកា | អង្កេ |
|---|---|
| ចូឡនិទ្ទេសេ ជតុកណ្ណិមាណវកបញ្ហានិទ្ទេសោ | ២៣២ |
| ខត្តិយាទយោ | " |
| ខន្ធកុសលាទយោ | ២៣៥ |
| កាយទុច្ចរិតាទិកា មារសេនា | ២៣៦ |
| រូបតណ្ហាទយោ | ២៥៤ |
| តិស្សោ បរិញ្ញា | " |
| បត្តាពោ អាសវា | ២៥៦ |
| កិលេសាទយោ ឧបធី | ២៥៨ |
| ហេមកមាណវកបញ្ហានិទ្ទេសោ | ២៦៣ |
| កិញ្ចិ លោកេ បិយរូបំ សាតរូបំ | ២៦៩ |
| ឆន្ទរាគវិនោទនំ | ២៧១ |
| តោទេយ្យមាណវកបញ្ហានិទ្ទេសោ | ២៧៦ |
| ទ្វេ កាមា | ២៧៨ |
| សទ្ធាធនាទីនិ | ២៨១ |
| សមន្តចក្ខុ ភគវា | ២៨២ |
| រាគាទីនិ កិញ្ចនានិ | ២៨៥ |

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ


ចូឡនិទ្ទេស នន្ទមាណវកប្បញ្ហានិទ្ទេស ២៣២

*ជនមានក្សត្រជាដើម.......................................................... "*

*អ្នកឈ្មោសក្នុងខន្ធជាដើម...................................................២៣៥*

*មារសេនាមានកាយទុច្ចរិតជាដើម.........................................២៣៦*

*រូបតណ្ហាជាដើម..............................................................២៥៤*

*បរិញ្ញា ៣ យ៉ាង.............................................................. "*

*អាសវៈ ៤ យ៉ាង...............................................................២៥៦*

*កិលេសជាដើម ឈ្មោះថាឧបធិ............................................២៥៨*

ហេមកមាណវកប្បញ្ហានិទ្ទេស ២៦៣

*អ្វីជាបិយរូប សាតរូប ក្នុងលោក.........................................២៦៩*

*ការបន្ទោបង់នូវឆន្ទរាគ.....................................................២៧១*

តោទេយ្យមាណវកប្បញ្ហានិទ្ទេស ២៧៦

*កាម ២ យ៉ាង...................................................................២៧៨*

*ទ្រព្យគឺសទ្ធាជាដើម..........................................................២៨១*

*ព្រះមានព្រះភាគមានចក្ខុជុំវិញ...........................................២៨២*

*គ្រឿងកង្វល់មានរាគៈជាដើម..............................................២៨៥*

# មាតិកាបត្តានិ

| មាតិកា | អង្កេ |
| --- | --- |

ចូឡនិទ្ទេសេ កប្បមាណវកប្បញ្ហានិទ្ទេសោ ២៨៧

*សំសារោ សរោ*............................................................ "

*សំសារស្ស បុរិមា កោដិ ន បញ្ញាយតិ*...................... "

*សំសារស្ស បច្ឆិមា កោដិ ន បញ្ញាយតិ*.....................២៩១

*តណ្ហា អាទានំ*..............................................................២៩៨

ចតុកណ្ណីមាណវកប្បញ្ហានិទ្ទេសោ ៣០៣

*ទ្វេ កាមា*.......................................................................៣០៤

*ធម្មា សន្តិបទា*.............................................................៣០៦

*ភគវា ញាណតេជី*........................................................៣០៩

*រាគកិញ្ចនាទីនិ*...........................................................៣១៥

*តណ្ហា គេធោ*................................................................ ៣១៧

*បត្តាពោ អាសវា* .......................................................... "

# សន្លឹកប្រាប់មាតិកា


មាតិកា ទំព័រ

## ចូឡនិទ្ទេស កប្បមាណវកប្បញ្ហានិទ្ទេស ២៨៧

*សង្ខារ ឈ្មោះថាស្រះ* ................................................ "

*ទីបំផុតខាងដើមនៃសង្ខារមិនប្រាកដ* ............................ "

*ទីបំផុតខាងចុងនៃសង្ខារមិនប្រាកដ* ..............................២៩១

*តណ្ហាជាអាទាន:(គ្រឿងប្រកាន់មាំ)*...............................២៩៨

## ចតុកណ្ណីមាណវកប្បញ្ហានិទ្ទេស ៣០៣

*កាម ២ យ៉ាង*...........................................................៣០៤

*ធម៌ ជាសន្តិបទ*..........................................................៣០៦

*ព្រះមានព្រះភាគមានតេជ:គឺញាណ* ............................៣០៩

*គ្រឿងកង្វល់គឺរាគ:ជាដើម*.............................................៣១៥

*តណ្ហា ជាគេធ: (គ្រឿងតម្រេក)*.................................... ៣១៧

*អាសវ: ៤*....................................................................... "

# មាតិកាបត្ថានំ

## មាតិកា អង្កេ

ចូឡនិទ្ទេសេ ភទ្រាវុធមាណវកបញ្ហានិទ្ទេសោ ៣១៩

ពុទ្ធោ ឱកញ្ជហោ .......................................................... "

រូបតណ្ហាទិកា តណ្ហា................................................... ៣២០

ពុទ្ធោ តណ្ហច្ឆិទោ .......................................................... "

ពុទ្ធោ អនេជោ................................................................. "

ទ្វេ កប្បា ..................................................................... ៣២២

ពុទ្ធោ កប្បញ្ជហោ.......................................................... "

ខន្ធមារាទយោ ................................................................ ៣២៨

---

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| ចូឡនិទ្ទេស ភទ្រាវុធមាណវកប្បញ្ហានិទ្ទេស | ៣១៩ |
| ព្រះពុទ្ធទ្រង់លះបង់ទីលំនៅ........................................ | " |
| តណ្ហាមានរូបតណ្ហាជាដើម .......................................... | ៣២០ |
| ព្រះពុទ្ធទ្រង់កាត់បង់តណ្ហា .......................................... | " |
| ព្រះពុទ្ធទ្រង់មិនញាប់ញ័រ............................................. | " |
| គ្រឿងកំណត់ ២ យ៉ាង ............................................. | ៣២២ |
| ព្រះពុទ្ធទ្រង់លះបង់កប្បៈ(គ្រឿងកំណត់) ...................... | " |
| មារគឺខន្ធជាដើម.......................................................... | ៣២៨ |

## រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

## គណៈកម្មការពុទ្ធិកវប្បធម៌អត្ថការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះត្រៃបិដកបាលី និងសេចក្តីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក

សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្តីសុខសួស្តី

សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា

សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព ។

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៩២៩, (៨៥៥) ៨៨៧ ៩៦១ ៩២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

*“Wherever the Buddha’s teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share.”*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

## Taking Refuge with a mind of Bodhichitta

**In the Buddha, the Dharma and the Sangha,**
**I shall always take refuge**
**Until the attainment of full awakening.**

**Through the merit of practicing generosity**
**and other perfections,**
**May I swiftly accomplish Buddhahood,**
**And benefit of all sentient beings.**

## The Prayers of the Bodhisattvas

**With a wish to awaken all beings,**
**I shall always go for refuge**
**To the Buddha, Dharma, and Sangha,**
**Until I attain full enlightenment.**

**Possessing compassion and wisdom,**
**Today, in the Buddha's presence,**
**I sincerely generate**
**the supreme mind of Bodhichitta**
**For the benefit of all sentient beings.**

"As long as space endures,
As long as sentient beings dwell,
Until then, may I too remain
To dispel the miseries of all sentient beings."

# GREAT VOW
## BODHISATTVA EARTH-TREASURY
## ( BODHISATTVA KSITIGARBHA )

**" Unless Hells become empty,
I vow not to attain Buddhahood;
Till all have achieved the Ultimate Liberation,
I shall then consider my Enlightenment full !"**

**Bodhisattva Earth-Treasury is
entrusted as the Caretaker of the World until
Buddha Maitreya reincarnates on Earth
in 5.7 billion years.**

Reciting the Holy Name:
**NAMO BODHISATTVA KSITIGARBHA**

Karma-erasing Mantra:
**OM BA LA MO LING TO NING SVAHA**

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**

# NAME OF SPONSOR
# 助印功德芳名

**Book's Title: KHMER PALI TRIPITAKA VOL.57 ~ VOL.70 (SUTTANTA PITAKA)**

**書 名：柬埔寨巴利文大藏經 第五十七冊至第七十冊 （經藏）**

**Book Serial No., 書 號：CA157 ~ CA170**

N.T. Dollars：

**1,209,840**：〔釋心庭、蔡耀裕、葉明炤、葉王桂花、賴錦瑩、黃怡禎、黃智美、黃寶嬌、黃彩嬉、黃世熙、黃婕寧、黃婕米、黃婕棋、徐淑美、林燦東、邱彩華、林裕翔、林宜蒨、林若妤、陳健明、陳俊廷、陳俊弘、蔡文裕、蔡欣洲、蔡慶雲、黃張緣、丁全福。〕

（迴向正法久住，所有成佛功德法，悉以迴向諸群生，願令一切皆清淨，到佛莊嚴之彼岸。）

**1,315,974**： 佛陀教育基金會。

**Amount:** N.T. Dollars **2,525,814；Print 2,000 sets**

**以上合計：新台幣 2,525,814 元；恭印二千套。**

**Dedication of Merits:**

Wherever the Buddha's teachings have flourished, either in cities or countrysides,
People would gain inconceivable benefits.
The land and people would be enveloped in peace.
The sun and moon will shine clear and bright.
Wind and rain would appear accordingly, and there will be no disasters.
Nations would be prosperous and there would be no use for soldiers or weapons.
People would abide by morality and accord with laws.
They would be courteous and humble, and everyone would be content without injustices.
There would be no thefts or violence.
The strong would not dominate the weak and everyone would get their fair share.

**回向：**天下和順，日月清明，風雨以時，災厲不起，國豐民安，兵戈無用，崇德興仁，務修禮讓，國無盜賊，無有怨枉，強不凌弱，各得其所。法界一切有情，所有六道四生，宿世冤親，現世業債，咸憑法力，悉得解脫。現世者增福延壽，發菩提心，常隨佛學，勤修精進，利濟群生。已故者往生淨土，同出苦輪，共登覺岸，直證阿鞞跋致，圓滿無上菩提。

**附記：**本會接受善信發心印贈經書，其必要之費用，皆經本會審慎評估；若有結餘，均續作本會之印(購)經書及運費使用，為施主廣積陰德。

# DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.
May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.

Homage to Amita Buddha!

**NAMO AMITABHA**

**南無阿彌陀佛**

《東埔寨巴利文大藏經 第六十七冊（經藏）》
〈KHMER PALI TRIPITAKA VOL.67 (SUTTANTA PITAKA)〉
財團法人佛陀教育基金會 印贈
台北市杭州南路一段五十五號十一樓
Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website: http://www.budaedu.org
Mobile Web: m.budaedu.org

**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

Printed in Taiwan
2,000 copies; July 2015
CA167 - 13308